# រឿងរ៉ាវដែលទាក់ទង

# នឹង

# ពុទ្ធស្ថាន

# ភាគទី ៥

ដកស្រង់ឯកសារដោយ

ខ្ញុំព្រះករុណា

អាត្មាភាព **យង់ សុផាត**

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# រឿងរ៉ាវដែលទាក់ទង

# នឹង

# ពុទ្ធស្ថាន

# ភាគទី ៥

ដកស្រង់ឯកសារដោយ

ខ្ញុំព្រះករុណា

អាត្មាភាព **យង់ សុផាត**

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៥

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា

**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**<u>កម្មវត្ថុ</u>** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**<u>យោង</u>** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***<u>ចម្លងជូន</u>*** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " <u>ដើម្បីជូនជ្រាប</u> "
- សាលាខេត្តបាត់ដំបង
  " <u>ដើម្បីមុខការ</u> "
- ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

សៀវភៅ **រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន** ភាគ ៥ នេះជាភាគបញ្ចប់ ( ដែលដាក់ឈ្មោះយ៉ាងនេះ ពីព្រោះក្នុងសៀវភៅនេះ មានរឿងរ៉ាវទាក់ទងចំពោះពុទ្ធស្ថាន នាសម័យពុទ្ធកាលតែប៉ុណ្ណោះ ) កើតឡើងក្នុងដំណើរទៅថ្វាយបង្គំពុទ្ធស្ថាននានា **នៅប្រទេសឥណ្ឌា** និង **ប្រទេសនេប៉ាល់** លើកទី ៤ ក្នុង **ព.ស. ២៥៥៤ គ.ស. ២០១១** ដែលមានពុទ្ធបរិស័ទទៅប្រមាណ **២៧៧** នាក់ ក្នុងនោះ មានព្រះសង្ឃចំនួន **៤០ អង្គផងដែរ** ទៅរយៈពេលជិត **១ ខែ** អាស្រ័យហេតុដូច្នេះ ទើបបានជាខ្ញុំផ្តើមរៀបចំសៀវភៅនេះឡើង ក្នុងគោលបំណង ដូចខាងក្រោមនេះ គឺ

១- ប្រមូលរឿងរ៉ាវសំខាន់ៗ ដែលទាក់ទងនឹងពុទ្ធស្ថាន ដែលព្រះសង្ឃ និងពុទ្ធបរិស័ទទៅថ្វាយបង្គំ ឲ្យបានដឹងជាមុន ពេលដែលទៅដល់ពុទ្ធស្ថាននោះ ក៏ដូចជាការញ៉ាំងបុព្វចេតនាឲ្យកើតឡើងផងដែរ ។

២- ដើម្បីងាយស្រួលសម្រាប់ព្រះសង្ឃ និងពុទ្ធបរិស័ទ បាន

ឱកាសសម្តែងព្រះធម៌តាមឡានទីមួយៗ ដើម្បីបានជាពុទ្ធានុស្សតិផង ។

៣-ចង់ប្រកាសព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធ និងអរិយសាវក ដែលមានរឿងរ៉ាវកើតឡើង ចំពោះស្ថានទីដែលទៅថ្វាយបង្គំ ។

៤- ចង់ឲ្យព្រះសង្ឃ និងពុទ្ធបរិស័ទ ដែលមិនធ្លាប់បានទៅកាន់ពុទ្ធស្ថាន ឬកំពុងតែធ្វើដំណើរទៅកាន់ពុទ្ធស្ថាននោះ ឲ្យបានជ្រាបចំពោះពុទ្ធស្ថានទីមួយៗ មានប៉ុន្មានកន្លែង ដែលយើងត្រូវថ្វាយបង្គំ ។

៥- ដើម្បីបុណ្យកុសល ក្នុងការប្រមូលរឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថានទីមួយៗ ផង ដើម្បីងាយស្រួលដល់គណាធម្មយាត្រាផង ដើម្បីបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេសផង ។

អាស្រ័យហេតុដូចរៀបរាប់ខាងលើនេះហើយ បានជាខ្ញុំខំស្រាវជ្រាវឯកសារនៅក្នុង **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** និង **សៀវភៅជំនួយ-សតិភាគទី ១៤** ដែលរៀបរៀងដោយលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ធ្វើជាគោលក្នុងការរៀបចំសៀវភៅរឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាននៅ **ប្រទេសឥណ្ឌា** និង **ប្រទេសនេប៉ាល់** ឡើង ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើរជាងអត់ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមានខុសមិនខាន ជួនដោយចេះមិនដល់ ជួនដោយការភ្លេចភ្លាំង ជាពិសេសនោះគឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិតជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

**សូមអស់មិត្តអ្នកអាន** បានទទួលនូវការចេះដឹង ជាកេរ្តិ៍មរតកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់ព្រះនិព្វាន ដែលជាបរិយោសាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា

អាត្មាភាព បានសម្ដែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០ ព្រះអង្គផងដែរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ **ថ្វាយបង្គំបាន ៥១ កន្លែង** បានការឧបត្ថម្ភអំពីឧបាសក **ឡាយ សុខុម** និងឧបាសិកា **ឱម លក្ខណា** នៅក្នុង **ព.ស. ២៥៥០** ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្ដា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្ដា

ង

ជ្រះថ្លាក្រៃលែង ។

៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង

នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក

ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរចាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល) និង ប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសកឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិប ចណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

ប

# និកឃើញលង្កា

នឹកឃើញលង្កា នឹកឃើញកាលណា ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន ១៩ កន្លែង ដែលខ្ញុំបានស្វែង
ទៅថ្វាយបង្គំ ។
១២១ អង្គា គាល់ព្រះបាទា នាស្ថានមនោរម
លើសុមនកូដ ជេស្ដាឧត្ដម ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។
ទឹកដីលង្កា ទឹកដីអស្ចារ្យ ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត ធម្មយាត្រាប្រណីត
ក្នុង ព.ស.២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. **២៥៥២** ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស. **២៥៥១** ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល (២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅ

ពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គផងដែរ** បានការឧបត្ថម្ភមកអំពីឧបាសក **យឹត សុវណ្ណាត** ឧបាសិកា **ហ៊ុន ម៉ារ៉ានី** M. SU SOKUNORA et MmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ឹង វិទ្ធារី** ឧបាសិកា **ស្ងួន តល្យាណ** ឧបាសិកា **ស្ងួន ចរណៃ** នៅក្នុង **ព.ស. ២៥៥២** ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គ រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

*នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង* **ប្រទេសស្រីលង្កាជាលើកទីពីរ** *ដែលមានលោកគ្រូធម្មបណ្ឌិត* **រស់ សុផាត** *ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **៣៦ នាក់** *នៅក្នុងនោះទៀត ក៏មាន* **ព្រះសង្ឃ ៣ ព្រះអង្គផងដែរ** *បានការឧបត្ថម្ភមកអំពីឧបាសក* **ឆាយ អ៊ីចស៊ាង** *ឧបាសិកា* **ហុង គឹមសែ** *ក្រោមការជ្រោមជ្រែងរបស់ឧបាសក* **យន្ត សួន** *នៅក្នុង* **ព.ស. ២៥៥២** *( ១១.០៣.២០០៩ ) ។*

*នៅមានបុណ្យកុសលនៅក្នុង* **ព.ស. ២៥៥៣** *ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង* **ព.ស. ២៥៥២** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល** *(* **១៣ លាន ០ សែន ៨ ម៉ឺន** *)* **និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង*

**ប្រទេសឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

## ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងែងអស្ចារ្យ
ឱះ ឱ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៤** ផ្នែកខាងសម្តែង

ព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

## គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាំង
ប្រៀបបានព្រៃស្ងាត់ ។

២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់

បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ជម្ទយាត្រាកំណត់

ក្នុងពុទ្ធសករាជ ២៥៥៤ ។

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិស មហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យន់ ស្វេង** ( ស្លាប់ ) និងញោមស្រី **ឈឹម ហយ** ( ស្លាប់ ) មយ៉ាងទៀត ញាតិកានៅក្នុង សង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូន ចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីខ** ជាដើម សូមឲ្យបាននូវ ចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!**

ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសល នៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

*ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណានីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុប្បដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីទ្រង់ត្រាស់ថា* **នត្ថិ សន្តិ បរំ សុខំ** *ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។*

*អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៥*

**ដោយប្រធានសមាគមធម្មទានអរិយវង្សយំសុធាត**

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាល្វន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គីម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ម៉ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន ចន្ធនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ៃយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការងារធម្មទាន

ឧបាសក សន ឈៀត ជួយប្រែ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ម្ល ស៊ីផ្ល ជួយពិនិត្យអក្ខរាវិរុទ្ធ

លោកគ្រូធម្មាចារ្យ គាំ អ៊ីច ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រឹម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

៧

# សមាជិកសមាគមធម្មទានអរិយវង្សយង់សុផាត

សម្ដេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ង៉ែត** ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ **យង់ សុផាត** ជាប្រធានសមាគម

លោកអភិបាលស្រុក **ស្រេង ស្រ៊ាង** ជាទីប្រឹក្សាសមាគម

ឧបាសក **អ៊ឹម អ៉ៃយ៉ា** ជាអនុប្រធានសមាគម

ឧបាសិកា **ង៉ែត យូអេង** ជាអនុប្រធានសមាគម

សាមណេរ **ម៉ី សាល្លួន** ជាលេខាធិការ

ឧបាសក **ឡាន សុខុម** ជាលេខាធិការរង

ឧបាសិកា **តាំង ម៉ោងជីង** ជាហេរញ្ញិក

ឧបាសិកា **ជា នាង** ជាបេឡា

លោកគ្រូធម្មបណ្ឌិត **អឿ សៅ** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក **ឡាយ សុខុម** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **អ៊ឹង រិទ្ធារី** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ហោ គាព** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **គួ ម៉ីនគាង** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ឃុំ សុធា** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ម៉ែន រម្មណីយ៍ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឌិម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឌុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីដា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីចន្ទ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង គន្ធា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ហេង សុភ័ក្ត្រ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា តែង តល្យណា ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហ៊ុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហ៊ុង សុវណ្ណារ៉ែត ជាសមាជិកសកម្ម

# មាតិការឿង

ល.រ ទំព័រ

## ១២–ទីក្រុងសាវត្ថី


-ទីក្រុងសាវត្ថី ........................................................ ១

-កន្លែងសម្ដែងយមកប្បាដិហារ្យ .................................. ៥

-វត្តបុព្វារាម........................................................ ៩៨

-ផ្ទះលោកសេដ្ឋីអនាថបិណ្ឌិក ...................................... ២៥០

-ទីវត្តរាជិការាម ........................................................ ៥៧៧

-វត្តជេតពន ........................................................ ២៦២

-អានន្ទពោធិ៍ ........................................................ ៣៦២

-ទីដែនដីស្រូបភិក្ខុទេវទត្ត ............................................ ៥៦២

-ទីដែនដីស្រូបនន្ទមាណព ............................................ ៤០០

-ទីដែនដីស្រូបនាងចិញ្ចា ............................................ ៥៥២

-ស្ទឹងអចិរវតី ........................................................ ៥០៥

-ប្រវត្តិរបស់ឧបាសិកាវិសាខា ...................................... ៤២

-ប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ................................... ២៥០

-ជាស្រុកកំណើតរបស់ព្រះឧប្បលវណ្ណាថេរី .................. ៣៩៣

-ជាស្រុកកំណើតរបស់ព្រះបដាចារាថេរី ......................... ៤៧០

-រឿងវិឌូឌភៈ ............................................................... ៥០៥

-រឿងនាងចិញ្ចមាណវិកា ................................................ ៥៥២

-រឿងភិក្ខុទេវទត្ត ......................................................... ៥៦២

-ជាស្រុកកំណើតរបស់ព្រះនន្ទកត្ថេរ ............................... ៥៨៥

-ជាស្រុកកំណើតរបស់ព្រះនាងសោណាថេរី .................. ៦១៧

-ជាស្រុកកំណើតរបស់ព្រះនាងសកុលាថេរី .................... ៦៣៤

-ជាស្រុកកំណើតរបស់ព្រះនាងកិសាគោតមីថេរី ............. ៦៤៨

## ១៣–សញ្ជី

-សញ្ជី ............................................................................ ៦៨០

-ជាស្រុកកំណើតរបស់ព្រះមហាកច្ចាយនត្ថេរ ................ ៦៨១

-ជាស្រុកកំណើតរបស់ព្រះនាងវេទេសទេវី .....................

-ជាស្រុកកំណើតព្រះមហិន្ទត្ថេរ និងព្រះនាងសង្ឃមិត្តា ....

-កន្លែងតម្កល់ព្រះអដ្ឋិធាតុព្រះសារីបុត្រ+ព្រះមហាមោគ្គល្លាន

-កន្លែងតម្កល់ព្រះអដ្ឋិធាតុព្រះអរហន្ត ១០ អង្គ ................

## ១៨-ភ្នំហិមពាន្ត

-ភ្នំហិមពាន្ត ........................................................................ ៧៤១

-សេចក្តីអធិប្បាយទឹកដីនៃព្រៃហិមពាន្ត ............................

## ១៩-ភ្នំអាជិន្តា

-ភ្នំអាជិន្តា ........................................................................ ៧៤៦

-សេចក្តីអធិប្បាយភ្នំអាជិន្តា ..............................................

# ១២-ទីក្រុងសាវត្ថី

✵-**វត្តជេតពនដ៏អស្ចារ្យ** ព្រះបរមសាស្តា គង់ចាំវស្សាអស់ ១៩ ព្រះវស្សា ។ ទីនេះតែងកើតមានវត្តគ្រប់ពេលដែលព្រះសម្មាសម្ពុទ្ធត្រាស់ដឹង ព្រះគន្ធកុដិ និងជើងគ្រែរបស់ព្រះពុទ្ធគ្រប់អង្គឋិតនៅក្នុងទីតែមួយ ។ ក្នុងបរិវេណវត្ត ពេញទៅដោយទីដែលព្រះអរហន្តធ្លាប់គង់នៅ មានវិហារ មានឧបដ្ឋានសាលា មានកុដិដ៏ច្រើន និងព្រះពោធិព្រឹក្សអានន្ទពោធិ៍ ។ល។ ( **សេចក្តីពិស្តារមាននៅក្នុងជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ទំព័រ ២៥០** ) ។

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត ព្រះអរហន្តទាំងឡាយបរិនិព្វានទៅអស់ហើយ ព្រះអរិយបុគ្គលដទៃ ក៏មិនឃើញមានដែរ សល់តែកន្លែងគួរជាទីនឹករលឹកប៉ុណ្ណោះ ព្រះអរិយបុគ្គលទាំងនោះទៅតាមព្រះមានព្រះភាគអស់ហើយ ។

✵-**កន្លែងសម្តែងយមកប្បាដិហារ្យ** ប្រមាណ ២.៥០០

ម៉ែត្រពីវត្តជេតពន នៅជិតខ្លោងទ្វារក្រុងសាវត្ថីសម័យពុទ្ធកាល ។ មនុស្ស និងទេវតា បានឃើញយមកប្បាដិហារ្យ ព្រមទាំងបានស្តាប់ព្រះធម៌ ដែលព្រះពុទ្ធនិមិត្ត ទូលសួរហើយ ។ មនុស្ស និងទេវតា បានសម្រេចអមតធម៌ ក្នុងគ្រានោះប្រមាណ ២០ កោដិ ។ សេចក្តីពិស្តារ មាននៅក្នុង ទំព័រ ៥ ។

✵-**វត្តបុព្វារាម** ជាទីវិការយនៃពុទ្ធបរិស័ទ ។កសាងដោយមហាឧបាសិកា វិសាខា ។ សេចក្តីពិស្តារ មានក្នុង ទំព័រ ៩៨ ។

✵-**ផ្ទះលោកសេដ្ឋីអនាថបិណ្ឌិក** នៅជិតផ្ទះ បុរោហិតបិតាអង្គុលិមាល គួរឲ្យទស្សនា ។ ( សេចក្តីពិស្តារមាននៅក្នុងជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ទំព័រ ២៥០ ) ។

✵-**ទីវត្តរាជិការាម** នៅជាប់វត្តជេតពន ជាទីគង់នៅនៃភិក្ខុនីសង្ឃសម័យពុទ្ធកាល សាងដោយព្រះបាទបសេនទិកោសលព្រះរាជានៃនគរសាវត្ថី ។ សេចក្តីពិស្តារ មានក្នុង ទំព័រ ៥៧៧ ។

✵-**វត្តជេតពន** កសាងដោយអនាថបិណ្ឌិកសេដ្ឋី ។ (សេចក្តីពិស្តារមាននៅក្នុងជីវប្រវត្តិអនាថបិណ្ឌិកសេដ្ឋី ទំព័រ ២៦២) ។

✵-**អានន្ទពោធិ៍** ជាទីរីករាយនៃពុទ្ធបរិស័ទណាស់ ។ សេចក្តីពិស្តារ មានក្នុង ទំព័រ ៣៦២ ។

✵-**ទីដែលដីស្រូបភិក្ខុទេវទត្ត** ភិក្ខុទេវទត្តបានធ្វើ លោហិតុប្បាទ ផង បំបែកសង្ឃ ផង ត្រូវព្រះធរណីស្រូប នៅខាងមុខវត្តជេតពន មានស្នាមស្រុតដី ដូចជាត្រពាំងទឹកនៅដល់សព្វថ្ងៃនេះ គួរឲ្យសង្វេគចំពោះទោសរបស់ **ទិដ្ឋិ មានះ** និង **តណ្ហា** ។ សេចក្តីពិស្តារ មានក្នុង ទំព័រ ៥៦២ ។

✵-**ទីដែលដីស្រូបនន្ទមាណព** នន្ទមាណពបានប្រទូស្ត (រំលោភ) ចំពោះ ព្រះនាងឧប្បលវណ្ណាថេរី បន្ទាប់មក នន្ទមាណពបានធ្វើដំណើរគេចចេញពីវត្តជេតពន ត្រូវព្រះធរណីស្រូប មានស្នាមស្រុតដី ដូចជាត្រពាំងទឹកនៅដល់សព្វថ្ងៃនេះ គួរឲ្យសង្វេគចំពោះ

ទោសរបស់កាមទាំងឡាយ ។ សេចក្តីពិស្តារ មានក្នុង **ទំព័រ ៤០០** ។

✵-**ទីដែលដីស្រូបនាងចិញ្ចា** នាងចិញ្ចាចោទព្រះមានជោគថា ព្រះមានព្រះភាគប្រព្រឹត្តអសទ្ធម្មជាមួយនាង ព្រះឥន្ទបានជួយធ្វើអន្តរាគមន៍នាងរត់ចេញពីវត្តជេតពន ត្រូវព្រះធរណីស្រូប មានស្នាមស្រុតដី ដូចជាត្រពាំងទឹកនៅដល់សព្វថ្ងៃនេះ គួរឲ្យសង្វេគចំពោះទោសរបស់អវិជ្ជាណាស់ ។ សេចក្តីពិស្តារ មានក្នុង **ទំព័រ ៥៥២** ។

✵-**ស្ទឹងអចិរវតី** ប្រមាណបួនគីឡូម៉ែត្រទៅទិសខាងជើងឆៀងខាងកើតនៃវត្តជេតពន គួរឲ្យនឹកទៅដល់សម័យពុទ្ធកាល ។ នាងបជាបាពច្ចងស្ទឹងនេះឯង កូនរបស់នាងពីរនាក់ត្រូវស្លាប់ ។ **វិឌូឌភ** ព្រមទាំងកងពលត្រូវទឹកជំនន់នៃ **ស្ទឹងអចិរវតី** នេះកួចនាំយកទៅហើយត្រូវស្លាប់ទៅកាន់នរក ព្រោះបានលើកកងទ័ពទៅប្រហារ អ្នកសក្យវង្សក្រុងកបិលពស្តុ ។ សេចក្តីពិស្តារ មានក្នុង **ទំព័រ ៥០៥** ។ ( **នាងបជាបាពច្ចងស្ទឹង** សេចក្តីពិស្តារ មានក្នុង **ទំព័រ ៤៧៦** ) ។

✵-**វត្តខ្មែរសាវត្ថី** ជាទីរីករាយចិត្តរបស់ពុទ្ធបរិស័ទ ។

# ការសម្ដែងយមកប្បាដិហារ្យ

## មានសេចក្ដីផ្ដើមថា

ព្រះសាស្ដា ទ្រង់ប្រារព្ធទេវតា និងពួកមនុស្សជាច្រើន ទៀបទ្វារនគរឈ្មោះសង្កស្ស ត្រាស់ព្រះធម្មទេសនានេះថា **យេ ឈានប្បសុតា ធីរា** ជាដើម ។

ក៏ទេសនាតាំងឡើងហើយក្នុងក្រុងរាជគ្រឹះ ។

## សេដ្ឋីបានខ្ទឹមចន្ទន៍ធ្វើបាត្រ

សេចក្ដីពិស្ដារថា សម័យមួយ សេដ្ឋីក្រុងរាជគ្រឹះប្រើឲ្យគេហ៊ុមព័ទ្ធសំណាញ់ដើម្បីដោះភ័យ និងដើម្បីរក្សាអាភរណៈជាដើម ដែលរបូតទៅដោយការភ្លាំងភ្លាត់ ហើយលេងល្បែងក្នុង **ទន្លេគង្គា** ។

ក្នុងកាលនោះ ដើមចន្ទន៍ក្រហមមួយដើមដុះក្បែរឆ្នេរព្ធដ៏ខាងលើនៃ **ទន្លេគង្គា** មានឫសត្រូវទឹកក្នុងទន្លេគង្គាច្រោះបាក់ធ្លាក់ខ្ទាត់ខ្ទាយនៅលើថ្មទាំងឡាយក្នុងទីនោះៗ ។ គ្រានោះ ពកមួយដុំមានប្រមាណប៉ុនក្អមត្រូវថ្មត្រដុស ត្រូវរលកទឹកទាំងឡាយបក់បោកជារបស់រលើប

រលោងរសាត់ទៅដោយលំដាប់ ត្រូវសារាយ ( ស្លែ ) រុំរឹតជុំវិញ ហើយមកជាប់នៅក្នុងសំណាញ់របស់រាជគហសេដ្ឋីនោះ ។ សេដ្ឋីសួរថា **អ្វីហ្នឹង** ? ពួកអ្នកបម្រើប្រាប់ថា បពិត្រលោកសេដ្ឋី **ពកឈើ** ក៏ប្រើអ្នកបម្រើឲ្យនាំពកឈើនោះ មកចាំងដោយចុងកាំបិត ដើម្បីពិចារណាមើល ( ពិនិត្យមើល ) ថា ពកឈើនោះ ឈ្មោះអ្វី ? ចន្ទន៍ក្រហមមានពណ៌ដូចជាល័ក្តស្រស់ប្រាកដ ក្នុងខណៈឯង ។ ក៏ក្នុងពេលនោះ សេដ្ឋីនោះមិនមែនជាអ្នក **សម្មាទិដ្ឋិ** មិនមែនជាអ្នក **មិច្ឆាទិដ្ឋិ** ជាអ្នកមានសភាពជាកណ្តាល គាត់គិតថា ចន្ទន៍ក្រហមក្នុងផ្ទះរបស់យើងមានច្រើន យើងនឹងយកចន្ទន៍ក្រហមនេះធ្វើអ្វីហ្ន៎ ? គ្រានោះ សេចក្តីត្រិះរិះកើតមានដល់សេដ្ឋីនោះ ដូច្នេះថា ក្នុងលោកនេះ ពួកដែលពោលថា យើងទាំងឡាយជាព្រះអរហន្តដូច្នេះ មានច្រើនគ្នា យើងមិនដឹងព្រះអរហន្តសូម្បីតែ ១ អង្គ យើងនឹងឲ្យប្រកបគ្រឿងក្រឡឹងទុកក្នុងផ្ទះ ឲ្យក្រឡឹងបាត្រ ហើយដាក់ក្នុងសង្រែក ព្យួរក្នុងអាកាសប្រមាណ ៦០ **ហត្ថ** ដោយតៗ នៃដើមឫស្សីហើយ និងពោលថា បើព្រះអរហន្តមានពិត សូមមកតាមអាកាស ហើយសូមកាន់យកបាត្រនេះចុះ អ្នកណា

នឹងកាន់យកបាត្រនោះបាន យើងព្រមទាំងបុត្រ និងភរិយា នឹងដល់អ្នកនោះជាសរណៈ ។ គាត់ឲ្យគេក្រឡឹងបាត្រ ដូចដែលគាត់បានគិតទុកនោះឯង ឲ្យលើកឡើងដោយដើមឫស្សី តៗ គ្នា ហើយពោលថា ក្នុងលោកនេះអ្នកណា ជាព្រះអរហន្ត អ្នកនោះ សូមមកតាមអាកាសកាន់យកបាត្រនេះចុះ ។

## គ្រូទាំង ៦ ចង់បានបាត្រខ្លឹមចន្ទន៍

គ្រូទាំង ៦ ពោលថា បាត្រនោះសមគួរដល់យើងទាំងឡាយ លោកចូរឲ្យបាត្រនោះ ដល់យើងទាំងឡាយចុះ សេដ្ឋីនោះពោលថា ពួកលោកចូរមកតាមអាកាស ហើយកាន់យកចុះ ។

ក្នុងថ្ងៃទី ៦ សាស្តាឈ្មោះនិគ្រន្ថនាដបុត្របញ្ជូនពួកអន្តេវាសិកទៅ ដោយពាក្យថា ពួកអ្នកចូរទៅនិយាយនឹងសេដ្ឋីនោះយ៉ាងនេះថា បាត្រនុ៎ះសមគួរដល់អាចារ្យរបស់យើងទាំងឡាយ លោកកុំធ្វើនូវកិរិយាមកតាមអាកាស ព្រោះហេតុនៃរបស់បន្តិចបន្តួចឡើយ សូមលោកឲ្យបាត្រនោះមកពួកយើងចុះ ។ ពួកអន្តេវាសិករបស់សាស្តាឈ្មោះនិគ្រន្ថ-នាដបុត្រទៅនិយាយនឹងសេដ្ឋីដោយប្រការដូច្នោះ ។សេដ្ឋីពោលថា អ្នក

ដែលអាចមកតាមអាកាសហើយកាន់យកបាន ចូរកាន់យកទៅចុះ ។

## នាដបុត្រប្រើឧបាយយកបាត្រ

និគណ្ឋនាដបុត្រជាអ្នកប្រាថ្នានឹងទៅខ្លួនឯង ទើបបានឲ្យសញ្ញាដល់ពួកអន្តេវាសិកថា យើងនឹងលើកដៃ និងជើងម្ខាង ដូចជាមានការប្រាថ្នានឹងហោះឡើង ពួកអ្នកចូរស្រែកប្រាប់យើងថា លោកអាចារ្យលោកប្រុងធ្វើអ្វី ? លោកចូរកុំសម្តែងភាពជាព្រះអរហន្ត ដែលជាគុណជាតដ៏កំបាំងព្រោះ ហេតុនៃបាត្រឈើដល់មហាជនឡើយ លុះពោលដូច្នេះហើយ ចូរនាំគ្នាចាប់ជើង និងដៃរបស់យើងទាញមក ឲ្យដួលទៅលើផែនដី ។សាស្តាឈ្មោះនិគណ្ឋនាដបុត្រទៅកាន់ទីនោះហើយ ពោលនឹងសេដ្ឋីថា មហាសេដ្ឋី បាត្រនេះ សមគួរដល់យើង មិនសមគួរដល់ពួកជនដទៃទេ លោកកុំគាប់ចិត្តនឹងការហោះឡើងទៅក្នុងអាកាសរបស់អាត្មាភាព ព្រោះហេតុនៃរបស់ត្រឹមតែបន្តិចបន្តួចឡើយ ចូរឲ្យបាត្រនោះដល់អាត្មាភាពចុះ ។

សេដ្ឋី. បពិត្រលោកដ៏ចម្រើន លោកចូរហោះឡើងទៅតាមអាកាសហើយ កាន់យកចុះ ។ គ្រានោះ នាដបុត្រពោលថា បើដូច្នោះ

ពួកអ្នកចូរចៀសចេញ លុះពួកអន្តេវាសិកចៀសចេញទៅហើយ ក៏ពោលថា យើងនឹងហោះឡើងទៅក្នុងអាកាស ដូច្នេះហើយ ក៏លើកដៃម្ខាង និងជើងម្ខាងឡើង ។ ក្លាមនោះ ពួកអន្តេវាសិកពោលនឹងនាដបុត្រថា បពិត្រអាចារ្យ លោកនឹងធ្វើអ្វីហ្នឹង ? ប្រយោជន៍អ្វី ដោយគុណដ៏កំបាំង ដែលលោកសម្តែងដល់មហាជន ព្រោះហេតុនៃបាត្រឈើនេះ ហើយជួយគ្នាចាប់នាដបុត្រនោះត្រង់ដៃ និងជើងទាញឲ្យដួលទៅលើផែនដី ។ និគណ្ឋ-នាដបុត្រប្រាប់សេដ្ឋីថា មហាសេដ្ឋី អន្តេវាសិកទាំងនេះមិនឲ្យអាត្មាភាពហោះទេ លោកចូរឲ្យបាត្រដល់អាត្មាភាពចុះ ។

សេដ្ឋី.បពិត្រលោកដ៏ចម្រើន លោកចូរហោះឡើងទៅយកចុះ ។

ពួកតិរ្ថិយសូម្បីព្យាយាមយ៉ាងនេះអស់ ៦ ថ្ងៃហើយ នៅតែមិនបានបាត្រនោះដដែល ។

## អ្នកក្រុងយល់ថាមិនមានព្រះអរហន្ត

**នៅថ្ងៃទី ៧** ក្នុងកាលដែលព្រះមហាមោគ្គល្លាន និងព្រះបិណ្ឌោល-ភារទ្វាជៈទៅឈរលើថ្មដាមួយកន្លែង ហើយឃ្លុំចីវរ ដោយតាំងចិត្តថានឹងត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ពួកអ្នកលេងជជែកគ្នាថា

ពួកយើងអើយ ក្នុងកាលមុនគ្រូ ទាំង ៦ តែងតែពោលថា ពួកយើងជាព្រះអរហន្តក្នុងលោក ប៉ុន្តែកាលសេដ្ឋីក្រុងរាជគ្រឹះឲ្យលើកបាត្រឡើងហើយពោលថា បើថាព្រះអរហន្តមាន សូមមកតាមអាកាសហើយកាន់យកចុះ ថ្ងៃនេះជាថ្ងៃទី ៧ ហើយ សូម្បីតែមនុស្សម្នាក់ ដែលអាចហោះឡើងទៅក្នុងអាកាសដោយសម្តែងខ្លួនថា យើងជាព្រះអរហន្តក៏មិនមានថ្ងៃនេះ ពួកយើងបានដឹងថាព្រះអរហន្ត មិនមានក្នុងលោកទេ ។ ព្រះមហាមោគ្គល្លានបានឮពាក្យនោះហើយ ក៏ពោលនឹងព្រះបិណ្ឌោលភារទ្វាជៈថា អាវុសោភារទ្វាជៈ លោកបានឮពាក្យអ្នកលេងទាំងនេះទេ ? ពួកអ្នកលេង ទាំងនេះនិយាយគ្នា ដូចជាកោសរូសព្រះពុទ្ធសាសនាខ្លាំងណាស់ ក៏អ្នកសោតជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ដូច្នេះអ្នកចូរទៅ ចូរមកតាមអាកាស ហើយកាន់យកបាត្រនោះចុះ ។

បិណ្ឌោលភារទ្វាជៈ. អាវុសោមោគ្គល្លាន លោកជាអ្នកផ្ទើមជាងសាវ័កអ្នកមានឫទ្ធិទាំងឡាយ លោកចូរកាន់យកបាត្រនោះចុះ ប៉ុន្តែកាលលោកមិនកាន់យកទេ ខ្ញុំនឹងកាន់យក ។

# ព្រះបិណ្ឌោលភារទ្វាជៈសម្តែងបាដិហារិយ៍

កាលព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា អាវុសោ បិណ្ឌោ-លភារទ្វាជៈ អ្នកចូរកាន់យកចុះ ក៏ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទចេញហើយ យកចុងជើងគាបថ្មជាប្រមាណ ១ គាវុត ឃោងឡើងទៅក្នុងអាកាសដូចសំឡី ហើយធ្វើលជុំវិញខាងលើព្រះនគររាជគ្រឹះអស់វារៈ ៧ ជុំ ។ ថ្មដានោះ ប្រាកដដូចជាគម្របព្រះនគរមានប្រមាណ ៣ គាវុត ។ ពួកអ្នកនគរខ្លាចស្រែកថា ថ្មនឹងធ្លាក់សង្កត់ខ្ញុំ ទើបធ្វើគ្រឿងការពារទាំងឡាយ មានចង្អេរជាដើមលើក្បាល ហើយពួនក្នុងទីនោះៗ ។ ក្នុងវារៈទី ៧ ព្រះថេរៈបានទម្លាយថ្មដាហើយសម្តែងខ្លួន ។ មហាជនបានឃើញព្រះថេរៈហើយ ក៏ពោលថា បពិត្រលោកម្ចាស់បិណ្ឌោលភារទ្វាជៈដ៏ចម្រើន សូមលោកម្ចាស់ចាប់ថ្មរបស់លោកម្ចាស់ឲ្យមាំ កុំធ្វើពួកខ្ញុំទាំងអស់គ្នាឲ្យវិនាសឡើយ ។ព្រះថេរៈបោះថ្មចោលដោយចុងជើង ។ ផែនថ្មនោះទៅតាំងនៅក្នុងកន្លែងដើមវិញ ។ព្រះថេរៈបានឈរនៅក្នុងទីបំផុតនៃផ្ទះរបស់សេដ្ឋី ។ សេដ្ឋីឃើញថេរៈហើយ ក៏ក្រាបចុះ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមនិមន្តចុះមក និមន្តព្រះថេរៈដែលចុះ

មកអំពីអាកាសឲ្យគង់ហើយ ប្រើគេសម្រូតបាត្រចុះមក ធ្វើបាត្រនោះឲ្យពេញដោយវត្ថុ ដែលមានរសឆ្ងាញ់ ៤ មុខ ហើយប្រគេនព្រះថេរៈៗ ទទួលបាត្រនោះហើយ ក៏និមន្តទៅកាន់វិហារវិញ ។

គ្រានោះ អ្នកទៅកាន់ព្រៃក្តី អ្នកទៅកាន់ស្រុកក្តី មិនបានឃើញបាដិហារិយ៍របស់ព្រះថេរៈ, អ្នកទាំងនោះប្រជុំគ្នា ហើយពោលអង្វរព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្តែងបាដិហារ្យដល់ពួកខ្ញុំផង ដូច្នេះហើយ ក៏នាំគ្នាជាប់តាមព្រះថេរៈ ។ ព្រះថេរៈសម្តែងបាដិហារិយ៍ដល់ពួកជននោះៗ បណ្តើរ និមន្តទៅកាន់ព្រះវិហារបណ្តើរ ។

## ព្រះសាស្តាទ្រង់ហាមមិនឲ្យភិក្ខុធ្វើបាដិហារិយ៍

ព្រះមានជោគ ទ្រង់ព្រះសណ្តាប់នូវសំឡេងរបស់មហាជន ដែលជាប់តាមព្រះថេរៈហើយ ក៏ត្រាស់សួរថា ម្នាលអានន្ទ នុ៎ះជាសំឡេងរបស់នរណា ? លុះទ្រង់ព្រះសណ្តាប់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិណ្ឌោលភារទ្វាជៈហោះឡើងទៅក្នុងអាកាស ហើយកាន់យកបាត្រខ្លឹមចន្ទន៍ នុ៎ះជាសំឡេងមហាជន ដែលនៅក្នុងសម្នាក់របស់លោក ទើបត្រាស់ឲ្យហៅព្រះបិណ្ឌោលភារទ្វាជៈមក ត្រាស់សួរថា ម្នាលបិណ្ឌោល

អ្នកបានធ្វើយ៉ាងនោះពិតមែនឬ ? កាលព្រះបិណ្ឌោលភារទ្វាជៈ ក្រាបទូលថា ព្រះករុណាព្រះអង្គ ពិតមែន ព្រះអង្គក៏ត្រាស់ថា ម្នាលភារទ្វាជៈ ហេតុម្តេចទើបអ្នកធ្វើយ៉ាងនោះ ទ្រង់តិះដៀលព្រះថេរៈហើយ ត្រាស់ឲ្យទម្លាយបាត្រនោះឲ្យជាកំណាត់តូចកំណាត់ធំ ហើយត្រាស់ឲ្យៗ ដល់ភិក្ខុទាំងឡាយ ដើម្បីជាប្រយោជន៍ដល់ការកិន ធ្វើជាថ្នាំបន្តក់ភ្នែក ហើយទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយដើម្បីជាប្រយោជន៍ដល់កិរិយាមិនធ្វើនូវបាដិហារិយ៍ ។ ចំណែកពួកតិរ្ថិយបានឮថា ព្រះមានព្រះភាគឲ្យទម្លាយបាត្រនោះ ហើយទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយហាមសាវកមិនឲ្យធ្វើបាដិហារិយ៍ ទើបដើរប្រាប់គ្នាក្នុងថ្នល់ព្រះនគរថា សាវកទាំងឡាយនៃព្រះសមណគោតមមិនឈានកន្លងសិក្ខាបទ ដែលទ្រង់បញ្ញត្តហើយ សូម្បីព្រោះហេតុនៃជីវិត សូម្បីព្រះសមណគោតមក៏នឹងរក្សាសិក្ខាបទដែលទ្រង់បញ្ញត្តនោះដែរ ឥឡូវនេះ ពួកយើងបានឱកាសហើយ ហើយពោលថា ពួកយើងរក្សាគុណរបស់ខ្លួន ទើបមិនសម្តែងគុណរបស់ខ្លួនដល់មហាជន ព្រោះហេតុនៃបាត្រក្នុងកាលមុន ពួកសាវករបស់ព្រះសមណគោតមសម្តែងគុណរបស់ខ្លួន ព្រោះហេតុ

នៃបាត្រព្រះសមណគោតមត្រាស់ឲ្យទម្លាយបាត្រនោះហើយ ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវក ព្រោះព្រះអង្គជាបណ្ឌិត ឥឡូវនេះ ពួកយើងនឹងធ្វើបាដិហារិយ៍ជាមួយនឹងព្រះសមណគោតម ។

## ព្រះសាស្ដាទ្រង់បំណងនឹងធ្វើបាដិហារិយ៍

ព្រះបាទពិម្ពិសារ ទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ស្ដេចទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះពុទ្ធអង្គទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវក ដើម្បីត្រូវការមិនឲ្យធ្វើបាដិហារិយ៍ពិតឬ ?

ព្រះសាស្ដា. ថ្វាយព្រះពរមហាបពិត្រ ពិតមែនហើយ ។

ព្រះរាជា. ឥឡូវនេះ ពួកតិរ្ថិយនាំគ្នាពោលថា ពួកយើងនឹងធ្វើបាដិហារិយ៍ជាមួយព្រះអង្គ ឥឡូវនេះ ព្រះអង្គនឹងទ្រង់ធ្វើដូចម្ដេច ?

ព្រះបរមសាស្ដា. មហាបពិត្រ កាលតិរ្ថិយទាំងនោះធ្វើ តថាគតក៏នឹងធ្វើដែរ ។

ព្រះរាជា. ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទុកហើយមិនមែនឬ ?

ព្រះបរមសាស្ដា. មហាបពិត្រ តថាគតមិនបានបញ្ញត្តសិក្ខាបទដើម្បីខ្លួនទេ សិក្ខាបទនោះ តថាគតបញ្ញត្តទុកដើម្បីសាវ័កទាំងឡាយប៉ុណ្ណោះ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទឈ្មោះថា ព្រះអង្គទ្រង់បញ្ញត្តដល់សាវ័កទាំងឡាយ វៀរព្រះអង្គចេញឬ ?

ព្រះបរមសាស្ដា. មហាបពិត្រ បើដូច្នោះ តថាគតនឹងត្រឡប់សួរទៅមហាបពិត្រក្នុងរឿងមួយវិញ មហាបពិត្រ ក៏ព្រះរាជឧទ្យាន ក្នុងដែនរបស់ព្រះអង្គមានឬ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន មាន ។

ព្រះសាស្ដា. បពិត្រមហារាជ ប្រសិនបើមហាជន គប្បីទំពាស៊ីនូវផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើម ក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ព្រះអង្គទ្រង់ធ្វើយ៉ាងណាចំពោះជនទាំងនោះ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន គប្បីដាក់អាជ្ញា ។

ព្រះសាស្ដា. ចំណែកព្រះអង្គសោយបានឬទេ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន អាជ្ញាមិនមានដល់ខ្ញុំព្រះអង្គទេ

ខ្ញុំព្រះអង្គអាចសោយនូវវត្ថុជារបស់នៃខ្លួនបាន ។

ព្រះសាស្តា. បពិត្រមហារាជ អាជ្ញារបស់ព្រះអង្គរមែងផ្សាយទៅក្នុងរាជាណាចក្រប្រមាណ ៣០០ យោជន៍ អាជ្ញានោះមិនមានដល់ព្រះអង្គ ក្នុងការសោយនូវផ្លែឈើទាំងឡាយ មានផ្លែស្វាយជាដើមក្នុងឧទ្យានរបស់ព្រះអង្គ ប៉ុន្តែរមែងមានដល់ជនទាំងឡាយដទៃ យ៉ាងណាសូម្បីអាជ្ញារបស់តថាគតរមែងផ្សាយទៅក្នុងសែនកោដិចក្រវាល អំពើល្មើស ព្រោះកិរិយាប្រព្រឹត្តកន្លងនូវសិក្ខាបទរបស់ខ្លួន រមែងមិនមានដល់តថាគត,ប៉ុន្តែរមែងមានដល់សាវកទាំងឡាយដទៃ ព្រោះហេតុនោះទើបតថាគតនឹងធ្វើបាដិហារ្យ ។ ពួកតិរត្ថិយឮនូវព្រះពុទ្ធតម្រាស់នោះហើយ ប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងវិនាសហើយ បានឮថា ព្រះសមណគោតម ទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយប៉ុណ្ណោះ មិនទ្រង់បញ្ញត្តដល់ខ្លួនទេ, បានឮថា ព្រះសមណគោតម ប្រាថ្នានឹងធ្វើនូវបាដិហារ្យដោយខ្លួនឯងតែម្តង, ពួកយើងនឹងធ្វើដូចម្តេចហ្ន៎ ? ព្រះរាជាទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធអង្គនឹងទ្រង់ធ្វើបាដិហារ្យក្នុងកាលណា ?

ព្រះសាស្តា. បពិត្រមហារាជ តថាគតនឹងធ្វើក្នុងតិថី ពេញបូណ៌មី នៃខែអាសាឍ ដោយកាលកន្លងទៅ ៤ ខែទៀត អំពីថ្ងៃនេះ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគនឹងទ្រង់ធ្វើនៅទីណា ?

ព្រះបរមសាស្តា. បពិត្រមហារាជ តថាគតនឹងធ្វើនៅក្នុង ក្រុងសាវត្ថី ។

មានពាក្យសួរសេិកចូលមកថា ហេតុដូចម្តេច ទើបព្រះសាស្តាទ្រង់សម្តែងអាងនូវទីដ៏ឆ្ងាយយ៉ាងនេះ ?

ឆ្លើយថា ព្រោះទីនោះជាទីធ្វើមហាបាដិហារ្យរបស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ, ន័យមួយទៀតថា ព្រះអង្គទ្រង់សម្តែងអាងនូវទីដ៏ឆ្ងាយយ៉ាងនោះ ព្រោះដើម្បីប្រយោជន៍ឲ្យមហាជនប្រជុំគ្នា ។ ពួកតិរ្ថិយបានឮនូវពុទ្ធតម្រាស់នោះហើយ ពោលថា បានឮថា នៅសល់ ៤ ខែទៀត ព្រះសមណគោតមនឹងធ្វើបាដិហារ្យនៅក្នុងសាវត្ថី, ឥឡូវនេះ ពួកយើងកុំលះបង់ព្រះសមណគោតមឲ្យសោះ ត្រូវជាប់តាមព្រះអង្គជានិច្ច, មហាជនឃើញពួកយើង ហើយសួរថា តើមានរឿងអ្វី ? កាលនោះពួកយើង

នឹងប្រាប់មហាជនថា ពួកយើងនិយាយហើយថា នឹងធ្វើបាដិហារ្យជាមួយនឹងព្រះសមណគោតម, ព្រះសមណគោតមរមែងរត់គេច, ពួកយើងមិនឲ្យព្រះសមណគោតមរត់គេច ទើបជាប់តាម ។

ព្រះសាស្តា ស្តេចត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងរាជគ្រឹះ ហើយស្តេចចេញមក, ចំណែកពួកតិរ្ថិយ ក៏ចេញមកអំពីខាងក្រោយព្រះអង្គ ហើយឋិតនៅក្នុងទីជិតព្រះពុទ្ធអង្គធ្វើភត្តកិច្ច, ថ្ងៃស្អែកឡើងពួកគេនាំគ្នាបរិភោគអាហារពេលព្រឹក ក្នុងទីដែលខ្លួននៅនោះឯង ។ ពួកតិរ្ថិយទាំងនោះ ត្រូវមនុស្សទាំងឡាយ សួរថា ការណ៍នេះដូចម្តេច ក៏ប្រាប់តាមន័យដូចដែលបានពោលហើយខាងដើម ។ ចំណែកមហាជនជាប់តាមព្រះសាស្តាដោយគំនិតថា ពួកយើងនឹងមើលបាដិហារ្យ ។ ព្រះសាស្តាស្តេចដល់ក្រុងសាវត្ថីដោយលំដាប់ ។

## ពួកតិរ្ថិយត្រៀមធ្វើបាដិហារ្យយ៉ាងខ្លាំង

សូម្បីពួកតិរ្ថិយ ក៏ទៅកាន់ក្រុងសាវត្ថីជាមួយនឹងព្រះសាស្តាដែរ បបួលឧបដ្ឋាករបស់ខ្លួន បានទ្រព្យ ១ សែនហើយ ប្រើគេឲ្យធ្វើមណ្ឌប

ដោយសសរឈើគគីរទាំងឡាយ ឲ្យប្រក់ដោយផ្កាឧប្បលខៀវទាំងឡាយ ហើយអង្គុយនិយាយគ្នាថា ពួកយើងនឹងធ្វើបាដិហារ្យក្នុងទីនេះ ។

គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយឲ្យគេធ្វើមណ្ឌបហើយ, ចំណែកខ្ញុំព្រះអង្គនឹងបញ្ជាឲ្យគេធ្វើមណ្ឌបសម្រាប់ព្រះអង្គ ។

ព្រះសាស្តា. កុំឡើយ មហាបពិត្រ អ្នកធ្វើមណ្ឌបដើម្បីតថាគតមានហើយ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន អ្នកដទៃណាទៅ វៀរលែងខ្ញុំព្រះអង្គចេញនឹងអាចធ្វើបាន ។

ព្រះសាស្តា. សក្កទេវរាជ ។

ព្រះរាជាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះលោកនាថទ្រង់ធ្វើបាដិហារ្យក្នុងទីណា ?

ព្រះមានជោគ. បពិត្រមហារាជ អាត្មាភាពនឹងធ្វើនៅទៀបគល់នៃគណ្ឌាម្ពព្រឹក្ស ។

ពួកតិរ្ថិយបានឮថា ព្រះមានជោគទ្រង់នឹងធ្វើបាដិហារ្យក្បែរគល់នៃ

ដើមស្វាយ, ក៏ប្រាប់ឧបដ្ឋាករបស់ខ្លួន ឲ្យដកកូនស្វាយ ដោយហោចទៅ សូម្បីទើបតែកើតក្នុងថ្ងៃនោះ ក្នុងទីប្រមាណ ១ យោជន៍ ហើយឲ្យយក ទៅបោះចោលក្នុងព្រៃ ។ ក្នុងថ្ងៃពេញបូណ៌មី **ខែអាសាឍ** ព្រះសាស្តា ស្តេចចូលទៅខាងក្នុងព្រះនគរ ។ បុរសអ្នករក្សាឧទ្យានរបស់ព្រះរាជា ឈ្មោះគណ្ឌៈ ឃើញផ្លែស្វាយទុំមួយផ្លែ ក្នុងចន្លោះនៃកញ្ចប់ស្លឹកដែល ស្រមោចក្រហម ( អង្ក្រង ) ទាំងឡាយធ្វើសំបុក ដេញសត្វក្អែកទាំង ឡាយ ដែលមកចោមរោមផ្លែស្វាយនោះ ដោយសេចក្តីលោភក្នុងក្លិន និងរសនៃផ្លែស្វាយនោះឲ្យរត់ទៅហើយ កាន់យកទៅដើម្បីថ្វាយព្រះរាជា កាលដើរទៅ បានឃើញព្រះមានជោគក្នុងចន្លោះផ្លូវ ក៏គិតថា ព្រះរាជា សោយ ផ្លែស្វាយនេះហើយគប្បីព្រះរាជទានកហាបណៈដល់យើង ៨ កហាបណៈ ឬ ១៦ កហាបណៈប៉ុណ្ណោះ, ហើយកហាបណៈនោះមិន ល្មមដល់ការចិញ្ចឹមជីវិត ក្នុងមួយអត្តភាពរបស់យើងផង, ប៉ុន្តែប្រសិន បើយើងនឹងថ្វាយអម្ពទាននេះចំពោះព្រះសាស្តា, នោះនឹងជាគុណនាំមក នូវប្រយោជន៍ដល់អញរកទីបំផុតគ្មាន ។ លុះគិតដូច្នោះហើយ ក៏បង្អោន ផ្លែស្វាយនោះ ចូលទៅថ្វាយចំពោះព្រះសាស្តា ។ ព្រះសាស្តាទ្រង់ទត

ព្រះអានន្ទ ។ លំដាប់នោះ ព្រះអានន្ទនាំបាត្រ ដែលមហារាជទាំង ៤ ថ្វាយចេញមក ហើយតម្កល់ក្នុងព្រះហស្តរបស់ព្រះអង្គ ព្រះសាស្តា ទ្រង់បង្អោនបាត្រចូលទៅទទួលផ្លែស្វាយ ហើយទ្រង់សម្តែងនូវអាការ គឺកិរិយាគង់ក្នុងទីនោះតែម្តង ។ ព្រះថេរៈក្រាលចីវរថ្វាយ ។

គ្រានោះ ព្រះថេរៈត្រងទឹកស្អាត ប្របាច់ផ្លែស្វាយទុំធ្វើឲ្យទៅ ជាទឹកគួរផឹក ( ទឹកបាន ) ថ្វាយចំពោះព្រះមានព្រះភាគ ដែលគង់នៅ ហើយក្នុងទីនោះ ។ ព្រះសាស្តា ទ្រង់សោយទឹកបាននោះហើយ ទ្រង់ ត្រាស់ទៅកាន់ឧទ្យានបាលឈ្មោះ គណ្ឌៈនោះថា ម្នាលគណ្ឌៈ អ្នកចូរ កកាយអាចម៍ដីឡើង ហើយចូរដាំគ្រាប់ស្វាយក្នុងទីនេះ ។ បុរសអ្នក រក្សាឧទ្យាន ឈ្មោះគណ្ឌៈនោះ ក៏បានធ្វើហើយដោយប្រការ ដូច្នោះ ។

## ប្រវត្តិគណ្ឌម្ពព្រឹក្ស

ព្រះសាស្តា ទ្រង់លាងព្រះហស្តលើគ្រាប់ស្វាយនោះ ។ គ្រាន់តែ ព្រះសាស្តាទ្រង់លាងព្រះហស្តហើយភ្លាម, ដើមស្វាយ មានទំហំប៉ុន ក្បាល ( យាម ) នង្គ័ល **កម្ពស់ ៥០ ហត្ថ** ដុះឡើង ។ មានមែកធំ ៥ មែក គឺក្នុងទិសទាំងបួន ៤ មែក និងទិសខាងលើមួយមែក ក្នុង

មែកនីមួយៗ មានប្រវែង ៥០ ហត្ថ, ជាឈើដល់ព្រមហើយដោយផ្កា និងផ្លែក្នុងខណៈឯង ជាឈើទ្រទ្រង់នូវចង្កោមនៃស្វាយទុំដោយជុំវិញ ។ ពួកភិក្ខុដែលនិមន្តមកខាងក្រោយ មកឆាន់ផ្លែស្វាយទុំនោះដែរ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ថា បានឮថា ដើមស្វាយបែបនោះដុះឡើងហើយ ក៏ទ្រង់បញ្ជាឲ្យគេរក្សាយ៉ាងមាំដោយព្រះតម្រាស់ថា នរណាៗ កុំកាត់ដើមស្វាយនោះ ។ ក៏ដើមនោះប្រាកដឈ្មោះថា គណ្ឌាម្ពព្រឹក្ស ព្រោះជាដើមស្វាយ ដែលឧទ្យានបាលឈ្មោះគណ្ឌៈជាអ្នកដាំ ។ ចំណែកឯពួកអ្នកលេងស៊ីផ្លែស្វាយទុំនោះហើយពោលថា ម្នាលតិរ្ថិយគម្រក់ទាំងឡាយអើយ ពួកឯងដឹងថា ព្រះសមណគោតមនឹងទ្រង់ធ្វើបាដិហារិយ៍ទៀបគល់នៃគណ្ឌាម្ពព្រឹក្ស ក៏ប្រើគេឲ្យដកកូនស្វាយទាំងឡាយ សូម្បីទើបតែកើតក្នុងថ្ងៃនោះ ក្នុងទីប្រមាណ ១ យោជន៍, ដើមស្វាយនេះឈ្មោះគណ្ឌាម្ពព្រឹក្ស ។

លុះពោលដូច្នោះហើយ ក៏យកគ្រាប់ស្វាយប្រហារពួកតិរ្ថិយទាំងនោះ ។

# សក្កទេវរាជទំលាយវិធីរបស់ពួកតិរ្ថិយ

សក្កទេវរាជទ្រង់បញ្ជាវាតវលាហកទេវបុត្ត ( ទេវបុត្រអ្នកបង្អុរមកនូវខ្យល់ ) ថា ម្នាលវាតវលាហកៈដ៏ចម្រើន អ្នកចូរដកមណ្ឌបរបស់ពួកតិរ្ថិយដោយខ្យល់ ហើយឲ្យខ្យល់បក់ ( សែងយក ) ទៅចោលក្នុងរណ្ដៅលាមក និងគំនរសំរាមចុះ។ ទេវបុត្រនោះ ក៏បានធ្វើដោយប្រការៈដូច្នោះ ។

សក្កទេវរាជបញ្ជា **សុរិយទេវបុត្រ** ថា ម្នាលសុរិយៈដ៏ចម្រើន អ្នកចូរពង្រីកមណ្ឌលព្រះអាទិត្យ ញ៉ាំង (ពួកតិរ្ថិយ) ឲ្យក្ដៅចុះ ។

**សុរិយទេវបុត្រ** ក៏បានធ្វើហើយដោយប្រការដូច្នោះ ។ សក្កទេវរាជ ទ្រង់បញ្ជា **វាតវលាហកទេវបុត្រ** ទៀតថា ម្នាលវាតវលាហកៈដ៏ចម្រើន អ្នកចូរញ៉ាំងមណ្ឌលនៃខ្យល់ ( ខ្យល់កំបុតក្បាល ) ឲ្យតាំងឡើងទូទៅចុះ ។ ទេវបុត្រនោះក៏បានធ្វើហើយដោយបការៈដូច្នោះ ហើយរោយខ្ទាញ់នៃធូលីទាំងឡាយព្ធដ៏ខាងលើសរីរៈ ដែលមានញើសហូរចេញរបស់តិរ្ថិយទាំងឡាយ ។ តិរ្ថិយទាំងនោះ ជាបុគ្គលប្រាកដស្មើដោយដំបូកក្រហម ។ សក្កទេវរាជទ្រង់បញ្ជាវស្សវលាហកទេវបុត្រថា

ម្នាលវស្សវលាហកដ៏ចម្រើន អ្នកចូរញ៉ាំងតំណក់ទឹកគ្រាប់ធំៗ ឲ្យធ្លាក់ចុះ ។ ទេវបុត្រនោះ ក៏បានធ្វើហើយដោយប្រការដូច្នោះ ។ គ្រានោះកាយរបស់ពួកតិរ្ថិយទាំងនោះ ដូចជាមេគោពពាល ។ ពួកតិរ្ថិយទាំងនោះបែកពួកគ្នារត់ទៅកាន់ទិសផ្សេងៗ ។ កាលពួកគេរត់ទៅយ៉ាងនោះ អ្នកស្រែម្នាក់ ដែលជាឧបដ្ឋាករបស់បូរណកស្សបគិតថា ពេលនេះ ជាពេលធ្វើបាដិហារ្យនៃលោកម្ចាស់របស់យើង, យើងនឹងមើលនូវបាដិហារ្យនោះ លុះគិតដូច្នោះហើយ ក៏លែងគោ កាន់ផ្ទាំងបបរដែលខ្លួននាំមកហើយអំពីព្រលឹម និងខ្សែដើរមក ឃើញសាស្តាឈ្មោះបូរណៈកំពុងរត់ដោយប្រការដូច្នោះ ក៏សួរថា បពិត្រលោកអាចារ្យ ខ្ញុំមកដោយបំណងថា នឹងមើលនូវបាដិហារ្យរបស់លោកអាចារ្យ តើលោកអាចារ្យនឹងទៅកាន់ទីណា ?

បូរណៈ. ប្រយោជន៍អ្វីដល់អ្នក ដោយបាដិហារ្យនោះ, ចូរឲ្យផ្ទាំងនិងខ្សែនោះមកយើង ។

សាស្តាឈ្មោះបូរណៈនោះកាន់យកផ្ទាំង និងខ្សែដែលឧបដ្ឋាករបស់ខ្លួនឲ្យហើយ ដើរទៅកាន់ឆ្នេរស្ទឹង ចងផ្ទាំងនឹងករបស់ខ្លួនដោយ

ខ្សែហើយ លោតចុះទៅក្នុងអន្លង់ទឹក ញ៉ាំងពពុះឲ្យតាំងឡើង ធ្វើកាលកិរិយាហើយ ទៅកើតក្នុងនរក **ឈ្មោះអវិចី** ។

ព្រះសាស្ដា ទ្រង់និម្មិតនូវទីចង្ក្រមជាវិការៈនៃកែវក្នុងអាកាស ។ ទីបំផុតម្ខាងនៃទីចង្ក្រមនោះ ឋិតនៅក្នុងកណ្ដាប់មាត់ចក្រវាលខាងកើត ចុងម្ខាងទៀត នៅក្នុងកណ្ដាប់មាត់ចក្រវាលខាងលិច ។ ព្រះសាស្ដាកាលបរិស័ទប្រមាណ **៣៦ យោជន៍** ប្រជុំគ្នាហើយ, ក្នុងវេលានៃព្រះអាទិត្យមានស្រមោលកំពុងចម្រើន ( រសៀល ) ស្ដេចចេញចាកព្រះគន្ធកុដិ ដោយទ្រង់ព្រះតម្រិះថា ពេលនេះជាពេលធ្វើបាដិហារ្យ លុះទ្រង់ព្រះតម្រិះដូច្នោះហើយ ក៏ទ្រង់ឈរនៅក្នុងទីចំពោះមុខបរិស័ទទាំងនោះ ។

## សាវកសាវិកាទទួលអាសាធ្វើបាដិហារ្យជំនួស

គ្រានោះ ឧបាសិកាជាអនាគាមីម្នាក់ ជាមាតារបស់នន្ទមាណព ឈ្មោះឃរណី ចូលទៅគាល់ព្រះអង្គ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលធីតាដូចជាខ្ញុំព្រះអង្គនៅមាន, កិច្ចដែលព្រះអង្គត្រូវលំបាករមែងមិនមាន, ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យជំនួសព្រះអង្គ ។

ព្រះសាស្ដា. ម្នាលនាងឃរណី នាងនឹងធ្វើដូចម្ដេច ?

ឧបាសិកា ឈ្មោះយរណីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើនូវមហាប្រឹថពីក្នុងផ្ទៃចក្រវាលឲ្យទៅជាទឹក ហើយមុជចុះក្នុងទឹក សម្តែងខ្លួនក្នុងកណ្តាប់មាត់ចក្រវាលខាងកើត, កណ្តាប់មាត់ចក្រវាលខាងលិចខាងជើង និងខាងត្បូង, និងត្រង់កណ្តាល, កាលបើដូច្នោះ មហាជនឃើញខ្ញុំព្រះអង្គហើយ, ក៏សួរថា នរណានុ៎ះ ? ក៏ប្រាប់ថា នុ៎ះជានាងយរណី, អានុភាពរបស់ស្ត្រីម្នាក់នេះ ដល់ម៉្លោះទៅហើយ, ពោលថ្វីដល់អានុភាពរបស់ព្រះពុទ្ធ នឹងប្រាកដដូចម្តេចទៅ! ពួកតិរ្ថិយមិនបាច់ឃើញព្រះអង្គទេ នឹងរត់ទៅដោយប្រការយ៉ាងនេះ ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងនាងថា ម្នាលនាងយរណី តថាគតរមែងដឹងនូវភាវៈនៃនាងជាស្ត្រី អាចធ្វើបាដិហារ្យបែបនេះបាន, ប៉ុន្តែកម្រងផ្កានេះគេមិនបានចងទុកដើម្បីជាប្រយោជន៍ដល់នាងទេ លុះទ្រង់ត្រាស់ដូច្នោះហើយ ក៏ទ្រង់ហាមឃាត់ ។

នាងយរណីនោះគិតថា ព្រះសាស្តាមិនទ្រង់អនុញ្ញាតដល់យើង, ប្រាកដជាមានអ្នកដទៃ ដែលអាចធ្វើបាដិហារ្យ ឲ្យក្រៃលែងជាងយើងដោយពិត លុះគិតដូច្នោះហើយ ក៏ឈរនៅក្នុងចំណែកម្ខាង ។

ចំណែកព្រះសាស្តា ទ្រង់ត្រិះរិះថា គុណរបស់សាវ័កទាំងនោះនឹងប្រាកដដោយអាការយ៉ាងនេះឯង ទ្រង់សម្គាល់ថា ពួកសាវ័កនឹងបន្លឺសីហនាទត្រង់កណ្តាលបរិស័ទ **មានប្រមាណ ១២ យោជន៍** ដោយអាការយ៉ាងនេះ ទើបត្រាស់សួរសាវ័ក មួយពួកទៀតថា ពួកអ្នកនឹងធ្វើបាដិហារិយ៍ដូចម្តេច ? សាវ័កទាំងនោះក៏ក្រាបទូលថា ពួកខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនេះៗ ព្រះអង្គ ហើយឈរនៅចំពោះព្រះភក្ត្រនៃព្រះសាស្តាបន្លឺសីហនាទ ។

ក្នុងបណ្តាសាវ័កទាំងនោះ បានឮថា **ចូឡអនាថបិណ្ឌិក** គិតថា នាកាលបុត្រជាអនាគាមីឧបាសកប្រាកដដូចជាយើង នៅមានកិច្ចដែលព្រះសាស្តាត្រូវលំបាករមែងមិនមាន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារិយ៍ ត្រូវព្រះមានជោគត្រាស់សួរថា អ្នកនឹងធ្វើដូចម្តេច ? ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនិម្មិតអត្តភាពជាព្រហ្ម មានប្រមាណ **១២ យោជន៍** នឹងទះដូចព្រហ្មដោយសំឡេង ដូចមហាមេឃគ្រហឹមក្នុងកណ្តាលបរិស័ទ មហាជននឹងសួរគ្នាថា សំឡេងទ្ទុះជាសំឡេងអ្វី ? ហើយនឹងបានឮថា សំឡេងទ្ទុះ

ជាសំឡេងនៃការទះដូចជាព្រហ្មរបស់ចូឡអនាថបិណ្ឌិក ពួកតិរ្ថិយគិតថា អានុភាពរបស់គហបតីដល់ម៉្លោះទៅហើយ ចំណង់បើអានុភាពរបស់ព្រះពុទ្ធជាម្ចាស់ នឹងប្រាកដដូចម្ដេចទៅ ! ពួកតិរ្ថិយមិនបាច់ឃើញព្រះអង្គឡើយ នឹងរត់ទៅ ។ ព្រះមានជោគត្រាស់ដូច្នោះដែរ សូម្បីដល់ចូឡអនាថបិណ្ឌិកនោះថា តថាគតជ្រាបអានុភាពរបស់អ្នក ហើយមិនទ្រង់អនុញ្ញាតការធ្វើបាដិហារិយ៍ ។ តមក សាមណេរីឈ្មោះ **វីរា** មានអាយុ **៧ ខួប** សម្រេចបដិសម្ភិទាមួយរូប ថ្វាយបង្គំព្រះសាស្ដាហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារិយ៍ ។

ព្រះសាស្ដា. ម្នាលនាងវីរា នាងនឹងធ្វើដូចម្ដេច ?

វីរា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនាំភ្នំសិនេរុផង ភ្នំចក្រវាលផង ភ្នំហិមពាន្តផង តម្រៀបទុកក្នុងទីនេះ ហើយនឹងចេញអំពីភ្នំនោះៗ ទៅ មិនបានជាប់ដូចជាមេហង្ស មហាជនឃើញខ្ញុំព្រះអង្គហើយ នឹងសួរថា នុ៎ះជានរណា ? ហើយនឹងពោលថា វីរាសាមណេរី ពួកតិរ្ថិយគិតគ្នាថា អានុភាពរបស់សាមណេរី អ្នកមានអាយុ ៧ ខួប ដល់ម៉្លោះទៅហើយ ចំណង់បើអានុភាពរបស់ព្រះមានជោគ នឹងប្រាកដ

ដូចម្ដេចទៅ មិនបាច់ឃើញព្រះពុទ្ធអង្គឡើយ នឹងវត់ចៀសចេញទៅ ។ បន្ទាប់អំពីនេះទៅ គប្បីជ្រាបពាក្យបែបនេះតាមលំអាននៃពាក្យ ដែលពោលហើយនោះចុះ ។ ព្រះមានព្រះភាគត្រាស់ទៅកាន់សាមណេរីនោះថា តថាគតជ្រាបអានុភាពរបស់នាងហើយ លុះទ្រង់មានព្រះតម្រាស់ដូច្នោះហើយ ក៏ទ្រង់មិនអនុញ្ញាតការធ្វើបាដិហារិយ៍ ។

គ្រានោះ សាមណេរឈ្មោះចុន្ទៈ ដែលជាព្រះខីណាស្រពសម្រេចបដិសម្ភិទាមួយរូប មានអាយុ **៧ ខួប** អំពីកំណើត ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារិយ៍ ត្រូវព្រះសាស្ដាត្រាស់សួរថា ម្នាលចុន្ទៈ អ្នកនឹងធ្វើម្ដេច ? ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចាប់ដើមព្រីងធំ ដែលជាទង់នៃជម្ពូទ្វីបត្រង់ដើម ហើយអង្រួន នាំផ្លែព្រីងធំមកឲ្យបរិស័ទទាំងនេះស៊ី រួចស្រេចហើយ ខ្ញុំព្រះអង្គនឹងនាំមកនូវផ្កាបារិច្ឆត្តព្រឹក្សទាំងឡាយ ថ្វាយព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា តថាគតជ្រាបអានុភាពរបស់អ្នកហើយ ដូច្នេះហើយ ក៏ទ្រង់ហាមឃាត់ការធ្វើនូវបាដិហារិយ៍របស់សាមណេរ ។

លំដាប់នោះ ព្រះថេរីឈ្មោះឧប្បលវណ្ណាថ្វាយបង្គំព្រះសាស្តា ហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារិយ៍ ត្រូវព្រះសាស្តាត្រាស់សួរថា ម្នាលឧប្បលវណ្ណា នាងនឹងធ្វើដូចម្តេច ? ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងសម្តែងបរិស័ទ ដែលមានប្រមាណ **៣២ យោជន៍ដោយជុំវិញ** នឹងជាស្តេចចក្រពត្តិ ដែល បរិស័ទ មានប្រមាណ **៣៦ យោជន៍** ដោយចំណែកមូលចោមរោម ហើយ មកថ្វាយបង្គំព្រះអង្គ ។ ព្រះមានជោគត្រាស់ថា តថាគតជ្រាប អានុភាពរបស់នាងហើយ ក៏ទ្រង់ហាមការធ្វើបាដិហារិយ៍ សូម្បីរបស់ ព្រះថេរីរូបនោះ ។

គ្រានោះ ព្រះមហាមោគ្គល្លានត្ថេរ ថ្វាយបង្គំព្រះមានព្រះភាគ ហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យ ត្រូវព្រះមានជោគត្រាស់សួរថា ម្នាលមោគ្គល្លាន អ្នកនឹងធ្វើដូចម្តេច ? ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងដាក់ស្តេចភ្នំឈ្មោះ សិនេរុទុក ក្នុងចន្លោះធ្មេញ ហើយទំពាភ្នំនោះដូចទំពាគ្រាប់ស្ពៃ ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងមូរមហាប្រឹថពីនេះឲ្យដូចជាកន្ទេល ហើយដាក់ចូល ( គៀតទុក ) ក្នុងចន្លោះម្រាមដៃ ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងបង្វិលមហាប្រឹថពីឲ្យដូចជាបង្វិលកង់ភាជនៈដីរបស់ស្មូនឆ្នាំង ហើយឲ្យមហាជនទំពាស៊ីឱជានៃផែនដី ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងធ្វើផែនដីទុកក្នុងដៃខាងឆ្វេង ហើយដាក់សត្វទាំងនេះទុកក្នុងទ្វីបដទៃ ដោយដៃខាងស្តាំ ។

ព្រះសាស្តា. អ្នកនឹងធ្វើអ្វីដទៃទៀត ?

មោគ្គល្លាន. ខ្ញុំព្រះអង្គនឹងធ្វើភ្នំសិនេរុឲ្យជាដងឆត្រ ហើយលើកមហាប្រឹថពីឡើង ដាក់ពួដ៏ខាងលើភ្នំសិនេរុនោះ យកដៃម្ខាងកាន់ដូចជាភិក្ខុអ្នកមានឆត្រក្នុងដៃ ចង្រ្កមក្នុងអាកាស ។ ព្រះមានជោគត្រាស់ថាតថាគតជ្រាបអានុភាពរបស់អ្នកហើយ ដូច្នេះហើយ ក៏មិនទ្រង់អនុញ្ញាតការធ្វើបាដិហារិយ៍សូម្បីរបស់ព្រះថេរៈនោះ ។ ព្រះថេរៈគិតថា ប្រហែលជាព្រះសាស្តា ទ្រង់ជ្រាបអ្នកដែលអាចធ្វើបាដិហារិយ៍ក្រៃលែងជាងយើង

លុះគិតដូច្នោះហើយ ក៏បានឋិតនៅក្នុងចំណែកម្ខាង ។ គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់ព្រះមហាមោគ្គល្លានថា ម្នាលមោគ្គល្លាន ភួងផ្កានេះគេមិនបានចងទុកដើម្បីអ្នកទេ ព្រោះថា តថាគតជាអ្នកមានធុរៈរកបុគ្គលស្មើគ្មាន អ្នកដទៃឈ្មោះថា ជាអ្នកអាចនាំទៅនូវធុរៈរបស់តថាគតមិនមាន អ្នកដែលនឹងអាចនាំទៅនូវធុរៈរបស់តថាគតមិនបានមានក្នុងកាលឥឡូវនេះ ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាអស្ចារ្យទេ សូម្បីក្នុងកាលដែលតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ដែលជាអហេតុកកំណើត អ្នកដទៃដែលអាចនាំទៅនូវធុរៈរបស់តថាគត ក៏មិនបានមានដូចគ្នា កាលព្រះថេរៈទូលសួរថា រឿងរ៉ាវហ្នឹងបានមានហើយ ក្នុងកាលណា ព្រះអង្គ ? ទើបទ្រង់នាំអតីតនិទានមកត្រាស់ កណ្ហឧសភជាតកឲ្យពិស្តារថា

ធុរៈធ្ងន់ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួកជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោនោះ ក៏នាំធុរៈដ៏ធ្ងន់នោះទៅបាន ។

កាលទ្រង់សម្ដែងរឿងនោះ ឲ្យពិស្ដារក្រៃលែងតទៅទៀត ទើបត្រាស់នន្ទវិសាលជាតកនេះឲ្យពិស្ដារថា

បុគ្គលគប្បីពោលពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីពោលនូវពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាៗ ឡើយ ( ព្រោះ ) កាលព្រាហ្មណ៍ជាម្ចាស់ពោលនូវពាក្យជាទីគាប់ចិត្ត គោឈ្មោះនន្ទិវិសាលអូស ភារៈដ៏ធ្ងន់ទៅបាន ញុំាងព្រាហ្មណ៍ជាម្ចាស់នោះឲ្យបានទ្រព្យ ទាំងព្រាហ្មណ៍នោះ បានជាអ្នកមានចិត្តរីករាយ ព្រោះការបានទ្រព្យនោះ ។

លុះទ្រង់ត្រាស់រឿងនោះចប់ហើយ ក៏ទ្រង់ឡើងកាន់ទីចង្រ្កមកែវនោះ ។ ខាងមុខមានបរិស័ទប្រមាណ ១២ យោជន៍ ខាងក្រោយ ខាងឆ្វេង និងខាងស្តាំក៏ដូចគ្នា ចំណែកទីត្រង់ មានប្រមាណ ២៤ យោជន៍ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើយមកប្បាដិហារិយ្យក្នុងកណ្តាលបរិស័ទ ។ យមកប្បាដិហារ្យនោះ បណ្ឌិតគប្បីជ្រាបតាមព្រះបាលីយ៉ាងនេះចុះ ។

## លក្ខណៈរបស់យមកប្បាដិហិរញ្ញាណ

ញាណក្នុងយមកប្បាដិហិរញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ? ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារិយ៍ ដែលមិនទូទៅដល់ពួកសាវ័កក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីកាយខាងក្រោម គំនរភ្លើងចេញអំពីកាយខាងក្រោម ផ្ការទឹកចេញអំពី

កាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះកាយខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ គំនរភ្លើងចេញអំពីចុង្កយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចុង្កយព្រះអង្សាខាងឆ្វេង គំនរភ្លើងចេញអំពីចុង្កយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចុង្កយព្រះអង្សាខាងស្តាំ គំនរភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្តខាងឆ្វេង គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹកចេញអំពីព្រះហស្តខាងស្តាំ គំនរភ្លើងចេញអំពីខាងខាងស្តាំ ផ្ការទឹកចេញអំពីខាងខាងឆ្វេង គំនរភ្លើងចេញអំពីខាងខាងឆ្វេង ផ្ការទឹកចេញអំពីខាងខាងស្តាំ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្ការទឹកចេញអំពី

ព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្ការទឹកចេញអំពី ព្រះបាទខាងស្តាំ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយៗ ផ្ការទឹកចេញអំពី ចន្លោះនៃព្រះអង្គុលី គំនរភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ផ្ការទឹកចេញ អំពីព្រះអង្គុលីមួយៗ គំនរភ្លើងចេញអំពីព្រះលោមាមួយៗ ផ្ការទឹកចេញ អំពីព្រះលោមាមួយៗ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយៗ ផ្ការ ទឹកចេញអំពីរណ្តៅព្រះលោមាមួយៗ ( ព្រះមានព្រះភាគទ្រង់បញ្ចេញ ) ព្រះឆព្វណ្ណរង្សីខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេកៗ ព្រះមានជោគ ទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគ ទ្រង់ឈរ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគ ទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគ ទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់គង់ ព្រះមានព្រះភាគ ទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ឈរ ព្រះមានព្រះភាគ ទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់គង់ ព្រះមានព្រះភាគ ទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ នេះឈ្មោះថា យមកប្បាដិហិរញ្ញាណរបស់ព្រះតថាគត ។ ព្រះសាស្តាស្តេចទ្រង់ចង្រ្កម លើទីចង្រ្កម ទ្រង់ធ្វើបាដិហារិយ៍ហើយដោយប្រការដូច្នេះ ។ ដើម្បីនឹង

សម្ដែងនូវសេចក្ដីនោះ គំនរភ្លើងចេញអំពីព្រះកាយខាងលើ ដោយអំណាចតេជោកសិណសមាបត្តិរបស់ព្រះអង្គ, ទ.ទឹកហូរចេញអំពីព្រះកាយខាងក្រោម ដោយអំណាចអាបោកសិណសមាបត្តិ, គំនរភ្លើងរមែងចេញអំពីទីដែលទ.ទឹកហូរចេញហើយទៀត, ហើយទ.ទឹកក៏ហូរចេញអំពីទីដែលគំនរភ្លើងចេញហើយ ព្រះសារីបុត្រក៏ពោលថា **ហេដ្ឋិមកាយតោ ឧបរិមកាយតោ** ។ ន័យក្នុងបទទាំងពួង ក៏គប្បីជ្រាបដូច្នេះ ។ ក៏ក្នុងយមកប្បដិហារិយ៍នេះគំនរភ្លើងមិនបានលាយឡំនឹងទ.ទឹកឡើយ, ទ.ទឹកក៏មិនបានលាយឡំនឹងគំនរភ្លើងដែរ, បានឮថា គំនរភ្លើង និងទ.ទឹកទាំងពីរនេះអណ្ដែតឡើងដរាបដល់ព្រហ្មលោក ហើយរាលដាលដល់កណ្ដាប់មាត់ចក្រវាល ។ ក៏ព្រោះភាវៈនៃពាក្យដែលព្រះសារីបុត្រពោលទុកថា **ឆន្នំ វណ្ណានំ** ព្រះរស្មីមានពណ៌ ៦ ប្រការ នៃព្រះមានព្រះភាគអង្គនោះអណ្ដែតឡើងអំពីផ្ទៃចក្រវាលមួយ ទៅទល់នឹងព្រហ្មលោក ដូចជាមាសរលាយ ដែលគេចាក់ចេញចាកបាវទាំងឡាយ និងដូចជាទទឹកមាស ដែលហូរចេញអំពីចំពួយនៃយន្ត ហើយត្រឡប់មកកាន់កណ្ដាប់មាត់ចក្រវាលដូចដើមវិញ ។ ផ្ទៃចក្រមួយមានពន្លឺតែមួយ ដូចជាខឿននៃពោធិព្រឹក្សដែលគេរួបរឹត ហើយដោយបន្តង់កោង ។ ក្នុងថ្ងៃនោះ ព្រះសាស្ដាស្ដេច

ចង្ក្រម ទ្រង់ធ្វើ ( យមកៈ ) បាដិហារិយ៍ សម្តែងធម្មកថាដល់មហាជន ជាចន្លោះៗ, ក៏កាលទ្រង់សម្តែងមិនទ្រង់ធ្វើមហាជន ឲ្យមានដង្ហើមតឹងទេ ទ្រង់ប្រទាននូវដង្ហើមដ៏ធូរក្រៃលែង ។ ក្នុងគ្រានោះ មហាជនញ៉ាំង សាធុការឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងកាលដែលសាធុការនៃមហាជន កំពុងតែប្រព្រឹត្តទៅនោះ ព្រះសាស្តាទ្រង់រមិលមើលនូវចិត្តរបស់បរិស័ទ ដ៏ច្រើនដល់ម្ល៉ោះ បានទ្រង់ជ្រាបវារៈចិត្តជនម្នាក់ៗ ដោយអំណាចអាការ ១៦ យ៉ាង ។ ចិត្តរបស់ព្រះពុទ្ធទាំងឡាយប្រព្រឹត្តទៅដោយរហ័សយ៉ាង នេះ ។ បុគ្គលឯណាៗ ជ្រះថ្លាក្នុងធម៌ណា និងក្នុងបាដិហារ្យណា, ព្រះ មានជោគ ព្រះអង្គទ្រង់សម្តែងធម៌ និងទ្រង់សម្តែងនូវបាដិហារ្យ ដោយ អំណាចអធ្យាស្រ័យនៃបុគ្គលនោះៗ ។ កាលព្រះអង្គទ្រង់សម្តែងធម៌ និងទ្រង់សម្តែងបាដិហារ្យដោយអាការយ៉ាងនេះ ធម្មាភិសម័យបានកើត មាន ហើយដល់មហាជន ។ ព្រះសាស្តាមិនទ្រង់ឃើញបុគ្គលដទៃ ដែល អាចកាន់យកព្រះទ័យរបស់ព្រះអង្គហើយ សួរបញ្ហាក្នុងសមាគមនោះ ទើបព្រះអង្គទ្រង់និម្មិតព្រះពុទ្ធនិម្មិត ។ ព្រះមានជោគទ្រង់ដោះស្រាយនូវ ប្រស្នាដែលព្រះពុទ្ធនិម្មិតនោះសួរហើយ ។

ព្រះពុទ្ធនិម្មិតនោះ ទ្រង់ដោះស្រាយនូវប្រស្នាដែលព្រះមានជោគត្រាស់សួរហើយ ។ ក្នុងវេលាដែលព្រះសាស្តាទ្រង់ចង្ក្រម ព្រះសាស្តាសម្រេចឥរិយាបថទាំងឡាយ មានឥរិយាបថឈរជាដើមមួយ ។ ក្នុងពេលដែលព្រះពុទ្ធនិម្មិតចង្ក្រម ព្រះមានជោគទ្រង់សម្រេចនូវឥរិយាបថទាំងឡាយ មានឥរិយាបថឈរណាមួយ ដើម្បីនឹងសម្តែងនូវសេចក្តីនោះ ព្រះធម្មសង្គាហកាចារ្យក៏បានពោលពាក្យជាដើមថា ព្រះពុទ្ធនិម្មិតរមែងចង្ក្រមខ្លះជាដើម ។

ធម្មាភិសម័យ (កិរិយាត្រាស់ដឹងនូវលោកុត្តរធម៌) បានកើតមានដល់សត្វ ២០ កោដិ ក្នុងសមាគមនោះ ព្រោះឃើញបាដិហារិយ៍របស់ព្រះសាស្តា ដែលទ្រង់ធ្វើយ៉ាងនោះផង ព្រោះបានស្តាប់ធម្មកថាផង ។

## ព្រះសាស្តាស្តេចចាំវស្សានៅឋានតាវត្តិង្ស

ព្រះទសពល កាលកំពុងទ្រង់ធ្វើបាដិហារិយ៍នោះ ទ្រង់រំពឹងថា ព្រះពុទ្ធក្នុងអតីត ធ្វើបាដិហារិយ៍នេះហើយ ចាំវស្សានៅទីណាហ្ន៎ ។

ទ្រង់ឃើញថា ចាំវស្សាក្នុងភពតាវត្តិង្ស ហើយទ្រង់សម្តែងព្រះអភិធម្មបិដកប្រោសព្រះពុទ្ធមាតា ដូច្នេះហើយ ទ្រង់លើកព្រះបាទស្តាំ

ប្រតិស្ឋានលើកំពូល **ភ្នំយុគន្ធរ** ទ្រង់លើកព្រះបាទម្ខាងទៀត ប្រតិស្ឋានលើកំពូល **ភ្នំសិនេរុ** ។ ការៈនៃជំហានទាំងឡាយ ៣ បានមានហើយក្នុងទី **៦៨ សែនយោជន៍** ដោយអាការយ៉ាងនេះ ។ ចន្លោះនៃព្រះបាទទាំង ២ ជាចន្លោះ មានកិរិយាដាក់ចុះ ប្រាកដស្មើដោយជំហាននៃព្រះបាទជាប្រក្រតី ។ នរណាៗ មិនគប្បីកំណត់ថា ព្រះសាស្ដា ទ្រង់សណ្ដូកព្រះបាទជាន់ហើយ ព្រោះក្នុងពេលដែលព្រះអង្គ ទ្រង់លើកព្រះបាទឡើង ភ្នំទាំងនោះ ក៏មកកាន់ទីជិតព្រះបាទទទួលព្រះបាទព្រះសម្មាសម្ពុទ្ធ, ហើយក្នុងវេលាដែលព្រះសាស្ដាទ្រង់ជាន់ ភ្នំទាំងនោះក៏តាំងនៅក្នុងទីដដែលវិញ ។ សក្កទេវរាជទ្រង់ឃើញហើយ ទ្រង់គិតថា អើហ្ន៎ ព្រះសាស្ដានឹងទ្រង់ចាំព្រះវស្សាក្នុងកណ្ដាល បណ្ឌុកម្ពលសិលានេះ ( សិលា មានសណ្ឋានដូចជាសំពត់កម្ពលពណ៌លឿង ), ឧបការៈនឹងមានដល់ពួកទេវតាដ៏ច្រើនហ្ន៎ ! ប៉ុន្តែថា កាលព្រះសាស្ដា ទ្រង់ចាំវស្សានៅនោះ ពួកទេវតាដទៃៗ មិនអាចដាក់ដៃបាន ក៏ឯបណ្ឌុកម្ពលសិលានេះ **បណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍** កាលព្រះសាស្ដាទ្រង់គង់ហើយ ក៏គង់នឹងក្លាយទៅជារបស់ទទេ ។ព្រះសាស្ដាទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ទ្រង់បោះសង្ឃាដីរបស់ព្រះអង្គ ទៅគ្របជិតផ្ទៃសិលានោះ ។

សក្កទេវរាជ ទ្រង់ព្រះតម្រិះថា ព្រះសាស្តា ទ្រង់បោះសង្ឃាដីមកគ្រប មុន, ក៏ព្រះអង្គនឹងទ្រង់គង់ក្នុងទីមានប្រមាណតិច ដោយព្រះអង្គឯង ។ ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យរបស់សក្កទេវរាជ ក៏ទ្រង់គង់ធ្វើបណ្តុកម្ពលសិលា ឲ្យនៅតែក្នុងក្រេនចីវរប៉ុណ្ណោះ ដូចជាភិក្ខុអ្នកទ្រទ្រង់នូវមហាចីវរបង្សុកូល គង់ធ្វើនូវតាំងដ៏ទាបឲ្យនៅតែក្នុងក្រេនចីវរ ដូច្នោះ ។ ខណៈនោះឯង មហាជនរកមើលព្រះសាស្តាក៏មិនឃើញ ។ កាលនោះ ដូចជាកាលព្រះចន្ទអស្តង្គតហើយផង ដូចជាកាលនៃព្រះអាទិត្យអស្តង្គតហើយផង ។ មហាជនក៏ខ្សឹកខ្សួលពោលនូវគាថានេះថា

*ព្រះសាស្តាស្តេចទៅកាន់ភ្នំចិត្តកូដឬ ឬក៏ទៅកាន់ភ្នំកៃលាស ឬក៏ស្តេចទៅកាន់ភ្នំយុគន្ធរ, ទើបយើងទាំងឡាយ មិនឃើញព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាបុគ្គលធ្មើមក្នុងលោក ព្រះអង្គជានរៈដ៏អង់អាច ប្រសើរជាងនរៈទាំងពួង ។*

មួយពួកទៀតខ្សឹកខ្សួលថា ព្រះសាស្តា ព្រះអង្គទ្រង់ត្រេកអរហើយក្នុងវិវេក, ព្រះអង្គនឹងស្តេចទៅកាន់ដែនដទៃ ឬជនបទដទៃហើយ ព្រោះទ្រង់ខ្មាសថា តថាគតធ្វើបាដិហារិយ៍បែបនេះដល់បរិស័ទបែបនេះ,

ឥឡូវនេះ យើងទាំងឡាយ នឹងមិនបានឃើញព្រះអង្គទៀតទេ ដូច្នេះ ពោលគាថានេះថា

ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ត្រេកអរហើយក្នុងវិវេក ស្តេចនឹងមិនត្រឡប់មកកាន់លោកនេះទៀតទេ ។ យើងទាំងឡាយ និងជនទាំងនោះ សួរព្រះមហាមោគ្គល្លានថា មិនបានឃើញព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាអ្នកធ្មើមក្នុងលោក ជានរៈដ៏អង់អាច ប្រសើរជាងនរៈ ដូច្នេះ ។

# ✍ ជីវប្រវត្តិរបស់ឧបាសិកាវិសាខាមិគារមាតា ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកឱ្យទាន "

*ឧបាសិកាវិសាខា ជាអរិយសាវិកាមួយរូប ដែលជាអ្នកមានការឧបត្ថម្ភទំនុកបម្រុងភិក្ខុសង្ឃយ៉ាងច្រើន ដោយបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនកសាងវត្តបុព្វារាមថ្វាយទុកក្នុងព្រះពុទ្ធសាសនា ជាអ្នកដែលបានទទួលការរាប់អានយ៉ាងទូលំទូលាយក្នុងសង្គម និងជាអ្នកដែលបានទទួលការលើកតម្កើងឲ្យជាឯតទគ្គៈពីព្រះលោកនាថ ទើបសមគួរដល់ឋានៈ ហើយបានទទួលកំណត់នាមថា* ***មហាឧបាសិកា*** *។*

*ជីវប្រវត្តិរបស់មហាឧបាសិកាវិសាខា មានសម្ដែងទុកនៅក្នុង* ***អដ្ឋកថាគម្ពីរធម្មបទ*** *នៃ* ***បុប្ផវគ្គ*** *ក្នុង* ***រឿងរបស់ឧបាសិកាវិសាខា*** *និងក្នុង* ***អដ្ឋកថាមនោរថបូរណី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង* ***គម្ពីរអង្គុត្តរនិកាយ ឯកនិបាត*** *ដូចមានសេចក្ដីថា ៖*

*មហាឧបាសិកាវិសាខា ជាកូនស្រីរបស់នាងសុមនាទេវី ដែលជា*

កិរិយាធនញ្ជយសេដ្ឋី ហើយធនញ្ជយសេដ្ឋី ជាបុត្ររបស់មេណ្ឌកសេដ្ឋី នៅក្នុងភទ្ទិយនគរ ដែនអង្គៈ ពួកញាតិបានដាក់ឈ្មោះឲ្យនាងថា **វិសាខា** ។ ក្នុងកាលដែលនាងវិសាខាមានអាយុបាន **៧ ខួប** ព្រះមានជោគ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់វេនេយ្យសត្វ គឺសត្វដែលគប្បីណែនាំប្រៀនប្រដៅបាន ដើម្បីឲ្យបានត្រាស់ដឹងនូវធម៌ មានសេលព្រាហ្មណ៍ជាដើម ទើបទ្រង់នាំភិក្ខុសង្ឃជាច្រើន ស្តេចយាងទៅកាន់ភទ្ទិយនគរ ក្នុងដែនអង្គៈ ។ សម័យនោះឯង មេណ្ឌកសេដ្ឋី ជាប្រធាននៃអ្នកមានបុណ្យ ៥ នាក់ ដែលបានទទួលការតែងតាំងទុកក្នុងតំណែងជាសេដ្ឋីនៅក្នុងនគរនោះ ដែលមានឈ្មោះថា **មេណ្ឌកសេដ្ឋី** ១ ភរិយារបស់មេណ្ឌកៈឈ្មោះថា **ចន្ទបទុមា** ១ បុត្រច្បងរបស់មេណ្ឌកសេដ្ឋី មានឈ្មោះថា **ធនញ្ជ័យ** ១ ភរិយារបស់ធនញ្ជយសេដ្ឋី មានឈ្មោះថា **នាងសុមនាទេវី** ១ អ្នកបម្រើរបស់លោកសេដ្ឋី មានឈ្មោះថា **បុណ្ណៈ** ១ ។ ប៉ុន្តែមិនមែនមានតែចំពោះមេណ្ឌកសេដ្ឋីប៉ុណ្ណោះទេ ក្នុងដែនមគធៈរបស់ព្រះបាទពិម្ពិសារ ក៏មានបុគ្គលដែលជាអ្នកមានទ្រព្យសម្បត្តិរាប់

ប្រមាណមិនបានដូចគ្នាគឺ ១ ជោតិកៈ ២ ជដិល ៣ មេណ្ឌកៈ ៤ បុណ្ណៈ ៥ កាកវល្លិយៈ ។ ក្នុងបណ្តាបុគ្គលដែលមានទ្រព្យប្រមាណមិនបានទាំងនេះ មេណ្ឌកសេដ្ឋីបានជ្រាបដំណឹងថា ព្រះមុនីមកដល់កទ្ទិយនគរហើយ ទើបឲ្យហៅចៅស្រីវិសាខា ដែលជាកូនស្រីរបស់ធនញ្ជយសេដ្ឋីជាបុត្ររបស់លោកមក ហើយប្រាប់ថា ចៅ កាពជាសិរីមង្គល រមែងមានដល់ចៅ និងតាផង ចៅ និងក្មេងស្រី ថែមទាំងបរិវារ ៥ រយនាក់របស់ចៅ ចូរឡើងរថ ៥០០ ចោមរោមទៅដោយទាសី ៥ រយនាក់ចូរទៅទទួលព្រះវិជិតមារចុះ ។

គ្រានោះ វិសាខា ដែលជាទារិកាពោលទទួលថា ចាំ តា ហើយនាងបានធ្វើតាមយ៉ាងនោះ ។ ប៉ុន្តែកិច្ចការដែលវិសាខាទារិកា ជាក្មេងឆ្លាតក្នុងហេតុដែលគួរ និងមិនគួរ ទើបនាងទៅដោយយាន តាមដែលយានល្មមអាចទៅបាន ហើយចុះចាកយាន ដើរចូលទៅគាល់ព្រះសក្យមុនីថ្វាយបង្គំរួចហើយ ទើបឈរនៅក្នុងទីដ៏សមគួរ ។ ពេលនោះ ព្រះភគវាទ្រង់សម្តែងធម៌ តាមការសមគួរនឹងបុព្វចរិយារបស់នាងវិសាខាទារិកា ។

ក្នុងពេលដែលព្រះសាស្តា ទ្រង់ទេសនាចប់ វិសាខាទារិកា ព្រមដោយក្មេងស្រី ៥០០ នាក់ ក៏បានសម្រេចសោតាបត្តិផល ។ ចំណែកមេណ្ឌកសេដ្ឋី ក៏ទៅគាល់ព្រះមុនី ថ្វាយបង្គំហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះអង្គទ្រង់ក៏បានទេសនាប្រោស តាមសមគួរនឹងបុព្វចរិយារបស់មេណ្ឌកសេដ្ឋី កាលព្រះអង្គទេសនាចប់ មេណ្ឌកសេដ្ឋីក៏បានសម្រេចសោតាបត្តិផល ហើយទើបក្រាបទូលនិមន្តព្រះសាស្តា ដើម្បីទទួលចង្ហាន់ក្នុងថ្ងៃស្អែក នៅក្នុងផ្ទះរបស់ខ្លួន ។ លុះដល់ថ្ងៃស្អែកឡើង មេណ្ឌកសេដ្ឋី បានអង្គាសភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដោយខាទនីយ និងភោជនីយាហារដ៏ប្រណីត ក្នុងផ្ទះរបស់ខ្លួន និងបានថ្វាយមហាទានក្នុងទំនងដូចគ្នានេះ រហូតដល់កន្លះខែ ។ ព្រះភគវា លុះទ្រង់ប្រថាប់នៅក្នុងភទ្ទិយនគរ តាមសមគួរអធ្យាស្រ័យហើយ ទើបស្តេចចៀសចេញទៅ ។ ក្នុងគ្រានោះ ព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសល មួយអង្គក៏បានជាភស្តា (ស្វាមី) របស់ព្រះភគិនី (ប្អូនស្រី) មួយអង្គទៀត (ឬហៅម្យ៉ាងទៀត គឺជាប្អូនថ្លៃ) ។ ថ្ងៃមួយ ព្រះបាទបសេន-

ទិកោសលមានព្រះរាជតម្រិះថា បុគ្គលមានទ្រព្យសម្បត្តិប្រមាណមិនបាន ជាអ្នកមានបុណ្យទាំង ៥ នាក់ នៅក្នុងដែនរបស់ព្រះបាទពិម្ពិសារ ចំណែកក្នុងដែនកោសលរបស់យើង បុគ្គលដូចនោះ សូម្បីត្រឹមម្នាក់ក៏មិនមានដែរ កុំដូច្នោះឡើយ យើងនឹងទៅគាល់ព្រះបាទពិម្ពិសារ ទូលសូមអ្នកមានបុណ្យច្រើនដូចនោះមកបានម្នាក់ ។ ព្រះបាទបសេនទិកោសល ស្តេចក៏បានយាងទៅកាន់ដែនមគធៈរបស់ព្រះបាទពិម្ពិសារ ។ ព្រះបាទពិម្ពិសារ ទ្រង់ក៏បានធ្វើបដិសណ្ឋារៈ ថែមទាំងទ្រង់ទូលសួរថា ព្រះអង្គស្តេចយាងមកនេះ មានការអ្វី ? ព្រះបាទបសេនទិកោសល ក៏បានទូលតបថា ទូលបង្គំមកដោយគិតថា បុគ្គលជាអ្នកមានទ្រព្យសម្បត្តិប្រមាណមិនបាន ជាអ្នកមានបុណ្យច្រើនដល់ទៅ ៥ នាក់ នៅក្នុងដែនរបស់ព្រះអង្គ ទូលបង្គំនឹងទូលសូមម្នាក់ ក្នុងចំណោមអ្នកទាំង ៥ ណាមួយក៏បាន សូមទ្រង់ព្រះរាជទានដល់ទូលព្រះបង្គំផងចុះ ។

គ្រានោះ ព្រះបាទពិម្ពិសារទូលតបថា ទូលបង្គំមិនអាចឲ្យត្រកូលធំៗ ផ្លាស់ប្តូរទីកន្លែងបានទេ ។ គ្រានោះ ព្រះបាទបសេនទិកោសល

ទូលថា ប្រសិនបើទូលបង្គំមិនបាន នឹងមិនត្រឡប់ទៅវិញដែរ ។ ទើបព្រះបាទពិម្ពិសារ ទ្រង់ប្រឹក្សាជាមួយនឹងពួកអាមាត្យ ហើយទូលថា កាលនឹងផ្លាស់ប្តូរត្រកូលធំៗ មានជោតិកសេដ្ឋីត្រកូលជាដើម ដូចគ្នានឹងធ្វើឲ្យផែនដីញ័រ តែបុត្ររបស់មេណ្ឌកសេដ្ឋី ឈ្មោះថា **ធនញ្ជយសេដ្ឋី** ទូលបង្គំប្រឹក្សានឹងគេរួចស្រេចហើយ ទើបថ្វាយចម្លើយដល់ព្រះអង្គ ហើយមានព្រះរាជតម្រាស់ឲ្យហៅធនញ្ជយសេដ្ឋីមកគាល់ បានត្រាស់ថា នែបា ព្រះបាទបសេនទិកោសលត្រាស់ថា នឹងទូលសូមសេដ្ឋីអ្នកមានទ្រព្យសម្បត្តិទៅបានម្នាក់ ដូច្នេះ អ្នកចូរទៅជាមួយព្រះអង្គចុះ ។ គ្រានោះ ធនញ្ជយសេដ្ឋីក្រាបបង្គំទូលថា សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ កាលបើព្រះអង្គ ទ្រង់បញ្ជូនខ្ញុំទៅ ខ្ញុំព្រះអង្គក៏នឹងទៅ ព្រះករុណាថ្លៃវិសេស ។ គ្រានោះ ទើបព្រះបាទពិម្ពិសារ ត្រាស់ថា ប្រសិនបើដូច្នោះ ចូរលោកធ្វើការរៀបចំខ្លួនចុះ ។ ធនញ្ជយសេដ្ឋី បានធ្វើកិច្ចចាំបាច់ដែលគួរធ្វើរបស់ខ្លួន រៀបរយហើយ ។ ព្រះបាទពិម្ពិសារទ្រង់ក៏ធ្វើសក្ការៈឲ្យដល់ធនញ្ជយសេដ្ឋី ថែមទាំងទ្រង់ជូនដំណើរព្រះបាទ

បសេនទិកោសល ទៅដោយព្រះរាជតម្រាស់ថា សូមព្រះអង្គទ្រង់នាំធនញ្ជយសេដ្ឋីនេះទៅចុះ ។ ព្រះបាទបសេនទិកោសល ទ្រង់ក៏បាននាំធនញ្ជយសេដ្ឋីត្រឡប់ទៅកាន់ដែនរបស់ព្រះអង្គ ដោយទ្រង់ឈប់សម្រាកកន្លែងនីមួយៗ មួយយប់ ក៏ស្តេចធ្វើដំណើរបន្តទៅទៀត លុះដល់ទីកន្លែងមួយ ដែលមានសេចក្តីសុខសប្បាយ ហើយទ្រង់ឈប់សម្រាកនៅក្នុងទីនោះ ។ គ្រានោះ ទើបធនញ្ជយសេដ្ឋី ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ទីកន្លែងនេះ ជាដែនរបស់ព្រះរាជាអង្គណាព្រះអង្គ ? ព្រះបាទបសេនទិកោសលត្រាស់តបថា នែលោកសេដ្ឋី ទីនេះជាដែនរបស់យើង ។ ធនញ្ជយសេដ្ឋីក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពីទីកន្លែងនេះទៅដល់ក្រុងសាវត្ថី មានរយៈផ្លូវចម្ងាយប៉ុន្មាន ព្រះអង្គ ? ព្រះបាទបសេនទិកោសលត្រាស់តបថា ពីទីកន្លែងនេះទៅដល់ក្រុងសាវត្ថី មានរយៈចម្ងាយផ្លូវប្រមាណជា ៧ យោជន៍ ។ ទើបធនញ្ជយសេដ្ឋីក្រាបបង្គំទូលសូមព្រះរាជានុញ្ញាតថា បពិត្រព្រះអង្គដ៏ចម្រើន ខាងក្នុងក្រុងចង្អៀតណាស់ បរិវាររបស់ខ្ញុំព្រះអង្គ មានចំនួនជា

ច្រើន ប្រសិនបើព្រះអង្គទ្រង់ព្រះអនុញ្ញាត ខ្ញុំព្រះអង្គនឹងសូមនៅក្នុងនេះឯង ព្រះអង្គ ។ ពេលនោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់អនុញ្ញាតថា បាន ហើយមានព្រះបរមរាជឱង្ការឲ្យកសាងក្រុងឡើង នៅក្នុងទីកន្លែងនោះព្រះរាជទានដល់ធនញ្ជយសេដ្ឋី ហើយព្រះអង្គក៏ស្តេចយាងចៀសចេញទៅ ។ ក្រុងថ្មីនេះមានឈ្មោះថា **សាកេត** ព្រោះថា ទីនោះធនញ្ជយសេដ្ឋីចាប់ដីកសាងកន្លែងនៅរបស់ខ្លួន ក្នុងពេលល្ងាច ។

ចំណែកក្រុងសាវត្ថី មានសេដ្ឋីម្នាក់ឈ្មោះ **មិគារសេដ្ឋី** លោកមានបុត្រឈ្មោះថា **បុណ្ណវឌ្ឍនកុមារ** ពេលដែលបុណ្ណវឌ្ឍនកុមារចម្រើនវ័យធំដឹងក្តីហើយ គ្រានោះ មាតាបិតា បានពោលជាមួយនឹងបុណ្ណវឌ្ឍនកុមារថា កូន ចូរកូនជ្រើសរើសរកស្ត្រីម្នាក់ ដែលជាទីស្រឡាញ់ពេញចិត្តរបស់កូនចុះ ។ បុណ្ណវឌ្ឍនកុមារជម្រាបតបថា បាទលោកឪពុកអ្នកម្តាយ ខ្ញុំមិនត្រូវការមានភរិយាទេ ។ ទើបមាតាបិតាពោលណែនាំដោយហេតុផលថា កូន កូនកុំធ្វើយ៉ាងនេះឡើយ ត្រកូលដែលមិនមានបុត្រ មិនអាចតាំងនៅបានទេណាកូន ។ កាលបើមាតាបិតា

និយាយរំអុកជារឿយៗ ទើបបុណ្ណវឌ្ឍនកុមារពោលថា លោកឪពុក អ្នកម្ដាយ ប្រសិនបើបំណងប្រាថ្នារបស់លោកឪពុកអ្នកម្ដាយយ៉ាងនេះ កាលបើខ្ញុំបានស្ត្រីក្រមុំ ដែលនាងប្រកបដោយបញ្ចកល្យាណី ខ្ញុំក៏ធ្វើតាមពាក្យអង្វររបស់លោកឪពុកអ្នកម្ដាយ ។ ពេលនោះ មាតាបានស្ដាប់ឮពាក្យនិយាយរបស់កូនប្រុស ដូច្នោះហើយ ក៏បានសង្ស័យ ទើបសួរកូនប្រុសថា កូន បញ្ចកល្យាណី គឺអ្វីទៅ ? បុណ្ណវឌ្ឍនកុមារ ទើបជម្រាបប្រាប់ថា បញ្ចកល្យាណី គឺភាពស្អាត ៥ យ៉ាង បានដល់ ១- សក់ ២- សាច់ ៣ ធ្មេញ ៤- សម្បុរ ៥- វ័យ ។ សក់របស់ស្ត្រីដែលមានបុណ្យច្រើន ដូចគ្នានឹងសំណុំកន្ទុយក្ងោក ពេលដែលរំសាយសក់មកនោះ សក់នោះក៏បានធ្លាក់ទៅដល់សំពត់ស្លៀក ហើយមានចុងសក់ង.ស្ទើតឡើង នេះហៅថា ស្អាតដោយសក់ ។ បបូរមាត់មានពណ៌ដូចផ្លែបាសទុំ ទាំងមានពណ៌រាបស្មើ នេះហៅថា សាច់ស្អាត ។ចំណែកធ្មេញវិញ មានការរាបស្មើ មិនឃ្លាតពីគ្នាល្អដូចរបៀបនៃពេជ្រដែលគេលើកឡើងតម្កល់ទុក ឬដូចរបៀបនៃស័ង្ខដែលគេលាបពណ៌ល្អហើយ

នេះហៅថា ធ្មឹងល្អ ។ សម្បុររបស់ស្រ្តីខ្មៅ មិនបានលាបលេន ដោយគ្រឿងផាត់ស្បែកអ្វីផ្សេងៗ រលើងដូចផ្កាឧប្បលខៀវ បើសម្បុរនៃស្រ្តី.ស ក៏ស.ដូចផ្កាកណិការ នេះហៅថា សម្បុរស្អាត ។ស្រីដែលប្រសូតកូនរួចហើយ ១០ ដង ក៏នៅដូចជាស្រ្តីប្រសូតកូនត្រឹមតែម្តង មើលទៅដូចជាស្រីនៅក្រមុំ ស្រស់ស្អាតជានិច្ច នេះហៅថា វ័យស្អាត ។

គ្រានោះ មាតាបិតា កាលបើជ្រាបសេចក្តីត្រូវការរបស់កូនប្រុសដូច្នេះ ទើបអញ្ជើញពួកព្រាហ្មណ៍ ១០៨ នាក់ មកទទួលអាហារហើយសួរថា ស្រ្តីដែលប្រកបដោយបញ្ចកល្យាណី មានដែរឬ ? ពួកព្រាហ្មណ៍ទាំងនោះតបថា មាន ។ ទើបមិគារសេដ្ឋីពោលថា បើយ៉ាងនេះ ចូរឲ្យព្រាហ្មណ៍ ៨ នាក់ ទៅស្វែងរកក្មេងស្រីដូច្នោះ ហើយទើបប្រគល់ទ្រព្យជាច្រើន ព្រមទាំងប្រគល់កម្រងផ្កាមាស ដែលមានតម្លៃមួយសែនកហាបណៈឲ្យ ថែមទាំងពោលថា ក្នុងពេលដែលពួកលោកត្រឡប់មកពួកខ្ញុំនឹងពិចារណាវត្ថុដែលគួរធ្វើដល់ពួកលោក ពួកលោកចូរនាំគ្នាទៅស្វែងរកក្មេងស្រីដែលមានលក្ខណៈ ជាបញ្ចកល្យាណីចុះ ពេលដែល

ពួកលោកជួបហើយ ចូរប្រដាប់កម្រងផ្កាមាសនេះដល់នាង កាលលោកសេដ្ឋីពោលដូច្នេះហើយ ក៏បានបញ្ជូនព្រាហ្មណ៍ទាំងនោះទៅ ។ ពួកព្រាហ្មណ៍ទាំង ៨ នាក់នោះ បានទៅស្វែងរកគ្រប់ទីក្រុងធំៗ ក៏មិនបានប្រទះស្ត្រី ដែលប្រកបដោយលក្ខណៈបញ្ចកល្យាណី ហើយក៏បាននាំគ្នាត្រឡប់មកដល់ក្រុងសាកេត ក្នុងថ្ងៃនោះ មានបុណ្យនក្ខត្តឫក្ស ( ជាបុណ្យប្រចាំឆ្នាំរបស់ក្រុងសាកេត ក្នុងបុណ្យនោះ អ្នកស្រុកគ្រប់គ្នាក៏បានបើកសំពត់គ្របមុខចេញ ធ្វើដំណើរទៅកាន់ស្ទឹង ) ជាបុណ្យដែលមានប្រចាំឆ្នាំ ។ ក្នុងកាលនោះ សូម្បីត្រកូលដែលមិនធ្លាប់ចេញទៅខាងក្រៅស្រុក ក៏ត្រូវចេញចាកផ្ទះព្រមនឹងបរិវារ មិនបិទមុខដើរទៅកាន់ច្នេរស្ទឹង ។ ក្នុងថ្ងៃនោះ ពួកបុត្រទាំងឡាយរបស់មហាសាលជាដើមម្នាក់ៗ ក៏ឈរនៅក្បែរៗ ផ្លូវនោះ ដោយតាំងចិត្តថា ពួកយើងនឹងបានជួបស្ត្រី ដែលមានជាតិត្រកូលស្មើគ្នា លុះពេញចិត្តហើយ ក៏បានពាក់កម្រងផ្កាឲ្យ ។ ចំណែកពួកព្រាហ្មណ៍ ៨ នាក់នោះ ក៏បាននាំគ្នាទៅឈរនៅក្នុងសាលាមួយខ្នង ដែលនៅក្បែរច្នេរស្ទឹង ។ ក្នុងខណៈនោះ នាង

វិសាខា ដែលមានអាយុឈានចូល ១៥-១៦ ឆ្នាំហើយ ស្អិតស្អាងខ្លួន ដោយគ្រឿងអាភរណៈសព្វគ្រប់ ចោមរោមដោយកុមារី ដែលមានវ័យ ដូចគ្នាប្រមាណ ៥០០ នាក់ ក៏បាននាំគ្នាទៅកាន់ទីកន្លែងនោះ ដោយ គិតថា ពួកយើងនឹងចុះទៅងូតទឹកស្ទឹង ។ ក្នុងពេលនាងវិសាខា ព្រម ដោយបរិវារទៅដល់ទីកន្លែងនោះ ពពកក៏បានតាំងឡើង ហើយភ្លៀង ក៏បានបង្អុរចុះមក ។ ក្មេងស្រីទាំង ៥០០ នាក់នោះ កាលបើឃើញ ដូច្នោះហើយ ក៏បាននាំគ្នាប្រញាប់រត់ចូលទៅក្នុងសាលា ដោយរហ័ស មិនបានឃើញត្រូវនឹងលក្ខណៈបញ្ចកល្យាណី សូម្បីតែម្នាក់សោះ ។ ពេលនោះ នាងវិសាខាបានដើរទៅតាមប្រក្រតី ចូលទៅកាន់សាលា ហើយគ្រឿងប្រដាប់របស់នាងទទឹកភ្លៀងជោក ដោយនាងបានដើរចូល ទៅកាន់សាលា ដែលក្មេងស្រីទាំងនោះចូលទៅជ្រក មិនបានសម្តែង អាការខ្លាចភ្លៀងធ្លាក់ទទឹក សូម្បីតែបន្តិចសោះឡើយ ពួកព្រាហ្មណ៍ ទាំងនោះ កាលបើបានឃើញនាងវិសាខាដូច្នេះ ក៏គិតថា ស្ត្រីក្រមុំដទៃៗ ដែលមានរូបរាងកាយល្អស្អាត ក៏មិនមានអ្នកណាលើសស្រីនេះ តែថា

រូបរាងកាយនេះ ជាធម្មជាតិដែលស្រីពួកខ្លះតាក់តែងបាន ដូចជារថ តាក់តែងជុំរថដូច្នោះ កាលបើពួកព្រាហ្មណ៍បានឃើញភាពស្អាតនាង ហើយ មានបំណងនឹងចង់ឃើញធ្មេញ ទើបពោលជាមួយគ្នា និងគ្នា ដែលប៉ះទង្គិចដល់នាងថា ធីតារបស់ពួកយើងជាស្រីខ្ជិលច្រអូស ស្វាមី របស់នាងនេះ ប្រហែលជាមិនបានបរិភោគសូម្បីត្រឹមតែបាយចុងអង្ករ ទេមើលទៅ ។ គ្រានោះ ទើបនាងវិសាខាសួរពួកព្រាហ្មណ៍ទាំងនោះថា លោកដ៏ចម្រើនទាំងឡាយ ពួកលោក ថាឲ្យអ្នកណា ? ពួកព្រាហ្មណ៍ ទាំងនោះតបថា ថាឲ្យនាងហ្នឹងឯង ។ បានឮថា សំឡេងរបស់នាង វិសាខា ដែលបានបន្លឺចេញទៅនោះ មានសំឡេងដ៏ពីរោះ ដូចគ្នានឹង សំឡេងគោះនរង៉ែ ។ ទើបនាងវិសាខា សួរពួកព្រាហ្មណ៍ទាំងនោះ ដោយសំឡេងដ៏ពីរោះទៀតថា ព្រោះហេតុអ្វី ទើបពួកលោកថាឲ្យខ្ញុំ ពួកព្រាហ្មណ៍ទាំងនោះ ទើបពោលពន្យល់ថា ស្រីបរិវាររបស់នាង មិនព្រមឲ្យសំពត់ និងគ្រឿងស្អិតស្អាងខ្លួនទទឹកទឹកភ្លៀង ប្រញាប់រត់ ចូលទៅក្នុងសាលា កិច្ចដែលត្រូវប្រញាប់មកដល់ទីនេះ នាងក៏មិនអាច

ធ្វើបានទៅហើយ នាងបានបណ្ដោយឲ្យសំពត់ និងគ្រឿងស្អិតស្អាងខ្លួនទទឹកអស់ ព្រោះដូច្នោះ ទើបពួកយើងនាំគ្នាថាឲ្យនាងយ៉ាងហ្នឹងឯងទៅ ។

គ្រានោះ ទើបនាងវិសាខា ពោលថា បពិត្រលោកឪពុកទាំងឡាយពួកលោកកុំនិយាយយ៉ាងនេះ ខ្ញុំមានកម្លាំងខ្លាំងក្លាជាងស្ត្រីទាំងនោះ តែខ្ញុំកំណត់ហេតុការណ៍ មានហេតុយ៉ាងដទៃទៀតហើយ ទើបមិនប្រញាប់រត់មក ដោយលឿនរហ័សយ៉ាងនេះ ។ពួកព្រាហ្មណ៍ កាលបានស្ដាប់ពាក្យឆ្លើយតបរបស់នាងវិសាខាដូច្នេះហើយ ក៏បានទឹកចាប់អារម្មណ៍ទើបសួរថា មានហេតុការណ៍អ្វីទៅនាង ? លំដាប់នោះ នាងវិសាខាទើបពោលតបថា បពិត្រលោកឪពុកទាំងឡាយ ជន ៤ ជំពូក កាលបើរត់ទៅ រមែងមិនស្អាត ឬមិនល្អ ។ទើបពួកព្រាហ្មណ៍សួរតទៅទៀតថានែនាង ជន ៤ ជំពូកពួកណា កាលរត់ទៅរមែងមិនស្អាត ឬល្អនោះ ? នាងវិសាខាបានពោលពន្យល់ថា បពិត្រលោកឪពុកទាំងឡាយ ព្រះរាជាដែលទ្រង់បានអភិសេករួចហើយ ទ្រង់បានប្រដាប់ដោយគ្រឿងអលង្ការទាំងពួងហើយ កាលបើព្រះរាជាទ្រង់សើយសំពត់ចងក្បិនរត់ទៅលើ

ព្រះលានហ្លួង រមែងមិនស្អាត រមែងបានទទួលការរិះគន់និន្ទាយ៉ាងពិត
ប្រាកដថា ហេតុដូចម្តេច ទើបព្រះរាជាអង្គនេះ ទ្រង់រត់ទៅដូចជាគហបតី
តែកាលបើព្រះរាជា ទ្រង់ព្រះរាជដំណើរទៅសន្សឹមៗ ទើបមើលទៅ
ស្អាត ។ ឯដំរីមង្គលរបស់ព្រះរាជាដែលបានប្រដាប់ហើយ រត់ទៅមិនស្អាត
ពេលដែលដើរទៅលីលារបស់ដំរី ទើបមើលទៅស្អាត ។ បព្វជិត
កាលបើរត់ទៅក៏មិនស្អាត រមែងបានទទួលការនិន្ទាតែម្យ៉ាងប៉ុណ្ណោះថា
ដូចម្តេច ទើបសមណៈរូបនេះ រត់ទៅដូចជាគ្រហស្ថ តែសមណៈតែង
មើលទៅស្អាតនោះ គឺដោយអាការដើរទៅយ៉ាងស្ងប់ស្ងៀម ។ ស្រី
កាលបើរត់ទៅក៏មិនស្អាត រមែងត្រូវគេតិះដៀលថា ដូចម្តេចហ្ន៎
ស្រីរូបនេះ បានជារត់ទៅដូចជាប្រុស ស្ត្រីដែលមើលទៅស្អាតនោះ
ដោយការឈានដើរទៅតាមធម្មតា បពិត្រលោកឪពុកទាំងឡាយ ជន
៤ ជំពូកនេះឯង កាលបើរត់ទៅ រមែងមើលមិនស្អាត ។

ពួកព្រាហ្មណ៍សួរទៀតថា នែនាង ដែលនាងពោលថា មានហេតុ
យ៉ាងដទៃទៀត បានដល់អ្វី ? នាងវិសាខាពោលតបថា បពិត្រលោក

ឪពុកទាំងឡាយ ធម្មតាមាតាបិតាចិញ្ចឹមកូន ថែរក្សាកូនស្រីរាំងអវយវៈ តូចធំ ព្រោះថា ពួកខ្ញុំជឿថា ជារបស់របរដែលមាតាគួរលក់ទៅ មាតាបិតាថែរក្សាខ្ញុំ ដើម្បីត្រូវការនឹងជូនទៅកាន់ត្រកូលដទៃ បើក្នុងពេលដែលខ្ញុំរត់ទៅជាន់ជាយសំពត់ដែលស្លៀក ឬចែជន្យ រអិលដួលលើផែនដីដៃ ឬជើងបាក់ ពួកខ្ញុំក៏នឹងត្រូវធ្លាក់ជាភារៈថែរក្សានៅក្នុងត្រកូលរបស់ខ្លួននោះឯង ចំណែកគ្រឿងតាក់តែងខ្លួនទទឹកហើយ ក៏នឹងអាចស្ងួតទៅវិញបានដែរ ខ្ញុំកំណត់ហេតុនេះឯងហើយ ទើបមិនរត់ទៅ ។ ពួកព្រាហ្មណ៍ បានឃើញភាពល្អស្អាតរបស់ធ្មេញ ក្នុងពេលដែលនាងនិយាយហើយ ទើបបន្លឺវាចាឡើង ដើម្បីសម្តែងការសរសើរដល់នាងថា សម្បត្តិដូចនេះ ពួកយើងនៅមិនទាន់ធ្លាប់បានឃើញឡើយ នែនាងកម្រងផ្កានេះ សមគួរដល់នាងហើយ ពោលដូច្នេះរួច ទើបបំពាក់កម្រងផ្កាមាសឲ្យដល់នាង ។ ទើបនាងវិសាខា សួរពួកព្រាហ្មណ៍ទាំងនោះថា លោកឪពុកទាំងឡាយអញ្ជើញមកអំពីទីក្រុងណា ? ពួកព្រាហ្មណ៍តបថា នាង ពួកយើងមកពីក្រុងសាវត្ថី ។ នាងវិសាខាសួរថា

ត្រកូលសេដ្ឋីឈ្មោះថាអ្វី ? ពួកព្រាហ្មណ៍ឆ្លើយថា ត្រកូលសេដ្ឋីឈ្មោះមិគារសេដ្ឋី ។ នាងវិសាខាសួរថា បុត្ររបស់លោកសេដ្ឋីឈ្មោះអ្វី ? ព្រាហ្មណ៍ឆ្លើយថា ឈ្មោះបុណ្ណវឌ្ឍនកុមារ ។ នាងវិសាខាពោលទទួលថា ត្រកូលរបស់យើងស្មើគ្នា ហើយនាងបាននាំដំណឹងនោះ ឲ្យទៅដល់ធនញ្ជយសេដ្ឋី ដែលជាបិតាថា សូមលោកឪពុកអ្នកម្តាយរៀបចំបញ្ជូនរថទៅឲ្យពួកខ្ញុំផង ។ ការពិត ក្នុងពេលដែលនាងវិសាខាមក នាងក៏ដើរមកបានជាធម្មតា តែចាប់ផ្តើមពីពេលដែលនាង បានទទួលការបំពាក់កម្រងផ្កាមាសនោះហើយ រមែងឈានជើងដើរមកវិញមិនបាន ព្រោះក្មេងស្រីទាំងឡាយជាធំ រមែងទៅដោយយាន មានរថជាដើម ចំណែកក្មេងស្រីក្រៅអំពីនេះ ក៏បានឡើងជិះយានធម្មតាទៅ បុគ្គលទាំងឡាយ ក៏បាននាំគ្នាបាំងឆត្រ ឬស្ទឹកត្នោតឲ្យ កាលបើរបស់នោះមិនមាន ក៏លើកជាយសំពត់ឡើងមកបាំងត្រង់មុខ ចំណែកធនញ្ជយ-សេដ្ឋី ដែលជាបិតារបស់នាងវិសាខា បានបញ្ជូនរថទៅទទួល ៥០០ ។ នាងវិសាខា និងបរិវាររបស់នាងបានឡើងជិះលើរថត្រឡប់មកផ្ទះវិញ ។

ចំណែកពួកព្រាហ្មណ៍ទាំង ៨ នាក់ ក៏បានទៅផ្ទះរបស់នាងវិសាខា ព្រមជាមួយនឹងក្បួនរថរបស់នាង ។ គ្រានោះ ធនញ្ជយសេដ្ឋីបានសួរព្រាហ្មណ៍ទាំងនោះថា ពួកលោកអញ្ជើញមកពីក្រុងណា ? ពួកព្រាហ្មណ៍ទាំងនោះឆ្លើយថា បពិត្រលោកមហាសេដ្ឋី ពួកខ្ញុំមកពីផ្ទះលោកសេដ្ឋីនៅក្នុងក្រុងសាវត្ថី ។ ធនញ្ជយសេដ្ឋីសួរថា សេដ្ឋីនោះ មានឈ្មោះអ្វី ? ពួកព្រាហ្មណ៍ឆ្លើយថា ឈ្មោះថា **មិគារសេដ្ឋី** ។ ធនញ្ជយសេដ្ឋីសួរថា បុត្ររបស់លោកសេដ្ឋី មានឈ្មោះអ្វី ? ពួកព្រាហ្មណ៍ឆ្លើយថា ឈ្មោះបុណ្ណវឌ្ឍនកុមារ ។ ធនញ្ជយសេដ្ឋីសួរថា លោកសេដ្ឋីមានទ្រព្យសម្បត្តិប៉ុន្មាន ? ពួកព្រាហ្មណ៍ឆ្លើយថា បពិត្រលោកសេដ្ឋី មិគារសេដ្ឋីមានទ្រព្យ ៤០ កោដិ ។ ធនញ្ជយសេដ្ឋី កាលបានស្តាប់ពាក្យរបស់ព្រាហ្មណ៍នោះហើយ គិតថា ទ្រព្យត្រឹមតែប៉ុណ្ណេះ កាលបើប្រៀបធៀបនឹងទ្រព្យរបស់យើងហើយ ក៏ស្មើនឹងមួយកាកណិក (ទ្រព្យដែលមានតម្លៃស្មើតម្លៃរបស់ដុំសាច់ ល្មមដែលក្អែកនាំយកទៅបាន ជាឈ្មោះមាត្រា ប្រាក់យ៉ាងទាបបំផុត) តែយើងមិនត្រូវការប្រយោជន៍យ៉ាងដទៃទេ ឲ្យបាន

ត្រឹមតែនាងមានត្រកូលស្មើគ្នា ក៏គ្រប់គ្រាន់ណាស់ទៅហើយ ទើបបាន ទទួលទុក ហើយលោកសេដ្ឋីក៏បានធ្វើការទទួលរាក់ទាក់ចំពោះព្រាហ្មណ៍ ទាំងនោះ ដោយឲ្យព្រាហ្មណ៍ទាំងនោះស្នាក់អាស្រ័យនៅ ២ ថ្ងៃហើយ ទើបឲ្យត្រឡប់ទៅវិញ ។ ពួកព្រាហ្មណ៍ទាំង ៨ នាក់នោះ កាលត្រឡប់ទៅ ដល់ក្រុងសាវត្ថីវិញហើយ ក៏បាននាំគ្នាទៅប្រាប់សេចក្ដីដែលគួរត្រេកអរ ឬការសប្បាយចិត្តឲ្យដល់មិគារសេដ្ឋីបានជ្រាបថា ពួកខ្ញុំបានជួបនាង ទារិកា ជាអ្នកដែលមានលក្ខណៈបញ្ចកល្យាណីហើយ ។ មិគារសេដ្ឋី ទើបសួរថា នាងជាកូនក្រមុំរបស់អ្នកណា ? ពួកព្រាហ្មណ៍តបថា នាង ជាកូនក្រមុំរបស់ធនញ្ជយសេដ្ឋី ។ មិគារសេដ្ឋីស្ដាប់ពាក្យនោះហើយ ក៏មានចិត្តត្រេកអរ រួចគិតថា យើងបាននាងទារិកា ដែលជាអ្នកមាន ត្រកូលខ្ពង់ខ្ពស់ ដូចនេះ គួរតែប្រញាប់នាំមកឲ្យបានរហ័ស កាលគិត ឃើញដូច្នេះហើយ ទើបលោកសេដ្ឋីក្រាបបង្គំទូលព្រះបាទបសេនទិ-កោសល ដើម្បីឲ្យស្ដេចយាងទៅក្រុងសាកេតដែរ ។ ព្រះរាជាទ្រង់ ត្រិះរិះថា ត្រកូលធំនេះ យើងនាំមកពីរាជសម្នាក់របស់ព្រះបាទពិម្ពិសារ

នៅក្នុងនគររាជគ្រឹះ ហើយឲ្យនៅក្នុងក្រុងសាកេត យើងគួរនឹងធ្វើការលើកតម្កើងដល់ត្រកូលនោះ កាលទ្រង់ត្រិះរិះដូចនេះហើយ ទើបព្រះអង្គមានព្រះរាជតម្រាស់ថា យើងនឹងទៅដែរ ។ មិគារសេដ្ឋីក្រាបបង្គំទូលថា សូមអរព្រះគុណព្រះមហាករុណាក្រៃលែង ហើយលោកសេដ្ឋីក៏បានបញ្ជូនដំណឹងឲ្យទៅដល់ធនញ្ជយសេដ្ឋីថា កាលខ្ញុំមក សូម្បីព្រះរាជាក៏ទ្រង់ស្ដេចយាងមកដែរ ពួកពលសេនារបស់ព្រះរាជាជាច្រើន លោកអាច ឬមិនអាចក្នុងការទទួលមនុស្សដែលមានចំនួនច្រើនយ៉ាងនេះ ? ចំណែកធនញ្ជយសេដ្ឋី ក៏បញ្ជូនដំណឹងតបទៅវិញថា សូម្បីព្រះរាជាស្ដេចយាងមក ១០ អង្គ ក៏សូមស្ដេចយាងមកចុះ ។ក្នុងគ្រានោះ មិគារសេដ្ឋីក៏បាននាំបុគ្គលទាំងពួងក្នុងក្រុង ដោយបន្សល់ទុកតែអ្នកចាំផ្ទះប៉ុណ្ណោះ ឯពួកគណៈរបស់លោកសេដ្ឋីធ្វើដំណើរទៅទៀតកន្លះយោជន៍ បានដល់ក្រុងសាកេត ក៏ឈប់សម្រាក ហើយបញ្ជូនដំណឹងទៅថា ពួកខ្ញុំមកហើយ ។ ធនញ្ជយសេដ្ឋី ក៏បានរៀបចំបញ្ជូនគ្រឿងបណ្ណាការទៅចំនួនជាច្រើន ( ដើម្បីសម្ដែងការពេញចិត្តទទួលភ្ញៀវ )

ហើយទើបប្រឹក្សានឹងនាងវិសាខាថា ឥឡូវនេះ បានឮថា ឪពុកក្មេក របស់កូន មកជាមួយនឹងព្រះបាទបសេនទិកោសល តើយើងគួររៀបចំ ផ្ទះមួយខ្នងណា សម្រាប់ទទួលឪពុកក្មេក ផ្ទះមួយខ្នងណាសម្រាប់ ថ្វាយព្រះរាជា ផ្ទះមួយខ្នងណាសម្រាប់បុគ្គលទាំងឡាយ មានឧបរាជ ជាដើម ។ គ្រានោះ នាងវិសាខា ដែលជាធីតារបស់ធនញ្ជយសេដ្ឋី ជាអ្នកឆ្លាត ជាអ្នកមានបញ្ញាមុតស្រួចដូចជាពេជ្រ ដែលជាអ្នកបាន តាំងសេចក្ដីប្រាថ្នាទុកមកហើយ អស់មួយសែនកប្ប ជាអ្នកសម្បូរទៅ ដោយអភិនីហារ ទើបបញ្ជាឲ្យពួកទាសកម្មករថា អ្នកទាំងឡាយចូរនាំគ្នា រៀបចំផ្ទះខ្នងឯណោះ ដើម្បីឪពុកក្មេករបស់ខ្ញុំ ផ្ទះខ្នងនោះ ដើម្បីថ្វាយ ព្រះរាជា ផ្ទះខ្នងឯណោះទៀត ដើម្បីជនទាំងឡាយ មានឧបរាជជាដើម ហើយនាងបញ្ជាឲ្យពួកទាសកម្មករទៀតថា ពួកអ្នកប៉ុណ្ណេះនាក់ ចូរធ្វើ វត្ថុដែលគួរធ្វើថ្វាយដល់ព្រះរាជា ពួកអ្នកប៉ុណ្ណេះនាក់នេះ ចូរធ្វើវត្ថុ ដែលគួរធ្វើឲ្យដល់បុគ្គលទាំងឡាយ មានឧបរាជជាដើម ពួកអ្នកប៉ុណ្ណេះ នាក់ ចូរថែរក្សាសូម្បីសត្វពាហនៈទាំងឡាយ មានដំរី និងសេះជាដើម

សូម្បីបុគ្គលទាំងឡាយ មានអ្នកចិញ្ចឹមសេះជាដើម មកដល់ហើយ ប្រាកដជាបានពោលសរសើរ ចំពោះមហោស្រពក្នុងមង្គលការរបស់ យើងមិនខានឡើយ ។ មានពាក្យសួរថា ព្រោះហេតុអ្វី ទើបនាង វិសាខាឲ្យមនុស្សរៀបចំធ្វើយ៉ាងនេះ ? មានពាក្យឆ្លើយថា ព្រោះ នាងវិសាខាគិតថា កុំឲ្យបុគ្គលទាំងឡាយនិយាយថា ពួកយើងបានទៅ ចូលរួមក្នុងមង្គលការរបស់នាងវិសាខាមិនបានអ្វីសោះ រវល់ធ្វើតែកិច្ច ការ មានការចិញ្ចឹមសេះជាដើម មិនមានឱកាសដើម្បីបានដើរទៅមើល ទីនេះ ទីនោះបានសប្បាយសោះ ។

ក្នុងថ្ងៃនោះឯង ធនញ្ជយសេដ្ឋី ដែលជាបិតារបស់នាងវិសាខា បានឲ្យហៅជាងមាស ៥០០ នាក់មកហើយ ប្រាប់ថា ពួកលោកចូរធ្វើ គ្រឿងប្រដាប់ដែលមានឈ្មោះថា **អាវមហាលតាបសាធន៍** ឲ្យដល់ធីតា របស់យើង ហើយប្រាប់ឲ្យយកមាសទឹកដប់មួយពាន់ដុំ ប្រាក់ កែវមណី កែវមុក្តា កែវប្រវាឡ និងពេជ្រជាដើម ដែលសមរម្យនឹងមាសនោះ ។ គ្រានោះ ព្រះរាជាសម្រាកនៅបាន ២-៣ ថ្ងៃ ហើយទ្រង់បញ្ជូនដំណឹងទៅ

ឲ្យដល់ធនញ្ជយសេដ្ឋីថា ប្រសិនបើលោកសេដ្ឋី មិនអាចឧបត្ថម្ភដល់ពួកយើងបានតទៅទៀតទេ ចូរលោកសេដ្ឋីកំណត់ពេលវេលារបស់នាងទារិកា ដែលជាធីតារបស់លោកចុះ ។ ចំណែកធនញ្ជយសេដ្ឋីក៏បានបញ្ជូនដំណឹងទៅក្រាបបង្គំទូលព្រះរាជាវិញថា ពេលនេះជារដូវភ្លៀង នរណាៗ មិនអាចដើរទៅណាបានទេ រហូត ៤ ខែ ការដែលពួកពលរបស់ព្រះករុណាជីវិតតម្កល់លើត្បូង គួរនឹងបានវត្ថុណាៗ វត្ថុនោះៗ ទាំងអស់ជាភារៈរបស់ខ្ញុំព្រះអង្គ ។ ចាប់ផ្តើមអំពីកាលនោះ ក្រុងសាកេតក៏បានជាក្រុងដូចគ្នា មានបុណ្យនក្ខត្តឫក្សជានិច្ច ។ បានមានអ្នករៀបចំផ្កាឈើរបស់ក្រអូប និងគ្រឿងស្លៀកពាក់ជាដើម នាំយកទៅឲ្យដល់ពួកអ្នកទាំងអស់នោះ និងថ្វាយដល់ព្រះរាជាជាដើម ។ ជនទាំងនោះគិតគ្នាថា លោកសេដ្ឋីបានធ្វើសក្ការៈដល់ពួកយើងមួយចំណែក រហូតកន្លងទៅបាន ៣ ខែហើយ ដោយអាការយ៉ាងនេះ តែគ្រឿងប្រដាប់ដែលមានឈ្មោះថា **អាវមហាលតាបសាធន៍** នៅមិនទាន់រួចសោះ ។ អ្នកគ្រប់គ្រងការងារ ប្រាប់ដល់ធនញ្ជយសេដ្ឋីថា បពិត្រលោកសេដ្ឋី

វត្ថុដទៃមិនខ្វះខាតទេ លើកលែងតែអុសសម្រាប់ប្រើចម្អិនអាហារ ។ គ្រានោះ ទើបធនញ្ជយសេដ្ឋី ប្រាប់ដល់ពួកអ្នកគ្រប់គ្រងការងារថា នែអ្នកទាំងឡាយ ពួកអ្នកចូរទៅរុះរើរោងដំរីចាស់ និងផ្ទះចាស់ជាដើម ក្នុងក្រុងនេះ ជញ្ជូនយកឈើនោះមកប្រើក្នុងការចម្អិនអាហារនោះចុះ ។ ( ពួកអ្នកត្រួតត្រាការងារ ក៏បាននាំគ្នាចាត់ចែងក្នុងការរុះរើរោងដំរី និង ផ្ទះចាស់ៗ យកមកធ្វើជាអុស តាមដែលលោកសេដ្ឋីប្រាប់ឲ្យធ្វើ ) ។ បន្ទាប់អំពីនោះកន្លងទៅបានកន្លះខែទៀត ពួកអ្នកត្រួតត្រាការងារ ទើបមកជម្រាបលោកសេដ្ឋីម្តងទៀតថា លោកសេដ្ឋី អុសអស់ទៀត ហើយ ។ គ្រានោះ ទើបធនញ្ជយសេដ្ឋីពោលថា ក្នុងពេលនេះមិនអាច រកអុសបាន ដូច្នេះ ពួកលោកចូរទៅបើកឃ្លាំងសំពត់ទាំងឡាយ យកសំពត់មានសាច់គ្រោតគ្រាត មកមូរធ្វើជាធ្នុង ហើយជ្រលក់ជា មួយខ្លាញ់ក្នុងពាងឲ្យជោក ហើយយកមកប្រើធ្វើជាអុសចម្អិនអាហារ ទៀតចុះ ។ បុគ្គលទាំងនោះ ក៏បាននាំគ្នាធ្វើតាមពាក្យណែនាំរបស់ លោកសេដ្ឋី រហូតអស់កន្លះខែទៀត ។

កាលកន្លងទៅ ៤ ខែហើយ គ្រឿងប្រដាប់ឈ្មោះថា អាវមហាលតាបសាធន៍ទើបរួច ។ ក្នុងគ្រឿងប្រដាប់ឈ្មោះថាអាវមហាលតា-បសាធន៍នោះ មានពេជ្រ ៤ នាឡិ កែវមុក្តា ១១ នាឡិ កែវប្រវាឡ ២០ នាឡិ កែវមណី ៣៣ នាឡិ ។ អាវមហាលតាបសាធន៍នោះ បានសម្រេចដោយកែវទាំងនោះ និងកែវយ៉ាងដទៃទៀត គ្រឿងប្រដាប់ខ្វះមិនបានត្រូវប្រើកែវទេ ព្រោះពួកជាងបានប្រើប្រាក់ជំនួស ។ គ្រឿងប្រដាប់អាវមហាលតាបសាធន៍នេះ កាលបើពាក់ត្រង់ក្បាល រមែងវែងចុះទៅទល់ខ្នងជើង ។ ពួកជាងបានធ្វើឡេវអាវដោយមាស ចំណែករង្វង់ឡេវអាវធ្វើដោយប្រាក់ បានធ្វើឡេវនៅត្រង់កណ្តាលក្បាល ១ នៅត្រង់ត្រចៀក ២ នៅត្រង់-ក ១ នៅត្រង់ជង្គង់ ២ នៅត្រង់កែងដៃ ២ នៅត្រង់ចង្កេះ ២ ។ រោមស្លាបធ្វើដោយមាស គឺស្លាបខាងស្តាំ ៥០០ ស្លាបខាងឆ្វេង ៥០០ ចំពុះធ្វើដោយកែវប្រវាឡ ភ្នែកធ្វើដោយកែវមណីខៀវ.ក និងរង្វង់កន្ទុយ ធ្វើដោយកែវមណី បំពង់រោមធ្វើដោយប្រាក់ ជើងរបស់សត្វក្ងោកធ្វើដោយប្រាក់ ។ សត្វក្ងោកនោះ តាំងនៅលើក្បាល

របស់នាងវិសាខា លក្ខណៈរបស់ក្ងោកប្រាកដហាក់បីដូចជាឈររាំនៅលើកំពូលភ្នំ សំឡេងរបស់បំពង់រោមស្លាប ១០០០ រោម ឮដូចសំឡេងតន្ត្រីទិព្វ និងប្រៀបដូចជាសំឡេងស្គរគឹកកងនៃតន្ត្រី ដែលប្រកបដោយអង្គ ៥ ។ ជនទាំងឡាយចូលទៅជិត ទើបជ្រាបថា ក្ងោកនោះមិនមែនក្ងោកពិតប្រាកដទេ គ្រឿងប្រដាប់អាវមហាលតាបសាធន៍នោះមានតម្លៃ ៩ កោដិកហាបណៈ ។ ធនញ្ជយសេដ្ឋីឲ្យតម្លៃជាង ដែលបានធ្វើនោះមួយសែនកហាបណៈ ។ មានពាក្យសួរថា នាងវិសាខាបានគ្រឿងប្រដាប់អាវមហាលតាបសាធន៍នេះ ព្រោះផលនៃកុសលកម្មអ្វី ? មានពាក្យឆ្លើយថា ព្រោះក្នុងកាលនៃព្រះពុទ្ធសាសនារបស់ព្រះកស្សបសម្ពុទ្ធ នាងវិសាខាធ្លាប់បានថ្វាយចីវរទានដល់ភិក្ខុសង្ឃពីរម៉ឺនរូប ដូច្នេះ ទើបផលនៃចីវរទាននេះ ធ្វើឲ្យនាងបាននូវអាវមហាលតាបសាធន៍ដូច្នេះ ។ ស្ត្រីទាំងឡាយថ្វាយចីវរទាន រមែងប្រសព្វផលដល់ទីបំផុត ដោយគ្រឿងប្រដាប់ឈ្មោះថា អាវមហាលតាបសាធន៍ ។ ចំណែកបុរសទាំងឡាយ កាលថ្វាយចីវរទាន រមែងប្រសព្វផលដល់

ទីបំផុត ដោយបានបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ឬបានបួស ជាឯហិភិក្ខុ ដោយអំណាចបុណ្យនោះ ។ ធនញ្ជយសេដ្ឋីបានធ្វើការត្រៀម ដើម្បីធីតាអស់យ៉ាងនេះហើយ កាលនឹងឲ្យវត្ថុដែលគួរឲ្យដល់ធីតា ទើបឲ្យផ្ទុកកហាបណៈ ៥០០ រទេះ ភាជនៈមាស ៥០០ រទេះ ភាជនៈ ប្រាក់ ៥០០ រទេះ ភាជនៈមាសក្រហម ៥០០ រទេះ ភាជនៈសំរឹទ្ធិ ៥០០ សំពត់ថ្មី ៥០០ រទេះ ទឹកដោះថ្លា ៥០០ រទេះ ប្រេង ឬខ្លាញ់ ៥០០ រទេះ ស្ករអំពៅ ៥០០ រទេះ ស្រូវសាលី ៥០០ រទេះ គ្រឿង ឧបករណ៍ មានទន្គ័ល និងផាលជាដើម ៥០០ រទេះ ។ ធនញ្ជយសេដ្ឋី មានការគិតថា ក្នុងទីកន្លែងដែលធីតារបស់យើងទៅហើយ នាងកុំបាន បញ្ជូនមនុស្សទៅសុំរបស់អ្នកដទៃថា យើងត្រូវសូមរបស់ឈ្មោះនេះ ព្រោះដូច្នោះ ទើបធនញ្ជយសេដ្ឋី ប្រាប់ឲ្យប្រគល់គ្រឿងឧបករណ៍ សព្វគ្រប់ដល់ធីតារបស់ខ្លួន ។ ធនញ្ជយសេដ្ឋី បានឲ្យរថ ៥០០ នឹមទៀត មួយនឹមៗ ឲ្យមានស្រីបរ ដែលជាស្ត្រីប្រដាប់ដោយគ្រឿងប្រដាប់ សព្វគ្រប់ ក្នុងរថនីមួយៗ ៣ នាក់ ថែមទាំងបានឲ្យស្រីអ្នកបម្រើ ១៥០០

នាក់ ដោយប្រាប់ថា ពួកអ្នកប៉ុណ្ណេះ មាននាទីដួតទឹកឲ្យធីតារបស់យើង ពួកអ្នកប៉ុណ្ណេះ មាននាទីរៀបចំអាហារឲ្យបរិភោគ ពួកអ្នកប៉ុណ្ណេះ មាននាទីស្អិតស្អាងខ្លួន ឲ្យដល់ធីតារបស់យើង ។

គ្រានោះ ធនញ្ជយសេដ្ឋីគិតថា យើងនឹងឲ្យគោដល់ធីតារបស់យើង ទើបប្រាប់ដល់អ្នកបម្រើថា ពួកអ្នកចូរទៅបើកទ្វារក្រោលគោបន្តិច ចូរឈរនាំគ្នាកាន់ស្គរ ៣ នៅក្នុងទីកន្លែង ៣ គាវុត ចូរឈរនៅត្រើយទាំងពីរខាង ដោយចំណែកទទឹងក្នុងទីប្រមាណ ១ ឧសភៈ កុំឲ្យហ្វូងមេគោទៅខាងផ្លូវដទៃ កាលមេហ្វូងឈប់ឈរហើយ គប្បីវាយស្គរជាសញ្ញាឡើង ។ បុរសទាំងនោះ កាលបានស្តាប់ពាក្យបញ្ជារបស់លោកសេដ្ឋីដូច្នេះហើយ ក៏បាននាំគ្នាធ្វើតាមយ៉ាងនោះ ។ ពេលដែលហ្វូង មេហ្វូងគោទៅបានកន្លះយោជន៍ ពួកគេក៏បាននាំគ្នាវាយស្គរឲ្យជាសញ្ញាទៀត ។ ប៉ុន្តែក្នុងពេលដែលមេហ្វូងគោទៅបាន ៣ គាវុត ទទឹងប្រមាណ ១ ឧសភៈ ដោយអាការយ៉ាងនេះ ។ ធនញ្ជយសេដ្ឋីបានប្រាប់ឲ្យបិទទ្វារក្រោលគោ ដោយពោលថា ហ្វូងមេគោប៉ុណ្ណេះ

ល្មមហើយដល់ធីតារបស់ខ្ញុំ ពួកអ្នកចូរបិទទ្វារក្រោលគោនោះចុះ ។ កាលបើពួកបុរសទាំងនោះ បាននាំគ្នាបិទទ្វារក្រោលគោហើយ ប៉ុន្តែគោឈ្មោលដែលមានកម្លាំង និងមេគោទាំងឡាយ នៅតែលោតផ្លោះរបងក្រោលគោចេញរត់ទៅតាមទៀត ទាំងនេះកើតមានព្រោះបុណ្យរបស់នាងវិសាខា ។ ក្នុងខណៈដែលបុគ្គលទាំងឡាយនាំគ្នាពាំងគោទុកនោះ ក៏នៅមានគោឈ្មោល ដែលមានកម្លាំង ៦ ម៉ឺនក្បាលទៀត និងមេគោ ៦ ម៉ឺនក្បាល និងកូនគោដែលមានកម្លាំងប្រមាណ ៦ ម៉ឺនក្បាលទៀតចេញរត់ទៅតាម ពួកគោឈ្មោលឧសភៈរបស់មេគោទាំងនោះក៏បានរត់ទៅតាមដែរ ។ មានពាក្យសួរថា គោទាំងឡាយដែលទៅតាមយ៉ាងនេះ ព្រោះផលនៃកុសលកម្មអ្វី ? មានពាក្យឆ្លើយថា ព្រោះផលនៃទាន ដែលនាងវិសាខា បានថ្វាយដល់ភិក្ខុសង្ឃ ។ ដូចមានរឿងពោលទុកថា ក្នុងពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ នាងវិសាខាបានជាព្រះកនិដ្ឋារបស់ព្រះរាជធីតាទាំង ៦ ព្រះអង្គ របស់ព្រះបាទកិកិ ទ្រង់មានព្រះនាមថា **សង្ឃទាសី** កាលទ្រង់ថ្វាយបញ្ចគោរសដល់ភិក្ខុសង្ឃប្រមាណ

ពីរម៉ឺនរូប សូម្បីភិក្ខុសង្ឃ លោកបាននាំគ្នាបិទបាត្រហើយក៏ដោយ ព្រះនាងក៏នៅតែពិតថេរវាចាថា វត្ថុនេះឆ្ងាញ់ វត្ថុនេះគួរឆាន់លោកម្ចាស់ ហើយទ្រង់បានប្រគេនទៅទៀត ។ ព្រោះផលនៃកុសលកម្មនេះ ទើបធ្វើឲ្យគោទាំងនោះ ទោះបីត្រូវមានអ្នកឃាត់រាំងយ៉ាងហ្នឹងក៏ដោយ ក៏នៅបេះតែរត់ចេញទៅទៀត ។

ក្នុងពេលដែលធនញ្ជយសេដ្ឋី ឲ្យទ្រព្យចំនួនប៉ុណ្ណោះដល់នាងវិសាខាហើយ កិរិយារបស់ធនញ្ជយសេដ្ឋីបាននិយាយថា វត្ថុទាំងពួងសម្រាប់កូនស្រីរបស់យើង លោកបានចាត់ចែងរួចហើយ តែអ្នកបម្រើប្រុសស្រី សម្រាប់ជាអ្នកជួយ លោកនៅមិនទាន់បានចាត់ចែងឲ្យទេ ព្រោះហេតុអ្វី ? ធនញ្ជយសេដ្ឋីបានពោលពន្យល់ថា ហេតុដែលមិនបានចាត់ចែង ដើម្បីត្រូវការឲ្យដឹងថា អ្នកដែលស្រឡាញ់កូនស្រីរបស់យើង ព្រោះយើងមិនត្រូវការអ្នកដែលមិនពេញចិត្តបញ្ជូនទៅជាមួយកូនស្រីរបស់យើង តែពេលដែលកូនស្រីរបស់យើង ឡើងជិះយានពាហនៈទៅនោះ ទើបយើងប្រកាសថា អ្នកណាមានបំណងទៅជាមួយនាង

វិសាខា ដែលជាធីតារបស់យើងក៏ចូរទៅចុះ អ្នកដែលមិនមានបំណង កុំចាំបាច់ទៅឡើយ ។ គ្រានោះ ធនញ្ជយសេដ្ឋីគិតថា កូនស្រីរបស់យើង នឹងទៅក្នុងថ្ងៃស្អែកនេះឯង ទើបចូលទៅអង្គុយនៅក្នុងបន្ទប់ ហើយ ឲ្យនាងវិសាខាមកអង្គុយជិត បានពោលអប់រំថា កូន ធម្មតាស្ត្រី ដែលទៅនៅក្នុងត្រកូលរបស់ស្វាមី គួររក្សាមារយាទឲ្យបានយ៉ាងល្អ ។ ចំណែកមិគារសេដ្ឋី ដែលបានអង្គុយនៅក្នុងបន្ទប់ជាប់គ្នានោះដែរ ក៏បានឮពាក្យពោលណែនាំរបស់ធនញ្ជយសេដ្ឋី ។ ចំណែកធនញ្ជយសេដ្ឋី បានពោលប្រៀនប្រដៅនាងវិសាខាយ៉ាងនោះហើយ ជាពិសេសនោះ បានឲ្យឱវាទ ១០ ប្រការថា ១- មិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ ២- មិនគួរនាំភ្លើងខាងក្រៅចូលមកខាងក្នុង ៣-គួរឲ្យមនុស្សដែលគួរ ឲ្យប៉ុណ្ណោះ ៤- មិនគួរឲ្យដល់មនុស្សដែលមិនគួរឲ្យ ៥- គួរឲ្យដល់ មនុស្សដែលគួរឲ្យ និងមិនគួរឲ្យ ៦-គួរអង្គុយឲ្យជាសុខ ៧-គួរបរិភោគ ឲ្យជាសុខ ៨-គួរដេកឲ្យជាសុខ ៩-គួរបម្រើភ្លើង ១០-គួរគោរព ទេវតាខាងក្នុង ។ លុះធនញ្ជយសេដ្ឋីបានឲ្យឱវាទ ១០ យ៉ាងដូច្នេះហើយ

លុះដល់ពេលព្រឹកឡើង ទើបហៅឲ្យទាសកម្មករទាំងអស់មកប្រជុំគ្នា ហើយតាំងកុដុម្ពិកៈ ៨ នាក់ ឲ្យជាអ្នកធានាទទួលនៅក្នុងកណ្ដាលរាជសេនា បានពោលថា ប្រសិនបើកំហុសកើតឡើងដល់ធីតារបស់យើង ក្នុងទីកន្លែងដែលធីតារបស់យើងទៅហើយ ពួកលោកត្រូវជម្រះជួយដោះស្រាយបញ្ហា ទើបប្រដាប់នាងវិសាខាដោយគ្រឿងអាវមហាលតាបសាធន៍ ដែលមានតម្លៃ ៩ កោដិ ទាំងឲ្យប្រាក់ ៥៤ កោដិទៀត ជាតម្លៃលម្អិតខ្ញីមចន្ទន៍ ប្រើក្នុងពេលងូតទឹក ហើយឲ្យនាងវិសាខាឡើងជិះយានពាហនៈ ឲ្យមនុស្សដើរវាយស្គរបង្ហូកប្រកាសក្នុងស្រុកសួយ ១៤ តំបន់ ដែលមួយតំបន់ៗ ធំស្មើនឹងក្រុងអនុរាធបុរី ដែលជាពួកអ្នកស្រុករបស់ខ្លួននៅជុំវិញក្រុងសាកេតថា អ្នកទាំងឡាយដែលមានបំណងទៅជាមួយនឹងធីតារបស់យើង ក៏ចូរទៅចុះ ។ គ្រានោះ អ្នក ១៤ តំបន់ កាលបានឮសំឡេងស្គរ និងស្រែកបង្ហូកប្រកាស ម្នាក់ៗ ក៏គិតថា ពេលដែលនាងម្ចាស់របស់ពួកយើងទៅហើយ ពួកយើងនឹងនៅក្នុងទីនេះ ដើម្បីប្រយោជន៍អ្វី ហើយបាននាំគ្នាចេញទៅ មិនមាននរណាម្នាក់នៅសល់

ឡើយ ។ ចំណែកធនញ្ជយសេដ្ឋី ក៏បានធ្វើសក្ការៈដល់ព្រះរាជា និង មិគារសេដ្ឋីហើយ បានតាមជូនដំណើរនាងវិសាខា និងបុគ្គលទាំងនោះ បន្តិច ។ មិគារសេដ្ឋីក៏បានឡើងទៅអង្គុយនៅក្នុងយានតូច នៅខាង ក្រោយយានទាំងអស់ ពេលនោះបានក្រឡេកឃើញ ពួកបរិវាររបស់ នាងវិសាខាហើយ ទើបសួរថា ពួកនេះជាពួករបស់អ្នកណា ?មានអ្នក ជម្រាបប្រាប់ថា ជាពួកអ្នកបម្រើប្រុស និងពួកអ្នកបម្រើស្រីរបស់កូន ប្រសាលោក ។ មិគារសេដ្ឋីកាលដឹងថា ជាមនុស្សរបស់នាងវិសាខា ទើបពោលថា នរណានឹងអាចចិញ្ចឹមបុគ្គលជាច្រើនប៉ុណ្ណេះបាន ចូរដេញ វាយបុគ្គលទាំងនោះឲ្យត្រឡប់ទៅវិញ ចូរអូសទាញពួកដែលមិនព្រម ត្រឡប់ទៅវិញនោះ ។

ចំណែកនាងវិសាខា កាលបើដឹងដូច្នោះហើយ ទើបពោលថា កុំ កុំហាមបុគ្គលទាំងនេះ ខ្ញុំជាអ្នករ៉ាប់រងក្នុងការចិញ្ចឹមបុគ្គលទាំងនេះ ដោយខ្លួនឯង ។ ទោះបីនាងវិសាខាពោលយ៉ាងនេះហើយក៏ដោយ មិគារសេដ្ឋី ក៏នៅតែពោលថា នាង យើងមិនត្រូវការបុគ្គលទាំងនេះទេ

នរណានឹងចិញ្ចឹមបុគ្គលទាំងនេះបាន ហើយប្រាប់ឲ្យវាយដោយដំបង និងគ្រវែងដោយដុំដីជាដើម ដើម្បីឲ្យបុគ្គលទាំងនោះរត់វិលត្រឡប់ទៅវិញ ។ ហើយនាំយកចំពោះតែពួកដ៏សេសទៅ ដោយគិតថា យើងបានមនុស្សចំនួនប៉ុណ្ណោះទៅក៏ល្មមហើយ ។ លុះដល់ទ្វារក្រុងសាវត្ថីនាងវិសាខាគិតថា យើងនឹងអង្គុយនៅក្នុងយាន ដែលបិទបាំងចូលទៅ ឬនឹងឈរនៅលើរថចូលទៅ ហើយនាងក៏សម្រេចចិត្តថា កាលបើយើងចូលទៅដោយយានដែលបិទបាំង ភាពវិសេសនៃគ្រឿងប្រដាប់អាវមហាលតាបសាធន៍ នឹងមិនប្រាកដ កាលបើនាងនឹងបង្ហាញខ្លួនឲ្យប្រាកដដល់អ្នកក្រុងទាំងអស់ ទើបឈរនៅលើរថចូលទៅកាន់ក្រុង ។ គ្រានោះ អ្នកក្រុងសាវត្ថី កាលបានឃើញសម្បត្តិរបស់នាងវិសាខាហើយ ទើបនិយាយគ្នាថា ស្រីនេះឯង បានឮថា ឈ្មោះ **នាងវិសាខា** សម្បត្តិដូចនេះ សមគួរដល់នាងយ៉ាងពិតប្រាកដ ។ នាងវិសាខាបានចូលទៅកាន់ផ្ទះរបស់មិគារសេដ្ឋី ដោយសម្បត្តិច្រើនយ៉ាង គឺក្នុងថ្ងៃដែលនាងវិសាខាមកដល់ក្រុងសាវត្ថី អ្នកក្រុងទាំងអស់ បានបញ្ជូន

គ្រឿងបណ្ណាការទៅតាមកម្លាំងរបស់ខ្លួន ដោយគិតថា ធនញ្ជយសេដ្ឋី បានធ្វើសក្ការៈជាច្រើនដល់ពួកយើង ដែលទៅដល់ក្រុងរបស់ខ្លួន ។ នាងវិសាខាបានឲ្យចាត់ចែងគ្រឿងបណ្ណាការ ដែលគេជូនមកឲ្យហើយៗ ឲ្យជាប្រយោជន៍គ្រប់យ៉ាងដល់ត្រកូលដទៃៗ ក្នុងក្រុងនោះនុ៎ះឯង ( គឺ របស់ត្រកូលមួយ ឲ្យដល់ត្រកូលមួយទៀត ) នាងបាននិយាយស្តីដោយ ពាក្យដ៏ពីរោះ គួរឲ្យស្រឡាញ់សមរម្យដល់វ័យរបស់បុគ្គលទាំងនោះៗ ថា នាងចូរឲ្យវត្ថុនេះដល់ម្តាយរបស់ខ្ញុំ នាងចូរឲ្យវត្ថុនេះដល់ឪពុក របស់ខ្ញុំ ចូរឲ្យវត្ថុនេះដល់បងប្រុស ប្អូនប្រុសរបស់ខ្ញុំ ចូរឲ្យវត្ថុនេះ ដល់បងស្រី ប្អូនស្រីរបស់ខ្ញុំ ហើយក៏ជូនបណ្ណាការទៅ ។ នាងវិសាខា បានធ្វើឲ្យអ្នកក្រុងទាំងអស់ ឲ្យដូចជាពួកញាតិដោយអាការយ៉ាងនេះ ។ តមកក្នុងវេលាអធ្រាត្រ មេលាជាមេសេះអាជានេយ្យរបស់នាងវិសាខា បានកើតកូន ទើបនាងឲ្យពួកទាសីកាន់ប្រទីបទៅទីនោះ ដោយបានទៅ ដល់ហើយ បានងូតទឹកឧណ្ហ និងលាបប្រេងឲ្យមេលា ហើយទើបនាង ត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ។ ចំណែកមិគារសេដ្ឋីកាលធ្វើ

អាវាហមង្គលដល់បុត្រ ក៏មិនបាននឹកដល់ព្រះមានព្រះភាគ សូម្បីថា ព្រះសម្មាសម្ពុទ្ធប្រថាប់នៅវត្តជិតផ្ទះ ព្រោះគេរាប់អានចំពោះអ្នកបួសអាក្រាត ឬថា ពួកអចេលក៏ជាយូរមកហើយ ទើបគិតថា យើងនឹងធ្វើសក្ការៈដល់លោកម្ចាស់របស់យើង ។ ថ្ងៃមួយ មិគារសេដ្ឋីបានប្រើឲ្យមនុស្សរៀបចំមធុបាយាស ដែលមានទឹកតិចដាក់ក្នុងភាជនៈថ្មីច្រើនរយហើយឲ្យទៅអញ្ជើញពួកអចេលក៍ ( អ្នកបួសអាក្រាត ខាងក្រៅព្រះពុទ្ធសាសនា ) ៥០០ នាក់ កាលចូលទៅដល់ក្នុងផ្ទះហើយ បានបញ្ជូនដំណឹងឲ្យទៅដល់នាងវិសាខាថា សូមឲ្យកូនប្រសារបស់យើង មកថ្វាយបង្គំព្រះអរហន្តរបស់យើងផង ។

នាងវិសាខាជាអរិយសាវិកា គឺនាងបានជាព្រះសោតាបន្ន លុះនាងបានស្ដាប់ពាក្យថា ព្រះអរហន្តទាំងឡាយប៉ុណ្ណោះ ក៏មានចិត្តរីករាយសប្បាយ ក៏បានទៅកាន់ទីកន្លែងឆាន់អាហាររបស់ពួកអចេលក៍ទាំងនោះ កាលនាងបានក្រឡេកឃើញពួកអចេលក៍ទាំងនោះហើយនាងគិតថា ពួកអ្នកទាំងអស់នេះមិនមានហិរិឱត្តប្បៈទាល់តែសោះ ដូចនេះ

មិនមែនជាព្រះអរហន្តទេ ហេតុអ្វី បានជាលោកឪពុកក្មេករបស់យើង ហៅយើងមក ថែមទាំងបានពោលតិះដៀលលោកឪពុកក្មេក ហើយក៏បានត្រឡប់ទៅកាន់លំនៅរបស់ខ្លួនវិញ ។ គ្រានោះ ពួកអចេលក៍កាលឃើញអាការរបស់នាងវិសាខាហើយ ទើបពោលតិះដៀលថា នែលោកសេដ្ឋី លោករកស្ត្រីដទៃមិនបានទេឬ ទើបឲ្យសាវិការបស់ព្រះសមណគោតម ដែលនាងជាស្រីកាឡកណ្ណីចូលមកនៅក្នុងផ្ទះនេះ ? លោកចូរបណ្តេញនាងចេញពីផ្ទះនេះឲ្យឆាប់ទៅ កុំឲ្យនាងនៅតទៅទៀត ។ ពេលនោះ មិគារសេដ្ឋីគិតថា យើងមិនអាចបណ្តេញនាងទៅត្រឹមតែពាក្យរបស់លោកម្ចាស់នេះប៉ុណ្ណោះទេ ព្រោះនាងជាធីតារបស់ត្រកូលខ្ពង់ខ្ពស់ ហើយទើបពោលនឹងអចេលក៍ថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ ធម្មតាក្មេង រមែងធ្វើដឹងខ្លះ មិនដឹងខ្លះ សូមលោកម្ចាស់ទាំងឡាយនៅស្ងៀមសិនចុះ ។ លុះមិគារសេដ្ឋីជូនពួកអចេលក៍ទាំងនោះត្រឡប់ទៅវិញហើយ បានទៅអង្គុយលើអាសនៈដែលមានតម្លៃច្រើន បរិភោគមធុបាយាស ដែលមានទឹកតិច ដាក់ក្នុងថាសមាស ។ ក្នុង

គ្រានោះ មានព្រះថេរៈមួយរូប អ្នកកាន់បិណ្ឌបាតជាវត្ត កំពុងតែចារិកបិណ្ឌបាត បាននិមន្តទៅដល់ត្រង់ផ្ទះរបស់សេដ្ឋី ។ គ្រានោះ នាងវិសាខាកំពុងតែឈរកាន់ផ្ចិតបក់ជូនឪពុកក្មេក បានក្រឡេកឃើញព្រះថេរៈរូបនោះហើយ គិតថា ការប្រាប់ដល់លោកឪពុកក្មេក ជាការមិនសមគួរ ទើបនាងគេចចេញទៅឈរនៅត្រង់កន្លែងមួយទៀត ដោយអាការដើម្បីឲ្យឪពុកក្មេកបានក្រឡេកឃើញព្រះថេរៈដែរ ។ តែមិគារសេដ្ឋីជាមនុស្សល្ងង់ខ្លៅ សូម្បីឃើញព្រះថេរៈហើយ ក៏ក្លែងធ្វើដូចមិនឃើញ ថែមទាំងបានអង្គុយឱនមុខចុះ បរិភោគមធុបាយាសធ្វើមិនដឹងតទៅទៀត ។ គ្រានោះ នាងវិសាខាដឹងថា សូម្បីបានក្រឡេកឃើញព្រះថេរៈហើយ នៅតែធ្វើដូចមិនដឹង ទើបនាងពោលថា សូមនិមន្តលោកម្ចាស់ទៅខាងមុខទៀតចុះ ត្បិតលោកឪពុកក្មេករបស់ខ្ញុំកំពុងតែបរិភោគអាហារចាស់ ។ ពេលនោះ មិគារសេដ្ឋីឮដូច្នោះហើយ ដោយបានអត់សង្កត់ចិត្តទុក តាំងអំពីពេលដែលពួកនិគ្រន្ថនិយាយប្រាប់ម្តងរួចមកហើយ តែក្នុងខណៈដែលនាងវិសាខា ដែលបានពោលថា លោកឪពុកក្មេករបស់ខ្ញុំ កំពុងតែបរិភោគ

អាហារចាស់ប៉ុណ្ណោះ ទើបលោកដាក់ដៃចុះឈប់ទទួលទាន ហើយពោលថា ពួកនាងចូរយកបាយមធុបាយាសនេះចេញពីទីនេះភ្លាម ហើយចូរប្រញាប់ដេញស្រីនេះចេញពីផ្ទះភ្លាមដែរ ព្រោះស្រីនេះបាននិយាយថា យើងទទួលទានអាហារចាស់ ក្នុងវេលាព្រឹកព្រលឹមនេះ ។

បណ្តាទាសៈ និងកម្មករទាំងអស់ក្នុងផ្ទះនោះ សុទ្ធតែជាមនុស្សរបស់នាងវិសាខាទាំងអស់ ទើបមិនមាននរណាហ៊ានចូលទៅជិត តើនរណានឹងហ៊ានចូលទៅចាប់ដៃ ឬចាប់ជើងរបស់នាងវិសាខា សូម្បីអ្នកដែលអាចហៅថានាងក៏មិនមានទៅហើយ ( មានតែអ្នកដែលហៅថាអ្នកម្ចាស់ប៉ុណ្ណោះ ) ។ គ្រានោះ នាងវិសាខា បានស្តាប់ពាក្យពោលរបស់ឪពុកក្មេកដូច្នោះហើយ ទើបពោលថា លោកឪពុក ខ្ញុំមិនចេញទៅដោយហេតុត្រឹមប៉ុណ្ណោះទេ ។ ខ្ញុំមិនមែនអ្នកដែលលោកឪពុកនាំមកដូចនាងកុម្ភទាសី ( ទាសីអ្នកប្រើក្អមដងទឹក ) មកពីកំពង់ទឹក ធម្មតាធីតារបស់មាតាបិតា ដែលនៅមានជីវិតរស់នៅ នឹងមិនចេញទៅដោយហេតុត្រឹមតែប៉ុណ្ណោះទេ ។ ព្រោះពេលដែលខ្ញុំមកទីនេះ លោកឪពុក

របស់ខ្ញុំបានហៅកុដុម្ពិកៈ ៨ នាក់ មកប្រគល់ឲ្យមើលការខុសត្រូវចំពោះខ្ញុំថា ប្រសិនបើកំហុសកើតឡើងដល់ធីតារបស់យើង ពួកលោកត្រូវជម្រះសាកសួរ ឬដោះស្រាយ ។ ដោយហេតុនេះឯង សូមលោកឪពុកក្មេក ឲ្យហៅពួកអ្នកទាំងអស់នោះមក ហើយឲ្យសាកសួរជម្រះកំហុសរបស់ខ្ញុំចុះ ។ ពេលនោះ មិគារសេដ្ឋីគិតថា នាងវិសាខានេះនិយាយត្រូវហើយ ទើបបានឲ្យហៅកុដុម្ពិកៈទាំង ៨ នាក់នោះមកហើយប្រាប់ថា នាងវិសាខានេះបានថាយើងអង្គុយទទួលបាយមធុបាយាសដែលមានទឹកតិចក្នុងថាសមាស ក្នុងពេលធ្វើមង្គលថា បរិភោគអាហារចាស់ ពួកលោកចូរលើកកំហុសរបស់នាងវិសាខាឡើងមកពិចារណាហើយចាប់ទាញនាងចេញពីផ្ទះរបស់យើងភ្លាម ។ លំដាប់នោះ ពួកកុដុម្ពិកៈសាកសួរនាងវិសាខាថា យ៉ាងនេះពិតមែនឬនាងម្ចាស់ ? នាងវិសាខាតបថា ខ្ញុំមិនបាននិយាយយ៉ាងនោះទេ តែកាលដែលមានព្រះថេរៈមួយរូប លោកបាននិមន្តមកបិណ្ឌបាត លោកម្ចាស់អង្គនោះ បានឈរនៅត្រង់ផ្ទះរបស់លោកឪពុកក្មេកខ្ញុំ ដោយគាត់កំពុងតែទទួលទានអាហារ

មិនបានយកចិត្តទុកដាក់ចំពោះព្រះថេរៈរូបនោះ ទាំងដែលបានឃើញហើយ ខ្ញុំក៏គិតថា លោកឪពុកក្មេករបស់ខ្ញុំ មិនធ្វើបុណ្យទុកក្នុងអត្តភាពនេះតទៅទៀតសោះ គិតតែបរិភោគបុណ្យចាស់តែប៉ុណ្ណោះ ។ ទើបខ្ញុំបានពោលថា សូមលោកម្ចាស់និមន្តទៅខាងមុខចុះ ព្រោះឪពុកក្មេករបស់ខ្ញុំព្រះករុណា កំពុងតែបរិភោគអាហារចាស់ កំហុសរបស់ខ្ញុំនឹងមានព្រោះហេតុនេះឬ ? គ្រានោះ ទើបពួកកុដុម្ពិកៈពោលនឹងមិគារសេដ្ឋីថា លោកសេដ្ឋី កំហុសព្រោះហេតុយ៉ាងនេះមិនមានដល់ធីតារបស់ពួកខ្ញុំទេ នាងពោលអ៊ីចឹងត្រូវហើយ ព្រោះហេតុអ្វីលោកសេដ្ឋីបានទៅជាខឹងក្រោធទៅវិញ ។ ពេលនោះ មិគារសេដ្ឋីពោលថា នែអស់លោកកុដុម្ពិកៈទាំងឡាយ កំហុសក្នុងរឿងនេះក៏ចាត់ទុកថាគ្មានទៅចុះ ប៉ុន្តែថ្ងៃមួយក្នុងពេលកណ្តាលអធ្រាត្រនាងវិសាខា មានអ្នកបម្រើប្រុសស្រីហែហមបានទៅក្រោយផ្ទះធ្វើអ្វី ? ទើបពួកកុដុម្ពិកៈទាំងនោះ សាកសួរនាងវិសាខាថា ពិតយ៉ាងនោះមែនឬនាងម្ចាស់ ? នាងវិសាខាតបថា បពិត្រលោកកុដុម្ពិកៈ ខ្ញុំមិនបានទៅដោយហេតុដទៃ ក្រៅអំពីទៅមើលមេលា

ដែលជាមេសេះអាជានេយ្យកើតកូននៅក្បែរផ្ទះនេះ ខ្ញុំគិតថា បើយើង មិនយកចិត្តទុកដាក់នូវធុរៈនេះ ដោយអង្គុយនៅស្ងៀមនោះ មិនសម គួរទេ កាលគិតឃើញដូច្នេះហើយ ទើបឲ្យមនុស្សកាន់ប្រទីបទៅជាមួយ នឹងអ្នកបម្រើ កាលធ្វើការរក្សាមេលា ដែលកើតកូនហើយ ក៏ត្រឡប់ មកវិញ តើក្នុងរឿងនេះ ខ្ញុំនឹងមានកំហុសដូចម្ដេច ? ពួកកុដុម្ពិកៈ បានពោលជាមួយនឹងមិគារសេដ្ឋីថា បពិត្រលោកសេដ្ឋី ធីតារបស់ ពួកខ្ញុំបានធ្វើវត្ថុដែលពួកអ្នកបម្រើក្នុងផ្ទះរបស់លោកគួរធ្វើ តែលោក នៅតែថាមានកំហុសក្នុងហេតុនេះទៀតឬ ? ពេលនោះ មិគារសេដ្ឋី ពោលថា បពិត្រលោកកុដុម្ពិកៈទាំងឡាយ សូម្បីក្នុងផ្ទះនេះមិនមានកំហុស ក៏ណ្ហើយចុះ តែថា បិតារបស់នាងវិសាខា កាលនឹងប្រៀនប្រដៅនាង វិសាខា ក្នុងពេលដែលមុនមកក្នុងទីនេះ បានឲ្យឱវាទ ១០ ប្រការ ដែលមានសេចក្ដីលាក់លៀមក្នុងរឿងនោះ ខ្ញុំមិនយល់សេចក្ដីនៃឱវាទ នោះទេ នាងចូរប្រាប់សេចក្ដីនៃឱវាទទាំងនោះដល់ខ្ញុំ តាមដែលបិតា របស់នាងប្រៀនប្រដៅផងចុះ ។

ចុះត្រង់ពាក្យដែលថា កូនមិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ ពួកយើងមិនអាចដែលថា មិនត្រូវឲ្យភ្លើងដល់ផ្ទះដែលនៅជិតខាងគ្នា ដែលធ្លាប់មានការស្និទ្ធស្នាលទាំងពីរខាងបានឬ ? ពួកកុដុម្ពិកៈសួរនាងវិសាខាថា ពិតយ៉ាងនោះមែនឬ នាងម្ចាស់ ?នាងវិសាខាពោលតបថា លោកឪពុករបស់ខ្ញុំ មិនបាននិយាយសំដៅយកហេតុ យ៉ាងនោះទេ តែបាននិយាយសំដៅយកហេតុយ៉ាងនេះថា កូន កូនបានឃើញកាព មិនល្អរបស់លោកឪពុកក្មេក ម្ដាយក្មេក និងស្វាមីរបស់កូនហើយ កូនកុំនាំយកទៅនិយាយខាងក្រៅ គឺផ្ទះអ្នកដទៃៗ ព្រោះថា ភ្លើងដូចគ្នានឹងភ្លើងបែបនេះមិនមាន ។ គ្រានោះ ទើបមិគារសេដ្ឋី ពោលថា ប្រការនេះសូមលើកទុកសិនចុះ តែបិតារបស់នាងវិសាខាបានពោលថា មិនគួរនាំភ្លើងខាងក្រៅចូលមកខាងក្នុង ប្រសិនបើភ្លើងក្នុងផ្ទះរលត់ ពួកយើងមិនអាចដើម្បីនឹងទៅនាំយកភ្លើងពីខាងក្រៅ ចូលមកខាងក្នុងផ្ទះបានឬ ? ពួកកុដុម្ពិកៈទាំងនោះ បានសាកសួរនាងវិសាខាថា យ៉ាងនោះពិតមែនឬនាងម្ចាស់ ? នាងវិសាខាតបថា លោកឪពុករបស់ខ្ញុំ មិនបាន

និយាយសំដៅយកហេតុយ៉ាងនោះទេ តែបាននិយាយសំដៅយកហេតុ ដូច្នេះថា ប្រសិនបើស្ត្រី ឬបុរសទាំងឡាយនៅក្នុងផ្ទះរបស់កូននិយាយ តិះដៀលឪពុកក្មេក ម្ដាយក្មេក និងប្ដីរបស់កូនហើយ កូនកុំនាំយកពាក្យ សម្ដីរបស់អ្នកទាំងនោះមកនិយាយប្រាប់ថា មានមនុស្សឈ្មោះនេះ បាននិយាយថាឲ្យលោកយ៉ាងនេះ យ៉ាងនោះ ព្រោះថា ភ្លើងដូចគ្នា នឹងភ្លើងនេះមិនមានឡើយ ។ នាងវិសាខាបានរួចទោសព្រោះហេតុ យ៉ាងនេះ យ៉ាងណាមិញ សូម្បីក្នុងពាក្យដ៏សេស នាងក៏បានរួចផុត ពីការដាក់ទោស ឬយកកំហុស ដោយនាងបានអធិប្បាយសេចក្ដីក្នុង ឱវាទរបស់លោកសេដ្ឋីធនញ្ជ័យ ដែលត្រូវជាបិតាបង្កើត ដែលបាន ប្រៀនប្រដៅលើកមកពន្យល់ ឲ្យលោកឪពុកក្មេកបានយល់តទៅនេះថា ក្នុងឱវាទទាំងនោះ ប្រការដទៃៗ មានពាក្យអធិប្បាយដូចនេះ ពាក្យ ដែលធនញ្ជយសេដ្ឋី បានពោលប្រដៅនាងវិសាខាថា កូន កូនគួរឲ្យ មនុស្សទាំងឡាយ ដែលគួរឲ្យប៉ុណ្ណោះ ពាក្យនេះមានសេចក្ដីថា មនុស្សណា មកខ្ចីគ្រឿងប្រើប្រាស់របស់ផ្សេងៗ ទៅហើយ នឹងនាំយក

មកឲ្យវិញ ទើបគួរឲ្យដល់មនុស្សនោះ ។ ពាក្យថា មិនគួរឲ្យដល់អ្នកដែលមិនគួរឲ្យ សេចក្តីថា មនុស្សណាមកខ្ចីគ្រឿងប្រើប្រាស់ហើយមិនយកមកឲ្យវិញទេ មិនគួរឲ្យដល់មនុស្សនោះ ។ ពាក្យថា គួរឲ្យដល់មនុស្សដែលគួរឲ្យ និងមិនគួរឲ្យ សេចក្តីថា កាលបើញាតិ និងមិត្រដែលទីទ័លក្រមកដល់ហើយ បុគ្គលទាំងនោះអាចយកមកឲ្យវិញឬក៏មិនយកមកឲ្យវិញក៏ដោយ ក៏គួរដល់ញាតិ និងមិត្រទាំងនោះដែរ ។ ពាក្យថា គួរអង្គុយនៅជាសុខ សេចក្តីថា ការអង្គុយក្នុងទីដែលមើលឃើញឪពុកក្មេក ឬម្តាយក្មេក និងប្តី ហើយត្រូវក្រោកឡើង មិនគួរអង្គុយ ( គឺអង្គុយហើយ នឹងមិនមានសេចក្តីសុខ ព្រោះត្រូវក្រោករឿយៗ ) ។ ពាក្យថា គួរបរិភោគឲ្យជាសុខ សេចក្តីថា មិនគួរបរិភោគមុនឪពុកក្មេក ម្តាយក្មេក និងប្តី គួរមើលលោកទាំងនោះសិន មើលថាលោកទាំងនោះគ្រប់ៗ គ្នា បានអាហារហើយឬនៅ ហើយទើបខ្លួនឯងបរិភោគក្នុងពេលជាខាងក្រោយ ។ ពាក្យថា គួរដេកឲ្យជាសុខ សេចក្តីថា មិនគួរចូលដេកមុនឪពុកក្មេក ម្តាយក្មេក និងប្តី គួរធ្វើវត្តប្រតិបត្តិដែល

ជានាទីរបស់ខ្លួន ដល់លោកទាំងនោះសិន ហើយទើបខ្លួនឯងគួរចូលទៅដេកក្នុងពេលជាខាងក្រោយ ។ ពាក្យថា គួរបម្រើភ្លើង សេចក្តីថា គួរឃើញលោកឪពុកអ្នកម្តាយ និងប្តី ដូចគ្នានឹងគំនរភ្លើង ឬដូចស្តេចនាគដូច្នោះ ។ ពាក្យថា គួរគោរពទេវតាខាងក្នុង សេចក្តីថា គួរឃើញឪពុកក្មេក ម្តាយក្មេក និងប្តី ដូចគ្នានឹងទេវតា ។

ពេលនោះ មិគារសេដ្ឋីបានស្តាប់សេចក្តីនៃឱវាទទាំង ១០ ប្រការយ៉ាងនេះរួចហើយ មិនឮពាក្យឆ្លើយតប ទើបអង្គុយឱនមុខនៅស្ងៀមឈឹង ។ គ្រានោះ ទើបពួកកុដុម្ពិកៈសួរមិគារសេដ្ឋីថា បពិត្រលោកសេដ្ឋី ធីតារបស់ពួកខ្ញុំ នៅមានកំហុសយ៉ាងដទៃទៀតដែរឬទេ ? មិគារសេដ្ឋីតបថា បពិត្រលោកកុដុម្ពិកៈទាំងឡាយ កំហុសយ៉ាងដទៃទៀត មិនមានឡើយ ។ ទើបពួកកុដុម្ពិកៈទាំងនោះ សួរថា កាលបើដូច្នោះ ហេតុអ្វីទើបលោកសេដ្ឋីឲ្យបណ្តេញនាង ដែលជាអ្នកមិនមានកំហុសឲ្យចេញអំពីផ្ទះ ដោយមិនមានកំហុសសោះ ។ កាលបើពួកកុដុម្ពិកៈនិយាយជាមួយនឹងមិគារសេដ្ឋីដូច្នេះហើយ នាងវិសាខាក៏បាននិយាយឡើងថា

បពិត្រលោកកុដុម្ពិកៈទាំងឡាយ កាលបើខ្ញុំនៅតទៅទៀត មិនសមគួរ ឡើយក៏ពិតមែន តែពេលដែលខ្ញុំមុននឹងមក លោកឪពុករបស់ខ្ញុំបាន ប្រគល់ខ្ញុំទុកនឹងពួកលោក ដើម្បីត្រូវការសោកសួរជម្រះកំហុសរបស់ខ្ញុំ ពួកលោកក៏បានជ្រាបសេចក្តីដែលខ្ញុំមិនមានកំហុសហើយ ឥឡូវនេះ ខ្ញុំសមគួរនឹងទៅបានហើយ ទើបនាងបញ្ជាឲ្យអ្នកបម្រើទាំងបុរសទាំង ស្ត្រីថា ពួកអ្នកចូរជួយគ្នាចាត់ចែងវត្ថុ មានយានពាហនៈជាដើម ។ ចំណែកមិគារសេដ្ឋី បានបបួលពួកកុដុម្ពិកៈទាំងនោះទុក ហើយនិយាយ អង្វរចំពោះនាងវិសាខាថា នែនាង ពុកនិយាយទៅ ព្រោះពុកមិនដឹង សូមកូនអត់ទោសឲ្យពុកផងចុះ ។ ទើបនាងវិសាខាពោលថា បពិត្រ លោកឪពុក ខ្ញុំអត់ទោសដែលគួរ លើកទោសឲ្យលោកឪពុកដោយ សុទ្ធចិត្ត តែខ្ញុំជាធីតារបស់ត្រកូលដែលមានសេចក្តីជ្រះថ្លា នៅក្នុង ព្រះពុទ្ធសាសនា ខ្ញុំមិនអាចវៀរចាកភិក្ខុសង្ឃហើយរស់នៅបានទេ ប្រសិនបើខ្ញុំបានប្រព្រឹត្តប្រតិបត្តិភិក្ខុសង្ឃ តាមសេចក្តីពេញចិត្តរបស់ ខ្ញុំៗ ក៏នឹងនៅតទៅទៀត ។ គ្រានោះមិគារសេដ្ឋីបានពោលអនុញ្ញាតថា

នាងចូរប្រព្រឹត្តប្រតិបត្តិ ទំនុកបម្រុងសមណៈរបស់កូនតាមការពេញចិត្តចុះ ។ នាងវិសាខា កាលបានទទួលការអនុញ្ញាតពីឪពុកក្មេកហើយ ទើបប្រើមនុស្សឲ្យទៅក្រាបទូលនិមន្តព្រះភគវា ដើម្បីឲ្យស្តេចចូលមកកាន់និវេសន៍ក្នុងថ្ងៃស្អែក ។ ចំណែកពួកអចេលក៏បានឮថា ព្រះមុនីស្តេចយាងទៅកាន់ផ្ទះរបស់មិគារសេដ្ឋី ទើបទៅអង្គុយព័ទ្ធជុំវិញផ្ទះ ។ កាលនាងវិសាខាបានរៀបចំចង្ហាន់រួចហើយ ក៏បានបញ្ជូនដំណឹងឲ្យទៅដល់មិគារសេដ្ឋីថា ខ្ញុំបានរៀបចំគ្រឿងសក្ការៈគ្រប់សព្វបរិបូណ៌ហើយ សូមអញ្ជើញលោកឪពុកក្មេករបស់ខ្ញុំមកអង្គាសចង្ហាន់ ថ្វាយដល់ព្រះលោកនាថ និងភិក្ខុសង្ឃ ។

គ្រានោះ ពួកអាជីវក បានហាមមិគារសេដ្ឋីថា នែគហបតីលោកកុំទៅរកព្រះសមណគោតមឡើយ ។ មិគារសេដ្ឋីបានតបទៅកូនប្រសាវិញថា ចូរកូនអង្គាសចង្ហាន់ថ្វាយដល់ព្រះមហាវីរៈ និងភិក្ខុសង្ឃដោយខ្លួនឯងចុះ ឪពុកមិនបានទៅទេ ។ នាងវិសាខា ក៏បានអង្គាសភត្តាហារប្រគេនដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន កាលបើ

រៀបចំក្នុងការអង្គាសកត្តាហាររួចហើយ ទើបនាងជូនដំណឹងទៅទៀតថា សូមអញ្ជើញលោកឪពុកមកស្តាប់ធម្មកថាផង ។ គ្រានោះ ទើបមិគារ-សេដ្ឋីគិតថា ការដែលយើងមិនទៅក្នុងគ្រានេះ មិនសមគួរយ៉ាងក្រៃលែង ក៏នឹកចង់ទៅស្តាប់ធម៌ដែរ ពេលនោះ ពួកអាជីវកក៏បានហាមទៀតថា បើលោកទៅស្តាប់ធម៌របស់ព្រះសមណគោតមហើយនោះ លោកចូរអង្គុយនៅខាងក្រៅវាំងនន ថាហើយ ពួកអាជីវកបានចងវាំងននទុកជាមុនៗ ពេលដែលមិគារសេដ្ឋីទៅដល់ ។ មិគារសេដ្ឋីក៏បានទៅអង្គុយខាងក្រៅវាំងនន តាមពាក្យប្រាប់របស់ពួកអាជីវកមែន ។ គ្រានោះ ព្រះបរមសាស្តាត្រាស់ថា លោកអង្គុយនៅខាងវាំងនន ឬខាងក្រៅជញ្ជាំងផ្ទះរបស់អ្នកដទៃក៏ដោយ ឬក៏ត្រើយម្ខាងភ្នំ ឬមួយនៅខាងក្រៅចក្កវាឡក៏ដោយ តថាគតអាចឲ្យអ្នកស្តាប់ឮ សំឡេងរបស់តថាគតបាន ហើយទើបព្រះសក្យមុនីទ្រង់ចាប់ផ្តើមសម្តែងអនុបុព្វីកថា គឺពាក្យដែលពោលទៅតាមលំដាប់ ដើម្បីទ្រង់សម្តែងធម៌ហាក់បីដូចទ្រង់ចាប់ដើមព្រីងមួយដើមធំអង្រួន ឬហាក់បីដូចធ្វើភ្លៀង គឺអមតធម៌ធ្លាក់ចុះ

មក ។ កាលព្រះបរមគ្រូ ទ្រង់កំពុងសម្តែងព្រះធម៌ មនុស្សទាំងឡាយ ដែលឈរនៅខាងមុខ ឬឈរនៅខាងក្រោយ ឈរនៅត្រើយនៃចក្កវាឡ រយពាន់ចក្កវាឡ ឬឈរនៅព្រហ្មលោកជាន់អកនិដ្ឋក្តី រមែងពោលថា ព្រះទសពល រមែងទតឃើញយើងតែម្នាក់ ទ្រង់ទេសនាប្រោសយើងតែម្នាក់ ។ ជាការពិតណាស់ ព្រះមានជោគ ដូចជាទតមើលអ្នកនោះៗ ដូចជាត្រាស់នឹងអ្នកនោះនៅចំពោះមុខតែម្តង ។ ដូចបានឮមកថា ព្រះពុទ្ធទាំងឡាយ ឧបមាដូចព្រះចន្ទ ធម្មតាព្រះចន្ទ ដែលតាំងនៅក្នុងកណ្តាលផ្ទៃមេឃ រមែងប្រាកដដល់សត្វទាំងពួងថា ព្រះចន្ទនៅលើក្បាលរបស់យើង យ៉ាងណាមិញ ព្រះពុទ្ធទាំងឡាយ រមែងប្រាកដដូចជា ទ្រង់គង់ប្រថាប់ឈរនៅត្រង់ចំពោះមុខនៃសត្វលោកទាំងឡាយ មិនថាអ្នកនៅទីណាមួយទេ ដូច្នោះដែរ ។ បានឮថា នេះជាផលនៃទានដែលព្រះពុទ្ធទាំងឡាយ កាលនៅជាព្រះពោធិសត្វ ទ្រង់បានកាត់ព្រះសិរដែលប្រដាប់ហើយឲ្យជាទាន ទ្រង់ខ្វេះភ្នែកឲ្យជាទាន ទ្រង់កាត់បេះដូងឲ្យជាទាន ទ្រង់បរិច្ចាគព្រះឱរស ព្រះរាជធីតាឲ្យជាទាន ទ្រង់បរិច្ចាគ

ព្រះនាងមទ្រី ដើម្បីឲ្យជាទាសៈរបស់អ្នកដទៃ ។

កាលព្រះសាស្តា ទ្រង់សម្តែងធម៌ទេសនា ផ្លាស់ប្តូរទីកន្លែងធម៌ ។ ចំណែកមិគារសេដ្ឋី ដែលអង្គុយនៅខាងក្រៅវាំងននទនោះ ក៏បានតាំងនៅក្នុងសោតាបត្តិផល ដែលប្រដាប់ដោយន័យមួយពាន់ន័យ ហើយជាអ្នកប្រកបដោយអចលសទ្ធា គឺការជឿដែលមិនកម្រើក ជាអ្នកមិនមានសេចក្តីសង្ស័យក្នុងព្រះរតនត្រ័យ ទើបលើកជាយវាំងននឡើងយកមាត់បៀមសុដនរបស់នាងវិសាខា ដែលជាកូនប្រសាស្រី ថែមទាំងតាំងនាងវិសាខាទុកក្នុងភាពជាម្តាយ ដោយពោលថា នាងចូរជាម្តាយរបស់ខ្ញុំ ចាប់តាំងអំពីថ្ងៃនេះទៅ ។ ចាប់ពីពេលនោះមក នាងវិសាខាមានឈ្មោះថា **មិគារមាតា** មានសេចក្តីថា នាងជាមាតារបស់មិគារសេដ្ឋី ។ កាលមិគារសេដ្ឋីលែងដោះរបស់នាងហើយ បានចូលទៅក្រាបចុះទៀបព្រះបាទរបស់ព្រះមហាមុនី បានប្រេបាច់ព្រះបាទដោយដៃ និងជញ្ជក់ព្រះបាទដោយមាត់ ថែមទាំងបានប្រកាសឈ្មោះឡើង ៣ ដងថា ខ្ញុំព្រះអង្គឈ្មោះមិគារៈ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន

ខ្ញុំព្រះអង្គមិនដឹង រហូតមកដល់អស់កាលយូរត្រឹមប៉ុណ្ណោះថា ទានដែលបុគ្គលធ្វើហើយ ក្នុងព្រះពុទ្ធសាសនានេះឲ្យមានផលច្រើន ខ្ញុំព្រះអង្គទើបតែជ្រាបផលនៃទានក្នុងពេលឥឡូវនេះ ព្រោះកូនប្រសាស្រីរបស់ខ្ញុំព្រះអង្គៗ ជាអ្នករួចផុតចាកទុក្ខហើយ ក្នុងអបាយទាំងពួង កូនប្រសាស្រីនាងបានចូលមកកាន់ផ្ទះរបស់ខ្ញុំព្រះអង្គដើម្បីជាប្រយោជន៍ ដើម្បីចិត្តមេត្តា ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ ហើយបានពោលគាថានេះថា

ខ្ញុំព្រះអង្គនេះ រមែងដឹងទូទៅដល់ទាន ដែលបុគ្គលឲ្យហើយក្នុងខេត្តដែលបុគ្គលឲ្យហើយ មានផលច្រើនក្នុងថ្ងៃនេះ កូនប្រសាស្រីជាមនុស្សល្អ របស់ខ្ញុំព្រះអង្គមកកាន់ផ្ទះនេះ ដើម្បីជាប្រយោជន៍ដល់ខ្ញុំព្រះអង្គដោយពិត ។

គ្រានោះ នាងវិសាខា បានក្រាបទូលនិមន្តព្រះសាស្តា ដើម្បីទទួលចង្ហាន់ក្នុងថ្ងៃស្អែកទៀត សូម្បីក្នុងថ្ងៃស្អែកឡើង ម្តាយក្មេករបស់នាងវិសាខា ក៏បានសម្រេចសោតាបត្តិផល ជាព្រះអរិយបុគ្គលថ្នាក់ដំបូងនៅក្នុងព្រះសាសនានេះដែរ ។ ចាប់តាំងអំពីនោះទៅផ្ទះរបស់

លោកសេដ្ឋី បានបើកទ្វារដើម្បីព្រះលោកនាថ ។ មិគារសេដ្ឋីគិតថា កូនប្រសារបស់យើងមានឧបការៈចំពោះយើងច្រើនណាស់ យើងនឹងធ្វើរបស់សំណាញចិត្តឲ្យនាង ព្រោះគ្រឿងប្រដាប់របស់នាងធ្ងន់ណាស់ មិនអាចប្រដាប់អស់កាលជានិច្ចបាន យើងនឹងឲ្យជាងធ្វើគ្រឿងប្រដាប់បែបស្រាលៗ ឲ្យដល់នាង ដែលអាចប្រដាប់បានគ្រប់ឥរិយាបថទាំងពេលយប់ និងពេលថ្ងៃ កាលលោកគិតឃើញដូច្នេះហើយ ទើបឲ្យជាងធ្វើគ្រឿងប្រដាប់ឈ្មោះថា **ឃនមដ្ឋក:** មានតម្លៃមួយសែនកហាបណៈ ។ កាលបើគ្រឿងប្រដាប់នោះធ្វើរួចស្រេចហើយ ទើបមិគារសេដ្ឋីនិមន្តភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដើម្បីប្រគេនចង្ហាន់ កាលចាត់ចែងចង្ហាន់រួចស្រេចហើយ ឲ្យនាងវិសាខាងូតទឹកក្រអូប ១៦ ក្អម ឲ្យនាងឈរនៅត្រង់ព្រះភក្ត្ររបស់ព្រះសាស្តា ឲ្យថ្វាយបង្គំព្រះមហាវីរៈហើយ ។ ព្រះមហាមុនី ទ្រង់ធ្វើការអនុមោទនាស្រេច ទើបស្តេចយាងចៀសចេញទៅ ។ ចាប់ផ្តើមអំពីកាលនោះមក នាងវិសាខា ពេលដែលធ្វើបុណ្យផ្សេងៗ មានទានជាដើម បានទទួលពរ ៨ ប្រការ ពីសម្មាក់

ព្រះសម្ពុទ្ធ នាងប្រាកដហាក់បីដូចចន្ទលេខា ( វង់ព្រះចន្ទ ) នៅក្នុងផ្ទៃមេឃ ថែមទាំងនាងដល់នូវភាពចម្រើនដោយបុត្រា និងបុត្រីទៀតផង ។ បានដឹងមកថា នាងវិសាខាមានកូនប្រុស ១០ នាក់ កូនស្រី ១០ នាក់ ។ ក្នុងបណ្តាកូនប្រុសស្រីទាំងនោះ ម្នាក់ៗ មានកូនប្រុស ១០ នាក់ កូនស្រី ១០ នាក់ ។ ចំណែកចៅរបស់នាងវិសាខា ម្នាក់ៗ មានកូនប្រុស ១០ កូនស្រី ១០ ។ ដោយន័យដូចពោលមកនេះ នាងវិសាខាមានកូន ចៅ និងចៅទួតតៗ គ្នាទៅដល់ ៨៤២០ នាក់ ។ នាងវិសាខាមានអាយុបាន ១២០ ឆ្នាំហើយក៏ដោយ តែសក់សូម្បីស្កូវមួយសរសៃក៏មិនមានដែរ នាងប្រាកដដូចក្មេងស្រី ដែលនៅក្នុងបឋមវ័យ ១៦ ឆ្នាំជានិច្ច ។ បុគ្គលទាំងឡាយ កាលក្រឡេកឃើញនាងវិសាខាដែលមានបុត្រ និងចៅជាបរិវារដើរទៅវត្ត រមែងសាកសួរគ្នាថា ស្រីណាជានាងវិសាខា ? បុគ្គលអ្នកដែលឃើញនាងវិសាខាកំពុងតែដើរ រមែងគិតថា សូមដើរទៅបន្តិចទៀត ម៉ែម្ចាស់របស់យើងដើរស្អាតណាស់ ។ ឯបុគ្គលដែលឃើញនាងវិសាខាឈរ ឬអង្គុយ ដេកក៏ដោយ រមែង

គិតថា សូមឲ្យឈរបន្តិចទៀត អង្គុយបន្តិចទៀត ដេកបន្តិចទៀត ម៉ែម្ចាស់របស់យើងឈរ អង្គុយ ដេកស្អាតណាស់ ។ នាងវិសាខាជាអ្នកដែលនរណាៗ និយាយនិន្ទា មិនបានសោះឡើយ ព្រោះថាក្នុងឥរិយាបថទាំង ៤ របស់នាងវិសាខាមិនស្អាត ក្នុងឥរិយាបថនោះមិនមានឡើយ ។

ចំពោះឧបាសិកាវិសាខា មិនមែនបរិបូណ៌តែរូបកាយប៉ុណ្ណោះទេ សូម្បីតែកម្លាំងក៏អស្ចារ្យដែរ គឺថាកម្លាំងរបស់ឧបាសិកាវិសាខាស្មើនឹងដំរី ៥ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ថា មហាឧបាសិកាវិសាខា មានកម្លាំងស្មើនឹងដំរី ៥ ដោយព្រះរាជាទ្រង់មានព្រះរាជបំណងចង់សាកល្បងមើលកម្លាំងរបស់នាង ទើបត្រាស់ឲ្យលែងដំរីចេញទៅ ក្នុងពេលដែលនាងត្រឡប់មកពីស្ដាប់ព្រះធម៌ ។ ដំរីនោះ បានលើកប្រមោយឲ្យខ្ពស់ឡើង ហើយរត់តម្រង់ចូលទៅរកឧបាសិកាវិសាខា គ្រានោះ ស្ត្រីដែលជាបរិវារទាំង ៥០០ នាក់ អ្នកខ្លះក៏បានរត់គេចទៅ អ្នកខ្លះក៏មិនព្រមលះបង់ចោលមហាឧបាសិកាវិសាខាឡើយ ។ ពេលនោះ ឧបាសិកា

វិសាខា កាលបានក្រឡេកឃើញដំរីរត់តម្រង់ចូលមករកនាងៗ ទើបសួរបរិវារទាំងនោះថា ដូចម្តេចនេះ ? ស្រីដែលជាបរិវារតបថា បពិត្រនាងម្ចាស់បានជ្រាបថា ព្រះរាជាទ្រង់មានព្រះរាជបំណងចង់សាកល្បងមើលកម្លាំងរបស់នាងម្ចាស់ ទើបបញ្ជាឲ្យគេលែងដំរីមកយ៉ាងនេះ ។ គ្រានោះ ឧបាសិកាវិសាខាគិតថា មានប្រយោជន៍អ្វីដែលដំរីមកហើយយើងរត់គេចទៅ តែយើងនឹងចាប់ដំរីនេះយ៉ាងណាល្អហ្ន៎ ប្រសិនបើយើងចាប់ដំរីឲ្យណែន ដំរីនេះប្រាកដជានឹងស្លាប់ ។ កាលបើនាងគិតឃើញដូច្នេះហើយ ទើបបានយកម្រាមដៃពីរចាប់ប្រមោយដំរីហើយប្រានទៅ ។ ពេលនោះ ដំរីនោះមិនអាចទ្រទ្រង់ខ្លួននៅបាន ទ្រេតទ្រោតដួលនៅកន្លែងមុខព្រះលានហ្លួងនោះឯង ។ គ្រានោះ មហាជនទាំងពួងបានឲ្យសាធុការ ( គឺការបន្លឺវាចាដើម្បីសម្តែងការលើកសរសើរ ) ។ ឯឧបាសិកាវិសាខា ព្រមដោយបរិវារ បាននាំគ្នាត្រឡប់មកផ្ទះវិញដោយសេចក្តីសុខ ។ ក្នុងសម័យកាលឧបាសិកាវិសាខា ដែលជាអ្នកមានកូនច្រើន មានចៅច្រើន កូន និងចៅរបស់នាង ជាអ្នកមិនមានរោគ

ទើបបានទទួលការសន្មតិថា ជាមង្គលយ៉ាងក្រៃលែងនៅក្នុងក្រុងសាវត្ថី ។ បណ្ដាកូន និងចៅដែលមានចំនួនពាន់ៗ នាក់យ៉ាងនេះ សូម្បីដែលនឹងស្លាប់ ក្នុងរវាងអាយុមិនមានឡើយ ។ ក្នុងបុណ្យមហោស្រពដែលជាមង្គល អ្នកក្រុងសាវត្ថីបានអញ្ជើញឧបាសិកាវិសាខាឲ្យបរិភោគមុន (ជាការយកពាសី ដើម្បីបំណាងឲ្យកើតមង្គលសួស្ដី) ។ លុះមកដល់ថ្ងៃមហោស្រពថ្ងៃមួយ កាលមហាជនតែងខ្លួនល្អហើយ ដោយបាននាំគ្នាទៅកាន់វត្តដើម្បីស្ដាប់ព្រះធម៌ សូម្បីមហាឧបាសិកាវិសាខាទទួលទានអាហារក្នុងទីកន្លែងដែលគេអញ្ជើញទៅហើយ ទើបតែងគ្រឿងអាវមហាលតាបសាធន៍ ហើយទៅវត្តជាមួយនឹងមហាជន តែនាងបានដោះអាវមហាលតាបសាធន៍នោះចេញឲ្យអ្នកបម្រើកាន់ ។ មូលហេតុដែលនាងដោះអាវមហាលតាបសាធន៍ចេញវេចទុក ហើយបានហុចទៅឲ្យអ្នកបម្រើ ថែមទាំងនិយាយថា នែនាង នាងចូរទទួលបង្វេច នេះទុកឲ្យបានល្អ ។

បានឮថា ឧបាសិកាវិសាខា កាលដែលកំពុងតែដើរទៅវត្តនោះ

នាងគិតថា កាលដែលយើងពាក់គ្រឿងប្រដាប់ ដែលមានតម្លៃច្រើនដល់ម្ល៉េះ តាំងអំពីលើក្បាលចុះទៅដល់ខ្នងជើង ចូលទៅកាន់វត្តនោះ ជាការមិនសមគួរ ហើយទើបនាងដោះអាវមហាលតាបសាធន៍នោះចេញ យកមកវេចទុក រួចបានហុចឲ្យអ្នកបម្រើរបស់នាងកាន់ ដែលជាអ្នកមានកម្លាំងស្មើនឹងដំរី ៥ ដែលកើតឡើងដោយសារបុណ្យ ដូចគ្នា ( អ្នកបម្រើនេះមានត្រឹមតែម្នាក់ ដែលអាចកាន់អាវមហាលតាបសាធន៍នោះបាន ) ។ ព្រោះហេតុនោះ ទើបឧបាសិកាវិសាខា និយាយនឹងអ្នកបម្រើស្រីនោះថា នែនាង នាងចូរកាន់អាវនេះទុកឲ្យល្អ ខ្ញុំនឹងពាក់វិញ ក្នុងពេលដែលត្រឡប់ពីសម្នាក់ព្រះមានព្រះភាគវិញ ។ លុះឧបាសិកាវិសាខា ឲ្យអាវមហាលតាបសាធន៍ដល់ស្រីអ្នកបម្រើនោះហើយ នាងក៏បានពាក់គ្រឿងប្រដាប់ដែលមានឈ្មោះថា **ឃនមដ្ឋកៈ** ចូលទៅគាល់ព្រះសម្ពុទ្ធ ដើម្បីស្តាប់ព្រះធម៌ កាលស្តាប់ព្រះធម៌ចប់ហើយ នាងវិសាខា បានក្រាបថ្វាយបង្គំលាព្រះភគវាត្រឡប់មកវិញ ។ ឯស្រីអ្នកបម្រើរបស់នាង ក៏បានភ្លេចបង្វេចដែលបានវេចអាវមហាលតាបសាធន៍

ដោយបានដាក់ទុកនៅត្រង់វិហារ គ្រានោះ ព្រះអានន្ទ បានឃើញដូច្នោះ ហើយ ចង់រក្សាវត្ថុនោះទុកឲ្យ ដោយហេតុនេះ ក្នុងថ្ងៃនោះ ក្រោយពី ព្រះអានន្ទបានឃើញអាវមហាលតាបសាធន៍ លោកក៏បានក្រាបទូល ឲ្យដល់ព្រះមុនីទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន មហាឧបាសិកា វិសាខា នាងបានភ្លេចអាវមហាលតាបសាធន៍ ហើយនាងត្រឡប់ទៅ វិញបាត់ហើយ ព្រះអង្គ ។ គ្រានោះ ព្រះលោកនាថត្រាស់ថា ម្នាល អានន្ទ អ្នកចូររក្សាទុកនៅក្នុងទីបំផុតម្ខាងនោះចុះ ។ ទើបព្រះអានន្ទ លើកអាវមហាលតាបសាធន៍នោះ ដាក់ទុកនៅត្រង់ក្បែរខាងជណ្តើរ ។ ចំណែកឧបាសិកាវិសាខា និងនាងសុប្បិយានាំគ្នាដើរនៅខាងក្នុងវត្ត ដោយតាំងចិត្តថា នឹងដឹងវត្ថុ ដែលគួរធ្វើដល់ភិក្ខុអាគន្តុកៈ និងភិក្ខុ ត្រៀមខ្លួនដើរទៅផ្លូវឆ្ងាយ ថែមទាំងភិក្ខុមានជម្ងឺជាដើម ។ តាមប្រក្រតី ភិក្ខុកំលោះ និងសាមណេរ អ្នកមានសេចក្តីត្រូវការទឹកដោះថ្លា ទឹកឃ្មុំ និងប្រេងជាដើម កាលឃើញឧបាសិកាទាំងនោះនៅខាងក្នុងវត្តហើយ តែងតែកាន់ភាជន៍ មានថាសជាដើមដើរចូលទៅរក សូម្បីក្នុងថ្ងៃនោះ

ក៏បានធ្វើយ៉ាងនោះដូចគ្នាដែរ ។ ពេលនោះ នាងសុប្បិយាបានក្រឡេក ឃើញភិក្ខុមួយរូបឈឺ ហើយបានសួរថា លោកម្ចាស់ត្រូវការអ្វី ? ភិក្ខុឈឺតបថា អាត្មាត្រូវការរសនៃសាច់ ។ ទើបនាងសុប្បិយាពោល តបថា បានលោកម្ចាស់ ខ្ញុំនឹងបញ្ជូនមកប្រគេនលោកម្ចាស់ឲ្យបាន ។ កាលដល់ថ្ងៃទី ២ នាងសុប្បិយារកសាច់ដែលជាកប្បិយៈ ( សាច់ដែល គួរដល់សមណបរិភោគ ) មិនបាន ទើបនាងអារសាច់ភ្លៅរបស់ខ្លួនឯង ធ្វើជាចង្ហាន់បញ្ជូនទៅប្រគេនលោក តែដោយនាងមានសេចក្តីជ្រះថ្លា ក្នុងព្រះសាស្តា សាច់ដែលនាងត្រូវអារទៅ ក៏ត្រឡប់មានសភាពល្អ ដូចប្រក្រតីដើមវិញ ក្នុងកាលដែលបានឃើញព្រះមានជោគប៉ុណ្ណោះ ។ ចំណែកឧបាសិកាវិសាខា បានដើរមើលភិក្ខុកំលោះ និងសាមណេរ ទាំងឡាយដែលមានជំងឺរួចហើយ បានដើរចេញទៅតាមខ្លោងទ្វារដទៃ និងបានឈរនៅចាំក្បែរវត្ត ប្រាប់ស្រីអ្នកបម្រើថា នែនាង នាងចូរនាំ យកអាវមហាលតាបសាធន៍មកឲ្យខ្ញុំពាក់វិញ ។

ក្នុងខណៈនោះ ស្ត្រីអ្នកបម្រើដឹងខ្លួនថា ខ្លួនបានភ្លេចអាវមហា

លតាបសាធន៍នោះ ហើយក៏ជម្រាបទៅវិញថា បពិត្រអ្នកនាងម្ចាស់ ខ្ញុំភ្លេចអាវនោះបាត់ទៅ ។ ទើបឧបាសិកាវិសាខាប្រាប់ថា បើដូច្នេះនាង ចូរទៅយកមក តែប្រសិនបើព្រះអានន្ទរបស់យើងរក្សាទុកក្នុងទីដទៃ នាងកុំយកមក ខ្ញុំបរិច្ចាគអាវមហាលតាបសាធន៍នោះប្រគេនដល់លោក ម្ចាស់ទៅចុះ ។មានកិត្តិសព្ទដែលនាងវិសាខាដឹងថា ព្រះអានន្ទតែងតែ រក្សាវត្ថុដែលបុគ្គលទាំងឡាយភ្លេច ព្រោះដូច្នោះ ទើបនាងនិយាយប្រាប់ យ៉ាងនេះទៅ ។ ចំណែកព្រះអានន្ទ កាលបានក្រឡេកឃើញស្ត្រីអ្នក បម្រើនោះមក ទើបសួរថា នាងមកដើម្បីត្រូវការអ្វីឬ ? អ្នកបម្រើស្ត្រី នោះតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានភ្លេចអាវ មហាលតាបសាធន៍របស់នាងម្ចាស់ខ្ញុំព្រះករុណា ទើបបានមករក ។ គ្រានោះ ព្រះអានន្ទមានអាយុពោលថា អាវមហាលតាបសាធន៍នោះ អាត្មាបានរក្សាទុកនៅកន្ទែងជណ្តើរ នាងចូរទៅយកចុះ ។ អ្នកបម្រើស្ត្រី ក៏បានពិតថេរវាចាថា បពិត្រលោកម្ចាស់ដ៏ចម្រើន នាងម្ចាស់របស់ ខ្ញុំព្រះករុណាបានប្រាប់មកថា បង្វេចកណ្ឌៈដែលលោកម្ចាស់ ចាប់ពាល់

ត្រូវហើយ មិនឲ្យនាំយកត្រឡប់ទៅវិញទេ ។ ហើយនាងត្រឡប់ទៅវិញដោយដៃទទេទៅ ។ កាលបើឧបាសិកាវិសាខា បានក្រឡេកឃើញស្រ្តីអ្នកបម្រើនោះ ត្រឡប់មកវិញដោយដៃទទេ ទើបសួរថា មានហេតុដូចម្តេចនាង ? អ្នកបម្រើស្រីបានជម្រាបរឿងនោះ ឲ្យដល់ឧបាសិកាវិសាខា ដែលត្រូវនឹងទម្លាប់បានដឹងរួចមកហើយ ។ ទើបឧបាសិកាពោលថា យើងមិនពាក់របស់ដែលលោកម្ចាស់របស់យើងប៉ះពាល់ហើយទេ យើងបានបរិច្ចាគហើយ ប៉ុន្តែលោកម្ចាស់រក្សាទុកជាការលំបាកយើងនឹងលក់គ្រឿងប្រដាប់នោះហើយ នឹងនាំយកវត្ថុដែលសមគួរទៅប្រគេនវិញ នាងចូរទៅនាំយកអាវនោះមកចុះ ( អ្នកបម្រើស្រីក៏បានទៅយកអាវមហាលតាបសាធន៍ មកជូនដល់នាងវិសាខាវិញ ) ។ចំណែកនាងវិសាខាក៏មិនបានពាក់អាវមហាលតាបសាធន៍នោះវិញទេ នាងប្រាប់ឲ្យពួកជាងមាសមកវាយតម្លៃ ។ ពួកជាងមាសទាំងនោះប្រាប់ថា មានតម្លៃដល់ទៅ ៩ កោដិកហាបណៈ និងមានតម្លៃឈ្នួលមួយសែនកហាបណៈទៀត ។

ឧបាសិកាវិសាខា បានលើកអាវមហាលតាបសាធន៍នោះឡើងដាក់លើយាន ហើយប្រាប់ថា ពួកលោកចូរយកអាវមហាលតាបសាធន៍នេះទៅលក់ ។ ដោយនាងគិតឃើញថា មិនមាននរណាអាចនឹងឲ្យប្រាក់មានចំនួនប៉ុណ្ណោះ ទទួលយកអាវមហាលតាបសាធន៍ទុកបាន ព្រោះថា ស្រីដែលសមគួរនឹងអាវមហាលតាបសាធន៍នេះ រកបានដោយកម្រ ។ ដោយសេចក្ដីថា ក្នុងមណ្ឌលប្រឹថពីនេះ ស្ត្រីដែលមានអាវមហាលតាបសាធន៍នេះ មានត្រឹមតែ ៣ នាក់ប៉ុណ្ណោះ គឺ១- មហាឧបាសិកាវិសាខា ២- នាងមល្លិកា ដែលជាភរិយារបស់ពន្ធុលសេនាបតី ៣- កូនស្រីរបស់សេដ្ឋីនៅក្នុងក្រុងពារាណសី ។ ព្រោះដូច្នោះ ទើបឧបាសិកាវិសាខា ទិញអាវមហាលតាបសាធន៍នោះខ្លួនឯង ហើយឲ្យដឹកប្រាក់ ៩ កោដិ និងមួយសែនកហាបណៈ ដាក់ផ្ទុកក្នុងរទេះនាំយកទៅកាន់វត្ត នាងថ្វាយបង្គំព្រះជិនស្រី ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អាវមហាលតាបសាធន៍របស់ខ្ញុំម្ចាស់ លោកម្ចាស់អានន្ទបានយកដៃប៉ះត្រូវហើយ ចាប់ផ្ដើមពីកាលលោកម្ចាស់ប៉ះ

ហើយ ខ្ញុំព្រះករុណាមិនអាចពាក់បានទៀតទេ តែខ្ញុំព្រះករុណាឲ្យលក់អាវនោះ ដោយគិតថា កាលបើលក់បានហើយ នឹងនាំយកវត្ថុដែលសមគួរមកប្រគេន តែមិនឃើញអ្នកដទៃទិញអាវនោះសោះ ទើបខ្ញុំព្រះអង្គទិញទុកដោយខ្លួនឯង ហើយនាំយកប្រាក់មកប្រគេន ខ្ញុំព្រះអង្គបង្អោនចូលទៅក្នុងបច្ច័យណា ក្នុងបច្ច័យទាំង ៤ យ៉ាងនោះ ? គ្រានោះ ព្រះពុទ្ធអង្គត្រាស់តបថា នែនាងវិសាខា នាងគួរធ្វើលំនៅ ( វត្ត ) ប្រគេនដល់ភិក្ខុសង្ឃ ដែលនិមន្តមកទីទិសទាំង ៤ នោះចុះ ។ ឧបាសិកាវិសាខាក្រាបទូលទទួលថា ព្រះករុណាព្រះអង្គ នាងក៏មានចិត្តសប្បាយរីករាយត្រេកអរ ទើបនាំយកប្រាក់ ៩ កោដិកហាបណៈទៅទិញដី និងប្រាក់ ៩ កោដិកហាបណៈទៀត កសាងសេនាសនៈថ្វាយដល់ភិក្ខុសង្ឃ ។ ថ្ងៃមួយ កាលព្រះលោកនាយក ទ្រង់ប្រមើលមើលឧបនិស្ស័យនៃសត្វលោក ក្នុងពេលជិតភ្លឺ ទ្រង់បានទតឃើញឧបនិស្ស័យនៃសេដ្ឋីបុត្រឈ្មោះភទ្ទិយៈ ដែលជាអ្នកចុតិចាកទេវលោកមកហើយទៅកើតក្នុងត្រកូលសេដ្ឋី នៅក្នុងភទ្ទិយនគរ ក្នុងពេលដែលព្រះសម្ពុទ្ធ

ទទួលភត្តាហារក្នុងផ្ទះរបស់ អនាថបិណ្ឌិកសេដ្ឋីរួចហើយ ស្តេចបាន បែរព្រះភក្ត្រទៅកាន់ទ្វារទិសឧត្តរ ។ តាមប្រក្រតីព្រះមុនី ទ្រង់ទទួល ភត្តាហារក្នុងផ្ទះរបស់នាងវិសាខាហើយ ក៏ស្តេចយាងចេញតាមទ្វារ ទិសទក្សិណ ហើយប្រថាប់នៅក្នុងវត្តជេតពន ។ ទ្រង់ទទួលភត្តាហារ ក្នុងផ្ទះអនាថបិណ្ឌិកសេដ្ឋីហើយ ស្តេចក៏យាងចេញទៅតាមទ្វារទិស បូព៌ា ហើយប្រថាប់នៅក្នុងវត្តបុព្វារាម ។ គ្រានោះ មហាជនទាំងឡាយ បានឃើញព្រះជិនស្រី ស្តេចពុទ្ធដំណើរទៅត្រង់ទិសឧត្តរ រមែងដឹង បានថា ព្រះលោកនាថ នឹងស្តេចចារិកទៅកាន់ទីកន្លែងដទៃ ។ សូម្បី ក្នុងថ្ងៃនោះ ឧបាសិកាវិសាខាជ្រាបថា ព្រះមានបុណ្យស្តេចពុទ្ធដំណើរ បែរព្រះភក្ត្រទៅតាមទ្វារទិសឧត្តរ ទើបប្រញាប់ទៅថ្វាយបង្គំក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់មានព្រះបំណងស្តេចចារិកទៅឬ ព្រះអង្គ ? ព្រះសម្ពុទ្ធត្រាស់តបថា ត្រូវហើយ វិសាខា ។ ឧបាសិកា វិសាខា ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បាន បរិច្ចាគទ្រព្យចំនួនប៉ុណ្ណោះឲ្យកសាងវត្តថ្វាយភិក្ខុសង្ឃ ចាំព្រះអង្គស្តេច

យានត្រឡប់មកវិញសិនចុះ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ថា នែនាងវិសាខា ការទៅនេះជាការទៅយូរណាស់ តថាគតមិនត្រឡប់មកវិញភ្លាមៗ ទេ ។ ឧបាសិកាវិសាខាគិតថា ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នឹងឃើញអ្នកណាម្នាក់ហើយ ដែលសម្បូរទៅដោយឧបនិស្ស័យជាពិតប្រាកដ ទើបក្រាបទូលថា ប្រសិនបើយ៉ាងនោះ សូមព្រះលោកនាថត្រាស់ឲ្យភិក្ខុមួយរូប អ្នកយល់ការណ៍ដែលខ្ញុំព្រះអង្គធ្វើ សូមនិមន្តត្រឡប់ទៅវិញ ហើយព្រះអង្គស្តេចយាងទៅចុះ ។ ពេលនោះ ទ្រង់ត្រាស់ថា នែនាងវិសាខា នាងពេញចិត្តភិក្ខុរូបណា ចូរទទួលបាត្ររបស់ភិក្ខុរូបនោះចុះ ។ សូម្បីថា ឧបាសិកាវិសាខាពេញចិត្ត ចំពោះលោកម្ចាស់អានន្ទក៏ពិតមែន តែនាងបានគិតឃើញថា ព្រះមហាមោគ្គល្លាន ជាអ្នកមានឫទ្ធិ ការងាររបស់យើងនឹងបានសម្រេច យ៉ាងឆាប់រហ័ស ព្រោះអាស្រ័យព្រះមហាមោគ្គល្លាន កាលនាងគិតឃើញដូច្នេះហើយ ទើបទទួលបាត្ររបស់ព្រះមហាមោគ្គល្លានទុក ។ ចំណែកព្រះមហាមោគ្គល្លានបានក្រឡេកមើលព្រះភក្ត្ររបស់ព្រះបរមគ្រូ ។ គ្រានោះ ទើបព្រះមុនី

ត្រាស់ថា ម្នាលមោគ្គល្លាន អ្នកចូរនាំភិក្ខុសង្ឃ ៥០០ រូប ដែលជាបរិវាររបស់អ្នកត្រឡប់ទៅវិញចុះ ។ ព្រះមហាមោគ្គល្លានបានត្រឡប់តាមព្រះពុទ្ធតម្រាស់នោះ ដោយអានុភាពរបស់ព្រះមហាមោគ្គល្លានបុគ្គលទាំងឡាយ អ្នកដែលត្រាច់ទៅដើម្បីរកឈើ និងថ្មនោះ ក៏ទៅបានឆ្ងាយដល់ ៥០-៦០ យោជន៍ ដោយបានជញ្ជូនយកឈើ និងថ្មច្រើនៗទាន់ចិត្តក្នុងថ្ងៃនោះឯង ។ សូម្បីពេលលើកឈើ និងថ្មដាក់លើរទេះក៏មិនលំបាក សូម្បីដាក់ច្រើននោះ ភ្លៅរទេះក៏មិនបាក់ដែរ ។ កាលតមកមិនយូរប៉ុន្មាន ពួកគេបានកសាងប្រាសាទពីរជាន់រួចស្រេច ដោយប្រាសាទនោះ មានបន្ទប់ ១០០០ គឺជាន់ខាងក្រោម ៥០០ បន្ទប់ជាន់ខាងលើ ៥០០ បន្ទប់ ។

ព្រះបរមសាស្តា ស្តេចពុទ្ធដំណើរទៅបាន ៩ ខែហើយ ទើបព្រះអង្គស្តេចយាងត្រឡប់មកកាន់ក្រុងសាវត្ថីម្តងទៀត ។ ការកសាងប្រាសាទរបស់មហាឧបាសិកាវិសាខា ក៏បានកសាងរួចស្រេចជាស្ថាពរ ដោយចំណាយពេលវេលា ៩ ខែ ។ ឧបាសិកាវិសាខា បានឲ្យកសាង

កំពូលប្រាសាទធ្វើជាផ្ទាំងទឹកធំ ដែលដាក់ចំណុះទឹកបាន ៦០ ផ្ទាំង ដោយប្រើមាសសុទ្ធធ្វើផ្ទាំងទឹកនោះ ។ ( មួយទៀត ឈ្មោះវត្តដែលឧបាសិកាវិសាខាកសាងថ្វាយភិក្ខុសង្ឃនោះ នៅក្នុង **អដ្ឋកថាសុមង្គលវិលាសិនី** និង **គម្ពីរបបញ្ចសូទនី** មានឈ្មោះថា **ប្រាសាទមិគារមាតា** នៅក្នុងវត្តបុព្វារាម គឺតមកខាងក្រោយ កាលមហាឧបាសិកាវិសាខាបានជាឧបដ្ឋាយិការបស់ព្រះសាស្ដាហើយ បានលះបង់គ្រឿងប្រដាប់ដែលមានឈ្មោះថា **អាវមហាលតាបសាធន៍នោះប្ដូរជាប្រាក់ ៩ កោដិនិងមួយសែនកហាបណៈ** (ដោយប្រាក់របស់នាង) ហើយ បានកសាងវត្តថែមទាំងបានកសាងព្រះគន្ធកុដិថ្វាយចំពោះព្រះមានជោគ បានកសាងប្រាសាទមួយខ្នងមានពីរជាន់ មួយជាន់ៗ មាន ៥០០ បន្ទប់ រួមត្រូវជាមួយពាន់បន្ទប់ ប្រាសាទនោះ នៅមានកុដិដែលមានកំពូលពីរកំពូលស្រដៀងប្រាសាទពីរកំពូលនៅព័ទ្ធជុំវិញ ៥០០ ខ្នងទៀត មានប្រាសាទតូចៗ ៥០០ មានរោងប្រទីប និងផ្ទះភ្លើង ៥០០ ទៀត ដែលវត្តនោះមានឈ្មោះថា **វត្តបុព្វារាម** ព្រោះបានកសាងឡើងនៅទិសខាងកើតនៃក្រុង

សាវត្ថី ស្ត្រីដទៃៗ ដែលបានលះបង់ទ្រព្យច្រើននៅក្នុងព្រះសាសនានេះ ដូចគ្នានឹងនាងវិសាខាមិនមានឡើយ ។ លុះឧបាសិកាវិសាខា បានឮដំណឹងថា ព្រះសាស្តា ស្តេចយាងត្រឡប់មកនៅវត្តជេតពនវិញ ទើបនាងទៅទទួលព្រះមុនី ដោយបាននាំព្រះអង្គទៅកាន់វត្តរបស់ខ្លួន ហើយបានក្រាបទូលទទួលបេ្តជ្ញាថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះភគវា និងភិក្ខុសង្ឃគង់ប្រថាប់នៅក្នុងវត្តនេះ ៤ ខែ ខ្ញុំព្រះអង្គ នឹងបានធ្វើបុណ្យឆ្លងវត្តបុព្វារាមនេះ ។ គ្រានោះ ព្រះមហាមុនី ទ្រង់បានទទួលប្រាសាទរបស់ឧបាសិកាវិសាខាដែលថ្វាយទុកជាវត្ត នៅក្នុងព្រះពុទ្ធសាសនានេះ ។ ចាប់ផ្តើមអំពីកាលនោះទៅ ឧបាសិកាវិសាខាបានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននៅក្នុងវត្តនោះ ។ គ្រានោះស្ត្រីដែលជាសម្លាញ់របស់មហាឧបាសិកាវិសាខា បានកាន់សំពត់មួយផ្ទាំង ដែលមានតម្លៃ ១០០០ កហាបណៈ បានពោលថា នែសម្លាញ់ខ្ញុំត្រូវការក្រាលសំពត់ផ្ទាំងនេះ ធ្វើជាសំពត់កម្រាលនៅក្នុងប្រាសាទរបស់នាង សូមនាងជួយប្រាប់កន្លែងក្រាលឲ្យដល់ខ្ញុំផង ។ មហាឧបាសិកា

ពោលថា នែសម្លាញ់ ប្រសិនបើខ្ញុំប្រាប់ថា មិនមានកន្លែងចន្លោះទំនេរ នាងក៏នឹងយល់ថា ខ្ញុំមិនមានបំណងនឹងមិនឲ្យឱកាសដល់នាង ហេតុដូច្នេះ នាងចូរដើរពិនិត្យមើលផ្ទៃប្រាសាទទាំងពីរជាន់ ដែលមានបន្ទប់ ១០០០ ហើយចូរជ្រើសរើសរកទីកន្លែងក្រាលខ្លួនឯងចុះ ។ ពេលនោះទើបស្ត្រីដែលជាសម្លាញ់នោះ កាន់សំពត់ដែលមានតម្លៃ ១០០០ កហាបណៈ ដើរពិនិត្យមើលក្នុងទីកន្លែងនោះៗ ក៏មិនឃើញសំពត់ដែលមានតម្លៃតិចជាងសំពត់របស់ខ្លួន ទើបតូចចិត្តថា យើងមិនបានចំណែកបុណ្យក្នុងប្រាសាទនេះទេ ហើយបានឈរយំនៅកន្លែងមួយ ។ គ្រានោះព្រះអានន្ទដ៏មានអាយុ បានក្រឡេកឃើញស្ត្រីនោះហើយ ទើបសួរថា នាងយំព្រោះមានហេតុអ្វីឬ ? ស្ត្រីនោះពិតថេរវាចា ឲ្យព្រះអានន្ទបានជ្រាប ។ ព្រះអានន្ទបានពោលជាស់តឿនឲ្យមានសតិថា កុំគិតតូចចិត្តអ្វីឡើយ អាត្មានឹងប្រាប់កន្លែងដែលត្រូវក្រាល ហើយទើបពោលណែនាំថា នាងចូរក្រាលនៅកន្លែងជណ្តើរ សម្រាប់ជាសំពត់ជូតជើង កាលភិក្ខុសង្ឃទាំងឡាយ លោកលាងជើងរួចហើយ លោកត្រូវការជូតជើងនៅក្នុង

កន្លែងនោះសិន ទើបចូលទៅខាងក្នុង កាលបើដូចនេះ នាងនឹងបានបុណ្យជាច្រើនទៀតផង ។

បានឮថា ទឹកន្លែងនោះ ជាទឹកន្លែងដែលមហាឧបាសិកាវិសាខាមិនបានកំណត់ទុក ។ ឧបាសិកាបានថ្វាយទានដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន នៅក្នុងវត្តអស់ ៤ ខែហើយ នៅក្នុងថ្ងៃចុងក្រោយនៃការថ្វាយទាន ឧបាសិកាវិសាខា បានថ្វាយសំពត់សាដក សម្រាប់ធ្វើចីវរដល់ភិក្ខុសង្ឃ ( មួយទៀត សំពត់សាដកសម្រាប់ធ្វើចីវរ ដែលភិក្ខុបួសថ្មីក្នុងសង្ឃបានហើយ មានតម្លៃ ១០០០ កហាបណៈ ។ ឧបាសិកាវិសាខា ក៏បានថ្វាយភេសជ្ជដាក់ពេញបាត្ររបស់ភិក្ខុសង្ឃគ្រប់ៗ រូប ។ ក្នុងការបរិច្ចាគទានរបស់មហាឧបាសិកាវិសាខា ក្នុងរយៈពេល ៤ ខែនោះ បានចំណាយទ្រព្យទៅអស់ ៩ កោដិកហាបណៈ ។ ឧបាសិកាវិសាខា បានបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនានេះទាំងអស់ ២៧ កោដិកហាបណៈ គឺទិញដីដើម្បីកសាងវត្ត ៩ កោដិ កសាងសេនាសនៈ ៩ កោដិ និងធ្វើបុណ្យឆ្លង ៩ កោដិទៀត រួមទាំងអស់ត្រូវជា ២៧ កោដិ ។

ការបរិច្ចាគទ្រព្យច្រើនដល់ម៉្លេះនេះ ស្រីដទៃដែលជាអ្នកនៅក្នុងផ្ទះរបស់បុគ្គលជាមិច្ឆាទិដ្ឋិ ក៏មិនមាននរណាអាចធ្វើបានឡើយ ។ ទីកន្លែងផ្ទះរបស់ឧបាសិកាវិសាខា ជាទីកន្លែងដែលមានពណ៌ស្រស់ខ្ចី ដោយពន្លឺនៃសំពត់កាសាវពស្រ្ត ជាទីកន្លែងដែលមានក្លិនផ្សាយទៅបណ្តោយខ្យល់ និងច្រាសខ្យល់ ដោយក្លិននៃសីលរបស់អ្នកស្វែងរកធម៌ ដែលជាគ្រឿងផុតចាកទុក្ខ ទាំងក្នុងពេលព្រឹកល្ងាច នៅក្នុងផ្ទះរបស់ឧបាសិកាវិសាខា មានតែការរៀបចំទេយ្យធម៌ ដែលត្រូវទុកថ្វាយដល់ភិក្ខុសង្ឃ ដូចគ្នានឹងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីដែរ ។ ឧបាសិកាវិសាខាថ្វាយភត្តាហារដល់ភិក្ខុសង្ឃក្នុងវេលាព្រឹក លុះដល់វេលាល្ងាច ទើបឲ្យមនុស្សកាន់ភេសជ្ជៈផ្សេងៗ មានទឹកបាន ឬទឹកអដ្ឋបាន ចេញទៅកាន់វត្តប្រគេនដល់ភិក្ខុសង្ឃហើយ ក៏បាននាំគ្នាទៅស្តាប់ព្រះធម៌ព្រះសាស្តា ហើយក៏ត្រឡប់មកផ្ទះវិញ ។ ភាពជាអ្នកមានសេចក្តីប្រសើររបស់ឧបាសិកាវិសាខា រហូតដល់បានទទួលការរាប់អានដោយទូទៅរបស់ពុទ្ធបរិស័ទទៀតផង ។ ក្រោយមក កាលព្រះវិជិតមារ ទ្រង់បានប្រកាសតែងតាំង

ឧបាសិកាទុកក្នុងតំណែងផ្សេងៗ តាមលំដាប់នោះ ទ្រង់ក៏បានប្រកាសតែងតាំងមហាឧបាសិកាវិសាខា ទុកក្នុងតំណែងជាឯតទគ្គៈផងដែរ មានសេចក្តីថា

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ ទាយិកានំ យទិទំ វិសាខាមិគារមាតា** ម្នាលភិក្ខុទាំងឡាយ ពួកឧបាសិកាជាទាយិកា ( អ្នកឲ្យទាន ) ស្រេចនឹងនាងវិសាខាមិគារមាតា ។

ជីវប្រវត្តិរបស់ឧបាសិកាវិសាខា ដែលជាទាយិកា ( អ្នកឲ្យទាននេះ ) មានរឿងសម្តែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **បុប្ផវគ្គ** ក្នុង **រឿងនាងវិសាខា** ដូចមានសេចក្តីថា ៖

ក្នុងថ្ងៃនៃការធ្វើវត្តបុញ្ញារាមរួចស្រេចហើយ ក្នុងវេលារសៀល មហាឧបាសិកាវិសាខា ដែលមានកូនចៅហែហមគិតឡើងថា សេចក្តីប្រាថ្នាណាៗ ដែលយើងបានតាំងចិត្តទុកហើយ ក្នុងកាលមុន ការប្រាថ្នាទាំងអស់នោះ បានដល់ទីបំផុតហើយ ទើបនាងដើរជុំវិញវិហារ ហើយបានបន្លឺឧទាន ( វាចាដែលពោលឡើងដោយការរីករាយចិត្តនេះឡើង )

ដោយសំឡេងដ៏ពីរោះ ៥ គាថាថា

កាលណាហ្ន៎ យើងនឹងបានថ្វាយប្រាសាទថ្មី លាបដោយកំបោរ និងដី ជាវិហារទាន សេចក្តីត្រិះរិះរបស់ខ្ញុំ ក៏បានពេញបរិបូណ៌ហើយ ។ កាលណាហ្ន៎ យើងនឹងបានថ្វាយគ្រែ តាំង ពូក និងខ្នើយ ជាគ្រឿងសេនាសនៈ សេចក្តីត្រិះរិះរបស់ខ្ញុំ ក៏បានពេញបរិបូណ៌ហើយ ។ កាលណាហ្ន៎ ទើបយើងនឹងបានថ្វាយសលាកភត្ត លាយដោយសាច់ដ៏ស្អាត ជាអាហារទាន សេចក្តីត្រិះរិះរបស់ខ្ញុំ ក៏បានពេញបរិបូណ៌ហើយ ។ កាលណាហ្ន៎ ទើបយើងនឹងបានថ្វាយសំពត់កាសី សំពត់សម្បកឈើ និងសំពត់កប្បាស ជាចីវរទាន សេចក្តីត្រិះរិះរបស់ខ្ញុំ ក៏បានពេញបរិបូណ៌ហើយ ។ កាលណាហ្ន៎ ទើបយើងនឹងបានថ្វាយទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ជាភេសជ្ជទាន សេចក្តីត្រិះរិះរបស់ខ្ញុំ ក៏បានពេញបរិបូណ៌ហើយ ។

គ្រានោះ ភិក្ខុទាំងឡាយបានឮសំឡេងរបស់ឧបាសិកាវិសាខា បន្លឺឧទានដូច្នេះហើយ ទើបក្រាបទូលដល់ព្រះសក្យមុនីថា បពិត្រព្រះអង្គ

ដ៏ចម្រើន ការច្រៀងរបស់នាងវិសាខា ពួកខ្ញុំព្រះអង្គមិនដែលធ្លាប់ឃើញ ឬឮមកអស់កាលយូរប្រមាណត្រឹមប៉ុណ្ណោះ ថ្ងៃនេះនាងវិសាខា ដែលមានកូនចៅហែហមហើយ បានច្រៀងដើរជុំវិញវិហារ នាងកើតប្រមាត់កម្រើក ឬថា នាងឆ្កួតឬ ព្រះអង្គ ? ពេលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធីតារបស់តថាគតមិនបានច្រៀង តែនាងមានសេចក្តីប្រាថ្នាពេញប្រៀបហើយ ទើបនាងសប្បាយចិត្តថា សេចក្តីប្រាថ្នារបស់យើងតាំងទុកដល់ទីបំផុតហើយ ទើបបានដើរបន្លឺឧទានដូច្នេះទៅ ។ ភិក្ខុទាំងឡាយ ក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន នាងវិសាខាបានតាំងសេចក្តីប្រាថ្នាតាំងពីពេលណាមក ? ទើបព្រះបរមគ្រូត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចង់ស្តាប់ឬ ? ភិក្ខុទាំងឡាយទូលតបថា ព្រះករុណាព្រះអង្គ ចង់ស្តាប់ ។ គ្រានោះ ទើបព្រះសម្ពុទ្ធទ្រង់នាំអតីតនិទានមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងមួយសែនកប្បពីកទូកប្បនេះទៅ មានព្រះសម្មាសម្ពុទ្ធព្រះនាមព្រះបទុមុត្តរៈ ទ្រង់ឧប្បត្តិកឡើងក្នុងលោក ។ ព្រះសម្ពុទ្ធបទុមុត្តរៈ មានព្រះជន្ម ១ សែន

ឆ្នាំ មានភិក្ខុសង្ឃជាព្រះខីណាស្រព ១ សែនរូបជាបរិវារ ប្រថាប់នៅក្នុងនគរហង្សវតី ។ ព្រះបិតាព្រះនាម **សុនន្ទ** ព្រះមាតាព្រះនាម **សុជាតា** ។ មានឧបាសិកាដែលជាឧបដ្ឋាយិកា បានក្រាបទូលសូមពរ ៨ ប្រការ ហើយតាំងនៅក្នុងឋានៈដូចជាមាតា បានគាល់ប្រតិបត្តិទំនុកបម្រុងព្រះសាស្តា ដោយបច្ច័យ ៤ រមែងទៅកាន់ទីទំនុកបម្រុងទាំងពេលព្រឹក ទាំងពេលល្ងាច ។ ស្រីដែលជាសម្លាញ់ម្នាក់របស់ឧបាសិកានោះ បាននៅវត្តជាមួយនឹងឧបាសិកានោះជានិច្ច ។ ស្រីដែលជាសម្លាញ់នោះ បានក្រឡេកឃើញឧបាសិកានិយាយជាមួយព្រះមុនីដោយភាពស្និទ្ធស្នាល ទើបគិតថា នាងធ្វើកម្មអ្វីហ្ន៎ បានជាអ្នកបាននូវភាពស្និទ្ធស្នាលជាមួយព្រះពុទ្ធយ៉ាងនេះ ។ ហើយទើបក្រាបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ស្រីនេះជាអ្វីរបស់ព្រះភគវា ? ព្រះបរមសាស្តាត្រាស់តបថា ស្ត្រីនេះជាឧបដ្ឋាយិកា ។ ស្រីដែលជាសម្លាញ់នោះ ក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន នាងធ្វើកម្មអ្វីទុកបានជានាងបានជាឧបដ្ឋាយិកាយ៉ាងនេះព្រះអង្គ ? ព្រះបទុមុត្តរៈ

ត្រាស់តបថា នាងបានតាំងសេចក្តីប្រាថ្នាទុកអស់មួយសែនកប្បមកហើយ ស្រីដែលជាសម្លាញ់នោះក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំម្ចាស់អាចប្រាថ្នាបានឬទេ ព្រះអង្គ ? ព្រះបទុមុត្តរៈត្រាស់តបថា បានទេតើនាង ។ ស្រីដែលជាសម្លាញ់បានក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានជោគ ព្រមទាំងភិក្ខុសង្ឃមួយសែនរូបទទួលភត្តរបស់ខ្ញុំព្រះអង្គ ក្នុងរយៈពេល ៧ ថ្ងៃ ព្រះអង្គ ។ ព្រះបទុមុត្តរៈទ្រង់ទទួលនិមន្តន៍របស់ស្រីនោះ ដោយតុណ្ហីភាព ។ ស្ត្រីដែលជាសម្លាញ់ បានថ្វាយទានអស់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៧ នាងបានថ្វាយសំពត់សាដកដើម្បីធ្វើចីវរ ហើយក្រាបទូលព្រះបទុមុត្តរៈថា បពិត្រព្រះអង្គដ៏ចម្រើន ដោយផលនៃទាននេះ ខ្ញុំមិនប្រាថ្នាវត្ថុណានីមួយដែលមានសភាពជាធំ នៅក្នុងទេវលោកជាដើមទេ តែសូមឲ្យខ្ញុំបានទទួលពរ ៨ ប្រការនេះ ក្នុងសម្នាក់ព្រះពុទ្ធ ដូចគ្នានឹងឧបដ្ឋាយិកាដែលព្រះអង្គបានតាំងនៅក្នុងឋានៈដូចជាមាតារបស់ឧបាសិកា អ្នកអង់អាចដើម្បីទំនុកបម្រុងដោយបច្ច័យ ៤ នោះ ព្រះអង្គ ។ គ្រានោះ ព្រះបទុមុត្តរៈ

ទ្រង់ត្រិះរិះថា ការប្រាថ្នារបស់ស្រីនេះ នឹងបានសម្រេចឬទេហ្ន៎ ទ្រង់ក៏បានប្រមើលមើលដល់អនាគតកាល រហូតមួយសែនកប្ប ទើបត្រាស់ថា ក្នុងទីបំផុតមួយសែនកប្ប មានព្រះពុទ្ធទ្រង់ព្រះនាមគោតមឧប្បត្តិកឡើងក្នុងលោក ក្នុងគ្រានោះ នាងនឹងបានជាឧបាសិកាមានឈ្មោះថា **វិសាខា** នឹងបានទទួលពរ ៨ ប្រការនេះ នៅក្នុងសម្នាក់ព្រះគោតម ថែមទាំងបានតាំងនៅក្នុងឋានៈដូចជាមាតា និងបានជាកំពូលជាងស្ត្រីទាំងឡាយ ផ្នែកឧបដ្ឋាយិកា គឺជាអ្នកទំនុកបម្រុងភិក្ខុសាមណេរ ។ សម្បត្តិនោះ ហាក់បីដូចជាសម្បត្តិ ដែលបានទទួលនៅក្នុងថ្ងៃស្អែកអ៊ីចឹង ។ ចាប់តាំងអំពីនោះមក ស្ត្រីដែលជាសម្លាញ់នោះក៏បានតាំងចិត្តធ្វើបុណ្យកុសលរហូតដល់អស់ជីវិត កាលនាងស្លាប់អំពីជាតិនោះទៅហើយ បានត្រាច់រង្គាត់ស្លាប់កើតៗ ស្លាប់ ជាមនុស្សនិងទេវតាអស់កាលដ៏យូរអង្វែង ។

ជីវប្រវត្តិមហាឧបាសិកាវិសាខាតទៅនេះ ក្រៅអំពីដែលមានសម្តែងនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **បុប្ផវគ្គ** ក្នុង **រឿងនាងវិសាខាហើយ**

ក៏នៅមានសម្តែងនៅក្នុង អដ្ឋកថាមនោរថបូរណី ថា ៖

លុះមកដល់ពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ នាងកុលធីតានោះបានមកកើតជាព្រះរាជធីតា ជាព្រះកនិដ្ឋកគិនី ( ប្អូនពៅ ) ក្នុងបណ្តាព្រះរាជធីតា ៧ អង្គរបស់ព្រះបាទកាសី មានព្រះនាមថា កិកិ នៅក្នុងក្រុងពារាណសី ។ ព្រះរាជធីតា ៧ អង្គនោះ គឺ ១- ព្រះនាងសមណី ២- ព្រះនាងសមណគុត្តា ៣- ព្រះនាងភិក្ខុនី ៤- ព្រះនាងភិក្ខុទាសី ៥- ព្រះនាងធម្មា ៦- ព្រះនាងសុធម្មា ៧- ព្រះនាងសង្ឃទាសី ។ មកដល់បច្ចុប្បន្នកាលនេះ ព្រះរាជធីតាទាំង ៧ ព្រះអង្គនោះ បានមកកើតជាស្ត្រីនៅក្នុងឋានៈផ្សេងៗ គ្នា គឺ ១- ព្រះនាងសមណី បានមកកើតជាព្រះនាងខេមា ២- ព្រះសមណគុត្តា បានមកកើតជាព្រះនាងឧប្បលវណ្ណា ៣- ព្រះនាងភិក្ខុនី បានមកកើតជាព្រះនាងបដាចារា ៤- ព្រះនាងភិក្ខុទាសី បានមកកើតជាព្រះនាងគោតមី ៥- ព្រះនាងធម្មា បានមកកើតជាព្រះនាងធម្មទិន្នា ៦- ព្រះនាងសុធម្មា បានមកកើតជាព្រះនាងមហាមាយា ៧- ព្រះនាងសង្ឃទាសី បានមកកើតជាមហា

ឧបាសិកាវិសាខា ។ ព្រះនាងសង្ឃទាសី ទ្រង់បានបំពេញព្រះរាជកុសល ជាមួយនឹងម្ចាស់បងនោះអស់កាលដ៏យូរ ទ្រង់បានធ្វើសេចក្ដីប្រាថ្នាទុក ទៀបបាទមូលរបស់ព្រះកស្សបសម្ពុទ្ធថា ក្នុងអនាគតកាល សូមឲ្យ ខ្ញុំបានពរ ៨ ប្រការ ក្នុងសម្នាក់របស់ព្រះពុទ្ធ សូមឲ្យតាំងនៅក្នុងឋានៈ ដូចជាមាតា ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងឧបដ្ឋាយិកា ឬអ្នកថ្វាយបច្ច័យ ៤ ចាប់ផ្ដើមអំពីកាលនោះមក នាងបានត្រាច់រង្គាត់ ដោយកើតស្លាប់ៗ កើតជាមនុស្ស និងទេវតាអស់មួយពុទ្ធន្តរ ។ លុះមកដល់កទ្ទកប្បនេះ នាងក៏បានមកកើតជាធីតារបស់នាងសុមនាទេវី ដែលជាភរិយារបស់ធនញ្ជយសេដ្ឋី ដែលជាបុត្រប្រុសរបស់មេណ្ឌក-សេដ្ឋី ជាអ្នកបានធ្វើបុណ្យទុកជាច្រើនទៀតផង នៅក្នុងសាសនារបស់ តថាគតនេះ ។

ហេតុដែលឧបាសិកាវិសាខា បានទទួលការពិភាក្សាពិចារណា ពីភិក្ខុសង្ឃទាំងឡាយហើយ ព្រះមានព្រះភាគរ៉ាប់រងគុណសេចក្ដីល្អ របស់មហាឧបាសិកាវិសាខា ដូចមានរឿងតំណាលប្រាកដទុកនៅក្នុង

អដ្ឋកថាធម្មបទ នៃ បុប្ផវគ្គ ក្នុង រឿងរបស់នាងវិសាខា ថា ៖

ព្រះសម្ពុទ្ធ កាលទ្រង់សម្តែងអតីតនិទាន ដែលជាការពោលដល់សេចក្តីល្អ របស់មហាឧបាសិកាវិសាខាចប់ហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិតារបស់តថាគតមិនបានប្រៀងដោយអាការខូចសតិ តែនាងឃើញការបានសម្រេចក្នុងសេចក្តីប្រាថ្នារបស់នាងដែលនាងបានតាំងសេចក្តីប្រាថ្នាទុកនោះ ទើបបន្លឺឧទាន គឺការពោលចេញមកដោយកាពសប្បាយក្នុងចិត្តយ៉ាងនោះទៅ ។ លុះព្រះសាស្តាត្រាស់ទទួលរ៉ាប់រងដូច្នេះហើយ មុននឹងទ្រង់សម្តែងធម៌ បានត្រាស់ថា ម្នាល់ភិក្ខុទាំងឡាយ នាយមាលាការ អ្នកឈ្លាសវៃក្នុងការក្រងផ្កាហើយធ្វើការក្រងផ្កា មានប្រការផ្សេងៗ យ៉ាងណា ចិត្តរបស់មហាឧបាសិកាវិសាខា រមែងបង្អោនទៅដើម្បីធ្វើកុសល មានប្រការផ្សេងៗក៏ដូច្នោះដែរ ហើយព្រះពុទ្ធអង្គ ទ្រង់ត្រាស់គាថានេះថា

នាយមាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កាផ្សេងៗគ្នា ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើ

ឲ្យច្រើនយ៉ាងនោះ ។

ក្នុងពេលដែលព្រះលោកនាយកទ្រង់ទេសនាចប់ មានបរិស័ទជាច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។

បុណ្យដែលឧបាសិកាវិសាខាបានធ្វើការថ្វាយទាន ដែលចាត់ថាជាទានស្រដៀងគ្នានឹងអសទិសទាន គឺទានដែលមិនមាននរណាធ្វើដូចព្រះបាទបសេនទិកោសល តាមដែលមានសេចក្ដីពោលទុក ដោយសេចក្ដីសង្ខេប នៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ថា ៖

មហាឧបាសិកាវិសាខា បានថ្វាយមហាទាន ដែលត្រូវប្រើវត្ថុចតុប្បច្ច័យស្រដៀងគ្នានឹងអសទិសទាន ជាទានដែលធ្វើបានដោយកម្រ ប្រសិនបើកាន់តួយ៉ាងដែលព្រះនាងមល្លិកាទេវីរៀបចំនោះ ដែលត្រូវប្រើស្វេតច្ឆត្រ ៥០០ ដំរីប្រមាណ ៥០០ ទូកមាស ៨ ឬ ១០ ស្ត្រីដែលមកជួយបុណ្យនេះ មានចំនួនជាច្រើន និងជាទានដែលថ្វាយដល់ភិក្ខុសង្ឃ ៥០០ រូប មានព្រះពុទ្ធជាប្រធាន កាលពោលដោយសរុបហើយ ការថ្វាយអសទិសទាន ត្រូវចំណាយប្រាក់ ១៤ កោដិកហាបណៈ។

ប៉ុន្តែមហាឧបាសិកាវិសាខា បានថ្វាយទានល្មមសមគួរ ឬស្មើគ្នានឹងអសទិសទាន ដោយនាងបានថ្វាយ ៣ ថ្ងៃ ។

ការក្រាបទូលសូមពរ ៨ ប្រការ របស់មហាឧបាសិកាវិសាខា និងការបានទទួលការអនុញ្ញាតព្រះពុទ្ធអង្គនោះ ដែលមានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរមហាវគ្គ ព្រះវិនយបិដក** និងក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង **សុរុចិជាតក** នៅក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖

គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្រុងពារាណសី គួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់ក្រុងសាវត្ថីនោះ ។ បានឮមកថា ព្រះសាស្តា ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ ។ វេលានោះ នាងវិសាខាមិគារមាតាបានចូលទៅគាល់ព្រះមុនី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ កាលនាងវិសាខា

មិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះមានជោគ ទ្រង់ពន្យល់ នាងវិសាខាមិគារមាតា ដែលអង្គុយនៅក្នុងទីដ៏សមគួរហើយនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាងវិសាខាមិគារមាតា លុះព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ព្រះមានជោគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ នាងវិសាខាមិគារមាតា បានដឹងច្បាស់ថាព្រះមានជោគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះសាស្តា ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។ សម័យនោះឯងលុះរាត្រីនោះកន្លងទៅហើយ មានភ្លៀងធំធ្លាក់ចុះសព្វទ្វីបទាំង ៤ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភ្លៀងធ្លាក់ចុះក្នុងវត្តជេតពន យ៉ាងណា ភ្លៀងធ្លាក់ចុះ

ក្នុងទ្វីបទាំង ៤ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរងូតជម្រះកាយគ្រប់ៗ គ្នាចុះ ព្រោះភ្លៀងធំដែលធ្លាក់សព្វទ្វីបទាំង ៤ នេះ ជាទីបំផុតត្រឹមនេះហើយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះសាស្តាដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាដាក់ចីវរចេញ ងូតទឹកភ្លៀងជម្រះកាយ ( ភិក្ខុទាំងនោះងូតទឹកភ្លៀងគ្មានសំពត់ងូត គឺអាក្រាត ) គ្រានោះ នាងវិសាខាមិគារមាតា បានឲ្យជនតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តមហើយបង្គាប់ទាសីថា នែហង ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ ទាសីនោះបានទទួលស្តាប់ពាក្យរបស់នាងវិសាខាមិគារមាតា ដោយពាក្យថា ចាស អ្នកជាម្ចាស់ ហើយទៅកាន់អារាមក៏បានឃើញពួកភិក្ខុដែលដាក់ចីវរចេញ កំពុងងូតទឹកភ្លៀងជម្រះកាយលុះឃើញហើយក៏គិតថា ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានតែពួកអាជីវកកំពុងងូតទឹកភ្លៀងជម្រះកាយ រួចហើយក៏ត្រឡប់ចូលទៅកាន់

សម្នាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងនាងវិសាខាថា បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវកកំពុងងូតទឹកភ្លៀងជម្រះកាយ ។ លំដាប់នោះនាងវិសាខាជាបណ្ឌិត ជាស្រីឈ្លាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយដាក់ចីវរចេញ ហើយនាំគ្នាងូតទឹកភ្លៀងជម្រះកាយ តែទាសីនេះ ជាស្រីល្ងង់សម្គាល់ថា ក្នុងអារាមគ្មានភិក្ខុ មានសុទ្ធតែពួកអាជីវកកំពុងតែនាំគ្នាងូតទឹកភ្លៀងជម្រះកាយ នាងវិសាខាបង្គាប់ទាសីថា នែហង ហងចូលទៅកាន់អារាមហើយ ក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ កាលនោះ ភិក្ខុទាំងនោះងូតទឹកភ្លៀងឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយក៏នាំគ្នាយកចីវរទាំងឡាយ ចូលទៅកាន់លំនៅដូចដើមវិញ ។ ឯទាសីនោះទៅកាន់អារាមមិនឃើញពួកភិក្ខុ ក៏គិតថា ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទទេ ហើយក៏ត្រឡប់ចូលទៅកាន់សម្នាក់នាងវិសាខាវិញ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ

នឹងនាងវិសាខាថា បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទទេ ។ លំដាប់នោះ នាងវិសាខាជាបណ្ឌិត ជាស្រីឈ្លាសជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយផ្លូតទឹកភ្លៀងឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយនាំយកចីវរទាំងឡាយ ចូលទៅកាន់លំនៅដូចដែលទាសីនេះ ជាស្រីល្ងង់ សម្គាល់ថាក្នុងអារាមគ្មានពួកភិក្ខុសោះ មានតែអារាមទទេ ។ នាងវិសាខា ក៏បង្គាប់ទាសីទៀតថា នែហង ហងចូលទៅកាន់អារាមហើយ ក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នករាល់គ្នារៀបចំបាត្រ និងចីវរចុះ ព្រោះដល់ពេលចង្ហាន់ហើយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះបន្ទូលព្រះសាស្តាដោយពាក្យថា ព្រះករុណាព្រះអង្គ ។ លុះវេលាព្រឹកឡើង ព្រះភគវាទ្រង់ស្បៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ហើយទ្រង់បំបាត់ព្រះអង្គអំពីវត្តជេតពន ទៅប្រាកដទៀបខ្លោងទ្វាររបស់នាងវិសាខា ដោយ

ធាប់រហ័ស ប្រៀបដូចបុរសមានកម្លាំងលាដៃដែលខ្លួនបត់ចូល ឬបត់ដៃដែលខ្លួនលាចេញ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលគេតាក់តែងថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ គ្រានោះ នាងវិសាខាគិតថា អើហ្ន៎ ហេតុនេះអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុនេះចម្លែកពេកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា ជំនន់ប្រមាណត្រឹមជង្គង់ខ្លះ ត្រឹមចង្កេះខ្លះកំពុងហូរទៅៗ សូម្បីតែជើង ឬចីវររបស់ភិក្ខុមួយអង្គ ក៏គ្មានទទឹកឡើយ ហើយក៏មានចិត្តរីករាយខ្ពស់ឡើង រួចអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយ និងភោជនីយាហារដ៏ឧត្តម ដោយដៃរបស់ខ្លួនឯង ត្រាតែភិក្ខុសង្ឃហាមឃាត់ លុះកំណត់ដឹងថា ព្រះមានព្រះភាគឆាន់ហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ នាងក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ នាងវិសាខាអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមពរ ៨ ប្រការ អំពីព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ធម្មតាព្រះតថាគតទាំងឡាយគ្មានពរទេ ។ នាងវិសាខា

ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមតែពរណា ដែលគួរ និងពរណាដែលឥតទោស ។ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចូរនាងនិយាយមកចុះ ។ នាងវិសាខាក៏ក្រាបបង្គំ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់ប្រគេនវស្សិកសាដក ( សំពត់សម្រាប់ងូតទឹកភ្លៀង ) ចង់ប្រគេនអាគន្តុកភត្ត ( ភត្តដែល ប្រគេនដល់ភិក្ខុទើបមកដល់ថ្មី) ចង់ប្រគេនគមិកភត្ត ( ភត្តដែលប្រគេន ដល់ភិក្ខុអ្នកមានដំណើរទៅ) ចង់ប្រគេនគិលានភត្ត (ភត្តដែលប្រគេន ដល់ភិក្ខុមានជំងឺ ) ចង់ប្រគេនគិលានុបដ្ឋាកភត្ត ( ភត្តដែលប្រគេន ដល់ភិក្ខុអ្នកបម្រើជំងឺ ) ចង់ប្រគេនគិលានភេសជ្ជៈ ( ថ្នាំដែលប្រគេន ដល់ភិក្ខុមានជំងឺ) ចង់ប្រគេនធុវយាគូ (បបរដែលត្រូវប្រគេនជានិច្ច) ដល់ព្រះសង្ឃ និងចង់ប្រគេនឧទកសាដក ( សំពត់សម្រាប់ងូតទឹក ) ដល់ភិក្ខុនីសង្ឃជរាបអស់មួយជីវិត ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលនាងវិសាខា នាងឃើញអំណាចប្រយោជន៍ដូចម្តេច បានជាសុំពរ ៨ ប្រការអំពីតថាគត ? នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គ

ដ៏ចម្រើន ក្នុងវេលាព្រឹកមិញនេះ ខ្ញុំព្រះអង្គបង្គាប់ទាសីថា នែហង ហងចូលទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ បពិត្រព្រះអង្គដ៏ចម្រើន ទាសីនោះក៏ទៅកាន់អារាម ហើយបានឃើញពួកភិក្ខុដាក់ចីវរចេញ ហើយកំពុងងូតទឹកភ្លៀងជម្រះកាយ លុះឃើញហើយក៏សម្គាល់ថា ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវកកំពុងងូតទឹកភ្លៀងជម្រះកាយ រួចក៏ត្រឡប់ចូលមកកាន់សម្នាក់របស់ខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ បាននិយាយពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រអ្នកម្ចាស់ ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវកងូតទឹកភ្លៀងជម្រះកាយ បពិត្រព្រះអង្គដ៏ចម្រើន កិរិយាអាក្រាត ជាការមិនស្អាត គួរខ្ពើមរអើម បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនវស្សិកសាដកអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ពរដទៃមានតទៅទៀត ភិក្ខុជាអាគន្តុកៈមិនទាន់ឈ្លាសក្នុងផ្លូវ មិនទាន់ឈ្លាសក្នុងទីគោចរ លំបាកនឹងត្រាច់ទៅបិណ្ឌបាត ភិក្ខុ

ជាអាគន្តុកៈនោះ នឹងបានអាគន្តុកភត្តរបស់ខ្ញុំព្រះអង្គហើយ មុខជានឹង ឈ្លាសក្នុងផ្លូវ ឈ្លាសក្នុងទីគោចរ មិនលំបាកនឹងត្រាច់ទៅបិណ្ឌបាត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនអាគន្តុកភត្តដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គ ដ៏ចម្រើន ពរដទៃមានតទៅទៀត ភិក្ខុអ្នកដំណើរ បើរវល់តែស្វែងរក ភត្តសម្រាប់ខ្លួន មុខជានឹងបែកខ្ញែកចាកសាមគ្គីគ្នា ឬបើចង់ទៅកាន់ លំនៅក្នុងប្រទេសណា នឹងចូលទៅដល់ប្រទេសនោះខុសកាលវេលា នាំឲ្យលំបាកនឹងទៅកាន់ផ្លូវឆ្ងាយ កាលបើភិក្ខុអ្នកដំណើរនោះ បានបាន គមិកភត្តរបស់ខ្ញុំព្រះអង្គហើយ មុខជាមិនបែកខ្ញែកចាកគ្នីគ្នាទេ ឬបើ ចង់ទៅកាន់លំនៅក្នុងប្រទេសណា នឹងបានចូលទៅដល់ប្រទេសនោះ មិនខុសកាលវេលា ឃើញថា មិនលំបាកនឹងទៅកាន់ផ្លូវឆ្ងាយ បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជា ចង់ប្រគេនគមិកភត្តដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ពរដទៃមានតទៅទៀត ភិក្ខុមានជំងឺទាំងឡាយ កាលបើមិនបានភោជន

ជាទីសប្បាយទេ អាពាធក៏រឹងរឹតតែចម្រើនឡើង ឬនឹងធ្វើមរណភាពទៅក៏សឹងមាន កាលបើភិក្ខុមានជំងឺនោះ បានឆាន់គិលានភត្តរបស់ខ្ញុំព្រះអង្គហើយ អាពាធក៏មិនចម្រើនឡើង មរណភាពក៏គ្មាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានភត្តដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ពរដទៃមានតទៅទៀត ភិក្ខុអ្នកបម្រើភិក្ខុឈឺ កាលបើរវល់តែនឹងស្វែងរកភត្តសម្រាប់ខ្លួនហើយ មុខជានឹងនាំយកភត្តមកឲ្យភិក្ខុឈឺក្នុងវេលាថ្ងៃពេកហើយក៏នឹងធ្វើឲ្យភិក្ខុឈឺដាច់ចង្ហាន់ បើភិក្ខុអ្នកបម្រើភិក្ខុឈឺនោះ បានឆាន់គិលានុបដ្ឋាកភត្តរបស់ខ្ញុំព្រះអង្គហើយ នឹងបាននាំយកភត្តមកឲ្យភិក្ខុឈឺក្នុងកាលគួរ ហើយនឹងមិនធ្វើឲ្យភិក្ខុឈឺដាច់ចង្ហាន់ឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានុបដ្ឋាកភត្តដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ពរដទៃមានតទៅទៀត ភិក្ខុមានជំងឺទាំងឡាយ កាលបើមិនបានភេសជ្ជៈជាទីសប្បាយទេ អាពាធក៏រឹងរឹតតែចម្រើនឡើង ឬក៏នឹងធ្វើមរណភាពទៅ

ក៏សឹងមាន កាលបើភិក្ខុមានជំងឺនោះ បានឆាន់គិលានភេសជ្ជៈរបស់ខ្ញុំព្រះអង្គហើយ អាពាធក៏មិនចម្រើនឡើង មិនធ្វើមរណកាលទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានភេសជ្ជៈដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ពរដទៃមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់យល់ឃើញអានិសង្សទាំង ១០ យ៉ាងនេះហើយ បានជាទ្រង់អនុញ្ញាតបបរក្នុងអន្ធកវិន្ទប្រទេស បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញអានិសង្សទាំងនោះដែរ បានជាចង់ប្រគេនធុវយាគូ ដល់សង្ឃអស់មួយជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុនីក្នុងសាសនានេះ មានកាយអាក្រាតងូតទឹកក្នុងកំពង់មួយជាមួយនឹងស្រីពេស្យា នាស្ទឹងអចិរវតី បពិត្រព្រះអង្គដ៏ចម្រើន ពួកស្រីពេស្យាទាំងនោះ នាំគ្នាចំអកចំអន់ឲ្យពួកភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយនៅក្មេងនៅឡើយ ប្រញាប់ធ្វើអ្វីក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ គួរតែលោកម្ចាស់ទាំងឡាយនៅបរិភោគកាមគុណសិន បើលោកម្ចាស់ទាំងឡាយចាស់ជរាវេលាណា

សឹមនាំគ្នាប្រព្រឹត្តព្រហ្មចរិយធម៌វេលានោះចុះ យ៉ាងនេះ ទើបឈ្មោះថាលោកម្ចាស់ទាំងឡាយ បានរក្សាប្រយោជន៍ទាំងពីរទុក បពិត្រព្រះអង្គដ៏ចម្រើន កាលបើពួកស្រីពេស្យានិយាយចំអកចំអន់ឲ្យដូច្នេះហើយ ភិក្ខុនីទាំងនោះ ក៏មានការអៀនខ្មាស បពិត្រព្រះអង្គដ៏ចម្រើន មាតុគ្រាមមានកាយអាក្រាត ជាការមិនស្អាតទេ គួរខ្ពើមរអើមពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនឧទកសាដកដល់ភិក្ខុនីសង្ឃអស់មួយជីវិត ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចុះនាងយល់ឃើញអានិសង្សដូចម្តេចបានជានាងសូមពរ ៨ ប្រការអំពីតថាគត ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុក្នុងសាសនានេះ នៅចាំវស្សាក្នុងទិសទាំងឡាយ រួចហើយនឹងមកកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះអង្គភិក្ខុទាំងនោះ នឹងចូលមកគាល់ព្រះអង្គហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះនេះ ធ្វើមរណកាលហើយ ភិក្ខុនោះមានគតិដូចម្តេចមានបរលោកដូចម្តេច ព្រះមានព្រះភាគ មុខជានឹងទ្រង់ត្រាស់ព្យាករ

បញ្ហានោះក្នុងសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី ខ្ញុំព្រះអង្គនឹងចូលទៅរកភិក្ខុទាំងនោះ ហើយសួរថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន លោកម្ចាស់នោះធ្លាប់និមន្តមកក្រុងសាវត្ថីដែរឬ បើប្រសិនជាពួកភិក្ខុនិយាយប្រាប់ខ្ញុំព្រះអង្គថា ភិក្ខុនោះធ្លាប់មកកាន់ក្រុងសាវត្ថីដែរ ខ្ញុំព្រះអង្គនឹងដល់នូវសេចក្តីចូលចិត្តក្នុងហេតុនេះថា ច្បាស់ជាលោកម្ចាស់នោះ ធ្លាប់បានបរិភោគប្រើប្រាស់វស្សិកសាដកក្តី អាគន្តុកភត្តក្តី គមិកភត្តក្តី គិលានភត្តក្តី គិលានុ-ប្បដ្ឋាកភត្តក្តី គិលានភេសជ្ជៈ ធុវយាគូក្តីមិនខាន កាលខ្ញុំព្រះអង្គនោះរឭកទាននោះរឿយៗ ហើយ សេចក្តីត្រេកអរទន់នឹងកើតឡើង កាលបើសេចក្តីត្រេកអរទន់កើតឡើងហើយ ចិត្តប្រកបដោយបីតិនឹងកើតឡើង កាលបើចិត្តប្រកបដោយបីតិកើតឡើងហើយ កាយក៏នឹងស្ងប់រម្ងាប់ លុះខ្ញុំព្រះអង្គមានកាយស្ងប់រម្ងាប់ នឹងទទួលសេចក្តីសុខ កាលបើខ្ញុំព្រះអង្គបានទទួលសេចក្តីសុខហើយ ចិត្តក៏នឹងតម្កល់មាំ ឥន្ទ្រិយភាវនា ពលភាវនា ពោជ្ឈង្គភាវនា នឹងមានដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គ

ដ៏ចម្រើន ខ្ញុំព្រះអង្គបានយល់ឃើញអានិសង្សនេះហើយ បានជាសុំពរ ៨ ប្រការអំពីព្រះតថាគត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ល្អហើយ ល្អហើយ ម្នាលនាងវិសាខា នាងបានយល់ឃើញអានិសង្សនេះ ហើយបានសូមពរ ៨ ប្រការអំពីតថាគត ជាការប្រពៃពិត ម្នាលនាងវិសាខា បើដូច្នោះ តថាគតអនុញ្ញាតពរ ៨ ប្រការដល់នាង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនាចំពោះនាងវិសាខា ដោយគាថាទាំងឡាយនេះថា

ស្រីណា ជាអ្នកឲ្យបាយ និងទឹក មានចិត្តរីករាយ មានសីលបរិបូណ៌ ជាសាវិកាបស់ព្រះសុគត គ្របសង្កត់នូវសេចក្តីកំណាញ់បានហើយឲ្យទាន ស្រីនោះឯង តែងបាននូវផល គឺអារម្មណ៍ដ៏ប្រសើរដោយប្រពៃ មានរូបជាដើម បានបន្ទោបង់នូវសេចក្តីសោក នាំមកនូវសេចក្តីសុខ មានកម្លាំង និងអាយុជាទិព្វ ស្រីនោះ ជាស្រីមានសេចក្តីប្រាថ្នានូវបុណ្យ មានសេចក្តីសុខ ឥតមានទុក្ខ តែងរីករាយក្នុងស្ថានសួគ៌អស់កាលជាអង្វែង ព្រោះអាស្រ័យនូវមគ្គចិត្តដ៏ប្រាសចាកធូលី មិនមាន

កិលេសនោះឯង ។

កាលនោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនាចំពោះនាងវិសាខា មិគារមាតា ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ យាង ចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះទសពល ទ្រង់ធ្វើ ធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាល ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវស្សិកសាដក អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុបដ្ឋាកភត្ត គិលានភេសជ្ជៈ ធុវយាគូ និងឧទកសាដក ជារបស់ភិក្ខុនីសង្ឃ ។

ព្រះពុទ្ធោវាទ ដែលព្រះអង្គទ្រង់ទេសនាប្រោសដល់ឧបាសិកា វិសាខា ដែលមានសម្តែងប្រាកដនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត** នៃ **ឧបោសថវគ្គ** ក្នុង **វិសាខសូត្រ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសាស្តា កាលគង់នៅក្នុងមិគារមាតុប្រាសាទ នៅក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខាមិគារមាតា ។ល។ អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយ

នៅក្នុងទីដ៏សមគួរហើយ ព្រះមហាវីរៈ ទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតា **មនាបកាយិកា** ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ? ម្នាលនាងវិសាខា មាតុគ្រាមក្នុងលោកនេះ ដែលមាតាបិតាមានប្រាថ្នា សេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្ត្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ចំពោះស្វាមីនោះ ១ ។ល។ ជាស្ត្រីមានចាគៈ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគស្រឡះហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ១ ។ ម្នាលនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ រមែងទៅកើតជាមួយនឹងពួកទេវតា **មនាបកាយិកា** ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមីនោះ សព្វកាលជានិច្ច មិនមើលងាយបុរសជាស្វាមី ដែលនាំមកនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះ ជាស្រីល្អ មិនបានធ្វើស្វាមីឲ្យក្តៅក្រហាយដោយពាក្យប្រណៃន ជាស្ត្រីមានបញ្ញា តែងបូជាស្វាមី និងបុគ្គលដែលជាទីគោរពទាំងអស់ ជាស្ត្រីមានសេចក្តីខ្នះខ្នែង មិនខ្ជិលច្រអូស សង្គ្រោះជនជាបរិស័ទ តែងប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្តនៃស្វាមី ថែទាំទ្រព្យសម្បត្តិ ដែលស្វាមីរកបានមក នារីណា ជាស្ត្រីលុះក្នុងអំណាចសេចក្តីប្រាថ្នារបស់ស្វាមី ប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួកទេវតា ឈ្មោះមនាបកាយិកា ។

ការថ្វាយសំពត់សម្រាប់ជូតមុខ ដែលនាងវិសាខាមិគារមាតាធ្លាប់បានធ្វើទុកជាតួយ៉ាង តាមដែលមានរឿងពោលទុកនៅក្នុង គម្ពីរមហាវគ្គ ព្រះវិនយបិដក នៃ ចីវរក្ខន្ធកៈ ដូចមានសេចក្តីថា ៖

គ្រានោះ នាងវិសាខាមិគារមាតា នាំយកសំពត់សម្រាប់ជូតមុខចូលទៅកាន់សម្នាក់ព្រះមានបុណ្យ លុះចូលទៅដល់ហើយ ថ្វាយបង្គំ

ព្រះវិជិតមារ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះជិនស្រីដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទទួលសំពត់សម្រាប់ជូតមុខរបស់ខ្ញុំព្រះអង្គ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរអង្វែង ។ ព្រះសម្មាសម្ពុទ្ធ ក៏បានទទួលសំពត់សម្រាប់ជូតមុខនោះ ។ វេលានោះព្រះសក្យមុនី ទ្រង់ពន្យល់វិសាខាមិគារមាតា ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ ឯនាងវិសាខាមិគារមាតា កាលដែលព្រះសាស្តាទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានជោគ ធ្វើប្រទក្សិណ ( ដើរវិលខាងស្តាំ ) ហើយចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះលោកនាថទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅពួកភិក្ខុមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់សម្រាប់ជូតមុខ ។ ព្រះពុទ្ធានុញ្ញាតក្នុងប្រការនេះឡើង ក៏ព្រោះនាងវិសាខាមិគារមាតា ជាអ្នកធ្វើឲ្យកើតឡើង

ក្នុងរឿងសំពត់សម្រាប់ងូតមុខនេះ ។

មហាឧបាសិកាវិសាខា ថ្វាយរបស់ប្រើប្រាស់ដល់ព្រះសាស្តា និងបានទទួលព្រះករុណាពីព្រះអង្គ ក៏ទ្រង់បានទទួល ហើយត្រាស់អនុញ្ញាតឲ្យដល់ភិក្ខុសង្ឃ ទើបបានជាតួយ៉ាងមួយ ដែលឧបាសិកាវិសាខាបានធ្វើទុកជាបែបបច្បាប់ ដែលមានរឿងពោលនៅក្នុងបាលី **គម្ពីរចុល្លវគ្គ ព្រះវិនយបិដក** នៃ **ខុទ្ទកវត្ថុក្ខន្ធកៈ** ដូចមានសេចក្តីថា ៖

គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកគ្គជនបទ គួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងចារិកទៅកាន់ក្រុងសាវត្ថី ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់ក្រុងសាវត្ថីនោះ ។ ឮថា ព្រះមុនីទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះ នាងវិសាខាមិគារមាតានាំយកក្អម និងទ្រនាប់សម្រាប់ជូតជើង មានរចនាដូចពកផ្លែឈូក និងអំបោសចូលទៅគាល់ព្រះមុនី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាអង្គុយនៅក្នុងទីដ៏សមគួរហើយ

បានក្រាបបង្គំទូលព្រះសាស្តា ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទទួលក្អម ទ្រនាប់ជូតជើង និងអំបោសដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំម្ចាស់អស់កាលជាអង្វែងទៅ ។ ព្រះសាស្តា ទ្រង់ទទួលតែក្អម និងអំបោស ។ ព្រះអង្គទ្រង់មិនទទួលទ្រនាប់ជូតជើងឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់នាងវិសាខាឲ្យយល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាងវិសាខា កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្អម និងអំបោស ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់សម្រាប់ជូតជើង មានរចនាដូចពកផ្លែឈូកទេ ភិក្ខុណាប្រើប្រាស់ត្រូវ

អាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់សម្រាប់ជូតជើង ៣ យ៉ាង គឺក្រួស ឬដុំថ្ម ១ អំបែងក្បឿង ឬឥដ្ឋ ១ ផ្សិតដែលកើតពីពពុះទឹកសមុទ្រ ១ ។

គ្រាខាងក្រោយ នាងវិសាខាមិគារមាតា នាំយកផ្ចិត ៤ ជ្រុង និងផ្ចិតមូល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានជោគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទទួលយកផ្ចិត ៤ ជ្រុង និងផ្ចិតមូល (ស្ពឹកត្នោត) ដើម្បីជាប្រយោជន៍ដើម្បីសេចក្ដីសុខដល់ខ្ញុំម្ចាស់ អស់កាលជាអង្វែង ។ ព្រះមានព្រះភាគទ្រង់ទទួលយកផ្ចិត ៤ ជ្រុង និងផ្ចិតមូលរួចហើយ ។ ទើបព្រះភគវាទ្រង់ពន្យល់នាងវិសាខាមិគារមាតាឲ្យយល់ ( ប្រយោជន៍ ) ដោយធម្មីកថា ។បេ។ ធ្វើប្រទក្សិណ រួចចៀសចេញទៅ ។

ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើ

ធម្មិកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតផ្ចិត ៤ ជ្រុង និងផ្ចិតមូល ។

ឧបាសិកាវិសាខា ជាអ្នកបានទទួលកិត្តិយស ត្រូវបានទទួលការ អញ្ជើញពីប្រជាជន គឺអ្នកដែលនឹងធ្វើការថ្វាយទាន ថែមទាំងបាន ទទួលការយកចិត្តទុកដាក់ពីភិក្ខុសង្ឃទាំងឡាយ ដែលមកទទួលការ ថ្វាយទាន តាមដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **យមកវគ្គ** ក្នុង **រឿងនាងសុមនាទេវី** ដូចមានសេចក្ដីថា ៖

នៅក្នុងផ្ទះអនាថបិណ្ឌិកសេដ្ឋី និងនៅក្នុងផ្ទះរបស់នាងវិសាខា មិគារមាតា នៅក្នុងក្រុងសាវត្ថីនោះ មានភិក្ខុសង្ឃដែលមកទទួលចង្ហាន់ ជាប្រចាំថ្ងៃ ២០០០ រូប ។ បុគ្គលណាក៏ដោយ នៅក្នុងក្រុងសាវត្ថី មានសេចក្ដីប្រាថ្នានឹងថ្វាយទាន អ្នកនោះនឹងត្រូវបានឱកាស ( វេលា ដ៏សមរម្យ ) ពីលោកទាំងពីរនាក់នោះជាមុន ទើបបានធ្វើ ។ មានពាក្យ សួរថា ព្រោះហេតុអ្វី ? មានពាក្យឆ្លើយថា ព្រោះពេលដែលមាន អ្នកដទៃៗ មកសួរម្ចាស់អ្នកផ្ដើមបុណ្យថា អនាថបិណ្ឌិកសេដ្ឋី និង

ឧបាសិកាវិសាខា អញ្ជើញមកបុណ្យរបស់អ្នកឯងដែរឬទេ ? កាលបើអ្នកម្ចាស់ផ្តើមបុណ្យតបថា មិនបានមកទេ សូម្បីទានដែលបុគ្គលនោះ ( ម្ចាស់ផ្តើមបុណ្យ ) លះបង់ទ្រព្យដល់ទៅមួយសែនកហាបណៈធ្វើបុណ្យ ក៏នៅមានអ្នកតិះដៀលថា នេះទានអ្វី ដោយហេតុថា លោកទាំងពីរនាក់រមែងដឹងការពេញចិត្តរបស់ភិក្ខុសង្ឃ និងកិច្ចដ៏សមគួរធ្វើដល់ភិក្ខុសង្ឃ កាលលោកទាំងពីរនាក់នោះ បានចូលរួមក្នុងកម្មវិធីបុណ្យ ភិក្ខុសង្ឃទាំងឡាយ រមែងបានឆាន់តាមការពេញចិត្ត ព្រោះដូច្នោះ បុគ្គលទាំងពួងដែលមានបំណងនឹងថ្វាយទាន ទើបអញ្ជើញលោកទាំងពីរនាក់ គឺអនាថបិណ្ឌិកសេដ្ឋី និងឧបាសិកាវិសាខាចូលរួមផងដែរ កាលលោកទាំងពីរនាក់មិនបានទទួលការយល់ព្រមភិក្ខុសង្ឃទាំងឡាយ ដែលមកទទួលចង្ហាន់ នៅក្នុងផ្ទះរបស់ខ្លួនដោយហេតុនេះ ។ ព្រោះហេតុដូច្នេះ ទើបឧបាសិកាវិសាខា ពិចារណាមើលថា អ្នកណាហ្ន៎ ល្មមនឹងធ្វើនាទីរក្សាភិក្ខុសង្ឃជំនួសយើងបាន ហើយបានឃើញធីតារបស់បុត្រ ( ជាចៅ ) ជាអ្នកសមរម្យ ទើបបានតាំងនាងឲ្យជាអ្នកមើលការខុសត្រូវ

ជំនួសខ្លួន ធីតារបស់បុត្រ ( ចៅស្រី ) ទទួលនាទីហើយ បានចាត់ការរក្សាភិក្ខុសង្ឃយ៉ាងល្អ នៅក្នុងផ្ទះរបស់ឧបាសិកាវិសាខា ។

ឧបាសិកាវិសាខា មិនមែនត្រឹមតែទំនុកបម្រុងព្រះពុទ្ធសាសនា ដោយការបរិច្ចាគទានតែម្យ៉ាងប៉ុណ្ណោះទេ នាងបានជួយការពារសេចក្តីជ្រះថ្លារបស់ភិក្ខុសង្ឃ នៅក្នុងផ្នែកខាងវិន័យទៀតផង តាមដែលមានសម្តែងនៅក្នុងបាលី **គម្ពីរមហាវិភង្គ ឬ អាទីនវកម្ម ព្រះវិនយបិដក** ដូចមានសេចក្តីថា ៖

សម័យនោះ ព្រះពុទ្ធដ៏មានបុញ្ញសិរី គង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កាលណោះ ឧទាយីដ៏មានអាយុជាភិក្ខុចូលទៅរកត្រកូល តែងចូលទៅរកត្រកូលទាំងឡាយជាច្រើន នៅក្នុងក្រុងសាវត្ថី ។ សម័យនោះ កុមារីនៃត្រកូលជាឧបដ្ឋាកឧទាយីដ៏មានអាយុ មាតាបិតាបានផ្សំឲ្យដល់កុមារម្នាក់នៃត្រកូល ។ គ្រាក្រោយឧទាយីដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ក្នុងពេលព្រឹកព្រហាម ហើយចូលទៅរកត្រកូលនោះ លុះចូលទៅហើយ ក៏សួរ

មនុស្សទាំងឡាយថា កុមារីឈ្មោះនេះទៅណាហើយ ? មនុស្សទាំងអម្បាលនោះ បាននិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កុមារីនោះ យើងខ្ញុំឲ្យទៅកុមារនៃត្រកូលឯណោះហើយ ។ ឯត្រកូលនោះឯង ក៏ជាឧបដ្ឋាកឧទាយីដ៏មានអាយុដែរ ។ គ្រានោះឯង ឧទាយីដ៏មានអាយុចូលទៅរកត្រកូលនោះ លុះចូលទៅដល់ហើយ ក៏សួរមនុស្សទាំងឡាយថា កុមារីឈ្មោះនេះនៅឯណា ? មនុស្សទាំងឡាយឆ្លើយថា លោកម្ចាស់ចូររកមើលចុះ កុមារីនោះនៅក្នុងបន្ទប់តូច ។ ទើបឧទាយីដ៏មានអាយុតែម្នាក់ឯង ចូលទៅរកកុមារីនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើសេវនកិច្ចបានជាមួយនឹងកុមារីតែម្នាក់ឯងនោះ ហើយនិយាយគ្នាអស់កាលដ៏គួរ ( ភិក្ខុអង្គុយជាមួយនឹងកុមារីអស់ពេលដែលគ្មានអ្នកណាទៅមកហើយនិយាយពាក្យស្និទ្ធស្នាលនឹងគ្នាថា សព្វថ្ងៃនាងឯងមិនអផ្សុកទេឬ នាងឯងមិនលំបាកចិត្តទេឬ នាងឯងមិនស្រេកឃ្លានទេឬ ? ដូច្នេះជាដើម) និងនិយាយធម៌អស់កាលដ៏គួរ ( ភិក្ខុអង្គុយជាមួយនឹងកុមារីអស់ពេល

ដែលគ្មានអ្នកណាទៅមក ហើយនិយាយធម៌ប្រាប់ស្រីនោះថា នាងឯង ត្រូវរក្សាឧបោសថសីល នាងត្រូវឲ្យសលាកភត្ត ដូច្នេះជាដើម ) ។

សម័យនោះឯង នាងវិសាខាជាម្ដាយនៃមិគារសេដ្ឋី នាងមានកូនច្រើន មានចៅច្រើន ទាំងកូនក៏មិនសូវមានរោគ ចៅក៏មិនសូវមានរោគ ជាស្រីមានមង្គលដ៏ប្រសើរ ។ មនុស្សទាំងឡាយ កាលមានការធ្វើទានធំ កាលបើមានអាវាហៈ និងវិវាហមង្គលជាដើម កាលបើមានមហោស្រព មានថ្ងៃចូលវស្សា និងថ្ងៃចេញវស្សាជាដើម តែងឲ្យនាងវិសាខាជាម្ដាយនៃមិគារសេដ្ឋី បរិភោគមុនគេជាដរាប ។ គ្រានោះឯង នាងវិសាខាជាមិគារមាតា គេបានអញ្ជើញឲ្យទៅកាន់ត្រកូលជាឧបដ្ឋាកនៃឧទាយីនោះ ។ ឯនាងវិសាខាជាមិគារមាតា បានឃើញឧទាយីដ៏មានអាយុតែម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើសេវនកិច្ចបាន ជាមួយនឹងកុមារីតែម្នាក់ឯងនោះ លុះឃើញហើយបាននិយាយពាក្យនេះនឹងឧទាយីដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ការនេះមិនមែនជាការស្ងាត់កំបាំងទេ មិនសមគួរទេ លោកម្ចាស់តែមួយអង្គ មកអង្គុយលើ

អាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើសេវនកិច្ចបាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនត្រូវការដោយធម៌នោះក៏ពិតមែនហើយ តែថា មនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងឲ្យជឿបានដោយក្រ ។ ចំណែកឧទាយីដ៏មានអាយុ ទុកជានាងវិសាខាជាមិគារមាតាថាឲ្យយ៉ាងនេះ ក៏នៅមិនអើពើសោះ ។ ទើបនាងវិសាខាជាមិគារមាតាចេញទៅ ហើយពិតរឿងនោះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស ។ល។ ភិក្ខុទាំងនោះពោលទោសតិះដៀលបន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ឧទាយីដ៏មានអាយុ ម្នាក់ឯងអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើសេវនកិច្ចបានជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ។ លំដាប់នោះឯង ភិក្ខុទាំងនោះក្រាបទូលរឿងនោះចំពោះព្រះសាស្តា ។ល។ ព្រះអង្គត្រាស់ថា ម្នាលឧទាយី ឮថា អ្នកឯងតែម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើសេវនកិច្ចបាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ពិតមែនឬ ? ឧទាយីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការនោះពិតមែន ។ ព្រះពុទ្ធ

ដ៏មានបុញ្ញសិរី ទ្រង់តិះដៀលថា ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិនស្រួល មិនទំនង ។បេ។ ម្នាលមោឃបុរស ហេតុដូចម្ដេចក៏អ្នកឯង តែម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើសេវនកិច្ចបាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង ។បេ។ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយ គប្បីសម្ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ តែម្នាក់និងម្នាក់ អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ សេវនកិច្ចបាន ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរ ជឿបាន ឃើញភិក្ខុនោះហើយ គប្បីចោទដោយអាបត្តិ ៣ យ៉ាង ចំពោះ អាបត្តិណាមួយ គឺអាបត្តិបារាជិកក្ដី សង្ឃាទិសេសក្ដី បាចិត្តិយក្ដី ភិក្ខុទទួលប្ដេជ្ញាការអង្គុយនោះមែន វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ ៣ យ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្ដី សង្ឃាទិសេសក្ដី បាចិត្តិយក្ដី ម្យ៉ាងទៀត ឧបាសិកានោះមានវាចាគួរជឿបាន ចោទដោយ អាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។

អាបត្តិនេះ ឈ្មោះថា អនិយត ( មិនទៀង ) ។

ម្នាលភិក្ខុទាំងឡាយ ព្រោះនិទាននេះ ដំណើរនេះ តថាគតបញ្ញត្ត នូវសិក្ខាបទដល់ភិក្ខុទាំងឡាយ ដោយអំណាចប្រយោជន៍ ១០ ប្រការ បានដល់ ១- ដើម្បីសេចក្តីល្អដល់សង្ឃ ២- ដើម្បីការនៅសប្បាយ ដល់សង្ឃ ៣-ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលទ្រុស្តសីល ៤- ដើម្បីកិរិយានៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ អ្នកមានសីល ជាទីស្រឡាញ់ ៥- ដើម្បីរាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ៦- ដើម្បីកម្ចាត់បង់អាសវធម៌ទាំងឡាយក្នុងបរលោក ៧- ដើម្បីញ៉ាំងបុគ្គល ទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ៨- ដើម្បីញ៉ាំងបុគ្គល ទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ៩- ដើម្បីឲ្យ ព្រះសទ្ធម្មតម្កល់នៅមាំ ១០- ដើម្បីអនុគ្រោះដល់ព្រះវិន័យ ។

ដោយព្រះពុទ្ធទ្រង់បញ្ញត្តថា ភិក្ខុរូបណាអង្គុយនៅក្នុងទីកំបាំង ជាមួយនឹងមាតុគ្រាម ប្រសិនបើមានឧបាសិកា អ្នកមានវាចាគួរជឿបានៗ ឃើញភិក្ខុ និងមាតុគ្រាមនោះហើយ គប្បីចោទឡើងដោយអាបត្តិ ៣

យ៉ាង អាបត្តិណាទីមួយ គឺអាបត្តិបារាជិក ១ អាបត្តិសង្ឃាទិសេស ១ អាបត្តិបាចិត្តិយ ១ ភិក្ខុអ្នកអង្គុយនោះ ទទួលដោយអាបត្តិណា ក្នុងអាបត្តិទាំង ៣ យ៉ាងនោះ គួរប្រាប់យ៉ាងនោះ ឬឧបាសិកាអ្នកមានវាចាគួរជឿបាននោះ ចោទដោយអាបត្តិណា គួរប្រាប់ភិក្ខុនោះ ដោយអាបត្តិនោះ អាបត្តិនេះហៅថា **អនិយត** ។ ក្នុងគ្រាមួយទៀត ឧទាយិភិក្ខុបន្តរឿងទៀត ដោយឧទាយិភិក្ខុគិតថា ព្រះលោកនាថ ទ្រង់ហាមឃាត់ក្នុងការអង្គុយនៅក្នុងទីកំបាំងជាមួយនឹងមាតុគ្រាម កាលលោកគិតឃើញដូច្នេះហើយ ទើបបានទៅអង្គុយនៅក្នុងទីកំបាំងត្រចៀក សទ្ទនា ឬសម្ដែងព្រះធម៌ តាមសមគួរដល់វេលាចំពោះខ្លួន ជាមួយនឹងស្រីតូចនោះទៀត ។ សូម្បីក្នុងគ្រាទី ២ នោះ ឧបាសិកាវិសាខា ក៏បានទទួលការអញ្ជើញទៅក្នុងផ្ទះត្រកូលនោះទៀត ហើយឧបាសិកាបានឃើញឧទាយិភិក្ខុអង្គុយនៅក្នុងទីកំបាំងត្រចៀកជាមួយនឹងនាងស្រីតូចនោះទៀត ទើបបានចូលទៅពោលដាស់តឿន ប៉ុន្តែឧទាយិភិក្ខុមិនស្ដាប់ កាលឧបាសិកាត្រឡប់មកវិញហើយ បាននាំយករឿងនោះ ប្រាប់ដល់ភិក្ខុទាំងឡាយ ភិក្ខុណា

មានសេចក្តីប្រាថ្នាតិច ភិក្ខុនោះក៏ពោលទោសតិះដៀល ថែមទាំងនាំយករឿងនោះ ទៅក្រាបទូលដល់ព្រះមុនីឲ្យទ្រង់ជ្រាប ។ ព្រោះនិទាននុ៎ះ ដំណើរនុ៎ះ ព្រះមហាវីរៈទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយបានត្រាស់សួរឧទាយិភិក្ខុ រហូតដល់ឧទាយិភិក្ខុទទួលសារភាពការពិត ហើយទើបទ្រង់បញ្ញត្តសិក្ខាបទទៀតថា ភិក្ខុណាអង្គុយក្នុងទីដែលមិនមានគ្រឿងបិទបាំង មិនអាចធ្វើអំពើអាក្រក់បាន ប៉ុន្តែអាចនិយាយចរចាជាមួយនឹងមាតុគ្រាមដោយវាចាគ្រោតគ្រាតបាន ភិក្ខុណាអង្គុយក្នុងទីអង្គុយដូចនេះ ដែលជាកន្លែងកំបាំងត្រចៀក ទល់គ្នាជាមួយនឹងមាតុគ្រាមប្រសិនបើមានឧបាសិកា អ្នកមានវាចាគួរជឿបានៗ ឃើញ ហើយចោទឡើងដោយអាបត្តិ ២ យ៉ាង គឺអាបត្តិសង្ឃាទិសេស ១ អាបត្តិបាចិត្តិយ ១ ភិក្ខុអ្នកអង្គុយនោះ ទទួលដោយអាបត្តិណា ក្នុងអាបត្តិទាំង ២ យ៉ាងនោះ ឲ្យប្រាប់ដោយអាបត្តិនោះ ឬឧបាសិកា អ្នកមានវាចាគួរជឿបាននោះ ចោទឡើងដោយអាបត្តិណា គឺអាបត្តិសង្ឃាទិសេស ឬបាចិត្តិយ ឲ្យប្រាប់ភិក្ខុដោយអាបត្តិនោះ អាបត្តិនេះហៅថា **អនិយត** ។

នេះបង្ហាញឲ្យឃើញថា ឧបាសិកាវិសាខា មានការព្រួយបារម្ភ និងការវិនាស ដែលត្រូវកើតឡើងដល់ភិក្ខុសង្ឃ និងព្រះពុទ្ធសាសនា ។

មនុស្សយើង មិនថា មានឋានៈ ឬមានសេចក្ដីល្អយ៉ាងណាទេ សូម្បីការប្រព្រឹត្តខ្លួនឲ្យល្អត្រឹមត្រូវ ក៏នៅតែមានរឿងមិនល្អ ដែលជាហេតុឲ្យកើតការសាំញ៉ាំ ហើយក្លាយជាសេចក្ដីទុក្ខទៀតផង ការពិតយ៉ាងនេះ សូម្បីមហាឧបាសិកាវិសាខា អ្នកបានផ្ដល់រំលំសេចក្ដីទុក្ខយ៉ាងនោះ ដោយគុណធម៌ គឺសេចក្ដីល្អ ក៏នៅមានទៀត ដូចដែលមានរឿងសម្ដែងទុកនៅក្នុងព្រះបាលី **ខុទ្ទកនិកាយ ឧទាន** នៃ **នវមសូត្រ** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** ដូចមានសេចក្ដីថា ៖

ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាមុនី ទ្រង់គង់នៅក្នុងប្រាសាទមិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ប្រយោជន៍ណាមួយរបស់នាងវិសាខាមិគារមាតា ជាប្រយោជន៍ទាក់ទងនឹងព្រះបាទបសេនទិកោសល ។ ព្រះបាទបសេនទិកោសល ទ្រង់មិនពិចារណាប្រយោជន៍នោះតាមបំណងឡើយ ។ គ្រានោះ នាង

វិសាខាចូលទៅគាល់ព្រះមហាវីរបុរសទាំងថ្ងៃក្តៅ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានបុណ្យ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះមានជោគទ្រង់ត្រាស់សួរថា ម្នាលនាងវិសាខា នាងមកអំពីណាទាំងថ្ងៃក្តៅម៉្លេះ ? នាងវិសាខាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រយោជន៍មួយរបស់ខ្ញុំព្រះអង្គក្នុងទីនេះ ជាប្រយោជន៍ជាប់ទាក់ទងនឹងព្រះបាទបសេនទិកោសលៗ ទ្រង់មិនបាន ពិចារណាប្រយោជន៍តាមបំណងឡើយ ។ លុះព្រះបរមសាស្តា ទ្រង់បានជ្រាបច្បាស់នូវសេចក្តីនោះហើយ ទើបទ្រង់បន្លឺឧទាននេះនៅក្នុងវេលានោះថា

ប្រយោជន៍ណាមួយ ដែលនៅក្នុងអំណាចនៃជនទាំងអស់ នាំមកនូវសេចក្តីទុក្ខ ឥស្សរភាពទាំងអស់ នាំមកនូវសុខ សត្វទាំងឡាយ ដែលជ្រមុជទៅក្នុងហេតុនៃទុក្ខទូទៅ តែងនឿយណាយ ព្រោះកិលេសជាគ្រឿងប្រកបទាំងឡាយ សត្វកន្លងបានដោយក្រ ។

សូមនាំពាក្យអធិប្បាយសេចក្តីនៃព្រះគាថានេះខ្លះៗ មកពោល

ទុកតាមន័យរបស់ព្រះអដ្ឋកថាចារ្យដូចតទៅនេះ ពាក្យថា ប្រយោជន៍ណាមួយ ដែលនៅក្នុងអំណាចនៃជនទាំងអស់ សេចក្តីថា មិនថាប្រយោជន៍ណាមួយ ដែលនៅក្នុងអំណាចនៃជនទាំងអស់ គឺទាក់ទងនឹងអ្នកទាំងអស់ ឈ្មោះថា ជាទុក្ខ គឺជារបស់ធ្វើឲ្យកើតទុក្ខទាំងពួងព្រោះមិនអាចឲ្យសម្រេចតាមសេចក្តីប្រាថ្នារបស់ខ្លួន ជារបស់មិនទៀង ។ ពាក្យថា **ប្រយោជន៍ណាមួយ ដែលជាឥស្សរៈ ជាសុខទាំងអស់** សេចក្តីថា ប្រយោជន៍ដែលជាឥស្សរៈមាន ២ ប្រការ បានដល់ ១- ឥស្សរៈផ្លូវលោក គឺជាធំក្នុងផ្លូវលោក ២- ឥស្សរៈក្នុងផ្លូវលោកុត្តរ គឺជាធំក្នុងផ្លូវផុតចាកលោក ។ ពាក្យថា **ប្រយោជន៍ណា គឺទូទៅដល់អ្នកដទៃ** សេចក្តីថា ទុក្ខ និងសុខ ដែលទាក់ទងជាមួយនឹងអ្នកដទៃសុទ្ធតែជាហេតុឲ្យសត្វទាំងឡាយក្តៅក្រហាយ តែប៉ុណ្ណោះ ។ ពាក្យថា ព្រោះការទាក់ទងទាំងឡាយ ដែលសត្វសុទ្ធតែកន្លងបានដោយក្រសំដៅដល់សេចក្តីទាក់ទងទាំង ៤ បានដល់ ១- ការទាក់ទងតាមផ្លូវកាមារម្មណ៍ ២- ការទាក់ទងក្នុងភព ៣- ការទាក់ទងតាមការឃើញ

៤- ការទាក់ទងក្នុងផ្លូវមិនដឹង ។

រឿងឧបោសថសីល និងអានិសង្សនៃការរក្សាឧបោសថសីល ដោយព្រះភគវា ត្រាស់សម្តែងពន្យល់ឲ្យនាងវិសាខាបានទទួលស្តាប់ ទើបធ្វើឲ្យយើងបានដឹងគោលរបស់ឧបោសថសីល ដូចមានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ តិកនិបាត** ថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ថ្ងៃនោះជាថ្ងៃឧបោសថសីល នាងវិសាខាបានចូលទៅគាល់ព្រះលោកនាយក លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះសាស្តា ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះភគវាបានត្រាស់ដូច្នេះថា នែនាងវិសាខា ចុះនាងមកពីណា ទាំងថ្ងៃម៉្លេះ ? នាងវិសាខាក្រាបទូលថា ថ្ងៃនេះ ខ្ញុំម្ចាស់រក្សាឧបោសថសីល ព្រះអង្គ ។ គ្រានោះ ព្រះបរមគ្រូត្រាស់ថា នែនាងវិសាខា ឧបោសថសីល មាន ៣ យ៉ាង ។ ឧបោសថសីល ៣ យ៉ាង តើដូចម្តេច ? ១- គោបាល

ឧបោសថ ( ឧបោសថរបស់អ្នកគង្វាលគោ ) ២- និគ្គណ្ឋឧបោសថ ( ឧបោសថរបស់និគ្រន្ថ ) ៣- អរិយុបោសថ ( ឧបោសថរបស់ព្រះអរិយៈ ) ។ នែនាងវិសាខា **គោបាលឧបោសថ តើដូចម្ដេច ?** នែនាងវិសាខា ដូចអ្នកគង្វាលគោប្រគល់គោទាំងឡាយឲ្យដល់អ្នកម្ចាស់គោក្នុងវេលាល្ងាចរួចហើយ គិតរំពឹងដូច្នេះថា ថ្ងៃនេះ គោទាំងឡាយត្រាច់ទៅរកស៊ីក្នុងទីឯណោះៗ ផឹកទឹកក្នុងទីឯណោះៗ ថ្ងៃស្អែកនេះ គោទាំងឡាយនឹងត្រាច់ទៅរកស៊ីក្នុងទីឯណោះៗ នឹងផឹកទឹកក្នុងទីឯណោះៗ យ៉ាងណាមិញ ។ នែនាងវិសាខា បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នករក្សាឧបោសថសីលហើយ គិតជញ្ជឹងដូច្នេះថា ក្នុងថ្ងៃនេះ អាត្មាអញបានទំពាស៊ីនូវខាទនីយនេះផងៗ អាត្មាបានបរិភោគនូវភោជនីយាហារនេះផងៗ ថ្ងៃស្អែកនេះ អាត្មាអញនឹងទំពាស៊ីនូវខាទនីយនេះផងៗ និងបរិភោគនូវខាទនីយនេះផងៗ បុគ្គលនោះមានចិត្តប្រកបដោយអភិជ្ឈា តែងញុំាងថ្ងៃឲ្យកន្លងទៅដោយលោភៈនោះ ក៏យ៉ាងនោះឯង ។ នែនាងវិសាខា យ៉ាងនេះឯងឈ្មោះថា **គោបាលឧបោសថ** ។ នែនាងវិសាខា

គោបាលឧបោសថ ដែលបុគ្គលរក្សាយ៉ាងនេះ ជាឧបោសថមិនមាន ផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលបានច្រើនទេ ។

នែនាងវិសាខា ចុះនិគ្គណ្ឋឧបោសថ តើដូចម្តេច ? នែនាងវិសាខា មានពួកសមណៈហៅថា និគ្គណ្ឋ សមណៈអម្បាលនោះ តែងដឹកនាំ សាវកយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកអាយសត្វទាំងឡាយ មាននៅទិសខាងកើត ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា ( សម្លាប់ ) សត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅទិស ខាងលិច ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វ អម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងជើង ខាង នាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយមាននៅទិសខាងត្បូង ខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញាក្នុងសត្វនោះចុះ ។ ពួកនិគ្គណ្ឋតែងដឹកនាំសាវកឲ្យ អាណិត អនុគ្រោះចំពោះពួកសត្វខ្លះ តែងដឹកនាំសាវកមិនឲ្យអាណិត

មិនឲ្យអនុគ្រោះចំពោះពួកសត្វខ្លះ ។ ក្នុងថ្ងៃឧបោសថនោះ គេតែងដឹកនាំសាវ័កយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកអាយ អ្នកចូរស្រោតសំពត់ឲ្យអស់ ហើយពោលយ៉ាងនេះថា អាត្មាអញមិនទាក់ទាមនឹងនរណាៗ ក្នុងទីណាៗ នឹងមានកង្វល់ក្នុងរបស់អ្វីៗ ក្នុងទីណាៗ ក៏មិនមានដល់អាត្មាអញឡើយ តែមាតាបិតារបស់គេក៏ដឹងថា នេះបុត្ររបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះមាតាបិតារបស់អញ បុត្រភរិយារបស់គេក៏ដឹងថា នេះជាស្វាមីរបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះជាបុត្រភរិយារបស់អញ ពួកបុរសជាទាសកម្មកររបស់គេក៏ដឹងថា នេះជាម្ចាស់របស់អញ ទាំងខ្លួនគេក៏ដឹងថា នេះជាពួកបុរស ដែលជាទាសកម្មកររបស់អញ ( សាវ័កទាំងនោះ ) ត្រូវគេដឹកនាំក្នុងសច្ចៈដូច្នេះក្នុងសម័យណា ( អ្នកដឹកនាំ ) ឈ្មោះថា ដឹកនាំក្នុងមុសាវាទ ក្នុងសម័យនោះ ។ តថាគតពោលថា ពាក្យដឹកនាំនេះ ជាពាក្យមុសាវាទរបស់គេ ។ លុះកន្លងរាត្រីនោះហើយ គេបរិភោគភោគៈទាំងអម្បាលនោះ ដែលម្ចាស់គេមិនបានឲ្យ ។ តថាគតពោលថា ការបរិភោគនេះ ជាអទិន្នាទានរបស់គេ ។ នែនាងវិសាខា

យ៉ាងនេះឯង ឈ្មោះថា **និគ្គណ្ឋឧបោសថ** ។ នែនាងវិសាខា និគ្គណ្ឋ-ឧបោសថដែលគេរក្សាយ៉ាងនេះ ជាឧបោសថមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ នែនាងវិសាខា ចុះអរិយុបោសថ តើដូចម្តេច ? នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ? នែនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះតថាគត ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជាក់ច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិល

ត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវ័កនោះ កំពុងរឭកនូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងនោះ អរិយសាវ័កនោះក៏លះបង់ចេញបាន នែនាងវិសាខា ដូចការជម្រះក្បាលដែលមិនស្អាត ឲ្យស្អាតបានដោយសេចក្តីព្យាយាម ។ នែនាងវិសាខា ចុះការជម្រះក្បាលដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ? នែនាងវិសាខា អាស្រ័យកាក (កន្ទួតព្រៃ) ផង អាស្រ័យដីផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះ របស់បុរសផង ទើបធ្វើក្បាលដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាមនោះយ៉ាងណាមិញ ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បានដោយសេចក្តីព្យាយាមក៏យ៉ាងនោះដែរ ។

នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់ ដោយសេចក្តីព្យាយាម តើដូចម្តេច ? នែនាងវិសាខា អរិយសាវ័កនៅក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះតថាគតថា ព្រះសាស្តាអង្គនោះ

។បេ។ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវកនោះ កំពុងរឭកជារឿយៗនូវព្រះតថាគត ចិត្តរមែងជ្រះថ្លា កាពរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ នែនាងវិសាខា អរិយសាវកនេះ ហៅថា រក្សាព្រហ្មុបោសថ (ឧបោសថរបស់ព្រហ្ម) នៅរួមនឹងព្រហ្ម ចិត្តរបស់គេប្រារព្ធចំពោះព្រហ្ម រមែងជ្រះថ្លា កាពរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមយ៉ាងនេះ ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭកជារឿយៗ នូវព្រះធម៌ថា ព្រះធម៌ដែលព្រះមានព្រះភាគ ត្រាស់ដោយ

ប្រពៃហើយ ជាធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវកនោះ កំពុងរឭកជារឿយៗ នូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា ដូចការជម្រះកាយដែលមិនស្អាត រមែងឲ្យស្អាតបានដោយសេចក្ដីព្យាយាម ។ នែនាងវិសាខា ចុះការជម្រះកាយដែលមិនស្អាត រមែងឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា ការអាស្រ័យដុំលម្អិតសម្រាប់ជម្រះកាយផង អាស្រ័យលម្អិតសម្រាប់ងូតផង អាស្រ័យទឹកផង អាស្រ័យសេចក្ដីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបធ្វើការជម្រះកាយ ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្ដីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមយ៉ាង

នោះដែរ ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ តែងរឭកជារឿយៗ នូវព្រះធម៌ថា ព្រះធម៌ដែល ព្រះសាស្ដា ត្រាស់ទុកដោយប្រពៃហើយ ។បេ។ ជាធម៌ដែលវិញ្ញូជន ទាំងឡាយ គប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវកនោះ កំពុងរឭក នូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេស ទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា អរិយសាវកនេះ ហៅថា រក្សា ធម្មុបោសថ នៅរួមដោយធម៌ ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះ ព្រះធម៌ រមែងជ្រះថ្លា សេចក្ដីរីករាយ ក៏រមែងកើតឡើង ឧបក្កិលេស ទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមយ៉ាងនេះ ។ នែនាងវិសាខា ការធ្វើ ចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។

នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បានដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ តែងរឭកជារឿយៗ នូវព្រះសង្ឃថា ពួកសាវកនៃព្រះសាស្ដា ប្រតិបត្តិដោយប្រពៃហើយ ពួកសាវកនៃព្រះមានព្រះភាគប្រតិបត្តិដោយត្រង់ហើយ ប្រតិបត្តិសមគួរហើយ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ពួកសាវកណា បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួក សាវកនៃព្រះមានព្រះភាគនោះ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកអំពីចម្ងាយ ហើយបូជា គួរទទួលនូវអាគន្ទុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តក្រៃលែងជាងគ្មាន ។ កាលអរិយ-សាវកនោះកំពុងរឭកជារឿយៗ នូវព្រះសង្ឃ ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់បាន ។ នែនាងវិសាខា ដូចការធ្វើសំពត់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម ។

នែនាងវិសាខា ចុះការធ្វើសំពត់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ?នែនាងវិសាខា ព្រោះអាស្រ័យចំហាយផង អាស្រ័យទឹកក្បុងផង អាស្រ័យអាចម៍គោផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបធ្វើសំពត់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះយ៉ាងណាមិញ ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បានដោយសេចក្តីព្យាយាមក៏យ៉ាងនោះឯង ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច? នែនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រមែងរឭកជារឿយៗនូវព្រះសង្ឃថា ពួកសាវកនៃព្រះសាស្តា លោកប្រតិបត្តិប្រពៃហើយ ។ល។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលព្រះអរិយសាវកនោះ កំពុងរឭកជារឿយៗ នូវព្រះសង្ឃ ចិត្តក៏ជ្រះថ្លាសេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្តឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។

នៃនាងវិសាខា អរិយសាវកនេះ ហៅថា រក្សាសង្ឃុបោសថ នៅរួម ជាមួយនឹងព្រះសង្ឃ ចិត្តរបស់ព្រះអរិយសាវកនោះ ប្រារព្ធចំពោះ ព្រះសង្ឃ រមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេស ទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នៃនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមយ៉ាងនេះឯង ។ នៃនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។

នៃនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នៃនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ រឭកជារឿយៗ នូវសីលរបស់ខ្លួន ជាសីលមិនដាច់ មិនធ្លុះធ្លាយ មិនពព្រុស មិនពពាល ជាសីលអ្នកជា ជាសីលដែល វិញ្ញូជនសរសើរហើយ ជាសីលប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ជាសីល ប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវកនោះ កំពុងរឭកជារឿយៗ នូវសីល ចិត្តក៏ជ្រះថ្លា សេចក្ដីរីករាយ រមែងកើតឡើង ឧបក្កិលេស

ទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា ដូចការដុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម ។ នែនាងវិសាខា ចុះដុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា ព្រោះអាស្រ័យប្រេងផង អាស្រ័យផេះផង អាស្រ័យប្រាស់ផង អាស្រ័យសេចក្ដីព្យាយាមសមគួរដល់កិច្ចនោះរបស់បុរសផង ទើបដុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម យ៉ាងនេះ យ៉ាងណាមិញ ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមក៏យ៉ាងនោះឯង ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចកីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា អរិយសាវក ក្នុងធម្មវិន័យនេះ រឭកជារឿយៗ នូវសីលរបស់ខ្លួន ដែលជាសីលមិនដាច់ មិនធ្លុះធ្លាយ ។ល។ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវកនោះ កំពុងរឭកជារឿយៗ នូវសីល ចិត្តក៏រមែងជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេស

ទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា អរិយសាវកនេះ ហៅថា រក្សាសីលុបោសថ នៅរួមដោយសីល មួយទៀត ចិត្តរបស់អរិយសាវកនោះ ប្រារព្ធចំពោះសីល ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយ-សាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ? នែនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ រឭកជារឿយៗ នូវទេវតាទាំងឡាយថា ពួកទេវតាជាន់ចាតុម្មហារាជិកាក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ពួកទេវតាជាន់យាមៈក៏មាន ពួកទេវតាជាន់តុសិតក៏មាន ពួកទេវតាជាន់និម្មានរតីក៏មាន ពួកទេវតាជាន់បរនិម្មិតវសវត្តីក៏មាន ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន

ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសីល មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សីលមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសុតៈ មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានមកកើតក្នុងភពនោះ សុតៈមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយចាគៈ មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ ចាគៈមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយបញ្ញា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ មានសភាពដូច្នោះ របស់អាត្មាអញក៏មាន ។ កាលអរិយសាវកនោះ រឭកជារឿយៗ នូវសទ្ធា សីល សុតៈ ចាគៈ

បញ្ញារបស់ខ្លួន និងរបស់ទេវតាទាំងអម្បាលនោះ ចិត្តក៏ជ្រះថ្លា សេចក្ដីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា ដូចការដុសខាត់មាស ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។

នែនាងវិសាខា ចុះការដុសខាត់មាស ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា ព្រោះអាស្រ័យបាវមាសផង អាស្រ័យដីប្រៃផង អាស្រ័យរង្គផង អាស្រ័យស្នប់ និងដង្កាប់ផង អាស្រ័យសេចក្ដីព្យាយាមដ៏សមគួរដល់កិច្ចនោះ របស់បុរសផង ទើបដុសខាត់មាស ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ក៏ដូច្នោះយ៉ាងនោះឯង ។ នែនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ? នែនាងវិសាខា អរិយសាវកក្នុងធម្មវិន័យនេះ

តែងរឭកជារឿយៗ នូវទេវតាថា ពួកទេវតាជាន់ចាតុម្មហារាជិកាក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ។ល។ ពួកទេវតា ដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសុតៈ... ដោយចាគៈ... ដោយបញ្ញា... មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ។ កាលអរិយសាវកនោះ រឭកជារឿយៗ នូវសទ្ធា សីល សុតៈ ចាគៈ បញ្ញារបស់ខ្លួន និងរបស់ទេវតានោះ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណា របស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះ ក៏លះបង់ចេញបាន ។ នែនាងវិសាខា អរិយសាវកនេះ ហៅថា **ទេវតូបោសថ** នៅរួមជាមួយនឹងពួកទេវតា មួយទៀត ចិត្តរបស់អរិយសាវកនោះ

ប្រាប់ទេវតា ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយរមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវកនោះក៏លះបង់ចេញបាន ។ នែនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បានដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។ នែនាងវិសាខា អរិយសាវកនោះ តែងពិចារណាឃើញដូច្នេះថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ចំពោះសព្វសត្វ ដែលមានជីវិត ដរាបដល់អស់ជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្ត

ទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតរហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតនៅអស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់ព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក ( អព្រហ្មចរិយៈ ) វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក (អព្រហ្មចរិយៈ) វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុកអស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់នូវមុសាវាទ វៀរចាកនូវ

មុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោលបង្ខាច់សត្វលោក រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះក៏លះបង់នូវមុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោលបង្ខាច់សត្វលោក អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់ការក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ រហូតអស់មួយជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់នូវការក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ វៀរចាកការក្រេបផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយបរិភោគភត្ត

តែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏បរិភោគកត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ វៀរចាកការមើលនូវរបាំ និងការស្តាប់នូវចម្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អាត្មាអញក្នុងថ្ងៃនេះ ក៏វៀរចាកការមើលរបាំ និងការស្តាប់ចម្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់ទីដេក ទីអង្គុយ

ដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាបលើគ្រែគ្គី លើកម្រាលស្មៅក្តី រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេក ទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាបលើគ្រែគ្គី លើកម្រាលស្មៅក្តី អស់យប់នេះ និងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ នែនាងវិសាខា យ៉ាងនេះឈ្មោះថាអរិយុបោសថ នែនាងវិសាខា អរិយុបោសថដែលបុគ្គលរក្សាយ៉ាងនេះ តែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន ផ្សាយផលទៅច្រើន ។ មានផលច្រើនដូចម្តេច មានអានិសង្សច្រើនដូចម្តេច មានសេចក្តីរុងរឿងច្រើនដូចម្តេច ផ្សាយផលទៅច្រើនដូចម្តេច ? នែនាងវិសាខា ប្រៀបដូចបុគ្គលណាមួយ គប្បីគ្រងរាជសម្បត្តិជាឥស្សរិយាធិបតីនៃមហាជនទាំង ១៦ នេះ ដែលមានរតនៈ ៧ ប្រការ

ដ៏ច្រើន មហាជនទាំង ១៦ គឺអង្គៈ មគធៈ កាសី កោសល វជ្ជី មល្លៈ ចេតី វង្សៈ កុរុ បញ្ចាលៈ មច្ឆៈ សុរសេនៈ អស្សកៈ អវន្តី គន្ធារៈ កម្ពោជៈ រាជសម្បត្តិរបស់បុគ្គលនោះ មានតម្លៃមិនស្មើនឹងចំណិតទីដប់ប្រាំមួយៗ លើកនៃឧបោសថ ដែលប្រកបដោយអង្គ ៨ ឡើយ ។ ដំណើរនេះព្រោះហេតុអ្វី ? នែនាងវិសាខា រាជសម្បត្តិ ជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខទិព្វ ឃើញស្តួចស្តើងណាស់ ។ នែនាងវិសាខា ៥០ ឆ្នាំរបស់មនុស្ស ជាមួយយប់ មួយថ្ងៃរបស់ពួកទេវតាជាន់ចាតុម្មហាជិកា រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៥០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់ចាតុម្មហារាជិកា ។ នែនាងវិសាខា ហេតុនោះរមែងមានប្រាកដត្រង់ពាក្យថា បុរស ឬស្ត្រីពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលោងកាយស្លាប់ទៅៗ កើតរួមជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកា ។ នែនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ

ឃើញស្តួចស្តើងនេះ តថាគតពោលសំដៅយកត្រង់ហេតុនោះឯង ។

នៃនាងវិសាខា ១០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយ ថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវត្តិង្ស ។ នៃនាងវិសាខា ហេតុនោះរមែងមានប្រាកដ ត្រង់ពាក្យថា បុរស ឬស្ត្រីពួកខ្លះ ក្នុងលោកនេះរក្សាឧបោសថ ប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅៗ កើតរួមជាមួយនឹងពួក ទេវតាជាន់តាវត្តិង្ស ។ នៃនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វឃើញស្តួចស្តើងនេះ តថាគតពោលសំដៅយកត្រង់ហេតុនោះឯង ។

នៃនាងវិសាខា ២០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់យាមៈ រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ២០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់យាមៈ ។ នៃនាងវិសាខា ហេតុនោះ រមែង

មានប្រាកដត្រង់ពាក្យថា បុរស ឬស្ត្រីពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថ ដែលប្រកដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅៗ កើតរួមជាមួយនឹងពួកទេវតាជាន់យាមៈ ។ នែនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ឃើញស្តួចស្តើងនេះ តថាគតពោលសំដៅយកត្រង់ហេតុនោះឯង ។ នែនាងវិសាខា ៤០០ ឆ្នាំ របស់មនុស្សជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់តុសិត រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៤០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តុសិត ។ នែនាងវិសាខា ហេតុនោះ រមែងមានប្រាកដត្រង់ពាក្យថា បុរស ឬស្ត្រីពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅៗ កើតរួមជាមួយនឹងពួកទេវតាជាន់តុសិត ។ នែនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ ឃើញស្តួចស្តើងនេះ តថាគតពោលសំដៅយកត្រង់ហេតុនោះឯង ។ នែនាងវិសាខា

៨០០ ឆ្នាំ របស់មនុស្ស ជា ១ យប់ ១ ថ្ងៃ របស់ពួកទេវតាជាន់និម្មានរតី រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៨០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់និម្មានរតី ។ នែនាងវិសាខា ហេតុនោះរមែងមានប្រាកដត្រង់ពាក្យថា បុរស ឬ ស្ត្រីពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅៗ កើតរួមជាមួយនឹងពួកទេវតាជាន់និម្មានរតី ។ នែនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខ ឃើញស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនោះឯង ។ នែនាងវិសាខា ១៦០០ ឆ្នាំ របស់មនុស្ស ជា ១ យប់ ១ ថ្ងៃ របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី រាប់តាមរាត្រីនោះ ៣០ រាត្រី ជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១៦០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ នែនាងវិសាខា ហេតុនោះរមែងមានប្រាកដត្រង់ពាក្យថា បុរស ឬស្ត្រីពួកខ្លះ ក្នុងលោកនេះ រក្សា

នូវឧបោសថប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅៗ កើតរួមជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ។ នៃនាងវិសាខា ដែលហៅថា រាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខទិព្វ ឃើញស្តួចស្តើងនេះ តថាគតពោលសំដៅយកត្រង់ហេតុនោះឯង ។

បុរស ឬស្ត្រី មិនគប្បីសម្លាប់សត្វ ១ មិនគប្បីលួចយកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ ១ មិនគប្បីនិយាយកុហក ១ មិនគប្បីក្រេបផឹក នូវទឹកស្រវឹង ១ គប្បីវៀរចាកមេថុន ដែលមិនមែនជាសេចក្តីប្រព្រឹត្ត ដ៏ប្រសើរ ១ មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រី និងភោជនក្នុង វេលាខុសកាលមួយ ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បីប្រើប្រាស់ គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ ( ដែលត្រូវប្រមាណ ) ឬកម្រាល ដែលក្រាលផ្ទាល់នឹងផែនដី ១ ( បណ្ឌិតទាំងឡាយពោលសរសើរ ) ឧបោសថប្រកបដោយអង្គ ៨ នោះ ដែលព្រះពុទ្ធទ្រង់ដល់នូវទីបំផុត នៃទុក្ខ ទ្រង់ប្រកាសទុកហើយ ។ ព្រះចន្ទ និងព្រះអាទិត្យទាំងពីរ មានរស្មី ដ៏រុងរឿង ភ្លឺធុះផ្សាយចេញទៅអស់ទីមានកំណត់ត្រឹមណា មួយទៀត

ព្រះចន្ទ និងព្រះអាទិត្យ មាននាទីកម្ចាត់បង់នូវភាពងងឹត មានដំណើរទៅក្នុងអាកាស ចាំងពន្លឺសព្វទិសតែងបំភ្លឺក្នុងផ្ទៃមេឃ ទ្រព្យណាមួយដែលមាននៅក្នុងចន្លោះនោះ គឺកែវមុក្តា កែវមណី កែវពៃទូរ្យដ៏ល្អមួយវិញទៀត ដែលហៅថា មាសសិង្គី មាសកាញ្ចនៈ មាសជាតរូប និងមាសសហជក ទ្រព្យទាំងអម្បាលនោះ ( មានតម្លៃ ) មិនដល់នូវចំណិតទីដប់ប្រាំមួយៗ លើកនៃឧបោសថប្រកបដោយអង្គ ៨ ឡើយ ដូចពួកផ្កាយទាំងអស់ ( ភ្លឺ ) មិនដល់ពន្លឺព្រះអាទិត្យឡើយ ព្រោះហេតុនោះ បុរសស្ត្រីអ្នកមានសីល បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ធ្វើបុណ្យទាំងឡាយដែលមានសុខជាកម្រៃ ជាអ្នកមិនត្រូវគេតិះដៀល តែងទៅកើតក្នុងស្ថានសួគ៌ ។

ក្រៅអំពីដែលមានចារឹកនៅក្នុងគម្ពីរ អង្គុត្តរនិកាយ តិកនិបាត ឧបោសថសីល ក្នុងវគ្គតទៅទៀតនេះ មានសម្តែងនៅក្នុងព្រះបាលីគម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត នៃ ឧបោសថវគ្គ ក្នុង នវមភាគបណ្ណាសកៈ ដែលពោលដោយឧបោសថ ប្រកបដោយអង្គ ៨ ប្រការ

មានផលច្រើន ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះសាស្ដា កាលគង់នៅនាប្រាសាទមិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខា ជាមិគារមាតា ចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះទសពល ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនាងវិសាខា ជាមិគារមាតា អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះសាស្ដា ទ្រង់ត្រាស់ដូចនេះថា ម្នាលវិសាខា ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងច្រើន មានសេចក្ដីផ្សាយទៅច្រើន ។ ម្នាលនាងវិសាខា ចុះឧបោសថដែលប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងច្រើន មានសេចក្ដីផ្សាយទៅច្រើន តើដោយប្រការដូចម្ដេច ? ម្នាលនាងវិសាខា អរិយសាវកក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះ

ហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំអញលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានគ្រឿងសស្ត្រាដាក់ចុះហើយ មានអាជ្ញាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វអស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផងខ្ញុំអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។ល។ ព្រះអរហន្តទាំងឡាយ លះបង់នូវសេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្តី លើកម្រាលដែលគេធ្វើដោយស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំ អញលះបង់សេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្តី លើកម្រាលដែលគេធ្វើដោយស្មៅក្តី អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់

ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលវិសាខា ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាយ៉ាងនេះហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ឧបោសថមានផលច្រើនដូចម្តេច មានអានិសង្សច្រើនដូចម្តេច មានសេចក្តីរុងរឿងច្រើនដូចម្តេច មានសេចក្តីផ្សាយទៅច្រើនដូចម្តេច ? ម្នាលនាងវិសាខា ប្រៀបដូចបុគ្គលសោយរាជ្យជាឥស្សរាធិបតី នៃមហាជនបទទាំង ១៦ នេះ ដែលជាជនបទសម្បូរដោយកែវ ៧ ប្រការ គឺមហាជនបទឈ្មោះអង្គៈ ១ មគធៈ ១ កាសី ១ កោសល ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វំសៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ រាជសម្បត្តិនៃមហាជនបទទាំងនោះ មិនដល់នូវចំណិត ១ ក្នុងចំណិតទីដប់ប្រាំមួយៗ លើកនៃឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ? ម្នាលនាងវិសាខា រាជសម្បត្តិ

របស់មនុស្សជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្យ ។ ម្នាលនាងវិសាខា ៥០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ទេវតាចាតុម្មហារាជិកា រាប់រាត្រីនោះ បាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់ពួកទេវតា ចាតុម្មហារាជិកា ។ ម្នាលនាងវិសាខា ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកា ។ ម្នាលនាងវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្យដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលនាងវិសាខា ១០០ ឆ្នាំរបស់មនុស្ស ត្រូវជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់តាវត្តិង្ស រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណ

នៃអាយុរបស់ទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ហេតុនេះរមែង មានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកប ដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា រាជសម្បត្តិ របស់មនុស្សនេះឯងស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តី សុខ ជារបស់ទិព្យដែលតថាគតសម្តែងហើយ អាស្រ័យហេតុនេះ ។ ម្នាលនាងវិសាខា ២០០ ឆ្នាំរបស់មនុស្ស ។ល។ ៤០០ ឆ្នាំរបស់មនុស្ស ។ល។ ៨០០ ឆ្នាំរបស់មនុស្ស ១៦០០ ឆ្នាំរបស់មនុស្ស ត្រូវជាមួយ យប់មួយថ្ងៃរបស់ពួកបរនិម្មិតវសវត្តីទេវតា រាប់រាត្រីនោះ បាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះ បាន ១៦០០០ ( មួយម៉ឺនប្រាំមួយពាន់ ) ឆ្នាំទិព្យ ត្រូវជាប្រមាណនៃ អាយុរបស់ពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលនាងវិសាខា ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅ

កើតជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យដែលតថាគតសម្តែងហើយព្រោះអាស្រ័យហេតុនេះ ។

បុគ្គលមិនគប្បីសម្លាប់សត្វ ១ មិនគប្បីកាន់យកវត្ថុ ដែលគេមិនបានឲ្យ ១ មិនគប្បីពោលពាក្យកុហក ១ មិនគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរ គឺមេថុន ១ មិនគប្បីបរិភោគភោជនក្នុងវេលារាត្រី និងក្នុងវេលាវិកាល ១ មិនគប្បីទ្រទ្រង់នូវផ្កាកម្រងមិនគប្បីប្រោះព្រំដោយគ្រឿងក្រអូប ១ គប្បីដេកលើគ្រែ លើផែនដីឬលើកម្រាល ១ ព្រះពុទ្ធព្រះអង្គដល់នូវទីបំផុតនៃសេចក្តីទុក្ខ ទ្រង់ប្រកាសហើយនូវឧបោសថប្រកបដោយអង្គ ៨ ប្រការនេះឯង សភាវៈទាំងឡាយ ២ គឺព្រះចន្ទ ១ ព្រះអាទិត្យ ១ ជាសភាវៈល្អមើល កាលបំភ្លឺលោក រមែងចរទៅអស់ទីត្រឹមណា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ដែលកម្ចាត់បង់នូវភាពងងឹត ចរទៅក្នុងអាកាស ញ៉ាំងទិសឲ្យរុងរឿងភ្លឺច្បាស់

ក្នុងអាកាសអស់ទីត្រឹមនោះ ទ្រព្យណាមានក្នុងចន្លោះនេះ គឺកែវមុក្តាក្តី កែវមណីក្តី ពៃទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គីក្តី ឈ្មោះសុវណ្ណក្តី ឬមាសឈ្មោះកាញ្ចនៈក្តី ឈ្មោះជាតរូបក្តី ឈ្មោះហដកៈក្តី ទ្រព្យទាំងអម្បាលនោះ មិនដល់នូវចំណិត ១ ក្នុងចំណែកដប់ប្រាំមួយៗ លើកនៃឧបោសថដែលប្រកបដោយអង្គ ៨ ប្រការឡើយ ដូចជាពួកផ្កាយទាំងអស់ មិនដល់នូវពន្លឺនៃព្រះចន្ទ ហេតុដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល គួរចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ ពួកជនដែលមិនមានគេនិន្ទា បំពេញនូវបុណ្យកុសល ដែលមានសេចក្តីសុខជាកម្រៃ រមែងចូលទៅកាន់ស្ថានសួគ៌បាន ។

មានពុទ្ធោវាទមួយសូត្រទៀត ដែលព្រះមានព្រះភាគសម្តែងប្រោសប្រទានដល់នាងវិសាខា តាមដែលមានសម្តែងប្រាកដនៅក្នុងគម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត នៃ ឧបោសថ ពោលដោយគុណរបស់មាតុគ្រាមអ្នកមានជ័យជម្នះ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសម្ពុទ្ធ កាលគង់នៅក្នុងវត្តបុព្វារាមជាប្រាសាទ

របស់មិគារមាតា ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះភគវា លុះចូលទៅដល់ហើយ ។ល។ ក៏អង្គុយនៅ ។ លុះនាងវិសាខាអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានជោគទ្រង់ត្រាស់ដូច្នេះថា នែនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិដើម្បីឈ្នះនូវលោកនេះ លោកនេះក៏ឈ្មោះថា មាតុគ្រាមនោះប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការនោះ តើដូចម្តេចខ្លះ ? ម្នាលនាងវិសាខា មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ ១ ចេះសង្គ្រោះពួកជនជាបរិស័ទ ១ ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តរបស់ស្វាមី ១ ចេះថែទាំសម្បត្តិដែលស្វាមីរកបានមក ១ ។ នែនាងវិសាខា ចុះមាតុគ្រាមជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ តើដូចម្តេច ? នែនាងវិសាខា មាតុគ្រាមក្នុងលោកនេះ ការងារទាំងឡាយណា ជាបន្ទុករបស់ស្វាមី ទោះរោមសត្វក្តី កប្បាសក្តី ជាស្ត្រីឆ្លៀវឆ្លាស មិនខ្ជិលប្រអូសក្នុងការងារទាំងនោះ ប្រកបដោយការពិចារណាដោយឧបាយក្នុងការងារនោះថា គួរធ្វើ គួរចាត់ចែង ។ នែនាងវិសាខា

មាតុគ្រាមជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃយ៉ាងនេះឯង ។ នែនាង វិសាខា ចុះមាតុគ្រាមជាស្ត្រីចេះសង្គ្រោះពួកជនជាបរិស័ទ តើដូចម្តេច ? នែនាងវិសាខា មាតុគ្រាមក្នុងលោកនេះ ពួកជនណាជាខាងក្នុង ជាបន្ទុក របស់ស្វាមី ទោះខ្ញុំក្តី អ្នកបម្រើក្តី កម្មករក្តី តែងដឹងនូវអំពើដែលជន ទាំងនោះធ្វើថា ដឹងនូវអំពើដែលជនទាំងនោះ មិនបានធ្វើថា មិនបានធ្វើ ដឹងនូវកម្លាំងតិច និងកម្លាំងច្រើន នៃពួកជនអ្នកធ្វើចេះចែកខាទនីយ ភោជនីយាហារ តាមចំណែកដែលគួរដល់ពួកជនខាងក្នុងបន្ទុកនោះ ។ ម្នាលនាងវិសាខា មាតុគ្រាមជាស្ត្រីសង្គ្រោះពួកជនជាបរិស័ទយ៉ាងនេះ ឯង ។ នែនាងវិសាខា ចុះមាតុគ្រាមចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត នៃស្វាមី តើដូចម្តេច ? នែនាងវិសាខា មាតុគ្រាមក្នុងលោកនេះ អំពើណា មិនជាទីគាប់របស់ស្វាមី បើទុកជាមានហេតុដល់ជីវិត ក៏មិនប្រព្រឹត្ត កន្លងនូវអំពើនោះ ។ នែនាងវិសាខា មាតុគ្រាមចេះប្រព្រឹត្តអំពើជាទី គាប់ចិត្តនៃស្វាមីយ៉ាងនេះឯង ។ នែនាងវិសាខា ចុះមាតុគ្រាមចេះថែទាំ សម្បត្តិដែលស្វាមីរកបានមក តើដូចម្តេច ? នែនាងវិសាខា ទ្រព្យណាក្តី

ស្រូវណាក្តី ប្រាក់ណាក្តី មាសណាក្តី ដែលស្វាមីរកបានមក មាតុគ្រាម ក្នុងលោកនេះ តែងសម្រេចដោយការរក្សាគ្រប់គ្រងនូវទ្រព្យជាដើមនោះ ទាំងជាស្រ្តី អ្នកមិនលេង មិនលួច មិនវិលខូច មិនធ្វើសម្បត្តិទាំងនោះ ឲ្យវិនាស ។ នែនាងវិសាខា មាតុគ្រាមចេះថែទាំសម្បត្តិ ដែលស្វាមី រកបានមកយ៉ាងនេះឯង ។ នែនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង ឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។

នែនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការឈ្មោះថា ប្រតិបត្តិដើម្បីឈ្នះនូវលោកខាងមុខ លោកខាងមុខក៏ឈ្មោះថា មាតុគ្រាម នោះបានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការនោះ តើដូចម្តេចខ្លះ ? នែនាងវិសាខា មាតុគ្រាមក្នុងលោកនេះ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ ដោយសីល ១ បរិបូណ៌ដោយចាគៈ ១ បរិបូណ៌ដោយបញ្ញា ១ ។ នែ នាងវិសាខា ចុះមាតុគ្រាមបរិបូណ៌ដោយសទ្ធា តើដូចម្តេច ? នែនាង វិសាខាក្នុងលោកនេះ ជាស្រីមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះ

តថាគតថា ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ទៅដោយវិជ្ជា និងចរណៈ ជាព្រះលោកនាយក ជាក់ច្បាស់នូវត្រៃលោក ទ្រង់ប្រសើរបំផុត ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព គឺលែងវិលត្រឡប់មកកើតទៀតហើយ ។ នែនាងវិសាខា មាតុគ្រាមបរិបូណ៌ដោយសទ្ធាយ៉ាងនេះឯង ។ នែនាងវិសាខា ចុះមាតុគ្រាមបរិបូណ៌ដោយសីល តើដូចម្តេច ? នែនាងវិសាខា មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីវៀរចាកបាណាតិបាត ។ល។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ នែនាងវិសាខា មាតុគ្រាមបរិបូណ៌ដោយសីលយ៉ាងនេះឯង ។ នែនាងវិសាខា ចុះមាតុគ្រាមបរិបូណ៌ដោយចាគៈ តើដូចម្តេច ? នែនាងវិសាខា មាតុគ្រាមក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរ

ក្នុងការចែករំលែកនូវទាន ។ នែនាងវិសាខា មាតុគ្រាមបរិបូណ៌ដោយ
ចាគៈយ៉ាងនេះឯង ។ នែនាងវិសាខា មាតុគ្រាមបរិបូណ៌ដោយបញ្ញា
តើដូចម្តេច ? នែនាងវិសាខា ចុះមាតុគ្រាមក្នុងលោកនេះ ជាស្ត្រីមាន
បញ្ញា ប្រកបដោយបញ្ញា ជាដំណើរទៅកាន់សេចក្តីចម្រើន និងសេចក្តី
វិនាស ជាបញ្ញាដ៏ប្រសើរមោះមុត ដល់នូវការអស់ទៅនូវទុក្ខដោយ
ប្រពៃ ។ នែនាងវិសាខា មាតុគ្រាមបរិបូណ៌ដោយបញ្ញាយ៉ាងនេះឯង ។
នែនាងវិសាខា មាតុគ្រាមបរិបូណ៌ដោយធម៌ ៤ ប្រការនេះ ឈ្មោះថា
ប្រតិបត្តិដើម្បីឈ្នះនូវលោកខាងមុខ លោកខាងមុខក៏ឈ្មោះថា
មាតុគ្រាមនោះ បានប្រារព្ធហើយ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួកជនជា
បរិស័ទ ១ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ១ ថែទាំសម្បត្តិដែល
ស្វាមីរកបានមក ១ បរិបូណ៌ដោយសទ្ធា ១ សីល ១ ដឹងនូវពាក្យពោល
១ ប្រាសចាកសេចក្តីកំណាញ់ ១ ជម្រះផ្លូវជាទីទៅកាន់បរលោកឲ្យស្អាត
ជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញពោលថា

នារីនោះមានសីល ស្ថិតនៅក្នុងធម៌ ពោលនូវពាក្យពិត ជាឧបាសិកា ដែលបរិបូណ៌ដោយអាការ ១៦ ( បានដល់ ដឹកនាំអ្នកដទៃឲ្យតាំងនៅក្នុងអដ្ឋធម៌ ៨ ប្រការនោះ ដូចនឹងខ្លួន គឺយើងមាន ៨ គេមាន ៨ រួមជា ១៦ ) ប្រកបដោយអដ្ឋទាំង ៨ ប្រការ មានសីលបែបនោះ រមែងទៅកើតក្នុងទេវលោក ឈ្មោះមនាបកាយិកា ។

គុណសម្បត្តិក្នុងផ្នែកខាងភាពអង់អាច របស់មហាឧបាសិកាវិសាខា ដែលមានភាពជំនាញនេះ មានរឿងសម្តែងទុកនៅក្នុង គម្ពីរអដ្ឋកថាធម្មបទ នៃ អត្តវគ្គ ក្នុង រឿងរបស់ព្រះមាតាកុមារកស្សប និងក្នុង អដ្ឋកថាជាតក ដែលអធិប្បាយសេចក្តីបាលី និគ្រោធជាតក គម្ពីរខុទ្ទកនិកាយ ជាតក ដូចមានសេចក្តីថា ៖

គ្រាមួយ បានកើតអធិករណ៍ឡើងនៅក្នុងពួកភិក្ខុនី គឺមានកូនស្រីរបស់សេដ្ឋីម្នាក់ ជាអ្នកជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា នាងធ្លាប់បានសូមការអនុញ្ញាតពីលោកឪពុកចេញបួស តែមិនបានទទួលការអនុញ្ញាតលុះក្រោយពីនាងរៀបការហើយ ទើបនាងសូមការអនុញ្ញាតពីស្វាមី

ចេញបួស ស្វាមីក៏យល់ព្រមដោយបាននាំនាងទៅបួសក្នុងសម្នាក់ភិក្ខុនី ដែលជាបក្សពួករបស់ព្រះទេវទត្ត ។ លុះនាងបានបួសជាភិក្ខុនីហើយ ប្រាកដថា គភ៌របស់នាងធំឡើងៗ ដរាបដល់ដឹងទូទៅដល់ភិក្ខុនីទាំង-ឡាយ ។ ទើបភិក្ខុនីទាំងឡាយនោះ សួរនាងថា នាងមានគភ៌ឬ ភិក្ខុនីតបថា នាងម្ចាស់ ខ្ញុំមិនជ្រាបថា មានគភ៌ឬទេ តែសីលរបស់ខ្ញុំមិនដាច់ធ្វើឲ្យសៅហ្មងអ្វីឡើយ ។ ភិក្ខុនីទាំងឡាយនោះ បាននាំនាងទៅជួបព្រះទេវទត្ត ដើម្បីឲ្យលោកសម្រេចអធិករណ៍នេះ ដោយប្រាប់ថា ពួកខ្លួនមិនដឹងនឹងធ្វើដូចម្ដេច ។ ចំណែកព្រះទេវទត្ត ខ្លាចវិនាសកេរ្តិ៍ឈ្មោះជាមួយនឹងពួកភិក្ខុនីដែលប្រព្រឹត្តតាមឱវាទរបស់ខ្លួន ទើបប្រាប់ឲ្យនាងសឹកចេញ ព្រោះសីលដាច់ហើយ ។ ភិក្ខុនីនោះ បានប្រាប់ទៅពួកភិក្ខុនីទាំងនោះវិញថា ខ្ញុំមិនបានបួសឧទ្ទិសចំពោះភិក្ខុទេវទត្តទេ សូមនាងម្ចាស់ទាំងឡាយ នាំខ្ញុំទៅគាល់ព្រះសម្មាសម្ពុទ្ធ ហើយភិក្ខុនីទាំងឡាយនោះទើបនាំនាងទៅគាល់ព្រះមានជោគ ដែលទ្រង់គង់នៅក្នុងវត្តជេតពន ។ ព្រះជិនស្រីទ្រង់ជ្រាបថា នាងមានការតាំងគភ៌តាំងពីនៅគ្រហស្ថម៉្លេះ

តែដើម្បីទ្រង់នឹងដោះស្រាយរឿងនេះ ឲ្យផុតពីពាក្យរិះគន់ និងនិន្ទា របស់ជនទាំងឡាយ ទើបត្រាស់ឲ្យយាងព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី និងឧបាសិកាវិសាខា ថែមទាំងត្រកូលធំៗដទៃៗ ទៀតមកដែរ ដោយព្រះពុទ្ធតម្រាស់ត្រាស់ប្រាប់ព្រះឧបាលី ដែលលោក ជាឯតទគ្គៈផ្នែកខាង ទ្រទ្រង់ព្រះវិន័យ ឲ្យធ្វើនាទីជម្រះអធិករណ៍របស់ ភិក្ខុនីនោះឲ្យផុតមន្ទិល នៅក្នុងកណ្ដាលបរិស័ទទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ ព្រះឧបាលីបានអញ្ជើញមហាឧបាសិកាវិសាខា មកអង្គុយត្រង់ព្រះភក្ត្ររបស់ព្រះបាទបសេនទិកោសល ដើម្បីធ្វើនាទី សាកសួររកហេតុនៃអធិករណ៍ ដែលកើតឡើងចំពោះនាងភិក្ខុនីនោះ ។ មហាឧបាសិកាវិសាខាជាអ្នកមានបញ្ញាឈ្លាសវៃ មុននឹងនាងធ្វើការសម្រេច ការសាកសួរ ទើបពិនិត្យមើលរាងកាយរបស់នាងភិក្ខុនី បានឲ្យគេ បាំងរាំងននព័ទ្ធជុំវិញហើយ ទើបឲ្យនាងភិក្ខុនី ចូលទៅខាងក្នុងរាំងនន តពីនោះ ទើបនាងបានផ្ដើមពិនិត្យមើលដៃ ជើង ផ្ចិត និងផ្ទៃពោះរបស់ នាងភិក្ខុនី ហើយរាប់ខែ និងថ្ងៃ គិតមើលទៅ បានជ្រាបថា នាងភិក្ខុនីនេះ

មានគភ៌រួចមកហើយ តាំងតែនៅពីគ្រហស្ថម្ល៉េះ គឺមុនចូលមកបួស ជាភិក្ខុនី ទើបនាងទូលដល់ព្រះឧបាលីឲ្យជ្រាប ។ ទើបព្រះឧបាលី សម្រេចអធិករណ៍ឲ្យភិក្ខុនីនោះ ជាអ្នកបរិសុទ្ធសីលនៅមិនទាន់ដាច់ នៅក្នុងកណ្តាលបរិស័ទទាំង ៤ ដែលមកប្រជុំគ្នានៅក្នុងទីកន្លែងនោះ។ ក្នុងសម័យក្រោយមក ភិក្ខុនីរូបនោះ ក៏បានប្រសូតកូនប្រុស ក្នុងវាំង ដែលនាងបួសជាភិក្ខុនីនោះ ចំពោះកូនប្រុសរបស់នាង តមកបានចេញបួស នៅក្នុងព្រះពុទ្ធសាសនានេះដែរ មាននាមថា ព្រះកុមារកស្សប លោក ជាព្រះអរហន្ត ដែលជាឯតទគ្គៈផ្នែកខាងសម្តែងធម៌ដ៏វិចិត្រទៀតផង ។ ចំណែកភិក្ខុនី ដែលជាមាតារបស់ព្រះកុមារកស្សប ក៏បានសម្រេច ជាព្រះអរហន្តីដូចគ្នាដែរ ។ ផលល្អដែលកើតឡើងដល់ភិក្ខុនីនោះ ដោយ មិនត្រូវពោលថា សីលដាច់ និងមិនត្រូវឲ្យលាចាកសិក្ខាបទ ថែមទាំង បានសម្រេចមគ្គផល ថ្នាក់ខ្ពង់ខ្ពស់បំផុតនៅក្នុងព្រះពុទ្ធសាសនានេះ ទៀតផង ទាំងនេះព្រោះអាស្រ័យមហាឧបាសិកាដែលជាអ្នកឈ្លាសវៃ ផងដែរ ។

ការសង្គ្រោះរបស់មហាឧបាសិកាវិសាខា ធ្លាប់បានធ្វើរួចមកហើយ ដល់ស្ត្រីដែលជាសម្លាញ់របស់ខ្លួន តាមដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ជរាវគ្គ** ក្នុងរឿងស្ត្រីដែលជាសម្លាញ់**របស់មហាឧបាសិកាវិសាខា** និងក្នុង **អដ្ឋកថាជាតក** ថា ៖

កាលព្រះមុនី ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថីនោះ ។ ព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនា ដោយទ្រង់ប្រារព្ធពួកស្ត្រីដែលជាសម្លាញ់របស់នាងវិសាខាឲ្យជាដើមហេតុ ដូចមានរឿងតំណាលទុកថា នៅក្នុងក្រុងសាវត្ថី មានកុលបុត្រ ៥០០ នាក់ បានមកសូមសំណូមពរឲ្យនាងវិសាខា ជួយគ្រប់គ្រងមើលថែរក្សាកិរិយារបស់ខ្លួន ដោយបំណងថា ឧបាយវិធីនេះ កិរិយាទាំងនេះ នឹងជាអ្នកមិនប្រមាទ ។ ពួកស្ត្រីដែលជាកិរិយារបស់កុលបុត្រទាំងនោះ កាលបើពួកគេទៅកន្លែងសួន ឬកន្លែងវត្តក្តី តែងតែបានទៅជាមួយនឹងមហាឧបាសិកាវិសាខា ។ គ្រាមួយ កាលមានគេឃោសនាអំពីរឿងមានមហោស្រពទាក់ទងនឹងសុរា រហូតអស់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ទើបនាំគ្នាឈប់ផឹក ហើយ

ចេញទៅដើម្បីធ្វើការងារជាធម្មតាឡើងវិញ ។ ចំណែកពួកស្ត្រីដែលជាភរិយាទាំងនោះ បានប្រឹក្សាគ្នាថា ពួកយើងមិនបានផឹកសុរាចំពោះមុខស្វាមីយូរណាស់មកហើយ សុរាដ៏សេស អំពីពួកស្វាមីផឹកហើយក៏នៅមានដែរ ពួកយើងនឹងផឹកសុរាដែលនៅសល់នេះ ដោយមិនឲ្យពួកស្វាមីរបស់យើងទាំងឡាយ បានដឹងក្នុងរឿងនេះ កាលបើពួកនាងទាំងនោះប្រឹក្សា ឬសម្រេចគ្នា ដូចនេះហើយ ទើបនាំគ្នាចូលទៅរកមហាឧបាសិកាវិសាខា ថែមទាំងបានពោលថា នាងម្ចាស់ ពួកខ្ញុំត្រូវការនឹងទៅដើរលេងតាមសួន ។ មហាឧបាសិកាវិសាខាពោលថា ល្អហើយនាងទាំងឡាយ បើដូច្នោះ ពួកនាងចូរធ្វើកិច្ចដែលគួរធ្វើស្រេចរៀបរយហើយទៅចុះ ។ ស្ត្រីទាំងនោះ បានទៅជាមួយនឹងឧបាសិកាវិសាខា តែពួកនាងៗ ទាំងនោះ បាននាំគ្នាលាក់ជបសុរាយ៉ាងល្អ នាំយកទៅកាន់សួនដើម្បីផឹកដើរលេងសប្បាយតាមសួននោះ រហូតដល់ស្រវឹង ។ ឧបាសិកាវិសាខា កាលឃើញអាការស្រវឹងរបស់ស្ត្រី ដែលជាសម្លាញ់ទាំងនេះហើយ ក៏បានគិតថា ពួកស្ត្រីទាំងនេះ ធ្វើកិច្ចដែលមិនសមគួរ ពួក

អនុត្ថិរិយ កាលបើដឹងរឿងនេះហើយនឹងពោលតិះដៀលថា ពួកសាវិកា របស់ព្រះសមណគោតម នាំគ្នាផឹកសុរាហើយដើរលេងសប្បាយតាមសួន ទើបនាងប្រាប់ដល់ពួកស្ត្រីទាំងនោះថា ពួកនាងធ្វើកិច្ចដែលមិនល្អ ធ្វើឲ្យយើងកើតការវិនាសផងដែរ ។ សូម្បីស្វាមីទាំងឡាយ របស់ពួក នាងក៏នឹងខឹង តើពួកនាងគប្បីធ្វើដូចម្តេចទៅក្នុងរឿងនេះ ។ ពួកស្ត្រី ទាំងនោះប្រាប់ឧបាយថា នាងម្ចាស់ ពួកខ្ញុំនឹងសម្តែងអាការបំភ្លាត់ថា ឈឺ ។ នាងវិសាខា កាលបើបានស្តាប់ពាក្យរបស់ស្ត្រីទាំងនោះហើយ ទើបពោលថា បើពួកនាងធ្វើយ៉ាងនេះ ពួកនាងក៏នឹងបានឃើញផល ពីការធ្វើរបស់ពួកនាងដោយខ្លួនឯង ។ ឯពួកស្ត្រីទាំងនោះ កាលត្រឡប់ ទៅដល់ផ្ទះវិញ ក៏បានក្លែងសម្តែងអាការដូចជាមនុស្សឈឺ ។ ពួកស្វាមី ត្រឡប់មកពីធ្វើការមកដល់ផ្ទះវិញ ទើបសួររកភរិយារបស់ខ្លួនៗ ថា ស្រីឈ្មោះនេះទៅណា បានឮថា ពួកនាងឈឺក៏មិនជឿ បានកំណត់រក ហេតុ ថែមទាំងចាប់ចំណុចបានថា ពួកនាងគង់នឹងនាំគ្នាផឹកសុរា ដែល នៅសល់នោះមិនខាន ទើបពួកគេវាយស្ត្រីដែលជាភរិយាទាំងនោះទៅ ។

ក្រោយមក មានមហោស្រពទៀត ពួកស្ត្រីដែលជាភរិយារបស់កុលបុត្រទាំងនោះ ចង់ផឹកសុរាដូចគ្នានឹងគ្រាមុនទៀត ទើបនាំគ្នាចូលទៅរកនាងវិសាខា ហើយប្រាប់ថា សូមនាងម្ចាស់ករុណានាំពួកខ្ញុំទៅដើរលេងតាមសួន ។ ឧបាសិកាវិសាខាពោលបដិសេធថា ក្នុងគ្រាមុនពួកនាងធ្វើឲ្យខ្ញុំ បានទទួលការអាប់យសម្តងរួចមកហើយ ពួកនាងចូរនាំគ្នាទៅខ្លួនឯងចុះ ខ្ញុំមិនបាននាំពួកនាងទៅទៀតទេ ។ ពួកស្ត្រីទាំងនោះនិយាយយកចិត្តថា នាងម្ចាស់ គ្រានេះ ពួកខ្ញុំមិនធ្វើយ៉ាងនោះទៀតទេបាស នាងវិសាខាក៏មិនព្រម ។ គ្រាក្រោយមកទៀត ពួកនាងបានចូលទៅរកឧបាសិកាម្តងទៀត ដោយនិយាយថា នាងម្ចាស់ ពួកខ្ញុំមានបំណងនឹងធ្វើពុទ្ធបូជា សូមនាងម្ចាស់នាំពួកខ្ញុំទៅកាន់វត្តចុះណានាងម្ចាស់ ។ ទើបឧបាសិកាវិសាខាពោលថា ល្អហើយ ពួកនាងចូរទៅចាត់ចែងរៀបចំខ្លួនឲ្យបានល្អចុះ ។ ពួកស្ត្រីទាំងនោះ បានប្រើឲ្យមនុស្សកាន់គ្រឿងក្រអូប និងផ្កាឈើជាដើម ចំណែកពួកខ្លួនយកដបដាក់សុរាចងភ្ជាប់នឹងដៃ គ្របដោយផ្ទាំងសំពត់ធំ ចូលទៅរកឧបាសិកាវិសាខា

ហើយនាំគ្នាដើរតាមឧបាសិកាទៅកាន់វត្ត តែមុននឹងពួកនាងទាំងនោះ ចូលទៅកាន់វត្ត បាននាំគ្នាអង្គុយផឹកសុរាដែលដាក់នៅក្នុងដប ដែលមានចំណុះប្រមាណមួយចំអាម ផឹករួចហើយ ក៏បោះចោលដបទៅ ហើយនាំគ្នាចូលទៅអង្គុយត្រង់ព្រះភក្ត្ររបស់ព្រះមានព្រះភាគ ក្នុងសាលាធម្មសភា គឺកន្លែងប្រជុំស្តាប់ព្រះធម៌ ។ ឧបាសិកាវិសាខា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងធម៌ប្រោសដល់ស្ត្រីទាំងនេះផង ។ ចំណែកពួកស្ត្រីទាំងនោះ មានអាការញ័រទាំងដៃទាំងជើង ដោយអំណាចសុរា ឬស្រវឹងសុរា ថែមទាំងបាននាំគ្នាគិតថា នឹងច្រៀងរាំ ។ គ្រានោះ មានទេវតាមួយអង្គ ដែលជាពួករបស់មារគិតថា ឥឡូវនេះ យើងនឹងចូលទៅសណ្ឋិតនៅក្នុងរាងកាយរបស់ស្ត្រីទាំងនោះ នឹងសម្តែងអាការខុសប្រក្រតីនៅចំពោះព្រះភក្ត្រ របស់ព្រះសមណ-គោតម ហើយទេវតានោះ ទើបចូលទៅសណ្ឋិត នៅក្នុងរាងកាយរបស់ស្ត្រីទាំងនោះ ។ បណ្តាស្ត្រីទាំងនោះ ស្ត្រីពួកខ្លះ ក៏បានផ្តើមទះដៃឡើងសើច ស្ត្រីពួកខ្លះក៏បានផ្តើមនឹងរាំនៅត្រង់ព្រះភក្ត្ររបស់ព្រះសាស្តា ។

ពេលនោះ ព្រះមានជោគទ្រង់ពិចារណាថា នេះជាអ្វី ហើយទើបទ្រង់ជ្រាបហេតុការណ៍នោះ ទើបទ្រង់ត្រិះរិះថា ឥឡូវនេះ តថាគតនឹងមិនឲ្យទេវតា ដែលជាបក្ខពួករបស់មារបានឱកាស ចំណែកតថាគតដែលបានបំពេញបារមីមក អស់កាលដ៏យូរត្រឹមប៉ុណ្ណេះ ក៏មិនបានបំពេញបារមីមក ដើម្បីឲ្យពួកមារទាំងនោះបានឱកាសទេ កាលព្រះអង្គទ្រង់មានបំណងធ្វើឲ្យពួកស្ត្រីទាំងនោះតក់ស្លុត ទើបទ្រង់បញ្ចេញព្រះរស្មីពីព្រះលោមា ក្នុងចន្លោះចិញ្ចើមចេញទៅ ដើម្បីឲ្យភាពងងឹតបានកើតឡើងទូទៅក្នុងពេលមួយរំពេចនោះឯង ។ ពួកស្ត្រីទាំងនោះកាលបានជួបប្រទះហេតុដូច្នេះហើយ ក៏កើតការខ្លាចតក់ស្លុត ចំពោះសេចក្តីស្លាប់ ហើយបានធ្វើឲ្យពួកនាងទាំងនោះ ស្វាងស្រាឡើង ។ ព្រះមហាវីរៈទ្រង់បាត់ពីបល្ល័ង្កទិគន់ប្រថាប់ហើយ ទៅប្រថាប់ឈរនៅលើកំពូលភ្នំសិនេរុ ទាំងទ្រង់បានបញ្ចេញព្រះរស្មីអំពីព្រះឧណ្ណាលោម ។ ក្នុងខណៈនោះ ពន្លឺបានប្រាកដឡើងដូចគ្នានឹងព្រះចន្ទរះ ព្រមគ្នាមួយពាន់ដួង ។ បន្ទាប់អំពីនោះ ទើបព្រះមហាមុនីត្រាស់នឹងពួកស្ត្រីទាំង

នោះថា កាលដែលពួកនាងមកកាន់សម្នាក់របស់តថាគត ជាអ្នកមក ដោយការស្រវឹងយ៉ាងនេះមិនគួរទេ ព្រោះទេវតាដែលជាបក្ខពួកនៃមារ បានឱកាសនៃការស្រវឹងរបស់ពួកនាង នឹងធ្វើឲ្យពួកនាងបញ្ចេញអាការមិនល្អ មានការងើបទះដៃជាដើម ក្នុងទីកន្លែងដែលមិនគួរសើច ឬរាំច្រៀង ឥឡូវនេះ ពួកនាងគួរធ្វើសេចក្តីឧស្សាហ៍ ដើម្បីបំណាងរំលត់ភ្លើង មានរាគៈជាដើម ហើយព្រះអង្គទ្រង់ត្រាស់នូវព្រះគាថាថា

កាលបើលោកសន្និវាស ត្រូវភ្លើងមានរាគៈជាដើម ឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយ ត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ (ម្តេចឡើយ) ក៏មិនស្វែងរកប្រទីប គឺប្រាជ្ញា ។

កាលព្រះមានបុណ្យ មានព្រះតម្រាស់យ៉ាងនេះចប់ ស្ត្រីទាំង ៥០០ នាក់នោះ ក៏បានតាំងនៅក្នុងព្រះសោតាបត្តិផល ។ ព្រះវិជិតមារទ្រង់បានជ្រាបថា ស្ត្រីទាំងនេះ ជាអ្នកតាំងនៅក្នុងអចលសទ្ធា គឺការជឿមិនកម្រើកហើយ ទើបស្តេចចុះចាកកំពូលភ្នំសិនេរុ មកគង់ប្រថាប់លើពុទ្ធាសនៈវិញ ។ គ្រានោះ ទើបឧបាសិកាវិសាខា ក្រាបទូលព្រះមុនីថា

បពិត្រព្រះអង្គដ៏ចម្រើន សុរានេះអាក្រក់ថោកទាបណាស់ ព្រោះថា ពួកស្ត្រីទាំងនោះមានគុណសម្បត្តិដូចនេះ ពេលដែលអង្គុយនៅព្រះភក្ត្រ របស់ព្រះអង្គ ក៏មិនអាចធ្វើឲ្យឥរិយាបថនៅបានរៀបរយ ដោយផ្ដើម នឹងក្រោកឡើងទះដៃ និងច្រៀងរាំជាដើម ។ លំដាប់នោះ ព្រះសម្ពុទ្ធ ត្រាស់ថា វិសាខា សុរានេះ អាក្រក់ថោកទាបពិតមែន ព្រោះប្រជាជន ច្រើនរយនាក់ ដល់នូវសេចក្ដីវិនាស ដោយហេតុមកពីសុរា ។ ឧបាសិកា វិសាខាបានក្រាបទូលសួរថា សុរានេះ កើតឡើងតាំងពីពេលណាមក ព្រះអង្គ ? ទើបព្រះសាស្ដា ទ្រង់នាំអតីតនិទានមក ដែលមានឈ្មោះថា **កុម្ភជាតក** មកត្រាស់សម្ដែងដោយពិស្ដារ ។

ហេតុកើតឡើងនៃសុរានេះ មានរឿងសម្ដែងទុកក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៅក្នុង **កុម្ភជាតក គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្ដីថា ៖

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជសម្បត្តិនៅក្នុង ក្រុងពារាណសី ។ កាលនោះ មាននាយព្រានព្រៃដែនកាសីម្នាក់ឈ្មោះ

សុរ: បានទៅរកម្រឹគ និងរបស់ប្រើប្រាស់នៅក្នុងព្រៃហិមពាន្ត ហើយគេបានទៅជួបប្រទះដើមឈើមួយដើមធំ ដែលមានមែកបែកចេញជាប្រគាប ៣ ប្រគាប ដោយចំណែកដែលបែកចេញជាប្រគាបនោះ មានប្រមាណកម្ពស់មួយជួរបុរស ។ ក្នុងចន្លោះប្រគាបនោះ មានប្រហោងធំទំហំប៉ុនពាងទឹក ក្នុងប្រហោងនោះ មានទឹកភ្លៀងដែលធ្លាក់ចុះមកដក់ពេញ ។ ក្នុងបរិវេណជុំវិញប្រគាបនៃដើមឈើនោះ មានដើមសម៉ដើមកន្ទួតព្រៃដើមម្ទេស មានវល្លិ៍ព័ទ្ធជុំវិញនៅត្រង់ប្រគាបនោះ ។ ផ្លែសម៉ ផ្លែកន្ទួតព្រៃផ្លែម្ទេស ពេលដែលទុំហើយ ក៏ជ្រុះចាកទងធ្លាក់ចុះទៅក្នុងប្រហោងនោះ ។ ក្នុងទឹកខ្សែងក្បែរដើមឈើធំនោះ មានស្រែស្រូវសាលីជាច្រើន មានសេកបានពាំយកកួរស្រូវសាលី ហើរទៅទំចឹកស៊ីស្រូវសាលី ក៏មានកួរស្រូវសាលី ធ្លាក់ទៅក្នុងប្រហោងឈើនោះ ។ ទឹកភ្លៀងដែលដក់នៅក្នុងប្រហោងឈើនោះ កាលបើត្រូវពន្លឺថ្ងៃធ្វើឲ្យក្តៅ ក៏បានក្លាយជាទឹកមានពណ៌ក្រហម ( ព្រោះលាយផ្សំផ្លែឈើ និងស្រូវសាលី ) ។ លុះដល់រដូវប្រាំងមានសត្វស្លាបទាំងឡាយស្រេកទឹក បាននាំគ្នាទៅ

ផឹកទឹកនៅក្នុងប្រហោងឈើនោះ ក្រោយពីសត្វស្វាបទាំងនោះ បានផឹកទឹកក្នុងប្រហោងនោះហើយ សត្វស្វាបនីមួយៗ ក៏ស្រវឹង រមៀលភ្លាត់ធ្លាក់ចុះមកនៅត្រង់គល់នៃដើមឈើនោះ ហើយដេកលក់នៅមួយស្របក់ លុះស្វាងការស្រវឹង សត្វស្វាបនីមួយៗ ក៏បានបញ្ចេញសម្រែករីករាយ ហើយក៏ហើរចេញទៅ ។ មិនមែនតែសត្វស្វាបតែប៉ុណ្ណោះទេ សូម្បីសុនខព្រៃ និងស្វាជាដើម ដែលបានមកកាន់ដើមឈើធំនោះ កាលបានផឹកទឹក ដែលស្រក់ចុះមកពីប្រហោងដើមឈើនោះ ក៏កើតអាការស្រវឹងដូចគ្នា ។ នាយព្រានសុរៈ បានឃើញហេតុការណ៍ដូច្នេះ ទើបឡើងទៅលើដើមនោះ ទៅពិនិត្យមើលថា មានវត្ថុអ្វីនៅលើដើមឈើនោះ គេក៏បានឃើញទឹកដក់នៅក្នុងប្រហោងប្រគាបឈើនោះ ក៏គិតថា ប្រសិនបើទឹកមានពិស សត្វស្វាបទាំងអស់ក៏ត្រូវស្លាប់ តែសត្វស្វាបទាំងនោះត្រឹមតែបាត់ស្មារតី ឬស្រវឹងនៅមួយរំពេចប៉ុណ្ណោះ ហើយវាក៏ហើរចេញទៅតាមសប្បាយ ទឹកនេះគង់មិនមានជាតិពិស ទើបគេសាកល្បងផឹកមើល ដើម្បីឲ្យប្រាកដក្នុងចិត្តថា ទឹកនេះមានឫទ្ធិអំណាច

ត្រឹមណា កាលគេផឹកទឹកនោះចូលទៅ ក៏កើតអាការស្រវឹងឡើងមួយរំពេច ទាំងចង់ស៊ីសាច់សត្វផ្សេងៗ ទើបគេចុះអំពីលើដើមឈើមកបង្កាត់ភ្លើងឡើង ដោយគេទៅចាប់សត្វ ដែលធ្លាក់មកដេកនៅត្រង់គល់នៃដើមឈើនោះ មានសត្វទទា មាន់ព្រៃជាដើមសម្លាប់ រួចអាំងក្រៀមទៅ ។

ចំណែកចិត្តរបស់នាយព្រានសុរៈ មានអានុភាពរីកប៉ោងឡើង គេបានស្រែកច្រៀងរាំម្នាក់ឯង ដោយដៃម្ខាងលើកឡើងចាក់ក្បាច់ ដៃម្ខាងទៀតកាន់សាច់អាំងខាំស៊ីក្រៀមជាមួយនឹងទឹកនោះ នៅក្នុងទីកន្លែងនោះ ២-៣ ថ្ងៃ ។ ក្នុងទីមិនឆ្ងាយពីបរិវេណនៃដើមឈើនោះ មានតាបសម្នាក់ឈ្មោះ វរុណ ស្នាក់អាស្រ័យនៅ ។ លុះដល់ថ្ងៃទី ៣ នាយព្រានសុរៈបានទៅកាន់សម្នាក់របស់តាបស លុះទៅដល់ហើយ គេជញ្ជឹងគិតថា យើងនឹងផឹកទឹកនេះ រួមជាមួយនឹងតាបស ទើបគេកាត់ឬស្សីធ្វើជាបំពង់ ហើយដងទឹកក្នុងប្រហោងដើមឈើនោះ ដាក់រហូតដល់ពេញ ថែមទាំងបានសាច់អាំងមួយចង្កោម និងយួរទឹកនោះទៅកាន់

បណ្ណសាលាទៅដល់ហើយ បានបបួលតាបសថា សូមលោកម្ចាស់ផឹកទឹកនេះចុះ ហើយអ្នកទាំងពីរនោះ បានផឹកទឹកនោះជាមួយគ្នា ថែមទាំងបានបរិភោគសាច់អាំងនោះ យ៉ាងសប្បាយរីករាយទៀតផង ។ ចាប់តាំងពីកាលនោះមក ទើបទឹកនោះមានឈ្មោះថា **សុរា** និង **វារុណី** ។ ទាំងនេះព្រោះហេតុនៃនាយព្រានសុរៈ បានជួបជាមនុស្សដំបូង និងតាបសវរុណ បានជាមនុស្សទី ២ ។ នាយព្រានសុរៈ និងតាបសវរុណ មានការរួមផ្សំគំនិតគ្នា គិតថា យើងមានវិការដែលនឹងធ្វើការរកស៊ីហើយ ទើបដងទឹកក្នុងប្រហោងឈើនោះ ដាក់ក្នុងបំពង់ឫស្សីពេញហើយ នាំយកទៅថ្វាយព្រះរាជាមួយព្រះអង្គ ដែលសោយរាជសម្បត្តិនៅក្នុងបច្ចន្តប្រទេស ។ ព្រះរាជាអង្គនោះបានសោយទឹកនោះ ២-៣ ដង ទ្រង់ក៏មានអាការស្រវឹង ថែមទាំងទ្រង់ដឹងថា មានភាពសប្បាយរីករាយ ក្នុងព្រះហឫទ័យយ៉ាងពន់ពេក ។ ប៉ុន្តែទឹកស្រវឹងនោះមានមិនច្រើន ល្មមត្រឹមតែព្រះរាជាសោយ បាន ២-៣ ថ្ងៃប៉ុណ្ណោះ ទឹកស្រវឹងនោះក៏អស់ទៅ ។ ទើបព្រះរាជាទ្រង់ត្រាស់សួរថា ទឹកបែបនេះ

មានទៀតឬទេ ? នាយព្រាន និងតាបសបានក្រាបទូលថា សូមព្រះតេជះតម្កល់លើត្បូងសូមទ្រង់ជ្រាប ទឹកនេះនៅមានព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា មាននៅទីកន្លែងណា ? អ្នកទាំងពីរនាក់នោះតបថា មាននៅក្នុងព្រៃហិមពាន្ត ។ ព្រះរាជាទ្រង់ត្រាស់ថា ប្រសិនបើដូច្នោះ លោកទាំងពីរនាក់ចូរប្រញាប់ទៅនាំយកទឹកនោះមក ។ អ្នកទាំងពីរនាក់នោះ បានក្រាបទូលទទួលព្រះរាជបញ្ជាហើយ ទើបប្រញាប់នាំគ្នាទៅនាំយកទឹកស្រវឹងនោះមកថ្វាយព្រះរាជា ។ កាលបើអ្នកទាំងពីរនាក់នោះ បានធ្វើដំណើរទៅនាំយកទឹកស្រវឹង ពីព្រៃហិមពាន្តមកពីរដងហើយ កាលទឹកស្រវឹងនោះអស់ គេក៏ត្រូវធ្វើដំណើរទៅយកមកទៀត ។

ចំណែកក្នុងគ្រាទី ៣ អ្នកទាំងពីរនាក់ប្រឹក្សាគ្នាថា យើងទាំងពីរនាក់មិនអាចទៅនាំយកទឹកនោះ មកថ្វាយជានិច្ចបានទេ ផ្លូវដែលល្អយើងគួរកំណត់ចងចាំវត្ថុ របស់ផ្សេងៗ ដែលមាននៅក្នុង ប្រហោងឈើនោះ និងយកសម្បកឈើរបស់ដើមឈើនោះ មកដាក់ត្រាំរួមគ្នាជាមួយនឹងគ្រឿងផ្សំផ្សេងៗ ទាំងនោះហើយ ទឹកនោះនឹងមានរសដូចគ្នា

ថែមទាំងធ្វើឲ្យអ្នកទាំងពីរនាក់នោះមានគំនិតឡើងថា នឹងធ្វើសុរាលក់ក្នុងក្រុងនោះ ។ កាលអ្នកក្រុងទាំងអស់ បានផឹកសុរានោះហើយ ក៏នាំគ្នាស្រវឹង ជាពិសេសនោះ បាននាំគ្នានិយមផឹកច្រើនឡើងៗ ធ្វើឲ្យមានការស្រវឹង ដូច្នេះ មិនបានទៅធ្វើការងាររកស៊ី សូម្បីបានប្រាក់មកក៏យកប្រាក់នោះទៅទិញសុរាមកផឹក ធ្វើឲ្យក្រលំបាកទៅជាលំដាប់ ។ អ្នកទាំងពីរដែលជាអ្នកផ្សំសុរាលក់ ទើបនាំគ្នារត់ចេញពីក្រុងនោះ ទៅកាន់ក្រុងពារាណសី ឲ្យសេវកាមាត្យចូលក្រាបបង្គំទូលព្រះបាទពារាណសីថា សូមតេជះតម្កល់លើត្បូង សូមទ្រង់ជ្រាបឥឡូវនេះ មានអ្នកនាំទឹកបែបពិសេសចូលមកក្នុងព្រះនគររបស់ព្រះអង្គហើយ ។ ព្រះបាទពារាណសីបានត្រាស់ឲ្យអ្នកទាំងពីរនោះចូលគាល់ ហើយបានត្រាស់ព្រះរាជទានស្បៀងចិញ្ចឹមជីវិត ឲ្យដល់អ្នកទាំងពីរនោះ ហើយបានត្រាស់ឲ្យអ្នកទាំងពីរនាក់នោះនាំទឹកនោះមកថ្វាយ កាលបើព្រះរាជាទ្រង់សោយហើយទ្រង់ក៏សព្វព្រះរាជហឫទ័យ ទើបទ្រង់អនុញ្ញាតឲ្យអ្នកទាំងពីរនោះធ្វើសុរាឡើង ដើម្បីលក់នៅក្នុងក្រុងពារាណសីនេះ ។ អ្នកក្រុងពារាណសី

ម្នាក់ៗ នាំគ្នាផឹកសុរា និងដោយច្រើនជាអ្នកជាប់ជំពាក់ចំពោះរសសុរា ដរាបដល់ភ្លេចសេចក្ដីទុក្ខលំបាក គឺដោយមិនចង់ទៅធ្វើការងារ ទីបំផុតក៏ធ្លាក់ខ្លួនក្រលំបាក ។ បុគ្គលទាំងពីរនោះ កាលឃើញដូច្នោះហើយ ទើបនាំគ្នាចេញពីក្រុងពារាណសី សំដៅទៅកាន់ក្រុងសាកេត ហើយបានធ្វើសុរាលក់នៅក្នុងក្រុងសាកេតនោះទៀត រហូតជាហេតុឲ្យអ្នកក្រុងសាកេតត្រូវដល់នូវវិបត្តិខ្វះខាត និងធ្លាក់ខ្លួនក្រ ព្រោះតែវង្វេងជាប់ក្នុងរសសុរានោះឯង ។ កាលអ្នកក្រុងសាកេតជួបប្រទះនូវហេតុដូច្នោះហើយ បុគ្គលទាំងពីរនោះ ក៏បាននាំគ្នាចេញពីក្រុងសាកេត ទៅកាន់ក្រុងសាវត្ថី ។ ក្នុងគ្រានោះ នៅក្រុងសាវត្ថី មានក្សត្រទ្រង់ព្រះនាមថា **សព្វមិត្ត** ព្រះអង្គទ្រង់អនុគ្រោះគេទាំងពីរនាក់ ថែមទាំងបានត្រាស់សួរថា អ្នកត្រូវការវត្ថុណាខ្លះ ឬវត្ថុអ្វីខ្លះ ? បុគ្គលទាំងពីរនាក់នោះក្រាបបង្គំទូលថា ខ្ញុំព្រះអង្គត្រូវការឫសឈើសម្រាប់ផ្សំធ្វើសុរា ម្សៅអង្ករសាលី និងពាងទឹក ៥០០ ។ ព្រះបាទសព្វមិត្ត បានត្រាស់រាជបញ្ជាឲ្យពួករាជសេវកាមាត្យ ឲ្យចាត់ចែងរកវត្ថុគ្រប់យ៉ាង ដល់បុគ្គលទាំងពីរ

នាក់នោះ ។ កាលបើនាយព្រានសុរៈ និងតាបសវរុណ បានរបស់ដែលខ្លួនត្រូវការសព្វគ្រប់ហើយ ទើបដាក់គ្រឿងផ្សំស្រាចុះក្នុងពាងទាំង ៥០០ ត្រាំក្នុងពាងនោះ ឲ្យប្រែសភាពជាទឹកស្រវឹងតាមសេចក្ដីត្រូវការ ។ ប៉ុន្ដែក្នុងទឹកន្ទែងធ្វើស្រានោះ មានសត្វកណ្ដុរច្រើន បុគ្គលទាំងពីរនោះ គិតនឹងការពារសត្វកណ្ដុរទាំងឡាយ ដែលមករំខានទឹកក្នុងពាងទាំងនោះ ទើបបានយកឆ្មាមកចងទុកនៅក្នុងចន្លោះពាងនីមួយៗ ។ កាលទឹកដែលត្រាំគ្រឿងផ្សំស្រា ក្នុងពាងប្រែសភាពជាពពុះឡើងមកក៏ហៀរហូរចេញពីមាត់ពាងទាំងនោះ ។ ចំណែកឆ្មាដែលចងលាមទុកខាងពាងនោះស្រេកទឹក ទើបផឹកទឹកដែលហូរស្រក់ចេញមកពីមាត់ពាងឆ្មាទាំងនោះក៏ស្រវឹងដេកលក់មិនដឹងខ្លួន ។ ពួកសត្វកណ្ដុរឃើញឆ្មាដេកលក់ហើយ ទើបនាំគ្នាមកកកេរខាំត្រចៀក ច្រមុះ និងកន្ទុយរបស់ឆ្មាទាំងនោះលេង ។ ពេលនោះ ពួកអមាត្យបានមកឃើញហេតុការណ៍ដូចនេះ ទើបនាំគ្នាទៅក្រាបបង្គំទូលព្រះបាទសព្វមិត្តថា សូមតេជះតម្កល់លើត្បូង សូមទ្រង់ជ្រាប ឆ្មាទាំងឡាយបាននាំគ្នាផឹកទឹកស្រា

ស្លាប់អស់ហើយ ព្រះករុណាថ្លៃវិសេស ។

គ្រានោះ ព្រះបាទសព្វមិត្តទ្រង់យល់ក្នុងព្រះទ័យថា បុគ្គលទាំងពីរនាក់នោះបានធ្វើថ្នាំពិស ទើបមានព្រះរាជឱង្ការឲ្យប្រហារជីវិតដល់បុគ្គលទាំងពីរនាក់នោះ ។ នាយព្រានសុរៈ និងតាបសវរុណា មុននឹងគេស្លាប់បាននាំគ្នាផឹកសុរា ហើយក្រាបបង្គំទូលថា សុរានេះ មានរសឆ្ងាញ់ណាស់ គេទាំងពីរនាក់បានក្រាបបង្គំទូលដូចនេះ រហូតដល់ដាច់ខ្យល់ស្លាប់ទៅ ។ កាលបើព្រះបាទសព្វមិត្តមានព្រះរាជឱង្ការឲ្យប្រហារជីវិតបុគ្គលទាំងពីរនាក់នោះហើយ ទើបត្រាស់បញ្ជាឲ្យវាយបំបែកពាងទាំងអស់នោះចោលទៀតផង ក្នុងខណៈដែលពួកអមាត្យកំពុងតែវាយបំបែកពាងចោល ពួកឆ្មាដែលស្រវឹងសុរាហើយនោះ ក៏បានស្វាងសុរារួចក្រាក់ក្រោកឡើងរត់លេង ពួករាជបុរសឃើញឆ្មាទាំងនោះដូច្នេះហើយ ទើបនាំគ្នាក្រាបបង្គំទូលព្រះបាទសព្វមិត្ត ឲ្យទ្រង់ជ្រាបចំពោះសេចក្ដីនោះ ។ ព្រះបាទសព្វមិត្ត ទ្រង់ត្រិះរិះថា ប្រសិនបើទឹកស្រវឹងនោះជាថ្នាំពិសពិតមែន ឆ្មាទាំងអស់នោះប្រាកដជានឹងស្លាប់ តែឆ្មាទាំងនោះ

មិនស្លាប់ សូម្បីតែមួយក្បាលក៏មិនមាន ហាក់បីដូចជាទឹកនោះ មានរសធ្លាញ់ពិតមែន ត្រូវនឹងពាក្យដែលបុគ្គលទាំងពីរនាក់នោះ ពោលមុនស្លាប់ហើយមើលទៅ យើងនឹងសាកល្បងផឹកទឹកនោះមើល ទ្រង់ត្រិះរិះដូចនេះហើយ ទើបឲ្យតាក់តែងព្រះនគរ និងសាងពន្លា ( រោង ឬសាលាដែលគេសង់សម្រាប់ថ្វាយព្រះរាជា ទ្រង់ប្រថាប់បណ្ដោះអាសន្នមួយវេលាៗ ) នៅទីព្រះលានហ្លួង ។ កាលតាក់តែង និងសាងសង់រួចហើយព្រះរាជាទ្រង់ទៅប្រថាប់ត្រង់រាជបល្ល័ង្ក ព្រមដោយពួកសេវកាមាត្យជាបរិវារចោមរោមមុខក្រោយ ព្រះរាជាទ្រង់ប្រារព្ធនឹងសោយសុរា ។ ក្នុងកាលនោះ សក្កទេវរាជទ្រង់ពិចារណាមើលពួកសត្វលោកថាសត្វពួកណាមិនប្រមាទ យកចិត្តទុកដាក់ក្នុងការប្រព្រឹត្តទំនុកបម្រុងមាតាបិតា ជាអ្នកមានបំណងបំពេញសុចរិតធម៌ទាំង ៣ ប្រការ គឺកាយវាចា ចិត្តឲ្យបរិបូណ៌ ក៏ទ្រង់ទតឃើញព្រះបាទសព្វមិត្ត ប្រថាប់នៅលើរាជបល្ល័ង្កក្រោមស្វេតច្ឆត្រ ដើម្បីនឹងសោយសុរា ទើបព្រះអង្គទ្រង់ត្រិះរិះថា ប្រសិនបើព្រះបាទសព្វមិត្តទ្រង់សោយសុរា ជម្ពូទ្វីបទាំងអស់

នឹងត្រូវវិនាសទៅ ហេតុដូច្នេះ យើងនឹងធ្វើ មិនឲ្យទ្រង់បានសោយសុរា ហើយព្រះអង្គទ្រង់ក្លែងភេទជាព្រាហ្មណ៍ ទ្រង់កាន់ក្អម ( ឆ្នាំង ) ដែលពេញដោយសុរា ស្ដេចចុះចាកមកពីស្ថានតាវត្តិង្ស ដោយប្រថាប់នៅលើអាកាស ត្រង់ទីប្រថាប់របស់ព្រះបាទសព្វមិត្តនោះ ហើយត្រាស់ថា សូមព្រះអង្គ ទ្រង់ទិញក្អមនេះចុះ ។ ព្រះបាទសព្វមិត្តទ្រង់ព្រះសណ្ដាប់នូវព្រះតម្រាស់នោះហើយ ទើបទ្រង់បែរព្រះភក្ត្រងើបមើលលើ ទ្រង់ឃើញព្រាហ្មណ៍មកឈរនៅលើអាកាសដូច្នោះក៏ទ្រង់សព្វព្រះហឫទ័យ ទើបត្រាស់សួរថា ព្រាហ្មណ៍ លោកជានរណាមកពីទីណា ទើបមានរស្មីផ្សាយទូទៅទាំងអាកាស ដូចគ្នានឹងពន្លឺនៃព្រះចន្ទក្នុងពេលរាត្រី ឬដូចគ្នានឹងពន្លឺ ផ្លេកបន្ទោរដូច្នោះ ។ លោកអាចស្ថិតនៅលើអាកាសបាន លោកឈរ ឬដើរនៅលើអាកាសបាន លោកជាអ្នកមានឫទ្ធិដូចជាទេវតា ដោយមិនត្រូវប្រើជើងដើរ នៅលើអាកាស លោកមកឈប់ឈរនៅលើអាកាស ហើយពោលជាមួយនឹងយើង ចូរទិញក្អមនេះទៅ ក្អមនេះ លោកប្រាប់ឲ្យយើងទិញ មាន

ប្រយោជន៍អ្វី សូមលោកប្រាប់ប្រយោជន៍ ឲ្យយើងបានជ្រាប ក្នុងកាលឥឡូវនេះផងបានដែរឬទេ ? គ្រានោះ ទើបសក្កទេវរាជដែលក្លែងភេទត្រាស់តបថា ក្អមនេះមិនមែនក្អមទឹកដោះថ្លា មិនមែនក្អមទឹកដោះខាប់ មិនមែនទឹកឃ្មុំ ទឹកអំពៅ តែក្អមនេះ មានទោសច្រើន សូមព្រះអង្គស្តាប់ទោសច្រើនយ៉ាង ដែលមាននៅក្នុងក្អមនេះចុះ ហើយសក្កទេវរាជបានពោលថា

បុគ្គលណាផឹកចូលទៅហើយ ដើរទ្រេតទ្រោត ភ្លាត់ធ្លាក់ទៅក្នុងជ្រោះ ធ្លាក់ទៅក្នុងអណ្តូង ធ្លាក់ទៅក្នុងរូង ធ្លាក់ទៅក្នុងអន្លង់ និងធ្លាក់ទៅក្នុងរណ្តៅស្មោកគ្រោក សូម្បីរបស់ដែលមិនគួរបរិភោគ ក៏បរិភោគបាន សូមព្រះអង្គទិញក្អម ដែលដាក់ពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយ ជាអ្នកខូចសតិ មិនមានក្រឹត្យក្រមក្នុងចិត្ត ដើរត្រែតត្រេតដូចជាគោស៊ីបាយស្រោ ដូចមនុស្សអនាថា គឺមនុស្សមិនមានទីពឹងឃើញនរណាច្រៀងរាំ ក៏ចូលទៅច្រៀងរាំជាមួយនឹងគេបាន ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយ ក្រោកឡើង

ដើរទ្រេតទ្រោតគ្រវីក្បាលទៅមក លើដៃច្រងស្ពាំឡើងរាំច្រៀង ស្រដៀងនឹងទីងមោង ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយ អាចស្រាតសំពត់ចោល ធ្វើឲ្យរាងកាយអាក្រាតនទលគកបានដូចគ្មានទឹងពួកអចេលក៍ ដើរគ្រប់កន្លែងតាមច្រកល្ហក មានចិត្តមួងល្អមួងអាក្រក់ ជាអ្នកដេកច្រើន ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយ ដេកលក់រហូតទល់ភ្លឺមិនដឹងខ្លួន អាចស៊ីអាហារដែលសល់ពីចចកបាន ជាហេតុធ្វើឲ្យត្រូវជាប់គុក ត្រូវសម្លាប់ ធ្វើឲ្យអស់ទ្រព្យសម្បត្តិ ។ ក្អមនេះពេញដោយទឹកបែបនោះ ។ អ្នកណាផឹកចូលទៅហើយ និយាយពាក្យដែលមិនគួរនិយាយបាន អង្គុយអាក្រាតកាយនៅក្នុងទីកន្លែងប្រជុំជនក៏មាន រាងកាយប្រឡាក់ធូលី ដេកនៅលើគំនរកម្អួតរបស់ខ្លួន ធ្វើឲ្យកើតការវិនាស មានតែការវិនាសតែម្យ៉ាងក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយយល់ខុសគិតថា ផែនដីទាំងអស់នេះ ជារបស់យើងតែម្នាក់ សូម្បីព្រះរាជាមានមហាសមុទ្រទាំង ៤ ជាព្រំដែន ក៏មិនស្មើនឹងយើង ក្អមនេះពេញ

ដោយទឹកបែបនោះ ។

បុគ្គលណាផឹកចូលទៅហើយ មានមានះ គឺការប្រកាន់ខ្លួន និង មើលងាយអ្នកដទៃ ចូលចិត្តបង្កជម្លោះ និយាយស៊ីកសៀតញុះញង់ ចូលចិត្តអាក្រាតដើររត់គ្មានគោលដៅ ចូលចិត្តស្និទ្ធស្នាលនឹងពួកអ្នក លេង ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយ ធ្វើត្រកូលទាំងឡាយក្នុងលោក ដែលសម្បូរទៅដោយទ្រព្យធនធាន ស្តុកស្តម្ភជាច្រើន ឲ្យដាច់សូន្យទាយាទ គឺអ្នកទទួលមត៌ក ក្អមនេះពេញ ដោយទឹកបែបនោះ ។ បុគ្គលណាផឹកចូលទៅហើយ បុគ្គលនោះ រមែងបំផ្លាញមុខរបរ ទ្រព្យសម្បត្តិ មានមាស ប្រាក់ ដី ស្រែចម្ការ គោក្របីឲ្យវិនាសទៅ បំផ្លាញត្រកូលដែលមានទ្រព្យឲ្យសាបសូន្យទៅ ព្រោះផឹកសុរា ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាផឹក ចូលទៅហើយ ក្លាយជាមនុស្សថោកទាប អាចជេរឪពុកម្តាយខ្លួនឯងបាន កូនប្រសាប្រុសចាប់ប៉ះពាល់ជីដូនខ្លះ ឪពុកក្មេកចាប់ដៃកូនប្រសាស្រីខ្លះ ដោយអំណាចកិលេសតណ្ហា ដោយសម្គាល់ថាជាភរិយា ក្អមនេះពេញ

ដោយទឹកបែបនោះ ។ បើជាស្ត្រីណាបានផឹកចូលទៅហើយ ក៏ក្លាយជា
មនុស្សថោកទាប អាចជេរម្តាយឪពុកក្មេក ឬប្តីរបស់ខ្លួនបាន ចាប់ដៃ
ជើងទាសៈ និងកម្មកររបស់ខ្លួនក៏បាន ដោយអំណាចនៃកិលេសតណ្ហា
សម្គាល់ថាជាស្វាមីរបស់ខ្លួន ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គល
ណាផឹកចូលទៅហើយ អាចសម្លាប់សមណៈ ឬព្រាហ្មណ៍ ដែលជាអ្នក
តាំងនៅក្នុងធម៌បាន ហើយត្រូវធ្លាក់ទៅកាន់អបាយភូមិ ព្រោះការធ្វើ
អំពើអាក្រក់នោះជាហេតុ ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណា
ផឹកចូលទៅហើយ ប្រព្រឹត្តអំពើទុច្ចរិតតាមផ្លូវកាយ វាចា និងចិត្ត
ពេលដែលអស់ជីវិតទៅ រមែងធ្លាក់ទៅកាន់នរក ព្រោះការប្រព្រឹត្តអំពើ
អាក្រក់នោះ ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណា ក្នុងកាលមុន
សូម្បីមានអ្នកឲ្យប្រាក់ជាច្រើន និយាយអង្វរឲ្យគេ និយាយកុហក
មិនបាន តែគ្រាកាលបុគ្គលនោះផឹកសុរាចូលទៅហើយ អាចនិយាយ
កុហកបាន ក្អមនេះពេញដោយទឹកបែបនោះ ។ មនុស្សជាអ្នកបម្រើណា
បានផឹកចូលទៅហើយ លុះត្រូវចៅហ្វាយនាយប្រើឲ្យទៅ កាលមានកិច្ច

ប្រញាប់ក្រោកឡើង លុះអ្នកបម្រើនោះ ទៅសាកសួរថា លោកមានធុរៈអ្វី គេមិនដឹងរឿងដែលខ្លួនត្រូវធ្វើ ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាបានផឹកចូលទៅហើយ សូម្បីខ្លួនធ្លាប់ជាមនុស្សមានសេចក្តីខ្មាសអៀន ក៏អាចធ្វើឲ្យជាមុនស្សលែងមានការខ្មាសអៀនបាន សូម្បីជាអ្នកចេះដឹង ក៏ធ្វើឲ្យលែងចេះដឹងបាន ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណា ផឹកចូលទៅហើយ ដើរដេកជួបជុំគ្នា ដូចកូនជ្រូកទាំងឡាយ ដេកអត់បាយ អត់ទឹក ដេកនៀលទៅមកនៅលើផែនដីយ៉ាងលំបាក រាងកាយកខ្វក់ អស់រាសី ត្រូវគេតិះដៀលនិន្ទា ក្អមនេះពេញដោយទឹកបែបនោះ ។ បុគ្គលណាបានផឹកចូលទៅហើយ ដេកបត់កដូចគោត្រូវគេចងជាប់នឹងនង្គ័ល គឺជាមនុស្ស ដូចគោដែលដេកងើបលែងរួច មិនស៊ីបាយ មិនផឹកទឹក ក្អមនេះពេញដោយទឹកបែបនោះ ។ មនុស្សទាំងឡាយណា វៀរចាកការផឹកទឹកដែលមានពិស ដូចគ្មានទឹងពស់មានពិសជាពន្លឹក តើបុគ្គលណាសមគួរនឹងផឹកទឹកសុរានោះ ដែលប្រៀបដូចសត្វអាសិរពិស ដែលមាននៅក្នុងលោក ក្អមនេះពេញដោយទឹក

បែបនោះ ។ ឱរសរបស់ស្តេចអន្ធកវេណ្ហុ គឺជាព្រះរាជាដែលមានបងប្អូន ១០ ព្រះអង្គ កាលទ្រង់សោយនូវទឹកបែបណាហើយ នាំស្រីទៅសប្បាយនៅកន្លែងឆ្នេរមហាសមុទ្រ ហើយកើតការវាយគ្នាដោយអង្រែរហូតដល់ស្លាប់ទាំងអស់គ្នា ក្អមនេះពេញដោយទឹកបែបនោះ ។ ទេវតាក្នុងកាលមុន គឺពួកអសុរបានផឹកសុរាហើយ កើតការស្រវឹង ទើបត្រូវច្បុតចាកស្ថានតាវត្តិង្ស តែនៅតែសម្គាល់ខ្លួនថា ជាអ្នកមានអាយុវែងធ្វើឲ្យពួកអសុរ ជាពួកម្ចាស់កលល្បិចមាយា ក្អមនេះ ពេញដោយទឹកបែបនោះ ។ បពិត្រមហារាជ បុគ្គលមានសេចក្តីក្លៀវក្លា មានប្រាជ្ញាដូចព្រះអង្គ កាលជ្រាបថា ទឹកនេះមានទោស ជាទឹកស្រវឹង គ្មានប្រយោជន៍ដូចនោះ ព្រះអង្គទ្រង់សោយធ្វើអ្វី ? ក្នុងក្អមនេះ មិនមែនទឹកដោះខាប់ មិនមែនទឹកឃ្មុំ មិនមែនទឹកអំពៅ មិនមែនប្រេង បពិត្រមហារាជ ព្រះអង្គទ្រង់ជ្រាបយ៉ាងនេះហើយ ចូរបំផ្លាញវាចោលទៅខ្ញុំបានបង្ហាញឲ្យឃើញនូវទោសរបស់ទឹក ដែលនៅក្នុងក្អមនេះ តាមសេចក្តីពិតហើយ ។

កាលព្រះបាទសព្វមិត្ត ទ្រង់បានព្រះសណ្ដាប់ព្រះរាជតម្រាស់របស់សក្កទេវរាជដូច្នោះហើយ ទ្រង់បានជ្រាបដល់ទោសនៃសុរា ក៏ទ្រង់មានព្រះទ័យរីករាយ ទើបទ្រង់បន្លឺឧទានសរសើរសក្កទេវរាជថា

លោកមិនមែនមាតាបិតារបស់ខ្ញុំ តែជាអ្នកអនុគ្រោះប្រយោជន៍ប្រាថ្នាផលយ៉ាងក្រៃលែងដល់ខ្ញុំៗ សូមធ្វើតាមពាក្យរបស់លោកក្នុងថ្ងៃនេះ ហើយត្រាស់តបស្នងសងគុណព្រាហ្មណ៍នោះថា ខ្ញុំឲ្យស្រុកសួយ ៥ តំបន់ នាងទាសី ១០០ នាក់ គោ ៧០០ ក្បាល និងឲ្យរថទឹមដោយសេះអាជានេយ្យ ១០ គ្រឿង ដល់លោកជាអាចារ្យ អ្នកប្រាថ្នាប្រយោជន៍ដល់ខ្ញុំ ។

គ្រានោះ សក្កទេវរាជ ទ្រង់ព្រះសណ្ដាប់នូវព្រះរាជតម្រាស់ដូច្នេះហើយ មានបំណងនឹងទ្រង់បង្ហាញព្រះអង្គ ឲ្យព្រះបាទសព្វមិត្តទ្រង់ជ្រាបថា ព្រះអង្គជាសក្កទេវរាជ ទើបទ្រង់ពោលទៅថា

បពិត្រមហារាជ ស្រុកសួយ ៥ តំបន់ នាងទាសី ១០០ នាក់ គោ ៧០០ ក្បាល និងរថទឹមដោយសេះអាជានេយ្យ ១០ គ្រឿង ដែល

លោកឲ្យដល់ខ្ញុំៗ សូមឲ្យដល់លោកវិញ ព្រោះហេតុថា ខ្ញុំជាសក្កទេវរាជ ជាអ្នកធំជាងទេវតានៅជាន់តាវត្តិង្ស សូមព្រះអង្គទ្រង់សោយតែសាច់ និងទឹកដោះថ្លា ប្រេង នំផ្សេងៗ ដ៏មានឱជារសចុះ ។ បពិត្រព្រះសព្វមិត្ត ទ្រង់ចូរត្រេកអរក្នុងធម៌ ដែលមិនមានអ្នកណាអាចតិះដៀលបាន ទ្រង់ចូរប្រព្រឹត្តធម៌ ដែលជាធម៌ឲ្យទៅកើតក្នុងស្ថានសួគ៌ គឺទ្រង់ចូរលះបង់ការផឹកសុរា ចូរលះបង់ទុច្ចរិត ៣ ប្រការ ចូរត្រេកអរប្រព្រឹត្តក្នុងសុចរិតធម៌ទាំង ៣ ប្រការ បានដល់ កាយសុចរិត វចីសុចរិត មនោសុចរិត ធម៌ទាំងនេះ នរណាៗ ក្នុងលោកនេះ មិនអាចតិះដៀលបាន ព្រោះទ្រង់ធ្វើយ៉ាងនេះ ទ្រង់នឹងទៅកើតក្នុងស្ថានសួគ៌ជាពិតប្រាកដ ។

លុះសក្កទេវរាជ ទ្រង់ប្រទានឱវាទឲ្យដល់ព្រះបាទសព្វមិត្ត ដូច្នេះហើយ ទើបស្ដេចត្រឡប់ទៅកាន់ស្ថានរបស់ព្រះអង្គវិញ ។ ឯព្រះបាទសព្វមិត្ត ក៏ទ្រង់មិនបានសោយសុរា ថែមទាំងត្រាស់បញ្ជាឲ្យគេវាយបំបែកកាជនៈដែលដាក់សុរានោះទាំងអស់ឲ្យបែកហើយ ព្រះអង្គទ្រង់សមាទានសីល ៥ ឲ្យទាន រហូតដល់ទ្រង់សោយទិវង្គត ហើយស្ដេច

ក៏បានទៅកើតក្នុងស្ថានសួគ៌ ។ កាលព្រះមានបុណ្យ ទ្រង់នាំអតីតនិទាន មកយ៉ាងនេះហើយ ដែលជាប្រវត្តិរបស់សុភ ឲ្យឧបាសិកាវិឌាសា និង ពួកស្ត្រីទាំងនោះបានស្តាប់ហើយ ទើបទ្រង់ប្រជុំនិទានជាតកថា ព្រះបាទ សព្វមិត្តក្នុងកាលនោះ បានមកជាព្រះអានន្ទ ចំណែកសក្កទេវរាជ បានមកជាតថាគតនេះឯង ។

សេចក្តីសោកសៅតូចចិត្ត រមែងកើតឡើងដល់បុគ្គលអ្នកមាន សេចក្តីស្រឡាញ់ ដោយទូទៅគ្រប់ជាតិ គ្រប់វណ្ណៈ មិនមានការលើកលែង ដោយថា ការសោកសៅតូចចិត្តក៏កើតបានដែរ ដូចជាឧបាសិកាវិសាខា ដែលជាព្រះសោតាបន្នហើយ ក៏នៅតែមានសេចក្តីសោកសៅដែរ តាម ដែលមានរឿងពោលទុកនៅក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ ឧទាន** នៃ **បាដលិគ្គាមិយវគ្គ** ក្នុង **អដ្ឋមសូត្រ** ដូចមានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់លើប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ចៅស្រីជាទីស្រឡាញ់ពេញចិត្តរបស់ឧបាសិកាវិសាខា

ធ្វើមរណកាល ។ គ្រានោះ វិសាខាមិគារមាតា មានសំពត់សើម សក់សើម ចូលទៅគាល់ព្រះមានជោគទាំងថ្ងៃត្រង់ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាង វិសាខាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះមុនីទ្រង់ត្រាស់ថា នែនាងវិសាខា ចុះនាងមកពីណា មានសំពត់សើម មានសក់សើម ចូលមកក្នុងទីនេះ ទាំងថ្ងៃត្រង់ ? បពិត្រព្រះអង្គដ៏ចម្រើន ចៅស្រីជាទី ស្រឡាញ់ពេញចិត្តរបស់ខ្ញុំព្រះអង្គ បានធ្វើមរណកាល ។ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គមានសំពត់សើម សក់សើម ចូលមកក្នុងទីនេះទាំង ថ្ងៃត្រង់ ។ នែនាងវិសាខា មនុស្សនៅក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូន និងចៅចំនួនប៉ុណ្ណោះឬ ? បពិត្រព្រះអង្គដ៏ចម្រើន មនុស្សនៅក្នុងក្រុងសាវត្ថី មានចំនួនប៉ុនណា ខ្ញុំព្រះអង្គចង់បានកូន និងចៅ មានចំនួនប៉ុណ្ណោះដែរ ។ នែនាងវិសាខា ចុះមនុស្សទាំងឡាយ នៅក្នុងក្រុងសាវត្ថីមានជាច្រើន តែងធ្វើមរណកាលរៀងរាល់ថ្ងៃប៉ុន្មាន នាក់ ? បពិត្រព្រះអង្គដ៏ចម្រើន មនុស្សនៅក្នុងក្រុងសាវត្ថី ធ្វើមរណកាល

រាល់ៗ ថ្ងៃ ១០ នាក់ខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សនៅក្នុងក្រុងសាវត្ថី ធ្វើមរណកាលពរាល់ៗ ថ្ងៃ ៩ នាក់ខ្លះ ៨ នាក់ខ្លះ ៧ នាក់ខ្លះ ៦ នាក់ខ្លះ ៥ នាក់ខ្លះ ៤ នាក់ខ្លះ ៣ នាក់ខ្លះ ២ នាក់ខ្លះ ម្នាក់ខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សនៅក្នុងក្រុងសាវត្ថី ចេះតែធ្វើមរណកាលមិនដែលស្ងាត់ទេ ។ នៃនាងវិសាខា នាងសម្គាល់ហេតុនោះដូចម្តេច ចុះនាងជាអ្នកមានសំពត់សើម សក់សើម ក្នុងកាលម្តងៗ ឬទេ ? បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះមិនមែនដូច្នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គល្មមត្រឹមតែកូន និងចៅចំនួនច្រើនប៉ុណ្ណោះ ។ នៃនាងវិសាខា បុគ្គលណាមានវត្ថុជាទីស្រឡាញ់ ១០០-៩០-៨០-៧០-៦០-៥០-៤០-៣០-២០-១០-៩-៨-៧-៦-៥-៤-៣-២-១ បុគ្គលនោះក៏មានសេចក្តីទុក្ខប៉ុណ្ណោះដែរ បុគ្គលណា មិនមានវត្ថុជាទីស្រឡាញ់ បុគ្គលនោះ ក៏មិនមានសេចក្តីទុក្ខដែរ ។ ទើបតថាគតពោលថា បុគ្គលទាំងនោះ ជាអ្នកមិនមានសោក ជាបុគ្គលប្រាសចាកធូលី គឺកិលេស ជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់ ។ លុះព្រះភគវា ទ្រង់ជ្រាបច្បាស់

សេចក្តីនោះហើយ ទើបទ្រង់បន្លឺឧទាននេះក្នុងពេលនោះថា

សេចក្តីសោកក្តី សេចក្តីខ្សឹកខ្សួលក្តី ណាមួយ ឬសេចក្តីទុក្ខជាច្រើនយ៉ាងក្នុងលោក ធម៌ទាំងនោះ រមែងកើតឡើង ព្រោះអាស្រ័យសត្វ និងសង្ខារដែលជាទីស្រឡាញ់ កាលបើមិនមានសត្វ និងសង្ខារដែលជាទីស្រឡាញ់ហើយ ធម៌ទាំងនោះ ក៏រមែងមិនមាន ។ ព្រោះហេតុនោះឯង បុគ្គលណា មិនមានសត្វ និងសង្ខារដែលជាទីស្រឡាញ់ក្នុងលោកណាមួយទេ ទើបបុគ្គលនោះ មានសេចក្តីសុខ ប្រាសចាកសេចក្តីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្តីមិនសោក និងការប្រាសចាកធូលី គឺកិលេស មិនគប្បីធ្វើសត្វ និងសង្ខារឲ្យជាទីស្រឡាញ់ក្នុងលោកណាមួយឡើយ ។

ចំណែករឿងសេចក្តីសោករបស់មហាឧបាសិកាវិសាខា ដែលជាសេចក្តីសោកទាក់ទងពីមរណភាពចៅជាទីស្រឡាញ់នោះ មានសម្តែងនៅក្នុង អដ្ឋកថាធម្មបទ នៃ បិយវគ្គ ក្នុង រឿងមហាឧបាសិកាវិសាខា ដូចមានសេចក្តីថា ៖

ព្រះសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់បានត្រាស់ព្រះធម៌ទេសនា ប្រារព្ធដល់មហាឧបាសិកាវិសាខាថា មហាឧបាសិកាវិសាខា បានតាំងកុមារីឈ្មោះ **សុទត្តី** នាងជាចៅរបស់បុត្រនាង បានតាំងចៅនោះទុកមើលការខុសត្រូវជំនួសខ្លួន ដោយឲ្យធ្វើការរៀបចំក្នុងការប្រគេនចង្ហាន់ចំពោះភិក្ខុសង្ឃ ដែលនិមន្តមកឆាន់ក្នុងផ្ទះរបស់ខ្លួន ។ ដោយសម័យតមក នាងសុទត្តីបានធ្វើកាលកិរិយាទៅ ។ មហាឧបាសិកាវិសាខា បានឲ្យធ្វើការបញ្ចុះសពរបស់នាងសុទត្តីដែលជាចៅក្រមុំហើយ នាងមិនអាចនឹងអត់សង្កត់សេចក្ដីសោកបាន មានទុក្ខតូចចិត្ត ហើយបានទៅកាន់សម្នាក់ព្រះមានជោគ ថ្វាយបង្គំរួចហើយអង្គុយនៅក្នុងទីសមគួរ ។ លំដាប់នោះ ព្រះមានបុណ្យ ទ្រង់ត្រាស់នឹងមហាឧបាសិកាវិសាខាថា នែនាងវិសាខា ដូចម្ដេចទើបនាងមានសេចក្ដីសោក ថែមទាំងមានទឹកភ្នែកហូរជោកមុខ អង្គុយយំដូច្នេះ ? មហាឧបាសិកាវិសាខាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដែលខ្ញុំព្រះអង្គមានសេចក្ដីសោកដូចនេះ ព្រោះនាងសុទត្តីកុមារី ដែលជា

ចៅស្រីរបស់ខ្ញុំព្រះអង្គ បានធ្វើមរណកាលទៅហើយ នាងសុទត្តីកុមារី ជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំព្រះអង្គ ជាពិសេសនោះ គឺជាអ្នកបាន បំពេញតួនាទីយ៉ាងល្អ ក្នុងការរៀបចំចង្ហាន់បិណ្ឌបាតប្រគេនចំពោះ ភិក្ខុសង្ឃនៅឯផ្ទះ ឥឡូវនេះ ខ្ញុំព្រះអង្គមិនឃើញនរណា ដែលមាន គុណសម្បត្តិយ៉ាងនេះ ដូច្នេះ ព្រះអង្គ ។ ទើបព្រះជិនស្រីទ្រង់ត្រាស់ សួរថា នែនាងវិសាខា នៅក្នុងក្រុងសាវត្ថី មានមនុស្សប៉ុន្មាននាក់ ? មហាឧបាសិកាវិសាខាបានទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន នៅក្នុង ក្រុងសាវត្ថីនេះ មានមនុស្ស ៧ កោដិ ព្រះអង្គ ។ ព្រះវិជិតមារត្រាស់ សួរថា នែនាងវិសាខា ប្រសិនបើមនុស្សមានចំនួនប្រមាណប៉ុណ្ណោះ និងមនុស្សប្រមាណប៉ុណ្ណោះដូចគ្នា នឹងចៅស្រីរបស់នាងៗ គប្បីប្រាថ្នា គេឬ ? នាងវិសាខាទូលតបថា យ៉ាងហ្នឹងព្រះអង្គ ។ ព្រះសក្យមុនី ត្រាស់ថា នែនាងវិសាខា មនុស្សនៅក្នុងក្រុងសាវត្ថីស្លាប់រាល់ៗ ថ្ងៃ មានចំនួនប៉ុន្មាននាក់ ? នាងវិសាខាទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន មនុស្សស្លាប់នៅក្នុងក្រុងសាវត្ថីនេះ មួយថ្ងៃៗ មានចំនួនច្រើនណាស់

ព្រះអង្គ ។ ព្រះសាស្តា ត្រាស់សួរទៀតថា នែនាងវិសាខា កាលបើមានដូច្នេះ ពេលដែលនាងនឹងជួរស្រោលពីសេចក្តីសោកក៏នឹងមិនមានមិនមែនទេឬ នាងនឹងត្រូវដើរយំទាំងយប់ទាំងថ្ងៃយ៉ាងនោះឬ ? នាងវិសាខាទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនេះលើកទុកសិនចុះខ្ញុំព្រះអង្គជ្រាបហើយ ព្រះអង្គ ។ ទើបព្រះសម្ពុទ្ធត្រាស់ពន្យល់ហេតុផលឲ្យដល់នាងវិសាខាថា នែនាងវិសាខា ប្រសិនបើដូច្នោះ នាងកុំសោកសេចក្តីសោក និងភ័យ រមែងកើតពីសេចក្តីស្រឡាញ់ ហើយព្រះអង្គទ្រង់ត្រាស់ព្រះគាថាថា

**សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកអំពីណា ?**

ក្នុងពេលដែលព្រះទសពល ទ្រង់សម្តែងព្រះធម៌ទេសនាចប់យ៉ាងនេះហើយ មានមហាជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមានព្រះសោតាបត្តិផលជាដើម ។

ការពិចារណាជ្រើសរើសព្រះលោកនាយក ដែលជាហេតុឲ្យមហាឧបាសិកាវិសាខា បានចូលទៅក្រាបទូលសួរព្រះភគវា ដូចមានរឿងតំណាលទុកនៅក្នុងព្រះបាលី **គម្ពីរមហាវគ្គ ព្រះវិនយបិដក នៃកោសម្ពិក្ខន្ធកៈ** វគ្គដែលពោលអំពីរឿងមហាឧបាសិកាវិសាខាចូលគាល់ក្រាបទូលសួរចំណុចបដិបត្តិ ដូចមានសេចក្ដីថា ៖

នាងវិសាខាជាមិគារមាតា បានឮដំណឹងថា ពួកភិក្ខុនៅក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្កហេតុ គឺឈ្លោះទាស់ទែងគ្នានឹងគ្នាធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ ។ លំដាប់នោះ នាងវិសាខាជាមិគារមាតាបានចូលទៅគាល់ព្រះបរមគ្រូ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះជិនវរ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនាងវិសាខាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើនឮថា ពួកភិក្ខុនៅក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្កហេតុ ឈ្លោះទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់

ក្រុងសាវត្ថីហើយ បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងពួកភិក្ខុទាំងនោះដូចម្ដេច ? គ្រានោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់តបថា នែនាងវិសាខា បើដូច្នោះ ចូរនាងឲ្យទានក្នុងសង្ឃទាំងពីរពួកចុះ លុះនាងឲ្យទានដល់សង្ឃទាំងពីរពួករួចហើយ ចូរនាងស្ដាប់ធម៌ក្នុងសម្នាក់សង្ឃទាំងពីរពួកទៀត លុះនាងស្ដាប់ធម៌ក្នុងសម្នាក់សង្ឃទាំងពីរពួកហើយ បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលជាធម្មវាទី ចូរនាងកាន់យកតាមទិដ្ឋិ សេចក្ដីគាប់ចិត្ត សេចក្ដីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះចុះ ។

ជីវិតរបស់សព្វសត្វ រមែងមានខាងដើម គឺកើត ហើយត្រូវមានខាងចុង គឺស្លាប់យ៉ាងពិតប្រាកដ តែការកើតនិងការស្លាប់របស់សព្វសត្វ ក៏មានសភាពប្លែកផ្សេងគ្នាទៅតាមអំណាចរបស់កម្មដែលខ្លួនធ្វើ ដូចសេចក្ដីដែលពោលទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយ វិមានវត្ថុ** នៃ **រឿងវិហារវិមាន** ( សេចក្ដីខ្លះក្នុងរឿងនេះបានពោលរួចមកហើយខ្លះនៅក្នុងវគ្គខាងដើម ប៉ុន្ដែមានសេចក្ដីប្លែកផ្សេងគ្នាខ្លះ ) ថា ៖

សម័យមួយ ព្រះសាស្តា ប្រថាប់គង់នៅវត្តជេតពន ជិតក្រុងសាវត្ថី ។ គ្រានោះ ឧបាសិកាវិសាខា ព្រមដោយស្ត្រីដែលជាសម្លាញ់និងបរិវារ ម្នាក់ៗ ខិតខំងូតទឹកសម្អាតខ្លួន ដើម្បីនឹងដើរទៅកាន់ឧទ្យាននៅក្នុងថ្ងៃមួយ ។ ចំណែកឧបាសិកាវិសាខា បានទទួលទានអាហារយ៉ាងប្រណីត ហើយប្រដាប់ដោយគ្រឿងអាវមហាលតាបសាធន៍ និងហែហមដោយពួកស្ត្រី ដែលជាសម្លាញ់ប្រមាណ ៥០០ នាក់ ចេញចាកផ្ទះព្រមដោយបរិវារជាច្រើនទៀត ជាក្បួនដ៏ធំ កំពុងតែដើរសំដៅទៅកាន់ឧទ្យាននោះ ទើបនាងគិតជញ្ជឹងថា មានប្រយោជន៍អ្វី ដែលយើងនាំគ្នាដើរទៅលេងដូចកូនក្មេង ដោយគ្មានប្រយោជន៍ដូចក្មេងស្រីល្ងង់ ដូច្នេះយើងត្រូវទៅកាន់វត្ត ដើម្បីថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ និងថ្វាយបង្គំព្រះភិក្ខុសង្ឃ ហើយស្តាប់ធម៌ កាលនាងគិតឃើញដូច្នេះហើយ ក៏បាននាំគ្នាដើរទៅកាន់វត្ត លុះទៅដល់ហើយ ទើបឈប់ឈរនៅកន្លែងមួយដ៏សមគួរ បានដោះគ្រឿងប្រដាប់អាវមហាលតាបសាធន៍ ប្រគល់ឲ្យនាងទាសីកាន់ ហើយនាងដើរទៅគាល់ព្រះលោកនាថ ថ្វាយបង្គំហើយ

ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះពុទ្ធអង្គទ្រង់សម្តែងធម៌ឲ្យមហាឧបាសិកាវិសាខាស្តាប់ ។ មហាឧបាសិកាវិសាខា ក្រោយអំពីស្តាប់ព្រះធម៌រួចហើយ ទើបក្រាបថ្វាយបង្គំលាព្រះសាស្តា ធ្វើប្រទក្សិណែថមទាំងថ្វាយបង្គំលាភិក្ខុសង្ឃទៀត ហើយចេញចាកវិហារទៅបានបន្តិចមហាឧបាសិកាវិសាខា បាននិយាយប្រាប់ទាសី ឲ្យហុចគ្រឿងប្រដាប់អាវមហាលតាបសាធន៍មកឲ្យថា ខ្ញុំត្រូវការគ្រឿងប្រដាប់វិញ ។ ចំណែកទាសីបានភ្លេចគ្រឿងប្រដាប់នោះទុកនៅឯវិហារ ហើយបាននិយាយប្រាប់នាងវិសាខាថា នាងម្ចាស់ ខ្ញុំភ្លេចគ្រឿងប្រដាប់នោះនៅឯវិហារហើយ សូមនាងម្ចាស់ឈប់រង់ចាំបន្តិចសិនចុះ ខ្ញុំនឹងទៅយកមកឲ្យ ។ ទើបនាងវិសាខាប្រាប់ថា នែនាង ប្រសិនបើនាងភ្លេចគ្រឿងប្រដាប់នោះនៅឯវិហារ បើលោកម្ចាស់អានន្ទរក្សាទុកហើយ ខ្ញុំនឹងបរិច្ចាគគ្រឿងប្រដាប់នោះ ដើម្បីកសាងវត្ត កាលនាងទាសីទៅដល់ឯវិហារក៏បានដឹងថា គ្រឿងប្រដាប់អាវមហាលតាបសាធន៍នោះ ព្រះអានន្ទបានរក្សាទុកមែន ហើយនាងទាសីនោះបានត្រឡប់នាំរឿងនោះ មកប្រាប់

ដល់នាងវិសាខាវិញ នាងវិសាខា កាលបានដឹងរឿងនោះដូច្នោះហើយ នាងបានចូលទៅកាន់វិហារ ដើម្បីគាល់ព្រះមហាវីរៈ ថ្វាយបង្គំរួចហើយ ពិតនូវបំណាំងរបស់ខ្លួនមក ដោយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងកសាងវត្ត សូមព្រះពុទ្ធអង្គទ្រង់មេត្តាអនុគ្រោះទទួលផង ព្រះអង្គ ។ ពេលនោះ ព្រះមហាមុនី ទ្រង់ទទួលដោយតុណ្ហីភាព ។ ឧបាសិកាវិសាខា បានលះបង់គ្រឿងប្រដាប់អាវមហាលតាបសាធន៍ ដែលមានតម្លៃ ៩ កោដិកហាបណៈ ដើម្បីកសាងវត្ត ថែមទាំងបាន លះបង់ប្រាក់ ៩ កោដិកហាបណៈទៀត ដើម្បីកសាងសេនាសនៈ ដែលមានប្រាសាទធំ សមគួរជាទីប្រថាប់របស់ព្រះលោកនាយក និង ទីលំនៅរបស់ភិក្ខុសង្ឃ ដោយកសាងជាប្រាសាទពីរជាន់មាន ១០០០ បន្ទប់ គឺជាន់ខាងក្រោម ៥០០ បន្ទប់ ជាន់ខាងលើ ៥០០ បន្ទប់ ប្រៀប ដូចជាទិព្វវិមាន មានផ្ទៃរាបដូចឃ្លាំងកែវមណី មានចំណែករបស់ផ្ទះ ជាដើមថា ជញ្ជាំង សសរ ធ្នឹម បង្កង់ បង្អួច ទ្វារ និងជណ្តើរ ដោយ ព្រះមហាមោគ្គល្លាន ដែលជាអ្នកគ្រប់គ្រងចាត់ចែងកសាងបានយ៉ាងល្អ

គួរឲ្យរីករាយចាប់ចិត្តណាស់ កាលជាងតាក់តែងធ្វើរៀបរយល្អហើយ ។ ដោយចិត្រករកសាងចិត្ត កម្មយ៉ាងវិចិត្រ មានក្បាច់ផ្កាឈើ និងក្បាច់វល្លិ៍ជាដើម ដោយប្រដាប់ស្អិតស្អាងយ៉ាងស្អាត ស្រស់ល្អឥតខ្ចោះ ថែមទាំងកសាងប្រាសាទ មួយខ្នងៗ តូចៗ ១០០០ ខ្នងជាបរិវាររបស់ប្រាសាទធំនោះ ដោយប្រើប្រាស់វេលាកសាងអស់ ៩ ខែ ទើបរួចជាស្រេច ។ កាលបើ.កសាងវត្តរួចហើយ មហាឧបាសិកាវិសាខា បានចំណាយប្រាក់ក្នុងការធ្វើបុណ្យឆ្លងវត្តអស់ ៩ កោដិកហាបណៈទៀត ហើយនាងព្រមដោយស្ត្រីដែលជាសម្លាញ់ ៥០០ នាក់ បានឡើងទៅលើប្រាសាទបានឃើញខាងក្នុងប្រាសាទរៀបរយល្អ ក៏កើតសេចក្ដីសោមនស្សយ៉ាងច្រើន ទើបនាងប្រាប់ដល់ស្ត្រីជាសម្លាញ់ទាំងនោះថា ខ្ញុំបានកសាងប្រាសាទនេះបានបុណ្យច្រើនយ៉ាងណា សូមឲ្យពួកនាងទាំងអស់គ្នាអនុមោទនានូវចំណែកបុណ្យដែលខ្ញុំធ្វើហើយនោះ ឲ្យបានស្មើៗ គ្នាឬដូចនាងបានធ្វើដោយខ្លួនឯងដែរ ។ ចំណែកស្ត្រីដែលជាសម្លាញ់ទាំងអស់នោះ ក៏បានតាំងចិត្តអនុមោទនាត្រេកអរ ជាមួយនឹងមហា

ឧបាសិកាវិសាខា ដោយម្នាក់ៗ អនុមោទនាថា សាធុ សាធុ ប្រពៃ ហើយៗ ។ បណ្តាស្ត្រីទាំងអស់នោះ មានស្ត្រីដែលជាសម្លាញ់ម្នាក់ បានចាប់អារម្មណ៍ នឹកដល់បុណ្យនោះជាពិសេស វេលាតមកមិនយូរ ប៉ុន្មាន ស្ត្រីនោះ ក៏បានធ្វើកាលកិរិយាទៅកើតក្នុងជាន់ស្ថានតាវត្តិង្ស ។ ដោយបុណ្យអានុភាពរបស់នាងនោះ បានធ្វើឲ្យមានវិមានមាសមួយ ខ្ពង់ធំកើតឡើង ដោយវិមានមាសនោះមានទទឹង បណ្តោយ និងកម្ពស់ ១៦ យោជន៍ ប្រដាប់ដោយប្រាសាទតូចៗ កំពែង ឧទ្យាន និងស្រះ បោក្ខរណីជាដើមជាច្រើន អណ្តែតនៅលើអាកាស ផ្សាយរស្មីរបស់ខ្លួន ទៅប្រមាណ ១០០ យោជន៍ ។ នាងទេពអប្សរនោះ កាលដើរទៅណា ក៏ដើរទៅព្រមជាមួយនឹងវិមាន និងស្រីទេពអប្សរដែលជាបរិវារ ១០០០ នាក់ ។ចំណែកមហាឧបាសិកាវិសាខា ជាអ្នកមានចាគៈយ៉ាងច្រើន និង មានសទ្ធាយ៉ាងមុតមាំ កាលអស់ជីវិតទៅ ក៏បានទៅកើតនៅក្នុងស្ថានសួគ៌ ជាន់និម្មានរតី បានជាអគ្គមហេសីរបស់ស្តេចសុនិម្មិតទេវរាជ ។

ហេតុដែលអាចដឹងរឿងរបស់មហាឧបាសិកាបាន ក្នុងគ្រាដែល

ព្រះអនុរុទ្ធ បាននិមន្តទៅកាន់ទេវលោក ហើយបានជួបនូវស្ត្រីដែលជាសម្លាញ់របស់មហាឧបាសិកាវិសាខា ដែលនាងបានទៅកើតក្នុងស្ថានតាវត្តិង្ស ទើបព្រះថេរៈសួរថា ទេពធីតាដែលនាងមានសម្បុរស្អាតបញ្ចេញរស្មីចេញទៅគ្រប់ទិស ដូចផ្កាយព្រឹក កាលនាងច្រៀងរាំ មានសំឡេងទិព្វគួរឲ្យចង់ស្តាប់ គួរឲ្យរីករាយចិត្ត ថែមទាំងមានពន្លឺចេញពីអវយវៈតូចធំគ្រប់ចំណែក កាលបើនាងកម្រើកកាយគ្រឿងប្រដាប់នៅលើផ្នួងសក់ ក៏បន្លឺសំឡេងកងរំពងយ៉ាងពីរោះ គួរឲ្យចង់ស្តាប់ ប្រៀបដូចតន្ត្រីប្រកបដោយអង្គ ៥ កម្រងផ្កាប្រដាប់ក្បាលនៅត្រង់ផ្នួងសក់ ត្រូវខ្យល់បក់ញ័រ ក៏បញ្ចេញសំឡេងឮរំពង ប្រៀបដូចតន្ត្រីប្រកបដោយអង្គ ៥ កម្រងផ្កានៅលើក្បាលរបស់នាង មានក្លិនក្រអូបទាក់-ទាញចិត្ត ចំណែកកាយក៏មានក្លិនក្រអូបផ្សាយទៅគ្រប់ទិស ដូចដើមឱឡោកដូច្នោះ ៗ នៃនាងទេពធីតា នាងហិតក្លិនដែលក្រអូប ឃើញរូបដែលជាទិព្វ សឹងមិនមែនជារបស់មនុស្ស កាលបើអាត្មាសួរនាងហើយ ចូរនាងប្រាប់មកចុះ ទិព្វសម្បត្តិយ៉ាងនេះ នាងបានដោយផលនៃកុសល

កម្មអ្វី ?នាងទេពធីតានោះ ក្រាបថ្វាយបង្គំព្រះថេរៈហើយតបថា បពិត្រ លោកម្ចាស់ដ៏ចម្រើន មហាឧបាសិកាវិសាខា អ្នកដែលជាសម្លាញ់ របស់ខ្ញុំ នៅក្នុងក្រុងសាវត្ថី បានកសាងមហាវិហារថ្វាយដល់ភិក្ខុសង្ឃ ខ្ញុំបានឃើញមហាវិហារ និងការបរិច្ចាគទ្រព្យដល់ភិក្ខុសង្ឃដូច្នោះ ក៏បាន ត្រេកអរ និងជ្រះថ្លាចំពោះបុណ្យនោះ ទើបអនុមោទនានូវទានកុសល ទាំងអស់នោះ ទើបធ្វើឲ្យខ្ញុំបានវិមាន ដែលគួរឲ្យអស្ចារ្យ គួរឲ្យទស្សនា ដោយការអនុមោទនាយ៉ាងនេះឯង វិមានអណ្តែតនៅលើវេហាស៍បាន តាមបំណង បញ្ចេញរស្មីទៅ ១២ យោជន៍ដោយជុំវិញ ដោយឫទ្ធិ របស់ខ្ញុំ ប្រាសាទតូចដែលជាទីលំនៅរបស់ខ្ញុំនេះ ដែលបុញ្ញកម្មរៀបចំ ទុកជាពុម្ពដូចគ្នា ហាក់បីដូចជានិម្មិតទុកជាចំណែកៗ កាលមានពន្លឺ ក៏ភ្លឺឆ្ងាយទៅ ១០០ យោជន៍ គ្រប់ទិស មួយទៀត កន្លែងវិមានរបស់ខ្ញុំ មានស្រះបោក្ខរណី មានទឹកថ្លាស្អាត មានផ្ទៃរាបក្រាលដោយខ្សាច់មាស មានហ្វូងមច្ឆានៅអាស្រ័យជាប្រចាំ ដេរដាសទៅដោយផ្កាបទុមច្រើនពណ៌ មានឈូក.សដុះរាយព័ទ្ធជុំវិញ ពេលមានខ្យល់មករំភើយៗ ធ្វើងកាត់

នាំមកនូវក្លិនក្រអូប ដ៏ជាទីសប្បាយត្រជាក់ចិត្ត ទាំងមាននូវរុក្ខជាតិបានដល់ ដើមព្រីង ដើមខ្នុរ ដើមត្នោត ដើមម៉ាក់ប្រាង និងដើមឈើទាំងឡាយឯទៀត បានដុះឡើងឯង មិនមាននរណាដាំក្នុងនិវេសន៍របស់ខ្ញុំ មិនមែនតែប៉ុណ្ណោះទេ ខាងក្នុងវិមានរបស់ខ្ញុំ គឺកកងដោយសំឡេងតន្ត្រីផ្សេងៗ ពួកនាងទេពអប្សរក៏បានបញ្ចេញសំឡេងដ៏ពីរោះសូម្បីនរជនដែលយល់សុបិនឃើញហើយ ក៏ត្រូវរីករាយចិត្ត វិមានមានរស្មីភ្លឺទៅគ្រប់ទិស ជាទីគួរឲ្យអស្ចារ្យ គួរឲ្យទស្សនាដូចនេះ កើតឡើងព្រោះអាស្រ័យបុញ្ញកម្ម ដែលខ្ញុំអនុមោទនារួមចំណែកជាមួយនឹងមហាឧបាសិកាវិសាខា ព្រោះដូច្នោះ សាធុជនទាំងឡាយគួរធ្វើបុណ្យទាំងឡាយទុក លោកម្ចាស់ ។

ព្រះអនុរុទ្ធមានសេចក្តីប្រាថ្នានឹងឲ្យទេពធីតានោះ ប្រាប់ដល់ទីកន្លែងកើតរបស់មហាឧបាសិកាវិសាខា ទើបសួរថា នាងបានវិមានដែលគួរឲ្យអស្ចារ្យ គួរឲ្យទស្សនា ដោយការអនុមោទនាដ៏បរិសុទ្ធនោះហេតុដូច្នេះចូរនាងប្រាប់ទីកន្លែងកើតរបស់មហាឧបាសិកាវិសាខា ដែល

ជាសម្លាញ់របស់នាង ដែលបានថ្វាយទានហើយ តើនាងកើតនៅទីកន្លែងណា ? នាងទេពធីតានោះ បានទូលតបព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន មហាឧបាសិកាវិសាខាដែលជាសម្លាញ់របស់ខ្ញុំ ដែលជាអ្នកបានកសាងមហាវិហារថ្វាយចំពោះភិក្ខុសង្ឃ នាងដឹងច្បាស់នូវធម៌ ហើយបានថ្វាយទាននោះ នាងបានកើតនៅក្នុងស្ថានជាន់និម្មានរតីជាអគ្គមហេសីរបស់ស្តេចសុនិម្មិតទេវរាជក្នុងស្ថានសួគ៌នោះ ផលនៃកុសលកម្មរបស់មហាឧបាសិកាវិសាខា ដែលនរណាៗ មិនគួរគិត ខ្ញុំព្រះអង្គបាននិតអំពីទីកើតរបស់ឧបាសិកាតាមសេចក្តីពិតហើយ ។ ហើយនាងទេពធីតានោះ កាលនឹងទូលផ្តាំចំពោះព្រះអនុរុទ្ធឲ្យទៅបបួលបុគ្គលដទៃៗ ថ្វាយទានផង ទើបពោលថា ប្រសិនបើយ៉ាងនោះ សូមលោកម្ចាស់បបួលអ្នកដទៃៗ ថា ពួកលោកអ្នកមានទ្រព្យ ចូរថ្វាយទានដល់ភិក្ខុសង្ឃចុះ ចូរមានចិត្តជ្រះថ្លាស្តាប់ព្រះធម៌ទេសនា លាភ គឺការបានមកជាមនុស្ស ជាការបានដ៏សែនកម្រ ពួកលោកអ្នកក៏បានហើយ ។ ព្រះពុទ្ធទ្រង់មានព្រះសូរសៀង ដូចសំឡេងព្រហ្ម ទ្រង់មានព្រះឆវីវណ្ណ

ដូចមាស ទ្រង់ជាធំក្នុងផ្លូវ ទ្រង់បានបង្ហាញផ្លូវហើយ លោកអ្នកទាំងឡាយអ្នកមានទ្រព្យ ចូរថ្វាយទានដល់ភិក្ខុសង្ឃ ព្រោះការថ្វាយទានដល់ភិក្ខុសង្ឃ រមែងមានផលច្រើន ។ ព្រះអរិយបុគ្គល ៨ ពួកបើរាប់ជាគូបាន ៤ គូ ជាអ្នកដែលលោកអ្នកចេះដឹងបានពោលសរសើរហើយ បុគ្គលទាំងនោះ ជាទក្ខិណេយ្យបុគ្គល ជាសាវករបស់ព្រះមានជោគ ទានដែលថ្វាយដល់បុគ្គលទាំងនោះ រមែងមានផលច្រើន លោកដែលទ្រទ្រង់នូវអរិយមគ្គ ៤ និងអរិយផល ៤ ជាអ្នកប្រតិបត្តិដ៏ត្រង់ ជាអ្នករឹងមាំនៅក្នុងសីល សមាធិ បញ្ញា ។ ទានដែលបុគ្គលទាំងឡាយបូជាអ្នកស្វែងរកនូវបុណ្យ បានថ្វាយទានដល់ភិក្ខុសង្ឃយ៉ាងនេះ រមែងមានផលច្រើន ព្រោះភិក្ខុសង្ឃជាអ្នកមានគុណធម៌ច្រើន ជាអ្នកមានគុណធម៌ប្រមាណមិនបាន ប្រៀបដូចគ្នានឹងទឹកមហាសមុទ្រ ដូច្នោះដែរ ។ ព្រះសង្ឃទាំងនេះជាអ្នកប្រសើរបំផុត ជាសាវករបស់ព្រះពុទ្ធ ជាអ្នកទ្រទ្រង់នូវសេចក្ដីព្យាយាម ទ្រង់ជាអ្នកធ្វើឲ្យកើតពន្លឺ ទ្រង់ពោលប្រៀនប្រដៅណែនាំក្នុងធម៌ ។ ទានដែលបុគ្គលថ្វាយដល់សង្ឃយ៉ាងនេះ

រាប់ជាទានដែលថ្វាយល្អហើយ បូជាល្អហើយ ការថ្វាយដល់សង្ឃបែបនេះ រមែងមានផលច្រើន ជាទានដែលព្រះពុទ្ធទ្រង់សរសើរហើយ ។ បុគ្គលណា បានវិលត្រឡប់រឭកដល់បុណ្យយ៉ាងនេះ កើតចំណេះដឹង ហើយកម្ចាត់ ការកំណាញ់ ព្រមទាំងឫស មិនត្រូវអ្នកដទៃតិះដៀល បុគ្គលទាំងនោះ រមែងទៅកើតក្នុងស្ថានសួគ៌ ( រឿងនេះជាគោលបង្ហាញឲ្យឃើញ ឬ អំពីទីកន្លែងកើតរបស់ឧបាសិកាវិសាខា ) ។

ការដែលបានសម្រេចជាព្រះសោតាបន្នរបស់ឧបាសិកាវិសាខា រាប់ថា ជាករណីពិសេស ព្រោះកាលវេលា ដែលមហាឧបាសិកាអស់ ជីវិតទៅ ទៅកើតក្នុងទេវលោកហើយ នឹងមិនត្រឡប់មកកើតជាមនុស្ស វិញទេ ដូចមានសេចក្តីសម្តែងទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែល ជាអដ្ឋកថាអធិប្បាយសេចក្តីបាលី **គម្ពីរបុគ្គលប្បញ្ញត្តិ ព្រះអភិធម្មបិដក** ដូចមានសេចក្តីថា ៖

មហាឧបាសិកាវិសាខា និងអនាថបិណ្ឌិកសេដ្ឋីជាដើម ដែល បានជាសោតា **ឧទ្ធំសោត** ( រួមទាំងអស់ ៧ នាក់ ) គឺអ្នកនឹងទៅ

កើតក្នុងស្ថានសួគ៌ជាន់ខ្ពស់ឡើងៗ ទៅដោយលំដាប់ រហូតទៅដល់ជាន់សុទ្ធាវាសព្រហ្ម ហើយឡើងទៅបរិនិព្វានទៅជាន់អកនិដ្ឋា គឺរូបព្រហ្មជាន់ខ្ពស់បំផុត ក្នុងបណ្តាព្រហ្មទាំង ១៦ ជាន់ ដែលជាន់ខ្ពស់បំផុតនិងជាជាន់សុទ្ធាវាសភូមិ ជាជាន់ខ្ពស់បំផុត ដោយមហាឧបាសិកាវិសាខានឹងមិនចុះមកកើតជាមនុស្សទៀតឡើយ តែមហាឧបាសិកាវិសាខាជាព្រះសោតាបន្ន ដែលហៅថា **វដ្តភិរតិ** ប្រែថា អ្នកត្រេកអរក្នុងវដ្តៈសំដៅដល់ការកើតវិលវល់ នៅក្នុងស្ថានសួគ៌តែម្យ៉ាង ទាំងនេះរាប់ថាជាអ្នកមានអធ្យាស្រ័យពេញចិត្តក្នុងវដ្តៈ បុណ្យបារមីរបស់ឧបាសិកាវិសាខា ទើបជាផលជួយឲ្យមហាឧបាសិកាវិសាខាបានសោយទិព្វសម្បត្តិនៅក្នុងស្ថានសួគ៌ជាន់ផ្សេងៗរហូតអស់កាលដ៏យូរហើយបានចូលទៅកាន់ព្រះនិព្វាន ជាទីបំផុតនៃជីវិត ដែលហៅថា គឺការរំលត់ខន្ធបរិ-និព្វាន ។៚

( ជីវប្រវត្តិរបស់មហាឧបាសិកាវិសាខា ចប់ )

8888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ✍

## “ លោកជាឯតទគ្គៈផ្នែកខាងអ្នកឱ្យទាន ”

អនាថបិណ្ឌិកសេដ្ឋី លោកជាអរិយឧបាសក ដែលជាអ្នកពេញចិត្ត ក្នុងការបរិច្ចាគទាន រហូតដល់មានអ្នកដទៃស្គាល់លោកជាច្រើន ពីព្រោះ លោកមិនធ្លាប់ស្តាយទ្រព្យសម្បត្តិក្នុងការឲ្យទាន ទោះជាអស់ប៉ុន្មាន ក៏មិនថា ហេតុដូច្នេះហើយ ទើបលោកបានទទួលការលើកតម្កើងពីព្រះ សយម្ភូថា ជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងការឲ្យទាន ក្នុងព្រះពុទ្ធសាសនានេះ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់អនាថបិណ្ឌិកសេដ្ឋី មានសម្តែងទុក នៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលី ក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖-

ក្នុងកាលមួយសែនកប្បកន្លងមកហើយ ដោយរាប់ថយក្រោយ ពីកប្បនេះទៅ ក្នុងសម័យពុទ្ធកាល នៃព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់

ក្នុងកាលនោះ អនាថបិណ្ឌិកសេដ្ឋីបានកើតនៅក្នុងត្រកូលមួយ នៅក្នុងនគរហង្សវតី កាលលោកចម្រើនវ័យធំដឹងក្តីឡើង លោកបានទៅស្តាប់ព្រះធម៌ទេសនានៃព្រះបទុមុត្តរៈជាម្ចាស់ កាលនោះ លោកបានឃើញព្រះបទុមុត្តរៈប្រកាសតែងតាំងឧបាសកមួយរូប ទុកក្នុងតំណែងឲ្យជាអ្នកប្រសើរជាងឧបាសកទាំងឡាយ ផ្នែកខាងការឲ្យទាន ទាំងនេះជាហេតុ ធ្វើឲ្យលោកនឹកពេញចិត្តក្នុងតំណែងនោះ ទើបបានរៀបចំការថ្វាយទាន និងបំពេញសេចក្តីល្អ ហើយតាំងសេចក្តីប្រាថ្នាក្នុងតំណែងនោះ ដោយអំណាចអធិការកុសលនេះ កាលលោកអស់ជីវិតពីជាតិនោះទៅហើយ ធ្វើឲ្យលោកមានការត្រាច់រង្គាត់ជាមនុស្ស និងទេវតា អស់មួយសែនកប្ប ។ តមក ក្នុងពុទ្ធុប្បាទកាលនេះ បានមកកើតជាបុត្ររបស់ **សុមនសេដ្ឋី** នៅក្នុងនគរសាវត្ថី ។ មាតាបិតា និងពួកញាតិ បានដាក់ឈ្មោះលោកថា **សុទត្តៈ** ប្រែថា អ្នកឲ្យសេចក្តីសុខ ។ ក្នុងកាលតមក សុទត្តមាណពបានរស់នៅក្នុងការគ្រប់គ្រងផ្ទះ មានភរិយារបស់លោកឈ្មោះ **បុញ្ញលក្ខណាទេវី** មានកូនស្រី ៣ នាក់ ឈ្មោះ **មហាសុភទ្ទា**

ចូឡសុភទ្ទា និង សុមនាទេវី ហើយមានកូនប្រុស ឈ្មោះ កាលៈ ។ លោកបានជាអធិបតី ( អ្នកជាម្ចាស់ទាន ) ទាំងបានបរិច្ចាគទាន ហេតុមាននាមថា អនាថបិណ្ឌិក ប្រែថា អ្នកឲ្យដុំបាយដល់បុគ្គលអនាថា គឺជាឈ្មោះដែលមហាជនដាក់ឲ្យ ព្រោះគុណ គឺសេចក្តីល្អ ដែលលោកបានធ្វើហើយ និងជាឈ្មោះដែលកើតឡើង ដោយអំណាចសេចក្តីល្អ ដែលលោកធ្វើទុករួចមកហើយតាំងអំពីអតីតជាតិ ហើយប្រាថ្នាក្នុងតំណែងនោះ ។

ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ក្រៅពីការពោលទុកនៅក្នុងអដ្ឋកថាគម្ពីរមនោរថបូរណីហើយ នៅមានពោលទុកក្នុង អនាថបិណ្ឌិកគហបតិកថា សន្តិកេនិទាន គម្ពីរនិបាតជាតក ក្នុងព្រះបាលី សេនាសនក្ខន្ធកៈ គម្ពីរចូឡវគ្គ ព្រះវិន័យបិដក និងក្នុង ព្រះបាលីយក្ខសំយុត្ត គម្ពីរខុទ្ទកនិកាយ សគាថវគ្គ នៃសុទត្តសូត្រ ដូចមានសេចក្តីថា ៈ-

សម័យមួយ ព្រះមានព្រះភាគ គង់ប្រថាប់នៅក្នុងព្រៃសីតវ័ន នៅនគររាជគ្រឹះ ។ អនាថបិណ្ឌិកសេដ្ឋី ត្រូវជាប្អូនថ្លៃរបស់រាជគហសេដ្ឋី

អ្នកនៅនគររាជគ្រឹះ ( គម្ពីរខ្លះពោលថា ជាសម្លាញ់នឹងគ្នា ) ។ គ្រាមួយ អនាថបិណ្ឌិកសេដ្ឋីផ្ទុកទំនិញ ៥០០ រទេះ ហើយនាំហ្វូងរទេះចេញពីក្រុងសាវត្ថី ធ្វើដំណើរទៅជួញដូរនៅនគររាជគ្រឹះ ដោយបានទៅស្នាក់នៅក្នុងនិវេសន៍របស់រាជគហសេដ្ឋី កាលនោះរាជគហសេដ្ឋីបាននិមន្តភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភត្តាហារ ក្នុងថ្ងៃស្អែក ទើបប្រាប់ដល់ពួកទាសកម្មករថា ពួកអ្នកចូរក្រោកពីព្រលឹម ចូរដាំបបរ ដាំបាយ ធ្វើម្ហូប ហើយចូរជួយគ្នារកអាហារដែលមានរសជាតិឆ្ងាញ់ៗ ទុកឲ្យច្រើន កុំឲ្យខ្វះ ។ អនាថបិណ្ឌិកសេដ្ឋីធ្លាប់បានមកស្នាក់នៅផ្ទះរបស់រាជគហសេដ្ឋី រាល់ពេលដែលធ្វើដំណើរមកដល់ក្រុងរាជគ្រឹះ តែការមកស្នាក់អាស្រ័យលើកនេះ មានហេតុការណ៍ខុសប្លែក ធ្វើឲ្យលោកគហបតីគិតថា កាលលើកមុន ពេលយើងមកដល់រាជគហសេដ្ឋី ត្រូវផ្អាកកិច្ចធុរៈទាំងពួងអស់ ហើយមកសម្តែងនូវការរាក់ទាក់រីករាយ និងសន្ទនាប្រាស្រ័យជាមួយយើងតែម្នាក់ តែពេលនេះ គេមានកាយវិការផ្លាស់ប្តូរ គេរវល់ខ្វល់ខ្វាយប្រាប់ទាសកម្មករទាំងឡាយ ឲ្យក្រោកពីព្រលឹម

ឲ្យជួយដាំស្ល ធ្វើអាហារដែលមានរសជាតិឆ្ងាញ់ បែបគេមានរៀបចំពិធី អាវាហមង្គល វិវាហមង្គល ឬធ្វើពិធីបូជាមហាយញ្ញ ឬក៏ក្រាបទូលយាង ព្រះបាទពិម្ពិសារមហារាជ ព្រមដោយពួកអាមាត្យ មកសោយអាហារ ក្នុងថ្ងៃស្អែកនេះទេដឹង ។

ពេលរាជគហសេដ្ឋីប្រាប់កម្មករ និងទាសៈ រួចស្រេចហើយ ទើបទៅរកអនាថបិណ្ឌិកសេដ្ឋី ហើយអង្គុយសន្ទនាគ្នា នៅត្រង់កន្លែង ដែលសមគួរមួយ ។ អនាថបិណ្ឌិកសេដ្ឋី បានសួររាជគហសេដ្ឋីថា កាលមុនពេលដែលខ្ញុំមកដល់ លោកបានផ្អាកកិច្ចការងារទាំងពួងហើយ មកសម្តែងសេចក្តីរីករាយ និងសន្ទនាជាមួយខ្ញុំតែម្នាក់គត់ តែពេលនេះ លោករវល់នៅជាមួយនឹងការងារ ទាំងប្រាប់កម្មករ និងទាសៈឲ្យរៀបចំ អាហារផ្សេងៗ លោករៀបចំអាវាហមង្គល វិវាហមង្គល ឬក៏ធ្វើពិធីបូជា មហាយញ្ញ ឬក្រាបទូលយាងព្រះបាទពិម្ពិសារមហារាជនៃដែនមគធៈ ព្រមដោយពួកអាមាត្យ ដើម្បីមកសោយអាហារនៅថ្ងៃស្អែក ឬយ៉ាងណា ? រាជគហសេដ្ឋីទើបតបថា លោកគហបតី ខ្ញុំមិនបានរៀបចំអាវាហមង្គល

ឬវិវាហមង្គល និងរៀបចំអ្វីសម្រាប់ស្ដេចផែនដី ព្រមទាំងពួកអាមាត្យ ដើម្បីមកសោយអាហារក្នុងថ្ងៃស្អែកនោះទេ តែខ្ញុំនឹងធ្វើពិធីបូជាមហាយញ្ញ គឺខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីស្ដេចយាងមក ទទួលភត្តក្នុងថ្ងៃស្អែកនេះ ។

ទើបអនាថបិណ្ឌិកសេដ្ឋីសួរថា លោកពោលថា ព្រះពុទ្ធជាម្ចាស់ ឬ? រាជគហសេដ្ឋីតបថា ត្រូវហើយ ខ្ញុំពោលថា ព្រះពុទ្ធជាម្ចាស់មែន ។ អនាថបិណ្ឌិកសេដ្ឋី បានសួររាជគហសេដ្ឋីដូច្នេះ រហូតដល់ ៣ ដង ព្រមគ្នានោះឯង ក៏បានស្ដាប់ពាក្យឆ្លើយតបព្រះនាមថា ព្រះពុទ្ធជាម្ចាស់ ទើបពោលថា លោករាជគហសេដ្ឋី ពាក្យថា ព្រះពុទ្ធជាម្ចាស់ នេះជា ពាក្យដែលរកបានដោយកម្រក្នុងលោក តើខ្ញុំអាចចូលទៅគាល់ព្រះសម្ពុទ្ធ ដែលទ្រង់ជាព្រះអរហន្តសម្មាសម្ពុទ្ធ នៅក្នុងលោកនេះបានដែរឬទេ ? រាជគហសេដ្ឋីតបថា លោកគហបតី ពេលនេះជាពេលដែលមិនគួរ ដើម្បីនឹងចូលទៅគាល់ព្រះលោកនាថទេ ព្រោះមិនមែនជាវេលាដែល នឹងត្រូវចូលទៅគាល់ រង់ចាំស្អែកសិនចុះ លោកនឹងអាចចូលទៅគាល់

បាន ។ ពេលអនាថបិណ្ឌិកសេដ្ឋីចប់ការសន្ទនាហើយ ក៏ចូលទៅកាន់ទីសម្រាក លោកក៏បានដេកនឹកដល់ព្រះពុទ្ធជាម្ចាស់មកជាអារម្មណ៍ជានិច្ចថា ព្រឹកស្អែកនេះ យើងនឹងបានចូលទៅគាល់ព្រះលោកនាយកទ្រង់ជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ។ ពេលដែលអនាថបិណ្ឌិកសេដ្ឋីដេកនឹកដល់ព្រះពុទ្ធអង្គដូច្នេះហើយ យប់នោះ លោកបានភ្ញាក់ ៣ ដងហើយយល់ថាភ្លឺហើយ ទើបក្រោកឡើង ធ្វើដំណើរទៅកាន់ព្រៃសីតវ័នពួកអមនុស្ស បានជួយបើកទ្វារឲ្យដល់អនាថបិណ្ឌិកសេដ្ឋី លោកបានធ្វើដំណើរចេញទៅដោយសុវត្ថិភាព ។

ខណៈដែលអនាថបិណ្ឌិកសេដ្ឋី បានដើរចេញពីដែនព្រះនគរទៅហើយ ពន្លឺក៏បាត់អស់ទៅ ភាពងងឹតក៏ប្រាកដឡើងមក លោកសេដ្ឋីក៏កើតការភ័យតក់ស្លុត រហូតដល់បះរោមឡើង ក៏គិតថា នឹងត្រឡប់ទៅវិញ ។ ក្នុងពេលនោះ **សីវកយក្ខ** មិនប្រាកដកាយឲ្យលោកសេដ្ឋីបានឃើញទេ តែបានបញ្ចេញសំឡេងឲ្យឮថា លោកសេដ្ឋី ដំរីមួយសែនក្បាល សេះមួយសែនក្បាល កុមារីតូចប្រដាប់ដោយក្រវិលពេជ្រផ្សេងៗ

មួយសែននាក់ ក៏នៅមិនស្មើនឹងចំណែកទី ១៦ ដែលជ្រៀកហើយជា ១៦ ចំណែកនៃការឈានទៅមុខត្រឹមតែមួយជំហាន ហេតុដូច្នេះ សូមលោកឈានទៅខាងមុខចុះ ការឈានទៅមុខរបស់លោក ទើបប្រសើរជាង លោកកុំត្រឡប់ថយក្រោយឡើយ ។ ពេលនោះ ភាពងងឹតក៏បាត់អស់ទៅ ហើយពន្លឺក៏កើតមានប្រាកដឡើង ធ្វើឲ្យអនាថបិណ្ឌិកសេដ្ឋីបាត់ការភ័យខ្លាច រោមដែលបះឡើងក៏ស្ងប់ទៅ ។ អនាថបិណ្ឌិកសេដ្ឋីទើបឈានជើងដើរទៅមុខទៀត ពេលដើរទៅបានមួយសន្ទុះ ហេតុការណ៍ដូចមុនបានប្រាកដឡើងទៀត ធ្វើឲ្យលោកសេដ្ឋីអល់អែកចិត្ត គិតនឹងថយក្រោយ តែក៏មានសំឡេងរបស់ **សីវកយក្ខ** មកពោលរឭកឲ្យកម្លាំងចិត្តដល់អនាថបិណ្ឌិកសេដ្ឋីម្តងទៀតជាលើកទី ២ ដូចមុន ។

ពេលភាពងងឹតបាត់ទៅ ពន្លឺក៏កើតប្រាកដឡើង ដល់អនាថបិណ្ឌិក-សេដ្ឋីៗ ទើបឈានដើរទៅមុខទៀត តែបន្ទាប់មកភាពងងឹតក៏កើតឡើងម្តងទៀត កាលបើជួបហេតុនោះទៀតហើយ លោកក៏គិតនឹងត្រឡប់ទៅវិញ តែសីវកយក្ខបានពោលឲ្យកម្លាំងចិត្តដូចលើកទី២ ដែរ ហើយ

ហេតុការណ៍ ក៏ត្រឡប់ពីភាពងងឹតមកភ្លឺវិញ ធ្វើឲ្យអនាថបិណ្ឌិកសេដ្ឋី អស់នូវភាពភ័យខ្លាច រោមដែលបះឡើងក៏ស្ងប់ទៅ ហើយអនាថបិណ្ឌិក-សេដ្ឋី បានដើរទៅមុខរហូតដល់ព្រៃសីតវ័ន ដែលជាស្ថានទីស្នាក់អាស្រ័យនៅរបស់ព្រះសម្ពុទ្ធ ។ ក្នុងពេលនោះ ជាពេលជិតភ្លឺ ព្រះសក្យមុនីទ្រង់តើនឡើង ទ្រង់យាងចង្រ្កមក្នុងទីស្រឡះមួយ បានទតឃើញអនាថបិណ្ឌិកសេដ្ឋី កំពុងធ្វើដំណើរមកអំពីចម្ងាយ ទើបទ្រង់ចេញពីទីចង្រ្កមទៅគង់លើអាសនៈដែលគេក្រាលទុក បន្ទាប់មក ព្រះអង្គបានត្រាស់ជាមួយអនាថបិណ្ឌិកសេដ្ឋីថា មកចុះ **សុទត្ត:** ។ កាលអនាថបិណ្ឌិកសេដ្ឋីបានស្តាប់ពុទ្ធតម្រាស់ត្រាស់ហៅ ក៏កើតការសប្បាយចិត្តថា ព្រះភគវាត្រាស់ហៅឈ្មោះរបស់យើងត្រូវ ទើបចូលទៅក្រាបថ្វាយបង្គំ ទៀបព្រះយុគលបាទនៃព្រះមុនី ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនតើព្រះអង្គសុខសប្បាយឬទេ ? ព្រះមានជោគបានត្រាស់តបជាធម្មកថាដោយត្រាស់ថា ព្រាហ្មណ៍ដែលជាអ្នករំលត់ទុក្ខបានហើយ រមែងនៅជាសុខគ្រប់ពេលវេលា អ្នកណាមិនជាប់នៅក្នុងកាមទាំងឡាយ ជាអ្នក

មានចិត្តត្រជាក់ ជាអ្នកមិនមានឧបធិ ជាអ្នកកាត់នូវបំណងបានគ្រប់យ៉ាងហើយ ជាអ្នកកម្ចាត់នូវគ្រឿងកង្វល់ក្នុងចិត្ត ជាអ្នកដល់នូវភាពស្ងប់រំងាប់នៃចិត្ត បុគ្គលនោះ រមែងនៅជាសុខ ។

ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី បន្ទាប់តពីនេះទៅ ក៏មានសម្តែងនៅក្នុង **គម្ពីរចុល្លវគ្គ ព្រះវិន័យបិដក** ដូចមានសេចក្តីថា ៖-

កាលព្រះសម្ពុទ្ធ ទ្រង់ត្រាស់តបដូច្នេះហើយ ទើបទ្រង់សម្តែង **អនុបុព្វីកថា** ដែលពោលអំពី **ទានកថា ១ សីលកថា ១ សគ្គកថា ១ អាទីនវកថា ១ នេក្ខម្មានិសំសកថា ១** ។ កាលទ្រង់ប្រកាសអានិសង្ស ក្នុងការចេញចាកកាមដូចនេះហើយ ក្នុងខណៈនោះ ព្រះមានជោគទ្រង់ជ្រាបថា អនាថបិណ្ឌិកសេដ្ឋី មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តជ្រះថ្លា ទើបព្រះអង្គទ្រង់សម្តែងនូវព្រះធម្មទេសនាទៀត បានដល់ **សាមុក្កង្សិកធម៌** គឺព្រះធម៌ដែលព្រះសម្ពុទ្ធ ទ្រង់លើកមកសម្តែងដោយព្រះអង្គឯង សំដៅដល់ **អរិយសច្ច ៤** ។ អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ព្រះធម៌ទេសនានេះហើយ **ធម្មចក្ខុ** បានដល់ ភ្នែក គឺបញ្ញា ដោយ

ពិចារណាឃើញថា វត្ថុណាមួយមានការកើតជាធម្មតា វត្ថុនោះមានការរលត់ទៅវិញជាធម្មតា ប្រៀបដូចជាសំពត់ដែលប្រាសចាកនូវភាពកខ្វក់ គួរដល់ការទទួលទឹកជ្រលក់ពណ៌ ដូច្នោះ ។ ពេលដែលអនាថបិណ្ឌិកសេដ្ឋី បានឃើញធម៌ហើយ ( សំដៅដល់ បានសម្រេចជាព្រះសោតាបន្នហើយ ) បានសម្រេចធម៌ហើយ បានដឹងធម៌ច្បាស់ហើយ ជាអ្នកចុះកាន់ធម៌ហើយ ជាអ្នកឆ្លងផុតនូវសេចក្តីសង្ស័យបានហើយ ជាអ្នកដល់នូវភាពក្លៀវក្លា ជាអ្នកមិនជឿបុគ្គលដទៃទៀត ក្នុងព្រះសាសនានេះ បានក្រាបទូលពោលសរសើរនូវព្រះធម៌ទេសនាថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ភ្លឺច្បាស់ពេកណាស់ ពីរោះពេកណាស់ ។ ព្រះអង្គបានសម្តែងនូវព្រះធម៌ទេសនា ដោយអនេកបរិយាយយ៉ាងនេះ ប្រៀបដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ហើយបើករបស់ដែលបិទ ប្រាប់ផ្លូវដល់បុគ្គលអ្នកវង្វេងផ្លូវ ឬទ្រោលប្រទីបក្នុងទីងងឹត ដោយតាំងចិត្តថា ឲ្យអ្នកមានភ្នែកភ្លឺ បានឃើញនូវរបស់ដែលចង់ឃើញ ។

អនាថបិណ្ឌិកសេដ្ឋី បានប្រកាសខ្លួនជាឧបាសក ( អ្នកអង្គុយជិត

ព្រះរតនត្រ័យ ) ថា ខ្ញុំព្រះករុណា សូមដល់ព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ គឺជាទីពឹងជាទីរឭក សូមព្រះអង្គចាំទុកខ្ញុំព្រះករុណាថា ជាឧបាសកអ្នកដល់ព្រះរតនត្រ័យ ចាប់ពីថ្ងៃនេះតទៅ រហូតអស់មួយជីវិត ព្រះអង្គ ។ បន្ទាប់ពីអនាថបិណ្ឌិកសេដ្ឋី បានប្រកាសខ្លួនជាឧបាសកហើយ ទើបក្រាបទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទទួលនូវភត្តាហាររបស់ខ្ញុំព្រះករុណាក្នុងថ្ងៃស្អែកនេះ ដើម្បីសេចក្តីចម្រើននូវបុណ្យកុសលដល់ខ្ញុំព្រះករុណាផង ព្រះអង្គ ។ គ្រានោះ ព្រះភគវា ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ ពេលនោះ អនាថបិណ្ឌិកសេដ្ឋីបានជ្រាបថា ព្រះសម្ពុទ្ធទ្រង់ទទួលនិមន្តន៍ហើយ ទើបក្រោកចាកពីទីនោះថ្វាយបង្គំលា ហើយធ្វើប្រទក្សិណ ( គឺការដើរជុំវិញ ៣ ជុំ ) ហើយត្រឡប់ទៅកាន់និវេសន៍របស់រាជគហសេដ្ឋីវិញ ។ ចំណែករាជគហសេដ្ឋីបានជ្រាបថា អនាថ-បិណ្ឌិកសេដ្ឋី បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភត្តាហារក្នុងថ្ងៃស្អែកនេះ ក៏បានសួរអនាថបិណ្ឌិកសេដ្ឋីថា លោកគហបតី

ខ្ញុំបានឮថា លោកបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ប៉ុន្តែលោកជាភ្ញៀវមកពីស្រុកក្រៅ ខ្ញុំនឹងឲ្យលោកខ្ចីទ្រព្យ ដើម្បីយកទៅចំណាយ ឬវត្ថុរបស់របរផ្សេងៗ ដើម្បីរៀបចំថ្វាយបិណ្ឌបាតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននោះ ។ អនាថបិណ្ឌិកសេដ្ឋីពោលហាមថា នែគហបតី មិនចាំបាច់ទេ ព្រោះទ្រព្យសម្បត្តិរបស់របរផ្សេងៗ ដែលត្រូវថ្វាយបិណ្ឌបាតដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាននោះរបស់ខ្ញុំមានហើយ ។ គ្រានោះ ព្រះបាទពិម្ពិសារ ជាព្រះរាជានៃដែនមគធៈ បានឮដំណឹងនោះ ក៏ទ្រង់មានព្រះរាជបំណងនឹងឲ្យអនាថបិណ្ឌិកសេដ្ឋីខ្ចីទ្រព្យ ដើម្បីចំណាយចាយវាយទៅក្នុងការថ្វាយចង្ហាន់បិណ្ឌបាតដល់ភិក្ខុសង្ឃ មានព្រះពុទ្ធអង្គជាប្រធាន ។

ចំណែកអនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលបដិសេធថា សូមតេជះក្រោមល្អងធូលីព្រះបាទ ជីវិតតម្កល់លើត្បូង នេះជាព្រះមហាករុណារបស់ព្រះអង្គ ប៉ុន្តែទ្រព្យសម្បត្តិខ្ញុំព្រះអង្គ ដែលត្រូវយកទៅចំណាយចាយវាយ ក្នុងការរៀបចំថ្វាយចង្ហាន់បិណ្ឌបាតដល់ភិក្ខុសង្ឃ ដែលមាន

ព្រះពុទ្ធជាប្រធាននោះ របស់ខ្ញុំព្រះអង្គមានហើយ ព្រះអង្គ ។ លុះដល់ព្រឹកស្អែកឡើង អនាថបិណ្ឌិកសេដ្ឋី បានបញ្ជូនមនុស្សឲ្យទៅក្រាបទូលកត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កត្តកាលដល់ហើយ កត្តសម្រេចហើយ ព្រះអង្គ ។ គ្រានោះ ព្រះសក្យមុនីព្រមទាំងភិក្ខុសង្ឃ ស្តេចយាងទៅកាន់និវេសន៍ របស់រាជគហសេដ្ឋីលុះទៅដល់ហើយ ទ្រង់គង់ប្រថាប់នៅលើអាសនៈ ដែលគេក្រាលទុកសម្រាប់ថ្វាយព្រះអង្គ រីឯភិក្ខុសង្ឃ បាននិមន្តគង់តាមលំដាប់វស្សាគ្នាចុះមក ។ អនាថបិណ្ឌិកសេដ្ឋី បានរៀបចំការថ្វាយចង្ហាន់បិណ្ឌបាត និងគ្រឿងបរិក្ខារដ៏ប្រណីតៗ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននោះដោយដៃខ្លួនឯង រហូតដល់ព្រះមានជោគសោយរួចស្រេចហើយ ទើបអង្គុយចុះនៅក្នុងទីដ៏សមគួរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះសម្ពុទ្ធ ព្រមដោយភិក្ខុសង្ឃ ទទួលអារាធនាយាងទៅចាំវស្សានៅក្នុងក្រុងសាវត្ថី ដែលជាស្រុកកំណើតរបស់ខ្ញុំព្រះអង្គផង ព្រះអង្គ ។ ព្រះភគវាត្រាស់ថា នែគហបតី តថាគតតែងតែរីករាយ ក្នុងសុញ្ញាគារ

(ផ្ទះស្ងាត់ ឬទីកន្លែងដែលមិនមានមនុស្ស) ។ កាលអនាថបិណ្ឌិកសេដ្ឋី ក្រាបទូលថា ខ្ញុំព្រះករុណាជ្រាបហើយ ព្រះអង្គ ។ បន្ទាប់ពីនោះ ព្រះលោកនាយក ទ្រង់សម្ដែងព្រះធម៌ទេសនា ឲ្យអនាថបិណ្ឌិកសេដ្ឋី ឃើញច្បាស់ ឲ្យជឿមាំ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈ ស្ដេចយាងត្រឡប់ទៅវិញ ។

ពេលដែលអនាថបិណ្ឌិកសេដ្ឋី បានធ្វើដំណើរត្រឡប់មកវិញ តាមផ្លូវនោះ បាននិយាយបបួលអ្នកស្រុកតាមផ្លូវថា អ្នកទាំងអស់គ្នា ចូរនាំគ្នាជួយកសាងអារាម កសាងវិហារ ផ្ដើមបំពេញទាន ពីព្រោះ ឥឡូវនេះ ព្រះពុទ្ធជាម្ចាស់ ទ្រង់ឧប្បត្តិកឡើងក្នុងលោកហើយ ម្យ៉ាងទៀត ខ្ញុំបានក្រាបទូលអារាធនានិមន្តទុកហើយ ព្រះលោកនាយកស្ដេចយាង មកតាមផ្លូវនេះឯង ។ ពពួកអ្នកស្រុក កាលដែលអនាថបិណ្ឌិកសេដ្ឋី បានបបួលយ៉ាងនេះហើយ ក៏នាំគ្នាកសាងអារាម កសាងវិហារ នាំគ្នា បំពេញទាន ទៅតាមកម្លាំងទ្រព្យដែលខ្លួនមាន ។ ពេលដែលអនាថ-បិណ្ឌិកសេដ្ឋី ត្រឡប់មកដល់ក្រុងសាវត្ថីវិញ បានចេញទៅរកមើលដី

នៅក្នុងក្រុងសាវត្ថី ដោយពិចារណាមើលថា តើព្រះលោកនាថ ទ្រង់គួរ
គង់ប្រថាប់ក្នុងទីណា ទើបជាស្ថានទីដែលសមគួរ ជាស្ថានទីមិនឆ្ងាយពេក
មិនជិតពេកពីភូមិ មានផ្លូវទៅមកស្រួល ហើយពេលថ្ងៃមិនមានមនុស្ស
ពពាក់ពពូន ពេលយប់ស្ងប់ស្ងាត់ មិនមានសំឡេងអឺកធឹក ជាស្ថានទី
សមគួរដល់សមណ: ជាស្ថានទីពួនសំងំ លោកក៏បានឃើញព្រះឧទ្យាន
របស់ស្តេចជេត ដែលជាស្ថានទីដ៏សមគួរ គិតឃើញដូច្នេះហើយ បាន
ចូលទៅគាល់ស្តេចជេតក្រាបទូលថា សូមថ្វាយបង្គំមហាបពិត្រ សូម
ទ្រង់ប្រទានលក់ព្រះឧទ្យានឲ្យដល់ខ្ញុំព្រះអង្គ ដើម្បីកសាងអារាមថ្វាយ
ដល់ព្រះពុទ្ធជាម្ចាស់ ។

គ្រានោះ ស្តេចជេតត្រាស់ថា នែគហបតី ឧទ្យានរបស់យើង
មិនអាចលក់ឲ្យបានទេ លុះត្រាតែអ្នកយកទ្រព្យទៅក្រាលក្នុងស្ថានទីនោះ
ឲ្យពេញត្រឹមណា ចូរអ្នកយកទៅចុះ ។ ពេលនោះ អនាថបិណ្ឌិកសេដ្ឋី
ក្រាបទូលថា បើយ៉ាងនោះពិតមែន ព្រះអង្គទ្រង់ព្រមលក់ព្រះរាជឧទ្យាននោះ
ឲ្យខ្ញុំព្រះអង្គពិតមែន ស្តេចជេតតបថា នែគហបតី យើងមិនទាន់ព្រមលក់

ឲ្យលោកនៅឡើយទេ ។ កាលអ្នកទាំង ២ នាក់ បាននិយាយមិនត្រូវគ្នា ទើបចូលទៅសួរអាមាត្យពិភាក្សាគ្នាថា ព្រមលក់ ឬមិនព្រមលក់ ។ អាមាត្យអ្នកពិភាក្សាតបថា ពេលដែលព្រះអង្គវាយតម្លៃហើយ គឺប៉ុនគ្នានឹងព្រះអង្គព្រមលក់ហើយ ព្រះអង្គ ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី កាលបើបានទទួលការយល់ព្រមពីស្តេចជេតហើយ ទើបប្រាប់ឲ្យមនុស្សទាំងឡាយ នាំគ្នាដឹកប្រាក់កាសដោយរទេះ នាំយកទៅក្រាលក្នុងព្រះរាជ-ឧទ្យាននោះ តែប្រាក់ដែលយកទៅនោះ នៅខ្វះត្រង់ខ្លោងទ្វារ លោកសេដ្ឋីបានឲ្យគេទៅប្រមូលប្រាក់មកទៀត ។ ខណៈនោះ ស្តេចជេតទ្រង់គិតថា រឿងនេះគង់មិនមែនជារឿងតូចតាចឡើយ ទើបធ្វើឲ្យលោកគហបតីហ៊ានលះបង់ទ្រព្យច្រើនយ៉ាងនេះ ទ្រង់ត្រិះរិះដូច្នេះហើយ ក៏បានប្រាប់ដល់អនាថបិណ្ឌិកសេដ្ឋីថា ល្មមហើយ លោកគហបតី លោកកុំយកប្រាក់មកក្រាលក្នុងទីនេះទៀតអី លោកចូរទុកទីនេះឲ្យខ្ញុំ ខ្ញុំនឹងចូលរួមជាមួយលោកដែរ ។

ពេលនោះ អនាថបិណ្ឌិកសេដ្ឋីពិចារណាឃើញថា ស្តេចជេត

ទ្រង់ជាអ្នកចង់បានឈ្មោះ នឹងធ្វើឲ្យមនុស្សទាំងឡាយ កាន់តែស្គាល់ព្រះអង្គថា ជាអ្នកធំ ហេតុនេះ ក៏នឹងធ្វើឲ្យព្រះអង្គកើតសេចក្ដីជ្រះថ្លាក្នុងធម្មវិន័យនេះបានដែរ ទើបទុកទីនោះឲ្យស្ដេចជេត ។ គ្រានោះ ស្ដេចជេតបានឲ្យគេកសាងខ្លោងទ្វារទុកនៅក្នុងទីនោះ ។ ចំណែកអនាថបិណ្ឌិកសេដ្ឋីបានឲ្យគេកសាងសេនាសនៈជាច្រើនខ្នងទុកនៅក្នុងវត្តជេតពន ឲ្យកសាងបរិវេណ ឲ្យកសាងខ្លោងទ្វារ ឲ្យកសាងសាលាធាន់ ឲ្យកសាងរោងភ្លើង ឲ្យកសាងកប្បិយកុដិ ឲ្យកសាងវច្ចកុដិ ឲ្យកសាងទីចង្រ្កម ឲ្យកសាងអណ្ដូងទឹក ឲ្យកសាងសាលានៅត្រង់អណ្ដូងទឹក ឲ្យកសាងផ្ទះបាយ ឲ្យកសាងសាលាបាយ ឲ្យកសាងស្រះបោក្ខរណី និងឲ្យគេកសាងមណ្ឌបសម្រាប់ជាទីនៅ និងជាទីប្រព្រឹត្តបដិបត្តិធម៌របស់ភិក្ខុសង្ឃទាំងឡាយ ។ ទីសេនាសនៈផ្សេងៗ ដែលអនាថបិណ្ឌិកសេដ្ឋីបានកសាងឡើង នៅក្នុងវត្តជេតពនមហាវិហារនោះ បានដល់ **ព្រះគន្ធកុដិ** ( កុដិដែលអប់ទៅដោយក្លិនក្រអូប ) សម្រាប់ព្រះភគវា ទុកនៅក្នុងកណ្ដាល មានកុដិ ១ ជាន់ កុដិ ២ ជាន់ សាលាវែងមានឈ្មោះ **ហង្សវដ្ដិកៈ** មណ្ឌបដែល

ជាអាវាស កន្លែងនៅរួមសម្រាប់ព្រះថេរៈ ៨០ អង្គ ស្រះបោក្ខរណី (ស្រះឈូក) ទីចង្ក្រម កន្លែងសម្រាកពេលយប់ និងកន្លែងសម្រាកពេលថ្ងៃ នៅជុំវិញព្រះគន្ធកុដិនោះ ។

ក្នុងរឿងការកសាងសាលាសម្នាក់តាមផ្លូវ ពីនគររាជគ្រឹះមកកាន់ក្រុងសាវត្ថី និងការកសាងវត្តជេតពន ដែលអនាថបិណ្ឌិកសេដ្ឋីបានលះបង់ទ្រព្យសម្បត្តិអស់ចំនួនជាច្រើន មានសម្តែងប្រាកដនៅក្នុង **អនាថបិណ្ឌិកគហបតិកថាសន្តិកេនិទាន នៃអដ្ឋកថាជាតក ក្នុងអដ្ឋកថាមនោរថបូរណី និងក្នុង អដ្ឋកថាសារត្ថប្បកាសិនី** ដូចមានសេចក្តីថា ៖-

អនាថបិណ្ឌិកសេដ្ឋី លោកបានលះបង់ទ្រព្យ ដើម្បីកសាងសាលាសម្នាក់មកតាមផ្លូវ ១ ខ្នង ១ សែនកហាបណៈ បានសាងឡើង ក្នុងរវាងផ្លូវ ១ យោជន៍ ១ ខ្នងៗ សម្រាប់ទុកជាទីសម្រាកតាមផ្លូវរបស់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បើគិតរយៈផ្លូវពីនគររាជគ្រឹះមកដល់ក្រុងសាវត្ថី មានចម្ងាយផ្លូវ ៤៥ យោជន៍ បើគិតពីចំនួនប្រាក់ ដែលអនាថបិណ្ឌិកសេដ្ឋីបរិច្ចាគកសាងសាលាមកតាមផ្លូវ ទាំងអស់ ៤ លាន

៥ សែនកហាបណៈ ។ ចំណែកប្រាក់ដែលចំណាយចាយវាយយកទៅក្រាលព្រះរាជឧទ្យានរបស់ស្តេចជេតអស់ចំនួន ១៨ កោដិកហាបណៈ និងប្រាក់ដែលចំណាយចាយវាយ ក្នុងការកសាងវត្តជេតពនទាំងអស់ចំនួន ១៨ កោដិកហាបណៈ សរុបប្រាក់ដែលចំណាយចាយវាយទៅលើដី និងទៅលើការកសាងទីសេនាសនៈទាំងអស់ចំនួន ៣៦ កោដិកហាបណៈ ។ វត្តដែលអនាថបិណ្ឌិកសេដ្ឋីកសាងឡើង មានឈ្មោះថា **វត្តជេតពនមហាវិហារ** ដោយនាំយកព្រះនាមរបស់ស្តេចជេតមកដាក់ជាឈ្មោះវត្ត ។ កាលកសាងវត្តជេតពនមហាវិហាររៀបរយស្រេចហើយ អនាថបិណ្ឌិកសេដ្ឋីបានបញ្ជូនទូត ឲ្យទៅក្រាបទូលអារាធនាព្រះភគវាមួយអន្លើដោយភិក្ខុសង្ឃជាច្រើន ឲ្យស្តេចយាងមកកាន់ក្រុងសាវត្ថី ។ ព្រះមានជោគ មួយអន្លើដោយភិក្ខុសង្ឃជាច្រើន ស្តេចបានយាងចេញចាកពីនគររាជគ្រឹះ មកតាមផ្លូវដែលអនាថបិណ្ឌិកសេដ្ឋី បានកសាងសាលា តាមលំដាប់ផ្លូវមកសម្រាប់ជាទីសម្រាកក្នុងរវាងផ្លូវ ១ ថ្ងៃ ១ យោជន៍ សរុបពេលវេលាដែលព្រះសម្ពុទ្ធ ទ្រង់ធ្វើពុទ្ធដំណើរមកអស់

រយៈពេល ៤៥ ថ្ងៃ ទើបស្តេចយាងមកដល់ក្រុងសាវត្ថី ។

ចំណែកអនាថបិណ្ឌិកសេដ្ឋី ក៏បានឲ្យគេរៀបចំតាក់តែងព្រះវិហារយ៉ាងស្អាត ហើយបានឲ្យបុត្រ ព្រមទាំងកុមារី ៥០០ នាក់ ឲ្យកាន់ទង់សំពត់ ៥ ពណ៌ ចំនួន ៥០០ ទង់ ទៅទទួលព្រះអង្គ ។ ក្នុងពេលដែលទទួលព្រះជិនស្រី មួយអន្លើដោយភិក្ខុសង្ឃ អនាថបិណ្ឌិកសេដ្ឋីបានរៀបចំក្បួនទទួលព្រះអង្គ ដោយឲ្យកុមារកាន់ទង់ ៥០០ នាក់នោះដើរនាំមុខព្រះសម្ពុទ្ធ ចំណែកក្បួនបន្ទាប់មកមានពួកឧបាសកដើរនាំមុខព្រះអង្គ ព្រមដោយភិក្ខុសង្ឃ ក្បួនបន្ទាប់តមកឲ្យភរិយា និងស្ត្រីបរិវារ ៥០០ នាក់ កាន់ឃ្លោកដាក់ទឹកដើរតាមក្រោយក្បួនព្រះលោកនាយក ហើយក្បួនចុងក្រោយជាក្បួនរបស់អនាថបិណ្ឌិកសេដ្ឋី និងសេដ្ឋីដែលជាបរិវារ ៥០០ នាក់ ដើរតាមក្បួនរបស់ព្រះមានជោគ ចូលទៅកាន់វត្តជេតពន ។ម្យ៉ាងទៀត អនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលព្រះបាទបសេនទិកោសល ដើម្បីសូមព្រះរាជានុញ្ញាត ក្រាបទូលយាងព្រះនាងសុមនារាជកុមារី ឲ្យទៅទទួលព្រះមុនីផង ហើយព្រះនាងសុមនារាជកុមារី

បានទទួលព្រះបរមរាជានុញ្ញាត ព្រមដោយកុមារី ៥០០ នាក់ ទាំងព្រះនាងសុមនារាជកុមារី បានស្តាប់ព្រះធម៌ទេសនាហើយ ក៏បានសម្រេចព្រះសោតាបត្តិផល ព្រមដោយកុមារី ៥០០ នាក់ ដែលបានមកទទួលព្រះមានព្រះភាគនោះដែរ ។

កាលដែលព្រះសម្មាសម្ពុទ្ធ ស្តេចយាងចូលទៅកាន់ព្រះវិហារព្រះអង្គបានឲ្យពួកឧបាសក នាំដំណើរព្រះអង្គ ចំណែកព្រះមានជោគព្រមដោយភិក្ខុសង្ឃ ស្តេចយាងទៅតាមក្រោយ ចូលទៅកាន់វត្តជេតពនដោយពុទ្ធលីលាដ៏សមសួន ដែលគ្មានអ្វីប្រៀបផ្ទឹមបាន ដោយទ្រង់បញ្ចេញរស្មី ៦ ពណ៌ ផ្សាយចេញពីព្រះវរកាយរបស់ព្រះអង្គ ទៅកាន់ទិសទាំងពួង ដែលគួរឲ្យអស្ចារ្យបំផុត សម្រាប់មនុស្ស និងទេវតាទាំងឡាយ ។ ពេលដែលព្រះភគវា ចូលទៅកាន់វិហាររៀបរយហើយអនាថបិណ្ឌិកសេដ្ឋី បានក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើនតើខ្ញុំព្រះអង្គគប្បីបដិបត្តិយ៉ាងណាក្នុងវិហារនេះ ? គ្រានោះ ព្រះសយម្ភូទ្រង់ត្រាស់តបថា ម្នាលគហបតី ចូរអ្នកថ្វាយវិហារនេះចំពោះភិក្ខុសង្ឃ

ដែលមកអំពីទិសទាំង ៤ ចុះ ។

អនាថបិណ្ឌិកសេដ្ឋី ទើបក្រាបទូលព្រះសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ហើយបានចាប់យកឃ្លោកមាសដែលមានទឹកដាក់ពេញ ប្រូចទៅលើព្រះហស្តនៃព្រះលោកនាយក ហើយក្រាបទូលថា ខ្ញុំព្រះអង្គសូមថ្វាយវត្តជេតពនមហាវិហារនេះចំពោះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធអង្គជាព្រះប្រធាន ។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ទទួលការថ្វាយវត្តជេតពនមហាវិហារ ហើយទ្រង់អនុមោទនាដោយទានកថា គឺព្រះអង្គទ្រង់ពណ៌នាដល់ទាន បានដល់ ការឲ្យទីអាស្រ័យថា ជាទានមានផលច្រើន ។លុះព្រឹកស្អែកឡើង ចាប់ពីថ្ងៃទី ២ ទៅ អនាថបិណ្ឌិកសេដ្ឋី បានផ្ដើមធ្វើបុណ្យឆ្លងវត្តជេតពន ដោយមានការទំនុកបម្រុងបរិស័ទទាំង ៤ ដោយការត្រៀមកត្តាហារ ក្នុងការធ្វើបុណ្យឆ្លងនោះ ដោយមិនឲ្យលំបាកដល់បរិស័ទដែលបានអញ្ជើញមក ចូលរួមជាមួយជារៀងរាល់ថ្ងៃ ការធ្វើបុណ្យឆ្លងវត្តជេតពននោះ ធ្វើរហូតដល់ ៩ ខែ ដោយអនាថបិណ្ឌិកសេដ្ឋី បានចំណាយចាយវាយប្រាក់ធ្វើបុណ្យឆ្លង

ទាំងអស់ៗ ចំនួន **១៨ កោដិកហាបណៈ** ។ បើសរុបប្រាក់ដែលអនាថ-បិណ្ឌិកសេដ្ឋី បានចំណាយចាយវាយទិញដីកសាងវិហារ និងបរិវេណ ហើយធ្វើបុណ្យឆ្លងនោះ រួមទឹកប្រាក់ទាំងអស់ **៥៤ កោដិកហាបណៈ** ។ ចាប់ពីពេលនោះមក អនាថបិណ្ឌិកសេដ្ឋី បានថ្វាយទានជាប្រក្រតី ក្នុងផ្ទះរបស់ខ្លួនរៀងរាល់ថ្ងៃ គឺការថ្វាយ **សលាកភត្ត** ( អាហារដែលថ្វាយតាមស្លាក ) មួយថ្ងៃ ៥០០ អង្គ, **បក្ខិកភត្ត** ( អាហារដែលថ្វាយមួយបក្ខម្ដង គឺ ១៥ ថ្ងៃម្ដង ) ម្ដង ៥០០ អង្គ, **សលាកយាគូ** ( បបរថ្វាយតាមស្លាក ) មួយថ្ងៃ ៥០០ អង្គ, **បក្ខិកយាគូ** ( បបរថ្វាយមួយបក្ខម្ដង ) ម្ដង ៥០០ អង្គ **ធុវភត្ត** ( អាហារថ្វាយជាប្រចាំ ) មួយថ្ងៃ ៥០០ អង្គ, **អាគន្តុកភត្ត** ( អាហារថ្វាយភិក្ខុសង្ឃមកពីទិសផ្សេងៗ ) ៥០០ អង្គ, **គមិកភត្ត** ( ភត្តដើម្បីធ្វើដំណើរ ) ៥០០ អង្គ, **គិលានភត្ត** ( ភត្តដែលថ្វាយដល់ភិក្ខុដែលអាពាធ ) និងក្រាលអាសនៈជាប្រចាំ សម្រាប់ភិក្ខុសង្ឃ ដែលនិមន្តមកជាប្រចាំ មួយថ្ងៃ ៥០០ អង្គ នៅនឹងផ្ទះរបស់លោក ។

កិត្តិគុណដ៏ថ្លៃថ្លារបស់អនាថបិណ្ឌិកសេដ្ឋី ដែលជាអ្នកបានទទួលការលើកតម្កើងពីព្រះមានជោគ ដែលមានសម្ដែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៈ-

ក្នុងកាលបន្តបន្ទាប់មក កាលដែលព្រះសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅវត្តជេតពន ទ្រង់បានប្រកាសតែងតាំងឧបាសកទាំងឡាយ ទុកក្នុងតំណែងជាឯតទគ្គៈ គឺប្រព្រឹត្តទៅតាមឧបនិស្ស័យ និងសមត្ថភាពរបស់ខ្លួនតាមសមគួរ ទ្រង់បានប្រកាសតែងតាំងអនាថបិណ្ឌិកសេដ្ឋី ទុកក្នុងតំណែងជាឯតទគ្គៈថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។** ម្នាលភិក្ខុទាំងឡាយ ពួកឧបាសកជាទាយក (អ្នកឲ្យទាន) ស្រេចនឹងសុទត្តគហបតី គឺអនាថបិណ្ឌិកសេដ្ឋី ។

អនាថបិណ្ឌិកសេដ្ឋី ក្រៅពីមានការសប្បាយចិត្តក្នុងការបរិច្ចាគទានហើយ លោកក៏ជាអ្នកប្រព្រឹត្តបដិបត្តិ សង្រួមនៅក្នុងសីល ទាំងមនុស្សដែលនៅក្នុងក្រុមគ្រួសាររបស់លោក ក៏បានជាអ្នកប្រព្រឹត្តប្រតិបត្តិតាម

ដូចដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថា គម្ពីរខុទ្ទកនិកាយជាតក នៃសរិកាឡកណ្ណិជាតក** ដូចមានសេចក្ដីថា ៈ-

អនាថបិណ្ឌិកសេដ្ឋី បានរក្សាសីល ៥ អស់កាលជានិច្ច តាំងពីពេលដែលលោកសម្រេចព្រះសោតាបត្តិផលហើយ សីល ៥ ដែលអនាថបិណ្ឌិកសេដ្ឋីរក្សាជានិច្ចនោះ ជាសីលសម្រាប់អ្នកគ្រប់គ្រងផ្ទះដែលប្រែថា **បកតិ** ឬត្រជាក់ មាន ៥ ប្រការ គឺ ១. វៀរចាកការសម្លាប់សត្វ ( **បាណាតិបាតា វេរមណី** ) ២. វៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យ (**អទិន្នាទានា វេរមណី**) ៣.វៀរចាកការប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ ( **កាមេសុមិច្ឆាចារា វេរមណី** ) ៤. វៀរចាកការនិយាយកុហក ( **មុសាវាទា វេរមណី** ) ៥. វៀរចាកការផឹកនូវទឹកស្រវឹង គឺសុរាមេរ័យ និងមជ្ជៈ ដែលជាទីតាំង នៃសេចក្ដីប្រមាទ ( **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** ) ។ រីឯនាង **បុញ្ញលក្ខណាទេវី** ដែលជាភរិយារបស់អនាថបិណ្ឌិកសេដ្ឋីក៏បានជាអ្នករក្សាសីល ៥ ជានិច្ចដូចគ្នា សូម្បីបុត្ររបស់លោកសេដ្ឋី ក៏រក្សាសីល ៥ តាមលោកសេដ្ឋី

និងរហូតដល់ទាសកម្មករទាំងឡាយរបស់លោក ក៏តាំងចិត្តរក្សាសីល ៥ ដូចគ្នា ( ទាំងនេះចាត់ជាគ្រួសារគំរូ ដែលប្រកាន់យកក្នុងជំណើរជីវិតជាអ្នកដល់ព្រមទៅដោយការរក្សាសីល ) ។ ផលល្អនៃការរក្សាសីលរបស់ទាសកម្មករ ដែលនៅក្នុងក្រុមគ្រួសាររបស់អនាថបិណ្ឌិកសេដ្ឋី បានផ្សាយទូទៅ គឺថ្ងៃមួយ ភិក្ខុទាំងឡាយ បានអង្គុយសន្ទនាគ្នា ក្នុងសាលាធម្មសភាថា លោកសេដ្ឋី ជាមនុស្សល្អទាំងខ្លួនឯង និងល្អទាំងបរិវារ ជាអ្នកប្រព្រឹត្តតាំងនៅក្នុង **បញ្ចសីល** គឺសីល ៥ អស់កាលជានិច្ច ។

ព្រះមុនី ស្តេចបានយាងទៅគង់ប្រថាប់នៅក្នុងសាលាធម្មសភា ដែលមានភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នា ហើយក៏បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុ អនាថបិណ្ឌិកសេដ្ឋីជាមនុស្សល្អ ទាំងខ្លួនឯង និងបរិវារទាំងអស់ ដែលជាអ្នកប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងសីល ។ ចំពោះបុគ្គលដែលជាអ្នកមានបុណ្យបារមីធ្វើទុករួចមកហើយ រមែងតែងតែប្រព្រឹត្តទៅឲ្យអ្នកដទៃបានទទួលនូវប្រយោជន៍ ដូចជាអនាថបិណ្ឌិកសេដ្ឋី ដែលជា

អ្នកមានបុញ្ញាភិនីហារ ផ្សាយទៅដល់ទាសកម្មកររបស់លោក ម្យ៉ាងទៀត ទាំងលោកក៏ជាអ្នកបដិបត្តិខ្លួនឯងឲ្យជាគំរូផង ទើបជាហេតុធ្វើឲ្យទាស-កម្មករទាំងអស់ ជាអ្នកប្រព្រឹត្តតាម ។

ដូចមានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាធម្មបទ** នៃ **អប្បមាទវគ្គ** ក្នុងរឿង **ព្រះនាងសាមាវតី** ថា ៈ-

មានបុរសកម្សត់ម្នាក់ ជាអ្នកដើរស្វែងរកស៊ីឈ្នួល ក៏បានទៅធ្វើជាកូនឈ្នួលនៅក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ដោយការធ្វើកិច្ចការងារក្នុងផ្ទះរបស់លោកសេដ្ឋី ដើម្បីចិញ្ចឹមជីវិត កាលតមក ដល់ថ្ងៃឧបោសថថ្ងៃមួយ អនាថបិណ្ឌិកសេដ្ឋី បានត្រឡប់ពីវត្តមកវិញ បានសួរថា ថ្ងៃនេះមាននរណា បានប្រាប់អំពីថ្ងៃឧបោសថដល់កូនឈ្នួល ដែលមកថ្មីនោះឬទេ ? មនុស្សនៅក្នុងផ្ទះឆ្លើយថា បពិត្រលោកម្ចាស់ មិនមាននរណាបានប្រាប់ឲ្យគេបានដឹងឡើយទាន ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី ទើបប្រាប់ថា បើដូច្នោះ ពួកអ្នកចូរធ្វើអាហារសម្រាប់ពេលល្ងាចទុកឲ្យផង ។ ហើយមនុស្សទាំងនោះ បាននាំគ្នាធ្វើអាហារគ្រប់ទុកឲ្យកូនឈ្នួលនោះ

ចំណែកកូនឈ្នួលនោះ កាលត្រឡប់មកអំពីការងារក្នុងព្រៃពេញមួយថ្ងៃ ហើយគេបានត្រឡប់មកដល់ផ្ទះវិញ ក្នុងពេលល្ងាច កាលមនុស្សទាំងឡាយបាននាំគ្នាយកអាហារមកឲ្យ ក៏មិនទាន់បរិភោគនៅក្នុងពេលនោះភ្លាមទេ ដោយគិតថា យើងកំពុងតែអស់កម្លាំង តែគិតពិចារណាថា ក្នុងថ្ងៃផ្សេងៗ កន្លែងដែលដើរទៅមក តែងតែមានភាពអ៊ូអរនៅក្នុងផ្ទះនេះ ដោយអ្នកខ្លះនិយាយថា សូមលោកឲ្យបាយផង ឲ្យសម្លផង តែក្នុងថ្ងៃនេះ មនុស្សទាំងនោះ បែរជាដេកនៅស្ងៀមគ្មានសំឡេងអ៊ូអរ តែគេបានចាត់ចែងអាហារគ្រប់ទុកឲ្យយើង តែម្នាក់ប៉ុណ្ណោះ នេះប្រាកដជាមានហេតុអ្វីហើយ ទើបសួរថា អ្នកដទៃៗ បានបរិភោគអាហារអស់ហើយឬ ? មនុស្សទាំងនោះឆ្លើយថា ពួកយើងទាំងអស់គ្នាមិនបានបរិភោគអាហារទេ ។ បុរសកម្សត់នោះ សួរដើម្បីឲ្យដឹងការពិត ព្រោះហេតុអ្វីបានជាអ្នកទាំងអស់គ្នាមិនបរិភោគអាហារ ។

មនុស្សទាំងនោះ ឆ្លើយតបយ៉ាងច្បាស់ថា នៅក្នុងផ្ទះនេះ គេមិនបរិភោគអាហារនៅពេលល្ងាច ក្នុងថ្ងៃឧបោសថទេ ដោយមនុស្សគ្រប់គ្នា

ទាំងអស់ ជាអ្នកបានសមាទានទូវឧបោសថសីល ដោយហោចទៅ សូម្បីតែទារកនៅបៅដោះ លោកសេដ្ឋីក៏ឲ្យខ្ពុរមាត់ ហើយបញ្ចុករបស់ដែលមានរសផ្អែម ៤ មុខ ហើយធ្វើឲ្យជាបុគ្គលរក្សាឧបោសថ កាលប្រទីបភ្លើងនេះដោយប្រេងក្រអូបអុជឡើងហើយ ក្មេងតូចៗ និងក្មេងធំទាំងឡាយបានចូលទៅកាន់កន្លែងដេក ហើយបាននាំគ្នាស្វាធ្យាយអាការៈ ៣២ តែថាពួកយើងភ្លេចប្រាប់ដល់លោកថា ថ្ងៃនេះ ជាថ្ងៃឧបោសថ ព្រោះហេតុនោះទើបពួកយើងធ្វើអាហារទុកសម្រាប់លោកតែម្នាក់ ចូរលោកទទួលទានអាហារនោះចុះ ។ បុរសកម្សត់ក៏សួរថា តើខ្ញុំអាចរក្សាឧបោសថ ក្នុងពេលនេះទៅបានឬទេ ហើយខ្ញុំឈ្មោះថា ជាអ្នកបានសមាទានរក្សាឧបោសថសីលដែរឬទេ ? មនុស្សទាំងនោះ និយាយប្រាប់ថា ចំពោះសេចក្តីនេះ មានតែអនាថបិណ្ឌិកសេដ្ឋី ទើបជាអ្នកដឹងក្នុងរឿងនេះ ។ បុរសកម្សត់និយាយថា បើដូច្នោះ សូមអ្នកទាំងអស់គ្នា សួរបញ្ហាក្នុងរឿងនេះ ចំពោះអនាថបិណ្ឌិកសេដ្ឋីឲ្យខ្ញុំផងណា ។ អ្នកទាំងនោះ ក៏បាននាំគ្នាទៅសួរចំពោះអនាថបិណ្ឌិកសេដ្ឋីហើយ ។ គ្រានោះ អនាថបិណ្ឌិក-

សេដ្ឋី ប្រាប់បុរសនោះថា បាន បុរសនោះកាលបើដឹងដូច្នេះហើយ ទើបតាំងចេតនា ក្នុងការសមាទានឧបោសថសីល រួចខ្លួរមាត់ ហើយបានអធិដ្ឋានឧបោសថសីល មួយរំពេចក្នុងពេលហ្នឹងឯង ។ បុរសកម្សត់នោះបានស្តាប់ពាក្យនោះហើយ ក៏បានធ្វើតាមពាក្យណែនាំទាំងនោះ ប៉ុន្តែគេមានការស្រេកឃ្លានយ៉ាងខ្លាំង ព្រោះគេធ្វើការងារពេញមួយថ្ងៃ ដោយការអត់អាហារនោះ ក៏បណ្តាលឲ្យកើតខ្យល់ចាប់ ធ្វើឲ្យរាងកាយរបស់គេញ័ររន្ធត់ ដូច្នេះគេយកខ្សែមកចងរឹតពោះ ចាប់ចុងខ្សែដេកបម្រះទៅមក ។ អនាថបិណ្ឌិកសេដ្ឋី បានឮសំឡេងនោះហើយ ទើបឲ្យគេកាន់គប់ភ្លើង ហើយឲ្យយករបស់មានរស ៤ យ៉ាង រួចទៅកាន់កន្លែងនៅរបស់បុរសកម្សត់នោះ លុះទៅដល់ហើយ បានសួរថា យ៉ាងណាហើយលោក ? បុរសកម្សត់នោះឆ្លើយថា លោកសេដ្ឋី ខ្យល់បានកើតឡើងពេញរាងកាយរបស់ខ្ញុំខ្លាំងណាស់ ។ អនាថបិណ្ឌិកសេដ្ឋីប្រាប់ថា បើដូច្នោះ អ្នកចូរក្រោកឡើង ទទួលអាហារនេះចុះ ។ បុរសកម្សត់សួរថា លោកសេដ្ឋី លោកទទួលទានហើយឬនៅ ? អនាថបិណ្ឌិកសេដ្ឋី

ពោលតបថា នែអ្នក ពួកយើងមិនបានឈឺអ្វីឡើយ អ្នកចូរបរិភោគអាហារនេះចុះ ។ បុរសកម្សត់ពោលដល់ការតាំងចិត្តថា លោកសេដ្ឋីខ្ញុំបានសមាទានឧបោសថសីល តែពាក់កណ្តាលថ្ងៃ ដូច្នេះ សូមឲ្យឧបោសថសីលដែលបានសមាទានរួចមកហើយនេះ របស់ខ្ញុំម្ចាស់ កុំឲ្យដាច់ពពាលឡើយ គេពោលដូច្នេះហើយៗ គេក៏មិនបរិភោគនូវអាហារនោះឡើយ ។ សូម្បីអនាថបិណ្ឌិកសេដ្ឋី ក៏និយាយអង្វរថា ចូរអ្នកកុំធ្វើយ៉ាងហ្នឹងឡើយ ។

បុរសនោះក៏មិនព្រមធ្វើតាមពាក្យអង្វររបស់អនាថបិណ្ឌិកសេដ្ឋី ដោយការអត់អាហារដូច្នេះមួយថ្ងៃ លុះដល់ពេលអរុណរះឡើង បុរសនោះក៏ស្លាប់ទៅ ប្រៀបដូចផ្កាឈើដែលក្រៀមស្វិតដូច្នោះ ហើយគេបានទៅកើតជាទេវតា នៅនឹងដើមជ្រៃមួយដើម ទេវតានោះ បានពោលពណ៌នាគុណរបស់អនាថបិណ្ឌិកសេដ្ឋីថា លោកសេដ្ឋីជាអ្នករាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ក្នុងរឿងបុរសអ្នកស៊ីឈ្នួល បានទៅកើតជាទេវតា ព្រោះបានឃើញគំរូដ៏ល្អ របស់អនាថបិណ្ឌិកសេដ្ឋី និងបរិវារ

របស់លោកសេដ្ឋីគ្រប់គ្នា សុទ្ធតែជាអ្នកតាំងចិត្តក្នុងការសមាទានរក្សា នូវឧបោសថសីលដូចគ្នាទាំងអស់ ទើបជាហេតុធ្វើឲ្យបុរសកម្មករនោះ តាំងចេតនាក្នុងការសមាទានឧបោសថសីលនោះដែរ សូម្បីនៅសល់ពេលវេលាត្រឹមតែកន្លះថ្ងៃប៉ុណ្ណោះ តែអានិសង្សរបស់ឧបោសថ ដែលគេតាំងចិត្តរក្សា ក៏ឲ្យផលដល់អ្នករក្សាជាច្រើនដែរ ។

រឿងមិនទៀងទាត់នៃជីវិតដោយទូទៅ ត្រូវគ្នានឹងពាក្យពោលថា មានហើយត្រឡប់ជាមិនមាន មិនមានត្រឡប់ជាមាន ឬរបស់នេះមាន ទើបរបស់នោះមាន ហេតុការណ៍បែបនេះ ក៏បានកើតមានដល់អនាថ-បិណ្ឌិកសេដ្ឋី ដែលជាព្រះសោតាបន្នដូចគ្នា ដែលមានរឿងពោលទុកនៅក្នុង **គម្ពីរធម្មបទ** នៃ **បាបវគ្គ** និងក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង **ខទិរង្គារជាតក** នៅក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្ដីថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ព្រះអង្គបានត្រាស់ធម្មទេសនា ប្រារព្ធចំពោះអនាថបិណ្ឌិកសេដ្ឋី ដែល

មានសេចក្តីជ្រះថ្លា បរិច្ចាគទ្រព្យសម្បត្តិ រហូតដល់អស់ ៥៤ កោដិកហាបណៈ សម្រាប់កសាងវត្តជេតពន និងធ្វើបុណ្យឆ្លងវត្តជេតពនក្នុងព្រះសាសនានេះ ។ ប្រក្រតីរបស់អនាថបិណ្ឌិកសេដ្ឋី តែងតែទៅកាន់វត្តមួយថ្ងៃ ៣លើក រៀងរាល់ថ្ងៃ មុនពេលដែលលោកសេដ្ឋីទៅកាន់វត្តលោកបានពិចារណាថា ភិក្ខុក្តី សាមណេរក្តី តែងតែមើលដៃរបស់យើងដោយគិតថា តើលោកសេដ្ឋីបានកាន់យកអ្វីមកខ្លះហ្ន៎! ដោយលោកសេដ្ឋីគិតដល់ភិក្ខុ និងសាមណេរ ដូច្នេះហើយ ពេលដែលលោកទៅកាន់វត្តដៃរបស់លោកមិនទៅដោយទទេទេ តែងតែកាន់របស់អ្វីទៅជាមួយ ។ ពេលដែលលោកសេដ្ឋីទៅក្នុងពេលព្រឹក ក៏បានឲ្យមនុស្សកាន់បបរទៅជាមួយ បន្ទាប់ពីបរិភោគអាហារព្រឹកហើយ វេលានឹងទៅកាន់វត្ត បានឲ្យគេកាន់យកភេសជ្ជៈទាំងឡាយ មានទឹកដោះថ្លា ទឹកដោះខាប់ ប្រេងលាប និងក្រណាត់ជាដើម លោកសេដ្ឋីបានថ្វាយទាន រក្សាសីល ដោយធ្វើយ៉ាងនេះជារៀងរាល់ថ្ងៃ អស់កាលជានិច្ចនិរន្តន៍ ។ តែពេលក្រោយមកអនាថបិណ្ឌិកសេដ្ឋី បានដល់នូវការអស់ទ្រព្យ ទាំងត្រូវអ្នករកស៊ីខូចខ្ជី

ប្រាក់របស់លោក ១៨ កោដិកហាបណៈមិនសង និងប្រាក់ ១៨ កោដិកហាបណៈដែលកប់ទុកជិតមាត់ទន្លេ ត្រូវទឹកទន្លេជន់លិចហូរកួចយកទៅអស់ ទ្រព្យរបស់លោកសេដ្ឋី ត្រូវបានវិនាសហិនហោចទៅជាលំដាប់ដូចដែលបានពោលរួចមកហើយ រហូតធ្វើឲ្យអនាថបិណ្ឌិកសេដ្ឋីធ្លាក់ខ្លួនក្លាយជាអ្នកក្រីក្រលំបាក ។

លោកសេដ្ឋី សូម្បីជាអ្នកខ្សត់ទ្រព្យសម្បត្តិ គ្មានអ្វីចំណាយក៏នៅតែតាំងចិត្តថ្វាយទានដល់ភិក្ខុសង្ឃជារឿយៗ តទៅទៀត តែមិនអាចថ្វាយទាននូវរបស់ដែលប្រណីតៗ បាន ។ ថ្ងៃមួយ ព្រះមានជោគត្រាស់សួរថា ម្នាលគហបតី អ្នកមានការឲ្យនូវទានជាប្រចាំឬ ? លោកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលរបស់ខ្ញុំព្រះអង្គនៅតែធ្វើជារឿយៗ ដដែល តែទាននោះមិនសូវប្រណីតទេ ព្រះអង្គដោយបាយកញ្ចុំអង្ករជាមួយនឹងទឹកជ្រក់ជាគម្រប់ពីរ ព្រះអង្គ ។ គ្រានោះព្រះភគវាត្រាស់នឹងអនាថបិណ្ឌិកសេដ្ឋីថា ម្នាលគហបតី អ្នកកុំគិតថាយើងថ្វាយទានដែលសៅហ្មង ព្រោះថា បើចិត្តប្រណីតហើយ ទានដែល

បុគ្គលថ្វាយដល់ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម រមែងមិនឈ្មោះថាជាទានសៅហ្មងទេ ។ ម្នាលគហបតី ប្រការមួយទៀត អ្នកបានថ្វាយទានដល់ព្រះអរិយបុគ្គល ទាំង ៨ ពួកហើយ ។ ចំណែកតថាគតកាលនៅជាវេលាមព្រាហ្មណ៍ បានឲ្យអ្នកស្រុក ឬអ្នកជម្ពូទ្វីបទាំងអស់ឲ្យផ្អាកធ្វើស្រែ ដើម្បីថ្វាយមហាទានដល់ពួកគេ ពេលនោះ សូម្បីទក្ខិណេយ្យបុគ្គលប្រភេទណាទីមួយក៏ដោយ ដែលជាអ្នកដល់នូវព្រះរតនត្រ័យ រមែងមិនមាន ទក្ខិណេយ្យបុគ្គលទាំងឡាយ រកបានដោយកម្រណាស់ កាលបើបុគ្គលរកបានយ៉ាងនេះ ព្រោះហេតុនោះ អ្នកកុំគិតឡើយថា ទានរបស់អ្នកសៅហ្មងឲ្យសោះ ។

ព្រះលោកនាយក ទ្រង់ព្រះករុណាត្រាស់ទេសនាប្រោសដល់អនាថបិណ្ឌិកសេដ្ឋី ដោយត្រាស់ **វេលាមសូត្រ** ដែលមានរឿងពោលទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ នវកនិបាត** ដូចមានសេចក្តីថា ៈ-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនក្បែរក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅគាល់

ព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយ អង្គុយចុះក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះមានជោគ ទ្រង់ត្រាស់សួរថា ម្នាលគហបតី ត្រកូលរបស់លោក នៅតែថ្វាយទានជាប្រក្រតីឬ ? អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា នៅតែ ឲ្យទានដដែល ព្រះអង្គ តែថា ទាននោះ ជារបស់សៅហ្មង ដោយមាន បាយកញ្ចុងអង្ករជាមួយនឹងទឹកជ្រក់ ជាគម្រប់ពីរប៉ុណ្ណោះ ព្រះអង្គ ។ ពេលនោះ ទើបព្រះលោកនាថត្រាស់ទូន្មានថា ម្នាលគហបតី បុគ្គល សូម្បីឲ្យរបស់ដែលសៅហ្មង ឬរបស់ប្រណីតក៏ដោយ បើឲ្យទានដោយ ការមិនគោរព ឲ្យទានដោយមិនកោតក្រែង មិនបានឲ្យទានដោយដៃ របស់ខ្លួនឯង ឲ្យទានដូចបោះចោល ឲ្យទានដោយមិនជឿនូវផលរបស់ ទាន ពេលអ្នកនោះកើតក្នុងទីណាៗ ក៏មិនបង្អោនចិត្តទៅដើម្បីនឹងបរិភោគ អាហារដែលល្អ ឬប្រណីត មិនដើម្បីនឹងប្រើប្រាស់គ្រឿងស្លៀកដណ្ដប់ ដែលល្អ មិនដើម្បីនឹងប្រើប្រាស់យានដែលល្អ ជាពិសេសនោះ សូម្បី បុត្រ និងភរិយា ឬបាវព្រាវក៏មិនជឿស្ដាប់ពាក្យសម្ដី ប្រការនេះព្រោះ ហេតុអ្វី ព្រោះហេតុថា សេចក្ដីនោះជាផលនៃទាន ដែលគេឲ្យដោយ

ការមិនគោរព ។ បុគ្គលដែលឲ្យទាននូវរបស់ដែលអន់ ឬរបស់ប្រណីត ក៏ដោយ ប្រសិនបើឲ្យដោយការគោរព ឲ្យដោយការរាប់អាន ឲ្យដោយដៃរបស់ខ្លួនឯង ឲ្យមិនដូចជារបស់បោះចោល ឲ្យដោយការជឿផល នៃទាន ពេលអ្នកនោះកើតក្នុងទីណាៗ គេក៏មានចិត្តបង្អោនទៅដើម្បីបរិភោគអាហារដែលល្អ និងស្លៀកដណ្តប់របស់ដែលល្អៗ សូម្បីប្រើប្រាស់យានក៏ជារបស់ល្អ ទាំងបុត្រ និងភរិយា ឬបាវព្រាវតែងតែជឿស្តាប់ពាក្យសម្តី សេចក្តីនោះព្រោះហេតុអ្វី ព្រោះហេតុថា នុ៎ះជាផល នៃទាន ដែលគេថ្វាយដោយសេចក្តីគោរព ។

ម្នាលគហបតី កាលមុនមានព្រាហ្មណ៍ម្នាក់ ឈ្មោះថា វេលាមព្រាហ្មណ៍ៗ បានឲ្យមហាទានប្រព្រឹត្តទៅដូច្នេះ គឺបានឲ្យថាសមាស ដែលដាក់ប្រាក់ពេញ ៨ ម៉ឺន ៤ ពាន់ថាស បានឲ្យថាសប្រាក់ ដែលដាក់មាសពេញ ៨ ម៉ឺន ៤ ពាន់ថាស បានឲ្យថាសសំរឹទ្ធ ដែលដាក់មាស ៨ ម៉ឺន ៤ ពាន់ថាស បានឲ្យដំរី ៨ ម៉ឺន ៤ ពាន់ក្បាល ដែលជាដំរីប្រដាប់ដោយគ្រឿងមាស មានទង់មាសគ្របដណ្តប់ ដោយសំណាញ់

មាស បានឲ្យរថ ៨ ម៉ឺន ៤ ពាន់គ្រឿង ពាសដោយស្បែករាជសីហ៍ ស្បែកខ្លាធំ ស្បែកខ្លាដំបង សំពត់កម្ពលពណ៌លឿង ប្រដាប់ដោយគ្រឿងមាស បានដល់ទង់មាស ស្រោបដោយមាស បានឲ្យមេគោជំទង់ ៨ ម៉ឺន ៤ ពាន់ក្បាល ជាមួយនឹងថាសសំរឹទ្ធ សម្រាប់ត្រងទឹកដោះគោ បានឲ្យស្រីក្រមុំ ៨ ម៉ឺន ៤ ពាន់នាក់ ម្នាក់ៗ សុទ្ធតែប្រដាប់ដោយកែវមុក្តា កែវមណី កណ្ឌល បានឲ្យបល្ល័ង្ក ៨ ម៉ឺន ៤ ពាន់ ក្រាលដោយសំពត់រោមសត្វ ដែលមានរោមវែងៗ ដែលធ្វើដោយរោមសត្វចៀម ធ្វើក្បាច់ដូចផ្កាឈើលាត ដោយសំពត់ស្បែកសត្វ មានសម្លស្បូយ៉ាងទន់ នៅខាងលើធ្វើជាពិតាន មានខ្នើយឱប ខ្នើយកល់ជើង បានឲ្យសំពត់ ៨ ម៉ឺន ៤ ពាន់ដុំ មានសំពត់សំបកក្រចៅ សំពត់សំបកធ្មៃ សំពត់សរសៃអំបោះយ៉ាងល្អ ចំណែកបាយ ទឹក បង្អែម ចម្អាប គ្រឿងលាបទីដេក ទីស្នាក់អាស្រ័យ មិនចាំបាច់និយាយដល់ ព្រោះថា មានច្រើនប្រៀបដូចនឹងទឹកទន្លេ ដែលហូរជន់ ។ ម្នាលគហបតី អ្នកកុំនឹកថា វេលាមព្រាហ្មណ៍ ដែលបានឲ្យមហាទានក្នុងកាលនោះ ជាអ្នកដទៃ

ការពិតតថាគតនេះឯង ជាវេលាមព្រាហ្មណ៍ ក្នុងកាលនោះ តថាគត បានឲ្យមហាទាន ដូចដែលបានពោលរួចមកហើយនេះ តែថា ការឲ្យមហាទានក្នុងគ្រានោះ មិនមានអ្នកគួរដល់ទក្ខិណាទានឡើយ មិនមានអ្នកណាធ្វើឲ្យទក្ខិណាទាន (ទានដែលធ្វើឲ្យមានផលច្រើន) ឲ្យបរិសុទ្ធ ។ ម្នាលគហបតី បុគ្គលណាឲ្យទានដល់អ្នកដែលបរិបូណ៌ដោយទស្សនៈ គឺឲ្យដល់ព្រះសោតាបន្នត្រឹមតែមួយរូបត្រឹមតែម្តងការឲ្យទានត្រឹមតែម្តង ចំពោះព្រះសោតាបន្ននោះ តែមួយរូបនោះ រមែងមានផលច្រើនជាង មហាទាន ដែលវេលាមព្រាហ្មណ៍ ឲ្យនោះទៅទៀត ។

បុគ្គលណាឲ្យទានដល់ **ព្រះសោតាបន្ន ១០០ រូប** ការឲ្យទានដល់ **ព្រះសកទាគាមី** ត្រឹមតែមួយរូប មានផលច្រើនជាងការឲ្យទានដល់ **ព្រះសោតាបន្ន ១០០ រូប** ។ បុគ្គលឲ្យទានដល់ **ព្រះសកទាគាមី ១០០ រូប** មានផលតិចជាងការឲ្យទានដល់ **ព្រះអនាគាមីមួយរូប** ។ បុគ្គលឲ្យទានដល់ **ព្រះអនាគាមី ១០០ រូប** មានផលតិចជាងការឲ្យទានដល់ **ព្រះអរហន្តមួយរូប** ។ បុគ្គលថ្វាយទានដល់ **ព្រះបច្ចេកពុទ្ធ ១០០ រូប**

មានផលតិចជាងការថ្វាយទានដល់ **ព្រះសម្មាសម្ពុទ្ធ** ។ បុគ្គលថ្វាយទានដល់ **ព្រះអរហន្តសម្មាសម្ពុទ្ធ** មានផលតិចជាងការឲ្យទានដល់ **ព្រះសង្ឃ** ដែលមានព្រះពុទ្ធជាប្រធាន ។ បុគ្គលឲ្យទានដល់ **ព្រះសង្ឃ** មានព្រះពុទ្ធជាប្រធាន មានផលតិចជាងការកសាងវិហារថ្វាយដល់ភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៤ ។ បុគ្គលកាលកសាងវិហារថ្វាយដល់ **ព្រះសង្ឃ** ដែលមកអំពីទិសទាំង ៤ នៅមានផលតិចជាង ដែលមានចិត្តជ្រះថ្លាគោរពរាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ជាទីរឭក ដែលហៅថា ការដល់ **ព្រះត្រៃសរណគមន៍** ។ ការដល់ត្រៃសរណគមន៍តែម្យ៉ាង នៅមានផលតិចជាង ការដល់ត្រៃសរណគមន៍ ហើយជាអ្នកដល់ព្រមដោយការសមាទានសីល ៥ ផង ។ ការដល់ត្រៃសរណគមន៍ព្រមដោយ**សីល៥**ហើយនោះនៅមានផលតិចជាងការអប់រំ**មេត្តាចិត្ត** គឺចិត្តមានមេត្តាត្រឹមតែមួយខណៈ នៃការហិតក្លិនក្រអូប ។ ការចម្រើន **អនិច្ចសញ្ញា** គឺការសម្គាល់ថា មិនទៀងត្រឹមតែមួយផ្ទាត់ក្រចក មានផលច្រើនជាងការអប់រំមេត្តាចិត្តទៅទៀត ។

នៅមានរឿងរបស់អនាថបិណ្ឌិកសេដ្ឋី ដែលបានពោលទុកក្នុង **អដ្ឋកថាធម្មបទ** នៃ **បាបវគ្គ** និងក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលី **ខទិរង្គារជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្ដីថា ៖-

អនាថបិណ្ឌិកសេដ្ឋី សូម្បីធ្លាក់ខ្លួនក្រខ្សត់ តែក្នុងផ្ទះរបស់លោកនៅមានការថ្វាយទានដល់ភិក្ខុសង្ឃប្រមាណ ៥០០ រូបជារៀងរាល់ថ្ងៃ មានពាក្យប្រៀបធៀបថា រឿងរបស់អនាថបិណ្ឌិកសេដ្ឋី ដូចគ្នានឹងស្រះបោក្ខរណី គឺស្រះដែលជីកទុកនៅត្រង់ផ្លូវបែកជា ៤ សម្រាប់ភិក្ខុសង្ឃតាំងនៅក្នុងឋានៈប្រហែលគ្នានឹងមាតាបិតា របស់ភិក្ខុសង្ឃទាំងឡាយទូទៅ ។ ព្រោះហេតុនោះ ព្រះមានជោគ ស្ដេចយាងទៅកាន់គេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋី ព្រមទាំងព្រះអសីតិមហាសាវក ៨០ រូបក៏និមន្តទៅជាមួយដែរ ។ ចំណែកភិក្ខុក្រៅពីនោះ ក៏បាននិមន្តទៅមកៗមិនមានកំណត់ចំនួនថាប៉ុន្មានទេ ។ ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី មាន ៧ ជាន់ មានទ្វារ ៧ នៅទ្វារទី ៤ នៃផ្ទះនោះ មានទេវតា ដែលជា

មិច្ឆាទិដ្ឋិមួយអង្គអាស្រ័យនៅ ។ ទេវតានោះ កាលព្រះមានព្រះភាគ ស្ដេចយាងចូលទៅក្នុងផ្ទះ និងស្ដេចយាងចេញមកវិញ រមែងមិនអាច នៅក្នុងវិមានរបស់ខ្លួនបាន ចាំបាច់ត្រូវនាំកូនទាំងឡាយចុះមក ពីវិមាន របស់ខ្លួនទៅខាងក្រោម ឬសូម្បីពេលដែលព្រះអសីតិមហាសាវក ៨០ រូប ចូលទៅក្នុងផ្ទះ និងចេញមកវិញ ទេវតានោះក៏ត្រូវធ្វើដូច្នោះដែរ ។ កាលទេវតានោះ បានទទួលការលំបាកយ៉ាងនេះហើយ ទើបគិតថា កាលព្រះសមណគោតម និងមហាសាវកនិមន្តចូលទៅក្នុងផ្ទះ របស់ អនាថបិណ្ឌិកសេដ្ឋីនេះ យើងមិនមានសេចក្ដីសុខឡើយ ព្រោះយើង មិនអាចចុះទៅមកជារឿយៗ អស់កាលជានិច្ចយ៉ាងនេះបានទេ ហេតុនេះ យើងគួរនឹងធ្វើឲ្យភិក្ខុសង្ឃទាំងឡាយនោះ ចូលមកក្នុងផ្ទះនេះមិនបាន ។ ក្រោយមកថ្ងៃមួយ ទេវតានោះក៏បានទៅរកបុរសម្នាក់ ដែលជាមេការ របស់លោកសេដ្ឋី ដែលនៅពេលនោះ បុរសនោះកំពុងតែរៀបចំចូល ដេកហើយ ទេវតានោះក៏បានបញ្ចេញពន្លឺឲ្យប្រាកដដល់មេការ ។ បុរស ដែលជាមេការនោះស្រែកសួរថា នរណាគេហ្នឹង ? ទេវតាឆ្លើយថា ខ្ញុំ

ជាទេវតានៅនឹងស៊ុមទ្វារទី ៤ របស់លោកសេដ្ឋី បុរសនោះសួរទៀតថា អ្នកមកទីនេះមានការអ្វី ? ទេវតាឆ្លើយថា អ្នកដ៏ចម្រើន អ្នកមិនបាន ពិចារណាមើលការធ្វើរបស់លោកសេដ្ឋីទេឬ ព្រោះលោកសេដ្ឋី គិតតែ លះបង់ទ្រព្យសម្បត្តិទំនុកបម្រុងព្រះសមណគោតម ដោយមិនទៅ ប្រកបការជួញដូរ និងមិនធ្វើការងារអ្វីឡើយ ហេតុដូច្នេះ ទើបធ្វើឲ្យ លោកសេដ្ឋីក្រលំបាក ចូរលោកប្រាប់រឿងដល់អនាថបិណ្ឌិកសេដ្ឋីឲ្យ ប្រកបកិច្ចការងារនោះដូចដើមវិញទៅ ហើយកុំឲ្យព្រះសមណគោតម និងសាវកចូលមកក្នុងផ្ទះនេះទៀត ។ បុរសដែលជាមេការ ក៏ពោល នឹងទេវតាថា នែទេវតាពាល លោកសេដ្ឋីដែលលះបង់ទ្រព្យសម្បត្តិ ធ្វើយ៉ាងនោះ គឺការទំនុកបម្រុងព្រះសាសនានេះ ក៏ជាផ្លូវប្រព្រឹត្តទៅ ដើម្បីរួចផុតចាកទុក្ខ សូម្បីលោកសេដ្ឋីយកខ្ញុំទៅលក់ ដូចជាទំនិញ ក៏ខ្ញុំមិនថាអ្វីនឹងលោកសេដ្ឋីដែរ តែទេវតាពាលឯង ចូរចេញពីទីនេះទៅ កុំនិយាយរឿងនេះនឹងយើងឡើយ ។ ថ្ងៃបន្ទាប់តមក ទេវតានោះ កាល និយាយជាមួយនឹងមេការនោះមិនបានសម្រេច ក៏ចូលទៅរកកូនច្បង

របស់អនាថបិណ្ឌិកសេដ្ឋី ហើយបានពោលណែនាំហេតុផលតែមួយ ដូចដែលបានពោលជាមួយនឹងមេការនោះ ។

កូនប្រុសច្បងរបស់លោកសេដ្ឋី បានស្តាប់ពាក្យនិយាយប្រាប់របស់ទេវតានោះហើយ ក៏ជ្រាបអធ្យាស្រ័យរបស់ទេវតានោះថា នេះជាទេវតាមិច្ឆាទិដ្ឋិ គេបាននិយាយបណ្តេញទេវតានោះទៅ ដូចបុរសដែលជាមេការបណ្តេញដែរ ។ ទេវតាកាលមិនអាចនិយាយញុះញង់ឲ្យបុគ្គលទាំងពីរនាក់នោះជឿបានហើយ ក៏រង់ចាំរកមើលឱកាសដើម្បីទៅនិយាយជាមួយនឹងលោកសេដ្ឋី តែក្នុងពេលដែលលោកសេដ្ឋីនៅមានទ្រព្យជាឥស្សរៈ ទេវតាក៏មិនហ៊ាននិយាយ លុះដល់ពេលលោកសេដ្ឋីក្រខ្សត់ ទេវតាយល់ថា លោកសេដ្ឋីក្រខ្សត់ហើយ គង់នឹងជឿពាក្យរបស់យើង ទើបចូលទៅបន្ទប់ដ៏មានសិរីរបស់លោកសេដ្ឋី នៅក្នុងពេលពាក់កណ្តាលយប់ ដោយទេវតាស្ថិតនៅលើអាកាស ហើយបញ្ចេញរស្មីឲ្យលោកសេដ្ឋីបានឃើញ ។ លោកសេដ្ឋីឃើញរស្មីនោះ ក៏សួរថា នរណាគេហ្នឹង ? ទេវតាឆ្លើយថា លោកសេដ្ឋី ខ្ញុំជាទេវតាដែលអាស្រ័យ

នៅទីនសុំមទ្វារទី ៤ របស់លោក ។ លោកសេដ្ឋីសួរថា អ្នកមករកខ្ញុំមានការអ្វី ? ទេវតាឆ្លើយថា ខ្ញុំមកនេះដើម្បីដាស់តឿនលោក ។ លោកសេដ្ឋីពោលថា បើយ៉ាងនោះ ចូរលោកនិយាយមកចុះ ។ ទេវតាពោលថា លោកសេដ្ឋី លោកមិនបានមើលក្នុងកាលជាខាងក្រោយឡើយ លោកមិនគិតដល់បុត្រធីតារបស់លោក ដោយលោកបានចំណាយទ្រព្យសម្បត្តិជាច្រើននៅក្នុងព្រះសាសនា របស់ព្រះសមណគោតម ដោយលោកអាស្រ័យព្រះសមណគោតម ទើបធ្វើឲ្យលោកធ្លាក់ខ្លួនក្រខ្សត់ ព្រោះហេតុដែលលោកចំណាយទ្រព្យសម្បត្តិ ច្រើនហួសពេក ដោយលោកមិនបានទៅធ្វើការលក់ដូរ និងការងារដទៃទៀត ហេតុដូច្នេះ ឥឡូវនេះ ទើបលោកជាអ្នកក្រលំបាក លោកជាអ្នកក្រលំបាកហើយ ក៏នៅតែលះបង់ទ្រព្យសម្បត្តិធ្វើជាទានទៀត រាល់ថ្ងៃនេះ សមណៈទាំងនោះ នាំគ្នាចូលមកផ្ទះរបស់លោក ទ្រព្យដែលសមណៈទាំងនោះនាំទៅហើយ មិនអាចនាំត្រឡប់មកវិញបាន បើលោកនៅតែធ្វើយ៉ាងនេះតទៅទៀត លោកនឹងមិនមានសូម្បីតែអាហារ និងគ្រឿងស្លៀកដណ្តប់នៅពីរបីថ្ងៃទៀតនេះ

យ៉ាងពិតប្រាកដ ចាប់ពីថ្ងៃនេះតទៅ លោកកុំទៅកាន់សម្នាក់ព្រះសមណ-គោតមទៀតឡើយ ហើយកុំឲ្យសាវ័កទាំងឡាយរបស់ព្រះសមណគោតមចូលមកកាន់ផ្ទះរបស់លោកទៀត លោកចូរលើកការបរិច្ចាគទានដែលលើសកម្លាំងចេញ ហើយចូរប្រកបកិច្ចការងាររលក់ដូរ ដូចដើមវិញចុះ ។

លោកសេដ្ឋីសួរថា នេះជាពាក្យជាស់តឿនដែលលោកចង់ប្រាប់ដល់ខ្ញុំឬ ? ទេវតាតបថា ត្រូវហើយលោកសេដ្ឋី ពាក្យនេះឯង ។ អនាថបិណ្ឌិកសេដ្ឋី បាននិយាយបណ្តេញទេវតាថា អ្នកចូរចេញទៅ ខ្ញុំមិនត្រូវការបុគ្គលដូចជាអ្នកទេ សូម្បីមានចំនួនទាំងរយ ទាំងពាន់ ទាំងសែននាក់ក៏ដោយ ក៏មិនអាចធ្វើឲ្យខ្ញុំញាប់ញ័របាន លោកនិយាយពាក្យដែលមិនសមគួរពោល លោកជាអ្នកគ្មានអាចារៈ ( មារយាទល្អ ) ជាអ្នកគ្មានសីល និងជាកាឡកណ្ណី ដូច្នេះ មិនឃើញមានប្រយោជន៍អ្វីឡើយ ដែលលោកនៅទីនផ្ទះនេះ ដូច្នេះ ចូរលោកចេញអំពីផ្ទះរបស់ខ្ញុំទៅឲ្យឆាប់ភ្លាម ។ ទេវតាបានស្តាប់ពាក្យបណ្តាញរបស់អនាថបិណ្ឌិក-សេដ្ឋី ដែលជាព្រះសោតាបន្នអរិយសាវ័កហើយ ក៏មិនអាចនឹងនៅលើស៊ុម

ទ្វារតទៅទៀតដូចមុនបាន ទើបនាំកូនទាំងអស់ចេញទៅ ហើយកាល ទេវតានោះចេញពីស៊ុមទ្វាររបស់លោកសេដ្ឋីហើយ ក៏ទៅរកកន្លែងដទៃ ទៀតមិនបាន ទើបគិតថា យើងនឹងសូមឲ្យលោកសេដ្ឋីអត់ទោសឲ្យហើយ នឹងសូមនៅកន្លែងដើមវិញ ហើយក៏បានចូលទៅរកទេវតា ដែលរក្សា ព្រះនគរ សារភាពទោសកំហុសដែលខ្លួនបានធ្វើហើយ ហើយយំអង្វរ ទេវតានោះថា សូមលោកជួយជូនខ្ញុំទៅកាន់សម្នាក់របស់លោកសេដ្ឋី ដើម្បីសុំឲ្យលោកសេដ្ឋីអត់ទោស ដែលខ្ញុំបានធ្វើហើយៗ ឲ្យខ្ញុំបាន នៅត្រង់ស៊ុមទ្វារនោះដូចដើមវិញ ។

ទេវតានោះពោលថា លោកពោលពាក្យនេះមិនសមគួរ ខ្ញុំមិន អាចហ៊ានជូនលោកទៅជួបលោកសេដ្ឋីទេ ។ ទេវតានោះ កាលអស់ សង្ឃឹម ក៏ចេញអំពីទេវតានោះ ទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក៏ត្រូវមហារាជទាំង ៤ នោះបដិសេធដូចគ្នា ក្រោយមក ទើបទេវតានោះ ចូលទៅគាល់សក្កទេវរាជ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ហើយ ក្រាបទូលអង្វរយ៉ាងគួរឲ្យអាណិតថា បពិត្រមហារាជ ខ្ញុំព្រះអង្គមិនមាន

ទីអាស្រ័យទេ ត្រូវនាំកូនដើរផ្សងព្រេងរកទីស្នាក់អាស្រ័យ ក៏រកមិនបាន ហេតុដូច្នេះ សូមមហារាជមេត្តាប្រោសដល់ខ្ញុំ ឲ្យលោកសេដ្ឋីអត់ទោស ឲ្យទីអាស្រ័យនោះដល់ខ្ញុំព្រះអង្គវិញផង ។ សក្កទេវរាជត្រាស់ជាមួយទេវតានោះថា សូម្បីយើងក៏មិនហ៊ាននិយាយជាមួយនឹងលោកសេដ្ឋីនោះដែរ ព្រោះហេតុតែអ្នកពោលពាក្យមិនសមគួរនោះ តែយើងនឹងប្រាប់ឧបាយដល់អ្នកមួយ ។ ទេវតាក្រាបទូលថា ល្អហើយ មហាបពិត្រ សូមព្រះអង្គករុណាប្រាប់ឧបាយនោះមកចុះ ។ សក្កទេវរាជប្រាប់ឧបាយវិធីថា អ្នកចូរត្រឡប់ទៅហើយ ចូរក្លែងធ្វើជាស្មៀនរបស់លោកសេដ្ឋី ឲ្យគេនាំយកបញ្ជីខ្ចីប្រាក់ ពីដៃរបស់លោកសេដ្ឋីមក ហើយដោយឲ្យអ្នកជំពាក់បំណុល ឲ្យគេសងប្រាក់ ១៨ កោដិកហាបណៈ ដែលពួកគេបានខ្ចីដោយអានុភាពរបស់ខ្លួនហើយ នាំយកមកទុកដាក់ក្នុងឃ្លាំងឲ្យពេញមួយទៀត ទ្រព្យ ១៨ កោដិកហាបណៈ ដែលហូរទៅកាន់មហាសមុទ្រនោះ និងទ្រព្យដទៃទៀត ដែលគ្មានម្ចាស់ មាននៅក្នុងទីនោះ ចូរលោកប្រមូលទ្រព្យទាំងនោះ យកមកទុកដាក់នៅក្នុងឃ្លាំងរបស់លោកសេដ្ឋី កាលបើ

អ្នកធ្វើយ៉ាងនេះរួចហើយ ចូរលោកទៅសុំទោសចំពោះលោកសេដ្ឋីចុះ ។ ទេវតាក្រាបទូលថា ព្រះករុណាមហាបពិត្រ ហើយក៏បានធ្វើតាមគ្រប់យ៉ាងដែលសក្កទេវរាជបានប្រាប់រួចស្រេចហើយ បានទៅកាន់បន្ទប់ដ៏មានសិរីរបស់អនាថបិណ្ឌិកសេដ្ឋី ដោយធ្វើឲ្យមានពន្លឺប្រាកដឡើង ខ្លួនឯងក៏ស្ថិតនៅលើអាកាស ពេលនោះ អនាថបិណ្ឌិកសេដ្ឋី បានឃើញហើយលោកសួរថា នរណាគេហ្នឹង ? ទេវតាតបថា ខ្ញុំជាទេវតា **អន្ធពាល** ដែលអាស្រ័យនៅស៊ុមទ្វារទី ៤ របស់លោកសេដ្ឋី ពាក្យដែលខ្ញុំពោលហើយចំពោះលោក គឺដោយសេចក្ដីល្ងង់ខ្លៅ ហេតុដូច្នេះ សូមលោកអត់នូវទោសនោះ ដល់ខ្ញុំផងចុះ ព្រោះខ្ញុំបានទទួលទោសនោះហើយដោយខ្ញុំទៅប្រមូលទ្រព្យ ៥៤ កោដិកហាបណៈ មកដាក់ឲ្យពេញក្នុងឃ្លាំងរបស់លោកហើយ តាមបញ្ជារបស់សក្កទេវរាជ ខ្ញុំកាលមិនបានទីអាស្រ័យនៅត្រង់ស៊ុមទ្វាររបស់លោកទេ រមែងជួបការលំបាក ឬមិនមានកន្លែងនៅ ។

លោកសេដ្ឋីគិតថា ទេវតានេះពោលថា **ទណ្ឌកម្ម** គឺការដាក់ទោស

របស់ខ្ញុំបានធ្វើហើយ ចាត់ថា ជាអ្នកភ្ញាក់រឭកដឹងនូវកំហុសរបស់ខ្លួន យើងនឹងនាំទេវតានេះទៅគាល់ព្រះសម្ពុទ្ធ លោកសេដ្ឋីគិតដូច្នេះហើយ ទើបនាំទេវតានោះទៅកាន់សម្នាក់ព្រះមានបុណ្យ ហើយក្រាបទូលកម្ម ដែលទេវតា បានធ្វើហើយទាំងអស់ថ្វាយព្រះអង្គឲ្យទ្រង់បានជ្រាប ។ ចំណែកទេវតា បានថ្វាយបង្គំទៀបព្រះបាទមូលរបស់ព្រះជិនស្រីហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹងនូវគុណទាំងឡាយ របស់ព្រះអង្គ បានពោលពាក្យអាក្រក់ ព្រោះភាពជាបុគ្គលល្ងង់ខ្លៅ ហេតុដូច្នេះ សូមព្រះអង្គអត់ទោសដល់ខ្ញុំព្រះអង្គ ដែលបានពោលពាក្យ មិនសមគួរផងចុះ ព្រះអង្គ ។ ព្រះបរមសាស្តា កាលដែលទ្រង់ទូន្មាន លោកសេដ្ឋី និងទេវតាដោយអំណាចវិបាកនៃកម្មល្អ និងអាក្រក់ ទើប ត្រាស់ថា ម្នាលគហបតី បុគ្គលដែលធ្វើបាបក្នុងលោកនោះ រមែង ឃើញបាបថាល្អ ដរាបណា បាបនៅមិនទាន់ឲ្យផល តែកាលណាបាប របស់គេឲ្យផល ពេលនោះ គេរមែងឃើញថា បាបពិតជាអាក្រក់មែន ចំណែកបុគ្គលដែលធ្វើអំពើល្អ រមែងឃើញកម្មល្អ ថាអាក្រក់ ដរាប

ដែលកម្មល្អ នៅមិនទាន់ឲ្យផល តែកាលណាកម្មល្អរបស់គេឲ្យផល ពេលនោះ គេរមែងឃើញថា បុណ្យ គឺល្អពិតមែន ។

កាលព្រះអង្គទ្រង់តអនុសន្ធិសម្តែងព្រះធម៌ ទើបត្រាស់ព្រះគាថាដូច្នេះថា បុគ្គលដែលធ្វើបាប រមែងឃើញថាបាបល្អ កាលណាបាបនោះនៅមិនទាន់ឲ្យផល កាលណាបាបឲ្យផល គេឃើញថា បាបនេះពិតជាអាក្រក់មែន បុគ្គលដែលធ្វើកម្មល្អ រមែងឃើញកម្មល្អថា អាក្រក់ដរាបដែលកម្មល្អនៅមិនទាន់ឲ្យផល នៅពេលណាដែលកម្មល្អឲ្យផលហើយ ពេលនោះ គេរមែងឃើញថា កម្មល្អ ពិតជាល្អមែន ។ តាមន័យព្រះគាថា ដែលអដ្ឋកថាចារ្យអធិប្បាយទុកថា បុគ្គលដែលធ្វើបាបកម្មតាមផ្លូវកាយ វាចា ចិត្ត ឈ្មោះថា អ្នកធ្វើបាប បុគ្គលនោះ កាលសោយសុខ ដែលកើតឡើងដោយអានុភាពនៃសុចរិតកម្មក្នុងអតីតជាតិ រមែងឃើញបាបកម្មថាល្អ ហើយបាបកម្មរបស់គេ ដែលនៅមិនទាន់ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងសម្បរាយិកភព គឺភពខាងមុខ ឬជាតិខាងមុខ ( អ្នកធ្វើបាបរមែងឃើញថាបាបល្អជានិច្ច ) តែពេលណាបាប

របស់គេឲ្យផល ក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងសម្បរាយិកភព ពេលនោះ គេរមែងទទួលនូវសេចក្តីទុក្ខផ្សេងៗ ទាំងក្នុងបច្ចុប្បន្នជាតិ និងទុក្ខក្នុងអបាយ ឬសម្បរាយិកភព រមែងឃើញថា បាបអាក្រក់ពិតមែន ។

បុគ្គលដែលធ្វើកម្មល្អ មានការធ្វើសុចរិត តាមផ្លូវកាយ វាចា ចិត្ត ឈ្មោះថា ធ្វើកម្មល្អ បុគ្គលធ្វើកម្មល្អនោះ ខណៈដែលបានទទួលទុក្ខដែលកើតឡើង ដោយអានុភាពនៃទុច្ចរិតកម្មក្នុងកាលមុន គេរមែងឃើញកម្មល្អថាអាក្រក់ ហើយបើកម្មល្អរបស់គេនៅមិនទាន់ឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងសម្បរាយិកភព ដរាបណា (បុគ្គលធ្វើកម្មល្អរមែងឃើញកម្មល្អថាអាក្រក់ដរាបនោះ ) តែពេលណា កម្មល្អនោះឲ្យផល ពេលនោះ បុគ្គលធ្វើកម្មល្អ រមែងបានទទួលសេចក្តីសុខ ដែលអាស្រ័យអាមិស មានលាភសក្ការៈជាដើម ក្នុងបច្ចុប្បន្នភព និងសុខដែលអាស្រ័យសម្បត្តិដែលជាទិព្វ ក្នុងភពខាងមុខ គេរមែងឃើញកម្មល្អថា ល្អពិតមែន ។ កាលព្រះលោកនាថត្រាស់ព្រះធម៌ទេសនានេះចប់ហើយ ទេវតានោះបានសម្រេចនូវសោតាបត្តិផល ហើយព្រះធម៌

ទេសនានោះ បានជាប្រយោជន៍ដល់ពុទ្ធបរិស័ទ ដែលមកប្រជុំគ្នា ក្នុងគ្រានោះជាច្រើនដែរ ។

អនាថបិណ្ឌិកសេដ្ឋី បានស្ដាប់ព្រះធម៌ទេសនាពីព្រះទសពលដោយព្រះអង្គទ្រង់ព្រះករុណាប្រោសទេសនានេះ ដូចមានរឿងដែលសម្ដែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត នៃ បត្តកម្មវគ្គទី ២** ដូចមានសេចក្ដីថា ៖-

សម័យមួយ ព្រះលោកនាថ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅគាល់ព្រះមានជោគដល់ទីគង់ប្រថាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរដល់ឋានៈរបស់ខ្លួន ។ គ្រានោះ ព្រះលោកនាយក ទ្រង់ត្រាស់ដូច្នេះថាម្នាលគហបតី ធម៌ ៤ ប្រការ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តដែលបុគ្គលរកបានដោយកម្រក្នុងលោកនេះ ។ធម៌ ៤ ប្រការ ដូចម្ដេចខ្លះ ? បានដល់ ១- បំណងថាភោគៈទាំងឡាយ ចូរកើតដល់អាត្មាអញដែលប្រកបដោយធម៌ ។ ២- កាលបើអាត្មាអញបាននូវភោគៈ ដោយកម្ម

ប្រកបដោយធម៌ហើយ សូមយសរបស់អាត្មាអញ ល្បីខ្ចរខ្ចាយឡើង ព្រមទាំងពួកញាតិ ព្រមទាំងពួកឧបជ្ឈាយ៍ គឺមិត្រសម្លាញ់ទាំងឡាយ ។ ៣- កាលបើអាត្មាអញបាននូវភោគៈ ដោយកម្មប្រកបដោយធម៌ហើយ បានយសហើយ ទើបអាត្មាអញព្រមទាំងពួកញាតិ ព្រមទាំងឧបជ្ឈាយ៍ នឹងចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែង ។ ៤- កាលបើ អាត្មាអញ បាននូវភោគៈ ដោយកម្មប្រកបដោយធម៌ហើយ បានយស ហើយ ទើបអាត្មាអញ ព្រមទាំងពួកញាតិ ព្រមទាំងឧបជ្ឈាយ៍ បាន ចិញ្ចឹមជីវិតអស់កាលយូរ រក្សាអាយុឲ្យបានវែង ហើយលុះបែកធ្លាយ រាងកាយបន្ទាប់អំពីមរណៈទៅ សូមឲ្យបានទៅកើតក្នុងសុគតិសួគ៌ទេវ-លោក ។ ម្នាលគហបតី ធម៌ ៤ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីបាន ចំពោះនូវធម៌ ៤ ប្រការ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ដែលបុគ្គលរកបានដោយក្រក្នុងលោកនេះ ។ ធម៌ ៤ ប្រការដូចម្តេច ? បានដល់ ១. **សទ្ធាសម្បទា** គឺដល់ព្រមដោយសទ្ធា ២. **សីលសម្បទា** គឺដល់ព្រមដោយសីល ៣. **ចាគសម្បទា** គឺការដល់ព្រមដោយបរិច្ចាគទាន

៤. បញ្ញាសម្បទា គឺការដល់ព្រមដោយបញ្ញា ។

ម្នាលគហបតី **សទ្ធាសម្បទា** គឺដល់ព្រមដោយសទ្ធា តើដូចម្តេច ? សំដៅដល់ ការជឿចំពោះការត្រាស់ដឹងរបស់ព្រះតថាគតថា **ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវា** សូម្បីហេតុនេះ ព្រះមានព្រះភាគនោះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង ដល់ព្រមដោយវិជ្ជា និងចរណៈ ស្តេចយាងទៅដោយល្អហើយ ជាអ្នកត្រាស់ដឹងនូវលោក ជាសារថី ទូន្មាននូវបុគ្គលដែលគួរទូន្មានបាន មិនមាននរណាក្រៃលែងជាងព្រះសាស្តា ទ្រង់ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ទ្រង់ជាអ្នកភ្ញាក់ និងរីកហើយ ជាអ្នកចែកនូវព្រះធម៌ នេះហៅថា **សទ្ធាសម្បទា** គឺការដល់ព្រមដោយសទ្ធា ។ **សីលសម្បទា** គឺការដល់ព្រមដោយសីល តើដូចម្តេច ? សំដៅដល់ ការវៀរចាកការសម្លាប់សត្វ ការវៀរចាកការលួចទ្រព្យគេ ការវៀរចាកការប្រព្រឹត្តខុសចំពោះប្រពន្ធកូនអ្នកដទៃ ការវៀរចាកការនិយាយកុហក ការវៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ **ចាគសម្បទា**

គឺការដល់ព្រមដោយការបរិច្ចាគទាន តើដូចម្ដេច ? សំដៅដល់ ជាអ្នកមានចិត្តប្រាសចាកសេចក្ដីកំណាញ់ ជាមន្ទិល មានការបរិច្ចាគហើយ មានដៃលាងស្អាត ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងទាន និងការចែកចាយ ។ **បញ្ញាសម្បទា** គឺការដល់ព្រមដោយបញ្ញា តើដូចម្ដេច ? សំដៅដល់ បុគ្គលដែលមានចិត្ត ត្រូវលោភៈគ្របសង្កត់ហើយ ត្រូវព្យាបាទគ្របសង្កត់ហើយ ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ ត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ រមែងធ្វើការងារដែលមិនគួរធ្វើ ញុំាងការងារដែលគួរធ្វើឲ្យវិនាសទៅ រមែងសាបសូន្យចាកយស និងសេចក្ដីសុខ ។ ម្នាលគហបតី អរិយសាវកដឹងថា សេចក្ដីលោភជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់នូវសេចក្ដីលោភនោះបាន ដឹងថា ព្យាបាទជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់ព្យាបាទចេញ ដឹងថា ថីនមិទ្ធៈជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់ថីនមិទ្ធៈចេញ ដឹងថា ឧទ្ធច្ចកុក្កុច្ចៈជាគ្រឿងសៅហ្មងរបស់ចិត្ត ក៏លះបង់ឧទ្ធច្ចកុក្កុច្ចៈចេញ ដឹងច្បាស់ថា វិចិកិច្ឆាជាគ្រឿងសៅហ្មងរបស់ចិត្ត

ក៏លះបង់វិចិកិច្ឆាចេញបាន ។ ព្រោះហេតុដែលព្រះអរិយសាវកលះបង់លោភ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆាចេញបាន ទើបហៅថាជាអ្នកមានបញ្ញាច្រើន ជាអ្នកមានបញ្ញាទូលំទូលាយ ជាអ្នកឃើញផ្លូវជាអ្នកដល់ព្រមដោយបញ្ញា ។

ម្នាលគហបតី អរិយសាវក រមែងឃើញវត្ថុដែលគួរឃើញ ៤ ប្រការ ដោយការបរិភោគទ្រព្យ ដែលខ្លួនរកបានមក ដោយសេចក្តីព្យាយាម ដែលសន្សំរកបានដោយកម្លាំងស្មុង ដែលធ្វើរហូតដល់ហូរញើសជោកកាយ ប្រកបដោយធម៌ ទើបបានមកហើយដោយត្រឹមត្រូវតាមធម៌ វត្ថុដែលគួរធ្វើ ៤ ប្រការ តើបានដល់វត្ថុអ្វីខ្លះ ? គឺព្រះអរិយ-សាវកក្នុងធម្មវិន័យនេះ បានបរិភោគទ្រព្យដែលរកបានដោយសេចក្តីព្យាយាម ដោយការសន្សំដោយកម្លាំងស្មុងរបស់ខ្លួនឯង និងដោយការធ្វើការ រហូតដល់ហូរញើសជោកកាយ ទើបបានភោគទ្រព្យដែលត្រឹមត្រូវតាមធម៌ ១. បានទ្រព្យមក ដែលត្រឹមត្រូវតាមធម៌ហើយ ចិញ្ចឹមខ្លួនឯងឲ្យជាសុខ ចិញ្ចឹមមាតាបិតាឲ្យជាសុខ ចិញ្ចឹមបុត្រភរិយា បាវព្រាវ

ឲ្យនៅជាសុខ ចិញ្ចឹមមិត្តអាមាត្យឲ្យនៅជាសុខ ។ ២. បានកោគទ្រព្យដែលត្រឹមត្រូវតាមធម៌មកហើយ រមែងការពារនូវអន្តរាយទាំងឡាយដែលកើតមកអំពីភ្លើង ពីទឹក ពីព្រះរាជា ពីចោរ ពីទាយាទដែលជាអ្នករួមមតិក ធ្វើខ្លួនឲ្យរួចផុតភ័យទាំងនោះ ដោយសួស្តី ។ ៣. កោគទ្រព្យដែលបានមកហើយ ត្រឹមត្រូវតាមធម៌ គប្បីធ្វើនូវពលិកម្ម ៥ យ៉ាង បានដល់ ១. **ញាតិពលី** បានដល់ ការសង្គ្រោះញាតិ ២. **អតិថិពលី** បានដល់ ការទទួលភ្ញៀវ ៣. **បុព្វបេតពលី** បានដល់ ការធ្វើបុណ្យឧទ្ទិសដល់អ្នកស្លាប់ ៤. **រាជពលី** បានដល់ ការថ្វាយមានពន្ធអាករជាដើមដល់ព្រះរាជា ៥. **ទេវតាពលី** បានដល់ ការធ្វើបុណ្យឧទ្ទិសដល់ទេវតា ។ ៤. បានកោគទ្រព្យ ដែលត្រឹមត្រូវតាមធម៌ហើយ បរិច្ចាគទានដល់សមណព្រាហ្មណ៍ ដែលជាអ្នកវៀរចាកសេចក្តីប្រមាទ ជាអ្នកមិនបណ្តោតបណ្តោយខ្លួន ជាអ្នកតាំងនៅក្នុងខន្តី និងសោរច្ចៈ ជាអ្នកហ្វឹកហាត់ខ្លួន ជាអ្នកស្ងប់ ជាអ្នករំលត់កិលេសក្នុងខ្លួន ។

ម្នាលគហបតី អរិយសាវកនេះ ឈ្មោះថា ជាអ្នកធ្វើវត្ថុដែលគួរ

ធ្វើ ៤ ប្រការ ដោយភោគទ្រព្យ ដែលរកបានមកដោយសេចក្ដីព្យាយាម និងដែលរកបានមកដោយកម្លាំងស្មង មានការធ្វើការងារ រហូតទៅដល់ហូរញើសជោកខ្លួន ប្រកបក្នុងធម៌ ទើបបានមកដោយត្រឹមត្រូវតាមធម៌ ។ ម្នាលគហបតី ភោគទ្រព្យរបស់អ្នកណា អស់ទៅដោយហេតុដទៃក្រៅពីវត្ថុដែលគួរធ្វើ ៤ ប្រការនេះ ភោគទ្រព្យរបស់អ្នកនោះ អស់ទៅដោយមិនមែនហេតុ អស់ទៅដោយមិនសមគួរ ចាយក្នុងផ្លូវដែលមិនត្រូវ ។ ចំណែកភោគទ្រព្យរបស់អ្នកណា ដល់នូវការអស់ទៅ ដោយការធ្វើវត្ថុដែលធ្វើ ៤ ប្រការនេះ ភោគទ្រព្យរបស់អ្នកនោះ ឈ្មោះថាអស់ទៅដោយហេតុដែលមិនសមគួរ អស់ទៅក្នុងស្ថានទីដែលមិនសមគួរ ចាយក្នុងផ្លូវដែលមិនត្រូវនោះទេ ។ កាលព្រះសាស្ដាត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថាថា ភោគទ្រព្យទាំងឡាយ យើងបានបរិភោគហើយ បុគ្គលគួរចិញ្ចឹម យើងបានចិញ្ចឹមហើយ យើងបានឆ្លងផុតនូវសេចក្ដីអន្តរាយទាំងឡាយហើយ ម្យ៉ាងទៀត ទក្ខិណាទានរបស់យើង ជាទានមានផលច្រើន យើងបានឲ្យហើយ ។ ចំពោះពលីកម្ម ៥ ប្រការ យើង

បានធ្វើហើយ អ្នកដែលមានសីល សង្រួមនៅក្នុងឥន្ទ្រិយ ប្រព្រឹត្តព្រហ្មចារ្យ យើងបានទំនុកបម្រុងហើយ បណ្ឌិតអ្នកនៅគ្រប់គ្រងផ្ទះ គប្បីប្រាថ្នាភោគទ្រព្យដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ យើងបានដល់ហើយតាមលំដាប់ កម្មដែលមិនក្ដៅក្រហាយក្នុងកាលជាខាងក្រោយ យើងបានធ្វើហើយ នរជនដែលត្រូវស្លាប់ កាលពិចារណាដល់ហេតុនេះ ជាអ្នកត្រូវនៅក្នុងធម៌របស់ព្រះអរិយៈ បណ្ឌិតទាំងឡាយរមែងសរសើរគេក្នុងលោកនេះ កាលគេស្លាប់ចាកលោកនេះទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ។

ការប្រារព្ធហេតុយ៉ាងណាទីមួយ ដើម្បីរកឱកាសនឹងធ្វើបុណ្យកុសល ឲ្យកើតផលដែលអ្នកបានធ្វើល្អ អនាថបិណ្ឌិកសេដ្ឋីបានធ្វើទុកជានិទស្សន៍ ជាឧទាហរណ៍ ដូចមានរឿងពោលទុកក្នុង **គម្ពីរមង្គលត្ថទីបនី ឬមង្គលសូត្រ នៃបទទី ១១** ពោលដោយការចិញ្ចឹមមាតាបិតា ។ ដូចមានរឿងពោលថា ស្ត្រីកីលៀងរបស់ក្មេងស្រី ដែលត្រូវជាចៅរបស់អនាថបិណ្ឌិកសេដ្ឋី យកកូនតុក្កតាអំបែងឲ្យដល់ក្មេងស្រីនោះ ពោលថា

អូនតូច យកតុក្កតានេះទៅលេងចុះ ថ្ងៃមួយ ពួកគេលេងតុក្កតាអំបែងនោះ ភ្លាត់ដៃក៏ធ្លាក់បែក ព្រោះសេចក្តីធ្វេសប្រហែស ទើបគេស្រែកយំថា កូនរបស់យើងស្លាប់ហើយ ពេលនោះ ព្រះលោកនាថទ្រង់គង់ប្រថាប់ នៅក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ហើយសូម្បីលោកសេដ្ឋីក៏អង្គុយ គាល់នៅជិតព្រះសាស្តា ស្រ្តីកីលៀងបាននាំក្មេងស្រីដែលកំពុងតែយំ ចូលទៅរកអនាថបិណ្ឌិកសេដ្ឋី ហើយនិយាយប្រាប់រឿងនោះឲ្យលោក សេដ្ឋីបានជ្រាប ។ លោកសេដ្ឋី កាលបានជ្រាបហើយ បានឲ្យចៅស្រី អង្គុយលើភ្លៅ ហើយនិយាយលួងលោមថា តានឹងថ្វាយទានដើម្បីឧទ្ទិស កុសលជូនដល់កូនស្រីរបស់ចៅ ហើយលោកសេដ្ឋីបានក្រាបទូល សេចក្តីនេះដល់ព្រះមានជោគ ហើយក្រាបទូលទៀតថា បពិត្រព្រះអង្គ ដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយទាន ដើម្បីឧទ្ទិសដល់តុក្កតា ដែលជាកូន របស់ចៅស្រីរបស់ខ្ញុំ សូមព្រះសាស្តា ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ មកទទួលចង្ហាន់ក្នុងថ្ងៃស្អែកនេះ ។ ព្រះសាស្តាទ្រង់ទទួលនិមន្តន៍ហើយ ក្នុងថ្ងៃទី ២ ព្រះអង្គបានស្តេចយាងទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី

ព្រមដោយភិក្ខុសង្ឃប្រមាណ ៥០០ រូប បន្ទាប់ពីព្រះអង្គទទួលភត្តរួចហើយ ពេលដែលព្រះអង្គទ្រង់ធ្វើការអនុមោទនាទាន ទើបត្រាស់ព្រះគាថាដូច្នេះថា បុគ្គលណាមិនមានសេចក្តីកំណាញ់ ធ្វើហេតុយ៉ាងណានីមួយឲ្យជាអារម្មណ៍ ប្រារព្ធនូវបុព្វការីជនដែលស្លាប់ទៅហើយ ទេវតាដែលស្ថិតនៅក្នុងទីទាំងឡាយ ឬមហារាជដែលជាលោកបាលទាំង ៤ ទិស **គឺព្រះបាទកុវេរៈ ព្រះបាទធតរដ្ឋៈ ព្រះបាទវិរូបក្ខៈ ព្រះបាទវិរុឡ្ហកៈ** ហើយគប្បីថ្វាយទាន បុព្វការីជន និងទេវតាទាំងឡាយជាដើមនោះ រមែងជាអ្នកដែលគេបូជាហើយ រមែងមិនឥតផលឡើយ ។ ការយំស្រែក សេចក្តីសោយសោក ឬសេចក្តីខ្សឹកខ្សួលយ៉ាងណានីមួយ បុគ្គលមិនគប្បីធ្វើឡើយ ព្រោះការយំជាដើមនោះ ជារបស់មិនមានប្រយោជន៍ដល់ជនដែលស្លាប់ទៅហើយទេ ញាតិទាំងឡាយ រមែងតាំងនៅយ៉ាងនោះដដែល ។ ទក្ខិណាទាននេះឯង ដែលគេឲ្យហើយ ឈ្មោះថា តាំងទុកដោយល្អហើយក្នុងសង្ឃ រមែងសម្រេចប្រយោជន៍ដ៏ប្រសើរ ដល់អ្នកដែលស្លាប់ទៅហើយ អស់កាលដ៏យូរអង្វែងតាមឋានៈ ។

អនាថបិណ្ឌិកសេដ្ឋី បានប្រើឧបាយធ្វើឲ្យកូនប្រុសរបស់លោកចូលវត្ត បានសម្រេចតាមការតាំងចិត្ត ដូចដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **លោកវគ្គ** ក្នុងរឿងនាយកាឡៈ ដែលជាកូនរបស់អនាថបិណ្ឌិកសេដ្ឋី ដូចមានរឿងពោលទុកថា ៖-

ក្នុងសម័យមួយ ព្រះលោកនាយក ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់ប្រារព្ធនាយកាឡៈ ដែលជាកូនរបស់អនាថបិណ្ឌិកសេដ្ឋី ហើយទ្រង់ត្រាស់ព្រះធម៌ទេសនាប្រោសដល់ពុទ្ធបរិស័ទគ្រានោះផងដែរ ។ នាយកាឡៈជាកូនរបស់អនាថបិណ្ឌិកសេដ្ឋីដែលលោកសេដ្ឋីដល់ព្រមដោយសទ្ធា គឺការជឿមាំទាំហើយ តែនាយកាឡៈមិនប្រាថ្នា ដើម្បីនឹងទៅកាន់សម្នាក់របស់ព្រះបរមសាស្តាឡើយ ថែមទាំងមានបំណងមិនចង់ឃើញព្រះមានជោគ ពេលព្រះអង្គស្តេចយាងមកកាន់ផ្ទះរបស់ខ្លួន មិនត្រូវការដើម្បីនឹងស្តាប់ធម៌ និងមិនរីករាយក្នុងការធ្វើបដិសណ្ឋារៈដល់ភិក្ខុសង្ឃ សូម្បីត្រូវបិតានិយាយថា កូនចូរធ្វើយ៉ាងនេះ គេក៏មិនជឿស្តាប់ពាក្យរបស់លោកសេដ្ឋី ។ ដោយហេតុ

ដូច្នេះ អនាថបិណ្ឌិកសេដ្ឋីពិចារណាថា កាឡៈកូនរបស់យើង កាល ប្រកាន់ទិដ្ឋិរឹងត្អឹងយ៉ាងនេះតទៅ ក្នុងកាលខាងមុខ ( កាលអស់ជីវិត ) នឹងទៅកាន់អវិចីនរក ដែលយើងដឹងដូច្នេះហើយ ក្នុងជំណើររបស់កូន យើង ដែលនឹងទៅកាន់នរកនោះ យើងមិនគួរនឹងបណ្តែតបណ្តោយ ឲ្យគេទៅជាយ៉ាងនោះទេ ដែលបានឈ្មោះថាសត្វ ជាអ្នកមិនប្រាថ្នាចង់ បានទ្រព្យសម្បត្តិនោះ រមែងមិនមានឡើយ យើងគួរនឹងប្រើវិធីក្នុងការ បំណាយទ្រព្យ ដើម្បីទម្លាយនូវទិដ្ឋិ ដ៏រឹងត្អឹងរបស់កូនយើង ។ កាល អនាថបិណ្ឌិកសេដ្ឋីគិតឃើញយ៉ាងនេះហើយ ទើបនិយាយនឹងនាយ កាឡៈថា នៃកាឡៈកូនប្រុសឪពុក កូនចូរជាអ្នករក្សាឧបោសថសីល ហើយទៅកាន់វិហារដើម្បីស្តាប់ព្រះធម៌ទេសនាចុះ ពុកនឹងឲ្យកហាបណៈ ដល់កូន ១០០ កហាបណៈ ។

នាយកាឡៈសួរថា លោកឪពុក នឹងឲ្យកហាបណៈដល់កូនពិត មែនឬ ? អនាថបិណ្ឌិកសេដ្ឋីតបថា ពុកនឹងឲ្យកហាបណៈដល់កូនពិតៗ ។ នាយកាឡៈបានទទួលប្តេជ្ញា ហើយបានជាអ្នករក្សាឧបោសថសីល និង

ទៅវត្តស្តាប់ព្រះធម៌ ។ តែកិច្ច គឺការស្តាប់ព្រះធម៌នោះ គេមិនបាន ធ្វើតាមឡើយ ព្រោះគេបានទៅដេកលក់ក្នុងកន្លែងមួយ លុះព្រឹកឡើង គេទើបក្រោកឡើងត្រឡប់ទៅផ្ទះវិញ ។ អនាថបិណ្ឌិកសេដ្ឋី បានប្រាប់ អ្នកបម្រើថា កូនរបស់យើង ទើបមកពីការរក្សាឧបោសថសីល ហេតុ ដូច្នេះ អ្នកទាំងឡាយចូរលើកបបរជាដើមមក ឲ្យកូនរបស់យើងដោយ រហ័ស ចំណែកនាយកាឡៈ បានពោលបដិសេធមិនទាន់ព្រមទទួល អាហារ ដោយនិយាយទារថ្លៃឈ្នួលថា បើកូនមិនទាន់បានទទួល កហាបណៈទេ កូននឹងមិនព្រមបរិភោគអាហារ ។ លោកសេដ្ឋី កាល បានស្តាប់ពាក្យនិយាយរបស់កូនប្រុសដូច្នេះហើយ ទើបឲ្យទៅយក កហាបណៈ តាមដែលសន្យាទុកមកឲ្យ ។ នាយកាឡៈ លុះបាន ទទួលកហាបណៈហើយ ទើបបរិភោគអាហារនោះ តមកថ្ងៃរះឡើង លោកសេដ្ឋី បានប្រាប់ឲ្យនាយកាឡៈទៅដោយពោលថា នែកូនប្រុស ឪពុកនឹងឲ្យកហាបណៈ ១០០០ ដល់កូន តែកូនត្រូវឈរចំពោះ ព្រះភក្ត្រនៃព្រះសម្ពុទ្ធ និងរៀនយកព្រះធម៌ ឬស្តាប់ធម៌ឲ្យបានមួយបទ

ហើយត្រឡប់មក ។ នាយកាឡៈបានយល់ព្រម ហើយទៅកាន់វិហារ ចូលទៅឈរចំពោះព្រះភក្ត្រនៃព្រះសាស្តា ក្នុងបំណងដើម្បីនឹងស្តាប់ព្រះធម៌ឲ្យចាំត្រឹមតែមួយបទប៉ុណ្ណោះ នឹងត្រឡប់មកវិញ ។ លំដាប់នោះ ព្រះលោកនាយក ទ្រង់ជ្រាប ទ្រង់បានធ្វើឲ្យនាយកាឡៈមិនអាចស្តាប់ចាំបានសូម្បីត្រឹមតែមួយបទ ។ ទោះបីនាយកាឡៈ ប្រឹងស្តាប់យ៉ាងណាក៏នៅតែមិនចាំ ទើបបានឈរស្តាប់តទៅទៀត ដោយតាំងចិត្តថា យើងនឹងប្រឹងស្តាប់ឲ្យចាំមួយបទទាល់តែបាន ។ កាលបុគ្គលបានតាំងចិត្តស្តាប់ព្រះធម៌ ដោយគិតថា យើងនឹងស្តាប់ឲ្យចាំ ដូច្នេះឈ្មោះថា ស្តាប់ព្រះធម៌ដោយសេចក្តីគោរព កាលបើបុគ្គលតាំងចិត្តស្តាប់ព្រះធម៌ដោយសេចក្តីគោរពយ៉ាងនេះហើយ រមែងឲ្យដល់នូវសោតាបត្តិមគ្គ ( ផ្លូវបដិបត្តិដែលឲ្យសម្រេចផល ជាព្រះសោតាបន្ន ) ជាដើម ។

សូម្បីនាយកាឡៈ ក៏ស្តាប់ធម៌ដោយគិតថា យើងនឹងស្តាប់ព្រះធម៌ឲ្យចាំមួយបទទាល់តែបាន ។ ព្រះទសពល ទ្រង់ជ្រាបដល់ឆន្ទៈរបស់នាយកាឡៈដូច្នេះហើយ ក៏ធ្វើឲ្យនាយកាឡៈចាំមិនបាន ។ ខណៈ

ដែលនាយកាឡៈកំពុងតែឈរស្តាប់ដោយការប៉ងក្នុងចិត្តថា យើងនឹងស្តាប់តទៅទៀតឲ្យចាំ ការតាំងចិត្តយ៉ាងនេះ ក៏ធ្វើឲ្យចិត្តរបស់នាយកាឡៈស្ងប់ មានចិត្តបង្អោនទៅតាមក្រសែនៃព្រះធម៌ រហូតបានសម្រេចនូវសោតាបត្តិផល ( ផលដែលចូលដល់ក្រសែនៃធម៌ ឬក្រសែនៃព្រះនិព្វាន) ។ លុះថ្ងៃរះឡើង នាយកាឡៈបានត្រឡប់ពីវត្តចូលទៅកាន់ក្រុងសាវត្ថី ព្រមដោយភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដើម្បីស្តេចយាងទៅកាន់និវេសន៍ របស់អនាថបិណ្ឌិកសេដ្ឋី ។ លោកសេដ្ឋីលុះក្រឡេកឃើញនាយកាឡៈ ដែលជាកូនប្រុសរបស់ខ្លួនហើយ ទើបគិតថា ថ្ងៃនេះ យើងពេញចិត្តចំពោះអាកប្បកិរិយារបស់កូនយើងណាស់ ។ ចំណែកនាយកាឡៈ បានមានបរិវិតក្ក គឺនឹកភ័យព្រួយក្នុងចិត្តថា ថ្ងៃនេះលោកឪពុករបស់យើងមិនគប្បីឲ្យកហាបណៈ នៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ គប្បីជួយបិទបាំងយើង ដែលជាអ្នករក្សាឧបោសថសីលព្រោះហេតុនៃការចង់បានកហាបណៈ តែប៉ុណ្ណោះ ។ សេចក្តីពិតរឿងទាំងអស់នោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជ្រាបថា នាយកាឡៈ ជាអ្នក

រក្សាឧបោសថសីល ព្រោះហេតុនៃការចង់បានកហាបណៈតាំងអំពីម្សិលមិញមកហើយ ។ កាលលោកសេដ្ឋី ឲ្យប្រគេនយាគូដល់ភិក្ខុសង្ឃដែលមានព្រះភគវាជាប្រធានរួចស្រេចហើយ ទើបឲ្យគេលើកបបរមកឲ្យដល់នាយកាឡៈ ។ចំណែកនាយកាឡៈក៏អង្គុយនៅស្ងៀម ដូចបុគ្គលដែលមានការកង្វល់ក្នុងចិត្ត កាលលើកបបរមកដល់ក៏បរិភោគ ដោយមិនទាររកកហាបណៈដូចថ្ងៃមុនទៀត ។ ពេលស្រេចភត្តកិច្ចនៃព្រះភគវាហើយ អនាថបិណ្ឌិកសេដ្ឋី ទើបប្រើអ្នកបម្រើឲ្យទៅយកកហាបណៈ ១០០០ យកមកឲ្យនាយកាឡៈ ហើយពោលថា កាឡៈកូនជាទីស្រឡាញ់ ពុកនិយាយថា នឹងឲ្យកហាបណៈ ១០០០ ដល់កូន ទើបឲ្យកូនទៅសមាទានឧបោសថសីលនៅឯវត្ត និងស្តាប់ព្រះធម៌ នេះកហាបណៈ ១០០០ របស់កូន ហេតុដូច្នេះ ចូរកូនយកទៅចុះ ។ នាយកាឡៈបានក្រឡេកឃើញកហាបណៈ ដែលឪពុកឲ្យនៅចំពោះព្រះភក្ត្រនៃព្រះសាស្តា ក៏កើតការអៀនខ្មាសឡើង ទើបពោលថា បពិត្រលោកឪពុក ខ្ញុំលែងត្រូវការកហាបណៈទៀតហើយ ។ សូមរឺអនាថបិណ្ឌិកសេដ្ឋីពោល

ទទូចអង្វរថា ចូរកូនទទួលយកទៅចុះ គេក៏មិនព្រមទទួលយក ។

កាលអនាថបិណ្ឌិកសេដ្ឋី ឃើញកូនប្រុសរបស់ខ្លួនមិនព្រមទទួលយក ទើបក្រាបបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ខ្ញុំព្រះអង្គពេញចិត្តចំពោះអាការៈនៃកូនប្រុសរបស់ខ្ញុំព្រះករុណាព្រះអង្គ ។ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតីមានហេតុការណ៍អ្វីឬ ? អនាថបិណ្ឌិកសេដ្ឋីក្រាបទូលតបថា ក្នុងថ្ងៃមុនខ្ញុំព្រះអង្គបានសន្យាថា ពុកនឹងឲ្យកហាបណៈដល់កូន ១០០ កហាបណៈ ហើយឲ្យទៅសមាទានឧបោសថសីលនៅឯវត្ត លុះដល់ថ្ងៃរះឡើង គេត្រឡប់មកដល់ផ្ទះវិញ កាលបើមិនទាន់បានកហាបណៈ គេក៏មិនព្រមបរិភោគអាហារដែរ តែថ្ងៃនេះ គេមិនត្រូវការកហាបណៈ សូម្បីទាំងដែលខ្ញុំព្រះអង្គឲ្យ ឬពោលអង្វរយ៉ាងណាក៏មិនព្រមដែរ ព្រះអង្គ ។ គ្រានោះ ព្រះមានជោគត្រាស់ថា ត្រូវហើយគហបតី សោតាបត្តិផលរបស់បុត្រលោក ប្រសើរជាងសម្បត្តិរបស់ស្តេចចក្រពត្តិ សម្បត្តិក្នុងទេវលោក និងប្រសើរជាងសម្បត្តិក្នុងព្រហ្មលោក ហើយព្រះអង្គត្រាស់

ព្រះគាថាថា សោតាបត្តិផលប្រសើរជាងឯករាជ្យលើផែនដី ប្រសើរជាងការទៅកាន់ស្ថានសួគ៌ និងប្រសើរជាងអធិបតីភាពក្នុងលោកទាំងមូល ។

តាមអត្ថន័យ ដែលអដ្ឋកថាចារ្យបានអធិប្បាយទុកថា ព្រះរាជាសូម្បីសោយរាជសម្បត្តិ ក្នុងទីមានប្រមាណប៉ុនណាៗ ក៏ដោយ រមែងជាអ្នកមិនអាចរួចផុតអំពីនរកបានឡើយ ។ ចំណែកព្រះសោតាបន្ន ជាអ្នកបិទទ្វារអបាយភូមិបានហើយ ព្រោះដូច្នោះ សោតាបត្តិផល ទើបប្រសើរឧត្តមជាងភាពជាស្តេចចក្រពត្តិ ឬជាងដំណើរទៅកាន់ស្ថានសួគ៌ ២៦ជាន់ និងភាពជាធំក្នុងលោកទាំងពួង ។

អនាថបិណ្ឌិកសេដ្ឋី បានជួយសង្គ្រោះទាសីរបស់លោក ដោយការជួយចាត់ចែងបូជាសពរបស់ទាសីឲ្យរៀបរយ ទាំងនេះក៏ជាគំរូដ៏ល្អដែលចៅហ្វាយនាយត្រូវតែអនុគ្រោះដល់បាវព្រាវក្នុងគ្រាមានទុក្ខ ដូចដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាជាតក** ដែលពង្រីកសេចក្តីបាលីនៃ **រោហិណីជាតក** ក្នុងគម្ពីរខុទ្ទកនិកាយជាតក ដូចមានសេចក្តីថា ៈ-

សម័យមួយ ព្រះបរមសាស្ដា ទ្រង់គង់ប្រថាប់នៅវត្តជេតពន ទ្រង់បានត្រាស់ព្រះធម៌ទេសនា រឿងអមិត្តប្រសើរជាង ដោយទ្រង់ប្រារព្ធទាសីម្នាក់របស់អនាថបិណ្ឌិកសេដ្ឋី ដូចមានរឿងពោលថា នាងរោហិណីជាទាសីរបស់អនាថបិណ្ឌិកសេដ្ឋី នាងមានម្ដាយចាស់ជរាមកដេកនៅក្នុងរោងបុកស្រូវ រុយទាំងឡាយមករោមចំពោះម្ដាយរបស់នាងយ៉ាងច្រើន បីដូចម្ជុលចាក់ ម្ដាយទើបប្រាប់នាងរោហិណីឲ្យជួយដេញរុយឲ្យ នាងរោហិណីគិតនឹងសម្លាប់រុយទាំងនោះឲ្យស្លាប់អស់ ហើយទើបលើកអង្រែវាយចំពោះរុយ ក៏ចំមាតា មាតារបស់នាងក៏ស្លាប់ទៅ កាលនាងរោហិណីដឹងដូច្នោះហើយ ក៏បានយំសោកខ្សឹកខ្សួល ដោយរៀបរាប់ថា មាតារបស់យើងស្លាប់ទៅហើយ ។ មនុស្សទាំងឡាយទើបនាំយករឿងនោះទៅប្រាប់អនាថបិណ្ឌិកសេដ្ឋី កាលលោកសេដ្ឋីបានជ្រាបហើយ បានឲ្យនាំគ្នាចាត់ចែងបូជាសពរបស់ម្ដាយនាងរោហិណី ហើយលោកសេដ្ឋីក៏បានទៅឯវត្តជេតពន ដោយក្រាបទូលរឿងនេះថ្វាយព្រះបរមសាស្ដាឲ្យទ្រង់ជ្រាប ។

កាលព្រះសម្ពុទ្ធទ្រង់ជ្រាប ទើបត្រាស់ថា ម្នាលគហបតី ស្រីនេះបានធ្លាប់សម្លាប់មាតា ដោយអង្រែដោយគិតថា នឹងសម្លាប់រុយត្រង់ខ្លួនមាតា មិនមែនមានតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់មានដែរ កាលព្រះពុទ្ធអង្គត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់សម្តែងរឿងក្នុងអតីតកាលថា

ក្នុងអតីតកាល ក្នុងរាជសម័យរបស់ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី សម័យនោះ ព្រះពោធិសត្វកើតនៅក្នុងត្រកូលសេដ្ឋី កាលបិតាស្លាប់ទៅហើយ ក៏បានទទួលតំណែងជាសេដ្ឋីជំនួសបិតា ហើយព្រះពោធិសត្វមាននាងរោហិណីជាទាសី ។ សម័យមួយ មាតារបស់នាងរោហិណី មកដេកនៅត្រង់រោងបុកអង្ករ បានប្រាប់ឲ្យនាងរោហិណីដែលជាកូនស្រី ដេញរុយដែលមករោម នាងរោហិណីក៏វាយរុយដោយអង្រែបុកអង្ករ ក៏ចំម្តាយរហូតដល់អស់ជីវិត កាលនាងដឹងថា ម្តាយរបស់នាងស្លាប់ហើយ នាងក៏យំសោកស្តាយចំពោះមាតា ។ គ្រានោះ ព្រះពោធិសត្វបានដឹងរឿងនោះហើយ ក៏ត្រិះរិះថា

ក្នុងលោកនេះ បណ្ឌិតសូម្បីជាសត្រូវ គង់ប្រសើរជាង ហើយពោលព្រះគាថាថា

សត្រូវ ( អមិត្ត ) ដែលមានបញ្ញាប្រសើរជាងបុគ្គល ដែលល្ងង់ខ្លៅ ដែលជាមិត្ត មានចិត្តគិតអនុគ្រោះ ចូរមើលនាងរោហិណីដ៏អាក្រក់ (ល្ងង់ខ្លៅ) នាងសម្លាប់មាតារបស់ខ្លួន ហើយសោយសោក ។

ព្រះលោកនាថ ទើបត្រាស់នឹងអនាថបិណ្ឌិកសេដ្ឋីតទៅទៀតថា ម្នាលគហបតី ស្រីនេះសម្លាប់មាតា ដោយយល់ថា នឹងសម្លាប់រុយមិនមែនមានតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន គេក៏សម្លាប់មានសភាពដូចគ្នាក្នុងកាលនេះឯង ហើយព្រះពុទ្ធអង្គទ្រង់ប្រមូលអតីតនិទានជាតកថា

មាតាក្នុងកាលនោះ បានមកជាមាតាក្នុងបច្ចុប្បន្នជាតិនេះ រីឯនាងរោហិណីក្នុងកាលនោះ ក៏បានមកជានាងរោហិណីក្នុងបច្ចុប្បន្នជាតិនេះដូចគ្នា ចំណែកព្រះពោធិសត្វ ដែលជាមហាសេដ្ឋី ឬដែលជាចៅហ្វាយរបស់នាងក្នុងកាលនោះ គឺជាតថាគតនេះឯង ។ នេះជានាទីរបស់ចៅហ្វាយ

ដែលល្អ ដែលជាអ្នកមានគុណធម៌ ក្នុងឋានៈជាចៅហ្វាយ ដោយបាន ជួយអើពើឧបការៈចំពោះបាវព្រាវ ក្នុងឋានៈជាអ្នកបម្រើ ដែលដល់នូវ សេចក្តីទុក្ខលំបាក និងជាឧទាហរណ៍ឲ្យដឹងថា មនុស្សក្នុងពុទ្ធសម័យ ដែលព្រះអង្គទ្រង់ធរមាននៅ ក៏មានធ្វើការបូជាសព ។

សម័យមួយ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅក្រាបទូលសួរ ចំពោះចំណុចបដិបត្តិ ក្នុងការជ្រើសរើស ឬការរាប់អានភិក្ខុ ចំពោះ ព្រះមានព្រះភាគ ដូចមានរឿងដែលពោលទុកនៅក្នុង **គម្ពីរមហាវគ្គ ព្រះវិន័យបិដក នៃកោសម្ពីខន្ធកៈ** មានសេចក្តីថា ៖-

សម័យមួយ អនាថបិណ្ឌិកសេដ្ឋីបានជ្រាបដំណឹងថា ភិក្ខុដែល នៅក្នុងក្រុងកោសម្ពី ដែលជាអ្នកបង្ករឿងឈ្លោះទាស់ទែងគ្នា បង្កវិវាទ ធ្វើការប្រេះឆា បង្កអធិករណ៍ក្នុងសង្ឃទាំងនោះ នាំគ្នាមកកាន់ក្រុង សាវត្ថី ទើបចូលទៅក្នុងពុទ្ធសម្នាក់ ថ្វាយបង្គំព្រះសាស្តារួចហើយ ក៏បានអង្គុយនៅក្នុងទីដ៏សមគួរ ទើបក្រាបទូលសួរខ.បដិបត្តិនេះនឹងព្រះ ទសពលថា ខ្ញុំព្រះអង្គបានជ្រាបដំណឹងមកថា ភិក្ខុនៅក្នុងក្រុងកោសម្ពី

បានបន្តរឿងបៀតបៀនគ្នា បន្តការឈ្លោះវិវាទ ទាស់ទែងគ្នា និងធ្វើការប្រេះឆា បន្តអធិករណ៍ក្នុងសង្ឃទាំងនោះ បាននាំគ្នាមកកាន់ក្រុងសាវត្ថី ខ្ញុំព្រះអង្គនឹងបដិបត្តិចំពោះភិក្ខុទាំងនោះដូចម្តេច ព្រះអង្គ ? ព្រះសាស្តាទ្រង់ត្រាស់ណែនាំថា ម្នាលគហបតី បើដូច្នោះ អ្នកចូរថ្វាយទានចំពោះភិក្ខុទាំងពីរចំណែកនោះ កាលបើអ្នកថ្វាយទានដល់ភិក្ខុទាំងពីរចំណែកនោះហើយ អ្នកចូរស្តាប់ធម៌ ក្នុងសម្នាក់ភិក្ខុទាំងពីរចំណែកនោះសិន កាលលោកស្តាប់ធម៌ របស់ភិក្ខុទាំងពីរចំណែកនោះ ហើយ ( ចូរអ្នកពិនិត្យពិចារណាមើល ) ពួកភិក្ខុណាក្នុងចំណែកទាំងពីរនោះ ជាធម្មវាទី ( អ្នកពោលតាមធម៌ ) អ្នកចូរពេញចិត្តក្នុងការឃើញ និងការជឿកាន់យកតាមភិក្ខុដែលជាធម្មវាទីនោះចុះ ( នេះជាវិធីការជ្រើសរើសរាប់អានភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ត្រូវមើលធម៌វិន័យ ដែលលោកប្រព្រឹត្តប្រតិបត្តិជាគោល ) ។

ភាពជាអ្នកមានការចេះដឹង ក្នុងគោលធម៌របស់អនាថបិណ្ឌិកសេដ្ឋី រហូតអាចអធិប្បាយគោលធម៌ ក្នុងព្រះសាសនានេះឲ្យពួកអន្យតិរ្ថិយ

និងបរិព្វាជកឲ្យអស់ផ្លូវ ( ក្នុងការ ) លើកវាទៈ និងបានទទួលការលើកតម្កើងអំពីព្រះសយម្ភូ ដូចដែលមានរឿងសម្ដែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ទសកនិបាត ក្នុងទិដ្ឋិសូត្រ** ( ព្រះសូត្រដែលពោលដោយការយល់ឃើញផ្សេងៗ ) **នៃឧបាសកវគ្គ** មានសេចក្ដីថា ៖-

សម័យមួយ ព្រះមហាវីរៈ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីបានចេញពីក្រុងសាវត្ថី ក្នុងពេលថ្ងៃត្រង់ ដើម្បីនឹងចូលទៅគាល់ព្រះភគវា តែលោកសេដ្ឋីបែរជាគិតថា ពេលនេះ មិនមែនជាពេលគួរនឹងចូលទៅគាល់ព្រះសម្ពុទ្ធទេ ព្រោះព្រះភគវា ព្រះអង្គពួនសំងំក្នុងទីស្ងាត់ និងមិនមែនជាពេលវេលានឹងទៅសួរសុខទុក្ខភិក្ខុសង្ឃទាំងឡាយដែរ ដែលជាអ្នកមានប្រក្រតីចម្រើនទៅដោយវិវេក ហើយជាអ្នកពួនសំងំនៅក្នុងទីស្ងាត់ កុំដូច្នោះឡើយ យើងនឹងចៀងទៅកាន់លំនៅរបស់ពួកអន្យតិរ្ថិយ និងបរិព្វាជកល្អជាង លុះអនាថបិណ្ឌិកសេដ្ឋីគិតឃើញដូច្នេះហើយ ទើបចូលទៅកាន់លំនៅរបស់ពួកអន្យតិរ្ថិយ និងបរិព្វាជក ក្នុងកាលនោះ ពួកអន្យតិរ្ថិយ

និងបរិព្វាជកកំពុងតែប្រជុំគ្នា មានសំឡេងអ៊ូអរ ដោយអង្គុយនិយាយគ្នា ក្នុងរឿងតិរច្ឆានកថាផ្សេងៗ លុះពួកអន្យតិរ្ថិយ និងបរិព្វាជកទាំងនោះ បានក្រឡេកឃើញអនាថបិណ្ឌិកសេដ្ឋីដើរមកអំពីចម្ងាយ ក៏ឲ្យសញ្ញាគ្នាថា អ្នកទាំងអស់គ្នាចូរនិយាយសំឡេងតិចៗ កុំនិយាយសំឡេងខ្លាំងៗ ឡើយ ព្រោះអនាថបិណ្ឌិកសេដ្ឋីនេះ ជាសាវ័ករបស់ព្រះសមណគោតម សាវ័កព្រះសមណគោតម សុទ្ធតែចូលចិត្តនិយាយសំឡេងតិចៗ បានទទួលការណែនាំឲ្យធ្វើសំឡេងតិច ពោលសរសើរសំឡេងតិច ទោះយ៉ាងនោះក៏ដោយ គាត់ឃើញទីប្រជុំរបស់ពួកយើងមានសំឡេងតិច គាត់ប្រាកដជាចូលមករក ។ ពេលនោះ ពួកបរិព្វាជកទាំងនោះក៏នាំគ្នានៅស្ងៀម ។ គ្រានោះ លោកសេដ្ឋី បានចៀងចូលទៅរកពួកបរិព្វាជកទាំងនោះដល់ទីលំនៅ បានអង្គុយចុះ សន្ទនាប្រាស្រ័យចរចាជាមួយគ្នា នឹងពួកបរិព្វាជកទាំងនោះ ដោយពាក្យសម្តីដែលគួររឭកដល់គ្នានិងគ្នា ។ រួចស្រេចហើយ ពួកបរិព្វាជកទាំងនោះ បានពោលជាមួយអនាថបិណ្ឌិកសេដ្ឋីថា ម្នាលគហបតី សូមលោកជួយប្រាប់ផងចុះថា ព្រះសមណគោតម មានការ

យល់ឃើញដូចម្តេច ? អនាថបិណ្ឌិកសេដ្ឋីឆ្លើយថា អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំមិនជ្រាបដល់ការយល់ឃើញ របស់ព្រះមានជោគទាំងអស់នោះទេ ។

ពួកបរិព្វាជកទើបពោលថា ម្នាលគហបតី កាលលោកមិនជ្រាបដល់ការយល់ឃើញទាំងអស់ របស់ព្រះសមណគោតម ក៏មិនជាអ្វី តែសូមលោកជួយប្រាប់ផងចុះថា ភិក្ខុទាំងឡាយមានការយល់ឃើញដូចម្តេច ? អនាថបិណ្ឌិកសេដ្ឋីតបថា អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំមិនជ្រាបដល់ការយល់ឃើញទាំងអស់ របស់ភិក្ខុទាំងនោះដូចគ្នា ។ ពួកបរិព្វាជកបានពោលតទៅទៀតថា ម្នាលគហបតី បើលោកមិនជ្រាបដល់ការយល់ឃើញទាំងអស់ របស់ព្រះសមណគោតម និងការយល់ឃើញទាំងអស់ របស់ភិក្ខុទាំងឡាយក៏មិនជាអ្វី តែខ្លួនលោកមានការយល់ឃើញដូចម្តេច ? គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានពោលថា អ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំមានការយល់ឃើញយ៉ាងណា ការយល់ឃើញយ៉ាងនោះ ខ្ញុំប្រាប់បានមិនលំបាកទេ តែចង់អញ្ជើញលោកទាំងអស់គ្នាប្រាប់ការយល់ឃើញ របស់លោកទាំងឡាយ ឲ្យខ្ញុំបានស្តាប់សិន

ហើយខ្ញុំទើបនឹងប្រាប់ដល់ការយល់ឃើញរបស់ខ្ញុំ ឲ្យលោកទាំងឡាយបានជ្រាបជាខាងក្រោយ មិនមែនជាការលំបាកទេ ។ កាលអនាថបិណ្ឌិក-សេដ្ឋីពោលយ៉ាងនេះហើយ បរិព្វាជកម្នាក់បានពោលនឹងអនាថបិណ្ឌិកសេដ្ឋីថា ម្នាលគហបតី យើងមានការយល់ឃើញថា លោកនេះទៀងការយល់ឃើញបែបនេះឯងពិត ការយល់ឃើញដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀត បានពោលជំទាស់នឹងអ្នកទី ១ ថា ម្នាលគហបតី យើងមានការយល់ឃើញថា លោកមិនស្ថិតស្ថេរ វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀតពោលថា ម្នាលគហបតី យើងមានការយល់ឃើញថា លោកមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ បរិព្វាជកដទៃទៀត ពោលផ្ទុយគ្នាថា ម្នាលគហបតី យើងមានសេចក្តីយល់ឃើញថា លោកមិនមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។

បរិព្វាជកម្នាក់ទៀត ទើបពោលថា ម្នាលគហបតីយើងមានការយល់ឃើញថា ជីវៈ និងសរីរៈដូចគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀត

មិនពិត ។ បរិព្វាជកម្នាក់ទៀតពោលជំទាស់នឹងបរិព្វាជក ដែលពោលរួចមកហើយថា ម្នាលគហបតី យើងមានការយល់ឃើញថា ជីវៈ និងសរីរៈជារបស់ផ្សេងគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត ។ បរិព្វាជកម្នាក់ទៀតពោលផ្ទុយគ្នានឹងបរិព្វាជកមុនៗ ថា ម្នាលគហបតី យើងមានការយល់ឃើញថា សត្វស្លាប់ហើយកើតទៀត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀតបានពោលផ្ទុយនឹងបរិព្វាជកមុនថា ម្នាលគហបតី យើងមានការយល់ឃើញថា សត្វស្លាប់ទៅហើយមិនកើតទៀត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ បរិព្វាជកម្នាក់ទៀតពោលថា ម្នាលគហបតី យើងមានការយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ កាលពួកបរិព្វាជកបានសម្តែងការយល់ឃើញរបស់ខ្លួនម្នាក់ម្យ៉ាងៗ សុទ្ធតែជំទាស់គ្នាឯងយ៉ាងនេះហើយ អនាថបិណ្ឌិកសេដ្ឋីទើបពោលនឹងបរិព្វាជកទាំងនោះថា អ្នកដ៏ចម្រើនទាំងឡាយ អ្នកណាពោលថា យើងយល់ឃើញថា លោកស្ថិតស្ថេរ វត្ថុនេះប៉ុណ្ណោះពិត

វត្ថុដទៃទៀតមិនពិត ការយល់ឃើញរបស់អ្នកនោះ កើតឡើងហើយ ព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត ដោយមិនត្រូវឧបាយរបស់ខ្លួនខ្លះ ឬព្រោះជឿស្តាប់ការឃោសនារបស់អ្នកដទៃជាបច្ច័យខ្លះ ការឃើញបែបនេះឯង កើតឡើងហើយ ដែលអាស្រ័យបច្ច័យតាក់តែងហើយ ដែលបច្ច័យក.ឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ មិនថាវត្ថុណានីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែលបច្ច័យក.ឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្ថុនោះមិនទៀង វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ អ្នកនោះក៏ជ្រាបនៅហ្នឹងវត្ថុនោះ អ្នកនោះក៏ចូលដល់នូវវត្ថុនោះឯង ។ អ្នកណាពោលថា យើងមានការយល់ឃើញថា លោកមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា លោកមិនមានទីបំផុត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។

អ្នកណាពោលថា យើងមានការយល់ឃើញថា ជីវៈ និងសរីរៈតែមួយដូចគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណា

ពោលថា យើងមានការយល់ឃើញថា ជីវៈ និងសរីរៈជារបស់ផ្សេងគ្នា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា សត្វទាំងឡាយស្លាប់ហើយ កើតទៀត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា សត្វស្លាប់ហើយមិនកើតទៀត វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ អ្នកណាពោលថា យើងមានការយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ល។ បុគ្គលណាពោលថា យើងមានការយល់ឃើញថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទៀតមិនពិត ។ ការយល់ឃើញរបស់អ្នកទាំងអស់នេះ កើតឡើងហើយព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត ដោយឧបាយមិនប្រពៃរបស់ខ្លួនខ្លះ ឬព្រោះជឿការឃោសនារបស់អ្នកដទៃជាបច្ច័យខ្លះ ការឃើញនេះឯងកើតឡើងហើយ ដែលអាស្រ័យបច្ច័យតាក់តែងហើយ ដែលបច្ច័យ

ក.ឡើងហើយ កើតឡើងហើយព្រោះអាស្រ័យបច្ច័យ មិនថា វត្ថុណា
នីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែល
បច្ច័យ.កឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្ថុនោះមិនទៀង
វត្ថុណាមិនទៀង វត្ថុនោះក៏ជាទុក្ខ ជាទីជាប់នៅរបស់បុរសនោះ ។
ការឃើញរបស់អ្នកទាំងអស់ កើតឡើងព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត
ដោយឧបាយមិនត្រូវទំនងរបស់ខ្លួនខ្លះ ព្រោះជឿការឃោសនារបស់
អ្នកដទៃខ្លះ ។

កាលអនាថបិណ្ឌិកសេដ្ឋីពោលយ៉ាងនេះហើយ ពួកបរិព្វាជក
ទាំងនោះ បានពោលថា ម្នាលគហបតី ពួកយើងទាំងអស់គ្នា បានប្រាប់
ដល់ការយល់ឃើញរៀងៗខ្លួន ឲ្យលោកបានស្តាប់ហើយ នៃគហបតី
ការយល់ឃើញរបស់លោកដូចម្តេច ចូរប្រាប់ឲ្យពួកយើងខ្ញុំ បានជ្រាប
ខ្លះផង ? អនាថបិណ្ឌិកសេដ្ឋីពោលបញ្ជាក់ថា អ្នកដ៏ចម្រើនទាំងឡាយ
ក៏វត្ថុណានីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ
ដែលបច្ច័យ.កឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្ថុនោះ

មិនទៀង វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ ខ្ញុំមានការយល់ឃើញនូវវត្ថុនោះថា វត្ថុនោះមិនមែនរបស់យើង វត្ថុនោះមិនមែនជាយើង វត្ថុនោះមិនមែនជាតួខ្លួនរបស់យើង ។ គ្រានោះ ពួកបរិព្វាជកទើបពោលថា ម្នាលគហបតី វត្ថុណានីមួយដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែលបច្ច័យ.កឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្ថុនោះមិនទៀង វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ លោកគហបតី ជាអ្នកជាប់នៅជាមួយនឹងវត្ថុនោះ លោកចូលដល់នូវវត្ថុនោះឯង ។ អនាថបិណ្ឌិកសេដ្ឋីបានពោលអធិប្បាយថា អ្នកដ៏ចម្រើនទាំងឡាយ វត្ថុណានីមួយ ដែលកើតឡើងហើយ ដែលបច្ច័យតាក់តែងហើយ ដែលបច្ច័យ.កឡើងហើយ កើតឡើងព្រោះអាស្រ័យបច្ច័យ វត្ថុនោះមិនទៀង វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ខ្ញុំឃើញវត្ថុនោះដោយបញ្ញា ( ការដឹងដោយជុំវិញ ) ដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះថា វត្ថុនោះមិនមែនរបស់យើង វត្ថុនោះមិនមែនជាតួខ្លួនរបស់យើង ទាំងដឹងនូវឧបាយដែលជាគ្រឿងរលាស់ចោលនូវ

វត្ថុនោះយ៉ាងកំពូលតាមសេចក្ដីពិត ។

កាលអនាថបិណ្ឌិកសេដ្ឋី បានពោលអធិប្បាយហេតុផលយ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នាអង្គុយនៅស្ងៀម ដោយខ្មាសអៀន ដោយឱនមុខសំយុងចុះ មិនមានពាក្យអ្វីណានីមួយឆ្លើយឆ្លងមកទៀតបានឡើយ ហើយអនាថបិណ្ឌិកសេដ្ឋី ទើបក្រោកចាកទីនោះទៅ ហើយចូលទៅគាល់ព្រះភគវាដល់ទីគង់ប្រថាប់ ថ្វាយបង្គំរួចហើយ បានអង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលចំពោះរឿងរ៉ាវ ដែលខ្លួនបានសន្ទនាគ្នាជាមួយពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ ទាំងអស់ឲ្យព្រះអង្គទ្រង់ជ្រាបគ្រប់ប្រការ ។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ប្រទានសាធុការថា ល្អហើយៗ គហបតី ដែលអាចកាច់ទិដ្ឋិពួកមោឃបុរសទាំងនោះ ឲ្យជាការមួយដ៏សមគួរ ដោយប្រពៃតាមធម៌ ហើយតពីនោះទៅ ព្រះសយម្ភូទ្រង់ចង្អុលបង្ហាញដល់អនាថបិណ្ឌិកសេដ្ឋី ឲ្យឃើញច្បាស់ ឲ្យអាចហ៊ានឲ្យរីករាយ ដោយធម្មីកថា ។ កាលអនាថបិណ្ឌិកសេដ្ឋីបានស្ដាប់ធម្មីកថាហើយ ទើបក្រាបថ្វាយបង្គំលា និងធ្វើប្រទក្សិណហើយចៀសចេញទៅ ។

អនាថបិណ្ឌិកសេដ្ឋីក្រាបថ្វាយបង្គំលាត្រឡប់ទៅមិនយូរប៉ុន្មាន ព្រះភគវា ទើបទ្រង់ត្រាស់ជាមួយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា បានដឹងច្បាស់នូវធម៌ដ៏មាំទាំក្នុងធម្មវិន័យនេះ មកអស់កាលដ៏យូរហើយ ភិក្ខុនោះ គប្បីសង្កត់សង្កិនពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ ឲ្យជាការ សង្កត់សង្កិនដោយល្អ ដោយប្រពៃតាមធម៌ ដូចជាអនាថបិណ្ឌិកសេដ្ឋី បានសង្កត់សង្កិនរួចហើយ ។

សច្ចវាចារបស់ព្រះអរិយបុគ្គល រមែងជាឯក ( ពិត ) ដូចដែល អនាថបិណ្ឌិកសេដ្ឋី បានសន្ទនាជាមួយនឹង **នាងបុណ្ណាទាសី** តាមដែល មានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថា អធិប្បាយសេចក្ដីបាលីនៃ **មាតាសូត្រ** ក្នុង **គម្ពីរអង្គុត្តរនិកាយ សត្តកនិបាត** និងក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនៃ **រថវិនីតសូត្រ** នៅក្នុង **គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ** តែក្នុងទីនេះ សូមលើកយកសេចក្ដីមកពោលតាមន័យនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលមានសេចក្ដីតទៅថា ៈ-

សម័យមួយ ព្រះសាស្តា ទ្រង់គង់ចាំវស្សាបវារណារួចហើយ ព្រះអង្គឲ្យអគ្គសាវកគង់នៅក្នុងវត្តជេតពន ដោយព្រះអង្គស្តេចយាង ចេញពីវត្តជេតពន ដោយទ្រង់បំណងនឹងយាងចារិកទៅកាន់ទក្ខិណា-គិរីជនបទ ។ គ្រានោះ ព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី មហាឧបាសិកាវិសាខា និងបុគ្គលដទៃទៀតជាច្រើន គ្រប់ៗគ្នា មិនអាច នឹងក្រាបទូលអារាធនា ឲ្យព្រះមានជោគ ទ្រង់គង់ក្នុងទីនេះទៀតបាន ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី ប្រារព្ធហេតុនោះ ទើបអង្គុយជញ្ជឹងគិត ខូចចិត្ត នៅត្រង់ទីកន្លែងមួយថា យើងមិនអាចនឹងក្រាបទូលអារាធនាឲ្យ ព្រះសាស្តា ទ្រង់គង់នៅក្នុងទីនេះទៀតបាន ។ ពេលនោះ នាងបុណ្ណាទាសី បានក្រឡេកឃើញអនាថបិណ្ឌិកសេដ្ឋីហើយ ទើបជម្រាបសួរថា បពិត្រ លោកសេដ្ឋី លោកមានឥន្ទ្រិយមិនថ្លូវផង់ ដោយទឹកមុខស្រពាប់ស្រពោន តើមានហេតុអ្វី ? គ្រានោះ អនាថបិណ្ឌិកសេដ្ឋីតបថា ត្រូវហើយ នាង បុណ្ណាទាសី តើឲ្យយើងសប្បាយដូចម្តេចទៅកើត បើព្រះមានជោគ ស្តេចយាងចារិកទៅហើយ ដោយយើងមិនអាចនឹងយាងព្រះសាស្តា

ឲ្យត្រឡប់មកវិញបាន ទាំងនៅមិនទាន់ជ្រាបថា ព្រះលោកនាយក នឹងយាងត្រឡប់មកវិញ ឬក៏អត់ទេ ព្រោះហេតុនោះ យើងទើបអង្គុយ សញ្ជប់សញ្ជឹង ខូចចិត្តនៅត្រង់ទីនេះ ។ ពេលនោះ នាងបុណ្ណាទាសី បានសាកសួរអនាថបិណ្ឌិកសេដ្ឋីថា លោកសេដ្ឋី ប្រសិនបើនាងខ្ញុំក្រាបទូល អារាធនាយាងព្រះអង្គត្រឡប់មកវិញបាន តើលោកសេដ្ឋីឲ្យអ្វីដល់នាងខ្ញុំ ? អនាថបិណ្ឌិកសេដ្ឋីតបថា ប្រសិនបើជាយ៉ាងនោះមែន យើងនឹងឲ្យនាង ជាអ្នកជា ( គឺរួចអំពីភាពជាទាសីមួយរំពេច ) ។ នាងបុណ្ណាទាសី កាល ឮដូច្នោះហើយ ទើបប្រញាប់ទៅថ្វាយបង្គំ ក្រាបចុះទៀបព្រះបាទទាំងគូ នៃព្រះសាស្តា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទ្រង់ព្រះករុណាប្រោសយាងត្រឡប់ទៅវិញ ព្រះអង្គ ។ គ្រានោះ ព្រះមុនី ត្រាស់សួរថា ម្នាលនាងបុណ្ណាទាសី កាលតថាគតត្រឡប់ទៅវិញនោះ តើនាងធ្វើដូចម្តេច នាងបុណ្ណា ? នាងបុណ្ណាទាសី បានក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធអង្គក៏ជ្រាបហើយថា ខ្ញុំព្រះអង្គជាទាសី របស់គេ ដោយការនៅបម្រើគេចិញ្ចឹមជីវិត ខ្ញុំព្រះអង្គមិនអាចនឹងធ្វើអ្វី

បានទេ ( ព្រោះទេយ្យធម៌មិនមាន ) តែខ្ញុំព្រះអង្គនឹងតាំងនៅក្នុងសរណគមន៍ ព្រមទាំងរក្សាសីល ៥ ព្រះអង្គ ។ ពេលនោះ ព្រះជិនស្រីទ្រង់ប្រទាន សាធុការថា ល្អហើយៗ នាងបុណ្ណទាសី ហើយព្រះអង្គក៏ស្ដេចយាង ត្រឡប់មកវិញ ទាំងនេះព្រោះការជូនក្នុងធម៌ ។ សមដូចមានព្រះពុទ្ធ តម្រាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកជូនក្នុងធម៌ ឬមានធម៌ជាទីគោរព ។

ព្រះបរមសាស្ដា ស្ដេចបានយាងត្រឡប់ចូលទៅកាន់វត្តជេតពន មហាវិហារវិញ ។ មហាជន កាលបើដឹងដូច្នោះហើយ ម្នាក់ៗ បានឲ្យ សាធុការ សម្ដែងនូវការកោតសរសើរដល់នាងបុណ្ណទាសី ។ ព្រះសម្ពុទ្ធ ទ្រង់បានសម្ដែងព្រះធម៌ប្រោសដល់ពួកពុទ្ធបរិស័ទទាំងនោះ ធ្វើឲ្យសត្វ ៨៤.០០០ បានផឹកនូវទឹកអម្រឹត ។

រឿងរបស់នាងបុណ្ណទាសី ដែលអាចធ្វើការបានសម្រេចតាម បំណងរបស់លោកសេដ្ឋី ហើយនាងបានទទួលផលតបស្នងដ៏ប្រសើរ ដូចមានសម្ដែងនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** យ៉ាងពិស្ដារថា ៖-

អនាថបិណ្ឌិកសេដ្ឋី បានឮអ្នកស្រុកនិយាយថា ព្រះមហាវីរៈ ដែលស្តេចយាងត្រឡប់មកវិញនេះ ក៏ព្រោះតែនាងបុណ្ណាទាសី ដូច្នេះ អនាថបិណ្ឌិកសេដ្ឋី ឃើញគុណសម្បត្តិរបស់នាងបុណ្ណាទាសីយ៉ាងនេះ ហើយ ទើបឲ្យនាងរួចផុតភាពជាទាសី ហើយតាំងនាងទុកក្នុងឋានៈ ជាធីតាទៀតផង ។

ភាពជាបុគ្គលមានការស្មោះត្រង់ចំពោះមិត្ត របស់អនាថបិណ្ឌិក-សេដ្ឋី ដោយលោកបានជួយស្រោចស្រង់មិត្តសម្លាញ់របស់លោក ដែល មានការប្រព្រឹត្តខុសផ្លូវ ឲ្យប្រែចិត្តមកប្រកបរបរក្នុងផ្លូវត្រូវវិញ ហើយ ទាំងនេះរាប់ថា ជាផលការងាររបស់លោក មួយរឿងទៀត ដែលលោក បានដឹកនាំបុគ្គលដែលរាប់អានលទ្ធិ របស់ពួកអន្យតិរ្ថិយ ឲ្យចូលមក ប្តេជ្ញាខ្លួនជាឧបាសក រាប់អានព្រះពុទ្ធសាសនា ដូចមានរឿងសម្តែង ប្រាកដនៅក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលី នៃ **អបណ្ណកជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** មានសេចក្តីថា ៖-

សម័យមួយ ព្រះជិនស្រី ស្តេចយាងទៅស្នាក់អាស្រ័យនៅក្នុង

ក្រុងសាវត្ថី ដោយព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន បានត្រាស់ព្រះធម្មទេសនាអបណ្ណកធម៌ (វត្ថុដែលមិនខុស) ដោយទ្រង់ប្រារព្ធចំពោះសាវកអន្យតិរ្ថិយ ៥០០ នាក់ ដែលជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋីថា ថ្ងៃមួយ អនាថបិណ្ឌិកសេដ្ឋី បាននាំសាវកអន្យតិរ្ថិយ ៥០០ នាក់ ដែលជាសម្លាញ់របស់ខ្លួន ឲ្យកាន់ផ្កា និងគ្រឿងក្រអូបជាច្រើន ព្រមទាំងប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ដែលជាគ្រឿងស្លៀកដណ្តប់ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តារួចហើយ នាំគ្នាបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ទាំងបានប្រគេនភេសជ្ជៈ និងសំពត់ជាគ្រឿងស្លៀកដណ្តប់ទាំងឡាយ ដល់ភិក្ខុសង្ឃស្រេចហើយ អនាថបិណ្ឌិកសេដ្ឋី ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ សូម្បីសាវករបស់ពួកអន្យតិរ្ថិយទាំងនោះ កាលថ្វាយបង្គំព្រះសម្ពុទ្ធហើយ ក៏បានអង្គុយនៅជិតអនាថបិណ្ឌិកសេដ្ឋី ដោយពួកគេបានក្រឡេកមើលព្រះភក្ត្រនៃព្រះលោកនាថដែលផូរផង់ ប្រកបដោយសិរី ប្រៀបបីដូចជាដួងព្រះច័ន្ទ ដែលរះក្នុងថ្ងៃពេញបុណ្ណមី ( ១៥ កើត ) ថែមទាំងសម្លឹងមើលព្រះវរកាយ ដែលប្រៀបបីដូចកាយនៃព្រហ្ម

ប្រកបដោយមហាបុរិសលក្ខណៈ និងអនុព្យញ្ជនៈ និងព្រះរស្មីផ្សាយចេញអំពីព្រះវរកាយ ប្រមាណ ១ ព្យាម ហើយពួកគេសម្លឹងមើលរស្មីព្រះពុទ្ធរង្សី ដែលផ្សាយចេញវិលជុំវិញជាគូៗ ។ ព្រះភគវាបានត្រាស់ធម្មកថា គឺព្រះវាចាដែលពោលដល់ធម៌ ដ៏ពីរោះវិចិត្រដោយន័យផ្សេងៗ ដូចជាសំឡេងព្រហ្ម ដែលគួរឲ្យចង់ស្ដាប់ ប្រកបដោយអង្គ ៨ ដូចជារាជសីហ៍ជំទង់ កំពុងតែបន្លឺសីហនាទ ដូចមេឃភ្លៀងដែលមានផ្គរគ្រហឹម ដូចទេវតាបណ្ដាលឲ្យភ្លៀងធ្លាក់ចុះ និងដូចផ្កាក្រងកម្រងកែវ ។

ពួកសាវកអន្យតិរ្ថិយទាំងនោះ កាលបើស្ដាប់ព្រះធម្មទេសនារបស់ព្រះមានជោគហើយ ក៏មានចិត្តជ្រះថ្លា ទើបក្រោកឡើងថ្វាយបង្គំព្រះមានបុណ្យ ដោយការបានប្រកាសក្នុងការឈប់រាប់អានសាសនាអន្យតិរ្ថិយជាសរណៈតទៅទៀត និងសូមដល់ព្រះពុទ្ធជាសរណៈ ។ ចាប់ពីថ្ងៃនោះតមក ពួកសាវកដែលជាអន្យតិរ្ថិយទាំងនោះ បាននាំគ្នាកាន់ផ្កា និងគ្រឿងក្រអូបជាដើមទៅវត្តជេតពន ជាមួយនឹងអនាថបិណ្ឌិក-សេដ្ឋី ហើយបានស្ដាប់ព្រះធម៌ទេសនា និងដល់ព្រមដោយការថ្វាយទាន

និងសមាទានឧបោសថសីលអស់កាលជានិច្ច ។ កាលតមក ព្រះសម្ពុទ្ធ ស្ដេចយាងចេញអំពីក្រុងសាវត្ថី ទៅនគររាជគ្រឹះ ។ ពេលដែលព្រះអង្គ ស្ដេចយាងទៅហើយ ពួកសាវកដែលជាអន្យតិត្ថិយ ជាអ្នកគោរពរាប់អាន ព្រះរតនត្រ័យនោះ ក៏បាននាំគ្នាឈប់គោរពរាប់អានព្រះរតនត្រ័យជា សរណៈទៀត ហើយត្រឡប់ទៅគោរពរាប់អានសាសនាអន្យតិត្ថិយជា សរណៈវិញ ដោយពួកគេប្រព្រឹត្តទៅក្នុងឋានៈ ដែលគេធ្លាប់រាប់អាន ដូចពីមុននោះ ។ ចំណែកព្រះលោកនាយក ស្ដេចយាងទៅគង់នៅក្នុង នគររាជគ្រឹះ និងទីដទៃទៀត ប្រមាណ ៧-៨ ខែ ហើយព្រះអង្គស្ដេចយាង ត្រឡប់មកកាន់វត្តជេតពនវិញ នាក្រុងសាវត្ថីម្ដងទៀត ។

អនាថបិណ្ឌិកសេដ្ឋី លុះបានជ្រាបការយាងត្រឡប់មកវិញ នៃ ព្រះសាស្ដាហើយ ទើបបាននាំពួកសាវកអន្យតិត្ថិយទាំងនោះ ចូលទៅ ថ្វាយបង្គំព្រះមានជោគទៀត ដោយអនាថបិណ្ឌិកសេដ្ឋីបានបូជាចំពោះ ព្រះសម្ពុទ្ធ ដោយគ្រឿងក្រអូប និងផ្កាជាដើម ថ្វាយបង្គំរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ចំណែកពួកសាវករបស់អន្យតិត្ថិយទាំងនោះ

ក៏នាំគ្នាថ្វាយបង្គំចំពោះព្រះមុនី រួចហើយក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានក្រាបទូលហេតុការណ៍ ដែលពួកគេទាំងនោះ បោះបង់ចោលក្នុងការគោរពរាប់អានព្រះរតនត្រ័យ តាំងពីពេលដែលព្រះទសពលស្តេចយាងទៅកាន់ទីដទៃម្ល៉េះ ហើយពួកគេទើបវិលត្រឡប់ទៅគោរពរាប់អាន ក្នុងលទ្ធិអន្យតិ្ថិយជាសរណៈ ដូចដើមវិញ ។ ពេលដែលព្រះជិនស្រីទ្រង់ជ្រាបរឿងនោះហើយ ទើបបន្លឺព្រះសូរសៀងដ៏ពីរោះ ប្រៀបបីដូចបើកប្រអប់កែវ ដែលពេញដោយគ្រឿងក្រអូបច្រើនប្រការ ដែលលាយគ្រឿងក្រអូបដ៏ជាទិព្វ ដោយអានុភាពនៃវចីសុចរិត ដែលព្រះពុទ្ធអង្គទ្រង់បំពេញមកជានិច្ចនិរន្តរ៍ អស់កោដិកប្បរាប់ប្រមាណមិនបាន ព្រះសាស្តាក៏បានត្រាស់សួរថា ម្នាលឧបាសកតថាគតបានឮថា អ្នកទាំងឡាយបានបោះបង់ចោលការគោរពរាប់អានព្រះរតនត្រ័យ ហើយត្រឡប់ទៅគោរពរាប់អានលទ្ធិអន្យតិ្ថិយជាសរណៈដូចដើមវិញឬ ? កាលពួកគេមិនអាចនឹងបិទបាំងបាន ទើបក្រាបទូលតាមការពិតថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ពិតយ៉ាងហ្នឹងហើយ ព្រះអង្គ ។

គ្រានោះ ព្រះលោកនាយក ត្រាស់អធិប្បាយថា ម្នាលឧបាសក ទាំងឡាយ ដែលបានឈ្មោះថា បុគ្គលដែលដូចគ្នានឹងព្រះពុទ្ធ ដោយគុណ ទាំងឡាយ មានសីលជាដើម រមែងមិនមាន ដែលរាប់តាំងពីអវីចីនរក ឡើងរហូតទៅដល់ភវគ្គព្រហ្ម ( ព្រហ្មជាន់ខ្ពស់ គឺនេវសញ្ញានាសញ្ញា-យតនៈ ) និងចំហៀងក្នុងលោកធាតុ ( ចក្រវាល ) ដែលរកប្រមាណ មិនបាន នឹងមាននរណាក្រៃលែងជាងព្រះអង្គឡើយ ទ្រង់បានប្រកាស គុណព្រះរតនត្រ័យ ដែលប្រាកដក្នុងសូត្រទាំងឡាយជាដើមថា ម្នាល ភិក្ខុទាំងឡាយ សត្វឥតជើង សត្វជើងពីរ សត្វជើង ៤ ឬសត្វមានជើង ច្រើនក្តី មាននៅប្រមាណប៉ុនណា ។ល។ ដែលគេពោលថា ព្រះតថាគត ជាបុគ្គលប្រសើរលើសជាងសត្វទាំងនោះ ។ ទ្រព្យ គឺគ្រឿងរីករាយចិត្ត ឯណាទីមួយ ក្នុងលោកនេះ ឬលោកខាងមុខ ។ល។ បុគ្គលណាជ្រះថ្លាហើយ នូវវត្ថុដែលប្រសើរនោះ ហើយព្រះអង្គត្រាស់ថា ឧបាសក ឬឧបាសិកា ក៏ដោយ ដែលជាអ្នកគោរពរាប់អានព្រះរតនត្រ័យ ដែលប្រកបដោយគុណ ដ៏ឧត្តមយ៉ាងនេះជាសរណៈហើយ ដំណើរទៅកាន់នរកជាដើមមិនមាន

ជាអ្នកបានរួចផុតអំពីកំណើតអបាយភូមិ(ទីកន្លែងដែលមិនមានសេចក្តីចម្រើន បានដល់ នរក ប្រេត តិរច្ឆាន និងអសុរកាយ )ហើយជាអ្នកទៅកើតក្នុងទេវលោក ជាអ្នកបរិបូណ៌ដោយសម្បត្តិទិព្វ តែព្រោះហេតុអ្វី ព្រោះហេតុអ្នកទាំងនោះលះនូវសរណៈ គឺការគោរពរាប់អានក្នុងលទ្ធិរបស់ពួកតិរ្ថិយជាសរណៈ ។

ពិតណាស់ ក្នុងរឿងនេះ ដើម្បីសម្តែងដល់សត្វទាំងឡាយជាអ្នកដល់នូវព្រះរតនត្រ័យ ជាសរណៈហើយ ដោយអំណាចមោក្ខៈ ( ការរួចផុតចាកកិលេស ) និងឧត្តម ( ប្រសើរបំផុត ) ដោយមិនធ្វើឲ្យបុគ្គលនោះទៅកើតក្នុងអបាយភូមិ មានសូត្រអាងថា ៖-

ជនពួកណានីមួយ ជាអ្នកដល់នូវព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃជាសរណៈ ជាទីពឹង ជាទីរឭក ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិ ក្រោយពីស្លាប់ទៅហើយ នឹងជាអ្នកបានទទួលទិព្វសម្បត្តិ ។ មនុស្សទាំងឡាយ មានចំនួនច្រើន កាលបើភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាម និងដើមឈើ និងចេតិយ

ទាំងឡាយខ្វះជាទីពឹង ។ទីពឹងនោះឯង មិនមែនជាទីពឹងដ៏ក្សេម មិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនោះទេ ។ បុគ្គលណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹង ជាទីរឭក ហើយឃើញនូវអរិយសច្ចទាំង ៤ គឺ សេចក្តីទុក្ខ ១ សមុទយៈជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ ១ និរោធជាទីកន្លងបង់នូវសេចក្តីទុក្ខ ១មគ្គមានអង្គ ៨ ដ៏ប្រសើរ ដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ជាស្ថានរំងាប់បង់នូវសេចក្តីទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ ។ ទីពឹងនោះឯង ជាទីពឹងដ៏ក្សេម ទីពឹងហ្នឹងឯងជាទីពឹងដ៏ឧត្តម ( របស់បុគ្គលនោះ ) បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

ព្រះបរមគ្រូ មិនមែនតែទ្រង់នឹងសម្តែងធម៌ ឲ្យដល់គេត្រឹមតែន័យប៉ុណ្ណោះទេ ដោយទ្រង់សម្តែងព្រះធម៌ ដោយន័យផ្សេងៗ ទៀតជាច្រើន ដូចមានសេចក្តីថា ៖-

ម្នាលឧបាសកទាំងឡាយ កម្មដ្ឋានដែលប្រារព្ធនូវពុទ្ធានុស្សតិ

ធម្មានុស្សតិ សង្ឃានុស្សតិ រមែងឲ្យបានសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ ឲ្យបានសម្រេចអរហត្តផល ។ ហើយព្រះពុទ្ធអង្គត្រាស់ទៀតថា ឈ្មោះថា សរណៈ គឺជាទីពឹង ជាទីរឭកនោះ បានដល់ ព្រះរតនត្រ័យ ដែលអ្នកទាំងឡាយ បានលះបង់នូវការគោរពរាប់អាន ទាំងនេះរាប់ថា ជាការធ្វើមិនសមគួររបស់អ្នកទាំងឡាយឡើយ ។ ម្យ៉ាងទៀត ពពួកសត្វដែលមាននូវពុទ្ធានុស្សតិ ជាកម្មដ្ឋានជាដើម មកជាអារម្មណ៍ រមែងបានសម្រេចអរិយធម៌ មានព្រះសោតាបត្តិមគ្គជាដើម គួរសម្តែងសូត្រទាំងឡាយឲ្យឃើញថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាឯក ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ( សេចក្តីតម្រេកក្នុងកាម ) ដើម្បីការរំលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីការដឹងដ៏ក្រៃលែង ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វាន ( ការរំលត់កិលេស និងកងទុក្ខ ) ធម៌ឯក បានដល់អ្វី ? បានដល់ពុទ្ធានុស្សតិ គឺការរឭកដល់ព្រះពុទ្ធ ។

កាលព្រះលោកនាយក បានត្រាស់ប្រៀនប្រដៅដល់ពួកឧបាសក ដោយប្រការផ្សេងៗ ដូច្នេះហើយ ទើបត្រាស់បញ្ជាក់ថា ៖-

ម្នាលឧបាសកទាំងឡាយ សូម្បីកាលមុន ពួកមនុស្សដោយច្រើន តែងតែតោងយកវត្ថុ ដែលមិនមែនជាសរណៈមកហើយ ដោយប្រកាន់តាមការរិះគិតនូវការប្រកាន់ខុសជាសរណៈ ទើបត្រូវក្លាយជាអាហាររបស់យក្ខ នៅក្នុងផ្លូវកន្តារ ដែលពួកអមនុស្សអាស្រ័យនៅ បានធ្វើឲ្យដល់នូវសេចក្តីវិនាសដល់បុរសទាំងនោះ ។ ចំណែកពួកមនុស្ស ដែលប្រកាន់មិនខុស ប្រកាន់ផ្លូវដែលត្រូវតែម្យ៉ាង ក៏បានចូលដល់ភាពជាសុខសាន្តក្នុងផ្លូវកន្តារនោះ ។ កាលព្រះសម្ពុទ្ធ ទ្រង់ត្រាស់បញ្ជាក់ ដូច្នេះហើយ ទើបទ្រង់នៅស្ងៀម ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីក្រោកឡើងពីអាសនៈ ហើយថ្វាយបង្គំព្រះជិនស្រី ដោយក្រាបទូលសរសើរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលពួកឧបាសកទាំងនេះឈប់គោរពរាប់អានសរណៈដ៏ឧត្តមហើយ ដោយទៅគោរពរាប់អានសរណៈរបស់គេដូចដើមវិញ ដោយការគិតឃើញខុស ខ្ញុំករុណាបានឃើញច្បាស់ ក្នុង

ពេលឥឡូវនេះហើយ ព្រះអង្គ តែការវិនាសរបស់ពួកមនុស្ស ដែលប្រកាន់ការគិតឃើញខុស ក្នុងផ្លូវកន្តារ ដែលពួកអមនុស្សអាស្រ័យនៅ និងភាពសួស្តីរបស់ពួកមនុស្ស ដែលមានការគិតឃើញត្រូវ ក្នុងកាលមុននោះ ខ្ញុំព្រះអង្គទាំងឡាយ មានសេចក្តីប្រាថ្នាចង់ដឹង ព្រះអង្គ ។

**ទើបព្រះមានព្រះភាគត្រាស់អតីតនិទាន ឲ្យអនាថបិណ្ឌិកសេដ្ឋី និងឧបាសកទាំងនោះ បានស្តាប់ ( នឹងសូមលើកយកមកពោលដោយសេចក្តីសង្ខេបក្នុងទីនេះ ) ដូចមានសេចក្តីថា ៖-**

ក្នុងអតីតកាល ដែលគ្រប់គ្រងរាជសម្បត្តិ ដោយព្រះបាទព្រហ្មទត្ត នៅក្នុងក្រុងពារាណសី ក្នុងកាលនោះ មាននាយឈ្មួញ ២ នាក់ ម្នាក់ៗ មានក្រុមពួករទេះជាបរិវារ ៥០០ រទេះ ។ នាយឈ្មួញម្នាក់ ជាបុគ្គលល្ងង់ខ្លៅ ជាអ្នកមានការគិតឃើញខុសថា គង់នឹងជាយ៉ាងនោះមែន ។ ហើយគ្រាមួយ គេបាននាំពួកក្រុមរទេះប្រមាណ ៥០០ រទេះ ផ្ទុកដោយទំនិញ ធ្វើដំណើរចេញទៅជួញ តែក្នុងរវាងផ្លូវ មានពួកយក្ខក្លែងខ្លួនធ្វើជាមនុស្សមកប្រាប់ថា ចំពោះផ្លូវកន្តារនេះ ពេលនេះឈប់លំបាកហើយ

ពីព្រោះមានភ្លៀងធ្លាក់ ទឹក និងស្មៅបរិបូណ៌ ពួកលោកចូរនាំគ្នាចោលទឹក និងស្មៅ ដែលនាំមកនោះឲ្យអស់ទៅ ទើបអាចធ្វើដំណើរទៅបានយ៉ាងរហ័ស ។ នាយឈ្មួញល្ងង់ខ្លៅ ក៏បានដាក់ចិត្តជឿ ដោយធ្វើតាមពាក្យដែលយក្ខិនីបានប្រាប់ ដែលនាងបានក្រឡាខ្លួនធ្វើជាមនុស្ស លុះធ្វើដំណើរទៅដល់ផ្លូវកន្តារនោះហើយ ទើបបានដឹងខ្លួនថា ត្រូវបាញ់បោកពពួកជនទាំងនោះ ពីព្រោះមិនមានទឹក និងស្មៅ តាមដូចដែលបានប្រាប់នោះទេ ធ្វើឲ្យពួកបរិវាររបស់គេ ត្រូវអស់ទឹក ទាំងគោរបស់ពួកគេក៏មិនមានទឹកផឹក និងស្មៅស៊ី រាងកាយក៏ទន់ខ្សោយ មិនមានកម្លាំងនឹងអាចដើរទៅមុខបាន ។ កាលជាទីបំផុត ទាំងមនុស្ស និងសត្វពាហនៈបានត្រូវយក្ខិនីចាប់ស៊ីទាំងអស់ នៅសល់តែគំនរឆ្អឹងរាត់រាយ នៅក្នុងវាលផ្លូវកន្តារនោះឯង ។

ចំណែកនាយឈ្មួញដែលជាអ្នកឆ្លាត បានទូន្មានពពួកបរិវារថា ពួកអ្នកទាំងអស់គ្នាកុំឲ្យជឿនរណាងាយៗ ទោះមាននរណាមកប្រាប់ថា នៅខាងមុខមានភ្លៀងធ្លាក់នោះ ចូរនាំគ្នាពិចារណាមើលមេឃសិន បើត្រូវ

ទំនង ឬមានសភាពដូចជាភ្លៀងធ្លាក់មែន ដោយមានពពកខ្មៅ ផ្គរបន្ទោរ រន្ទះផ្ទៀលឆ្វាត់ ទាំងផ្គរលាន់ក៏គ្រហឹម បើមានហេតុយ៉ាងនេះមែន ប្រាកដជាមានភ្លៀងមែនហើយ ទាំងនេះជាបទពិចារណាសម្រាប់អ្នកទាំងឡាយ ទោះបីមាននរណាមកប្រាប់ក្នុងរឿងនេះ ចូរពួកអ្នកទាំងអស់គ្នា ប្រាប់ឲ្យយើងបានដឹងផង ឬទាំងការទទួលបន្ទៃដែលពួកអ្នកទាំងអស់គ្នា មិនស្គាល់ក្រែងបរិភោគទៅហើយមានជាតិពុល ។ ពួកឈ្មួញរទេះដែលជាអ្នកឆ្លាតទាំង ៥០០ រទេះនោះ ដែលធ្វើដំណើរឆ្លងកាត់ផ្លូវកន្តារ ក៏ឆ្លងផុតទៅដោយសុវត្ថិភាព ពពួកយក្ខដែលនិយាយបោកបញ្ឆោតនាយឈ្មួញល្ងង់ខ្លៅទាំង ៥០០ រទេះ ដែលធ្វើដំណើរចេញទៅមុននោះ មិនអាចនិយាយបោកបញ្ឆោតឲ្យពួកឈ្មួញ ដែលជាអ្នកឆ្លាតទាំង ៥០០ រទេះនោះជឿបាន ទាំងនេះព្រោះពួកឈ្មួញរទេះទាំងនោះមិនជឿការនិយាយ ពួកគេបានពិចារណាហេតុផលត្រូវទំនង ។ គ្រានោះ ព្រះលោកនាយក ទ្រង់ត្រាស់និទានក្នុងរឿងនេះចប់ហើយ ទើបទ្រង់ត្រាស់បញ្ជាក់ថា ម្នាលគហបតី ក្នុងកាលមុន បុគ្គលព្រោះតែជឿដោយការស្មានខុស ដូច្នេះហើយ ទើបចូល

ដល់នូវសេចក្ដីវិនាស ។

រីឯបុគ្គលមិនជឿដោយការយល់ហេតុផល ទើបអាចធ្វើឲ្យខ្លួនរួចផុតអំពីកណ្ដាប់ដៃរបស់ពួកយក្ខ ក៏បានធ្វើដំណើរទៅដោយសុវត្ថិភាពត្រឡប់មកដល់ផ្ទះរៀងៗ ខ្លួន ហើយព្រះអង្គទ្រង់ត្រាស់ព្រះធម្មទេសនាអបណ្ណកធម៌ ហើយព្រះវិជិតមារ ទ្រង់បានសម្ដែងបដិបទា ដែលធ្វើឲ្យជួបកុសលសម្បត្តិ ៣ ប្រការ និងព្រហ្មលោក សម្បត្តិក្នុងស្ថានសួគ៌ជាន់កាមាវចរៈ ៦ ជាន់ ដល់ឧបាសកទាំងនោះ ហើយជាទីបំផុតទ្រង់ត្រាស់ដល់ផ្លូវដែលបដិបត្តិមិនខុស គឺអរហត្តផល ទ្រង់ត្រាស់ដល់បដិបទា គឺផ្លូវដែលធ្វើឲ្យទៅកើតក្នុងអបាយភូមិទាំង ៤ និងកើតនៅក្នុងត្រកូលទាបថោក ដែលជាផ្លូវបដិបត្តិខុស ហើយព្រះអង្គទ្រង់ប្រកាសអរិយសច្ចធម៌ទាំង ៤ ប្រការ ។ កាលព្រះលោកនាយក ទ្រង់ត្រាស់អរិយសច្ចធម៌ទាំង ៤ ចប់ហើយ ឧបាសកទាំង ៥០០ នាក់នោះ បានសម្រេចព្រះអរហត្តផល ( ហើយពួកឧបាសកទាំងនោះមិនត្រឡប់ទៅកាន់លទ្ធិអន្យតិរ្ថិយតទៅទៀតឡើយ ទាំងនេះក៏ព្រោះតែមកអំពីអនាថ-

បិណ្ឌិកសេដ្ឋីជាអ្នកដឹកនាំទៅក្នុងផ្លូវត្រូវ ) ។

កាលតមកជាខាងក្រោយ អនាថបិណ្ឌិកសេដ្ឋី តែងតែមានអ្នកដទៃអញ្ជើញលោកឲ្យទៅចូលរួមនៅក្នុងកម្មវិធីបុណ្យផ្សេងៗ យ៉ាងមមាញឹករហូតដល់មិនមានពេលទំនេរ ក៏បានឲ្យកូនស្រីរបស់លោកទទួលនាទីក្នុងការចាត់ចែងថ្វាយចង្ហាន់ចំពោះព្រះភិក្ខុសង្ឃ ដែលនិមន្តមកកាន់ផ្ទះរបស់ខ្លួន ដូចមានរឿងសម្តែងនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **យមកវគ្គ** ក្នុងរឿង **នាងសុមនាទេវី** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ទ្រង់បានត្រាស់ធម្មទេសនាប្រារព្ធនាងសុមនាទេវី ដូចមានសេចក្តីថា ឯផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី តែងតែមានភិក្ខុសង្ឃមកឆាន់ជាប្រចាំពីរពាន់អង្គជារឿយៗ រីឯផ្ទះមហាឧបាសិកាវិសាខាក៏មានសភាពនោះដូចគ្នាដែរ ។ កាលបើមានបុគ្គលណា ឬក៏អ្នកណានៅក្នុងក្រុងសាវត្ថីបានធ្វើបុណ្យ បុគ្គលនោះៗ តែងតែទៅអញ្ជើញអនាថបិណ្ឌិកសេដ្ឋី និងនាងវិសាខាមកចូលរួមក្នុងកម្មវិធីបុណ្យនោះ ។

មានពាក្យសួរថា ព្រោះហេតុអ្វី ? មានពាក្យឆ្លើយថា ប្រសិនបើមានបុគ្គលដទៃៗ សួរ (ម្ចាស់ទាន) ថា អនាថបិណ្ឌិកសេដ្ឋី ឬមហាឧបាសិកាវិសាខាអញ្ជើញមកចូលរួមទានរបស់អ្នកដែរឬ បើអ្នកម្ចាស់ទានឆ្លើយថា មិនបានមកទេ សូម្បីទានដែលអ្នកថ្វាយដោយលះទ្រព្យដល់ទៅ ១ សែនកហាបណៈ ថ្វាយជាទានហើយក៏ដោយ អ្នកទាំងនោះរមែងតិះដៀលថា នេះជាទានស្អី ទាំងនេះព្រោះតែអ្នកទាំងពីរនោះ មិនបានចូលរួមជាមួយដោយម៉្យាងទៀត លោកទាំងពីរនោះរមែងដឹងអធ្យាស្រ័យរបស់ភិក្ខុសង្ឃ និងកិច្ចដែលសមគួរដល់ភិក្ខុសង្ឃហើយ កាលបើលោកទាំងពីរនាក់នៅ ( រួមធ្វើបុណ្យផង ) ភិក្ខុសង្ឃទាំងឡាយ រមែងឆាន់របស់តាមគាប់ចិត្តនោះឯង ព្រោះដូច្នោះ គ្រប់ៗ គ្នា កាលដែលមានបំណងនឹងធ្វើបុណ្យតែងតែទៅអញ្ជើញអ្នកទាំងពីរនោះ ឲ្យមកចូលរួមជាមួយ ហេតុដូច្នេះហើយ ទើបធ្វើឲ្យអ្នកទាំងពីរនាក់នោះ មិនសូវបាននៅផ្ទះទំនុកបម្រុងភិក្ខុសង្ឃ ដោយហេតុដូច្នេះឯង ។

ព្រោះហេតុនោះ ឧបាសិកាវិសាខា បានពិចារណាថា នរណាហ្ន៎

អាចអង្គាសភិក្ខុសង្ឃជំនួសយើងបាន ពិចារណាទៅៗ ក៏បានឃើញចៅស្រី សមគួរដល់ឋានៈនេះ ទើបប្រាប់ឲ្យចៅស្រីជំនួស ក្នុងការអង្គាសភិក្ខុសង្ឃ ដែលមកកាន់ផ្ទះរបស់ខ្លួន ដោយចង្ហាន់បិណ្ឌបាត ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី ក៏បានពិចារណាក្នុងរឿងនេះដែរ ហើយក៏បានតាំងធីតាច្បង ដែលឈ្មោះថាមហាសុភទ្ទា ឲ្យជាអ្នកជំនួស ក្នុងការអង្គាសចង្ហាន់បិណ្ឌបាតភិក្ខុសង្ឃទាំងឡាយ ដែលនិមន្តមកកាន់ផ្ទះរបស់ខ្លួន ដោយឲ្យធ្វើកិច្ចការងារនេះជំនួសបិតា ។ រីឯនាងមហាសុភទ្ទាកាលបើបានទទួលនាទីនោះហើយ នាងក៏មានការខ្វល់ខ្វាយ ក្នុងការអង្គាសចង្ហាន់បិណ្ឌបាតដល់ភិក្ខុសង្ឃទាំងឡាយ ហើយថ្ងៃមួយ នាងបានស្តាប់ព្រះធម៌ទេសនា ក៏បានសម្រេចជាព្រះសោតាបន្ន ក្នុងកាលជាខាងក្រោយមក នាងក៏មានស្វាមី ហើយនាងក៏បានទៅរស់នៅក្នុងត្រកូលស្វាមីរបស់នាងទៅ ។ ព្រោះហេតុដូច្នោះ អនាថបិណ្ឌិកសេដ្ឋី ទើបបានតាំងនាងចុល្លសុភទ្ទាជំនួស ក្នុងតំណែងរបស់នាងមហាសុភទ្ទាវិញ ។ សូម្បីនាងចុល្លសុភទ្ទា ក៏មានប្រក្រតីធ្វើដូចជានាងមហាសុភទ្ទាជារឿយៗ

ដូចគ្នា ហើយកាលនាងចុល្លសុភទ្ទាបានសម្រេចជាព្រះសោតាបន្នហើយ ក្នុងកាលជាខាងក្រោយ នាងក៏មានស្វាមី នាងក៏បានទៅនៅក្នុងត្រកូលរបស់ស្វាមីនាងទៅ ។ កាលតមក អនាថបិណ្ឌិកសេដ្ឋី ក៏បានតាំងកូនស្រីពៅដែលមានឈ្មោះថា នាងសុមនាទេវី ឲ្យមើលការខុសត្រូវដូចគ្នានឹងនាងមហាសុភទ្ទា និងនាងចុល្លសុភទ្ទា ដែលធ្វើកន្លងរួចមកហើយ ។ ចំណែកនាងសុមនាទេវី ក៏ពេញចិត្តក្នុងកិច្ចការងារទាំងនោះ ដោយសេចក្ដីជ្រះថ្លា ក្នុងថ្ងៃមួយ នាងបានស្ដាប់ព្រះធម៌ទេសនាហើយ ក៏បានសម្រេចជាសកទាគាមិផល នៅក្នុងភាពជាកុមារីនៅឡើយ កាលតមកជាខាងក្រោយ នាងសុមនាទេវីក៏ធ្លាក់ខ្លួនឈឺ រហូតដល់ទទួលទានបាយមិនបានសម្រាន្តមិនលក់ នាងក៏មានបំណងនឹងចង់ជួបអនាថបិណ្ឌិកសេដ្ឋី ដែលជាបិតារបស់នាង ទើបឲ្យមនុស្សទៅអញ្ជើញបិតាមកជួប ។ រីឯអនាថបិណ្ឌិកសេដ្ឋី លុះបានជ្រាបដំណឹងថា សុមនាទេវីជាកូនស្រីពៅមានជំងឺធ្ងន់ ចង់ជួបនឹងខ្លួន ទើបចូលទៅរក ហើយសួរថា សុមនាកូន តើកូនកើតអី ? គ្រានោះ នាងសុមនាទេវីតបថា មិនកើតអ្វីទេប្អូនប្រុស ។

កាលអនាថបិណ្ឌិកសេដ្ឋី បានឮដូច្នេះហើយ ក៏សួរចំពោះកូនស្រីដោយការតក់ស្លុតក្នុងចិត្តថា កូនឯងកើតការវង្វេងវង្វាយហើយ ។ នាងសុមនាឆ្លើយថា ខ្ញុំមិនបានវង្វេងវង្វាយទេប្អូនប្រុស អនាថបិណ្ឌិកសេដ្ឋីសួរតទៅទៀតថា កូនខ្លាចឬកូន ? នាងសុមនាឆ្លើយថា ខ្ញុំមិនបានខ្លាចទេប្អូនប្រុស ។ នាងសុមនាទេវីពោលឆ្លើយឆ្លងបានត្រឹមតែប៉ុណ្ណោះ នាងក៏អស់ជីវិតទៅ ។

អនាថបិណ្ឌិកសេដ្ឋី សូម្បីជាព្រះសោតាបន្ន ក៏មិនអាចនឹងអត់ធន់ចំពោះសេចក្តីយំសោក ដែលកើតឡើងព្រោះតែនាងសុមនាទេវី ធ្វើកាលកិរិយាទៅ លោកសេដ្ឋីក៏បានឲ្យគេចាត់ចែងបូជាសព របស់នាងសុមនាទេវីរួចស្រេចហើយ បានចូលទៅគាល់ព្រះភគវា ទាំងមានមុខជោកជាំទៅដោយទឹកភ្នែក ។ គ្រានោះ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតី តើលោកមានបញ្ហាអ្វីមិនសប្បាយចិត្ត បានជាមានទឹកមុខជោកជាំទៅដោយទឹកភ្នែក តើមានហេតុអ្វី ? គ្រានោះ អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលចំពោះព្រះសាស្តាឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដ៏ចម្រើន ដែលខ្ញុំព្រះអង្គមានមុខទទឹកទៅដោយទឹកភ្នែកនេះ ពីព្រោះមកពីសុមនាទេវី

កូនស្រីពៅរបស់ខ្ញុំ ធ្វើកាលកិរិយាទៅហើយ ព្រះអង្គ ។ គ្រានោះ ព្រះជិនស្រីទ្រង់ត្រាស់សួរថា បើដូច្នោះ ព្រោះហេតុអ្វី បានជាលោកគហបតីសោកស្ដាយចំពោះនាងសុមនាទេវី ពីព្រោះថា សេចក្ដីស្លាប់របស់សព្វសត្វមានពិតប្រាកដមិនមែនឬ ? អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា សេចក្ដីនេះខ្ញុំព្រះករុណាជ្រាបហើយ ព្រះអង្គ តែកូនស្រីពៅរបស់ខ្ញុំព្រះករុណា ជាអ្នកសម្បូណ៌ទៅដោយហិរិ ( ការខ្មាសចំពោះបាប ) និងឱត្តប្ប: ( ការកែ្រងខ្លាចបាប ) បែបនេះព្រះអង្គ តែជិតនឹងស្លាប់កូនស្រីពៅរបស់ខ្ញុំព្រះអង្គ មិនអាចនឹងគ្រប់គ្រងសតិស្មារតីបាន នាងក៏បាននិយាយរវើរវាយ ហើយក៏ស្លាប់ទៅ ដោយហេតុនេះ ទើបសេចក្ដីសោកកើតមានដល់ខ្ញុំព្រះករុណា ព្រះអង្គ ។

គ្រានោះ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលគហបតី តើនាងសុមនាទេវីនិយាយរវើរវាយយ៉ាងណា ? អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលតបថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ខ្ញុំព្រះករុណាសួរនាងថា កូនសុមនា តើកូនកើតអ្វី លំដាប់នោះ នាងនិយាយជាមួយនឹងខ្ញុំថា មិនកើតអីទេ ប្អូនប្រុស

កាលខ្ញុំព្រះករុណាសួរថា កូនមានចិត្តរវើរវាយទៅហើយឬ នាងក៏តបថា ប្អូនប្រុស ខ្ញុំមានចិត្តមិនបានរវើរវាយទេ កាលខ្ញុំព្រះករុណាសួរថា សុមនា កូនខ្លាចឬ នាងក៏តបថា មិនខ្លាចទេប្អូនប្រុស នាងពោលបានត្រឹមតែប៉ុណ្ណេះ ក៏ធ្វើកាលកិរិយាទៅ ព្រះអង្គ ។ លំដាប់នោះ ព្រះសម្មាសម្ពុទ្ធ ទើបត្រាស់ប្រាប់អនាថបិណ្ឌិកសេដ្ឋីថា ម្នាលគហបតី សុមនាកូនស្រីពៅរបស់លោក ជាអ្នកមិនមានចិត្តរវើរវាយទេ ។ អនាថបិណ្ឌិកសេដ្ឋី ទើបក្រាបទូលសួរថា បើជាយ៉ាងនោះមែន ហេតុអ្វីក៏នាងនិយាយដូច្នោះ ព្រះអង្គ ? ព្រះលោកនាថត្រាស់តបថា ព្រោះលោកជាប្អូនប្រុសនាងដោយពិត ( នាងទើបនិយាយជាមួយនឹងលោកដូច្នោះ ) ម្នាលគហបតី ដែលនាងសុមនា ហៅលោកដូច្នោះ គឺហៅទៅតាមគុណធម៌ ព្រោះលោកបានត្រឹមតែសោតាបន្ន ចំណែកនាងសុមនា នាងបានសម្រេចជាសកទាគាមី ទើបបានជានាងពោលដូច្នេះ នាងជាធំដោយមគ្គ និងផល ។

អនាថបិណ្ឌិកសេដ្ឋី ទើបក្រាបទូលសួរថា យ៉ាងនោះមែនឬ ព្រះអង្គ ? ព្រះលោកនាថត្រាស់តបថា ពិតយ៉ាងនោះហើយ គហបតី ។

អនាថបិណ្ឌិកសេដ្ឋីបានក្រាបទូលសួរដល់នាងសុមនាទេវី ដែលជាកូនស្រីពៅថា បពិត្រព្រះអង្គដ៏ចម្រើន តើពេលនេះ សុមនាទេវី នាងទៅកើតក្នុងទីណា ព្រះអង្គ ? ព្រះទសពលត្រាស់តបថា ម្នាលគហបតី នាងទៅកើតក្នុងស្ថានតុសិតហើយ ។ អនាថបិណ្ឌិកសេដ្ឋីទើបក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន តើកូនស្រីពៅរបស់ខ្ញុំព្រះករុណាជាអ្នករីករាយ ដូចកាលដែលគេនៅជាមួយនឹងពពួកញាតិក្នុងលោកនេះ ចុះភាពរីករាយនេះ មានចំពោះគេដែរឬទេព្រះអង្គ ក្នុងទេវលោកនោះ ? គ្រានោះ ព្រះសាស្តាត្រាស់ជាមួយនឹងអនាថបិណ្ឌិកសេដ្ឋីថា ត្រូវហើយ ម្នាលគហបតី គ្រហស្ថ ឬបព្វជិត ជាអ្នកមិនមានសេចក្តីប្រមាទ រមែងរីករាយក្នុងលោកនេះផង និងលោកខាងមុខផងយ៉ាងពិតប្រាកដ រួចហើយ ព្រះពុទ្ធអង្គទើបត្រាស់ព្រះគាថាក្នុងធម្មបទថា

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរ ក្នុងលោកទាំងពីរ គឺ ត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងត្រេកអរ ដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើ

មរណកាលទៅកាន់សុគតិភព ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

ក្នុងពេលដែលព្រះវិជិតមារ ទ្រង់ត្រាស់ទេសនានេះចប់ហើយ មានបុគ្គលជាច្រើន បានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ព្រះធម្មទេសនានេះ ក៏បានជាប្រយោជន៍ដល់មហាជន ដែលមកប្រជុំគ្នាក្នុងទីនោះ ។

កាពជាអ្នករិះគិតចាប់ផ្ដើម រកនូវវត្ថុដែលគួរធ្វើសក្ការបូជាទុកជំនួសព្រះលោកនាថ របស់អនាថបិណ្ឌិកសេដ្ឋី ដូចមានរឿងសម្ដែងនៅក្នុង **អដ្ឋកថា គម្ពីរខុទ្ទកនិកាយជាតក** នៃ **កលិង្គជាតក** ថា ៖-

សម័យមួយ ព្រះមានជោគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ហើយព្រះសាស្ដា បានស្ដេចយាងចារិកចៀសចេញពីវត្តជេតពនទៅកាន់ជនបទនានា ដោយមានព្រះពុទ្ធបំណងនឹងសង្គ្រោះដល់វេនេយ្យសត្វ ( សត្វដែលគួរទូន្មានប្រៀនប្រដៅបាន ) ។ពពួកអ្នកស្រុកក្រុងសាវត្ថី ក៏បាននាំគ្នាកាន់គ្រឿងសក្ការៈទាំងឡាយ មានផ្កាឈើនិងគ្រឿងក្រអូបជាដើមទៅឯវត្តជេតពន កាលដែលមិនមានកន្លែងដែល

គួរដាក់បូជានោះ ទើបនាំគ្នាយកគ្រឿងសក្ការៈទាំងនោះទៅដាក់ត្រង់ទ្វារព្រះគន្ធកុដិនៃព្រះទសពល ហើយក៏ត្រឡប់ទៅវិញ ។ ការធ្វើបែបនេះរបស់ពួកអ្នកក្រុងសាវត្ថី ដែលគ្រាន់តែយកគ្រឿងសក្ការៈទៅដាក់គោរពបូជាទុកនៅត្រង់មុខទ្វារព្រះគន្ធកុដិ រមែងមានចិត្តរីករាយយ៉ាងខ្លាំង ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានឃើញហេតុដូច្នេះហើយៗ ក្នុងពេលដែលព្រះសយម្ភូ ស្ដេចយាងត្រឡប់មកគង់ប្រថាប់ឯវត្តជេតពនវិញ អនាថបិណ្ឌិកសេដ្ឋីទើបចូលទៅរកព្រះអានន្ទ ហើយពិតថេរវាចាឡើងថា បពិត្រលោកម្ចាស់អានន្ទដ៏ចម្រើន វិហារនេះ ពេលដែលព្រះសាស្ដាស្ដេចយាងចារិកចៀសចេញទៅហើយ រមែងប្រាសចាកទីពឹងពំនាក់របស់ជនទាំងឡាយដែលជ្រះថ្លា ដោយមិនមានស្ថានទីដែលគួរធ្វើសក្ការបូជាមានផ្កាឈើ និងគ្រឿងក្រអូបជាដើមនោះ បើមានកន្លែងណាមួយគង់នឹងជាការល្អ ប្រសិនបើលោកម្ចាស់អានន្ទដ៏ចម្រើន ក្រាបទូលរឿងនេះឲ្យព្រះសម្ពុទ្ធទ្រង់ជ្រាប ហើយព្រះជិនស្រី ព្រះអង្គទ្រង់ត្រាស់អនុញ្ញាតស្ថានទីដែលគួរធ្វើសក្ការគោរពបូជានៅត្រង់ណា ពួកយើងនឹងនាំគ្នា

ទៅធ្វើសក្ការគោរពបូជា ដើម្បីជាប្រយោជន៍ និងដើម្បីសេចក្តីសុខលោកម្ចាស់ ។ ព្រះអានន្ទត្ថេរ បានពោលធានាគំនិតរបស់អនាថបិណ្ឌិកសេដ្ឋីថា ល្អហើយ ហើយព្រះអានន្ទក៏បានចូលទៅគាល់ ហើយក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន វត្ថុដែលគួរជាចេតិយ មានប៉ុន្មានព្រះអង្គ ? ព្រះមានបុណ្យត្រាស់ឆ្លើយថា ម្នាលអានន្ទ វត្ថុដែលគួរដល់ចេតិយ មាន ៣ យ៉ាង ដែលគួរដល់ការគោរពបូជា ។

ព្រះអានន្ទត្ថេរ ក្រាបទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន តើចេតិយមាន ៣ ប្រការ បានដល់អ្វីខ្លះ ព្រះអង្គ ? ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ចេតិយដែលមាន ៣ ប្រការនោះ បានដល់ **១. ធាតុចេតិយ** គឺព្រះចេតិយដែលបញ្ចុះព្រះសារីរិកធាតុរបស់ព្រះសម្ពុទ្ធ ឬព្រះអរហន្តធាតុ ។ **២. បរិភោគចេតិយ** គឺព្រះចេតិយដែលបញ្ចុះគ្រឿងបរិក្ខារប្រើប្រាស់ មានបាត្រ ចីវរ និងដើមពោធិព្រឹក្សជាដើម ។ **៣. ឧទ្ទិស្សកចេតិយ** គឺព្រះពុទ្ធរូបដែលសាងឡើងតំណាងព្រះភគវា ។ ព្រះអានន្ទត្ថេរ ក៏បានក្រាបទូលសួរទៀតថា បពិត្រព្រះអង្គ ទ្រង់និរទុក្ខ

កាលដែលព្រះមានព្រះភាគស្ដេចយាងចារិកទៅកាន់ទីដទៃ ខ្ញុំព្រះករុណា នឹងធ្វើព្រះចេតិយទុក គ្រាន់បានធ្វើសក្ការគោរពបូជាបានឬទេ ព្រះអង្គ ? គ្រានោះ ព្រះភគវាទ្រង់ត្រាស់បញ្ជាក់ថា ម្នាលអានន្ទ រីឯធាតុចេតិយ ពេលនេះមិនទាន់មានទេ ទាល់តែតថាគតបរិនិព្វានទៅទើបមាន ចំណែក ឧទ្ទិស្សកចេតិយវិញ ក៏មិនមានអ្នកណាមួយសាងឡើងដែរ ចំពោះដើម ពោធិព្រឹក្សដែលជាបរិភោគចេតិយនោះ ក៏នៅមានហើយ ជាទីសមគួរ ដល់ពុទ្ធបរិស័ទ ដែលជាអ្នកជ្រះថ្លាបានសព្វកាល ។

ព្រះអានន្ទត្ថេរ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុង ពេលដែលព្រះមានព្រះភាគ ស្ដេចយាងទៅកាន់ទីដទៃហើយ មិនមាន វត្ថុណានីមួយ ដែលនឹងជាទីសក្ការគោរពបូជា របស់ពួកពុទ្ធបរិស័ទ ទាំងឡាយទុកឯក្នុងវត្តជេតពននេះ ព្រោះដូច្នោះ ខ្ញុំព្រះករុណានឹងនាំ គ្រាប់ពូជមកអំពីដើមមហាពោធិ៍ យកមកដាំនៅត្រង់មាត់ទ្វារវត្តជេតពន ទុកដើម្បីធ្វើសក្ការគោរពបូជារបស់ពួកពុទ្ធបរិស័ទទាំងឡាយ ព្រះអង្គ ។ គ្រានោះ ព្រះមហាវីរៈទ្រង់ត្រាស់អនុញ្ញាតថា ម្នាលអានន្ទ ល្អហើយ

អ្នកចូរនាំយកមកដាំតាមបំណងចុះ ។ កាលព្រះអានន្ទត្ថេរ បានទទួលពុទ្ធានុញ្ញាតហើយ ទើបប្រាប់ដំណើររឿងនេះឲ្យដល់ព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី និងឧបាសិកាវិសាខា ហើយឲ្យមនុស្សជីករណ្ដៅដើម្បីដាំគ្រាប់ពូជមហាពោធិ៍ នៅជិតមាត់ទ្វារវត្តជេតពន ហើយក៏បានពោលនឹងព្រះមហាមោគ្គល្លានត្ថេរ ដោយឲ្យទៅអាពធនាគ្រាប់ពោធិ៍មកអំពីមហាពោធិ៍ កន្លែងដែលព្រះអង្គត្រាស់ដឹង យកមកប្រតិស្ឋានក្នុងទីនេះ ។ ព្រះមហាមោគ្គល្លានក៏បានទទួលភារៈនោះហើយក៏បាត់អំពីទីនោះ ទៅប្រាកដឯពោធិមណ្ឌលស្ថាន ដោយលាតចីវរឡើងគ្រាប់មហាពោធិ៍ ក៏បានជ្រុះធ្លាក់មកអំពីដើមមហាពោធិ៍ មកលើចីវររបស់ព្រះមហាមោគ្គល្លាន ដោយមិនបានធ្លាក់ទៅលើដី ហើយព្រះមហាមោគ្គល្លានក៏បាននាំយកទៅឲ្យព្រះអានន្ទ ។

ចំណែកព្រះអានន្ទ ក៏បានប្រាប់ដំណឹងឲ្យដល់ព្រះបាទបសេនទិកោសលជាដើម ឲ្យបានជ្រាបទាំងអស់ អំពីថ្ងៃដែលនឹងដាំគ្រាប់ពោធិ៍ និងពេលវេលា ដោយកំណត់យកពេលរសៀល ។ ក្នុងពេលរសៀល

ក្នុងថ្ងៃដែលដាំដើមពោធិ៍នោះ ព្រះបាទបសេនទិកោសល ទើបចាត់ឲ្យ ក្មាក់ងារ ( រាជបុរស ) កាន់គ្រឿងឧបករណ៍គ្រប់ប្រភេទ ស្តេចយាងទៅ ជាមួយនឹងរាជបរិវារទាំងនោះ ។ អនាថបិណ្ឌិកសេដ្ឋី និងឧបាសិកាវិសាខា ក៏បាននាំគ្នាកាន់គ្រឿងសក្ការគោរពបូជា ទៅកាន់ស្ថានទីនោះដែរ រីឯ បុគ្គលដទៃជាច្រើនទៀត ដែលជាអ្នកមានសទ្ធាជ្រះថ្លា ក៏បាននាំគ្នាទៅ កាន់ស្ថានទីនោះដូចគ្នា ។ ព្រះអានន្ទបានដាក់ផើងមាសដ៏ធំក្នុងរណ្តៅ ហើយឲ្យគេចោះបាតផើងមាស រួចដាក់គ្រាប់មហាពោធិ៍ ព្រមទាំងក្រាប ទូលថា សូមស្តេចបរមមហាបពិត្រ ព្រះរាជសម្ភារ ទ្រង់ដាំគ្រាប់ពោធិ៍ នេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ក៏បានទទួលគ្រាប់ មហាពោធិ៍ហើយ ទ្រង់មានព្រះរាជតម្រិះថា ភាពជាព្រះរាជារបស់យើង មិនអាចតម្រង់នៅអស់កាលជាអង្វែងទេ យើងគួរឲ្យអនាថបិណ្ឌិកសេដ្ឋី ដាំគ្រាប់ពោធិ៍នេះ ហើយព្រះលោកនាយកក៏ឲ្យគ្រាប់ពោធិ៍នេះទៅដល់ អនាថបិណ្ឌិកសេដ្ឋី ។ ចំណែកអនាថបិណ្ឌិកសេដ្ឋី កាលបើបានទទួល គ្រាប់ពោធិ៍នោះហើយ ទើបប្របាច់ដីភក់ ដែលផ្សំដោយគ្រឿងក្រអូប

ហើយក៏កប់គ្រាប់ពោធិ៍ទៅក្នុងដីកក់នោះ ។

តែពេលដែលគ្រាប់ពោធិ៍ ដែលអនាថបិណ្ឌិកសេដ្ឋីដាក់ផុតចុះអំពីដៃ ដើមពោធិ៍នោះក៏ធំឡើងមួយរំពេច ដោយមានកម្ពស់ប្រមាណ ៥០ ហត្ថ ហើយមានមែក ៥ គឺលាតសន្ធឹងទៅកាន់ទិសទាំង ៤ នោះ ៤ មែក និងលូតឡើងទៅខាងលើមួយមែក មែកនីមួយៗ ប្រមាណ ៥០ ហត្ថស្មើគ្នា ប្រាកដគួរឲ្យជាទីជ្រះថ្លារបស់ពួកមហាជនក្នុងពេលនោះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ប្រទានឲ្យធ្វើផើងប្រាក់ ផើងមាស ១០៨ ផើង ឲ្យដាក់គ្រឿងក្រអូបពេញ ហើយឲ្យដាំបទុមជាតិ កម្ពស់ប្រមាណមួយហត្ថជាដើម ឲ្យរៀបជាជួរជុំវិញដើមមហាពោធិ៍ និងឲ្យកសាងបុស្បុកដោយកែវទាំង ៧ ប្រការ ឲ្យរោយខ្សាច់ដែលលាយដោយត្បូងក្នុងបុស្បុក ឲ្យរៀបរបងជុំវិញគល់មហាពោធិ៍រីឯចំណែកទ្វាររបងធ្វើដោយកែវ ៧ ប្រការ លុះធ្វើរួចជាស្រេចសព្វគ្រប់អស់ហើយ ព្រះអានន្ទត្ថេរ បានចូលទៅគាល់ព្រះសម្ពុទ្ធ ដោយក្រាបទូលអារាធនាឲ្យព្រះអង្គយាងទៅគង់ប្រថាប់នៅត្រង់ដើមមហាពោធិ៍ និងក្រាបទូល

ឲ្យព្រះអង្គទ្រង់ចូលសមាបត្តិ នៅត្រង់គល់មហាពោធិ៍នោះទៀតផង ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលតថាគតចូលសមាបត្តិនៅត្រង់គល់មហាពោធិ៍នេះហើយ ចំណែកទីដទៃ ក៏មិនអាចនឹងទ្រទ្រង់បាន ( គឺកម្រើកញាប់ញ័រ ) ។

គ្រានោះ ព្រះអានន្ទ ទើបក្រាបទូលថា បើដូច្នោះ សូមព្រះអង្គទ្រង់យកនូវគល់មហាពោធិ៍នេះ នៅដោយសេចក្តីសុខ ដែលកើតអំពីសមាបត្តិចុះ ព្រះអង្គ ។ ព្រះមុនីក៏ទ្រង់យកនូវគល់មហាពោធិ៍នោះ ដោយនៅជាសុខ ដែលកើតអំពីសមាបត្តិអស់មួយរាត្រី ។ ចំណែកព្រះអានន្ទ ទើបប្រាប់ដល់ពុទ្ធបរិស័ទទាំងឡាយ មានព្រះបាទបសេនទិ-កោសលជាដើម ដែលមកធ្វើសក្ការៈក្នុងការយកគ្រាប់មហាពោធិ៍មកដាំ ឲ្យជ្រាបរឿងរ៉ាវទាំងអស់នោះ ។ តមក ដើមមហាពោធិ៍នោះ ឈ្មោះថា អានន្ទពោធិ៍ ព្រោះជាដើមមហាពោធិ៍ ដែលព្រះអានន្ទឲ្យយកមកដាំទុក ដើម្បីធ្វើសក្ការគោរពបូជាជំនួសព្រះមានជោគ ។

អនាថបិណ្ឌិកសេដ្ឋីជាពីជំនឹ ដោយបានស្តាប់ធម្មកថា របស់

ព្រះសារីបុត្រ ដូចមានរឿងតំណាលប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ ទុសីល្យសូត្រទី ១** មានសេចក្ដីថា ៈ-

សម័យមួយ ព្រះលោកនាថ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ។ កាលនោះ អនាថបិណ្ឌិកសេដ្ឋី មានជំងឺជាទម្ងន់ ហើយក៏បានបញ្ជូនបុរសម្នាក់ ឲ្យទៅពិតថេរវាចាដល់ព្រះសារីបុត្របាន ជ្រាប និងឲ្យនិមន្តលោកមកសួរសុខទុក្ខផង ។ គ្រានោះ ព្រះសារីបុត្រ កាលបើជ្រាបដូច្នោះហើយ ក៏បានគ្រងចីវរ ប្រដាប់ដោយបាត្រ និមន្ត ទៅសួរសុខទុក្ខអនាថបិណ្ឌិកសេដ្ឋី ក្នុងវេលាព្រឹក ដោយមានព្រះអានន្ទ និមន្តទៅជាមួយផង ។ កាលព្រះថេរៈទាំងពីរអង្គ និមន្តទៅដល់ផ្ទះ អនាថបិណ្ឌិកសេដ្ឋីហើយ ទើបសួរសុខទុក្ខថា យ៉ាងម៉េចទៅហើយ លោកគហបតី បានធូរស្រាលខ្លះទេ ? អនាថបិណ្ឌិកសេដ្ឋីពិតថេរដីកា តបថា បពិត្រលោកម្ចាស់ដ៏ចម្រើន អាការជំងឺរបស់ខ្ញុំព្រះករុណា មិន បានធូរស្រាលទេ មានតែធ្ងន់ធ្ងរឡើង ទុក្ខវេទនាកើតមានយ៉ាងខ្លាំងក្លា មិនអន់ថយឡើយ ។ ព្រះសារីបុត្រទើបពោលថា ម្នាលគហបតី បុថុជ្ជន

អ្នកមិនបានស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះអរិយៈ ទាំងមិនប្រកប ដោយសទ្ធា គឺភាពមិនតាំងមាំនៅក្នុងគុណព្រះពុទ្ធ នៅក្នុងគុណព្រះធម៌ នៅក្នុងគុណព្រះសង្ឃ យ៉ាងណានីមួយ ពេលដែលរាងកាយបែកធ្លាយ ទៅហើយ ( ស្លាប់ ) រមែងចូលទៅកាន់អបាយភូមិ ទុគ្គតិ វិនិបាត នរក ។ ( បុគ្គល ) ដែលជាអ្នកជ្រះថ្លាក្នុងគុណព្រះពុទ្ធ ក្នុងគុណព្រះធម៌ ក្នុងគុណព្រះសង្ឃ ដំណើរបែបនោះរមែងមិនមាន (ទៅកាន់អបាយភូមិ ជាដើម) ។ ម្នាលគហបតី បុថុជ្ជនដែលមិនជឿស្ដាប់ពាក្យប្រៀនប្រដៅ និងជាអ្នកទ្រុស្តសីល (គឺជាអ្នកល្មើសក្នុងសិក្ខាបទ ឬវិន័យ) យ៉ាងណា ថែមទាំងជាអ្នកប្រកបដោយការយល់ខុសយ៉ាងណា ជាអ្នកប្រកបដោយ ការត្រិះរិះខុស វាចាខុស ការងារខុស ការចិញ្ចឹមជីវិតខុស ការព្យាយាម ខុស ការរឭកខុស ការតាំងចិត្តខុស ដឹងខុស រួចផុតខុស យ៉ាងណា ភាពជាអ្នកទ្រុស្តសីល និងភាពជាអ្នកយល់ខុស ត្រិះរិះខុស សម្ដីខុស ការងារខុស ការចិញ្ចឹមជីវិតខុស ការព្យាយាមខុស ការរឭកខុស ការ តម្កល់ចិត្តខុស ការដឹងខុស ការរួចផុតខុសយ៉ាងនេះ របស់អ្នកមិនមាន

អ្នកមានតែសីលដែលល្អ គឺសីលដែលព្រះអរិយៈស្រឡាញ់ សីលមិនដាច់ពព្រុស ពពាល សីលដែលមិនជាទាសៈនៃតណ្ហា សីលដែលមិនប្រឡាក់ដោយតណ្ហា សីលដែលអ្នកប្រាជ្ញទាំងឡាយបានសរសើរហើយ សីលដែលធ្វើឲ្យកើតសមាធិ ។ អ្នកមានតែការយល់ត្រូវត្រិះរិះត្រូវ វាចាត្រូវ ការងារត្រូវ ចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ រឭកត្រូវ តម្កល់ចិត្តត្រូវ ដឹងត្រូវ រួចផុតត្រូវ កាលអ្នកពិចារណាសីល ការយល់ត្រូវ ការត្រិះរិះត្រូវ វាចាត្រូវ ការងារត្រូវ ចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ រឭកត្រូវ តម្កល់ចិត្តត្រូវ ដឹងត្រូវ រួចផុតត្រូវ ( សំដៅដល់ព្រះអរហន្ត ) ដែលនៅក្នុងខ្លួនរបស់អ្នកហើយ វេទនានឹងរំងាប់ទៅដោយឆាប់រហ័ស ។

លំដាប់តពីនោះមក អនាថបិណ្ឌិកសេដ្ឋី កាលបើបានស្តាប់ព្រះធម៌ដូច្នោះហើយ វេទនាក៏ស្ងប់រំងាប់អន់ថយចុះទៅដោយឆាប់រហ័សក្នុងពេលនោះឯង ។ អនាថបិណ្ឌិកសេដ្ឋី ក៏បានរៀបចំថ្វាយភត្តដល់ព្រះសារីបុត្រ និងព្រះអានន្ទដោយខ្លួនឯង ។ កាលព្រះថេរៈទាំងពីរអង្គឆាន់ភត្តរួចស្រេចហើយ អនាថបិណ្ឌិកសេដ្ឋី បានចូលទៅអង្គុយជិត

ព្រះថេរៈទាំងពីរ ហើយព្រះសារីបុត្របានពោលអនុមោទនាទានដោយធម្មកថា ដូចមានសេចក្តីថា

បុគ្គលណាមានសទ្ធាតាំងមាំដោយល្អហើយ មិនញាប់ញ័រក្នុងព្រះតថាគត និងជាអ្នកមានសីលល្អ ដែលជាទីពេញចិត្តនៃព្រះអរិយៈថែមទាំងព្រះអរិយៈបានសរសើរ ប្រកបដោយសទ្ធាជ្រះថ្លាចំពោះព្រះសង្ឃ មានការយល់ត្រង់ អ្នកមានញាណទាំងឡាយ ហៅបុគ្គលនោះថាមិនក្រីក្រ ជីវិតរបស់បុគ្គលនោះ ជាជីវិតមិនទទេ ព្រោះដូច្នោះ បុគ្គលដែលមានគំនិតល្អ បុគ្គលដែលរឭកដល់ព្រះពុទ្ធសាសនា គួរប្រកបនូវសទ្ធា និងសីល សេចក្តីជ្រះថ្លា និងការឃើញព្រះធម៌ ។

កាលពោលអនុមោទនាទានកថាចប់ហើយ ព្រះសារីបុត្រ និងព្រះអានន្ទបានក្រោកចាកអាសនៈ ចម្រើនពរត្រឡប់ទៅវិញ ។ ចំណែកព្រះអានន្ទ កាលត្រឡប់ទៅដល់វត្តជេតពនហើយ បានចូលទៅគាល់ព្រះសម្ពុទ្ធ ថ្វាយបង្គំរួចហើយ អង្គុយក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះភគវាត្រាស់សួរថា ម្នាលអានន្ទ អ្នកមកអំពីទីណា ? ព្រះអានន្ទក្រាបទូល

តបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណានិមន្តអំពីផ្ទះអនាថបិណ្ឌិក-សេដ្ឋីជាមួយនឹងព្រះសារីបុត្រ ដោយព្រះសារីបុត្របានទៅសួរសុខទុក្ខ និងសម្ដែងធម្មកថា ឲ្យដល់អនាថបិណ្ឌិកសេដ្ឋីបានស្ដាប់ ព្រះអង្គ ។ ព្រះជិនស្រី ក៏ទ្រង់ត្រាស់សរសើរព្រះសារីបុត្រថា ម្នាលអានន្ទ សារីបុត្រ ជាបណ្ឌិត ជាអ្នកមានបញ្ញាច្រើន ដែលបានចែកអង្គនៃព្រះសោតាបន្ន ៣ ប្រការ ដោយអាការ ១០ យ៉ាង ។

ភាពមិនទៀងនៃជីវិត គឺការចាស់គ្រាំគ្រា និងសេចក្ដីស្លាប់ រមែងមានទូទៅដល់សត្វលោកយ៉ាងពិតប្រាកដ បានកើតមានមកដល់ អនាថបិណ្ឌិកសេដ្ឋី ដែលមានទាំងប្រាក់ និងគុណធម៌នោះ ដូចដែល មានរឿងសម្ដែងប្រាកដនៅក្នុង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** នៃ **សឡាយតនវគ្គ** ដូចមានសេចក្ដីថា ៈ-

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង អនាថបិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្ដីទុក្ខ មានជំងឺធ្ងន់យ៉ាងខ្លាំង ។ គ្រានោះ

អនាថបិណ្ឌិកសេដ្ឋី ហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន អ្នកឯង ចូរមកអាយ ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរអ្នកថ្វាយបង្គំព្រះបាទាព្រះភគវាដោយសិរសា តាមពាក្យរបស់យើង រួចហើយ ចូរក្រាបបង្គំទូលយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន អនាថ-បិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់សូមក្រាបថ្វាយបង្គំព្រះបាទា ព្រះលោកនាយកដោយសិរសា រួចហើយចូរអ្នកថ្វាយបង្គំព្រះសារីបុត្រមានអាយុ តាមពាក្យរបស់យើង រួចហើយ ចូរអ្នកទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អនាថបិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់សូមថ្វាយបង្គំព្រះបាទាព្រះសារីបុត្រមានអាយុដោយសិរសា ដូច្នេះផង ចូរអ្នកទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្រមានអាយុ អាស្រ័យសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅរបស់អនាថ-បិណ្ឌិកសេដ្ឋី ដូច្នេះផង ។ បុរសនោះ ទទួលពាក្យអនាថបិណ្ឌិកសេដ្ឋីថា បាទ លោកដ៏ចម្រើន ហើយក៏ចូលទៅគាល់ព្រះសាស្តា លុះចូលទៅ

ដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ ។

លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះលោកនាយកដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អនាថបិណ្ឌិកសេដ្ឋីមានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់សូមក្រាបថ្វាយបង្គំព្រះបាទា ព្រះមានបុណ្យដោយសិរសា ហើយបុរសនោះ ក៏ចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូរទៅដល់ថ្វាយបង្គំព្រះសារីបុត្រមានអាយុហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយក៏ទូលព្រះសារីបុត្រមានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អនាថបិណ្ឌិកសេដ្ឋី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់សូមថ្វាយបង្គំព្រះបាទា ព្រះសារីបុត្រមានអាយុដោយសិរសា ហើយបុរសនោះទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរសូមព្រះសារីបុត្រមានអាយុ អាស្រ័យសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅរបស់អនាថបិណ្ឌិកសេដ្ឋី ( ឲ្យទាន ) ។ ព្រះសារីបុត្រមានអាយុ

ក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះសារីបុត្រមានអាយុស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ មានព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ ក៏ចូលទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលប្រគេន ។

លុះព្រះសារីបុត្រមានអាយុ គង់រួចហើយ ក៏មានថេរវាចានឹងអនាថបិណ្ឌិកសេដ្ឋីដូច្នេះថា ម្នាលគហបតី សរីរយន្ត អ្នកល្មមអត់ធន់បានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាបានស្រាកស្រាន្តមិនចម្រើនឡើងទេឬ ការធូរថយរមែងប្រាកដ ឯការចម្រើនឡើងរមែងមិនប្រាកដទេឬ ? បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំព្រះករុណា ចេះតែចម្រើនឡើង មិនស្រាកស្រាន្តទេ ការចម្រើនចេះតែប្រាកដ ការធូរថយមិនប្រាកដទេ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរសមានកម្លាំង ចាក់អំបែងក្បាលដោយដែកស្រួចមុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដ៏ខ្លាំងចាក់ដោតអំបែងក្បាលខ្ញុំព្រះករុណា

ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រ ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំព្រះករុណា រមែងចម្រើនឡើង មិនស្រាកស្រាន្តទេ ឥតធូរថយសោះ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរសមានកម្លាំងយកចង្វាយព្រ័ត្រដ៏មាំ មកត្របែងក្បាល យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដ៏ខ្លាំង ធ្មៀលក្បាលខ្ញុំព្រះករុណា ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទាដ៏ខ្លាំងក្លារបស់ខ្ញុំព្រះករុណា តែងចម្រើនឡើង មិនស្រាកស្រាន្តទេ ឥតធូរថយសោះ ។

បពិត្រព្រះសារីបុត្រដ៏ចម្រើន អ្នកសម្លាប់គោក្តី កូនសិស្សរបស់អ្នកសម្លាប់គោដ៏ឈ្លាសក្តី វះពោះ ដោយកាំបិតសម្រាប់វះគោដ៏មុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដែលខ្លាំង រមែងអាពោះរបស់ខ្ញុំព្រះករុណា ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនា

ដ៏ខ្លាំងក្លារបស់ខ្ញុំព្រះករុណា តែងចម្រើនឡើង មិនស្រាកស្រាន្ត ឥតធូរថយសោះ ។ បុរស ២ នាក់ មានកម្លាំងចាប់បុរសម្នាក់ដែលខ្សោយជាង ត្រង់ដើមដៃទាំងពីរ រោលកម្តៅលើរណ្តៅរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ឯសេចក្តីក្តៅក្រហាយដ៏ខ្លាំង ក្នុងកាយរបស់ខ្ញុំព្រះករុណា ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ខ្លាំងក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ ឥតធូរថយសោះ ។

ព្រះសារីបុត្រតបថា ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុ ទាំងវិញ្ញាណដែលអាស្រ័យចក្ខុរបស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវត្រចៀក ទាំងវិញ្ញាណដែលអាស្រ័យត្រចៀករបស់អាត្មាអញ ក៏នឹងមិនមានឡើយ

ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវច្រមុះ ទាំងវិញ្ញាណដែលអាស្រ័យច្រមុះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអណ្តាត ទាំងវិញ្ញាណដែលអាស្រ័យអណ្តាត របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវកាយ ទាំងវិញ្ញាណដែលអាស្រ័យកាយរបស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចិត្ត ទាំងវិញ្ញាណដែលអាស្រ័យហទយវត្ថុរបស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូបរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសំឡេង... នឹងមិនប្រកាន់នូវក្លិន... នឹងមិនប្រកាន់នូវរស... នឹងមិនប្រកាន់នូវផោដ្ឋព្វៈ... នឹងមិនប្រកាន់នូវធម្មារម្មណ៍ ទាំងវិញ្ញាណដែលអាស្រ័យធម្មារម្មណ៍របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញ នឹងមិនប្រកាន់ចក្ខុវិញ្ញាណ... នឹងមិនប្រកាន់នូវសោតវិញ្ញាណ... នឹងមិនប្រកាន់នូវឃានវិញ្ញាណ... នឹងមិនប្រកាន់នូវជិវ្ហាវិញ្ញាណ... នឹងមិនប្រកាន់នូវកាយវិញ្ញាណ... នឹងមិនប្រកាន់នូវមនោវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យហទយវត្ថុរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាល

គហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យចក្ខុសម្ផស្សរបស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសោតសម្ផស្ស... នឹងមិនប្រកាន់នូវឃានសម្ផស្ស... នឹងមិនប្រកាន់នូវជិវ្ហាសម្ផស្ស... នឹងមិនប្រកាន់នូវកាយសម្ផស្ស... នឹងមិនប្រកាន់នូវមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យមនោសម្ផស្សរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនាដែលកើតអំពីចក្ខុសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីចក្ខុសម្ផស្ស របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាង

នេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីសោតសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីឃានសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីជិវ្ហាសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីកាយសម្ផស្ស... នឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីមនោសម្ផស្ស របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវបឋវីធាតុ ទាំងវិញ្ញាណដែលអាស្រ័យបឋវីធាតុ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាបោធាតុ... នឹងមិនប្រកាន់នូវតេជោធាតុ... នឹងមិនប្រកាន់នូវវាយោធាតុ... នឹងមិនប្រកាន់នូវអាកាសធាតុ... ទាំងវិញ្ញាណ ដែលអាស្រ័យវិញ្ញាណធាតុ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះ

ចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សា យ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូប របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាង នេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវ សិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា.. នឹងមិនប្រកាន់ នូវសញ្ញា... នឹងមិនប្រកាន់នូវសង្ខារទាំងឡាយ... នឹងមិនប្រកាន់នូវ វិញ្ញាណ...ទាំងវិញ្ញាណដែលអាស្រ័យនាមរូបរបស់អាត្មាអញ ក៏នឹង មិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សា យ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាកាសានញ្ចាយតនៈ ទាំង វិញ្ញាណដែលអាស្រ័យអាកាសានញ្ចាយតនៈ របស់អាត្មាអញក៏នឹង មិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាល គហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវិញ្ញាណញ្ចាយតនៈ... នឹងមិនប្រកាន់នូវ

អាកិញ្ចញ្ញាយតនៈ... នឹងមិនប្រកាន់នូវនេវសញ្ញានាសញ្ញាយតនៈ... ទាំងវិញ្ញាណដែលអាស្រ័យនូវនេវសញ្ញានាសញ្ញាយតនៈ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកនេះ ( អដ្ឋកថា លោកនេះសំដៅយកកន្លែងសម្រាប់នៅ គ្រឿងសម្រាប់ស៊ី និងគ្រឿងស្លៀកពាក់ ) ទាំងវិញ្ញាណដែលអាស្រ័យនូវលោកនេះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកខាងមុខ ( **អដ្ឋកថា** សង្គ្រោះយកលោកដទៃ លើកលែងតែមនុស្សលោកចេញ ។ អធិប្បាយថា ឲ្យលះចិត្តគិតថា អាត្មាអញនឹងកើតក្នុងទេវលោកឯណោះ នៅក្នុងទេវលោកឯណោះ បរិភោគ និងស្លៀកដណ្តប់យ៉ាងនេះ ) ទាំងវិញ្ញាណ ដែលអាស្រ័យលោកខាងមុខ របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាង

នេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សា យ៉ាងនេះថា ធម្មជាតិណា ដែលអាត្មាអញបានឃើញហើយ ឮហើយ ប៉ះពាល់ហើយ ដឹងច្បាស់ហើយ ស្វែងរកហើយ ស្ទាបស្ទង់ដោយចិត្ត ហើយ អាត្មាអញនឹងមិនប្រកាន់នូវធម្មជាតិនោះ ទាំងវិញ្ញាណដែល អាស្រ័យធម្មជាតិនោះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

កាលដែលព្រះសារីបុត្រ មានថេរវាចាយ៉ាងនេះហើយ អនាថ-បិណ្ឌិកសេដ្ឋី យំសម្រក់ទឹកភ្នែក ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ មានថេរវាចានឹងអនាថបិណ្ឌិកសេដ្ឋីដូច្នេះថា ម្នាលគហបតី អ្នកជាប់ នៅក្នុងទ្រព្យសម្បត្តិឬ ម្នាលគហបតី អ្នកលិចនៅក្នុងទ្រព្យសម្បត្តិឬ ? អនាថបិណ្ឌិកគហបតីឆ្លើយថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំមិនជាប់ មិនលិចនៅក្នុងទ្រព្យសម្បត្តិទេ តែថា ខ្ញុំព្រះករុណា ដែលចូលទៅអង្គុយ ជិតព្រះសាស្តា អស់កាលយូរហើយផង ចូលទៅអង្គុយជិតពួកភិក្ខុ ជាអ្នកចម្រើនចិត្ត អស់កាលយូរហើយផង ក៏ខ្ញុំព្រះករុណា មិនដែល

បានស្តាប់ធម្មីកថាមានសភាពដូច្នេះឡើយ ។ ម្នាលគហបតី ធម្មីកថាមានសភាពដូច្នេះ តែងមិនច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀក.សទេ ម្នាលគហបតី ឯធម្មីកថាមានសភាពដូច្នេះ រមែងច្បាស់ប្រាកដដល់ពួកបព្វជិត ( តែប៉ុណ្ណោះ ) ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បើដូច្នោះធម្មីកថាមានសភាពដូច្នេះ សូមឲ្យបានច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀក.សផង បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា មានពួកកុលបុត្រដែលប្រកបដោយជាតិ ជាអ្នកមានធូលីតិចក្នុងភ្នែក ជាអ្នកដឹងច្បាស់នូវធម៌ ព្រោះតែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យចាកធម៌មិនខាន ។ លុះព្រះសារីបុត្រ និងព្រះអានន្ទដ៏មានអាយុទូន្មានអនាថបិណ្ឌិកគហបតីដោយឱវាទនេះរួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ កាលបើព្រះសារីបុត្រ និងព្រះអានន្ទដ៏មានអាយុចៀសចេញទៅ អស់កាលមិនយូរប៉ុន្មាន អនាថបិណ្ឌិកគហបតីក៏ធ្វើមរណកាល ទៅកើតក្នុងពួកទេវតាក្នុងស្ថានតុសិត ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្រ លុះរាត្រីបឋមយាមកន្លងទៅហើយ មានពន្លឺដ៏រុងរឿងញុំាងវត្តជេតពនទាំងអស់

ឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានជោគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះសាស្តា ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះអនាថ-បិណ្ឌិកទេវបុត្រស្ថិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះសម្ពុទ្ធ ដោយគាថាទាំងឡាយថា

វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅអាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជគង់អាស្រ័យនៅ ជាទីញ៉ាំងបីតិឲ្យកើតព្រមដល់ខ្ញុំព្រះអង្គ កម្ម គឺមគ្គចេតនា ១ វិជ្ជា គឺមគ្គប្បញ្ញា ១ ធម៌ទាំងឡាយជាបក្ខពួកខាងសមាធិ ១ សីលឈ្មោះថាជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយរមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះយ៉ាងនេះបាន មានតែព្រះសារីបុត្រ ១ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារំងាប់នូវកិលេសផង ទុកជាភិក្ខុណាដល់នូវត្រើយ គឺព្រះនិព្វាន ( ភិក្ខុនោះ )

ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

លុះអនាថបិណ្ឌិកទេវបុត្រពោលនូវគាថានេះចប់ ព្រះសាស្តា ក៏មានព្រះហឫទ័យត្រេកអរ ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្រ ដឹងថា ព្រះសាស្តារបស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំព្រះទសពល ធ្វើប្រទក្សិណ រួចក៏បាត់ក្នុងទីនោះទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ព្រះមានជោគត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ កាលដែលរាត្រីបឋមយាមកន្លងទៅហើយ ក្នុង យប់នេះឯង មានទេវបុត្រមួយអង្គ មានរស្មីដ៏រុងរឿង ញុំាំងវត្តជេតពន ទាំងអស់ឲ្យភ្លឺស្វាង ហើយក៏ចូលមករកតថាគត លុះចូលមកដល់ ថ្វាយបង្គំតថាគត ហើយស្ថិតនៅក្នុងទីសមគួរ ។ លុះទេវបុត្រនោះ ស្ថិតនៅក្នុងទីសមគួរហើយ ពោលគាថាទាំងនេះ ចំពោះតថាគតថា

វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅអាស្រ័យ ជានិច្ច ដែលព្រះពុទ្ធជាធម្មរាជគង់អាស្រ័យនៅ ជាទីញុំាំងបីតិឲ្យកើត ព្រមដល់ខ្ញុំព្រះអង្គ កម្ម គឺមគ្គចេតនា ១ វិជ្ជា គឺមគ្គប្បញ្ញា ១ ធម៌

ទាំងឡាយជាបក្ខពួកខាងសមាធិ ១ សីលឈ្មោះថាជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយរមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះយ៉ាងនេះបាន មានតែព្រះសារីបុត្រ ១ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារំងាប់នូវកិលេសផង ទុកជាភិក្ខុណាដល់នូវត្រើយ គឺព្រះនិព្វាន ( ភិក្ខុនោះ ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

ម្នាលភិក្ខុទាំងឡាយ លុះទេវបុត្រនោះ កាលពោលនូវគាថានេះចប់ហើយ ដឹងច្បាស់ថា ព្រះសាស្តារបស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ក៏បាត់ក្នុងទីនោះទៅ ។ កាលបើព្រះជិនស្រី មានពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមហាវីរៈដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្រនោះឯង ប្រាកដជាអនាថបិណ្ឌិកគហបតីនោះ បពិត្រ

ព្រះអង្គដ៏ចម្រើន ព្រោះអនាថបិណ្ឌិកគហបតី បានជ្រះថ្លាក្រៃពេក ក្នុងព្រះសារីបុត្រមានអាយុ ។ ម្នាលអានន្ទ ត្រូវហើយៗ ម្នាលអានន្ទ ហេតុដែលអ្នកបានត្រិះរិះនោះ ត្រូវហើយ ទេវបុត្រនោះ គឺអនាថបិណ្ឌិកសេដ្ឋីហ្នឹងឯង មិនមែនអ្នកដទៃទេ ។ លុះព្រះទសពល ទ្រង់ត្រាស់នូវពាក្យនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្ដីត្រេកអរ រីករាយនឹងភាសិតព្រះសម្ពុទ្ធណាស់ ។

ការបានសម្រេចជាព្រះសោតាបន្ន របស់អនាថបិណ្ឌិកសេដ្ឋីចាត់ជាករណីពិសេស ព្រោះលោកអស់ជីវិតទៅ បានទៅកើតក្នុងទេវលោក ដោយមិនវិលត្រឡប់មកកើតក្នុងមនុស្សលោកទៀតឡើយ ដូចដែលមានសម្ដែងទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនៃ **គម្ពីរបុគ្គលប្បញ្ញត្តិ ព្រះអភិធម្មបិដក** ថា ៖-

អនាថបិណ្ឌិកសេដ្ឋី និងមហាឧបាសិកាវិសាខាជាដើម ដែលមានគ្នាទាំងអស់ ៧ នាក់ ( ជន ៥ នាក់ទៀត គឺចូឡរដ្ឋទេវបុត្រ មហារដ្ឋទេវបុត្រ អនេកវណ្ណទេវបុត្រ សក្កទេវរាជ និងនាគទត្តទេវបុត្រ )

ជាសោតាឧទ្ធំសោតៈ គឺជាអ្នកត្រូវទៅកើតក្នុងស្ថានសួគ៌ជាន់តៗ ទៅទៀតដោយលំដាប់ រហូតទៅដល់ជាន់សុទ្ធាវាសព្រហ្ម ហើយលោកនឹងបរិនិព្វានក្នុងអកនិដ្ឋកព្រហ្ម គឺរូបព្រហ្មជាន់ខ្ពស់បំផុត ក្នុងព្រហ្មទាំង ១៦ ជាន់ ដែលជាជាន់ប្រសើរជាង ជាន់សុទ្ធាវាសព្រហ្មខាងក្រោម ៤ ដោយមិនត្រឡប់មកកើត ក្នុងមនុស្សលោកទៀតឡើយ តែជាព្រះសោតាបន្ន ដែលហៅថា **វដ្តកិរតិ** ប្រែថា អ្នកត្រេកអរក្នុងវដ្តៈ គឺស្លាប់កើត កើតស្លាប់ក្នុងទេវលោកជាលំដាប់ ទាំងនេះរាប់ថា ជាអ្នកពេញចិត្តក្នុងវដ្តៈ បុញ្ញបារមីរបស់លោក ដែលបានធ្វើរួចមកហើយ អស់កាលដ៏យូរអង្វែងនោះ ទើបធ្វើឲ្យលោកបានសោយទិព្វសម្បត្តិក្នុងស្ថានសួគ៌ ជាន់ផ្សេងៗ រហូតអស់កាលដ៏យូរអង្វែង ហើយទីបំផុតលោកក៏បានរំលត់ខន្ធបរិនិព្វាន នៅក្នុងអកនិដ្ឋកព្រហ្ម ជាបរិយោសាននៃជីវិតរបស់លោក ដែលសម្រេចមកអំពីការបំពេញបុណ្យបារមី ។

( ជីវប្រវត្តិរបស់អនាថបិណ្ឌិកសេដ្ឋី ចប់ )

8888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះនាងឧប្បលវណ្ណាថេរី ✍

## " ព្រះនាងឧប្បលវណ្ណាថេរីជាអគ្គសាវិកាឆ្វេង និងជាអ្នកមានឫទ្ធិ "

ព្រះនាងឧប្បលវណ្ណាថេរី ជាអ្នកទ្រទ្រង់នូវគុណ ដ៏ឧត្តុង្គឧត្តមខ្ពង់ខ្ពស់ ថែមទាំងជាអ្នកបានទទួលការលើកតម្កើងពីព្រះសក្យមុនី ឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងជាអ្នកមានឫទ្ធិ ជាពិសេសនោះ ព្រះនាងបានទ្រទ្រង់នូវកិត្តិយសក្នុងឋានៈជាអគ្គសាវិកាឆ្វេង របស់ព្រះសាស្ដាទៀតផង ចំណែកជីវប្រវត្តិរបស់ព្រះនាងឧប្បលវណ្ណា មានសម្ដែងទុកក្នុងគម្ពីរផ្សេងៗ ជាច្រើន យ៉ាងពិស្ដារ មានទាំងបច្ចុប្បន្នជាតិ និងអតីតជាតិផងដែរ ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិ របស់ព្រះនាងឧប្បលវណ្ណាថេរី ដូចមានសម្ដែងប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** និងក្នុង **អដ្ឋកថាធម្មបទ នៃ ពាលវគ្គ** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជា

អដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** ដូចមានសេចក្តីថា ៖

**ព្រះនាងឧប្បលវណ្ណាថេរី** បានមកបដិសន្ធិ គឺកើតក្នុងត្រកូលសេដ្ឋី នៅក្នុងក្រុងសាវត្ថី មាតាបិតារបស់នាង បានដាក់ឈ្មោះ ឲ្យនាងថា **ឧប្បលវណ្ណា** ព្រោះនាងមានពណ៌សម្បុរកាយដូចផ្កាឧប្បលខៀវ ។ ពួកញាតិ មាតា បិតាជាដើម កាន់យកនិមិត្តនាម ទើបដាក់ឈ្មោះឲ្យនាងដូច្នេះ ។ កាលតមក នាងឧប្បលវណ្ណាមានវ័យចម្រើនពេញក្រមុំឡើងហើយ នាងមានរូបរាងល្អស្អាតណាស់ ដែលជាហេតុធ្វើឲ្យព្រះរាជាទាំងឡាយ ជាដើម ក្នុងជម្ពូទ្វីប ទ្រង់មានសេចក្តីប្រាថ្នាចង់បាននាងឧប្បលវណ្ណា ទុកជាសម្បត្តិរបស់ខ្លួនរៀងៗ ខ្លួន មួយអង្គៗ ក៏ទ្រង់បញ្ជូនរាជសាសន៍ ឬរាជបណ្ណាការឲ្យទៅដល់លោកសេដ្ឋីជាបិតាថា សូមលោកសេដ្ឋី លើកធីតារបស់លោកឲ្យដល់ខ្ញុំ ។ ប្រាកដថា មានបុរសជាច្រើនទៀត បានបញ្ជូនបណ្ណាការ ទៅឲ្យដល់លោកសេដ្ឋីនោះក៏មានច្រើនដែរ ។ លោកសេដ្ឋី កាលបានទទួលរាជសាសន៍ ឬទទួល

រាជបណ្ណាការពីព្រះរាជាទាំងឡាយជាច្រើន ក្នុងជម្ពូទ្វីប ហើយដែលទ្រង់បានបញ្ជូនមនុស្សមកជាប់តគ្នា ធ្វើឲ្យមានការធុញទ្រាន់ចិត្តដល់ហេតុការណ៍ដែលកើតឡើង ទើបគិតថា យើងមិនអាចនឹងយកចិត្តបុរសទាំងអស់នោះបាន តែយើងនឹងធ្វើឧបាយយ៉ាងណាមួយ លុះគិតរកឧបាយបានហើយ លោកទើបហៅនាងឧប្បលវណ្ណាមកសួរថា ឧប្បលវណ្ណាកូន កូនអាចនឹងចេញបួសបានទេ ? ពាក្យដែលលោកសេដ្ឋីនិយាយដូច្នេះ ប្រៀបដូចជាប្រេងល្វ ដែលគេរម្ងាស់ហើយ រម្ងាស់ទៀត ១០០ ដង ដែលបុគ្គលស្រោចដាក់នូវលើក្បាលហើយ អាចហូរជ្រួតជ្រាបចូលទៅក្នុងស្បែកបានដោយងាយ យ៉ាងណាមិញ ចំពោះពាក្យនេះ ដែលពោលប្រាប់ដល់នាងឧប្បលវណ្ណាក៏ដូច្នោះដែរ ព្រោះនេះជាភពចុងក្រោយនៃជីវិតរបស់នាង ដែលនាងមានការត្រាច់រង្គាត់ក្នុងសង្សារវដ្តអស់កាលដ៏យូររកប្រមាណមិនបាន ។ នាងឧប្បលវណ្ណា ទើបឆ្លើយទៅកាន់បិតាដោយមិនបានស្ទាក់ស្ទើរក្នុងចិត្តថា ចាស លោកឪពុក កូនអាចបួសបាន ។ លោកសេដ្ឋី កាលបើឮដូច្នេះហើយ ក៏សប្បាយចិត្តចំពោះឧបាយ

របស់ខ្លួនបានសម្រេចតាមបំណង ហើយលោកក៏បានរួចផុតអំពីកង្វល់នៅក្នុងចិត្ត ដែលកំពុងជួបប្រទះ ទើបបានរៀបចំគ្រឿងសក្ការៈជាច្រើនដើម្បីនាងឧប្បលវណ្ណា និងនាំនាងទៅកាន់សម្នាក់ភិក្ខុនី ហើយឲ្យបួសនៅក្នុងសម្នាក់ភិក្ខុនីនោះឯង ។ កាលនាងឧប្បលវណ្ណាថេរី បួសហើយមិនយូរប៉ុន្មាន ក៏ដល់កំណត់នាទីទទួលវេនរៀបចំរោងឧបោសថ នាងបានអុជប្រទីបបំភ្លឺ និងបោសសំអាត ជូតរោងឧបោសថហើយ នាងបានកាន់យកនិមិត្តនៃអណ្តាតប្រទីបនិងសម្លឹងមើលធ្វើឲ្យកើតឈានដោយតេជោកសិណ (សម្លឹងភ្លើងជាអារម្មណ៍ ហើយធ្វើឈាននោះឲ្យជាទីតាំង នាងក៏បានសម្រេចជាព្រះអរហន្តី ដល់ព្រមដោយបដិសម្ភិទា ៤ និងអភិញ្ញា ៦ ហើយគុណធម៌ទាំងនេះឯង ដែលជាហេតុធ្វើឲ្យនាងជាអ្នកស្ទាត់ជំនាញ ក្នុងការសម្តែងឫទ្ធិផ្សេងៗ បាន ។

ភាពជាអ្នកក្លៀវក្លាអង់អាចក្នុងការសម្តែងនូវឫទ្ធិ របស់ព្រះនាងឧប្បលវណ្ណាថេរី ដែលអាចជ្រាបទៅបាននោះ ពីព្រោះមានសម្តែងនៅក្នុង អដ្ឋកថាធម្មបទ នៃ ពុទ្ធវគ្គ ក្នុងរឿងយមកប្បាដិហារិយ៍ថា ៖

ក្នុងថ្ងៃដែលព្រះសាស្តា ទ្រង់សម្តែងយមកប្បាដិហារិយ៍ ដើម្បីកាច់បំបាក់ទិដ្ឋិពួកអន្យតិ្ថយ និងពួកនិគ្រន្ថ ដែលមកនិយាយបង្អុជម្លោះជាមួយគ្នានឹងព្រះអង្គ ។ គ្រានោះ ព្រះនាងឧប្បលវណ្ណាថេរី បានបន្លឺសីហនាទ ( បន្លឺសំឡេង ដូចជាសំឡេងរបស់រាជសីហ៍ ) ថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមសម្តែងបាដិហារិយ៍ជំនួសព្រះអង្គវិញ ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរឧប្បលវណ្ណាថា នាងនឹងសម្តែងនូវបាដិហារិយ៍យ៉ាងណា ? ព្រះនាងឧប្បលវណ្ណាថេរី ក្រាបទូលតបថា ខ្ញុំម្ចាស់នឹងសម្តែងឲ្យមានបរិស័ទប្រមាណ ១២ យោជន៍ ជាបរិមណ្ឌលដោយជុំវិញ និងជាស្តេចចក្រពត្តិ ដែលមានបរិស័ទក្នុងបរិវេណស្ថានទីប្រមាណ ៣៦ យោជន៍ជាវង់មូលព័ទ្ធជុំវិញ ហើយចូលមកថ្វាយបង្គំព្រះមានបុណ្យ ។ គ្រានោះព្រះសាស្តាត្រាស់រ៉ាប់រងថា ឧប្បលវណ្ណា តថាគតដឹងដល់អានុភាព ( ឫទ្ធិតេជះ ) របស់នាង ហើយព្រះអង្គទ្រង់ត្រាស់ហាមឃាត់ព្រះថេរីមិនឲ្យសម្តែងបាដិហារិយ៍ឡើយ ។

នៅមានសេចក្តីមួយទៀត ដែលទាក់ទងនឹងការសម្តែងឫទ្ធិរបស់ព្រះនាងឧប្បលវណ្ណាថេរី ដែលជាការបង្ហាញឲ្យឃើញថា ព្រះថេរីជាអ្នកមានឫទ្ធិជាច្រើន តាមដែលមានសម្តែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** នៃ **ទ្វាទសកនិបាត** ដូចមានសេចក្តីថា ៖

ក្នុងវេលាដែលព្រះបរមគ្រូ ទ្រង់នឹងសម្តែងយមកប្បាដិហារិយ៍ ខ្ញុំម្ចាស់បានសម្តែងឫទ្ធិរបស់ខ្លួននិម្មិតរថ ទឹមដោយសេះ ៤ ចូលទៅថ្វាយបង្គំព្រះយុគលបាទ របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់មានសិរី ទ្រង់ជាទីពឹងរបស់សត្វលោក ហើយទើបបានប្រតិស្ឋាននៅទី ១ ដ៏សមគួរ ។ សេចក្តីទាំងនេះ ជាការបង្ហាញឲ្យឃើញថា ព្រះនាងឧប្បលវណ្ណាថេរី ជាអ្នកមានឫទ្ធិច្រើន អាចសម្តែងឫទ្ធិផ្សេងៗ ចេញមកបាន តែសេចក្តីទាក់ទង ក្នុងរឿងការសម្តែងឫទ្ធិរបស់ព្រះថេរី នៅមានសម្តែងទុកក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដែលនឹងត្រូវលើកយកមកសម្តែងក្នុងវគ្គតទៅទៀតខាងមុខ ។

ព្រះមានព្រះភាគ ទ្រង់បានលើករឿងដែលព្រះឧប្បលវណ្ណាថេរី

ដែលជាអ្នកមានសេចក្ដីអង់អាច អាចបន្លឺសីហនាទ ហើយក្រាបទូល សូមសម្ដែងយមកប្បាដិហារិយ៍ជំនួសព្រះអង្គជាដើមហេតុ ទើបធ្វើឲ្យព្រះអង្គទ្រង់ត្រាស់សរសើរលើកតម្កើងព្រះថេរី ឲ្យជាឯតទគ្គៈ តាមដែលមានសម្ដែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

សម័យមួយ ព្រះលោកនាថទ្រង់គង់នៅកណ្ដាលភិក្ខុសង្ឃ ក្នុងវត្តជេតពន ព្រះអង្គបានប្រកាសតែងតាំងភិក្ខុនីទាំងឡាយ ទុកនៅក្នុងតំណែងជាឯតទគ្គៈផ្សេងៗ សមគួរទៅនឹងបុណ្យបារមីរៀងៗ ខ្លួន ដែលបានសន្សំមកហើយ ពេលនោះដែរ ព្រះលោកនាថក៏បានទ្រង់ប្រកាសតែងតាំង ព្រះនាងឧប្បលវណ្ណាថេរីមួយរូបផងដែរ ដូចមានសេចក្ដីថា

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា** ម្នាលភិក្ខុទាំងឡាយ នាងឧប្បលវណ្ណា ជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ដែលជាសាវិការបស់តថាគត ផ្នែកខាងជាអ្នកមានឫទ្ធិ ។

ក្រោយអំពីព្រះនាងឧប្បលវណ្ណាថេរី បានទទួលការលើកតម្កើង

ឲ្យជាអ្នកប្រសើរ ផ្នែកខាងជាអ្នកមានឫទ្ធិហើយ ព្រះនាងជាម្ចាស់បាន ទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ គឺបានជាអគ្គសាវិកាឆ្វេងរបស់ព្រះពុទ្ធអង្គ គូនឹងព្រះនាងខេមាថេរី ដែលជាអគ្គសាវិកាស្តាំរបស់ព្រះអង្គ ។

**ជីវប្រវត្តិបច្ចុប្បន្នជាតិ** របស់ព្រះនាងឧប្បលវណ្ណាថេរី ក៏មានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ពាលវគ្គ** និងក្នុង **អដ្ឋកថាគម្ពីរបឋមសមន្តប្បាសាទិកា** ដូចមានសេចក្តីថា ៖

កាលតមក ក្រោយពីព្រះនាងឧប្បវណ្ណាថេរី សម្រេចជាព្រះអរហន្តីហើយ ព្រះនាងជាម្ចាស់បានចារិក គឺត្រាច់ទៅក្នុងជនបទ ដើម្បីជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ដែលជាការកសាងប្រយោជន៍ឲ្យទៅដល់សង្គម ហើយត្រឡប់ចូលទៅនៅក្នុងព្រៃអន្ធវ័ន ( ព្រៃក្រាស់ ឬព្រៃបោរខ្វាក់ភ្នែក ) ។ ក្នុងរយៈវេលានោះ ព្រះមានបុណ្យ ទ្រង់នៅមិនទាន់បានបញ្ញត្តហាមភិក្ខុនីទាំងឡាយនៅក្នុងព្រៃ ។ គ្រានោះ ពួកមនុស្សបានកសាងខ្ទមនិងតម្កល់គ្រែបាំងវាំងននទុកក្នុងព្រៃអន្ធវ័ន ប្រគេនដល់ព្រះនាងឧប្បលវណ្ណាថេរី ។ វេលាព្រឹកឡើង ព្រះថេរីបានចូលទៅ

បិណ្ឌបាត នៅក្នុងក្រុងសាវត្ថី ហើយត្រឡប់ចេញពីក្រុងមកកាន់ខ្ទមទីសម្រាករបស់ខ្លួនវិញ ។ ក្នុងគ្រានោះ ក៏មាននន្ទមាណព ដែលជាកូនអំរបស់ព្រះថេរី ធ្លាប់បានមានចិត្តប្រតិព័ទ្ធ គឺស្រឡាញ់ចំពោះព្រះថេរីមកតាំងពីពេលដែលនាងនៅជាគ្រហស្ថ លុះគេជ្រាបដំណឹងថា ព្រះថេរីសម្រាកនៅក្នុងព្រៃ គេទើបចូលទៅកាន់ព្រៃអន្ធវននោះ ដើម្បីនៅរង់ចាំមុន ព្រះថេរីត្រឡប់មកពីបិណ្ឌបាត គេទើបចូលទៅនៅក្នុងខ្ទមហើយលាក់ខ្លួន នៅខាងក្រោមគ្រែរបស់ព្រះថេរី ។ ចំណែកព្រះនាងឧប្បលវណ្ណាថេរីត្រឡប់មកដល់ ទើបចូលទៅក្នុងខ្ទម បិទទ្វារហើយក៏អង្គុយនៅលើគ្រែ ពេលដែលព្រះថេរីចូលមកក្នុងខ្ទមថ្មីៗ ភ្នែកក៏នៅងងឹតមិនអាចមើលឃើញច្បាស់ ព្រោះត្រូវពន្លឺថ្ងៃខាងក្រៅ ។ គ្រានោះនន្ទមាណព ដែលលាក់ខ្លួននៅខាងក្រោមគ្រែ ទើបចេញមក ហើយក៏បានទៅចាប់ព្រះថេរី ដែលអង្គុយនៅលើគ្រែ ដើម្បីប្រព្រឹត្តអសទ្ធម្មជាមួយនឹងព្រះថេរី ។ ពេលនោះ ព្រះនាងឧប្បលវណ្ណា មានថេរវាចាហាមថា នែបុគ្គលពាល អ្នកកុំធ្វើយ៉ាងនេះឡើយ បើអ្នកធ្វើយ៉ាងនេះ

អ្នកនឹងវិនាសមិនខាន ។ នន្ទមាណព បានឮថេរីវាចាហាមរបស់ព្រះនាងដូច្នេះហើយ ក៏នៅតែប្រព្រឹត្តទៅតាមចំណង់របស់ខ្លួនទៀតទៅលើព្រះថេរី កាលប្រព្រឹត្តរួចស្រេចហើយ ក៏បានរត់គេចចេញទៅបាត់ ។ ខណៈដែលព្រះនាងឧប្បលវណ្ណាថេរី ត្រូវនន្ទមាណពប្រទូស្តនោះ នាងជាម្ចាស់ មិនមានការត្រេកអរក្នុងអសទ្ធម្មនោះឡើយ ឧបមាដូចបង្គោលថ្ម ឬដង្គត់ឈើគគីរដូច្នោះដែរ ។

ប៉ុន្តែកម្មដ៏ធ្ងន់ដែលនន្ទមាណព បានប្រទូស្តចំពោះព្រះអរហន្តីទីណាស្រេតនោះ ផែនដីដ៏ធំ និងមានកម្រាស់ក្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏មិនអាចទ្រទ្រង់ទម្ងន់ទោស ដែលនន្ទមាណពបានធ្វើហើយដែរ ភ្លាមៗ នោះ ផែនដីក៏បែកជាពីរចំណែក ស្រូបយកនន្ទមាណពទៅបានធ្លាក់ទៅក្នុងអវិចីមហានរក ។ ព្រះនាងឧប្បលវណ្ណាថេរី ដែលត្រូវនន្ទមាណពប្រទូស្តហើយ ក៏បានប្រាប់រឿងរ៉ាវទាំងអស់នោះ ឲ្យភិក្ខុនីទាំងឡាយបានជ្រាប ភិក្ខុនីទាំងនោះ ក៏បាននាំយកសេចក្តីនោះ ទៅក្រាបទូលព្រះវិជិតមារឲ្យទ្រង់ជ្រាប ។ កាលព្រះមានជោគ ទ្រង់ព្រះ

សណ្តាប់រឿងនោះហើយ ទ្រង់ក៏បានត្រាស់ហៅភិក្ខុទាំងឡាយ ឲ្យចូលគាល់ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនថាបុគ្គលពាល អ្នកណាទីមួយ ធ្វើបាបកម្មចំពោះភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា លុះធ្វើបាបកម្មដ៏លាមកនោះរួចហើយ ក៏នៅតែត្រេកអររីករាយ ដូចជាមានះឡើងៗ ឬប្រៀបដូចជាបុរសទំពារបស់ដែលមានរសផ្អែម មានទឹកឃ្មុំស្ករត្នោតជាដើម ព្រះអង្គក៏ទ្រង់ត្រាស់សម្តែងព្រះគាថាថា

ដរាបណាបាបមិនទាន់ឲ្យផល បុគ្គលពាល សម្គាល់ថា បាបនោះ មានរសជាតិផ្អែមដូចទឹកឃ្មុំ ដល់ពេលណា បាបឲ្យផល ទើបបុគ្គលពាលនោះ បានចូលដល់នូវសេចក្តីទុក្ខ ដែលលំបាកគ្រាំគ្រា ជាទីបំផុត ។

ព្រះគាថានេះ មានសេចក្តីអធិប្បាយថា កាលបើបុគ្គលពាលធ្វើបាប គឺអកុសលកម្ម កម្មនោះរមែងប្រាកដដូចទឹកឃ្មុំ ដែលមានរសផ្អែម មើលហើយគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត បុគ្គលពាលនោះ រមែងសម្គាល់ថាបាបនោះ ដូចជាទឹកឃ្មុំ ដរាបណា បាបនៅមិន

ទាន់ឲ្យផល ក្នុងទិដ្ឋធម៌ ( ក្នុងបច្ចុប្បន្ន ) ឬក្នុងសម្បរាយិកភព ( ភពខាងមុខ ) ។ ក្នុងកាលណា កាលបើបុគ្គលពាលនោះត្រូវបាបកម្មនោះឲ្យផលហើយ គេរមែងទទួលសេចក្តីទុក្ខក្នុងបច្ចុប្បន្ននេះផង និងធ្លាក់ទៅកាន់អបាយភូមិ មាននរកជាដើម ក្នុងសម្បរាយិកភព បាបនោះឈ្មោះថាឲ្យផល ក្នុងកាលនោះ បុគ្គលពាលនោះ រមែងប្រសព្វនឹងសេចក្តីទុក្ខជារឿយៗ ។ វេលាព្រះលោកនាយក ទ្រង់ត្រាស់ព្រះធម៌ទេសនាចប់ មានមនុស្សជាច្រើនបានសម្រេចអរិយផល មានព្រះសោតាបត្តិផលជាដើម ។

លុះសម័យខាងក្រោយមក មហាជនបាននាំយករឿងរបស់ព្រះនាងឧប្បលវណ្ណាថេរី មកសន្ទនាគ្នានៅក្នុងសាលាធម្មសភាថា សូម្បីព្រះខីណាស្រព ( អ្នកអស់កិលេសហើយ ) ទាំងឡាយ ប្រហែលជានឹងនៅមានសេចក្តីត្រេកអរក្នុងកាមសុខ នៅសេពកាម ដូចម្តេចនឹងមិនសេព ព្រោះព្រះខីណាស្រពទាំងនោះ មិនមែនឈើពុក មិនមែនដំបូក សឹងមានសាច់ និងរាងកាយនៅស្រស់នៅឡើយ ព្រោះដូច្នោះ

សូម្បីព្រះវីណាស្រេពទាំងនោះ ក៏គង់នៅមានការត្រេកអរក្នុងកាមសុខ និងសេពកាម ។ គ្រានោះ ព្រះបរមសាស្ដា ស្ដេចត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាពីរឿងអ្វី ? ភិក្ខុទាំងឡាយនោះក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះករុណាទាំងឡាយបានសន្ទនាគ្នា ពីរឿងព្រះវីណាស្រេពទាំងឡាយ នៅត្រេកអរក្នុងកាមសុខ និងនៅសេពកាម ព្រះអង្គ ។ លំដាប់នោះ ព្រះទសពលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះវីណាស្រេពទាំងឡាយ មិនត្រេកអរក្នុងកាមសុខ និងមិនសេពកាមឡើយ ដូចជាតំណក់ទឹកដែលស្រក់ចុះពីលើស្លឹកឈូក រមែងមិនជាប់ និងមិនទើរត្រង់ពាក់កណ្ដាល ហើយរមៀលធ្លាក់ចុះមកអំពីលើស្លឹកឈូក យ៉ាងណាមិញ នឹងដូចគ្រាប់ស្ពៃរមែងមិនជាប់ មិនតាំងនៅលើចុងដែកស្រួច រមែងរមៀលធ្លាក់ចុះមកចាកចុងដែកស្រួច យ៉ាងណា សូម្បីកាមទាំងពីរយ៉ាង ( **១- កិលេសកាម** គឺកិលេសដែលធ្វើឲ្យសេចក្ដីស្រឡាញ់កើតឡើង **២- វត្ថុកាម** គឺវត្ថុដែលគួរឲ្យស្រឡាញ់ បានដល់ កាមគុណ ៥ ) រមែងមិនជ្រៀតចូល មិន

តាំងនៅក្នុងចិត្តរបស់ព្រះឧីណាស្រេព ដូច្នោះដែរ ។

កាលព្រះលោកនាថ ទ្រង់នឹងបន្តរឿងដើម្បីសម្តែងធម្មទេសនា ទើបត្រាស់ព្រះគាថា ដែលមានសម្តែងប្រាកដទុកនៅក្នុង គម្ពីរធម្មបទ ខុទ្ទកនិកាយ នៃ ព្រាហ្មណវគ្គ ក្នុងរឿងព្រះនាងឧប្បលវណ្ណាថេរីថា ៖

បុគ្គលណា មានចិត្តមិនជាប់នៅ ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា មានមហាជនជាច្រើន ដែលបានស្តាប់ព្រះធម៌ទេសនាក្នុងពេលនោះ បានសម្រេចអរិយផលទាំងឡាយ មានព្រះសោតាបត្តិផលជាដើម ។ លុះហេតុការណ៍ដែលមិនល្អ មិនស្អាតកើតឡើង ចំពោះភិក្ខុនីដូច្នេះហើយ ទើបព្រះលោកនាថ ត្រាស់ឲ្យយាងព្រះបាទបសេនទិកោសល ព្រះរាជានៃដែនកោសល ដែលទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្រុងសាវត្ថី មកគាល់ព្រះអង្គ ហើយព្រះអង្គត្រាស់ថា មហាបពិត្រ កុលធីតាទាំងឡាយ ក្នុងព្រះពុទ្ធសាសនានេះ

លះបង់ពពួកញាតិជាច្រើន និងគំនរទ្រព្យសម្បត្តិជាច្រើនចេញមកបួស ហើយនៅអាស្រ័យក្នុងព្រៃ ដូចគ្នានឹងកុលបុត្រទាំងឡាយដ៏ច្រើនដែរ តែមនុស្សពាលដ៏លាមក ដែលត្រូវរាគៈ ( តម្រេក ) កើតឡើងក្នុងចិត្តហើយ រមែងប្រទូស្តចំពោះភិក្ខុនីនៅក្នុងព្រៃ ដោយសេចក្តីប្រមាថមើលងាយខ្លះ ទាំងនេះជាហេតុធ្វើឲ្យកើតអន្តរាយដល់ព្រហ្មចរិយធម៌ ( ការប្រព្រឹត្តធម៌ដ៏ប្រសើរ ឬការចេញបួសដែលលះនូវមេថុន ) ខ្លះ ព្រោះដូច្នោះ សូមមហាបពិត្រ គួរធ្វើទីនៅខាងក្នុងក្រុង ឲ្យដល់ភិក្ខុនីផងចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសលត្រាស់ទទួលថា ល្អហើយព្រះករុណាម្ចាស់ ហើយមានព្រះរាជឱង្ការឲ្យកសាងទីលំនៅ សម្រាប់ទីនៅរបស់ភិក្ខុនី នៅក្នុងកន្លែងមួយ នៅក្នុងក្រុង ។ ចាប់តាំងអំពីនោះមក ភិក្ខុនីទាំងឡាយ បាននៅខាងក្នុងស្រុកតែប៉ុណ្ណោះ ។

ភាពជាអ្នកអង់អាច ក្នុងការសម្តែងឫទ្ធិផ្សេងៗ របស់ព្រះនាងឧប្បលវណ្ណាថេរី តាមដែលមានសម្តែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដោយព្រះថេរី ជាអ្នកពោលតំណាលអំពីក្រសែជីវិត របស់

ព្រះនាងផ្ចាល់ខ្លួនឯងទុក ដូចមានសេចក្ដីថា ៖

ឧប្បលវណ្ណាភិក្ខុនី ដល់នូវត្រើយនៃឫទ្ធិ បានថ្វាយបង្គំព្រះបាទា ព្រះលោកនាយក ហើយពោលនូវពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ឆ្លងផុត នូវជាតិសង្សារហើយ ដល់នូវព្រះនិព្វាន ជាទីមិនកម្រើក ខ្ញុំម្ចាស់សូមក្រាបទូលនូវទុក្ខទាំងពួង របស់ខ្ញុំម្ចាស់ដែលអស់ហើយ ។ ពួកបរិស័ទទាំងប៉ុន្មាន ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី កំហុសរបស់ខ្ញុំម្ចាស់ មានចំពោះពួកជនណា សូមពួកជននោះ អត់ទោស ក្នុងទីចំពោះព្រះភក្ត្រនៃព្រះជិនស្រីឲ្យទាន ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់កំពុងអន្ទោលទៅក្នុងសង្សារ បើខ្ញុំម្ចាស់មានសេចក្ដីភ្ញាត់ភ្លាំង ខ្ញុំម្ចាស់សូមអង្វរ សូមព្រះអង្គអត់ទោសចំពោះកំហុសនៃខ្ញុំម្ចាស់នោះ ។ ម្នាលនាង ចូរនាងធ្វើតាមសាសនារបស់តថាគត បើដូច្នោះ ចូរនាងសម្ដែងនូវឫទ្ធិចុះ ចូរនាងញ៉ាំងបរិស័ទទាំង ៤ ឲ្យកាត់នូវសេចក្ដីសង្ស័យទាំងប៉ុន្មាន ក្នុងថ្ងៃនេះចុះ ។ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញា ទ្រទ្រង់នូវសេចក្ដីរុងរឿង ខ្ញុំម្ចាស់ជាធីតារបស់ព្រះអង្គ

ចំណែកខាងអំពើដ៏ច្រើន ដែលគេកម្រធ្វើបាន ខ្ញុំព្រះអង្គបានធ្វើឲ្យជា អំពើ រឹតតែកម្រក្រៃលែង ។ បពិត្រព្រះអង្គ ជាមហាវីរបុរស ទ្រង់មានបញ្ញាចក្ខុ សម្បុររបស់ខ្ញុំម្ចាស់ ដូចជាសម្បុរនៃផ្កាឧប្បល ខ្ញុំម្ចាស់មានឈ្មោះថា ឧប្បលវណ្ណា ជាធីតារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទា ។ ព្រះរាហុលត្ថេរ និងខ្ញុំម្ចាស់ធ្លាប់កើតក្នុងភពតែមួយ អស់រយៃនៃជាតិជាច្រើន ជាអ្នកមានចិត្ត និងមានឆន្ទៈស្មើគ្នា ។ ការកើតឡើងក្នុងភពជាមួយគ្នាក៏មាន ក្នុងជាតិជាមួយគ្នាក៏មាន លុះដល់បច្ឆិមជាតិជនទាំងពីរនាក់កើតដោយឈ្មោះ ( ផ្សេងគ្នា ) ។ ព្រះរាជបុត្រ បានមកជាកុមារឈ្មោះរាហុល ខ្ញុំម្ចាស់បានមកជាធីតាឈ្មោះឧប្បលវណ្ណា ។

បពិត្រព្រះអង្គ ជាវីរបុរស សូមព្រះអង្គ ទតឫទ្ធិនៃខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់នឹងសម្តែងកម្លាំងថ្វាយព្រះសាស្តា ។ នាងឧប្បលវណ្ណា ដាក់មហាសមុទ្រទាំង ៤ លើផ្ទៃបាតដៃ ។ នាងឧប្បលវណ្ណា ធ្ពឹះផែនដី ដាក់លើផ្ទៃបាតដៃ ដូចក្មេងជំទង់ដាក់នូវយ៉ាបូងដ៏វិចិត្រ ។ នាងឧប្បលវណ្ណាបាំងនូវបាតដៃស្មើចក្កវាឡលើក្បាល ហើយញុំាងគ្រាប់ភ្លៀង មានពណ៌

ផ្សេងៗ ឲ្យធ្លាក់ចុះ ។ នាងធ្វើផែនដីជាត្បាល់ ធ្វើគ្រួសជាស្រូវ ធ្វើភ្នំសិនេរុជាអង្រែ ដូចក្មេងបុកស្រូវ ។ ខ្ញុំម្ចាស់ឈ្មោះឧប្បលវណ្ណា ជាធីតារបស់ព្រះពុទ្ធដ៏ប្រសើរ ជាអ្នកស្ទាត់ក្នុងអភិញ្ញាទាំងឡាយ ជាអ្នកធ្វើតាមសាសនារបស់ព្រះអង្គ ។ បពិត្រព្រះអង្គ មានបញ្ញាចក្ខុ ខ្ញុំម្ចាស់សូមធ្វើនូវវិកុព្វនឫទ្ធិផ្សេងៗ សម្ដែងថ្វាយព្រះទសពល ហើយប្រកាសនូវនាម និងគោត្រ ទើបថ្វាយបង្គំព្រះបាទាព្រះអង្គ ។ បពិត្រព្រះភគវា ខ្ញុំម្ចាស់ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុឫទ្ធិផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាស ទាំងទិព្វចក្ខុក៏ខ្ញុំម្ចាស់ជម្រះហើយ អាសវៈទាំងអស់ ក៏អស់រលីងហើយ ឥឡូវនេះភពថ្មីទៀត មិនមានទៀតទេ ។ ញាណរបស់ខ្ញុំម្ចាស់ដ៏ទូលាយស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ តាមសភាពរបស់ព្រះពុទ្ធជាមហេសី ។ បពិត្រព្រះមហាមុនី ព្រះអង្គធ្លាប់សម្ដែងនូវសង្គ្រោមចំពោះព្រះជិនស្រីដ៏ប្រសើរទាំងឡាយ ក្នុងកាលមុន កិច្ចការដ៏ក្រៃលែងច្រើនយ៉ាងរបស់ខ្ញុំម្ចាស់ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ព្រះអង្គ ។បពិត្រព្រះសុគត

អំពើណាមានក្នុងកាលមុន ដែលខ្ញុំម្ចាស់បានធ្វើហើយ សូមព្រះអង្គ រឭកនូវអំពើជាកុសលរបស់ខ្ញុំម្ចាស់នោះ ។ បពិត្រព្រះសយម្ភូ បុណ្យ ដែលខ្ញុំម្ចាស់សន្សំទុកហើយ ដើម្បីជាប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រ ព្រះអង្គជាសក្កៈ ខ្ញុំម្ចាស់វៀរ ( នូវអំពើ ) ក្នុងទីមិនគួរ ហើយបាន ទាត់ចោលនូវអនាចារ ជីវិតដ៏ឧត្តម ដែលខ្ញុំម្ចាស់លះបង់ហើយ ដើម្បី ជាប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះជិនស្រី ព្រះអង្គបានប្រទាន ជីវិតដល់ខ្ញុំម្ចាស់ អស់ ១០ ពាន់កោដិ ទាំងខ្លួនខ្ញុំម្ចាស់បានលះបង់ហើយ ដើម្បីជាប្រយោជន៍ដល់ព្រះអង្គ ។ គ្រានោះ បរិស័ទទាំងអស់ស្ញប់ស្ញែង ក្រៃលែង ធ្វើអញ្ជលីដោយត្បូង បានពោលថា បពិត្រព្រះនាងម្ចាស់ សេចក្តីព្យាយាមមានឫទ្ធិច្រើនមិនបាន ដែលនាងធ្វើហើយ តើដូចម្តេច ?

សេចក្តីថា រឿងដែលទាក់ទងនឹងការសន្សំបុណ្យបារមី នៅក្នុង អតីតជាតិរបស់ព្រះនាងឧប្បលវណ្ណាថេរី នឹងបាននាំមកពោលទុកក្នុង អតីតជាតិរបស់នាង ចំណែកក្នុងវគ្គតទៅទៀតនេះ នឹងនាំយករឿង បច្ចុប្បន្នជាតិ របស់ព្រះនាងឧប្បលវណ្ណាថេរី តាមដែលមានសម្តែង

នៅក្នុង គម្ពីរសំយុត្តនិកាយ សគាថវគ្គ និងក្នុង គម្ពីរខុទ្ទកនិកាយ ថេរីគាថា និងក្នុង គម្ពីរខុទ្ទកនិកាយ អបទាន ដែលពោលទាក់ទងរឿងមារមករុកកួនព្រះនាងឧប្បលវណ្ណាថេរី ថា ៖

គ្រាមួយ ព្រះសាស្តា ទ្រង់គង់នៅវត្តជេតពន ជិតក្រុងសាវត្ថី ។ ក្នុងសម័យនោះ ព្រះនាងឧប្បលវណ្ណាថេរី ត្រឡប់ពីបិណ្ឌបាតពីក្រុងសាវត្ថី ក្នុងវេលាបច្ឆាភត្ត គឺតាំងអំពីពេលថ្ងៃជ្រេពីត្រង់ទៅ ព្រះថេរីបានចូលទៅនៅក្នុងព្រៃអន្ធវន និងទៅឈរនៅក្រោមដើមរាំងមួយដើមដែលមានផ្ការីកស្គុសស្គាយ ។ គ្រានោះ មារមានចិត្តបាប ប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោមឲ្យកើតឡើងដល់ព្រះនាងឧប្បលវណ្ណាភិក្ខុនី មានប្រាថ្នាឲ្យឃ្លាតចាកសមាធិ ហើយចូលទៅរកឧប្បលវណ្ណាភិក្ខុនី លុះចូលទៅដល់ហើយ បានពោលគាថានឹងព្រះឧប្បលវណ្ណាភិក្ខុនីថា ម្នាលភិក្ខុនី នាងអាស្រ័យ នូវដើមសាលព្រឹក្ស ( រាំង ) មានចុងប្រកបដោយផ្ការីកស្គុសស្គាយ ស្ថិតនៅតែម្នាក់ឯងក្រោមម្លប់ដើមសាលព្រឹក្ស ជាតុ គឺភេទ ( ភិក្ខុនីជាអ្នកមិនមានឡើយ )

ជាគម្រប់ពីររបស់នាងមិនមាន គួរតែមានស្ត្រីទាំងឡាយ ប្រាកដដូចជានាងមកនៅក្នុងទីនេះផង នាងខ្លាចអំពើពាល របស់ពួកអ្នកលេងឬ ? លំដាប់នោះ ឧប្បលវណ្ណាភិក្ខុនី មានសេចក្តីត្រិះរិះយ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬអមនុស្ស ( មក ) ពោលគាថា ដូច្នេះ ។ លុះនាងឧប្បលវណ្ណាភិក្ខុនីដឹងច្បាស់ថា នេះជាមារមានចិត្តបាប ហើយបានពោលគាថាទាំងឡាយ នឹងមារមានចិត្តបាបថា អ្នកលេងមួយរយនាក់ក៏ដោយ មួយពាន់នាក់ក៏ដោយ ជនទាំងឡាយ ប្រាកដដូចជាអ្នកដែលមកក្នុងទីនេះក៏ដោយ យើងក៏មិនព្រឺរោម មិនតក់ស្លុតទេ ម្នាលមារ យើងសូម្បីតែម្នាក់ឯងមែន ក៏មិនខ្លាចអ្នកឡើយ យើងនេះចង់បាត់ទៅក៏បាន ចង់ចូលក្នុងពោះអ្នកក៏បាន អ្នកមិនឃើញយើង ដែលកំពុងស្ថិតនៅក្នុងចន្លោះរោមភ្នែកឡើយ យើងជាស្ត្រីស្ទាត់នៅក្នុងចិត្តឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយដោយប្រពៃ យើងផុតហើយចាកចំណងទាំងអស់ ។ នៃអាវុសោ យើងមិនខ្លាចអ្នកទេ ។ លំដាប់នោះមារមានចិត្តបាបដឹងថា ឧប្បលវណ្ណាភិក្ខុនី ស្គាល់ខ្លួនហើយ ក៏មាន

សេចក្តីទុក្ខតូចចិត្ត បាត់អំពីទីនោះទៅ ។

ចំណែកឯជីវប្រវត្តិអតីតជាតិ របស់ព្រះនាងឧប្បលវណ្ណាថេរី ដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** និងក្នុង **អដ្ឋកថាមនោរថបូរណី** តែរឿងខ្លះក្នុងគម្ពីរទាំងពីរនេះ មានសេចក្តីផ្សេងគ្នាខ្លះ ដូច្នេះ សូមលើកយកន័យទាំងពីរគម្ពីរនោះ ដើម្បីមកជាសេចក្តីប្រៀបធៀបគ្នា ក្នុងវគ្គដំបូងនេះ សូមលើកយកសេចក្តីនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដែលបានសម្តែងអំពីបុព្វចរិយា របស់ព្រះថេរីមកសម្តែងមុន ដែលជាការពោលអំពីដំណើរជីវិតខ្លួនឯងផ្ទាល់ ក្រោយពីនាងបានសម្រេចអរិយធម៌ដ៏ខ្ពង់ខ្ពស់បំផុត ជាព្រះអរហន្តីហើយ ដូចដែលមានសេចក្តីថា ៖

ក្នុងកប្បទីមួយសែន អំពីកប្បនេះ កាលនោះ ខ្ញុំកើតជាកញ្ញានៃនាគ ឈ្មោះ **នាងវិមលា** ដែលគេសន្មតហៅថា ជាស្រីល្អជាងនាគកញ្ញាទាំងឡាយ ។ ពស់ធំឈ្មោះ **មហានាគ** ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី បាននិមន្តព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់មានតេជះច្រើន

ព្រមទាំងសាវ័ក ។ មហានាគនោះ បានរៀបចំនូវមណ្ឌប ជាវិការនៃកែវ ផង នូវបល្ល័ង្កជាវិការនៃកែវផង នូវគ្រឿងបរិភោគជាវិការនៃកែវផង ដែលលាយដោយខ្សាច់ជាវិការនៃកែវផង នូវផ្លូវដែលស្អិតស្អាងដោយ ទង់ជ័យជាវិការនៃកែវផង ហើយប្រគំដោយតូរ្យតន្ត្រីទទួលព្រះពុទ្ធ ។ ចំណែកខាងព្រះលោកនាថ ដែលបរិស័ទទាំង ៤ បានហែហមហើយ ទ្រង់គង់លើអាសនៈដ៏ប្រសើរ ក្នុងលំនៅនៃមហានាគ ។ ស្តេចនាគបាន ថ្វាយនូវបាយទឹកផង នូវភោជនដែលគេបរិភោគមានតម្លៃច្រើនផង នូវ ពរដ៏ប្រសើរផង ចំពោះព្រះពុទ្ធ ទ្រង់មានយសធំ ។ លុះព្រះសម្ពុទ្ធនោះ ទ្រង់សោយហើយ ទ្រង់លាងបាត្រ ហើយធ្វើអនុមោទនា ដោយឧបាយ នៃប្រាជ្ញាថា ចូរនាងនាគកញ្ញាមានឫទ្ធិច្រើនចុះ នាងនាគកញ្ញាបានឃើញ ព្រះសម្ពុទ្ធ ដែលទ្រង់ស្រស់បស់ មានយសច្រើន ចិត្តក៏ជ្រះថ្លាចំពោះ ព្រះសាស្តាផង ចិត្តក៏ប្រតិព័ទ្ធចំពោះព្រះសាស្តាផង ។ ក្នុងខណៈនោះ ព្រះសម្ពុទ្ធ ជាមហាវីរបុរស ព្រះនាមបទុមុត្តរៈ ទ្រង់ជាក់ច្បាស់នូវចិត្ត របស់ខ្ញុំ ទ្រង់បង្ហាញនូវភិក្ខុនីដោយឫទ្ធិ ។ ភិក្ខុនីនោះក្លៀវក្លា សម្តែង

នូវឫទ្ធិច្រើនប្រការ ខ្ញុំក៏រីករាយត្រេកអរ បានពោលពាក្យនេះ ចំពោះព្រះសាស្តាថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ខ្ញុំម្ចាស់បានឃើញឫទ្ធិទាំងនេះដែលរាប់ថាក្រៃលែងជាងឫទ្ធិឯទៀត ភិក្ខុនីនោះក្លៀវក្លាដោយឫទ្ធិខ្លាំងម៉្លេះ តើដោយប្រការដូចម្តេច ? ភិក្ខុនីនេះជាធីតា ជាឱរស កើតអំពីមាត់របស់តថាគត ទើបជាភិក្ខុនី មាននូវឫទ្ធិច្រើន ជាអ្នកធ្វើតាមអនុសាសនីរបស់តថាគត បានជានាងមានសេចក្តីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ។ លុះខ្ញុំស្តាប់ព្រះវាចានៃព្រះពុទ្ធហើយ ក៏ត្រេកអរពោលនូវពាក្យយ៉ាងនេះថា សូមឲ្យខ្ញុំម្ចាស់ ជាស្ត្រីក្លៀវក្លាក្រៃលែង ដោយឫទ្ធិប្រាកដដូចជាភិក្ខុនីនោះ ។

បពិត្រព្រះអង្គ ជានាយក ខ្ញុំម្ចាស់មានចិត្តអរសប្បាយរីករាយមានចិត្តខ្ពង់ខ្ពស់ សូមឲ្យបានដូចភិក្ខុនីនេះ ក្នុងកាលអនាគតកុំខាន ។ ( ខ្ញុំបានថ្វាយ ) នូវបល្ល័ង្កជាវិការនៃកែវមណីផង នូវមណ្ឌបដ៏ភ្លឺផ្លេកផង ហើយញុំាងព្រះពុទ្ធជាលោកនាយក ព្រមទាំងភិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ខ្ញុំបូជាផ្កាឧប្បលឈ្មោះ អរុណ

ជាផ្កាដ៏ប្រសើររបស់ពួកនាគ ចំពោះព្រះពុទ្ធជាលោកនាយក ហើយ សូមឲ្យពណ៌សម្បុរ របស់ខ្ញុំដូចជាពណ៌ផ្កានេះ ។ ដោយអំពើដែលខ្ញុំ ធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ខ្ញុំលះបង់រាង កាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងស្ថានតាវត្តិង្ស ។ លុះ ខ្ញុំចុតិចាកស្ថានតាវត្តិង្សនោះហើយ ក៏មកកើតស្ថានមនុស្ស បានថ្វាយ បិណ្ឌបាតដែលបិទបាំងដោយផ្កាឧប្បលទាំងឡាយ ចំពោះព្រះពុទ្ធជា សយម្ភូ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយក ព្រះនាម វិបស្សី មានព្រះនេត្រដ៏ភ្លឺថ្លា មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ទ្រង់កើត ឡើង ។ ក្នុងកាលនោះ ខ្ញុំបានកើតជាសេដ្ឋីធីតា ក្នុងបុរីដ៏ឧត្តម ឈ្មោះ ពារាណសី បាននិមន្តព្រះសម្ពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃ ខ្ញុំថ្វាយមហាទាន បូជាព្រះពុទ្ធជានាយក ដោយផ្កាឧប្បលទាំងឡាយ ហើយប្រាថ្នាឲ្យមានពណ៌សម្បុរ ល្អដូចផ្កាឧប្បលទាំងនោះ ។ នៅក្នុង កទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មាន យសច្រើន ប្រសើរជាងពួកជនពាល ទ្រង់កើតឡើង ។ គ្រានោះ ព្រះ

រាជាដែនកាសី ព្រះនាមកិកិ ជាឥស្សរៈលើប្រជាជន ក្នុងក្រុងពារាណសីបូរីដ៏ប្រសើរ បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។ ខ្ញុំជាធីតាទី ២ របស់ព្រះរាជាអង្គនោះ ឈ្មោះនាងសមណគុត្តា បានស្តាប់ធម៌របស់ព្រះពុទ្ធជិនស្រី ជាបុគ្គលប្រសើរហើយ ពេញចិត្តនឹងបព្វជ្ជា ។ គ្រានោះ ព្រះវររាជបិតារបស់យើង ទ្រង់មិនអនុញ្ញាត យើងក៏មិនខ្ជិលប្រអូសប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារី អស់ ២០ ពាន់ឆ្នាំ នៅក្នុងផ្ទះ ជារាជកញ្ញាស្ថិតនៅក្នុងសេចក្តីសុខ ត្រេកអរក្រៃក្នុងការបម្រើព្រះពុទ្ធ ព្រះរាជធីតា ៧ អង្គ គឺព្រះនាងសមណី ១ ព្រះនាងសមណគុត្តា ១ ព្រះនាងភិក្ខុនី ១ ព្រះនាងភិក្ខុទាសិកា ១ ព្រះនាងធម្មា ១ ព្រះនាងសុធម្មា ១ ព្រះនាងសង្ឃទាសី ១ ។ ( ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះ ធីតាទាំងនោះបានមកជា ) ១ ព្រះនាងសមណីបានមកជាព្រះនាងខេមាថេរី ២ ព្រះនាងសមណគុត្តា បានមកជាព្រះនាងឧប្បលវណ្ណាថេរី ៣ ព្រះនាងភិក្ខុនី បានមកជាព្រះនាងបដាចារាថេរី ៤ ព្រះនាងភិក្ខុនីទាសិកា បានជាព្រះនាងកុណ្ឌលកេសីថេរី ៥

ព្រះនាងធម្មា បានមកជាព្រះនាងកិសាគោតមីថេរី ៦ ព្រះនាងសុធម្មា បានមកជាព្រះនាងធម្មទិន្នាថេរី ៧ ព្រះនាងសង្ឃទាសី បានមកជាមហាឧបាសិកាវិសាខា ។ កាលព្រះនាងសមណគុត្តាទិវង្គតហើយ បានទៅកើតក្នុងស្ថានតាវត្តិង្ស និងវេលាច្យុតចាកស្ថានតាវត្តិង្សនោះហើយមកកើតក្នុងមនុស្សត្រកូលធំ ។ ក្នុងជាតិនេះ ឧប្បលវណ្ណាភិក្ខុនី នាងកើតជាធីតានៃត្រកូលធំ បានមានកុសលចិត្ត ថ្វាយនូវសំពត់សាច់ម៉ដ្ឋមានពណ៌លឿងដល់ព្រះអរហន្តមួយរូប ។ លុះអស់ជីវិតចាកជាតិដែលជាធីតានៃត្រកូលធំហើយ ក៏បានទៅកើតនៅក្នុងត្រកូលព្រាហ្មណ៍ ក្នុងអរិដ្ឋបុរី ដោយបានជាធីតានៃតិរិដិវច្ឆសេដ្ឋី ឈ្មោះនាងឧម្មាទន្តី ដែលមានសេចក្តីថា អ្នកនាំមកនូវភាពជាទីពេញចិត្ត របស់បុរសទាំងឡាយ ។ ទាំងនេះ ព្រោះនាងមានរូបរាងស្អាតណាស់ បុរសដែលបានឃើញនាងហើយ រមែងមានសេចក្តីពេញចិត្ត វង្វេងប្រាថ្នាក្នុងខ្លួននាង ។

រីឯជីវប្រវត្តិនៅក្នុងអតីតជាតិ របស់ព្រះនាងឧប្បលវណ្ណាភិក្ខុនី ដែលពោលដល់ការធ្វើអធិការកុសល ដែលជាផល ឲ្យបានទទួលនូវ

តំណែងជាឯតទគ្គៈ និងបានសម្រេចជាព្រះអរហន្ត៍ មាននៅក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** មានសេចក្ដីប្លែកផ្សេងគ្នាពី **គម្ពីរខុទ្ទកនិកាយ អបទាន** តាមដែលពោលរួចមកហើយខាងដើមនោះ តែការកសាងបុណ្យកុសលដទៃៗ ក្នុងជាតិផ្សេងៗ នោះ មានដូចគ្នាខ្លះ ផ្សេងគ្នាខ្លះក៏មាន ដូចមានសេចក្ដីថា ៖

គ្រាពុទ្ធកាល នៃព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់ ដោយរាប់ត្រឡប់ថយក្រោយពីកប្បនេះមួយសែនកប្ប ។ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានចុះកាន់បដិសន្ធិ គឺកើតនៅក្នុងផ្ទះ របស់អ្នកមានធនធានម្នាក់ ក្នុងនគរហង្សវតី ។ លុះនាងចម្រើនវ័យធំដឹងក្ដីហើយ នាងបានចូលទៅគាល់ព្រះបទុមុត្តរសម្ពុទ្ធ ព្រមជាមួយមហាជន ខណៈដែលនាងស្ដាប់ធម៌បានឃើញព្រះពុទ្ធ ជានាយក ទ្រង់ប្រកាសតែងតាំងភិក្ខុនីមួយរូបទុកក្នុងតំណែងជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងជាអ្នកមានឫទ្ធិ ។ នាងទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះបទុមុត្តរៈជាព្រះប្រធាន អស់ ៧ ថ្ងៃ ហើយតាំងនូវសេចក្ដីប្រាថ្នាក្នុង

តាំណែងនោះ តពីនោះមក នាងក៏បានធ្វើបុណ្យកុសលរហូតអស់ជីវិត កាលនាងអស់ជីវិតទៅហើយ បានត្រាច់រង្គាត់វិលស្លាប់កើត ជាមនុស្ស និងទេវតាអស់កាលដ៏យូរអង្វែង ។ ក្នុងពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ នាងក៏បានត្រឡប់មកកើតជាព្រះរាជធីតា របស់ព្រះបាទកិកិ ក្នុងនគរពារាណសី ទ្រង់មានព្រះនាមថា ព្រះនាងសមណគុត្តា ដែលរួមនៅក្នុងបណ្តាព្រះរាជធីតា ៧ អង្គ ដែលនាំគ្នាប្រព្រឹត្តព្រហ្មចរិយៈ អស់ ២០ ពាន់ឆ្នាំ ទ្រង់បានកសាងបរិវេណទីសម្រាកថ្វាយភិក្ខុសង្ឃ ។ ក្រោយពីព្រះនាងសមណគុត្តាទិវង្គតហើយ បានទៅកើតក្នុងទេវលោក ( ដូចដែលបានពោលទុករួចមកហើយពីខាងដើម ) ។ ប៉ុន្តែក្នុងជាតិមួយ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានមកកើតក្នុងត្រកូលមួយ ដែលជាត្រកូលអ្នកមិនមានធនធាន ដោយនៅជនបទមួយកន្លែង ជាត្រកូលដែលប្រកបការងារដោយដៃរបស់ខ្លួនឯង ។ ថ្ងៃមួយ នាងបានទៅកាន់ទីខ្ទមឯវាលស្រែ ឃើញផ្កាឈូករីកនៅក្នុងស្រះមួយរវាងផ្លូវ នាងទើបចុះទៅក្នុងស្រះដើម្បីបេះផ្កាឈូក និងស្ទឹកឈូកមក ដើម្បីនឹងយកមកទុកខ្ចប់បាយ នាង

ថែមទាំងបានក្តិចក្តួរស្រូវសាលីក្នុងស្រែមកអន្លុយលីងធ្វើជាលាជនៅក្នុងខ្ទមស្រែ ហើយនាងបានលីងលាជបាន ៥០០ គ្រាប់ ។ ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធមួយរូប ចេញអំពីនិរោធសមាបត្តិ (ការចូលនិរោធបានដល់ រលត់សញ្ញា គឺការចងចាំ និងវេទនា គឺការសោយអារម្មណ៍) នៅភ្នំគន្ធមាទន៍ ហើយហោះមកឈរនៅជិតនាង ។ នាង (ឧប្បលវណ្ណា) ឃើញព្រះបច្ចេកពុទ្ធហើយ ទើបកាន់យកផ្កាឈូក ព្រមដោយលាជដើរចេញពីខ្ទម ហើយយកលាជទៅដាក់ក្នុងបាត្រ ថែមទាំងបានយកផ្កាឈូកដាក់ទៅលើគ្របបាត្ររបស់ព្រះបច្ចេកពុទ្ធទៀតផង ។

កាលព្រះបច្ចេកពុទ្ធនិមន្តចេញទៅមិនយូរប៉ុន្មាន នាងកើតការត្រិះរិះថា ធម្មតាបព្វជិត លោកមិនត្រូវការផ្កា យើងនឹងទៅតាមយកផ្កាឈូកមកប្រដាប់ខ្លួនឯង លុះគិតយ៉ាងនេះហើយ នាងទើបប្រញាប់រត់ទៅតាមសុំផ្កាឈូកមក ពីព្រះបច្ចេកពុទ្ធវិញ តែនាងត្រឡប់គិតទៀតថា ប្រសិនបើលោកម្ចាស់មិនត្រូវការផ្កាឈូកទេ លោកក៏គង់តែមិនឲ្យយើងដាក់ផ្កាឈូក នៅលើគ្របបាត្ររបស់លោកដែរ ប្រហែលជា

លោកម្ចាស់គង់មានសេចក្ដីត្រូវការផ្កាឈូកនោះពិតប្រាកដដែរនាងគិតដូច្នេះហើយ ទើបប្រញាប់យកផ្កាឈូកទៅដាក់លើគ្របបាត្រវិញ ហើយពោលសូមខមាទោសចំពោះព្រះបច្ចេកពុទ្ធ ថែមទាំងបានតាំងសេចក្ដីប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដោយផលនៃការថ្វាយលាជនេះ សូមឲ្យខ្ញុំម្ចាស់មានបុត្រស្មើនឹងចំនួនគ្រាប់លាជ ដោយផលនៃការថ្វាយផ្កាឈូកនេះ សូមឲ្យខ្ញុំមានផ្កាឈូកផុសឡើង រង់ចាំទទួលទ្រជើងរបស់ខ្ញុំម្ចាស់គ្រប់ជំហាន ទៅក្នុងស្ថានទីកន្លែងដែលខ្ញុំកើតហើយ ។ ចំណែកព្រះបច្ចេកពុទ្ធ ក៏បានហោះទៅកាន់ភ្នំគន្ធមាទន៍ចំពោះមុខនាង និងបានដាក់ផ្កាឈូកនោះ នៅត្រង់ទីជិតជើងកាំជណ្ដើរ សម្រាប់ប្រើជូតជើងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ នៅជ្រោយភ្នំគន្ធមាទន៍នោះ ។ លុះវេលានាងច្យុតចាកស្ថានមនុស្ស ក៏បានទៅកើតនៅក្នុងទេវលោក ចាប់តាំងពីដែលនាងកើតហើយ ផ្កាឈូកធំបានផុសឡើងរង់ចាំទទួលបាតជើងនាងគ្រប់ជំហាន ។ ទេពធីតានោះ ច្យុតចាកស្ថានទេវលោក ក៏បានមកកើតក្នុងត្របកនៃផ្កាឈូក ក្នុងស្រះមួយកន្លែងក្បែរជើងភ្នំ ។ មានតាបស

មួយរូប ដែលអាស្រ័យនៅជើងភ្នំ វេលាព្រឹកព្រលឹម តាបសនោះបាន ទៅកាន់ស្រះនោះ ដើម្បីលុបមុខ ក៏បានឃើញផ្កាឈូកនោះ ហើយគិត ថា ផ្កាឈូកនេះធំជាងផ្កាឈូកដទៃៗ ដែលរីកអស់ហើយ នៅសល់តែ ផ្កាឈូកនេះមិនទាន់រីក ដូចជានឹងមានវត្ថុណាមួយ នៅខាងក្នុងផ្កាឈូក នេះ ហើយតាបសនោះ ទើបចុះទៅក្នុងស្រះ បេះផ្កាឈូកនោះយកមក ។ ផ្កាឈូកនោះ គ្រាន់តែតាបសនោះ យកដៃចាប់ប៉ះប៉ុណ្ណោះ ក៏រីកភ្លាមធ្វើ ឲ្យតាបសបានឃើញទារិកា ដែលដេកនៅខាងក្នុងត្របកផ្កាឈូក ពេល ដែលតាបសនោះ បានឃើញទារិកានោះ ក៏បានកើតសេចក្ដីស្រឡាញ់ ដូចគ្នានឹងកូនរបស់ខ្លួន ។

កាលតាបសបាននាំទារិកានោះ ទៅកាន់បណ្ណសាលាព្រមទាំង ផ្កាឈូក ហើយដាក់ឲ្យទារិកានោះ ដេកនៅលើគ្រែតូច ក្នុងខណៈនោះ ទឹកដោះក៏កើតភ្លាមឡើង នៅត្រង់ម្រាមដៃរបស់តាបស ទាំងនេះកើត ឡើងដោយអានុភាពនៃបុណ្យកុសលរបស់ទារិកានោះ នាងទារិកាបាន បៅទឹកដោះពីម្រាមដៃរបស់តាបស កាលផ្កាឈូកចាស់ស្វិត តាបស

នោះ ក៏បានទៅបេះផ្កាឈូកថ្មីមកប្តូរឲ្យនាងទារិកានោះដេក ។ លុះពេលកន្ទង់មកទារិកានោះ វត់លេងទៅមកបាន ក៏មានផ្កាឈូកផុសឡើងមករង់ចាំទទួលទ្រទ្រង់ជើងរបស់នាងគ្រប់ៗ ជំហាន ចំណែកទារិកានោះ មានពណ៌សម្បុរសេរីរៈ ដូចជាសម្បុរផ្កាឈូក និងជាអ្នកមានពណ៌សម្បុរស្អាតលើសលុប ជាងសម្បុរមនុស្សធម្មតា ( គឺលើសលុបជាងសម្បុររបស់នារីទាំងឡាយ ) តែនៅមិនទាន់ដល់សម្បុររបស់ទេវតា ( នាងមានឈ្មោះតាមនិមិត្តថា **បទុមវតី** ) ។ ក្នុងពេលដែលតាបសត្រាច់ទៅរកបេះផ្លែឈើ ឬទៅរកមើមឈើតូចធំ នាងបទុមវតី ក៏នៅចាំបណ្ណសាលា ។ កាលនាងបទុមវតីធំពេញវ័យក្រមុំហើយ ថ្ងៃមួយតាបសបានចូលទៅក្នុងព្រៃ ដើម្បីទៅរកបេះផ្លែឈើ ឬទៅរកមើមឈើតូចធំហើយនោះ ពេលនោះ មានព្រានព្រៃម្នាក់បានមកឃើញនាង ទើបគិតពិនិត្យថា ធម្មតាមនុស្សទាំងឡាយ រមែងមិនមានរូបរាងកាយស្អាតដល់ម្ល៉េះទេ ដូច្នេះ យើងត្រូវពិនិត្យមើលឲ្យដឹងការពិតសិន ហើយអង្គុយរង់ចាំឃ្លាំមើល ដរាបដល់តាបសនោះត្រឡប់មកវិញ ។ កាលតាបស

ត្រឡប់មកដល់ នាងបទុមវតីដើរចេញទៅទទួលអំរែក និងបំពង់ទឹក ពីដៃតាបសនោះមកកាន់ ហើយទើបបដិបត្តិចំពោះតាបស ពេលដែលតាបសអង្គុយរួចដោយប្រការផ្សេងៗ ។ ក្នុងគ្រានោះ ព្រានព្រៃបានជ្រាបថា នាងជាមនុស្ស ទើបចូលទៅក្រាបសំពះតាបស ហើយក៏អង្គុយចុះក្នុងទីដ៏សមគួរ ។ គ្រានោះ តាបសបានអញ្ជើញនាយព្រានព្រៃ ឲ្យបរិភោគផ្លែឈើ មើមឈើតូចធំ និងផឹកទឹក ហើយសួរថា នែបុរសដ៏ចម្រើន អ្នកមកពីទីណា ទៅទីណា មកទីនេះមានការអ្វីដែរ ? ព្រានព្រៃបានតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាទៅកាន់ទីដទៃទេ តែខ្ញុំករុណាដើរមកឃើញទីនេះ ក៏ចូលមកលេងលោកម្ចាស់សិនទៅ មិនមានការអ្វីទេ លោកម្ចាស់ ។

គ្រានោះ តាបសទើបនិយាយប្រាប់ថា ហេតុការណ៍ដែលអ្នកមកឃើញហើយទីនេះ បើអ្នកចេញទៅវិញ កុំនិយាយប្រាប់ឲ្យអ្នកណាបានដឹងឲ្យសោះ ចំពោះទីកន្លែងនេះណា ។ នាយព្រានតបថា ប្រសិនបើលោកម្ចាស់មិនប្រាថ្នាឲ្យខ្ញុំករុណាពោលប្រាប់ទេនោះ ខ្ញុំករុណាក៏មិន

ពោលប្រាប់ឲ្យអ្នកដទៃដឹងដែរលោកម្ចាស់ នាយព្រានព្រៃកាលពោលដូច្នេះហើយ ក៏បានក្រាបសំពះលាតាបសចេញទៅ តែកាលធ្វើដំណើរចេញទៅ នាយព្រានព្រៃ បានធ្វើគ្រឿងសម្គាល់ដោយមែកឈើ ធ្វើស្នាមគំនូស និងធ្វើគ្រឿងសម្គាល់ទុកត្រង់ដើមឈើ ដើម្បីនឹងឲ្យចំណាំចាំផ្លូវបាន ក្នុងពេលដែលខ្លួនត្រឡប់មកម្តងទៀត ។ កាលនាយព្រានព្រៃទៅដល់នគរពារាណសីហើយ ទើបចូលទៅគាល់ព្រះរាជា ។ គ្រានោះព្រះរាជាទតឃើញនាយព្រានព្រៃចូលមកគាល់ ទើបមានព្រះរាជតម្រាស់សួរថា នែនាយព្រាន អ្នកចូលមកគាល់យើងដើម្បីអ្វី ? នាយព្រានព្រៃក្រាបបង្គំទូលតបថា សូមតេជះតម្កល់លើត្បូង ខ្ញុំករុណាជាព្រានព្រៃបានទៅជួបនារីរត្នម្នាក់ គួរឲ្យអស្ចារ្យពេកណាស់ តែនាងអាស្រ័យនៅជាមួយនឹងតាបស នៅឯជើងភ្នំមួយឯណោះ ព្រះករុណាថ្លៃវិសេសដោយហេតុនេះហើយ ទើបចូលមកគាល់ ក្រាបបង្គំព្រះអង្គ ឲ្យទ្រង់ជ្រាប ។ លំដាប់នោះ ព្រះបាទពារាណសីទ្រង់ព្រះសណ្តាប់ពាក្យរបស់នាយព្រានព្រៃហើយ ក៏សព្វព្រះរាជហឫទ័យ ទើបស្តេចចេញទៅកាន់

កន្លែងជើងភ្នំនោះ ព្រមដោយពលយោធា ពេលដែលព្រះអង្គយាងទៅដល់កន្លែងនោះ ក៏មានព្រះរាជតម្រាស់ឲ្យតាំងបន្ទាយសម្រាកនៅជិតៗនឹងជើងភ្នំកន្លែងតាបសនោះស្នាក់អាស្រ័យ ហើយព្រះអង្គព្រមដោយនាយព្រានព្រៃ និងរាជបុរសដទៃៗ ស្ដេចយាងចូលទៅកាន់អាស្រមរបស់តាបស ។

ប៉ុន្តែក្នុងខណៈនោះ គឺជាពេលដែលតាបសកំពុងតែអង្គុយឆាន់អាហារ ព្រះរាជាឃើញដូច្នេះហើយ ក៏ក្រាបថ្វាយបង្គំតាបស ។ លុះក្រាបថ្វាយបង្គំរួចហើយ គង់ប្រថាប់នៅក្នុងទីដ៏សមគួរ ។ គ្រានោះព្រះរាជាទ្រង់ដាក់គ្រឿងបរិក្ខារ សម្រាប់បញ្ជិតទុកជិតនឹងជើងតាបសហើយមានព្រះរាជតម្រាស់ត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើនលោកម្ចាស់ឲ្យពួកខ្ញុំធ្វើអ្វីយ៉ាងណាមួយក្នុងទីនេះ ឬថា នឹងឲ្យទៅ ? តាបសទូលតបថា សូមថ្វាយព្រះពរមហាបពិត្រ សូមព្រះអង្គស្ដេចយាងចេញទៅ ។ លំដាប់នោះ ព្រះរាជាមានព្រះរាជតម្រាស់ត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅ តែខ្ញុំបានឮថា មានស្ត្រីនៅក្នុងទីនេះ

លោកម្ចាស់ ពីព្រោះថាស្រ្តី ជាមន្ទិលរបស់បព្វជិតទាំងឡាយដោយពិត ហេតុដូច្នេះ សូមលោកម្ចាស់ឲ្យនាងទៅនៅជាមួយខ្ញុំចុះ ។ តាបសទូលថា សូមថ្វាយព្រះពរ មហាបពិត្រ ធម្មតាចិត្តរបស់មនុស្សដឹងបានដោយកម្រ ទារិកានេះ នឹងទៅនៅជាមួយពួកមនុស្សជាច្រើនបានយ៉ាងណា ពីព្រោះនាងមិនធ្លាប់រស់នៅទេនោះ ។ ព្រះរាជា មានព្រះតម្រាស់ថា បពិត្រលោកម្ចាស់ ឲ្យតែលោកម្ចាស់លើកនាង ឲ្យខ្ញុំក្នុងពេលណាហើយ ខ្ញុំម្ចាស់នឹងតែងតាំងនាងទុកក្នុងតំណែងជាអគ្គមហេសី ហើយឲ្យគេជួយមើលថែរក្សាឲ្យបានល្អ ។

តាបសបានស្តាប់ព្រះរាជបន្ទូលរបស់ព្រះរាជាហើយ ទើបហៅធីតាដោយនិមិត្តនាម ដែលដាក់ឲ្យនាងនៅជាទារិកាថា កូនស្រីបទុមវតី ចូរកូនស្រីចេញមកណេះ ។ កាលតាបសហៅត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះ នាងបទុមវតីក៏ចេញមកភ្លាមពីបណ្ណសាលា ហើយក្រាបថ្វាយបង្គំតាបសរូបអន្តយក្នុងទីដ៏សមគួរ ។ គ្រានោះ តាបសនិយាយប្រាប់នាងថា នែកូនស្រីបទុមវតី កូនធំហើយ ដូច្នេះ ចូរកូនទៅនៅជាមួយ

នឹងព្រះរាជាចុះ កូននឹងបានសេចក្តីសុខ ពីព្រោះព្រះរាជាបានសន្យាជាមួយនឹងបិតាថា នឹងមើលថែរក្សាកូនស្រី ថែមទាំងបានតែងតាំងកូនស្រីទុកក្នុងតំណែងជាអគ្គមហេសីទៀតផង ។ នាងបទុមវតី តបទទួលពាក្យតាបសដោយបន្ទំចិត្តថា ល្អហើយ នាងក៏ថ្វាយបង្គំតាបសហើយក៏យំដោយការតូចចិត្ត ។ គ្រានោះ ព្រះរាជាទ្រង់ត្រិះរិះថា យើងនឹងត្រូវយកចិត្តតាបស ដែលជាបិតារបស់នាងបទុមវតី គិតដូច្នេះហើយទើបចាប់លើកនាងបទុមវតីឲ្យអង្គុយលើគំនរប្រាក់ គំនរមាស ហើយទ្រង់អភិសេក និងទ្រង់ស្រោចស្រង់ទឹកក្រអូប ឲ្យក្លាយជាអគ្គមហេសីក្នុងទីនោះឯង ។ តពីនោះ ព្រះបាទពារាណសី បានយាងអគ្គមហេសីបទុមវតីចូលទៅកាន់ក្រុងពារាណសី ។ ចាប់តាំងពីព្រះរាជា ស្តេចចូលមកដល់ក្រុងពារាណសី ឬព្រះរាជដំណាក់ហើយ ព្រះអង្គទ្រង់មិនចាប់អារម្មណ៍ចំពោះស្ត្រីដទៃឡើយ ទ្រង់តែងតែមកអភិរម្យត្រេកអរនៅជាមួយនឹងនាងបទុមវតីប៉ុណ្ណោះ ។ ហេតុទាំងនេះ ទើបធ្វើឲ្យពួកស្ត្រីដទៃទៀត ក៏កើតការមិនពេញចិត្តចំពោះនាងបទុមវតី ម្នាក់ៗ នាំគ្នាប្រណែន

រកឧបាយញុះញង់ព្រះរាជា ដើម្បីបំបែកបំបាក់នាងបទុមវតីពីព្រះរាជា ទើបនាំគ្នាក្រាបទូលថា បពិត្រព្រះមហារាជ ព្រះនាងបទុមវតីមិនមែនជាមនុស្សទេ ព្រោះមនុស្សទាំងឡាយ ដែលដើរទៅមក មិនធ្លាប់មានផ្កាឈូកផុសឡើងមករង់ចាំទ្រជើងទេ ព្រះអង្គធ្លាប់ទតឃើញក្នុងទីណាដែរឬ ដូច្នេះ នាងបទុមវតីនេះ ប្រាកដជានាងយក្ខិនីហើយ ព្រះអង្គ សូមព្រះអង្គទ្រង់ឲ្យគេនាំនាងចេញពីនគរចុះ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យក្រាបទូលរបស់ស្ត្រីទាំងនោះហើយ ទ្រង់ក៏នៅស្ងៀមព្រងើយ ។

លុះសម័យតមកទៀត ពេលមួយ ខាងជាយដែននៃព្រះរាជាណាចក្រមានសត្រូវបង្កភាពចលាចលកើតឡើង ព្រះរាជាទ្រង់ត្រិះរិះថា ព្រះនាងបទុមវតីកំពុងតែមានគភ៌ជិតគ្រប់ខែដែរ ទើបទ្រង់ឲ្យព្រះនាងបទុមវតីប្រថាប់នៅក្នុងព្រះនគរ ឯព្រះអង្គស្ដេចយាងទៅខាងជាយដែន នៃព្រះរាជាណាចក្រមួយព្រះអង្គឯង ។ គ្រានោះ ពួកស្ត្រីដែលមានចិត្តប្រណែនបានឲ្យទ្រព្យដល់នាងស្រីស្នំ អ្នកបម្រើរបស់ព្រះនាងបទុមវតី ហើយពោលថា កាលព្រះនាងបទុមវតីទ្រង់ប្រសូតបុត្រ នាងចូរនាំយកកូននោះ

ចេញទៅឲ្យផុត ហើយនាំយកកំណាត់ឈើមួយកំណាត់ យកឈាម លាបឲ្យប្រឡាក់ ហើយដាក់ជំនួសវិញ ។

លុះកាលមិនយូរប៉ុន្មាន ការប្រសូតបុត្ររបស់ព្រះនាងបទុមវតី បានកើតមានឡើង មានព្រះរាជឱរសទាំងអស់ចំនួន ៥០០ ព្រះអង្គ ។ ព្រះឱរសដែលនៅក្នុងព្រះគភ៌របស់ព្រះនាងបទុមវតី មានតែព្រះមហាបទុមកុមារត្រឹមតែមួយព្រះអង្គប៉ុណ្ណោះទេ ។ ចំណែកឯកុមារដ៏សេស ៤៩៩ អង្គទៀត កើតមកពីសំសេទជៈ ( គឺកើតពីញើស ) ។ ក្នុងពេលដែលព្រះមហាបទុមកុមារប្រសូតចាកព្រះគភ៌ ព្រះមាតាទ្រង់សន្លប់ ។ ខណៈនោះ អ្នកបម្រើរបស់ព្រះនាងបទុមវតី កាលឃើញថា ព្រះនាងនៅមិនទាន់ដឹងខ្លួនទេនោះ ក៏បាននាំយកកំណាត់ឈើមកលាបនឹងឈាម ហើយដាក់ទុកក្បែរព្រះនាងផ្ទំនោះ តពីនោះ ទើបបញ្ជូនទារកនោះ ទៅឲ្យស្រីទាំងឡាយ ដែលកំពុងតែរង់ចាំទទួល ។ ស្ត្រីចំនួន ៥០០ នាក់ ម្នាក់ៗ បីកុមារមួយ ហើយបញ្ជូនទៅឲ្យនាយជាងរចនាក្អកធ្វើប្រអប់ ( ប្រអប់មានជើង មានគម្រប ) ហើយនិយាយប្រាប់ថា ចូរធ្វើប្រអប់

នេះមក ហើយរៀបចំដាក់ព្រះរាជកុមារទាំងអស់ក្នុងប្រអប់ ឲ្យធ្វើគ្រឿងសម្គាល់ទុកត្រង់ខាងប្រអប់ទាំងនោះ ។ លុះព្រះនាងបទុមវតី មានស្មារតីឡើងវិញហើយ ទើបត្រាស់សួរនាងស្នំអ្នកបម្រើថា នាង ខ្ញុំប្រសូតបុត្រហើយឬ ? នាងស្នំអ្នកបម្រើក្រាបបង្គំទូលថា ព្រះនាងម្ចាស់ប្រសូតបុត្រហើយ ។ ព្រះនាងបទុមវតីត្រាស់សួរតទៅទៀតថា ខ្ញុំបានប្រសូតបុត្រប្រុស ឬបុត្រស្រី ? នាងស្នំអ្នកបម្រើក្រាបបង្គំទូលកុហក ចំពោះព្រះនាងថា ព្រះនាងម្ចាស់ ទ្រង់បានប្រសូតបុត្រមកពីណា ហើយអ្នកបម្រើបានលើកយកកំណាត់ឈើ ដែលប្រឡាក់ឈាមនោះឯង មកបង្ហាញព្រះនាង ហើយក្រាបទូលកុហកថា វត្ថុនេះឯង គឺជាបុត្រដែលប្រសូតចាកព្រះគភ៌របស់ព្រះនាងម្ចាស់ ។

គ្រានោះ ព្រះនាងបទុមវតី កាលបានទតឃើញកំណាត់ឈើហើយ ទ្រង់ទោមនស្ស ទើបមានព្រះរាជសវនីយ៍ថា នាងចូរនាំកំណាត់ឈើនេះទៅពុះចោលឲ្យឆាប់រហ័ស ប្រសិនបើមាននរណាៗមកឃើញខ្ញុំនឹងត្រូវខ្មាសគេជាពុំខាន ។ អ្នកបម្រើស្តាប់ព្រះសវនីយ៍ហើយ ក្លែង

ធ្វើដូចជាមានបំណងល្អ ចំពោះព្រះនាងបទុមវតីយ៉ាងក្រៃលែង ទើប ប្រញាប់យកកំណាត់ទៅពុះ ហើយដាក់ក្នុងជើងក្រានដុតចោលភ្លាមៗ នោះឯង មិនរង់ចាំពេលវេលាឲ្យយឺតយូរ ។ ចំណែកព្រះរាជា ស្ដេច បានយាងត្រឡប់ពីជាយដែនមកវិញដោយទ្រង់បានបោះបន្ទាយកងទ័ព សម្រាកនៅខាងក្រៅព្រះនគរ ។ គ្រានោះ ពួកស្រីស្នំទាំងឡាយ បានជ្រាប ដំណឹងនោះហើយ ក៏នាំគ្នាចេញទៅទទួលព្រះរាជា ដោយក្រាបបង្គំទូល ថា បពិត្រមហារាជ ទ្រង់គង់នឹងមិនជឿពួកខ្ញុំម្ចាស់ ដោយពាក្យដែលខ្ញុំ ម្ចាស់ក្រាបបង្គំទូលនេះ មើលហាក់បីដូចថា រកហេតុផលមិនមាន សូម ព្រះអង្គត្រាស់ហៅអ្នកបម្រើរបស់ព្រះមហេសីមកសាកសួរថា ព្រះទេវី ប្រសូតព្រះឱរសជាកំណាត់ឈើពិតមែនឬ ព្រះពរម្ចាស់ ព្រះអង្គ ។ព្រះ រាជាទ្រង់ពិចារណាហេតុការណ៍ផ្សេងៗ ដែលទ្រង់ព្រះសណ្ដាប់រួចមក ហើយពីស្ត្រីទាំងនោះ ទើបទ្រង់មានព្រះរាជតម្រិះ និងយល់សេចក្ដីថា ព្រះនាងបទុមវតី មិនមែនជាមនុស្សពិតប្រាកដមែន ទើបទ្រង់ត្រាស់ បណ្ដេញបំបរបង់ព្រះនាងបទុមវតីចេញចាកព្រះរាជវាំង ។ និមិត្តដែល

ខុសប្រក្រតីបានកើតឡើងដល់ព្រះនាងបទុមវតី ក្នុងពេលដែលព្រះនាងចេញផុតពីព្រះរាជវាំងហើយ ផ្កាឈូកទាំងឡាយ ដែលធ្លាប់ផុសឡើងទ្រព្រះយុគលបាទ ក៏វិនាសបាត់ទៅ ព្រះឆវីវណ្ណដែលធ្លាប់ផូរផង់ ក៏ប្តូរសម្បុរខុសប្រក្រតី ។ ព្រះនាងបទុមវតីមួយព្រះអង្គឯង ស្តេចយាងចេញទៅតាមផ្លូវ ដោយគ្មានគោលដៅ ។ គ្រានោះ មានជីដូនចាស់ជរាម្នាក់បានជួបព្រះនាងហើយ កើតការនឹកស្រឡាញ់ដូចគ្នានឹងកូនក្រមុំរបស់ខ្លួន ទើបសួរថា កូនអើយ កូនទៅទីណា ? ព្រះនាងបទុមវតីត្រាស់តបថា ខ្ញុំជាអ្នកដំណើរ ទាំងដែលគ្មានទិសដៅពិតប្រាកដ ឬទីសម្រាកកន្លែងណាក៏មិនមាន ។

ជីដូនចាស់ជរានោះទើបបបួលថា មកណេះចុះកូន ហើយនាំនាងបទុមវតីទៅកាន់ផ្ទះរបស់ខ្លួន ថែមទាំងបានរៀបចំបាយទឹកឲ្យព្រះនាងសោយទៀតផង ។ ខណៈពេលដែលព្រះនាងបទុមវតីមកនៅជាមួយនឹងជីដូនចាស់នោះ ពួកស្ត្រីទាំង ៥០០ នាក់ទាំងនោះ ព្រមគ្នាក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះមហារាជ នាកាលដែលព្រះអង្គ

ទ្រង់លើកកងទ័ពទៅ ពួកខ្ញុំម្ចាស់បានបន់ស្រន់ព្រះម៉ែគង្គាថា កាលបើព្រះសម្មតិទេពរបស់ពួកខ្ញុំម្ចាស់ឈ្នះសង្គ្រាម ស្ដេចយាងត្រឡប់មកវិញ ពួកខ្ញុំម្ចាស់ នឹងធ្វើពលិកម្ម បួងសួងដល់ព្រះម៉ែគង្គា ហើយនឹងនាំគ្នាលេងទឹក សូមព្រះអង្គទ្រង់ជ្រាបរឿងនេះចុះ ព្រះពរម្ចាស់ព្រះអង្គ ។ គ្រានោះ ព្រះរាជាទ្រង់សព្វព្រះហឫទ័យ នូវពាក្យក្រាបទូលរបស់ស្ត្រីទាំងនោះ ទើបបានស្ដេចយាងទៅ ដើម្បីនឹងទ្រង់លេងទឹកក្នុងទន្លេគង្គានោះ ទៅតាមដែលស្ត្រីទាំងនោះក្រាបទូលហើយ ។ ចំណែកស្ត្រីទាំង ៥០០ នាក់ បានកាន់ប្រអប់ដាក់ព្រះរាជកុមារទាំងនោះ រុំស្បែកលាក់ទុក ដោយជណ្ដប់សំពត់ហ៊ុមបិទបាំងប្រអប់ ដើម្បីនាំយកទៅទន្លេគង្គាដែរ ។ កាលស្ត្រីទាំងនោះ ចុះទៅលេងទន្លេគង្គា ទើបបណ្ដែតប្រអប់ទាំងនោះទៅតាមទឹកទន្លេគង្គា ប្រអប់ទាំងនោះបានអណ្ដែតមករួមជាប់គ្នា ហូរតាមទឹកទៅជាប់សំណាញ់ កន្លែងដែលការពារអន្តរាយក្រោមក្រសែទឹក ។លុះព្រះរាជាទ្រង់ឈប់លេងទឹកហើយ ទើបស្ដេចឡើងមកវិញ ពួករាជបុរសបាននាំគ្នាលើកសំណាញ់ឡើង ក៏បានឃើញប្រអប់

ទាំងនោះ ទើបនាំគ្នាក្រាបទូលថ្វាយព្រះរាជា ។ ព្រះរាជាទតឃើញប្រអប់នោះហើយ ទើបមានព្រះរាជតម្រាស់សួរថា មានអ្វីក្នុងប្រអប់នេះឬទេ ? ពួករាជបុរសបានក្រាបទូលថា ពួកខ្ញុំព្រះអង្គមិនដឹងទេ ។ ព្រះរាជាមានព្រះរាជតម្រិះត្រាស់ថា ឲ្យបើកប្រអប់ទាំងនោះចេញពិនិត្យមើល ចៃដន្យ បានបើកប្រអប់ដែលដាក់ព្រះមហាបទុមកុមារជាលើកដំបូង ចំណែកប្រអប់ដទៃៗ ក៏មានព្រះរាជកុមារដែរ ដែលនៅខាងក្នុងប្រអប់គ្រប់ៗ ប្រអប់ ។ ក្នុងថ្ងៃដែលព្រះរាជកុមារទាំងអស់អង្គ ត្រូវដាក់ក្នុងប្រអប់ទាំងអស់នោះ ទឹកដោះបានកើតឡើងត្រង់មេដៃរបស់ខ្លួនរៀងៗ ខ្លួន ដោយអំណាចបុញ្ញឫទ្ធិ ទើបជួយឲ្យព្រះមហាបទុម និងព្រះរាជកុមារទាំងអស់អង្គនោះ បានមានទឹកដោះបៅគ្រប់ពេល ដែលឃ្លានបៅទឹកដោះ ។

ប៉ុន្តែមុនព្រះបាទពារាណសី ព្រះរាជបិតារបស់កុមារទាំងនោះនឹងបានទតឃើញប្រអប់ទាំងឡាយ ព្រះឥន្ទ្រទ្រង់បានចារឹកអក្សរទុកខាងក្នុងប្រអប់ ដើម្បីកាត់នូវសេចក្តីសង្ស័យព្រះរាជាថា ព្រះរាជកុមារ

ទាំងនេះ ទ្រង់កើតនៅក្នុងព្រះគភ៌របស់ព្រះនាងបទុមវតី ជាឱរសរបស់ព្រះបាទពារាណសី ចំណែកហេតុការណ៍ដែលមានដូចនេះ ពីព្រោះស្រី ៥០០ នាក់ រួមស្វាមីជាមួយនឹងព្រះនាងបទុមវតី បាននាំព្រះរាជ-កុមារទាំងនេះដាក់ក្នុងប្រអប់ ហើយបណ្តែតចោលតាមទឹកទន្លេគង្គា សូមព្រះរាជាទ្រង់ជ្រាបហេតុការណ៍នេះចុះ ។ កាលបើពួករាជបុរសបើកប្រអប់ចេញហើយ ព្រះរាជាបានទតឃើញអក្សរ ព្រមទាំងព្រះរាជកុមារ ទើបទ្រង់អានសេចក្តីនេះ ហើយមានព្រះរាជតម្រាស់បញ្ជាថា ពួកលោកទាំងឡាយ ចូរលើកព្រះមហាបទុមកុមារឡើង រត់ដោយរហ័ស និងត្រៀមចេញសេះទៅ ហើយមានព្រះរាជតម្រាស់ថា ថ្ងៃនេះ ដល់ព្រះនគរហើយ យើងនឹងធ្វើសេចក្តីស្រឡាញ់ឲ្យកើតដល់ស្ត្រីពួកខ្លះ លុះស្តេចយាងមកដល់ព្រះនគរ ព្រះអង្គឡើងលើប្រាសាទមានព្រះរាជគំនិត ឲ្យដាក់ថង់ទ្រព្យមួយពាន់កហាបណៈទុកលើ-កដំរីហើយឲ្យដើរវាយស្គរ បន្លឺកប្រកាសថា អ្នកណាបានជួប និងបានឃើញព្រះនាងបទុមវតី អ្នកនោះនឹងបានទទួលប្រាក់មួយពាន់កហាបណៈ

ពីពួកយើង ។ គ្រានោះ ព្រះនាងបទុមវតី ទ្រង់បានស្តាប់សំឡេងបន្ទូកប្រកាសដូច្នេះហើយ ទើបត្រាស់ប្រាប់ជីដូនដែលចាស់ជរា ទុកដូចជាមាតាថា អ្នកម្តាយចូរទៅទទួលថង់ទ្រព្យមួយពាន់កហាបណៈពីលើ-កដីរមក ។ ជីដូនចាស់ជរាតបថា ម៉ែមិនហ៊ានទៅទទួលប្រាក់នោះទេកូន ។ ព្រះនាងបទុមវតី ត្រាស់ប្រាប់ឲ្យជីដូនចាស់ទៅទទួលប្រាក់ជាលើកទី ២ ជាលើកទី ៣ ។ ជីដូនចាស់នោះ បានសួរនាងថា យើងនឹងទៅនិយាយជាមួយនឹងគេដូចម្តេច ពេលដែលម្តាយទៅទទួលយកប្រាក់នោះ និយាយជាមួយពួកគេថាយ៉ាងណា ទើបនឹងបានទទួលថង់ប្រាក់នោះមកបាន កូន ? ព្រះនាងបទុមវតីត្រាស់ប្រាប់វិធីឲ្យថា អ្នកម្តាយចូរទៅប្រាប់ពួកគេថា កូនក្រមុំរបស់ខ្ញុំជាអ្នកបានជួប បានឃើញព្រះនាងបទុមវតី ហើយអ្នកម្តាយប្រាកដជានឹងបានទទួលថង់ប្រាក់ ១០០០ កហាបណៈនោះមក ។ ជីដូនចាស់ពោលថា វត្ថុណានឹងកើត វត្ថុនោះចូរកើត ហើយចូលទៅរករាជបុរសទាំងនោះ ដើម្បីទៅយកប្រាក់មួយពាន់កហាបណៈនោះមក ។

គ្រានោះ ពួករាជបុរសសួរជីដូនចាស់នោះថា លោកយាយឃើញព្រះនាងបទុមវតីទេឬ ? ជីដូនចាស់តបថា ខ្ញុំមិនបានឃើញខ្លួនឯងទេ តែកូនក្រមុំរបស់ខ្ញុំបានឃើញព្រះនាង ។ ពួករាជបុរសសួរថា កូនរបស់លោកយាយនៅទីណា ? កាលពួករាជបុរសបានជ្រាបដំណឹងពីជីដូនចាស់ហើយ ទើបនាំគ្នាដើរទៅតាមជីដូនចាស់នោះ ។ ពេលនោះពួករាជបុរស កាលជួបព្រះនាងបទុមវតីក៏ចាំបាន ទើបព្រមគ្នា បានក្រាបចុះថ្វាយបង្គំព្រះនាង ។ ហេតុការណ៍នោះ ធ្វើឲ្យជីដូនចាស់ធ្ងល់ហើយពោលសួរថា កូនស្រីនេះឬ គឺជាព្រះនាងបទុមវតីទេ ? ហើយទើបពោលតទៅទៀតថា កម្មដែលមនុស្សធ្វើធ្ងន់ដល់ម្ល៉ឹង សូម្បីព្រះនាងបទុមវតី ជាព្រះអគ្គមហេសីរបស់ព្រះរាជាដ៏ប្រសើរដល់ម៉្លេះ មកគង់នៅក្នុងកន្លែងដែលមិនមានការថែរក្សា ជាការមិនសមគួរទេ ។ ពួកព្រះរាជបុរស ទើបបានក្រាបបង្គំទូលយាងព្រះនាងបទុមវតី ឲ្យស្ដេចយាងចូលទៅកាន់ព្រះនគរវិញ ដោយឲ្យបាំងបាំងរាំងននពទ្ធជុំវិញ តាំងពីខ្លោងទ្វារ ហើយទើបទៅក្រាបបង្គំទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះ

រាជាទ្រង់បញ្ជូនគ្រែស្នែងមាស ទៅទទួលព្រះនាងបទុមវតីទេវី ។ រីឯព្រះនាងបទុមវតីទេវីត្រាស់ថា ខ្ញុំម្ចាស់មិនព្រមទៅដោយវិធីនេះទេ តែខ្ញុំម្ចាស់នឹងដើរទៅដោយជើងទទេ សូមឲ្យព្រះរាជានាំគ្រឿងប្រដាប់ ទាំងព្រះរាជទានចំពោះកម្រាលគ្រឿងក្រាលដ៏វិចិត្រមកក្រាលនូវលើផែនដីតាំងពីលំនៅរបស់ខ្ញុំម្ចាស់មកដល់ព្រះនគរ ចំណែកឯខាងលើឲ្យយកផ្ទាំងសំពត់ដ៏ល្អបាំងជាពិតាន ស្អិតស្អាងដោយផ្កាមាស អ្នកព្រះនគរទាំងអស់ នឹងបានឃើញអានុភាពបុណ្យខ្ញុំម្ចាស់ ដោយវិធីយ៉ាងនេះ ។ ព្រះរាជាមានព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរធ្វើតាមសេចក្ដីប្រាថ្នារបស់ព្រះនាងបទុមវតីទេវីចុះ ។

ព្រះនាងបទុមវតីទេវី ទ្រង់ស្អិតស្អាងដោយគ្រឿងប្រដាប់ទាំងពួងហើយត្រាស់ថា ខ្ញុំម្ចាស់នឹងទៅកាន់ព្រះនគរ ហើយព្រះនាងស្ដេចយាងទៅតាមជងផ្លូវ ។ ក្នុងខណៈដែលព្រះនាងបទុមវតី ស្ដេចឈានព្រះបាទចុះទៅ ក៏មានផ្កាឈូកផុសឡើងទ្រព្រះបាទព្រះនាងគ្រប់ៗ ជំហាន នៃព្រះបាទដែលព្រះនាងយាងជាន់ហើយ ។ ព្រះនាងបទុមវតី ទ្រង់បាន

សម្ដែងអំពីភាពអស្ចារ្យរបស់ខ្លួនឲ្យមហាជនបានឃើញ ដែលកើតមក អំពីបុណ្យ ហើយស្ដេចយាងឡើងកាន់ព្រះរាជនិវេសន៍ បានសូមឲ្យ ព្រះរាជាប្រទានគ្រឿងកម្រាលដ៏វិចិត្រទាំងអស់ ធ្វើឲ្យជាមូលតម្លៃគ្រឿង ថៃរក្សាជីដូនចាស់ ដែលព្រះនាងបានទៅស្នាក់អាស្រ័យនៅជាមួយ ។ ចំណែកព្រះរាជាត្រាស់បញ្ជា ឲ្យស្ត្រីទាំង ៥០០ នាក់ទាំងនោះ ចូល មកគាល់ហើយ ត្រាស់ថា នែព្រះទេវី យើងលើកស្ត្រីទាំង ៥០០ នាក់នេះ ឲ្យជាទាសីរបស់ព្រះទេវី ។ គ្រានោះ ព្រះនាងបទុមវតីក្រាប ទូលថា បពិត្រមហារាជ ល្អហើយ សូមព្រះអង្គទ្រង់ឲ្យអ្នកព្រះនគរ ទាំងអស់ទទួលការដឹងឮ ដែលព្រះអង្គព្រះរាជទានស្ត្រីទាំងនេះឲ្យដល់ ខ្ញុំម្ចាស់ហើយ ព្រះអង្គ ។ ព្រះរាជាត្រាស់ប្រាប់ឲ្យរាជបុរសវាយស្គរ ដើរប្រកាសទូទៅទាំងព្រះនគរថា ខ្ញុំបានលើកស្ត្រី ៥០០ នាក់ អ្នកគិត អាក្រក់ចំពោះព្រះនាងបទុមវតី ឲ្យជាទាសីរបស់ព្រះនាងបទុមវតី ។ លំដាប់នោះ ព្រះនាងបទុមវតី កាលបើទ្រង់ជ្រាបថា អ្នកព្រះនគរដឹង ទូទៅអស់ហើយថា ស្ត្រីទាំងនេះជាទាសីរបស់ព្រះនាងហើយ ទើបទូល

ព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមឲ្យខ្ញុំម្ចាស់បានដោះលែងទាសីទាំងនេះ ឲ្យមានសេរីភាពវិញ ព្រះពរម្ចាស់ ។ ព្រះរាជាត្រាស់ថា នែព្រះទេវី តាមតែព្រះទេវីសព្វព្រះទ័យចុះ ។ ព្រះនាងបទុមវតីទូលថា កាលបើព្រះអង្គទ្រង់អនុញ្ញាតហើយ ខ្ញុំម្ចាស់សូមឲ្យព្រះអង្គប្រកាសដល់អ្នកនគរទាំងអស់ឲ្យបានជ្រាបទូទៅម្តងទៀតថា ស្ត្រី ៥០០ នាក់ទាំងនេះ ដែលព្រះរាជាប្រទានឲ្យជាទាសី របស់ព្រះនាងបទុមវតីទេវីឥឡូវនេះ ព្រះនាងបទុមវតីក៏បានដោះលែង ឲ្យរួចចាកភាពជាទាសីហើយ ។ កាលស្ត្រីទាំង ៥០០ នាក់ផុតចាកភាពជាទាសី មានសេរីភាពវិញហើយ ព្រះនាងបទុមវតី បានប្រទានព្រះរាជឱរស ៤៩៩ ព្រះអង្គឲ្យដល់ស្ត្រីទាំងនោះជួយថែរក្សា ឯព្រះមហាបទុមកុមារ ព្រះនាងទទួលថែរក្សាដោយព្រះអង្គឯង ។

លុះសម័យជាខាងក្រោយមក កាលព្រះកុមារទាំងនោះ ទ្រង់ចម្រើនវ័យជីនក្តីហើយ ព្រះរាជាទ្រង់ឲ្យកសាងកន្លែងសម្រាប់លេងទឹកគ្រប់បែបយ៉ាងនៅក្នុងព្រះរាជឧទ្យាន ។ ក្នុងពេលដែលព្រះរាជកុមារ

ទាំងអស់ មានព្រះជន្មបាន ១៦ ព្រះវស្សា ស្ដេចបាននាំគ្នាលេងទឹកក្នុងស្រះបោក្ខរណី ដែលជាស្រះមង្គល ពោរពេញទៅដោយផ្កាឈូកក្នុងព្រះរាជឧទ្យាន និងបានទតឃើញផ្កាឈូកថ្មីរីក តែផ្កាចាស់ត្រូវបកផ្កាឈូក ក៏ជ្រុះធ្លាក់ចុះចាកទង ទើបកាន់យកជាអារម្មណ៍ថា ភាពជរា ( ភាពទ្រុឌទ្រោម ) ឃើញដូច្នេះ រមែងពិចារណាឃើញដំណើរនៃសង្ខារធម៌មិនទៀង មិនអាចគ្រប់គ្រងបាន ចាំបាច់ពោលទៅថ្វី ដល់សរីរៈរបស់ពួកយើង ព្រោះថា សរីរៈរបស់ពួកយើងក៏នឹងមានសភាពយ៉ាងនោះដែរ គឺមិនទៀង ។ ក្នុងគ្រានោះ ព្រះរាជកុមារទាំងអស់ ក៏បានសម្រេចបច្ចេកសម្ពោធិញ្ញាណ គឺដោយការពិចារណាឃើញផ្កាឈូកដែលមានសភាពមិនទៀង បានជាព្រះបច្ចេកពុទ្ធគ្រប់ៗ ព្រះអង្គ គឺទាំង ៥០០ ព្រះអង្គ ។ មួយព្រះអង្គៗ ក្រោកឡើង មកគង់លើផ្លែឈូកទាំងឡាយ ។ ពួករាជបុរស ដែលមកព្រមជាមួយនឹងព្រះរាជកុមារទាំងនោះ ឃើញថាដល់ពេលល្ងាចហើយ ទើបក្រាបទូលថា បពិត្រព្រះអយ្យបុត្រ សូមទ្រង់ជ្រាបពេលព្រះក្រយាហារសម្រាប់ព្រះអង្គចុះ

តែព្រះរាជកុមារទាំងនោះនៅស្ងៀមព្រងើយ ពួកព្រះរាជបុរស ទើបទៅចូលគាល់ក្រាបបង្គំទូលព្រះរាជាឲ្យទ្រង់ជ្រាបថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារទាំងអស់ គង់ប្រថាប់នៅលើផ្ទៃឈូក គ្រប់ៗ ព្រះអង្គ សូម្បីពួកខ្ញុំព្រះករុណាម្ចាស់ក្រាបទូលយ៉ាងណា ក៏មិនបានត្រាស់តបព្រះករុណាថ្លៃវិសេស ។ ព្រះរាជាមានព្រះរាជតម្រាស់ថា ពួកលោកចូរបណ្ដោយឲ្យពួកគេ គង់នៅតាមព្រះទ័យចុះ ។ រាជបុរសទាំងនោះត្រឡប់មកចាំថែរក្សារហូតទាល់ភ្លឺ ។ ចំណែកព្រះបច្ចេកពុទ្ធទាំងអស់អង្គនោះ ក៏នៅតែប្រថាប់គង់លើផ្ទៃឈូកទាំងឡាយដូចដើមដដែល ។ រាជបុរសទាំងឡាយ លុះដល់ព្រឹកឡើង ក៏នាំគ្នាក្រាបទូលថា បពិត្រព្រះរាជបុត្រ សូមព្រះអង្គទ្រង់ជ្រាបកាលនេះចុះ ព្រះករុណាថ្លៃវិសេស ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធទាំងនោះត្រាស់តបថា ពួកយើងមិនមែនជាព្រះរាជបុត្រទេ តែពួកយើងជាព្រះបច្ចេកពុទ្ធទេតើ ។ ពួកព្រះរាជបុរសក្រាបទូលថា បពិត្រព្រះរាជបុត្រ ព្រះអង្គត្រាស់ពាក្យនេះ ជាកម្មធ្ងន់ ដែលឈ្មោះថាព្រះបច្ចេកពុទ្ធនោះ មិនមែនដូចគ្នានឹងព្រះអង្គទាំងឡាយ

ទេ គឺព្រះបច្ចេកពុទ្ធ លោកមានតែព្រះកេសា និងព្រះមស្សុត្រឹមតែពីរអង្គុលី ព្រមទាំងមានបរិក្ខារទាំង ៨ ទៀតផង ព្រះករុណាថ្លៃវិសេស ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធជាម្ចាស់ ទ្រង់យកព្រះហស្តស្ទាបព្រះសិរសា មួយរំពេចនោះ ភេទគ្រហស្ថក៏បាត់ទៅ ហើយបានមានប្រាកដនូវបរិក្ខារទាំង ៨ របស់សមណៈវិញ ។ តពីនោះ ទាំងដែលមានមហាជនក្រឡេកមើលនោះឯង ព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយនោះ ស្តេចបានហោះទៅតាមផ្លូវអាកាស ទៅកាន់ជ្រោយភ្នំនន្ទមូលដែលនៅត្រង់ភ្នំគន្ធមាទន៍ ។ ចំណែកព្រះនាងបទុមវតីត្រិះរិះថា យើងជាអ្នកមានបុណ្យច្រើន តែបុត្រទាំងនោះបានព្រាត់ប្រាសចាកយើងទៅហើយ ព្រះនាងទ្រង់ព្រះកន្សែងយ៉ាងខ្លាំងក្លា ហើយស្តេចក៏សោយទិវង្គតទៅដោយអំណាចកុសលកម្មឯណានីមួយ ដែលនាងធ្វើមកហើយ បានធ្វើឲ្យព្រះនាងទៅកើតនៅក្នុងស្រុកមួយ ដែលមានការចិញ្ចឹមជីវិត ធ្វើការដោយដៃ ដែលស្ថិតនៅស្រុកជិតទ្វារព្រះនគររាជគ្រឹះ ។ លុះសម័យខាងក្រោយមក នាងចម្រើនវ័យធំដឹងក្តីហើយ នាងបានទៅកាន់ត្រកូល

ខាងប្ដី ថ្ងៃមួយ នាងបានយកយាគូទៅឲ្យស្វាមី ដែលកំពុងតែភ្ជួរស្រែ នាងក៏បានឃើញព្រះបច្ចេកពុទ្ធជាម្ចាស់ ៨ អង្គ ដែលនៅក្នុងចំណោម បុត្រ ៥០០ អង្គ របស់នាងក្នុងអតីតជាតិ កំពុងតែហោះទៅតាមផ្លូវ អាកាស ក្នុងពេលភិក្ខាចារ ( ត្រាច់បិណ្ឌបាត ) នាងឃើញដូច្នោះហើយ ទើបប្រញាប់ទៅរកស្វាមីដោយរហ័ស ហើយក៏បានប្រាប់ស្វាមីថា អ្នក បានឃើញព្រះបច្ចេកពុទ្ធទាំងឡាយទេ យើងនឹងនិមន្តព្រះបច្ចេកពុទ្ធទាំង នោះ មកប្រគេនចង្ហាន់បិណ្ឌបាត ។ ស្វាមីបានពោលថា ធម្មតាបក្សី ទាំងឡាយ រមែងត្រាច់ទៅយ៉ាងនេះឯងក៏មាន ជនទាំងនោះមិនមែនជា ព្រះបច្ចេកពុទ្ធទេ ។ ខណៈដែលស្វាមី និងភរិយាកំពុងតែសន្ទនាគ្នានោះ ព្រះបច្ចេកពុទ្ធទាំង ៨ អង្គនោះបានឮពាក្យសន្ទនារបស់អ្នកទាំងពីរនាក់ នោះ ទើបចុះចាកអាកាស ទៅប្រាកដត្រង់កន្លែងជិតអ្នកទាំងពីរនោះ។ ថ្ងៃនោះ ចំណែកភរិយាបានប្រគេននូវភោជនីយាហារ ដែលជាចំណែក របស់ខ្លួន ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយពោលថា ក្នុងថ្ងៃស្អែកនេះ សូមលោកម្ចាស់ទាំង ៨ អង្គ មកទទួលភិក្ខា របស់ខ្ញុំម្ចាស់ទៀត ។

ព្រះបច្ចេកពុទ្ធទាំងនោះពោលថា នែឧបាសិកា ល្អហើយៗ ប្រសិនបើ ក្នុងថ្ងៃស្អែកនេះ ឧបាសិកាបានឃើញព្រះបច្ចេកពុទ្ធច្រើនអង្គនោះ ចូរ ឧបាសិកាញុំាងសេចក្ដីត្រេកអរឲ្យកើតឡើងទៅបានហើយៗ ឧបាសិកា ចាត់ចែងអាសនៈតែ ៨ បានហើយ ព្រះបច្ចេកពុទ្ធពោលដូច្នេះហើយ ក៏បានហោះទៅកាន់ភ្នំគន្ធមាទន៍វិញទៅ ។ លុះព្រឹកឡើង ឧបាសិកានោះ ចាត់ចែងក្រាលអាសនៈទុក ៨ កន្លែង ដោយត្រៀមតែគ្រឿងសក្ការៈ ទុកសម្រាប់ព្រះបច្ចេកពុទ្ធទាំង ៨ អង្គប៉ុណ្ណោះ ។

ចំណែកព្រះបច្ចេកពុទ្ធ ៨ អង្គនោះ បាននិមន្តព្រះបច្ចេកពុទ្ធ អង្គដទៃៗ ទៀតថា ថ្ងៃនេះ សូមលោកម្ចាស់ទាំងឡាយ កុំនិមន្តទៅ បិណ្ឌបាតកន្លែងដទៃអី ចូរនាំគ្នាទៅប្រោសដល់ញោមស្រី របស់លោក ម្ចាស់ទាំងឡាយផងចុះ ព្រះបច្ចេកពុទ្ធទាំងអស់នោះ ដែលបានស្ដាប់ ពាក្យនិមន្តរបស់ព្រះបច្ចេកពុទ្ធទាំង ៨ អង្គនោះហើយ ទើបបានព្រម គ្នាហោះមកតាមផ្លូវអាកាស ដោយទៅប្រាកដនៅត្រង់មុខទ្វារផ្ទះរបស់ ញោមស្រី ។ ឧបាសិកា កាលបានឃើញព្រះបច្ចេកពុទ្ធ និមន្តមក

ច្រើនជាងការកំណត់និមន្ត ក៏មិនបានរន្ធត់ញាប់ញ័រចិត្ត ទើបបាននិមន្ត ព្រះបច្ចេកពុទ្ធទាំងអស់នោះ ចូលទៅគង់លើអាសនៈក្នុងផ្ទះ ដែលបាន រៀបចំក្រាលទុក ។ កាលព្រះបច្ចេកពុទ្ធទាំង ៨ អង្គ គង់លើអាសនៈ តាមលំដាប់វស្សាហើយ ព្រះបច្ចេកពុទ្ធទី ៩ បាននិម្មិតអាសនៈឡើង ៨ ទៀត ហើយដោយអង្គខ្លួនឯងគង់លើអាសនៈ ដែលនៅជិតនឹងខ្លួន ។ អាសនៈបន្ថែមច្រើនឡើងត្រឹមណា តួផ្ទះក៏រីកធំចេញទៅច្រើនប៉ុណ្ណោះ ( គឺរីកចេញទៅរហូតគ្រប់គ្រាន់ សម្រាប់ព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គ ) ។ កាលបើព្រះបច្ចេកពុទ្ធទាំងអស់ គង់លើអាសនៈរៀបរយ ហើយ ឧបាសិកាទើបថ្វាយគ្រឿងសក្ការៈ ដែលខ្លួនរៀបចំត្រៀមទុក ថ្វាយព្រះបច្ចេកពុទ្ធត្រឹមតែ ៨ អង្គ តែប្រាកដជា គ្រឿងសក្ការៈមាន គ្រប់គ្រាន់ថ្វាយដល់ព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គ ហើយទើបយកផ្កា ឈូកខៀវ ៨ ផ្កា ចេញមកដាក់ត្រង់ទីជិតព្រះបច្ចេកពុទ្ធទាំងឡាយ ដែលខ្លួននិមន្តមកនោះ ទើបតាំងសេចក្ដីប្រាថ្នាឡើងថា បពិត្រលោក ម្ចាស់ទាំងឡាយ សូមឲ្យឆវីវណ្ណនៃសរីរៈរបស់ខ្ញុំម្ចាស់ មានពណ៌ខៀវ

ដូចត្របកនៃផ្កាឈូកខៀវទាំងនេះ ក្នុងគ្រប់ៗ ទីកន្លែង ដែលខ្ញុំម្ចាស់កើតហើយៗ ។ គ្រានោះ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏បាននាំគ្នាធ្វើការអនុមោទនាទានដល់ឧបាសិកា ហើយបានហោះទៅកាន់ភ្នំគន្ធមាទនវិញទៅ ។ ចំណែកឧបាសិកានោះ បានធ្វើកុសលកម្មផ្សេងៗ រហូតដល់អស់ជីវិត កាលនាងអស់ជីវិតពីជាតិនោះទៅហើយ បានទៅកើតក្នុងទេវលោក ក្នុងពុទ្ធកាលនេះ នាងបានត្រឡប់មកកើតនៅក្នុងត្រកូលសេដ្ឋី មានឈ្មោះថា **ឧប្បលវណ្ណា** សមទៅតាមចេតនាបុណ្យបារមីដែលខ្លួនបានតាំងសេចក្តីប្រាថ្នាទុករួចមកហើយ ។

ជីវប្រវត្តិក្នុងអតីតជាតិ របស់ព្រះនាងឧប្បលវណ្ណាថេរី ដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ មហានិបាត** ដែលមានប្រវត្តិរួមនៅក្នុងរឿងខ្លះ នៃ **ទសជាតិ** ( ១០ ជាតិ ) ជាជាតិដែលព្រះមហាបុរសទ្រង់បំពេញបុណ្យបារមីទាំងឡាយ ដោយព្រះថេរីបានមានឱកាសធ្វើសេចក្តីល្អផ្សេងៗ រួមផង ដូចមានរឿងតំណាលតទៅនេះថា ៖

រឿងព្រះតេមិយៈ ដែលជារឿងរបស់ព្រះតេមិយពោធិសត្វ ឬហៅទូទៅថា **ព្រះតេមិយៈ** បានកើតឡើងក្នុងជាតិនេះ ដើម្បីបំពេញ **នេក្ខម្មបារមី** ( នេក្ខម្មៈ គឺការចេញបួស ឬការចេញចាកកាម ) ព្រះនាងឧប្បលវណ្ណាថេរី បានកើតជា **នាងទេពធីតា** អាស្រ័យនៅស្វេតច្ឆត្ររបស់ **ព្រះបាទកាសិករាជ** នៅក្នុងនគរពារាណសី ក្នុងអតីតជាតិនាងទេពធីតានោះធ្លាប់បានជាមាតានៃព្រះតេមិយរាជកុមារ នាងទេពធីតាបានជាអ្នកឆ្លើយការទើកគិតក្នុងចិត្ត របស់ព្រះតេមិយរាជកុមារ ដែលទ្រង់នឹកខ្លាចខ្លួនធ្លាក់នរក ព្រោះជាប់ទាក់ទង នឹងកាលដែលព្រះអង្គធ្លាប់ធ្វើជាព្រះរាជា ហើយត្រូវបញ្ជាឲ្យគេប្រហារ ជីវិតមនុស្សជាច្រើនដោយអំពើកម្មនេះ ទើបធ្វើឲ្យព្រះអង្គធ្លាក់ទៅសោយទុក្ខក្នុងនរក នឹកឃើញដូច្នេះហើយ ទើបពិចារណាថា ធ្វើយ៉ាងណាហ្ន៎ ទើបយើងនឹងរួចផុតពីរាជសម្បត្តិ ដែលដូចជាផ្ទះរបស់មហាចោរនេះបាន ។ គ្រានោះដោយព្រះនាងទេពធីតាពោលតបដាស់តឿន ឲ្យមានស្មារតីថា នៃបាតេមិយៈ បាកុំបានទុក្ខក្តៅក្រហាយអ្វីឡើយ ប្រសិនបើបាត្រូវការនឹងទៅ

ឲ្យផុតចាកទីនេះ ចូរធ្វើជាមនុស្សពិការ ធ្វើជាមនុស្សថ្លង់ ធ្វើជាមនុស្សធ្លួតចុះ បាកុំធ្វើជាមនុស្សល្អត្រឹមត្រូវ ។ ទាំងនេះ ចាត់ជាពាក្យដែលមានប្រយោជន៍ដល់ព្រះតេមិយៈ បានស្តាប់ការដាស់តឿនពីនាងទេពធីតា ព្រះតេមិយកុមារទ្រង់ធ្វើតាម ទីបំផុតរហូតទ្រង់ចេញបួសតាមសេចក្តីប្រាថ្នាបាន ព្រោះបានការជួយខ្នះខ្នែង ពីនាងទេពធីតា ។

***រឿងព្រះមហាជនក*** ដែលជារឿងសម្តែងដល់ការបំពេញនូវ***វិរិយបារមី*** របស់ព្រះមហាជនកពោធិសត្វ ដែលទ្រង់សោយរាជ្យនៅក្នុង ***នគរមិថិលា ដែនវិទេហៈ*** ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជានាង ***មណីមេខលាទេពធីតា*** នៅក្នុងគ្រាមួយ នាងបានជួយសង្គ្រោះព្រះមហាជនកឡើងពីការហែលទឹក នៅក្នុងមហាសមុទ្រអស់ ៧ ថ្ងៃ ឲ្យទ្រង់រួចផុតពីការលង់ទឹក ព្រោះរឿងរបស់ព្រះមហាជនក លិចសំពៅកណ្តាលមហាសមុទ្រ ដោយព្រះមហាជនកកំពុងតែព្យាយាមហែលទឹក នាងមណីមេខលា ទើបសួរព្រះមហាជនកថា អ្នកណាព្យាយាមហែលទឹកនៅកណ្តាលមហាសមុទ្រ ដែលមិនអាចឃើញត្រើយដូច្នេះបាន អ្នក

ឃើញប្រយោជន៍យ៉ាងណា ទើបបានតស៊ូព្យាយាមយ៉ាងនេះ ។ ព្រះមហាជនកទ្រង់ត្រិះរិះថា ចាប់តាំងពីការហែលទឹកនៅក្នុងមហាសមុទ្រមក អស់ ៧ ថ្ងៃហើយ នៅមិនទាន់មាននរណាចរចានឹងយើងឡើយ អ្នកនេះជានរណា ? លុះព្រះអង្គត្រិះរិះដូច្នេះហើយ ទើបទ្រង់ងើបព្រះភក្ត្រឡើងទតមើលលើអាកាស កាលទ្រង់ឃើញនាងមណីមេខលា ទើបត្រាស់តបថា នែនាងទេពធីតា យើងបានពិចារណាឃើញទំនៀមរបស់លោក និងផលនៃសេចក្តីព្យាយាមហើយ ទើបបានព្យាយាមហែលទឹកនៅក្នុងមហាសមុទ្រ ដែលក្រឡេកមើលមិនឃើញត្រើយនោះឯង ។ នាងមណីមេខលាពោលតទៅទៀតថា អ្នកក្រឡេកមិនឃើញត្រើយមហាសមុទ្រ សូម្បីអ្នកនឹងព្យាយាមហែលទៅ ក៏នឹងត្រូវស្លាប់ដដែល អ្នកនឹងមិនអាចហែលដល់ត្រើយមហាសមុទ្របានឡើយ ។ ព្រះមហាជនកទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ទើបទ្រង់ត្រាស់ថា នែនាងទេពធីតា ខណៈដែលបុគ្គលធ្វើសេចក្តីព្យាយាម សូម្បីស្លាប់ទៅក៏បានឈ្មោះថាមិនជាទីតិះដៀលរបស់មាតាបិតា ញាតិសន្តាន រហូតដល់ទេវតាទាំង-

ឡាយ ប្រការមួយទៀត បុគ្គលតាំងចិត្តធ្វើតាមនាទីរបស់បុរស រមែង មិនក្ដៅក្រហាយ កើតទុក្ខទោមនស្សក្នុងកាលជាខាងក្រោយឡើយ ។ នាងមណីមេខលាពោលជំទាស់តទៅទៀតថា ការងារដែលធ្វើមិនទាន់សម្រេច ហើយកើតការលំបាករហូតដល់ស្លាប់ទៅមុន មិនគួរព្យាយាមធ្វើការងារនោះ មិនមែនឬ ?

កាលព្រះមហាជនក ទ្រង់នឹងធ្វើឲ្យនាងមណីមេខលាទាល់បញ្ញា ទើបត្រាស់ថា កាលបុគ្គលណាដឹងថា ការងារដែលធ្វើទៅនឹងមិនទាន់សម្រេច ហើយមិនការពារអន្តរាយ បុគ្គលនោះក៏ឈ្មោះថា មិនរក្សាជីវិតខ្លួន ប្រសិនបើបុគ្គលនោះ លះបង់សេចក្ដីព្យាយាមចោលហើយ ក៏នឹងបានឃើញទោសនៃសេចក្ដីខ្ជិល បុគ្គលខ្លះបានឃើញផលនៃបំណងរបស់ខ្លួន ហើយតាំងចិត្តធ្វើការងារ សូម្បីថាការងារនឹងសម្រេច ឬមិនសម្រេចក៏ដោយ រមែងបានឃើញផលនៃការងារប្រេចក្សដល់ខ្លួន ចូរមើលបុគ្គលទាំងឡាយ ដែលមកនៅក្នុងសំពៅជាមួយគ្នានឹងយើងចុះ បុគ្គលទាំងនោះ ម្នាក់ៗ នាំគ្នាចុះចាញ់ចំពោះអន្តរាយ ទើបត្រូវនាំគ្នា

លិចទឹកស្លាប់ក្នុងមហាសមុទ្រ រហូតអស់រលីង នៅសល់យើងត្រឹមតែម្នាក់ប៉ុណ្ណោះ ដែលតស៊ូឧស្សាហ៍ព្យាយាមហែលទឹកនៅបាន ៧ ថ្ងៃ ៧ យប់ ក្នុងថ្ងៃនេះហើយ ឥឡូវនេះ យើងបានឃើញផលនៃការព្យាយាមនោះ គឺយើងបានឃើញនាងជាទេពធីតា ដែលមិនធ្លាប់ឃើញពីមុនមកសោះ ព្រោះដូច្នោះ យើងនឹងព្យាយាមជាបន្តទៅទៀត ឲ្យដល់ត្រើយមហាសមុទ្រឲ្យបាន ។ នាងមណីមេខលា បានស្តាប់ព្រះរាជបន្ទូលដ៏រឹងមាំ របស់ព្រះមហាជនកហើយ ទើបបានពោលសរសើរថា អន្លង់សមុទ្រដ៏ធំ រកប្រមាណមិនបានដូចនេះ លោកបានព្យាយាម រហូតមិនលិចក្នុងទឹកស្លាប់ រាប់ថា ជាបុគ្គលរកបានដោយកម្រក្នុងលោក ព្រោះដូច្នោះ ប្រសិនបើត្រេកអរនឹងទៅទីណា ក៏ចូរទៅតាមបំណងចុះ កាលនាងមណីមេខលាពោលដូច្នេះហើយ ទើបសួរព្រះមហាជនកថា បពិត្រលោកអ្នកជាបណ្ឌិត លោកជាអ្នកមាននូវសេចក្ដីព្យាយាមច្រើន ឥឡូវនេះ លោកមានបំណងនឹងទៅកាន់ទីកន្លែងណា ? ព្រះមហាជនកត្រាស់តបថា នែនាងទេពធីតា ខ្ញុំមានបំណងនឹងទៅកាន់នគរមិថិលា ។

នាងមណីមេខលា ទើបយកដៃត្រកងព្រះមហាជនកឡើង មកឱបផ្អិប នឹងទ្រូង ដូចគ្នានឹងម្តាយបីបុត្រជាទីស្រឡាញ់បំផុត ហើយនាងហោះនាំ យកទៅដាក់នគរមិថិលា ទៅតាមបំណងរបស់ព្រះមហាជនក ។ គ្រានោះ ព្រះមហាជនកទ្រង់អស់កម្លាំងខ្លាំង ដោយហែលទឹកមកអស់ ៧ ថ្ងៃ ហើយ លុះរាងកាយបានមកប៉ះសម្ផស្សរាងកាយដែលជាទិព្វ របស់ នាងមណីមេខលា ក៏ផ្ទំលក់ទៅ ។ កាលនាងមណីមេខលានាំព្រះជនក ដល់ព្រះរាជឧទ្យាន ក្នុងនគរមិថិលា នាងមណីមេខលា ទើបដាក់ព្រះ មហាជនកឲ្យផ្ទំនៅលើព្រះទែនសិលាអាសនៈហើយ ទើបប្រាប់ពពួក ទេវតាក្នុងទីកន្លែងនោះ ឲ្យជួយអភិបាលរក្សាតទៅ ចំណែកឯខ្លួន ក៏ ត្រឡប់មកកាន់ កន្លែងទិព្វវិមានរបស់ខ្លួនវិញ ។ នេះជារឿងដែលព្រះ នាងឧប្បលវណ្ណាថេរី នាងកើតជានាងមណីមេខលា និងជាទេពធីតា ធ្វើកម្មល្អរមទុក ជាមួយនឹងព្រះមហាជនកពោធិសត្វ ។

រឿងព្រះសុវណ្ណសាម ដែលជារឿងសម្តែងដល់ការបំពេញនូវ មេត្តាបារមី របស់ព្រះសុវណ្ណសាមពោធិសត្វ នៅក្នុងកាលនោះ ព្រះ

នាងឧប្បលវណ្ណាភិក្ខុនី នាងបានកើតជា **នាងសុន្ទរីទេពធីតា** នៅនឹងភ្នំគន្ធមាទន៍ បានពោលជាសច្ចៈព្រះបាទកបិលយក្ខ នៃព្រះរាជានៅក្នុងនគរពារាណសី ដែលទ្រង់ប្រើធ្នូលាបថ្នាំពិស បាញ់ព្រះសុវណ្ណសាមពោធិសត្វឲ្យស្លាប់ ហើយឲ្យព្រះរាជាទ្រង់ជួយថែរក្សាមាតាបិតា របស់ព្រះសុវណ្ណសាម នាងទេពធីតាបានប្រកាសសច្ចវាចាជាលំដាប់ទី ៣ ថា យើងនៅភ្នំគន្ធមាទន៍នេះមករហូតអស់កាលដ៏យូរ មិនធ្លាប់ស្រឡាញ់មិនធ្លាប់អាណិតនរណាប្រៀបស្មើបាសុវណ្ណសាមនេះឡើយ ។ ដោយពាក្យសច្ចៈនេះ សូមឲ្យថ្នាំពិស ចូរជ្រះស្រឡះចាកពីរាងកាយ របស់បាសុវណ្ណសាម ក្នុងពេលឥឡូវនេះ ដោយពាក្យសច្ចវាចានេះ បានធ្វើឲ្យព្រះសុវណ្ណសាមបាត់ឈឺចុកចាប់ និងក្រោកឡើងបានមួយរំពេចនោះឯង ។

**រឿងព្រះមហោសថនេះ** ដែលជារឿងសម្តែងដល់ការបំពេញនូវ**បញ្ញាបារមី** របស់ព្រះមហោសថពោធិសត្វ នៅក្នុងកាលនោះ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជា **នាងភេរីបរិព្វាជិកា** និងបានជា

សាក្សីឲ្យព្រះមហោសថ ផុតពីសេចក្ដីសង្ស័យ ដោយសេចក្ដីថា ជាអ្នកគិតក្បត់ ចំពោះស្ដេចចុល្វនី ។

*រឿងព្រះភូរិទត្ត ( ភូរិ ប្រែថា ការឈ្លាសវៃ ) ជារឿងដែលសម្ដែងដល់ការបំពេញ* ***សីលបារមី*** *របស់ព្រះភូរិទត្តពោធិសត្វ ទ្រង់ជាព្រះរាជឱរសរបស់* ***ស្ដេចនាគធតរថ*** *ជាមួយនឹងព្រះនាងសមុទ្ទ (ជាមនុស្ស) កាលនោះ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជានាងនាគឈ្មោះថា* ***អច្ចិមុខី*** *ដែលជាប្អូនស្រីរបស់ព្រះភូរិទត្ត នាងអច្ចិមុខី នាងមានពិស មានតេជះខ្លាំងក្លា បានក្លែងជាសត្វកង្កែបតូចមកនៅលើជដារបស់សុទស្សនៈ បានខ្ជាក់ពិសទម្លាយគ្រូអាលម្ពាយ រហូតដល់កើតរោគឃ្លង់ និងជួយព្រះភូរិទត្ត ឲ្យរួចពីការឃុំ ត្រឡប់ឲ្យមានឥស្សរភាព ហើយបានឱកាសរក្សាសីលតទៅទៀត ។*

*រឿងព្រះចន្ទកុមារ ជារឿងដែលព្រះចន្ទកុមារពោធិសត្វបំពេញ* ***ខន្តិបារមី*** *កាលនោះ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជា* ***ព្រះនាងសេលាកុមារី*** *ទ្រង់ជាព្រះកនិដ្ឋភគិនី របស់ព្រះចន្ទកុមារពោធិសត្វ*

ទ្រង់បានក្រាបបង្គំទូលសូមព្រះរាជទានអភ័យជីវិតចំពោះព្រះចន្ទកុមារ ពោធិសត្វ ដែលព្រះបាទឯករាជ ទ្រង់ជាព្រះរាជបិតា បានត្រាស់ឲ្យកណ្ឌព្រាហ្មណ៍ជាអ្នកមានចិត្តគិតអាក្រក់ រកឧបាយសម្លាប់ព្រះចន្ទកុមារពោធិសត្វ រហូតទាំងសព្វសត្វ ដោយប្រាថ្នាឲ្យបានទៅកើតស្ថានសួគ៌ជាន់តាវត្តិង្ស ឲ្យទ្រង់រួចផុតទៅបាន ។

**រឿងព្រះវិធូរៈ** ជារឿងដែលព្រះវិធូរបណ្ឌិតពោធិសត្វបំពេញ**សច្ចបារមី** កាលនោះ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជានាងនាគឈ្មោះ **ព្រះនាងវិមលា** ទ្រង់ជាអគ្គមហេសីរបស់ស្តេចនាគវរុណ ព្រះនាងមានទូវព្រះរាជបំណង ដើម្បីនឹងស្តាប់ព្រះធម៌ពីព្រះវិធូរបណ្ឌិតពោធិសត្វ តែក្លែងពោលថា មានសេចក្តីត្រូវការស៊ីសាច់បេះដូងរបស់ព្រះវិធូរបណ្ឌិត ទើបប្រើឲ្យបុណ្ណយក្ខទៅចាប់ខ្លួនព្រះវិធូរៈមក ទីបំផុតព្រះនាងក៏បានស្តាប់ធម្មីកថា សមតាមសេចក្តីប្រាថ្នាបានពិតមែន ។

**រឿងព្រះវេស្សន្តរ** ឬជួនកាលហៅថា **ព្រះមហាវេស្សន្តរ** ដែលជារឿងទី ១០ ឬជារឿងចុងក្រោយរបស់រឿងទសជាតិ ជារឿងដែល

ពណ៌នាដល់ការបំពេញ **ទានបារមី** របស់ព្រះមហាវេស្សន្តរពោធិសត្វ កាលនោះ ព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជា **ព្រះនាងក្រស្នា** ទ្រង់ជាធីតា របស់ព្រះមហាវេស្សន្តរពោធិសត្វ ដោយនាងបានធ្វើជាវត្ថុទាន ដែលជួយឲ្យព្រះវេស្សន្តរ លះបង់កូនជាទានបាន រាប់ថាជា **មហាបរិច្ចាគ** គឺការលះបង់យ៉ាងធំ របស់ព្រះពោធិសត្វ ១ ប្រការក្នុងចំណោម ៥ ប្រការ បានដល់ ១ **ធនបរិច្ចាគ** គឺលះបង់ទ្រព្យជាទាន ២ **អង្គបរិច្ចាគ** គឺការលះបង់អវយវៈជាទាន ៣ **ជីវិតបរិច្ចាគ** គឺ ការលះបង់ជីវិតជាទាន ៤ **បុត្តបរិច្ចាគ** គឺការលះបង់កូនជាទាន ៥ **ទារបរិច្ចាគ** គឺការលះបង់ប្រពន្ធជាទាន ។

**មួយវិញទៀត** កាលដែលព្រះនាងឧប្បលវណ្ណាភិក្ខុនី បានកើតជាព្រះរាជធីតា របស់ព្រះមហាវេស្សន្តរនោះ ក៏បានមានពោលរួចមកហើយ មានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដោយព្រះថេរីជាអ្នកពោលដោយខ្លួនអង្គឯង ក្នុងទីចំពោះព្រះភក្ត្រព្រះភគវាដូចមានសេចក្តីថា ៖

ដោយព្រះនាងឧប្បលវណ្ណាភិក្ខុនីពោលថា បពិត្រព្រះអង្គ ជាមហាវីរបុរស ទ្រង់មានបញ្ញាចក្ខុ សម្បុររបស់ខ្ញុំម្ចាស់ ដូចជាសម្បុរនៃផ្កាឧប្បល ខ្ញុំម្ចាស់មានឈ្មោះថា ឧប្បលវណ្ណា ជាធីតារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទា ។ ព្រះរាហុលត្ថេរ និងខ្ញុំម្ចាស់ធ្លាប់កើតក្នុងភពតែមួយ អស់រយៈនៃជាតិជាច្រើន ជាអ្នកមានចិត្ត និងឆន្ទៈស្មើគ្នា ។ ការកើតឡើងក្នុងភពជាមួយគ្នាក៏មាន ក្នុងជាតិជាមួយគ្នាក៏មាន លុះដល់បច្ឆិមភព ជនទាំងពីរនាក់ កើតដោយឈ្មោះផ្សេងគ្នា ។ ព្រះរាជបុត្រ បានមកកើតជាកុមារ ឈ្មោះរាហុល ខ្ញុំម្ចាស់បានមកកើតជាធីតាឈ្មោះឧប្បលវណ្ណា ។

**នៅមានរឿងអតីតជាតិ** របស់ព្រះនាងឧប្បលវណ្ណាភិក្ខុនី មានក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** ជារឿងដែលព្រះនាងពោលដល់ជីវិតត្រាំចិត្ត តូចចិត្តរបស់ព្រះនាង ដូចមានសេចក្ដីថា ៖

ក្នុងអតីតជាតិ នាងធ្លាប់បានជាភរិយារបស់អ្នកឈ្មួញរទេះម្នាក់

ដោយថ្ងៃមួយ អ្នកឈ្មួញរទេះនោះបានផ្ទុកទំនិញទៅលក់ឯក្រុងរាជគ្រឹះ ដោយទុកចោលឲ្យភរិយា ដែលទើបតែមានគភ៌ជាលើកដំបូង ឲ្យនៅផ្ទះជាមួយម្ដាយក្មេក គឺផ្ទះរបស់ខ្លួន ។ លុះសម័យខាងក្រោយមក ភរិយារបស់អ្នកឈ្មួញរទេះនោះ ក៏មានគភ៌គ្រប់ខែ ។ ចំណែកឯម្ដាយក្មេក កាលឃើញកូនប្រសាមានគភ៌ដូច្នេះហើយ ទើបនិយាយនឹងកូនប្រសាថា កូនប្រុសរបស់យើងទៅជួញយូរណាស់ហើយ នាងទើបតែមានគភ៌ នាងប្រាកដជាទៅសហាយស្មន់ជាមួយនឹងបុរសដទៃហើយមើលទៅ ។ កូនប្រសាទើបប្រាប់ថា នែអ្នកម្ដាយ ខ្ញុំមិនដែលធ្លាប់ស្គាល់បុរសដទៃណាម្នាក់នោះឡើយ ក្រៅអំពីកូនរបស់អ្នកម៉ែតែម្នាក់ប៉ុណ្ណោះ ។ គ្រានោះ ម្ដាយក្មេកបានស្ដាប់ពាក្យកូនប្រសាដូច្នេះហើយ ក៏នៅតែមិនជឿ ។ កាលបើមិនជឿហើយ ទើបបានបណ្ដេញកូនប្រសាឲ្យចុះចេញពីផ្ទះទៅ ។ ឯកូនប្រសាត្រូវធ្លាក់ខ្លួន ជាមនុស្សគ្មានទីនៅអាស្រ័យ ទាំងគភ៌ក៏គ្រប់ខែដែរហើយ នាងក៏បានដើរទៅរកស្វាមី ដោយចេញដំណើរទៅកាន់ក្រុងរាជគ្រឹះ តែនាងក៏មិនបានជួបស្វាមី កាលគភ៌

របស់នាងគ្រប់ខែហើយ នាងក៏បានទៅនៅអាស្រ័យប្រសូតបុត្រ ដែលមានកាយដូចផ្ទៃទន្ទាប់មាស នៅសាលាសម្នាក់មួយ ដែលស្ថិតនៅក្បែរផ្លូវសញ្ចរទៅមក នាងក៏បានដាក់កូន ឲ្យដេកនៅក្នុងសាលាតែម្នាក់ឯង ហើយនាងបានដើរទៅរកដងទឹក ។ ក្នុងវេលានោះ ចៃដន្យមានអ្នកឈ្មួញរទេះម្នាក់ ដែលជាមនុស្សមិនមានកូន ធ្វើដំណើរឆ្លងកាត់ផ្លូវក្បែរសាលានោះ ក៏បានឃើញទារកដេកនៅតែម្នាក់ឯង គាត់ទើបយល់ថាទារកនេះ មិនមានមាតាបិតា ទើបទៅយកទារកនោះមកចិញ្ចឹមធ្វើជាកូនរបស់ខ្លួន ដោយយកទៅឲ្យអ្នកបម្រើចិញ្ចឹមបីបាច់ថែរក្សាទារកនោះ ។

ចំណែកឯមាតារបស់ទារក កាលត្រឡប់មកកាន់សាលាសម្នាក់ ដើម្បីរកកូនជាទីស្រឡាញ់ ក៏មិនបានឃើញកូន និងមិនដឹងថា កូនបាត់ទៅទីណា ទើបកើតទុក្ខទោមនស្សយ៉ាងខ្លាំង នាងក៏សម្រេចចិត្តថា នឹងមិនចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីទៅរកស្វាមីទៀតដែរ ព្រោះខ្លួនអស់កូនជាកស្តូតាងហើយ ទើបដើរគេចចូលទៅក្នុងព្រៃ ។ គ្រានោះមានមេចោរម្នាក់បានមកជួបនាង ក៏កើតសេចក្តីប្រតិព័ទ្ធ ទើបបាននាំយក

នាងទៅធ្វើជាភរិយា ។ លុះសម័យខាងក្រោយមក កាលនាងមករស់នៅជាមួយនឹងមេចោរនោះ នាងមានកូនស្រីម្នាក់ទៀត ។ថ្ងៃមួយ ខណៈដែលនាងឲ្យកូនស្រីដេកនៅលើគ្រែ ក្បាលរបស់កូនស្រី ដែលនៅជាទារិកាប៉ះខ្ទប់នឹងជ្រុងនៃគ្រែ ធ្វើឲ្យក្បាលរបួសបន្តិច នាងខ្លាចស្វាមីរបស់ខ្លួនដាក់ទោស ទើបបានទឹកត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ។ ចំណែកកូនប្រុសរបស់នាងដែលបាត់ទៅ ក៏បានធំពេញកំលោះ ហើយបានមកជួបនឹងស្ត្រីជាមាតានោះ តែខ្លួនមិនស្គាល់ ( ព្រោះបានព្រាត់ប្រាសគ្នាទៅតាំងពីកើតមកម្ល៉េះ មិនធ្លាប់បានជួបគ្នាសោះឡើយ ) គេបានកើតការប្រតិព័ទ្ធចំពោះមាតា ហើយនាំមកធ្វើជាភរិយារបស់ខ្លួន ។ កាលជាខាងក្រោយមក កូនប្រុសរបស់នាង បានទៅសូមកូនក្រមុំចោរមកធ្វើជាភរិយា ព្រោះគេមិនដឹងថា កូនក្រមុំចោរនោះជាប្អូនស្រីរបស់ខ្លួន សូម្បីតែមាតាក៏មិនស្គាល់កូនស្រីរបស់ខ្លួនដូចគ្នា ។សេចក្តីថា មាណពនោះ បានមាតា និងប្អូនស្រីរបស់ខ្លួនធ្វើជាភរិយាទាំងពីរនាក់ ដោយរស់នៅរួមជាមួយគ្នា ។ ថ្ងៃមួយ ស្ត្រីជាមាតា បានស្រាយផ្នួងសក់របស់

កូនស្រីចេញរកចៃឲ្យ កាលនាងវែកសក់កូនស្រីរកចៃ ទៅបានបន្តិច នាងក៏បានឃើញស្លាកស្នាមរបួសត្រង់លើក្បាលរបស់កូនស្រី ទើបនឹកសង្ស័យថា ស្រីនេះគង់នឹងជាកូនស្រីរបស់យើងទេដឹង នាងទើបបានសាកសួរអំពីប្រវត្តិថា នាងជាកូននរណា ឪពុកម្តាយអ្នក ឈ្មោះអ្វី នៅទីណា ហើយនាងក៏បានជឿប្រាកដថា ស្រីនេះ គឺជាកូនស្រីរបស់ខ្លួន ដែលខ្លួនបានគ្នាជាមួយនឹងមេចោរនោះមែន នាងទើបកើតការស្លុតចិត្តយ៉ាងក្រៃលែង ( ជីវិតរបស់មនុស្សនេះ មិនមានអ្វីពិតប្រាកដសោះឡើយ ) នាងទើបសម្រេចចិត្តចេញបួសជាភិក្ខុនី ។

កាលព្រះនាងឧប្បលវណ្ណាថេរី បានធ្វើកិច្ចបព្វជិតនេះចប់ហើយ នាងក៏បាននៅជាសុខក្នុងឈាន សុខក្នុងផល និងសុខក្នុងព្រះនិព្វាន ។ ថ្ងៃមួយ នាងបានពិចារណាឃើញទោសក្នុងកាមទាំងឡាយ ដ៏ថោកទាប និងសៅហ្មង ទើបបានពោលគាថាដដែលជាមួយនឹងគាថា ដែលព្រះថេរីមានសេចក្តីស្លុតចិត្ត បានពោលជាមួយនឹងមារ ដែលជាអ្នកមកក្នុងបំណាងដើម្បីទម្លាយចាកវិវេករបស់ព្រះថេរី តាមដែលមានសម្តែងទុក

នៅក្នុង គម្ពីរខុទ្ទកនិកាយ ថេរីគាថា នៃ ទ្វាទសកនិបាត ថា ៖

យើងទាំងពីរនាក់ គឺមាតា និងធីតា មានប្តីជាមួយគ្នា ( ភរិយារួមប្តី ) សេចក្តីតក់ស្លុត សេចក្តីព្រឺរោម អស្ចារ្យចម្លែក កើតមានដល់ខ្ញុំនោះ ។ ថ្វីយ កាមទាំងឡាយ ជារបស់មិនស្អាត មានក្លិនអាក្រក់ ដូចជាបន្លាច្រើនយ៉ាង ដែលនាំយើងទាំងពីរនាក់ គឺមាតា និងធីតា ឲ្យជាភរិយាជាមួយគ្នា ។ លុះខ្ញុំឃើញទោសក្នុងកាមទាំងឡាយហើយ ឃើញនេក្ខម្មៈថាជារបស់ក្សេម ទើបចេញចាកផ្ទះក្នុងក្រុងរាជគ្រឹះ ចូលកាន់ផ្នួស ។ ខ្ញុំរឭកដឹងជាតិមុនៗ ( បុព្វេនិវាស ) ឯចក្ខុទិព្វ ( ភ្នែកទិព្វ ) និងចេតោបរិយញ្ញាណ ( គឺការដឹងចិត្តអ្នកដទៃ ) ខ្ញុំបានជម្រះហើយ ទិព្វសោតធាតុ ខ្ញុំជម្រះហើយដែរ ។ សូម្បីឫទ្ធិខ្ញុំក៏ធ្វើឲ្យច្បាស់ហើយ ធម្មៈជាទីអស់អាសវៈ ( កិលេសដែលដេកត្រាំនៅក្នុងសន្តាន ) ។ ខ្ញុំក៏សម្រេចអភិញ្ញា ( ដឹងដ៏ក្រៃលែង ) ៦ ប្រការ ខ្ញុំធ្វើឲ្យជាក់ច្បាស់ហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចស្រេចហើយ ។ ក្នុងវេលាដែលព្រះពុទ្ធ ទ្រង់នឹងធ្វើយមកប្បាដិហារិយ៍ ខ្ញុំបាននិម្មិតនូវរថ ទឹមដោយ

សេះ ៤ ដោយឫទ្ធិ ហើយចូលទៅថ្វាយបង្គំព្រះបាទទាំងគូ នៃព្រះពុទ្ធ ដ៏មានសិរី ជាទីពឹងនៃសត្វលោក ហើយបានឈរក្នុងទីដ៏សមគួរ ។

មារបានសួរផ្ចាញ់ផ្ចាលព្រះនាងឧប្បលវណ្ណាភិក្ខុនីថា នាងជាស្រីម្នាក់ឯង ចូលមកកាន់ដើមរាំងភ្នំ ដែលនៅចុងមានផ្ការីកស្គុសស្គាយ ហើយឈរនៅទៀបគល់ឈើ បុគ្គលណាមួយជាគម្រប់ពីររបស់នាង ក៏មិនមានដែរ នៃស្ត្រីពាល នាងមិនខ្លាចពួកអ្នកលេងទេឬ ? ព្រះនាងឧប្បលវណ្ណាថេរីបានតបថា បើទុកជាអ្នកលេងទាំងឡាយ មួយរយ ឬមួយពាន់ ជាបុគ្គលមានសភាពយ៉ាងនេះ មកជួបជុំគ្នាហើយ ក៏រោម ( របស់យើង ) មិនព្រឺព្រួច មិនញាប់ញ័រ ។ នៃមារ អ្នកម្នាក់ឯង នឹងធ្វើអ្វីដល់យើងកើត ។ យើងនឹងបាត់ទៅ ឬនឹងចូលទៅកាន់ផ្ទៃរបស់អ្នកក៏បាន ឬបើទុកជាឈរនៅក្បែរចន្លោះចិញ្ចើមរបស់អ្នក ក៏អ្នកមើលមិនឃើញយើងឈរដែរ យើងជាស្ត្រីស្ទាត់នៅក្នុងអធិចិត្ត ឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយ ដោយប្រពៃ អភិញ្ញា ៦ យើងបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនា យើងបានធ្វើហើយ ។ កាម

គឺការស្រឡាញ់ទាំងឡាយ ប្រៀបដោយលំពែង និងឈើស្រួច សម្រាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ អ្នកពោលនូវតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ មិនមែនជាតម្រេករបស់យើងឡើយ ។ សេចក្ដីរីករាយក្នុងកាមទាំងអស់ យើងបានកម្ចាត់ចេញហើយ គំនរនៃងងឹត (អវិជ្ជា) យើងបានទម្លាយចោលហើយ ។ នៃមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ នៃមារថោកទាប អ្នកត្រូវយើងកម្ចាត់ចេញហើយ ។

ផលល្អ និងកិត្តិគុណផ្សេងៗ របស់ព្រះនាងឧប្បលវណ្ណាភិក្ខុនីគង់នឹងមិនចាំបាច់ពោលសរសើរថាមានច្រើនយ៉ាងទេ ពីព្រោះថា ព្រះអរហន្តីដែលសាវិការបស់ព្រះពុទ្ធ ដែលជាអ្នកបានទទួលតំណែង ជាអគ្គសាវិកាឆ្វេង ដែលព្រះលោកនាថ ទ្រង់ប្រកាសតែងតាំងឲ្យដើម្បីជួយធ្វើកិច្ចការងារផ្សេងៗ មិនមែនតែងតាំងឲ្យដើម្បីជាកិត្តិយសប៉ុណ្ណោះទេ ដូច្នោះកាលបើការងារ គឺការសិក្សាចំណែកខ្លួនរបស់នាងបានចប់ ( មហាវិទ្យាល័យជីវិត ) យ៉ាងបរិបូណ៌ ដោយនាងដឹងជាក់ច្បាស់យល់ពិត ទាំងភាគទ្រឹស្ដី និងភាគបដិបត្តិ ។ ចំណែកការងារដែលគួរ

ធ្វើតទៅ ក៏បានដល់ ការងារដើម្បីសង្គម ដែលមានព្រះពុទ្ធតម្រាស់ត្រាស់ប្រាប់ចំពោះសាវកទាំងឡាយទុកថា អ្នកទាំងឡាយ ចូរត្រាច់ទៅក្នុងជនបទដើម្បីជាប្រយោជន៍និងសេចក្ដីសុខដល់ជនច្រើន ទើបជាហេតុឲ្យព្រះអរហន្តទាំងឡាយ ធ្វើការងារឲ្យដល់សង្គមមួយចំណែកដែរ មិនបានសង្ឃឹមយកតែប្រយោជន៍ និងសេចក្ដីសុខដើម្បីតែខ្លួនឯង តែម្នាក់ឡើយ ។ ផលបុណ្យរបស់ព្រះនាងឧប្បលវណ្ណាថេរី ផ្ដល់ប្រគល់ឲ្យនាងជាក់ច្បាស់នូវទីបំផុតទុក្ខ ត្រឹមតែមួយផ្នែកប៉ុណ្ណោះ ៕

( ជីវប្រវត្តិរបស់ព្រះនាងឧប្បលវណ្ណាថេរី ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាងបដាចារាថេរី ✍

## " ព្រះនាងបដាចារាថេរីជាឯតទគ្គៈ ផ្នែកខាងទ្រទ្រង់ព្រះវិន័យ "

ព្រះនាងបដាចារាថេរី ជាអ្នកទ្រទ្រង់នូវអរិយធម៌ដ៏ខ្ពង់ខ្ពស់បំផុត និងជាអ្នកមានអច្ឆរិយភាព ផ្នែកខាងទ្រទ្រង់ព្រះវិន័យ ដោយមិនមានព្រះថេរីរូបណាទីមួយ មកប្រៀបផ្ទឹមជាមួយនឹងអច្ឆរិយភាព ផ្នែកខាងទ្រទ្រង់ព្រះវិន័យស្មើបាន ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះនាងបដាចារាថេរី ក៏មានសម្ដែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** និងក្នុង **អដ្ឋកថាធម្មបទ** នៃ **សហស្សវគ្គ** ក្នុងរឿងព្រះនាងបដាចារាថេរី ដូចមានសេចក្ដីថា ៖

ព្រះនាងបដាចារាថេរី កាលដើមជាធីតាសេដ្ឋី អ្នកមានទ្រព្យ

៤០ គោដិកហាបណៈ នៅក្នុងក្រុងសាវត្ថី នាងជាស្ត្រីមានរូបរាងស្អាតណាស់ ។ ពេលដែលនាងចម្រើនវ័យធំដឹងក្តីបានអាយុ ១៦ ឆ្នាំហើយ មាតាបិតាមានការព្រួយបារម្ភ ភ័យខ្លាច មិនចង់ឲ្យមានពាក្យនិយាយនិន្ទាអាក្រក់ ដែលកើតមកអំពីការប្រព្រឹត្តរបស់កូនស្រី ឬមានការប៉ះពាល់ដល់ក្រុមគ្រួសារ ខូចនឹងប្រពៃណីដែលល្អ ទើបឲ្យកូនស្រីឡើងទៅលើប្រាសាទជាន់ទី ៧ ដោយរកផ្លូវការពារទុកជាមុន ល្អជាងពេលដែលហេតុនោះកើតហើយ ។សូម្បីមាតាបិតានៅរង់ចាំឃ្លាំមើលយ៉ាងណាក៏ដោយ នាងបដាចារាក៏នៅតែលបលាក់ស្រឡាញ់ជាមួយគ្នានឹងអ្នកបម្រើម្នាក់ ដែលនៅក្នុងផ្ទះរបស់ខ្លួន ។ ការស្រឡាញ់បានកើតឡើងលួកជ្រៅរហូតដល់ប្រព្រឹត្តខុសប្រពៃណី ដោយមិនមានអ្នកដទៃដឹង ឬឃើញឡើយ ។កាលជាខាងក្រោយ មាតាបិតារបស់នាងបដាចារា បានសម្រេចចិត្ត នឹងលើកកូនស្រីក្រមុំរបស់ខ្លួន ឲ្យទៅបុរសកំលោះម្នាក់ដែលជាអ្នកមានជាតិត្រកូលស្មើគ្នា ហើយកំណត់ថ្ងៃវិវាហមង្គល (គឺថ្ងៃការ )។ លុះថ្ងៃវិវាហមង្គលជិតចូលមកដល់ហើយ នាងបដាចារា

ទើបប្រាប់ដល់គូសង្សារថា បានឮដំណឹងថា លោកឪពុកអ្នកម្ដាយរបស់ខ្ញុំ នឹងលើកខ្ញុំឲ្យទៅដល់បុរសម្នាក់នៅក្នុងត្រកូលឯណោះ ពេលដែលខ្ញុំទៅកាន់ត្រកូលរបស់ស្វាមីហើយ អ្នកនឹងមិនអាចជួបនូវខ្ញុំបានឡើយ ហេតុដូច្នេះ បើអ្នកចង់នៅជាមួយនឹងខ្ញុំ ត្រូវការខ្ញុំពិតមែននោះ ចូរអ្នកនាំខ្ញុំរត់ទៅនៅក្នុងទីឯណានីមួយទៅ ។ គ្រានោះ អ្នកបម្រើទទួលពាក្យថា បាទ ខ្ញុំព្រម ថែមទាំងបានកំណត់ពេលវេលាថា ព្រឹកស្អែកនេះ ខ្ញុំនឹងទៅឈរចាំនៅទីកន្លែងត្រង់នោះ ដែលនៅជិតៗ នឹងទ្វារក្រុង នាងចូររត់ចេញទៅដោយឧបាយយ៉ាងណានីមួយ ហើយទៅជួបគ្នានៅទីកន្លែងនោះ ។

ក្រោយពីការចរចាគ្នា ចប់សព្វគ្រប់ហើយ លុះព្រឹកឡើង អ្នកបម្រើបានប្រមូលវត្ថុ ដែលមានតម្លៃ ល្មមដែលអាចកាន់យកទៅបាន ទើបយកទៅជាប់តាមខ្លួន ហើយគេបានទៅឈររង់ចាំនៅកន្លែង ដែលបានណាត់គ្នាទុកនោះ ។ អ្នកបម្រើក៏បាននាំនាងបដាចារាធ្វើដំណើរទៅចម្ងាយផ្លូវប្រមាណ ៣-៤ យោជន៍ពីក្រុងសាវត្ថី និងចូលទៅសម្រាកអាស្រ័យ តាំងទីលំនៅក្នុងតំបន់មួយកន្លែងហ្នឹងឯង ហើយប្រកបអាជីព

ធ្វើស្រែចម្ការ និងកាប់ឧស ឬស្វែងរកបេះបន្លែផ្សេងៗជាដើម ក្នុងការចិញ្ចឹមជីវិត ។ ចំណែកនាងបដាចារា បានជួយចាត់ចែងកិច្ចការងារ ក្នុងផ្ទះមានដាំស្ងោជាដើមដោយខ្លួនឯង ទើបធ្វើឲ្យនាងជួបនឹងសេចក្តីទុក្ខលំបាកដែលជាផលកើតមកពីការមិនជឿស្តាប់ ពាក្យរបស់មាតាបិតា ។ ការនៅរួមគ្នានៃស្វាមី និងភរិយាគូនេះ តមក នាងបដាចារា ក៏បានតាំងគភ៌ឡើង ។ ពេលដែលនាងបដាចារាមានគភ៌ ជិតគ្រប់ខែនឹងប្រសូតបុត្រនាងទើបបាននិយាយប្រាប់ដល់ស្វាមីថា ក្នុងទីកន្លែងនេះ យើងមិនមានញាតិសន្តានទេ ការពិត មាតាបិតា រមែងមានចិត្តទន់ភ្លន់ចំពោះកូនហេតុដូច្នេះ សូមអ្នកនាំខ្ញុំទៅរកលោកឪពុក អ្នកម្តាយទៅ ខ្ញុំនឹងមានបំណង ដើម្បីចង់ទៅប្រសូតបុត្រនៅឯផ្ទះរបស់លោកឪពុកអ្នកម្តាយវិញ ជាការល្អជាង ។ គ្រានោះ ស្វាមីបាននិយាយឃាត់នាងបដាចារាថានាងនិយាយអ្វី មាតាបិតារបស់នាង កាលបើបានឃើញខ្ញុំចូលទៅហើយលោកទាំងពីរប្រាកដជាដាក់ទោសខ្ញុំមិនខាន ខ្ញុំមិនអាចទៅផ្ទះលោកឪពុកអ្នកម្តាយរបស់នាងបានទេ ។ លំដាប់នោះ នាងបដាចារា បាននិយាយ

អង្វរស្វាមីម្តងហើយម្តងទៀត រីឯស្វាមីក៏តែងរកវិធីនិយាយអាងលេស ថា ចាំថ្ងៃនេះ ថ្ងៃនោះ គេនិយាយយ៉ាងនេះជារឿយៗ ជាច្រើនថ្ងៃ នាងគិតថា យើងនឹងមិនអាចបបួលស្វាមីរបស់យើង ឲ្យជូនយើងទៅបានឡើយ ។ នាងបដាចារាជ្រាបថា ស្វាមីរបស់យើងជាមនុស្សល្ងង់ខ្លៅ មិននាំយើងត្រឡប់ទៅផ្ទះពិតមែន ទោះជាគាត់មិននាំយើងទៅ ក៏មិនជាអ្វី យើងនឹងទៅដោយខ្លួនឯង ។ លុះកាលស្វាមីរបស់នាងចេញទៅខាងក្រៅផ្ទះបាត់ នាងបដាចារា ទើបប្រាប់ញាតិជិតខាងគ្នាថា បើស្វាមីខ្ញុំត្រឡប់មក គេមិនបានឃើញខ្ញុំ ហើយគេសួររកខ្ញុំថា ខ្ញុំទៅទីណា សូមអ្នកទាំងឡាយជួយ ប្រាប់គេផងថា ខ្ញុំត្រឡប់ទៅកាន់ផ្ទះរបស់ខ្ញុំ កាលប្រាប់រួចស្រេចហើយ ទើបនាងចាត់ចែងបិទទ្វារផ្ទះរួចរាល់ បានធ្វើដំណើរទៅតែម្នាក់ឯង ។

កាលស្វាមីត្រឡប់មកវិញហើយ មិនឃើញនាងបដាចារានៅក្នុងផ្ទះ ទើបសួរញាតិជិតខាងដែលធ្លាប់ស្គាល់គ្នា អ្នកទាំងអស់នោះក៏ប្រាប់ថា ភរិយារបស់អ្នក នាងបានត្រឡប់ទៅកាន់ផ្ទះឪពុកម្តាយនាង

ហើយ ។ បុរសជាស្វាមីគិតថា នាងជាធីតានៃត្រកូលជាសេដ្ឋី ឥឡូវនេះ ព្រោះតែយើងធ្វើឲ្យនាងលំបាក ឥតទីពឹង គិតឃើញដូច្នេះហើយ ទើបប្រញាប់ប្រញាល់ ធ្វើដំណើររត់ទៅតាមនាងដែរ ដើម្បីឲ្យនាងត្រឡប់មកវិញ តែកាលគេតាមទៅទាន់ បាននិយាយអង្វរឲ្យនាងត្រឡប់មកផ្ទះវិញ នាងក៏មិនព្រមត្រឡប់មក ទោះបីស្វាមីបាននិយាយច្រើនលើកច្រើនសាហើយក៏ដោយ ក៏មិនអាចនឹងនាំនាងឲ្យត្រឡប់មកផ្ទះវិញបានឡើយ ។ ក្នុងខណៈដែលនាងបដាចារា កំពុងនិយាយជាមួយនឹងស្វាមីនោះ ខ្យល់កម្មជវាត ( ខ្យល់កើតអំពីកម្ម គឺបក់ឡើងក្នុងគភ៌ ពេលដែលប្រសូតបុត្រ ) កើតរំជើបរំជួលឡើងក្នុងគភ៌មួយរំពេច នាងក៏ដឹងថា ជិតនឹងប្រសូតបុត្រហើយ ទើបចូលទៅទីគុម្ពោតព្រៃមួយកន្លែង ដែលស្ថិតនៅជិតៗ នោះ ហើយប្រាប់ស្វាមីថា ខ្ញុំឈឺពោះប្រសូតបុត្រហើយ នាងក៏ដេកនទៀលនៅលើផែនដីទៅមក រួចក៏ប្រសូតបុត្រនៅក្នុងពេលហ្នឹងឯង ដោយសេចក្តីលំបាកយ៉ាងក្រៃលែង ។ កាលនាងបដាចារាប្រសូតបុត្ររួចហើយ ទើបពោលនឹងស្វាមីថា ខ្ញុំនឹងទៅកាន់ត្រកូលមាតាបិតា

ដើម្បីជាប្រយោជន៍ ក្នុងការប្រសូតបុត្រ តែឥឡូវនេះ ប្រយោជន៍នោះ ក៏សម្រេចហើយក្នុងវាងផ្លូវនេះ ប្រសិនបើពួកយើងទៅក្នុងពេលនេះ ក៏មិនមានប្រយោជន៍អ្វី នាំគ្នាគិតឃើញដូច្នេះហើយ ក៏នាំគ្នាត្រឡប់មក កាន់ផ្ទះរបស់ខ្លួនវិញ ដោយមិនបានទៅត្រកូលមាតាបិតាទៀតទេ ។

លុះសម័យខាងក្រោយមកទៀត នាងបដាចារា ក៏តាំងគភ៌មួយ ទៀតជាលើកទី ២ កាលគភ៌នោះគ្រប់ខែហើយ នាងក៏និយាយប្រាប់ស្វាមី ឬអង្វរស្វាមីដូចលើកមុនដែរ ប៉ុន្តែស្វាមីក៏បាននិយាយបញ្ចៀស ដូច លើកមុនដែរ ។ ពេលដែលស្វាមីទៅធ្វើធុរៈខាងក្រៅផ្ទះ នាងបានបីកូន តូច ធ្វើដំណើរទៅកាន់ត្រកូលមាតាបិតាទៀត ។ ចំណែកស្វាមី កាល ត្រឡប់មកដល់ផ្ទះ មិនឃើញភរិយា និងកូន ក៏នឹកដឹងក្លាមថា នាងបាន ធ្វើដំណើរទៅកាន់ផ្ទះខាងមាតាបិតា ទើបប្រញាប់រត់ទៅតាម ដោយទៅ តាមទាន់គ្នាក្នុងវាងផ្លូវ ហើយគេនិយាយបបួលនាងបដាចារា ឲ្យត្រឡប់ មកផ្ទះវិញ តែនាងមិនព្រមត្រឡប់ ដោយប្រាថ្នានាំកូនទៅកាន់ផ្ទះម្តាយ ឪពុក ។ ក្នុងខណៈដែលអ្នកទាំងពីរកំពុងធ្វើដំណើរទៅ ស្រាប់តែមាន

ភ្លៀងធំតាំងឡើងខុសរដូវកាល ធ្វើឲ្យទិសទាំង ៤ ងងឹតឈឹងមិនប្រាកដ
រឹងផ្ទៃមេឃពេលនោះ ហាក់បីដូចជា ឆេះសន្ធោសន្ធៅដោយផ្លេកបន្ទោរ
ឆ្លៀលឆ្វាត់ចុះឡើងទៅមក មើលទៅគួរឲ្យភ័យខ្លាចណាស់ ថែមទាំង
មានសំឡេងផ្គរលាន់ដ៏ខ្លាំងលាន់ឮ រំពងញាប់ញ័ររន្ធត់ ហើយក៏មាន
ភ្លៀងធ្លាក់ចុះមកយ៉ាងខ្លាំង មិនដាច់គ្រាប់ ។ វេលានោះ នាងបជាចារា
កើតខ្យល់រំជើបរំជួលឡើងក្នុងផ្ទៃ នាងទើបប្រាប់ដល់ស្វាមីថា ខ្ញុំឈឺពោះ
មិនអាចអត់ទ្រាំបាន ចូរបងរកទីសម្រាកបិទបាំងភ្លៀងឲ្យខ្ញុំផង ខ្ញុំប្រាកដ
ជាប្រសូតបុត្រមិនខាន ។ គ្រានោះ ស្វាមីក៏ប្រញាប់ប្រញាល់ស្រវេស្រវា
ចាប់កាំបិត ដើរទៅរកកាប់មែកឈើ ដើមឈើក្នុងព្រៃ ដើម្បីយកមក
ធ្វើផ្ដត់ភ្លៀងឲ្យភរិយាប្រសូតបុត្រ ដើរទៅបានជួបគុម្ពោតព្រៃមួយគុម្ព
ដែលដុះនៅត្រង់ដំបូក គិតនឹងទៅកាប់ដើមឈើត្រង់ដំបូកនោះ មកធ្វើ
ទីជម្រក និងរកស្បូវមកធ្វើដំបូល ដើម្បីបាំងភ្លៀងឲ្យភរិយា និងកូនតូច
របស់ខ្លួន ។ កាលគេឈានឡើងទៅកាប់ឈើត្រង់ដំបូកនោះ ដោយមិន
បានពិចារណាមើលថា នឹងមានអន្តរាយអ្វីឬទេ ព្រោះដោយការប្រញាប់

បន្ទាន់ធ្វើទីបិទបាំងភ្លៀងឲ្យភរិយាប្រសូតបុត្រនោះ ។ គ្រានោះ ពស់វែក ដំបូកមួយដេកនៅត្រង់ដំបូកនោះ លូនចេញមកចឹកត្រង់ជើងរបស់ស្វាមី នាងបដាចារាទៅ កាលស្វាមីត្រូវពស់ចឹក រាងកាយក៏មានពណ៌សម្បុរ ខ្មៅទូទៅទាំងដងខ្លួន ដូចត្រូវភ្លើងឆេះ គេក៏ដួលស្លាប់ក្នុងទីនោះទៅ ។

ចំណែកឯនាងបដាចារា ត្រូវរងទុក្ខយ៉ាងធ្ងន់ធ្ងរ រង់ចាំការត្រឡប់ មករបស់ស្វាមីដោយគិតថា មួយសន្ទុះទៀត ស្វាមីនឹងមក តែនាងត្រូវ រង់ចាំគ្មានបានផល និងក្នុងរវាងដែលនាងរង់ចាំស្វាមី ដោយសម្លឹងមើល មិនដាច់ភ្នែកនោះ នាងក៏បានប្រសូតបុត្រម្នាក់ឯង ដែលភ្លៀងកំពុងតែ ខ្លាំង ។ រីឯកូនទាំងពីរអត់ទ្រាំនឹងទឹកភ្លៀងមិនបាន ក៏យំខ្លាំងឡើង នាង បដាចារាសែនអាណិតកូនជាទីបំផុត នាងទើបលុតជង្គង់ទាំងពីរ ដាក់ដៃ ទាំងពីរទល់នឹងផ្ទៃផែនដី យកខ្នងបាំងការពារកូន ទាំងពីរទុកនៅខាង ក្រោមពោះ ឬដើមទ្រូង នៅរហូតអស់មួយរាត្រី រាងកាយរបស់នាង ស្គាំងស្គម មានពណ៌សម្បុរដូចគ្មានឈាមសោះជាប់នឹងកាយឡើយ ។ ការនៅរង់ចាំស្វាមី មានពេល

វេលាយូរសែនយូរបែបនេះ ជាហេតុធ្វើឲ្យនាងបដាចារាគិតទៅផ្សេងៗ ថា យើងជាមនុស្សអនាថា ហើយគេបោះបង់ចោលយើងទុកក្នុងវាងផ្លូវនេះ ហើយរត់ចេញទៅ ។ កាលភ្លឺស្រាងៗ នាងបដាចារា បានត្រកងបីកូនតូចដែលទើបតែប្រសូតថ្មីៗ ដែលមានសម្បុរដូចដុំសាច់ទុកដោយដៃម្ខាង ចំណែកដៃម្ខាងទៀតដឹកដៃកូនបងដើរចេញទៅ នាងដើរពិនិត្យមើលស្នាមជើងរបស់ស្វាមី ហើយដើរទៅ និងនិយាយជាមួយកូនបងថា មកកូន ឪពុករបស់កូនគង់នឹងទៅតាមផ្លូវនេះ ហើយនាងនាំកូនដើរទៅតាមដានជើងដែលស្វាមីដើរទៅ ដើរៗ ទៅ ក៏បានទៅជួបស្វាមី ដែលមានរាងកាយរឹង និងមានសម្បុរខៀវខ្មៅដេកស្លាប់នៅក្បែរដំបូក នាងទើបយំរៀបរាប់ថា ស្វាមីរបស់យើង បានស្លាប់ចោលយើងហើយក្នុងវាងផ្លូវ ព្រោះយើងជាដើមហេតុ ហើយនាងក៏បីកូន និងដឹកដៃកូនបងធ្វើដំណើរទៅ រហូតដល់ស្ទឹងអចិរវតី ។ ព្រោះមកពីភ្លៀងធ្លាក់ខ្លាំងរហូតទាល់ភ្លឺ ទើបធ្វើឲ្យស្ទឹងអចិរវតី មានទឹកពេញព្រៀបប្រាំង តែកន្លែងខ្លះនៃស្ទឹងនោះ មានទឹកជ្រៅត្រឹមក្បាលជង្គង់ កន្លែងខ្លះត្រឹមដោះ ។

គ្រានោះ នាងបដាចារាយល់ខុស ដោយគិតថា ទឹកជ្រៅណាស់ មិនអាចនឹងនាំកូនឆ្លងទៅត្រើយម្ខាង ទៅតែម្តងទាំងពីរនាក់បាន ទើបដាក់កូនបងឲ្យឈប់ចាំនៅក្បែរច្រាំងនេះ ហើយបីកូនប្អូនឆ្លងទៅត្រើយខាងនោះ លុះទៅដល់ត្រើយម្ខាងហើយ នាងដើររកស្លឹកឈើមកក្រាលទ្រាប់ ហើយយកកូនប្អូនដាក់ចុះ ឲ្យដេកនៅលើស្លឹកឈើនោះ បាននាងគិតថា យើងនឹងត្រឡប់ទៅយកកូនបងទៀត តែមិនចង់ចាកចេញពីកូនប្អូនទៅសោះ ដោយការភ័យព្រួយបារម្ភ ពេលដែលនាងធ្វើដំណើរចេញពីកូនប្អូនទៅ ក៏បែរត្រឡប់មកមើលហើយមើលទៀត គឺនាងបែរមុខបែរខ្នងក្រឡេកមើលកូនប្អូន ក្រឡេកមើលកូនបងទៅមកៗ ។ ក្នុងខណៈដែលនាងបដាចារា ដើរលុយទឹកមកដល់កណ្តាលស្ទឹង មានសត្វខ្លែងមួយហើរឆ្លងកាត់មកតាមផ្លូវនោះ បានក្រឡេកឃើញកូនប្អូន ស្មានថាជាដុំសាច់ ក៏ហើរចុះមក នាងកាលឃើញខ្លែងចាបយកកូនប្អូន ដែលកំពុងតែយំ ទើបលើកដៃទាំងពីរឡើងដេញ និងស្រែកសំឡេងខ្លាំងៗ ដេញខ្លែងដល់បីដង តែខ្លែងមិនបានឮសំឡេង ស្រែកដេញនោះ ព្រោះ

នាងនៅឆ្ងាយ ខ្លែងទើបចាបយកកូនប្អូនទៅ ។ ចំណែកកូនបង ដែលចាំនៅប្រាំងម្ខាង ដោយភ្នែកសម្លឹងមើលម្តាយ មិនដាច់ក្រសែភ្នែកនោះ ដោយគិតថា កាលណាម្តាយទើបមកយកយើង មើលចុះមើលឡើង បានឃើញម្តាយលើកដៃទាំងពីរបក់ទៅបក់មក និងសំឡេងស្រែកនៅកណ្តាលស្ទឹង ទើបយល់ថា ម្តាយស្រែកហៅខ្លួន ទើបលោតចុះទៅក្នុងទឹក ក៏ត្រូវខ្សែទឹកហូររសាត់បាត់ទៅក្នុងស្ទឹងអចិរវតី ។ រីឯនាងបដាចារាត្រូវបាត់បង់ស្វាមី និងកូនទាំងពីរជាទីស្រឡាញ់ដូច្នេះហើយ ទើបធ្វើឲ្យកើតសេចក្តីសោកសៅយ៉ាងខ្លាំង ទើបនាងស្រែកយំត្អូញត្អែររៀបរាប់ជារឿយៗ ដើរទៅបណ្តើរ ។

ដោយសេចក្តីថា កូនរបស់យើងម្នាក់ត្រូវខ្លែងចាបយកទៅ កូនរបស់យើងម្នាក់ទៀត ត្រូវខ្សែទឹកកួចយកទៅដែរ រីឯស្វាមីរបស់យើងក៏ត្រូវស្លាប់ក្នុងរវាងផ្លូវ ។ កាលនាងបដាចារាដើរត្អូញត្អែររៀបរាប់ រហូតទៅដល់ក្រុងសាវត្ថី សូម្បីនាងដើរចូលខេត្តក្នុងចំណែកផ្ទៃដីនៃត្រកូលរបស់នាងហើយ នាងក៏មិនអាចចាំផ្ទះរបស់ខ្លួនបាន ពីព្រោះនាងត្រូវ

អំណាចសេចក្តីសោកសៅគ្របសង្កត់យ៉ាងក្រៃលែងផ្ទួនៗ ជាពិសេស នោះ សភាពនៃផ្ទះរបស់នាងប្រែផ្លាស់ប្តូរជាច្រើន ដូច្នេះហើយ ទើបធ្វើឲ្យនាងចាំមិនបានដែរ ។ នាងបដាចារា ដើរៗ ទៅ ក៏បានជួបនឹងបុរសម្នាក់ ទើបសួរថា អ្នកនៅទីណា បុរសនោះតបថា ខ្ញុំនៅក្នុងក្រុងសាវត្ថី ។ នាងបដាចារាទើបសួរតទៅទៀតថា អ្នកមានស្គាល់ត្រកូលសេដ្ឋីឈ្មោះនេះ ដែលមានទីលំនៅនៅត្រង់ថ្នល់នោះ ក្នុងក្រុងសាវត្ថីនេះដែរឬទេ ? បុរសនោះតបថា ស្គាល់ តែនាងកុំសួរដល់ត្រកូលនោះឡើយ បើនាងស្គាល់ត្រកូលដទៃក៏សូមសួរទៀតចុះ ។ នាងបដាចារាបានប្រាប់បុរសនោះថា ខ្ញុំមិនប្រាថ្នានឹងសួរដល់ត្រកូលដទៃ តែនឹងសូមសួរដល់ត្រកូលសេដ្ឋីឈ្មោះនេះតែប៉ុណ្ណោះឯង ។ បុរសនោះ និយាយនឹងនាងបដាចារាយ៉ាងប្លែកថា នាងសាកសួរដល់ត្រកូលឈ្មោះនេះ នឹងមានប្រយោជន៍អ្វី បើខ្ញុំមិនប្រាប់ ហាក់បីដូចជាមិនសមគួរទេ ។ នាងបដាចារានិយាយថា អ្នកចូរប្រាប់មកចុះ មិនជាអ្វីទេ បុរសនោះ ទើបសួរថា កាលពីយប់មិញនេះ មានភ្លៀងធ្លាក់រហូតទាល់ភ្លឺ តើនាងដឹង

ឬទេ ? នាងបដាចារាតបថា ដឹង ក្មៀងធ្លាក់មួយយប់ទាល់ភ្លឺ មិនមែនតែខ្ញុំម្នាក់ អ្នកដទៃក៏ដឹងដែរ តែខ្ញុំនឹងពោលហេតុការណ៍ ដែលភ្លៀងធ្លាក់ជាមួយលោកខាងក្រោយចុះ សូមអ្នកប្រាប់រឿងត្រង់ផ្ទះលោកសេដ្ឋីឲ្យដល់ខ្ញុំជ្រាបជាមុនសិន ។ បុរសនោះ ទើបពោលប្រាប់ហេតុការណ៍ដែលគួរឲ្យតក់ស្លុតចិត្ត ឲ្យនាងបដាចារាស្តាប់ថា កាលពីយប់មិញនេះ ផ្ទះរបស់សេដ្ឋីនោះ ត្រូវខ្យល់ព្យុះបក់រលំសង្កត់ស្លាប់មនុស្សបីនាក់ គឺលោកសេដ្ឋី ១ ភរិយារបស់លោកសេដ្ឋី ១ និងកូនប្រុសរបស់លោកសេដ្ឋី ១ ស្លាប់នៅក្នុងផ្ទះជាមួយគ្នា ដោយផ្ទះសង្កត់ស្លាប់ ហើយឥឡូវនេះ ជនទាំងបីនាក់នោះ ត្រូវគេនាំយកទៅដុតលើជើងថ្ករជាមួយគ្នា បុរសនោះ ដើម្បីនឹងបញ្ជាក់ពាក្យនិយាយរបស់ខ្លួន ដែលប្រាប់នោះ ទើបលើកដៃឡើងចង្អុលបង្ហាញឲ្យនាងបដាចារាបានឃើញថា នាងចូរមើលផ្សែងកំពុងហុយអណ្តែតឡើងនៅឡើយ នេះឯងជាផ្សែងដុតអ្នកទាំងបីនាក់នោះជាមួយគ្នា ។

កាលនាងបដាចារា បានស្តាប់ពាក្យនិយាយប្រាប់ របស់បុរស

នោះហើយ ទើបកើតការមមិងមមាំង និយាយឡើងថា អ្នកនិយាយថាអ្វី អម្បាញ់មិញនេះ ? តពីនោះ នាងបដាចារាអត់មានការទទួលខុសត្រូវ ចំពោះសម្លៀកបំពាក់របស់នាង មកពីនាងបាត់បង់ស្មារតី ដូច្នេះហើយ សូម្បីតែសម្លៀកបំពាក់ដែលជាប់នឹងខ្លួនក៏មិនមាន នាងក៏បានក្លាយជាមនុស្សឆ្កួតទៅ ។ នាងបដាចារា កាលត្រូវព្យុះភ្លៀងជីវិត គឺសេចក្តីទុក្ខគ្របសង្កត់ខ្លាំង ធ្វើឲ្យនាងទ្រាំនូវសភាពនៃសេចក្តីទុក្ខនោះមិនបាន ក៏បានធ្វើឲ្យនាងក្លាយជាមនុស្សវិកលចរិត ខុសប្រក្រតីដើម នាងក៏តែងដើរលើកដៃទាំងពីរឡើងទួញយំស្រែកឡូឡា ដោយដើរទៅកាន់កន្លែងដែលបូជាសពឪពុកម្តាយ និងបងប្រុស ដើម្បីសូមមើលជាលើកចុងក្រោយ ដោយគិតថា យើងមិនមានឱកាសបានឃើញពួកអ្នកតទៅទៀតទេ មានតែឱកាសពេលនេះឯង នាងទើបបានយំដើរត្អូញត្អែររៀបរាប់ភាពគ្មានដីងខ្លួន មានបរិទេវៈថា កូនទាំងពីរនាក់ស្លាប់ ហើយស្វាមីក៏ស្លាប់ក្នុងរវាងផ្លូវ មាតាបិតា និងបងប្រុសក៏ត្រូវដុតលើជើងថ្ករជាមួយគ្នា ។ កូនខ្ញុំពីរនាក់ត្រូវព្រាត់ប្រាសចាកទ្រូងទៅ ម្នាក់ធ្លាក់ទឹកស្លាប់បាត់

ស្វាត់ឈើង ម្នាក់ត្រូវខ្លែងចាបស៊ីទៅអស់ជីវិត ចំណែកស្វាមីត្រូវពស់ចឹកស្លាប់ ទាំងពុកម៉ែ និងបងប្រុស ក៏វិនាសខ្ទេច ផ្ទះបាក់សង្កត់លើកាយាគួរអាណិត ត្រូវដុតរួមលើគំនរភ្លើងឆេះខ្ទេច បាបណា បំផ្លាញបញ្ជូនផលដល់នូវសេចក្តីវិនាសឲ្យយើង ។ កាលនាងបដាចារា កើតការតូចចិត្តទួញយំ ហើយនាងដោះសម្លៀកបំពាក់ចោលអស់ សូម្បីមានអ្នកដទៃហុចសម្លៀកបំពាក់ឲ្យនាងៗ ក៏មិនត្រូវការ នាងក៏បានដើរសោត់អណ្តែតត្អូញត្អែររៀបរាប់ ដើរយំទៅដោយគ្មានគោលដៅ ចេញពីផ្លូវមួយ ទៅកាន់ផ្លូវមួយ ព្រោះនាងជួបនឹងសោកមរណកម្មយ៉ាងធ្ងន់ធ្ងរ ហេតុមិនអាចតាំងសតិឲ្យមាំបាន ។

មហាជនជាច្រើន កាលបានក្រឡេកឃើញនាង មានអាការដូច្នេះម្នាក់ៗ ក៏នាំគ្នាចោមរោមមើលនាង ក្នុងទីកន្លែងដែលខ្លួនបានជួប បានឃើញ ហើយស្តីឲ្យនាងថា ស្រីឆ្កួត អ្នកខ្លះយកសំរាម ឬលំអងធូលីរោយដាក់លើក្បាលរបស់នាង អ្នកខ្លះយកដុំដីគប់គ្រវែងនាង ។ នាងបដាចារា បានដើរទៅកន្លែងផ្សេងៗ ដោយមិនមានសម្លៀកបំពាក់ជាប់

នឹងខ្លួន ព្រោះហេតុដូច្នោះ មនុស្សទាំងឡាយ ទើបហៅនាងថា **បដាចារា** ដែលមានសេចក្ដីថា អ្នកមានការប្រព្រឹត្តមិនខ្មាស ព្រោះនាងជាមនុស្សខូចមារយាទ ដោយមិនមានសម្លៀកបំពាក់ជាប់នឹងខ្លួន (នេះជាទី.មកនៃឈ្មោះរបស់នាងថា **បដាចារា**) ។ ថ្ងៃមួយព្រះលោកនាថទ្រង់កំពុងសម្ដែងព្រះធម៌ទេសនា នៅក្នុងកណ្ដាលបរិស័ទទាំង ៤ ក្នុងវត្តជេតពន ទ្រង់បានពិចារណាឃើញនាងបដាចារា មានបុណ្យកុសល បានធ្វើទុកមកហើយក្នុងអតីតជាតិ និងតាំងសេចក្ដីប្រាថ្នាទុកក្នុងតំណែងជាឯតទគ្គៈផ្នែកខាងទ្រទ្រង់ព្រះវិន័យ នាងជាអ្នកបរិបូណ៌ទៅដោយបុញ្ញាភិនីហារ កំពុងតែដើរមកអំពីចម្ងាយ ព្រះលោកនាយក ទ្រង់ត្រិះរិះថា អ្នកដទៃក្រៅអំពីតថាគតហើយ មិនមាននរណាអាចជាទីពឹងរបស់នាងកុលធីតានេះបានទេ ទើបទ្រង់បណ្ដាលឲ្យនាងបដាចារា ដើរបែរមុខឆ្ពោះមកកាន់វត្តជេតពន ។ នាងបដាចារាបានដើរចូលទៅ នៅក្នុងទីបំផុតនៃបរិស័ទ គឺឈរនៅខាងក្រៅទីប្រជុំជន កាលពុទ្ធបរិស័ទទាំងឡាយ បានឃើញនាងដើរចូលមកក្នុងទីកន្លែងនោះ ទើបនិយាយគ្នាថា កុំឲ្យស្រីឆ្កួតចូល

មកទីនេះ រហូតធ្វើឲ្យកើតសំឡេងអ៊ូអរនៅក្នុងទីកន្លែងនោះ ។ គ្រានោះ ព្រះជិនស្រី ទើបត្រាស់ថា កុំហាមនាង ឲ្យនាងចូលមកចុះ កាលនាងបដាចារាចូលមកជិតដល់ ទើបទ្រង់ផ្សាយមេត្តាទៅឲ្យនាងបដាចារា ហើយត្រាស់ថា ប្អូនស្រី នាងចូរមានសតិឡើង ។ ដោយពុទ្ធានុភាពដែលទ្រង់បណ្តាលឲ្យប្រព្រឹត្តទៅ កាលនាងបដាចារាបានស្តាប់នូវព្រះពុទ្ធតម្រាស់ របស់ព្រះមានព្រះភាគជាម្ចាស់ហើយ នាងត្រឡប់ជាអ្នកមានសតិ និងកើតហិរិឱត្តប្បៈឡើងមកភ្លាមៗ ដឹងខ្លួនកើតការអៀនខ្មាសថា ខ្លួនឯងមិនមានសម្លៀកបំពាក់បិទបាំងកាយឡើយ នាងទើបអង្គុយចុះទីកន្លែងនោះឯង កាលនាងអង្គុយចុះជិតដល់ផែនដី គ្រានោះ មានបុរសម្នាក់ដែលឈរនៅជិតនាង បានហុចសំពត់សាដកសម្រាប់ដណ្តប់ឲ្យដល់នាងបដាចារា ។

កាលនាងបដាចារាទទួលសំពត់សាដកមកដណ្តប់រួចហើយ បានចូលទៅក្រាបថ្វាយបង្គំព្រះលោកនាថ ដោយបញ្ចង្គប្រតិស្ឋាន គឺការក្រាបថ្វាយបង្គំប្រកបដោយអង្គ ៥ ទៀបព្រះយុគលបាទ ដែលមាន

ពណ៌សម្បុរដូចមាស ហើយនាងក្រាបទូលថា សូមព្រះលោកនាយក ជាទីពឹងរបស់ខ្ញុំម្ចាស់ផងចុះ ព្រោះថា កូនម្នាក់របស់ខ្ញុំម្ចាស់ត្រូវខ្លែងធាបយកទៅ កូនម្នាក់ទៀត ក៏ត្រូវទឹកកួចយកទៅ ស្វាមីក៏ស្លាប់ក្នុងវវាងផ្លូវ មាតាបិតា និងបងប្រុស ត្រូវផ្ទះបាក់សង្កត់លើស្លាប់ ហើយត្រូវគេដុតលើជើងថ្ករជាមួយគ្នា ។ កាលព្រះអង្គ ទ្រង់ព្រះសណ្ដាប់ពាក្យក្រាបទូលរបស់នាងបដាចារាហើយ ទើបត្រាស់ថា នាងកុំគិតឡើយ នាងបានចូលមកកាន់សម្នាក់របស់តថាគត អ្នកនឹងបានជាទីពឹង ជាទីស្រឡាញ់របស់ខ្លួនឯង ជាតិនេះ កូនម្នាក់របស់នាង បានត្រូវខ្លែងធាបយកទៅ ម្នាក់ទៀតក៏ត្រូវទឹកកួចយកទៅ រីឯស្វាមីក៏ស្លាប់ក្នុងវវាងផ្លូវ មាតាបិតា និងបងប្រុស ក៏ត្រូវផ្ទះបាក់សង្កត់លើស្លាប់ យ៉ាងណាមិញ នាងដែលត្រូវយំសោក ព្រោះកូនស្លាប់ក្នុងមួយជាតិៗ ទឹកភ្នែករបស់នាង បើគិតការត្រាច់រង្គាត់ទៅក្នុងសង្សារវដ្តនេះ ការយំព្រាត់ប្រាសកូនជាដើមនោះ ទឹកភ្នែករបស់នាងច្រើនជាងទឹកមហាសមុទ្រទាំង ៤ ទៅទៀត ហើយព្រះអង្គត្រាស់ព្រះគាថាថា

ទឹកក្នុងមហាសមុទ្រទាំង ៤ តិចពេកណាស់ ទឹកភ្នែករបស់អ្នកមានទុក្ខសោក នៅតែច្រើនជាង ទឹកក្នុងមហាសមុទ្រទាំង ៤ ទៀត ហេតុអ្វីនាងនៅតែប្រកាន់ដដែល ។

កាលព្រះលោកនាយកទ្រង់សម្តែង **អនមតគ្គបរិយាយសូត្រ** គឺរឿងសង្សារវដ្តមិនមានទីបំផុតឲ្យនាងបដាចារាបានស្តាប់ ការសោកសៅក្នុងចិត្តរបស់នាង ក៏រំសាយថយចុះដោយលំដាប់ ។ លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបថា នាងបដាចារាមានសេចក្តីសោកសៅស្រាលចុះខ្លះហើយ ទើបត្រាស់ថា បដាចារា បុគ្គលទាំងឡាយ មានបុត្រជាដើមមិនអាចទប់ទល់ ឬជាទីពឹង ជាកន្លែងគេចកៀសខ្លួន ដល់អ្នកទៅកាន់បរលោក ( លោកខាងមុខ ) បានព្រោះដូច្នោះ សូម្បីបុត្រជាដើមមានក៏ស្មើគ្នានឹងមិនមាន គួរតែនឹងរក្សាសីលឲ្យបរិសុទ្ធ ដើម្បីជម្រះផ្លូវទៅកាន់ព្រះនិព្វាន ទើបជាការល្អ ។ ហើយព្រះលោកនាយក ទ្រង់ត្រាស់ព្រះគាថា ដើម្បីទ្រង់សម្តែងព្រះធម៌ទេសនា ឲ្យត្រូវគ្នានឹងឧបនិស្ស័យរបស់នាងបដាចារាថា

កូនទាំងឡាយទីពឹងពុំបាន ញាតិក៏ទីពឹងពុំបាន ទាំងផៅពង្ស ក៏ពឹងពុំបាន បុគ្គលដែលត្រូវសេចក្តីស្លាប់គ្របសង្កត់ ទីពឹងចំពោះញាតិពុំបានឡើយ ។ បណ្ឌិតកាលដឹងអំណាចរបស់ប្រយោជន៍នេះហើយ គប្បីជាអ្នកសង្រួមក្នុងសីល គប្បីប្រញាប់ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានដោយឆាប់រហ័ស ។

ពេលដែលព្រះសាស្តាទ្រង់ត្រាស់ទេសនាចប់ នាងបដាចារាក៏បានដុតកិលេស ដែលមានប្រមាណប៉ុនធូលី លើផែនដីធំ ហើយបានសម្រេចព្រះសោតាបត្តិផល ជាព្រះអរិយបុគ្គលថ្នាក់ដំបូង នៅក្នុងព្រះពុទ្ធសាសនានេះ និងមានបុគ្គលជាច្រើនទៀត ក៏បានសម្រេចមគ្គផលដែរ ទៅតាមឧបនិស្ស័យរបស់ខ្លួន ។ កាលនាងបដាចារាបានសម្រេចសោតាបត្តិផល គឺជាព្រះសោតាបន្នហើយ ទើបចូលទៅគាល់ក្រាបថ្វាយបង្គំព្រះទសពល និងក្រាបទូលសូមបព្វជ្ជា ។ គ្រានោះ ព្រះមុនីទ្រង់ត្រាស់អនុញ្ញាតបព្វជ្ជាដល់នាងបដាចារា ដោយទ្រង់បញ្ជូនឲ្យទៅកាន់សម្នាក់ភិក្ខុនី ហើយឲ្យនាងបានបួស ។ ពេលដែលនាងបដាចារា

បានឧបសម្បទាហើយ ក៏មានឈ្មោះប្រាកដថា បដាចារាដូចដើម ព្រោះជាអ្នកខូចមារយាទ ដែលមិនមានសម្លៀកបំពាក់ ក្នុងពេលដែលនាងបាត់បង់ស្មារតី ។ ថ្ងៃមួយ នាងបដាចារាកិក្ខុនីដងទឹកមកលាងជើង កាលឃើញទឹកធ្លាក់ចុះដល់ផ្ទៃដី មានទឹកហូរទៅបានបន្តិច នាងទើបចាក់ទឹកចុះជាលើកទី ២ ទឹកក៏ហូរទៅឆ្ងាយជាងមុនបន្តិច ។ កាលនាងចាក់ទឹកចុះទៅជាលើកទី ៣ ទឹកក៏បានហូរទៅឆ្ងាយជាងលើកទី ២ បន្តិចទៀត នាងទើបកាន់យកទឹកនោះមកជាអារម្មណ៍ កំណត់ទឹកដែលចាក់ទាំង ៣ លើក ហើយកាន់យកមកប្រៀបធៀបគ្នាក្នុងវ័យទាំងបីថា ពួកសត្វលោកខ្លះស្លាប់ហើយក្នុងបឋមវ័យ គឺវ័យខាងដើម ( កំណត់យកអាយុតាំងពីកើតរហូតដល់អាយុ ២៥ ឆ្នាំ ) ប្រៀបធៀបបាននឹងទឹកដែលយើងចាក់ទៅជាលើកដំបូងនុ៎ះឯង ។ ពួកសត្វលោកខ្លះ ស្លាប់ក្នុងមជ្ឈិមវ័យ គឺវ័យកណ្តាល ( កំណត់យកអាយុតាំងពី ២៦ ឆ្នាំ ដល់ ៥០ ឆ្នាំ ) ប្រៀបធៀបបាននឹងទឹក ដែលយើងចាក់ទៅជាលើកទី ២ ដែលមានអាយុវែងជាងពួកសត្វលោក ដែលស្លាប់ក្នុងបឋមវ័យក៏មាន ។ ពួក

សត្វលោកខ្លះ ស្លាប់ក្នុងបច្ឆិមវ័យ គឺវ័យចុងក្រោយ ( កំណត់យកអាយុតាំងពី ៥០ ឆ្នាំឡើងទៅ ) ប្រៀបធៀបបាននឹងទឹកដែលយើងចាក់ទៅលើកទី ៣ ដែលមានអាយុវែងជាងពួកសត្វលោក ដែលស្លាប់ក្នុងមជ្ឈិមវ័យក៏មាន ។

គ្រានោះ ព្រះមុនីគង់នៅក្នុងព្រះគន្ធកុដិ ទ្រង់បញ្ចេញព្រះរស្មីឲ្យទៅប្រាកដដូចព្រះអង្គប្រថាប់ឈរ ត្រាស់នៅទីចំពោះមុខបដាចារាថេរី ទើបត្រាស់ថា សេចក្ដីប្រៀបធៀបនេះត្រឹមត្រូវហើយ បដាចារា ការមានជីវិតរស់នៅត្រឹមតែមួយថ្ងៃក្ដី មួយខណៈក្ដី របស់អ្នកឃើញការតាំងឡើង និងការវិនាសទៅនៃខន្ធ ៥ នៅល្អជាងអ្នកមានជីវិតរស់នៅដល់ ១០០ ឆ្នាំ ដែលជាអ្នកមិនបានឃើញការវិនាសទៅ និងការតាំងឡើងនៃខន្ធ ៥ ព្រះអង្គទើបត្រាស់ព្រះគាថាថា

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកដែលឃើញការកើតឡើង និងការវិនាសទៅប្រសើរជាង ។

ព្រះគាថាទាំងនោះ មានសេចក្ដីអធិប្បាយថា ពាក្យថា បុគ្គលមិនឃើញការតាំងឡើង និងការវិនាសទៅ បានដល់ មិនឃើញការតាំងឡើង និងការវិនាសទៅនៃខន្ធ ៥ ( គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ) ដោយលក្ខណៈ ២៥ ( គឺការកើត-រលត់នៃខន្ធ ៥ ព្រមដោយហេតុ បានដល់ អវិជ្ជា តណ្ហា ឧបាទាន កម្ម អាហារ ក្នុងខន្ធមួយៗ រាប់បាន ៥ រួម ៥ ពួក = ២៥ ) ។ ចំណែកបុគ្គលឃើញការតាំងឡើង និងការវិនាសទៅ បានដល់ បុគ្គលមានជីវិតរស់នៅ សូម្បីត្រឹមតែមួយថ្ងៃ ដែលបានឃើញការតាំងឡើង និងការវិនាសទៅនៃខន្ធ ៥ ។ ក្នុងវេលាដែលចប់ព្រះធម៌ទេសនា ព្រះនាងបដាចារាភិក្ខុនី ក៏បានសម្រេចព្រះអរហត្ត ជាព្រះអរហន្តី ព្រមទាំងបដិសម្ភិទាទៀតផង ។ តមកព្រះនាងបដាចារាថេរី នឹងជាអ្នកមានចំណេះដឹងបែកធ្លាយជំនាញផ្នែកខាងទ្រទ្រង់ព្រះវិន័យ ។ លុះសម័យកាលខាងក្រោយតមក ព្រះលោកនាថគង់នៅក្នុងវត្តជេតពន ព្រះអង្គក៏បានប្រកាសតែងតាំងភិក្ខុនីទាំងឡាយ ទុកក្នុងតំណែងជាឯតទគ្គៈផ្សេងៗ ជាច្រើន ទៅតាមបុណ្យ

បារមីរបស់ខ្លួន ដែលបានសន្សំរួចមកហើយ ក្នុងអតីតជាតិ ។

ក្នុងគ្រានោះដែរ ព្រះលោកនាយក ទ្រង់បានប្រកាសតែងតាំងព្រះនាងបដាចារាភិក្ខុនី ទុកក្នុងតំណែងជាឯតទគ្គៈ គឺឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងទ្រទ្រង់ព្រះវិន័យ តាមដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ វិនយធរានំ យទិទំ បដាចារា** ម្នាលភិក្ខុទាំងឡាយ បដាចារា ជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ជាសាវិការបស់តថាគត ផ្នែកខាងទ្រទ្រង់ព្រះវិន័យ ។

ព្រះនាងបដាចារាភិក្ខុនី ក្រោយពីបានជាព្រះអរហន្តីហើយ ទើបបានពិចារណាដល់ការបដិបត្តិរបស់ខ្លួនឯង និងសម្តែងផល ដែលកើតមកអំពីការបដិបត្តិនោះ មានសម្តែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** ដូចដែលមានសេចក្តីថា ៖

ពួកមាណពភ្ជួរស្រែ ដោយនង្គ័លទាំងឡាយ ហើយព្រោះពូជទាំងឡាយលើផែនដី តែងបាននូវទ្រព្យចិញ្ចឹមកូន និងប្រពន្ធទាំងឡាយ ។

អាត្មាអញបរិបូណ៌ដោយសីល មិនខ្ជិល មិនរវើរវាយ ធ្វើតាមសាសនារបស់ព្រះសាស្តា ដូចម្តេចក៏មិនបានព្រះនិព្វាន ។ អាត្មាអញលាងជើងក្នុងទឹក ឃើញទឹកសម្រាប់លាងជើងហូរអំពីទីទួលមកកាន់ទីទាប ហើយធ្វើ ( ឲ្យជានិមិត្ត ) ក្នុងទឹកទាំងឡាយ លំដាប់ពីនោះមក អាត្មាអញកាន់ប្រទីប ចូលទៅកាន់លំនៅ រមិលមើលដំណេក ហើយអង្គុយលើគ្រែតូច ។ ក្នុងកាលនោះ អាត្មាអញកាន់រនុកទ្វារ ហើយបន្ទឹមចុះនូវប្រឆេះ ( នៃប្រទីប ) ចិត្តក៏បានរួចស្រឡះចាកកិលេស ដូចជាការរលត់នៃប្រទីប ។

ផលបុណ្យរបស់ព្រះនាងបដាចារាភិក្ខុនី ផ្នែកខាងអនុគ្រោះដល់ស្ត្រីដទៃ ដែលនឹងចូលមកបួសជាភិក្ខុនី និងផ្នែកខាងពោលនូវព្រះគាថាដែលជាគោលនៃពាក្យអប់រំដាស់តឿនស្មារតី ដែលមានសម្តែងប្រាកដនៅក្នុង គម្ពីរខុទ្ទកនិកាយ ថេរីគាថា ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៅក្នុង **គម្ពីរបរមត្ថទីបនី** ដូចមានសេចក្តីថា ៖

ព្រះនាងបដាចារាភិក្ខុនី បានជួយអនុគ្រោះស្ត្រី ៣០ នាក់ ឲ្យបាន

បួសជាភិក្ខុនី ដោយការពោលប្រៀនប្រដៅថា បុគ្គលទាំងឡាយ ដែលមានការងារផ្សេងៗ ធូន់ស្រោលជាដើម ដើរស្វែងរកទ្រព្យសម្បត្តិមកចិញ្ចឹមបុត្រ និងភរិយា បុគ្គលទាំងឡាយនោះ រមែងជួបប្រសព្វ នឹងសេចក្តីទុក្ខ សម្រាប់បុថុជ្ជន (ដែលជាអ្នកមានកិលេសក្រាស់) ហើយជាអ្នកមិនបានទទួលផលប្រយោជន៍ អ្វីតិចតួចអំពីកិច្ចការងារនោះឡើយ ព្រោះដូច្នោះ អ្នកទាំងឡាយចូរវៀរចាកនូវវត្ថុ ដែលធ្វើឲ្យយឺតយូរ គឺកិលេសនោះចេញរួចហើយ អ្នកទាំងឡាយចូរធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលរាប់ចូលក្នុងត្រៃសិក្ខា (សីល សមាធិ បញ្ញា) ចូរធ្វើឲ្យជាប្រយោជន៍ដ៏ប្រសើរ ឲ្យកើតឡើងក្នុងចិត្តរបស់ខ្លួន ចំណែកអំពើណាដែលធ្វើទៅហើយ កើតការក្តៅក្រហាយក្នុងកាលជាខាងក្រោយ អ្នកទាំងឡាយកុំធ្វើអំពើនោះអី ត្រូវតែធ្វើអំពើណា ដែលធ្វើទៅហើយនាំសេចក្តីសុខមកឲ្យដល់ខ្លួន ដែលជាអំពើដ៏ប្រសើរបំផុត ចូរអ្នកទាំងឡាយអប់រំសេចក្តីកម្មដ្ឋានទាំង ៤ (ដី ទឹក ភ្លើង ខ្យល់) ដោយការពិចារណាជារឿយៗ ថា មិនទៀងជាទុក្ខ និងជាអនត្តា ប្រព្រឹត្តទៅ

តាមហេតុបច្ច័យ ។

ក្នុងរឿងមួយទៀត ព្រះនាងបជាបាតិភិក្ខុនី បានអនុគ្រោះដល់ព្រះនាងចន្ទា ដែលនាងជាអ្នកមិនមានញាតិសន្ដាន ព្រោះញាតិកើត **អហិវាតករោគ** ស្លាប់អស់ហើយ ។ នាងចន្ទាត្រូវកាន់អំបែងដើរសុំទានគេ ដើម្បីចិញ្ចឹមជីវិតអស់រយៈពេលមក ៧ ឆ្នាំហើយ ថ្ងៃមួយ នាងបានចូលទៅកាន់កន្លែងរបស់ព្រះនាងបជាបាតិភិក្ខុនី ដែលកំពុងតែធាន់ចង្ហាន់បិណ្ឌបាត ភិក្ខុនីទាំងឡាយ កាលដឹងអំពីប្រវត្តិរបស់នាងចន្ទា ក៏កើតមានមេត្ដាចិត្តឡើង ទើបឲ្យចង្ហាន់បិណ្ឌបាតដែលសល់ដល់នាង ។ តមក នាងចន្ទាមានសេចក្ដីជ្រះថ្លា ក្នុងការប្រព្រឹត្តសង្រួមក្នុងសីលទាំងឡាយរបស់ភិក្ខុនីទាំងនោះ នាងទើបចូលទៅរកព្រះនាងបជាបាតិភិក្ខុនីៗ ក៏បានសម្ដែងធម៌ឲ្យស្ដាប់ ហើយនាងក៏កើតសេចក្ដីជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះពុទ្ធសាសនានេះ និងមានសេចក្ដីសង្វេគក្នុងដំណើរជីវិត ហើយបានសូមបព្វជ្ជា កាលនាងបួសមិនយូរប៉ុន្មាន ដោយការតាំងនៅក្នុងឱវាទរបស់ព្រះនាងបជាបាតិភិក្ខុនី ក្នុងកាលជាទីបំផុតក៏បានសម្រេចជា

ព្រះអរហន្តទៅ ។

ចំណែករឿងមួយទៀត ព្រះនាងបដាចារាភិក្ខុនី បានសម្តែងធម៌ឲ្យដល់ស្ត្រី ៥០០ នាក់ ដែលជាអ្នកមានបុត្រស្លាប់ដូចគ្នាទាំង ៥០០ នាក់ថា ពួកនាងមិនដឹងនូវផ្លូវរបស់អ្នកណាដែលមក ឬទៅ ហើយយំរកកូននោះ ដែល ( មិនដឹងថា ) មកអំពីទីណានោះថា ឱ! កូនអញអើយទៅទីណាហើយ បើទោះជានាងដឹងផ្លូវរបស់កូននោះ ដែលមក ឬទៅ ក៏មិនគប្បីសោកស្តាយអាឡោះអាល័យរកកូននោះឡើយ ព្រោះធម្មតាសត្វទាំងឡាយ រមែងមានការកើត និងការស្លាប់ ដូចគ្នាទាំងអស់ ។ កាលគេមកពីលោកដទៃ អ្នកណាៗ ក៏មិនបានអង្វរគេឲ្យមក គេមកហើយ កាលគេទៅពីមនុស្សលោកវិញ អ្នកណាៗ ក៏មិនបានអនុញ្ញាតឲ្យគេទៅឡើយ គេមកអំពីទីណាក៏ពួកយើងមិនដឹង មកអាស្រ័យនៅទីនេះ ២-៣ ថ្ងៃ ហើយទៅវិញក្តី មកអំពីទីនេះ ទៅកាន់ទីដទៃចាកទីនេះ ក៏ទៅកាន់ទីដទៃក្តី គេបែកស្ថានទៅហើយក្តី រមែងទៅតាមយថាកម្ម គេអន្ទោលទៅមកយ៉ាងណា ក៏ទៅយ៉ាងនោះ ការយំរៀបរាប់

ក្នុងការអន្ទោលទៅរបស់គេ តើមានប្រយោជន៍អ្វី ? ស្ត្រីទាំង ៥០០ នាក់នោះ កាលបើស្តាប់ដូច្នេះហើយ ក៏បានបន្ទោបង់នូវសេចក្តីសោក ហើយសូមបព្វជ្ជា នៅក្នុងសម្នាក់របស់ព្រះនាងបដាចារាភិក្ខុនី កាលភិក្ខុនីទាំង ៥០០ បួសបានសម្រេចជាព្រះអរហន្តីហើយ បានពោលព្រះគាថា ដែលព្រះនាងបដាចារាភិក្ខុនី ពោលហើយម្តងទៀត ព្រមទាំងបានពោលបន្ថែមគាថានោះថា

នាងម្ចាស់បានដកព្រួញ គឺសេចក្តីសោក ដែលបុគ្គលឃើញបានដោយកម្រ ។ ដែលចាក់ដោតនៅក្នុងចិត្តរបស់ខ្ញុំ កាលខ្ញុំត្រូវសេចក្តីសោកព្រោះស្រឡាញ់បុត្រគ្របសង្កត់ហើយ ។ នាងម្ចាស់បានជួយបន្ទោបង់នូវសេចក្តីសោក ព្រោះកូនជាទីស្រឡាញ់របស់ខ្ញុំស្លាប់ ថ្ងៃនេះ ខ្ញុំបានដកព្រួញចេញហើយ អស់នូវសេចក្តីទុក្ខក្តៅក្រហាយហើយ ។ ខ្ញុំសូមដល់នូវព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ។ មួយទៀត ពាក្យប្រៀនប្រដៅរបស់ព្រះនាងបដាចារាភិក្ខុនីនេះ រាប់ថាជាពាក្យប្រៀនប្រដៅដ៏ប្រសើរបំផុត គឺដើម្បីមិនឲ្យកើតសេចក្តីសោក

ក្នុងពេលដែលអ្នកមានកូនស្លាប់ទៅ ។

ជីវប្រវត្តិនៅក្នុងអតីតជាតិរបស់ព្រះនាងបដាចារាភិក្ខុនី មានសម្តែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** និងក្នុង **គម្ពីរអដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** និងក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ថា ៖

ក្នុងកប្បទីមួយសែន ដោយរាប់ថយក្រោយពីភទ្ទកប្បនោះទៅ ដែលត្រូវនឹងពុទ្ធសម័យ របស់ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួង ព្រះអង្គឈ្មោះមារ ព្រះអង្គជាលោកនាយក ។ បដាចារាភិក្ខុនី បានកើតក្នុងត្រកូលសេដ្ឋី ដ៏រុងរឿងស្តុកស្តម្ភមានរតនៈផ្សេងៗ ជាច្រើន ក្នុងនគរហង្សវតី នាងមានសេចក្តីសុខយ៉ាងក្រៃលែង ។ ពេលដែលនាងចម្រើនវ័យធំដឹងក្តីហើយ ថ្ងៃមួយ នាងបានចូលទៅថ្វាយបង្គំព្រះបទុមុត្តរសម្ពុទ្ធ ថែមទាំងបានស្តាប់ព្រះធម៌ទេសនា ហើយកើតសេចក្តីជ្រះថ្លាក្នុងគុណព្រះពុទ្ធ និងបន្ទឹវាចាសូមដល់ព្រះអង្គ ជាសរណៈ ។

គ្រានោះ ព្រះបទុមុត្តរៈ ទ្រង់បានប្រកាសតែងតាំងភិក្ខុនីមួយរូប ជាអ្នកមានភាពអៀនខ្មាស ជាអ្នកមានចិត្តនឹងធឹង ជាអ្នកមានភាពជំនាញក្នុងកិច្ចដែលគួរនិងមិនគួរ ឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងទ្រទ្រង់ព្រះវិន័យ នាងបានឃើញដូច្នេះហើយ ក៏កើតការពេញចិត្តក្នុងតំណែងនោះទើបក្រាបទូលអារាធនាព្រះបទុមុត្តរៈ ព្រមដោយភិក្ខុសង្ឃមកទទួលចង្ហាន់អស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ ដែលជាថ្ងៃចុងក្រោយ នាងបានថ្វាយបាត្រ និងចីវរដល់ព្រះបទុមុត្តរៈ ព្រមទាំងភិក្ខុសង្ឃទាំងអស់ស្រេចហើយ នាងក៏បានបង្អោនព្រះសិរសាទៀបព្រះយុគលបាទ ក្រាបទូលតាំងសេចក្ដីប្រាថ្នាថា បពិត្រព្រះមហាមុនី ទ្រង់ជាព្រះលោកនាថ ភិក្ខុនីរូបណា ព្រះអង្គបានប្រកាសតែងតាំងទុកក្នុងតំណែង ឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងទ្រទ្រង់ព្រះវិន័យនោះ សូមឲ្យខ្ញុំម្ចាស់បានសម្រេចដូចភិក្ខុនីរូបនោះដែរ ។ លំដាប់នោះ ព្រះបទុមុត្តរៈត្រាស់ថា នាងដ៏ចម្រើន នាងកុំមានវិតក្កអ្វីឡើយ ចូរជួរចិត្តចុះ នាងនឹងបានតំណែងនោះ សមតាមសេចក្ដីប្រាថ្នា របស់នាងក្នុងអនាគតកាល

ក្នុងកប្បទីមួយសែនអំពីកប្បនេះ នឹងមានព្រះសាស្តាព្រះនាមថា គោតម ទ្រង់សម្ភពក្នុងត្រកូលព្រះបាទឱក្កាកៈ ស្តេចកើតឡើងក្នុងលោក នាងដ៏ចម្រើននឹងបានជាភិក្ខុនីទាយាទ របស់ព្រះគោតមអង្គនោះ នឹងបានជាសាវិការបស់ព្រះលោកនាយក ដោយនាមរបស់នាងថា **បដាចារា** ។ លុះកុលធីតានោះ បានស្តាប់ពុទ្ធព្យាករណ៍ហើយ ក៏កើតសេចក្តីត្រេកអរយ៉ាងក្រៃលែង ថែមទាំងបានខំបំពេញបុណ្យកុសលផ្សេងៗ រហូតដល់អស់ជីវិត ។ ដោយកុសលកម្ម ដែលនាងបានធ្វើទុកហើយ ក្រោយពីស្លាប់អំពីជាតិនោះទៅ នាងក៏បានទៅកើតក្នុងស្ថានតាវត្តិង្សទេវលោក ។

លុះមកដល់ពុទ្ធកាល របស់ព្រះកស្សបសម្ពុទ្ធ នាងកុលធីតានោះ បានមកកើតជាព្រះរាជធីតារបស់ព្រះបាទកាសី ទ្រង់មានព្រះនាមថា កិកិ ទ្រង់ជាព្រះរាជឧបដ្ឋាករបស់ព្រះកស្សបសម្ពុទ្ធ ទ្រង់ជាអ្នកបរិបូណ៌ទៅដោយគុណ ។ កាលដែលនាងបានមកជាធីតា របស់ព្រះបាទកិកិក្នុងជាតិនោះ នាងមាននាមថា ភិក្ខុនី ទ្រង់ជាព្រះរាជធីតាទី ៣ ក្នុងចំណោមព្រះរាជធីតារបស់ព្រះបាទកិកិទាំង ៧ អង្គនោះ គឺ ១- ព្រះនាងសមណី ២- ព្រះនាងសមណគុត្តា ៣- ព្រះនាងភិក្ខុនី ៤-

ព្រះនាងភិក្ខុទាសិកា ៥- ព្រះនាងធម្មា ៦- ព្រះនាងសុធម្មា ៧- ព្រះនាងសង្ឃទាសិកា ។ បណ្ដាព្រះរាជធីតាទាំង ៧ អង្គនោះ ទ្រង់មានបំណងត្រេកអរក្នុងបព្វជ្ជាទាំងអស់អង្គ តែព្រះរាជបិតាទ្រង់មិនព្រមអនុញ្ញាត ។ ព្រះនាងទាំង ៧ អង្គនោះ ក៏ព្រមព្រៀងគ្នាតាំងព្រះទ័យប្រព្រឹត្តព្រហ្មចរិយៈ ដោយទ្រង់សមាទានសីល ១០ នៅរហូត ២០ ពាន់ឆ្នាំ ថែមទាំងបានកសាងវត្តថ្វាយភិក្ខុសង្ឃទៀតផង ។ លុះកាលភិក្ខុនីរាជធីតា ( បដាចារា ស្ដេចទិវង្គតចាកជាតិនោះទៅហើយ បានទៅកើតក្នុងស្ថានតាវត្តិង្ស ទទួលសេចក្ដីសុខក្នុងទិព្វសម្បត្តិរហូតមួយពុទ្ធន្តរ ( រយៈវេលាដែលទំនេរចាកព្រះពុទ្ធ គឺរយៈវេលាក្រោយពីព្រះពុទ្ធមួយព្រះអង្គបរិនិព្វានទៅហើយ នៅមួយព្រះអង្គទៀតមិនទាន់កើតឡើង ) ហើយទើបត្រឡប់មកចុះចាប់បដិសន្ធិ ក្នុងត្រកូលសេដ្ឋីនៅក្នុងក្រុងសាវត្ថី ក្នុងពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូនៃយើងនេះ នាងបានមកជានាងបដាចារា ដូចមានរឿងរ៉ាវ ដែលពោលក្នុងបច្ចុប្បន្នជាតិរបស់នាងរួចមកហើយ ។

ប៉ុន្តែនៅមានរឿងក្នុងបច្ចុប្បន្នជាតិនេះ ដោយនាងបានពោលពីជីវប្រវត្តិរបស់ខ្លួនឯងទុក ដែលមានសម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ**

អបទាន ដូចមានសេចក្តីថា ៖

ខ្ញុំបានស្តាប់ព្រះពុទ្ធវចនៈហើយ បានសម្រេចបឋមផល ( ព្រះសោតាបត្តិផល ) ក្រោយពីបួសហើយមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ( ផល គឺភាពជាអ្នកឆ្ងាយសត្រូវ គឺកិលេស ) ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងសោតធាតុជាទិព្វផង ខ្ញុំជាអ្នកធ្វើតាមសាសនានៃព្រះមុនីផង រមែងដឹងនូវចិត្តនៃបុគ្គលដទៃផង ។ ខ្ញុំដឹងនូវបុព្វេនិវាសទាំងទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធ ឥតមានមន្ទិល ព្រោះបានញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ។ លំដាប់នោះ ខ្ញុំបានរៀនវិន័យទាំងអស់ក្នុងសម្នាក់របស់ព្រះពុទ្ធ ព្រះអង្គឃើញហេតុទាំងអស់ផង ខ្ញុំឆ្លើយដោះស្រាយ នូវសេចក្តីពិស្តារគ្រប់យ៉ាងតាមពិតផង ។ ព្រះភគវាព្រះអង្គទ្រង់ត្រេកអរចំពោះគុណនោះហើយ ទើបតាំងខ្ញុំទុកក្នុងតំណែងជាឯតទគ្គៈថា បជាចារភិក្ខុនីឯក ប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងទ្រទ្រង់ព្រះវិន័យ ។l៚

( ជីវប្រវត្តិរបស់ព្រះនាងបជាចារភិក្ខុនី ចប់ )

# រឿងព្រះបាទវិឌូឌភៈ

សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធព្រះបាទវិឌូឌភៈ ព្រមទាំងបរិស័ទ ដែលត្រូវទឹកជំនន់កួចពន្លិចឲ្យសោយទិវង្គត ត្រាស់ព្រះធម្មទេសនានេះថា **បុប្ផានិ ហេវ បចិនន្តំ** ជាដើម ។

អនុបុព្វីកថាក្នុងរឿងនោះ មានដូចតទៅ

ព្រះកុមារ ៣ អង្គនោះ គឺព្រះរាជឱរសរបស់ព្រះបាទកោសលក្នុងនគរសាវត្ថី ព្រះនាមថា **បសេនទិកុមារ** ព្រះកុមាររបស់ស្ដេចលិច្ឆវី ក្នុងនគរវេសាលី ព្រះនាមថា **មហាលិ** ឱរសរបស់មល្លក្សត្រក្នុងក្រុងកុសិនារា ព្រះនាមថា **ពន្ធុលៈ** ស្ដេចទៅកាន់នគរតក្កសិលា ដើម្បីសិក្សាសិល្បៈក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ព្រះកុមារទាំង ៣ អង្គនោះ បានមកជួបគ្នាត្រង់សាលាក្រៅនគរ មួយអង្គៗ ក៏សួរអំពីហេតុដែលមក សួរអំពីត្រកូល និងព្រះនាមនៃគ្នានឹងគ្នា ហើយរាប់អានគ្នាជាសម្លាញ់ រួមគ្នាចូលទៅរកអាចារ្យ មិនយូរប៉ុន្មាន សិក្សាសិល្បៈចប់សព្វគ្រប់ ទើបលាអាចារ្យព្រមគ្នា ស្ដេចចេញពីក្រុងតក្កសិលា

ទៅកាន់នគររៀងៗ ខ្លួន ។

បណ្ដាព្រះរាជកុមារទាំង ៣ ព្រះអង្គនោះ បសេនទិកុមារ ទ្រង់សម្ដែងសិល្បៈថ្វាយព្រះរាជបិតា ធ្វើឲ្យព្រះរាជបិតាជ្រះថ្លា អភិសេកក្នុងរាជសម្បត្តិ ។

មហាលិកុមារ កាលនឹងទ្រង់សម្ដែងសិល្បៈថ្វាយស្ដេចលិច្ឆវីទាំងឡាយ ក៏ទ្រង់សម្ដែងដោយសេចក្ដីព្យាយាមយ៉ាងខ្លាំង ។ធ្វើឲ្យព្រះនេត្រទាំងពីររបស់ព្រះអង្គបែក ពួកស្ដេចលិច្ឆវីប្រឹក្សាគ្នាថា ពុទ្ធោអើយ អាចារ្យរបស់ពួកយើងវិនាសភ្នែកទៅហើយ ពួកយើងនឹងមិនលះបង់លោក នឹងទំនុកបម្រុងលោក ដូច្នេះហើយ ទើបថ្វាយស្រុកមួយហូតពន្ធបានមួយថ្ងៃ ១ សែន ថ្វាយមហាលិកុមារ ព្រះអង្គត្រូវអាស្រ័យស្រុកនោះ ឲ្យឱរសនៃស្ដេចលិច្ឆវី ៥០០ អង្គសិក្សាសិល្បៈ ។

ចំណែកពន្ធុលកុមារ កាលពួកមល្លរាជពោលថា ម្នាលពន្ធុលកុមារ ចូរកាប់ឫស្សីទាំងនេះ ដូច្នេះហើយ បានលោតទៅលើអាកាសកម្ពស់ ៨០ ហត្ថ ដកដាវកាប់បាច់ឫស្សី ៦០ ដើម ដែលពួកមល្លក្សត្រស៊កដែកពីខាងក្នុងឲ្យជាប់ខ្ទេចអស់ ពន្ធុលកុមារបានឮសំឡេងលាន់

ក្រឹកនៃដែកក្នុងបាច់ចុងក្រោយ ទើបសួរថា នេះជាសំឡេងអ្វី ? ទ្រង់ព្រះសណ្ដាប់ថា ជាសំឡេងដែក ដែលស៊កខាងក្នុងឫស្សីគ្រប់បាច់ ក៏បោះដាវចោល យំបណ្ដើរ និយាយបណ្ដើរថា បណ្ដាញាតិ និងមិត្ររបស់យើងប្រមាណប៉ុណ្ណេះ សូម្បីតែម្នាក់ដែលជាអ្នកមានសេចក្ដីស្រឡាញ់ ( ក្នុងយើង ) មិនបានប្រាប់ហេតុនេះ ( ដល់យើង ) ប្រសិនបើយើងបានដឹងជាមុននោះ យើងនឹងកាប់មិនឲ្យឮសំឡេងដែកលាន់ឮឡើងឡើយ ហើយក្រាបទូលព្រះរាជមាតា និងរាជបិតាថា បពិត្រព្រះមាតាបិតា ទូលបង្គំនឹងសម្លាប់មល្លក្សត្រទាំងនេះឲ្យអស់ហើយ ឡើងសោយរាជសម្បត្តិ ព្រះមាតា និងបិតា ហាមដោយប្រការផ្សេងៗ ជាដើមថា ម្នាលកូនសម្លាញ់ នេះជារាជប្រពៃណីទេ កូនឯងមិនអាចធ្វើយ៉ាងនោះបានទេ ទើបទូលថា បើដូច្នោះ ខ្ញុំម្ចាស់នឹងទៅកាន់សម្នាក់មិត្ររបស់ខ្ញុំម្ចាស់ដូច្នោះហើយ ស្ដេចក៏បានទៅកាន់ក្រុងសាវត្ថី ។

ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបការយាងមកដល់របស់ពន្ធុលៈ ទ្រង់ក៏ស្វាគមន៍អញ្ជើញឲ្យស្ដេចចូលកាន់ព្រះនគរ ដោយ

សក្ការៈដ៏ធំ ហើយទ្រង់តែងតាំងឲ្យធ្វើជាសេនាបតី ។ ពន្ធុលសេនាបតី នោះ បានអញ្ជើញព្រះមាតាបិតា មកស្នាក់អាស្រ័យនៅក្នុងក្រុង សាវត្ថីដែរ ។

ក្រោយមក ថ្ងៃមួយ ព្រះរាជាទ្រង់ឈរនៅលើប្រាសាទជាន់ លើទតទៅកាន់ថ្នល់ ឃើញភិក្ខុច្រើនពាន់រូបដែលត្រាច់ទៅ ដើម្បី កត្តកិច្ចក្នុងគេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី នាងវិសាខា នាងសុប្បវាសាក៏ត្រាស់សួរថា លោកម្ចាស់ទាំងឡាយ នោះនិមន្តទៅណា ? ពួករាជបុរសទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុពីរពាន់អង្គ ទៅដើម្បីប្រយោជន៍ដល់កត្តទាំងឡាយមាននិច្ចកត្ត សលាកកត្ត និងគិលានកត្តជាដើម ក្នុងគេហដ្ឋានរបស់អនាថបិណ្ឌិក សេដ្ឋីរាល់ៗ ថ្ងៃ ។ ភិក្ខុ ៥០០ អង្គ ទៅកាន់គេហដ្ឋានរបស់ចូឡអនាថ-បិណ្ឌិកសេដ្ឋីជានិច្ច ។ ផ្ទះរបស់នាងវិសាខា ( និង ) នាងសុប្បវាសា ក៏ដូចគ្នា ដូច្នេះហើយ ទ្រង់បំណងនឹងផ្គត់ផ្គង់ភិក្ខុសង្ឃ ដោយព្រះអង្គ ឯងដែរ ទើបស្ដេចទៅកាន់វិហារ ទ្រង់និមន្តព្រះសាស្ដា ព្រមទាំងភិក្ខុ ១០០០ អង្គ ថ្វាយដោយផ្ទាល់ព្រះហស្តព្រះអង្គឯងអស់ ៧ ថ្ងៃ ក្នុង

ថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ព្រះមេត្តាទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ព្រមទាំងភិក្ខុសង្ឃចំនួន ៥០០ រូបអស់កាលជានិច្ចចុះ ។

ព្រះសាស្តា. មហាបពិត្រ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនទទួលភិក្ខាជានិច្ចក្នុងកន្លែងតែមួយទេ ព្រោះជនជាច្រើនរមែងសង្ឃឹមចំពោះការយាងមករបស់ព្រះពុទ្ធទាំងឡាយ ។

ព្រះរាជា. បើដូច្នេះ សូមព្រះអង្គមេត្តាបញ្ជូនភិក្ខុមួយរូប ទៅជាប្រចាំចុះ ។ ព្រះសាស្តា ទ្រង់ឲ្យជាភារៈព្រះអានន្ទ ។

ព្រះរាជាទ្រង់ភ្លេចចាត់ចែងចង្ហាន់ប្រគេនភិក្ខុសង្ឃអស់ ៣ថ្ងៃ ព្រះរាជាទ្រង់មិនបានចាត់ ( មនុស្ស ) ទុកថា កាលភិក្ខុសង្ឃមកដល់ហើយ ជនទាំងនេះទទួលបាត្រហើយចូរអង្គាស ព្រះរាជាទ្រង់អង្គាសដោយព្រះអង្គឯង ចំនួន ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៨ ទ្រង់ក៏ភ្លេចបញ្ជាឲ្យគេចាត់ចែងភត្តប្រគេនភិក្ខុសង្ឃ ។

ក៏ធម្មតាក្នុងរាជត្រកូល ជនទាំងឡាយដែលព្រះរាជាទ្រង់មិន

បានបញ្ញាហើយ រមែងមិនក្រាលអាសនៈទាំងឡាយ មិននិមន្តពួកភិក្ខុសង្ឃឲ្យគង់ ហើយអង្គាសឡើយ ។ ពួកភិក្ខុក៏គិតគ្នាថា យើងមិននៅក្នុងទីនេះទេ លុះគិតដូច្នេះហើយ ក៏នាំគ្នាចៀសចេញទៅអស់ជាច្រើនរូប ។ សូម្បីក្នុងថ្ងៃទី ២ ព្រះរាជាក៏ទ្រង់ភ្លេចទៀត ភិក្ខុទាំងឡាយនាំគ្នាចៀសចេញទៅទៀត ។ សូម្បីក្នុងថ្ងៃទី ៣ ព្រះរាជាក៏ទ្រង់ភ្លេចទៀត វៀរតែព្រះអានន្ទមួយអង្គប៉ុណ្ណោះ ភិក្ខុដ៏សេសនាំគ្នាចៀសចេញទៅអស់ ។

ធម្មតាអ្នកមានបុណ្យទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ទើបរក្សាសេចក្តីជ្រះថ្លានៃត្រកូលទុកបាន ។ ក៏សាវ័ករបស់ព្រះសាស្តា ដែលមានឋានន្តរសក្តិទាំង ៨ រូប គឺអគ្គសាវ័ក ២ រូប ព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ អគ្គសាវិកា ២ រូប គឺនាងខេមា នាងឧប្បលវណ្ណា បណ្តាឧបាសកទាំងឡាយ ឧបាសកដែលជាអគ្គសាវ័ក ២ នាក់ គឺចិត្តគហបតី ហត្ថកឧបាសកអ្នកក្រុងអាឡវី បណ្តាឧបាសិកាទាំងឡាយ ឧបាសិកាដែលជាអគ្គសាវិកា ២ នាក់ គឺមាតារបស់នន្ទមាណពឈ្មោះ វេឡុកណ្តកី នាងខុជ្ជុត្តរា ( សុទ្ធ ) តែមានបុណ្យច្រើន

សម្បូណ៌ទៅដោយអភិនីហារ ព្រោះជាអ្នកបំពេញបារមី ១០ ដោយឯកទេស ។

សូម្បីព្រះអានន្ទត្ថេរ ក៏មានបារមីដែលបំពេញហើយអស់សែនកប្បសម្បូណ៌ដោយអភិនីហារ មានបុណ្យច្រើន កាលនឹងរក្សាសេចក្ដីជ្រះថ្លារបស់ត្រកូល ទើបបាននៅ ព្រោះការដែលខ្លួនប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ពួករាជបុរសនិមន្តព្រះអានន្ទតែមួយអង្គប៉ុណ្ណោះឲ្យគង់ ហើយអង្គាស ។

ព្រះរាជាយាងមកក្នុងពេលដែលភិក្ខុនិមន្តទៅអស់ ទតឃើញខាទនីយ និងភោជនាហារនៅដដែល ក៏ត្រាស់សួរថា លោកម្ចាស់ទាំងឡាយមិនបាននិមន្តមកទេឬ ? ទ្រង់បានស្ដាប់ថា បពិត្រមហារាជព្រះអានន្ទមួយរូបប៉ុណ្ណោះដែលមក ក៏ទ្រង់ក្រោធនឹងភិក្ខុទាំងឡាយថាលោកម្ចាស់ទាំងឡាយ បានកាត់ផ្ដាច់ទំនាក់ទំនងចំពោះយើងត្រឹមនេះដោយពិតប្រាកដ ទើបស្ដេចទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលថាបពិត្រព្រះអង្គចម្រើន ខ្ញុំព្រះអង្គចាត់ចែងភិក្ខាទុកដើម្បីភិក្ខុ ៥០០ រូបព្រះអានន្ទតែមួយអង្គប៉ុណ្ណោះ ដែលនិមន្តមក ភិក្ខាដែលខ្ញុំព្រះអង្គ

ចាត់ចែងហើយនោះនៅដដែល ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ ៥០០ រូប មិនធ្វើសេចក្តីស្និទ្ធស្នាល ក្នុងព្រះរាជវាំងរបស់ខ្ញុំព្រះអង្គ ( សោះ ) តើព្រោះហេតុអ្វីហ្ន៎ ?

ព្រះសាស្តា មិនត្រាស់ទោសរបស់ភិក្ខុទាំងឡាយ តែត្រាស់ថា បពិត្រមហារាជ សាវកទាំងឡាយរបស់តថាគត មិនមានសេចក្តីស្និទ្ធស្នាលនឹងព្រះអង្គ ទើបមិននិមន្តទៅកាន់ព្រះរាជវាំង របស់មហាបពិត្រ កាលនឹងប្រកាសហេតុនៃការមិនចូលទៅ និងហេតុនៃការចូលទៅកាន់ត្រកូលទាំងឡាយ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ព្រះសូត្រនេះថា

ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ ភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ លុះចូលទៅហើយ ក៏មិនគួរអង្គុយជិតត្រកូលដោយអង្គ ៩ នោះ តើត្រកូលប្រកបដោយអង្គ ៩ នោះ ដូចម្តេចខ្លះ ? ត្រកូលប្រកបដោយអង្គ ៩ គឺគេមិនទទួលដោយសេចក្តីពេញចិត្ត ១ មិនអភិវាទដោយសេចក្តីពេញចិត្ត ១ មិនឲ្យអាសនៈ ដោយសេចក្តីពេញចិត្ត ១ លាក់របស់ដែលមាន ១ កាលរបស់មានច្រើនក៏ឲ្យតិច ១

កាលមានរបស់ប្រណីត ក៏ឲ្យរបស់សៅហ្មង ១ ឲ្យដោយមិនគោរព មិនឲ្យដោយសេចក្ដីគោរព ១ មិនអង្គុយជិតដើម្បីស្ដាប់ធម៌ ១ កាលសម្ដែងធម៌គេមិនត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ នេះឯង ភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ លុះចូលទៅហើយ ក៏មិនគួរអង្គុយជិត ។

ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ ភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅ កាលចូលទៅហើយ ក៏គួរអង្គុយជិត ។

ត្រកូលដែលប្រកបដោយអង្គ ៩ តើដូចម្ដេច ? ត្រកូលដែលប្រកបដោយអង្គ ៩ គឺគេក្រោកទទួលដោយសេចក្ដីគោរព ១ អភិវាទដោយសេចក្ដីគោរព ១ ឲ្យអាសនៈដោយសេចក្ដីពេញចិត្ត ១ មិនលាក់របស់ដែលមាននៅ ១ កាលរបស់មានច្រើនក៏ឲ្យច្រើន ១ កាលមានរបស់ប្រណីតក៏ឲ្យរបស់ប្រណីត ១ ឲ្យដោយសេចក្ដីគោរព មិនឲ្យដោយមិនគោរព ១ ចូលទៅអង្គុយជិតដើម្បីស្ដាប់ធម៌ ១ កាលសម្ដែងធម៌គេត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ នេះឯង ភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅ កាលចូលទៅហើយ ក៏គួរ

អង្គុយជិត ដូច្នេះហើយ ទើបត្រាស់ថា មហាបពិត្រ សាវករបស់តថាគត កាលមិនបានសេចក្តីស្និទ្ធស្នាលអំពីសម្នាក់របស់ព្រះអង្គ ទើបមិននិមន្ត ទៅដោយប្រការដូច្នេះឯង ។ ពិតណាស់ បុរាណបណ្ឌិតទាំងឡាយ សូម្បីគេទំនុកបម្រុងដោយសេចក្តីគោរពក្នុងទីដែលមិនធ្លាប់ស្និទ្ធស្នាល សូម្បីមានវេទនាជិតនឹងស្លាប់ ក៏បានទៅកាន់ទីលំនៅនៃអ្នកដែលស្និទ្ធស្នាលដែរ ព្រះរាជាក៏ទូលសួរថា ក្នុងកាលណាព្រះអង្គ ? ទើបទ្រង់នាំយកអតីតនិទាន ( មកសាធក ) ដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះរាជាទ្រង់ព្រះនាមថា **កេសវៈ** ទ្រង់លះបង់រាជសម្បត្តិ បួសជាឥសី ។ បុរស ៥០០ នាក់ ចេញបួសតាមព្រះរាជាអង្គនោះដែរ ។ ព្រះអង្គមាននាមថា **កេសវតាបស** ម្យ៉ាងទៀត នាយកូសាមាលារបស់ព្រះអង្គ ក៏បួសតាមជាអន្តេវាសិកនាមថា **កប្បកៈ** កេសវតាបស និងបរិស័ទអាស្រ័យនៅក្នុងហិមវន្តប្រទេសអស់ ៨ ខែ ក្នុងរដូវភ្លៀង ត្រូវការសេពរសប្រៃ និងរសជូរ ទើបទៅកាន់ក្រុងពារាណសី ហើយចូលទៅកាន់នគរដើម្បីភិក្ខា គ្រានោះ ព្រះរាជាទតឃើញតាបសទាំងនោះ ក៏ទ្រង់

កើតសេចក្ដីជ្រះថ្លា ទ្រង់ប្ដេជ្ញាដើម្បីប្រយោជន៍ដល់ការនៅក្នុងសម្នាក់របស់ព្រះអង្គ រហូតដល់ ៤ ខែ ក៏និមន្តតាបសឲ្យគង់នៅក្នុងព្រះរាជ-ឧទ្យាន ព្រះរាជាតែងតែយាងទៅកាន់ទីទំនុកបម្រុងតាបសនោះ ទាំងព្រឹកទាំងល្ងាច ។ ចំណែកពួកតាបសជទែសម្រាកនៅ ២-៣ ខែ រំខានដោយសំឡេងផ្សេងៗ មានសំឡេងដីរីជាដើម ក៏ពោលថា បពិត្រលោកអាចារ្យ ពួកខ្ញុំត្រូវសេចក្ដីរំខានបៀតបៀន ដូច្នេះ ពួកខ្ញុំនឹងទៅវិញហើយ ។

កេសវៈ. ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយនឹងទៅកាន់ទីណា ?

អន្តេវា. បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងទៅកាន់ហិមវន្តប្រទេសវិញ ។

កេសវៈ. ក្នុងថ្ងៃដែលពួកយើងមកដល់ដំបូង ព្រះរាជាទ្រង់បានទទួលការប្ដេជ្ញាដើម្បីប្រយោជន៍ដល់ការនៅក្នុងទីនេះរហូត ៤ ខែ មិនមែនឬ ? ពួកអ្នកនឹងទៅយ៉ាងដូចម្ដេចកើត ?

អន្តេវាសិកពោលថា លោកអាចារ្យមិនប្រាប់ពួកខ្ញុំជាមុនសិនហើយចាំថ្វាយប្ដេជ្ញា ពួកខ្ញុំមិនអាចនឹងនៅទីនេះបានទេ នឹងនៅក្នុងទី

កន្លែងដែល ( ល្មម ) នឹងដឹងសុខទុក្ខរបស់លោកអាចារ្យបាន ដែលនៅមិនឆ្ងាយអំពីទីនេះ ។ ហើយនាំគ្នាថ្វាយបង្គំអាចារ្យចៀសចេញទៅ ។ ចំណែកអាចារ្យគង់នៅជាមួយនឹងអន្តេវាសិកឈ្មោះកប្បកៈ (ប៉ុណ្ណោះ) ។

ព្រះរាជា ស្តេចយាងមកកាន់ទីទំនុកបម្រុង បានត្រាស់សួរថា លោកម្ចាស់ទាំងឡាយទៅណាអស់ ? គេសវតាបសទូលថា បពិត្រមហារាជ តាបសទាំងនោះប្រាប់ថា ពួកខ្ញុំម្ចាស់ធុញ ដូច្នេះហើយក៏ទៅកាន់ហិមវន្តប្រទេសវិញ ។

ក្រោយមកមិនយូរប៉ុន្មាន សូម្បីកប្បកតាបសក៏ធុញទៀត សូម្បីលោកអាចារ្យឃាត់យ៉ាងណាក៏ដោយ ក៏នៅតែពោលថា មិនអាច ហើយក៏ចៀសចេញទៅ ។

ប៉ុន្តែកប្បកតាបសនោះមិនទៅកាន់សម្នាក់ពួកតាបសដែលចៀសចេញទៅមុននោះទេ រង់ចាំស្តាប់ដំណឹងរបស់អាចារ្យ នៅក្នុងទីមិនឆ្ងាយអំពីអាចារ្យប៉ុន្មានទេ ។

ក្រោយមក កាលអាចារ្យគិតដល់ពួកអន្តេវាសិក រោគក្នុងពោះក៏កើតឡើង ព្រះរាជាបញ្ជាពេទ្យឲ្យមកព្យាបាលរោគ ក៏មិនស្ងប់ ទើប

តាបសទូលថា បពិត្រមហារាជ ព្រះអង្គមានព្រះបំណងឲ្យរោគរបស់អាត្មាស្ងប់ឬ ?

ព្រះរាជា. បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើខ្ញុំព្រះករុណាអាច ក៏នឹងធ្វើសេចក្ដីសប្បាយឲ្យដល់លោកម្ចាស់ឥឡូវនេះឯង ។

តាបស. បពិត្រមហារាជ ប្រសិនបើព្រះអង្គប្រាថ្នាសេចក្ដីសុខដល់អាត្មា មេត្តាបញ្ជូនអាត្មាទៅកាន់សម្នាក់ពួកអន្តេវាសិកចុះ ។

ព្រះរាជាទ្រង់ទទួលថា ប្រពៃហើយលោកម្ចាស់ ហើយឲ្យតាបសនោះដេកលើគ្រែតូចមួយ ទ្រង់បញ្ជូនអាមាត្យទៅ ៤ នាក់ មាននារទអមាត្យជាប្រធាន ដោយបញ្ជាក់ថា ពួកលោកដឹងដំណឹងរបស់លោកម្ចាស់របស់ពួកយើងហើយ គប្បីបញ្ជូនដំណឹងមកឲ្យយើងផង ។

កប្បកអន្តេវាសិកដឹងថា អាចារ្យមក ក៏ធ្វើការក្រោកទទួល កាលអាចារ្យសួរថា ពួកតាបសក្រៅនេះទៅនៅទីណា ? ក៏ប្រាប់ថា នៅទីឯណោះ ។

អន្តេវាសិកទាំងនោះដឹងថា អាចារ្យរបស់ខ្លួនមក ( ក៏មក ) ប្រជុំគ្នាក្នុងទីនោះ ថ្វាយទឹកក្ដៅ និងផលាផលដល់អាចារ្យ រោគក៏ស្ងប់

ក្នុងខណៈនោះឯង ។ ព្រះតាបសនោះមានវណ្ណៈដូចមាសក្នុងកំឡុងពេល ២-៣ ថ្ងៃប៉ុណ្ណោះ ។ គ្រានោះ នារទអមាត្យសួរថា

បពិត្រកេសវៈដ៏មានជោគ ( អាចារ្យរបស់យើងខ្ញុំ ) នេះ លះបង់ព្រះបាទពារាណសី ដែលជាធំជាងមនុស្ស ជាអ្នកឲ្យនូវសេចក្ដីប្រាថ្នាទាំងពួង ហើយបានត្រេកអរក្នុងអាស្រមរបស់កូនសិស្សឈ្មោះកប្បកៈតើដោយឧបាយដូចម្ដេចហ្ន៎ ។

តាបសឆ្លើយថា ម្នាលអមាត្យ រសទាំងឡាយដ៏ឆ្ងាញ់ គួររីករាយក៏មាន ដើមឈើទាំងឡាយ ជាទីរីករាយក៏មាន ពាក្យជាសុភាសិតទាំងឡាយរបស់កប្បកៈតែងធ្វើឲ្យអាត្មាត្រេកអរបាន ។

នារទៈសួរថា លោកម្ចាស់ធាន់ចង្ហាន់អង្ករនៃស្រូវសាលី ដែលផ្សំដោយរសសាច់ដ៏ឆ្ងាញ់ ហេតុដូចម្ដេច បានជាស្រងែ និងស្មៅគែលលកដែលមិនមានរសប្រៃសោះ ធ្វើឲ្យលោកម្ចាស់ត្រេកអរបាន ?

តាបសឆ្លើយថា បុគ្គលមានសេចក្ដីស្និទ្ធស្នាលបរិភោគភោជនណាទោះបីឆ្ងាញ់ក្ដី មិនឆ្ងាញ់ក្ដី តិចក្ដី ច្រើនក្ដី ក្នុងកន្លែងណាមួយ ភោជននោះ ( ដែលបុគ្គលបរិភោគហើយ ក្នុងកន្លែងនោះ ជាភោជនប្រសើរ )

ព្រោះសេចក្តីស្និទ្ធស្នាលជារសយ៉ាងក្រៃលែង ។

ព្រះសាស្តា លុះទ្រង់នាំធម្មទេសនានេះមកហើយ ទ្រង់ប្រមូលជាតក ហើយត្រាស់ថា ព្រះរាជាក្នុងគ្រានោះ បានមកជាមោគ្គល្លាន នារទអមាត្យ បានមកជាសារីបុត្រ អន្តេវាសិកឈ្មោះកប្បកៈ បានមកជាអានន្ទ កេសវ តាបស គឺយើងតថាគតនេះឯង ដូច្នេះហើយ ត្រាស់ថា យ៉ាងនោះហើយ មហាបពិត្រ បណ្ឌិតក្នុងកាលមុន សូម្បីមាននូវវេទនាជិតនឹងស្លាប់ក៏ដោយ ក៏នៅតែទៅកាន់សម្នាក់អ្នកដែលស្និទ្ធស្នាលនឹងខ្លួនដែរ សាវកទាំងឡាយ របស់តថាគត ប្រហែលជាមិនបានទទួលនូវសេចក្តីស្និទ្ធស្នាលអំពី សម្នាក់របស់ព្រះអង្គហើយ មើលទៅ ។

ព្រះរាជាទ្រង់តម្រិះថា យើងគួរធ្វើសេចក្តីស្និទ្ធស្នាលជាមួយភិក្ខុ សង្ឃ តើយើងនឹងធ្វើយ៉ាងណាហ្ន៎ ? ដូច្នេះហើយ ទ្រង់ត្រិះរិះទៀតថា គួរធ្វើព្រះរាជធីតានៃព្រះញាតិ របស់ព្រះសម្ពុទ្ធជាម្ចាស់ព្រះរាជដំណាក់ កាលបើដូច្នោះហើយ ពួកភិក្ខុកំលោះ និងសាមណេរក៏នឹងអាចស្និទ្ធស្នាល ហើយមកកាន់សម្នាក់របស់យើងជានិច្ច ដោយគិតថា ព្រះរាជាជាព្រះ ញាតិរបស់ព្រះសម្មាសម្ពុទ្ធ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏បញ្ជូន

ព្រះរាជសារទៅកាន់សម្នាក់សក្យរាជទាំងឡាយថា សូមសក្យៈទាំងឡាយ ប្រទានព្រះរាជធីតាម្នាក់ដល់ទូលបង្គំជាខ្ញុំ ហើយផ្តាំទូតទាំងឡាយថា ពួកអ្នកគប្បីសួរថា ជាព្រះរាជធីតានៃសក្យៈអង្គណា ? ហើយ ( សឹម ) មក ។

ពួកទូតទៅហើយ ទូលសូមព្រះនាងម្ចាស់ ( មួយអង្គ ) អំពីសក្យៈទាំងឡាយ សក្យៈទាំងនោះប្រជុំគ្នាហើយ ទ្រង់ព្រះតម្រិះថា ព្រះរាជាជាបក្ខពួកជទៃ បើពួកយើងមិនឲ្យទេនោះ ព្រះរាជានឹងធ្វើឲ្យយើងវិនាសក៏ ( កាលពោល ) ដោយត្រកូល ព្រះរាជាអង្គនោះ មិនស្មើនឹងយើងឡើយ ពួកយើងគួរធ្វើយ៉ាងណាទើបល្អ ? មហានាមត្រាស់ថា ធីតារបស់ខ្ញុំម្ចាស់ឈ្មោះវាសភខត្តិយា កើតក្នុងផ្ទៃនៃនាងទាសី ជាអ្នកមានរូបរាងស្រស់ស្អាត ពួកយើងនឹងឲ្យនាងនោះ លុះទ្រង់ប្រឹក្សាគ្នាដូច្នេះហើយ ក៏ប្រាប់ពួកទូតថា ប្រពៃណាស់ ពួកយើងនឹងថ្វាយធីតាដល់ព្រះរាជា ទូតសួរថា ជាធីតារបស់សក្យៈអង្គណា ?

សក្យៈឆ្លើយថា ជារាជធីតារបស់មហានាមសក្យរាជ ដែលជាព្រះឱរសរបស់ម្ចាស់ពូនៃព្រះសម្មាសម្ពុទ្ធ ឈ្មោះវាសភខត្តិយា ។ ទូតទាំង

នោះទៅក្រាបទូលព្រះរាជារបស់ខ្លួន ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរប្រញាប់នាំមកចុះ ក៏ធម្មតាពួកក្សត្រ មានកលល្បិចច្រើន ( នឹង ) គប្បីបញ្ជូនកូននាងទាសីមក ( ក៏អាចប្រព្រឹត្តទៅបាន ) ពួកលោកចូរនាំធីតាដែលជាអ្នកសោយភោជន ក្នុងភាជនៈមួយជាមួយនឹងព្រះបិតាមក លុះទ្រង់មានព្រះតម្រាស់ដូច្នេះហើយ ទ្រង់បញ្ជូនទូតទាំងនោះទៅ ។

ពួកទូតទៅដល់សក្យនគរក្រាបទូលថា បពិត្រមហារាជ ព្រះរាជាទ្រង់ប្រាថ្នាព្រះរាជធីតា ដែលជាអ្នកសោយក្រយាហាររួមនឹងព្រះអង្គ មហានាមទទួលបញ្ជាក់ថា បាន ទើបឲ្យតាក់តែងនាង ក្នុងវេលាសោយរបស់ព្រះអង្គ បញ្ជាឲ្យហៅនាងមកសម្តែងអាការដូចជារួមសោយជាមួយនឹងនាង ហើយប្រគល់ឲ្យដល់ទូតទាំងឡាយ ។ ពួកទូតនាំនាងទៅកាន់ក្រុងសាវត្ថី ហើយក្រាបទូលរឿងនោះថ្វាយព្រះរាជា ។

ព្រះរាជាទ្រង់ពេញព្រះទ័យ តែងតាំងនាងជាស្រ្តីធំជាងស្រីចំនួន ៥០០ នាក់ អភិសេកជាអគ្គមហេសី ។ ក្រោយមក មិនយូរប៉ុន្មាន នាងក៏ប្រសូតព្រះឱរស មានពណ៌ដូចមាស ។ ក្នុងថ្ងៃថ្វាយព្រះនាមឱរសនោះ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ ទៅកាន់សម្នាក់ព្រះអយ្យកាថា

ព្រះនាងវាសភខត្តិយា ព្រះធីតានៃសក្យរាជប្រសូតព្រះឱរសហើយ ទ្រង់នឹងថ្វាយព្រះនាមព្រះកុមារនោះដូចម្តេច ?

ចំណែកអមាត្យ ដែលទទួលព្រះរាជសាសន៍នោះ ជាមនុស្សត្រចៀកធ្ងន់ ទៅដល់សក្យនគរហើយ ក៏ក្រាបទូលព្រះអយ្យការបស់ព្រះរាជា ។

ព្រះអយ្យកានោះ ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយត្រាស់ថា ព្រះនាងវាសភខត្តិយា សូម្បីមិនប្រសូតព្រះឱរស ក៏បានគ្រប់គ្រងជនទាំងអស់ ក៏ឥឡូវនេះ នាងនឹងជាទីប្រោសប្រាណយ៉ាងក្រៃលែងរបស់ព្រះរាជា ។

អមាត្យត្រចៀកធ្ងន់ស្តាប់ពាក្យថា **វល្លភា** មិនច្បាស់ យល់ថា **វិឌូឌភៈ** លុះចូលគាល់ព្រះរាជាហើយ ក៏ក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គថ្វាយព្រះនាមព្រះរាជកុមារថា វិឌូឌភៈ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ពាក្យថា វិឌូឌភៈ ជាឈ្មោះប្រចាំត្រកូលចាស់របស់យើង ទើបទ្រង់ថ្វាយព្រះនាមព្រះកុមារថា វិឌូឌភៈ ។

ក្រោយមក ព្រះរាជា បានព្រះរាជទានតំណែងសេនាបតីដល់

វិឌូឌភកុមារនោះ ក្នុងវេលាដែលទ្រង់នៅក្មេងនោះឯង ដោយតាំងព្រះទ័យថា នឹងធ្វើឲ្យជាទីប្រោសប្រាណរបស់ព្រះសាស្តា ។

វិឌូឌភៈនោះ ទ្រង់បរិបូណ៌ដោយគ្រឿងសម្រាប់កុមារ ក្នុងវេលាមានព្រះជន្ម ៧ ខួប ទ្រង់ឃើញរបស់លេងផ្សេងៗ មានរូបដំរី និងរូបសេះជាដើម របស់កុមារដទៃដែលបុគ្គលនាំមកអំពីត្រកូលយាយ ទើបសួរព្រះមាតាថា ព្រះមាតា នរណាៗ គេក៏នាំបណ្ណាការមកអំពីត្រកូលយាយ ដើម្បីពួកកុមារដទៃ ព្រះញាតិណាៗ មិនដែលបញ្ជូនបណ្ណាការអ្វីៗ មកដើម្បីខ្ញុំម្ចាស់ខ្លះសោះ ព្រះមាតា មិនមានព្រះមាតា បិតាទេឬ ?

ពេលនោះ ព្រះមាតាក៏លួងព្រះកុមារនោះថា កូនសម្លាញ់ សក្យរាជជាយាយរបស់កូន ប៉ុន្តែនៅឆ្ងាយ ហេតុនោះ ទើបពួកលោកមិនបានបញ្ជូនបណ្ណាការណាៗ មកដើម្បីកូន ។

ក្នុងវេលាមានព្រះជន្ម ១៦ ឆ្នាំ ព្រះរាជកុមារក៏ទូលព្រះមាតាទៀតថា បពិត្រមាតា ខ្ញុំម្ចាស់មានបំណងនឹងទៅសួរសុខទុក្ខម្ចាស់យាយ សូម្បីត្រូវព្រះមាតាហាមថា កុំឡើយកូន កូននឹងទៅធ្វើអ្វីនៅទីនោះ ព្រះកុមារក៏នៅតែអង្វររឿយៗ ។ ពេលនោះ ព្រះមាតារបស់ព្រះកុមារ ក៏ទ្រង់

អនុញ្ញាតថា បើដូច្នោះ កូនទៅចុះ ។

ព្រះកុមារក្រាបទូលព្រះរាជបិតាហើយ យាងចេញទៅជាមួយនឹងបរិវារជាច្រើន ។ ព្រះនាងវាសភខត្តិយា ទ្រង់បញ្ជូនសំបុត្រទៅមុនថា ខ្ញុំម្ចាស់សុខសប្បាយជាធម្មតាទេ សូមព្រះញាតិទាំងឡាយ កុំសម្តែងទោសណាៗ របស់ព្រះស្វាមីដល់ព្រះកុមារនោះឡើយ ។

សក្យៈទ្រង់ជ្រាបថា វិឌូឌភៈយាងមក ក៏ទ្រង់ពិភាក្សាគ្នាថា ពួកយើងមិនអាចសំពះ ( វិឌូឌភកុមារ ) បានទេ លុះទ្រង់ប្រឹក្សាគ្នាដូច្នេះហើយ បញ្ជូនព្រះរាជកុមារទាំងឡាយដែលនៅក្មេងៗ ជាងវិឌូឌភៈនោះទៅកាន់ជនបទអស់ កាលវិឌូឌភកុមារនោះស្តេចយាងមកដល់ កបិលពស្តុបុរី ក៏ប្រជុំគ្នានៅក្នុងរោង វិឌូឌភកុមារបានទៅប្រថាប់នៅទីនោះ គ្រានោះពួកសក្យៈបាននិយាយនឹងព្រះកុមារនោះថា នែបា អ្នកនេះជាសម្តេចតារបស់បា អ្នកនេះជាសម្តេចអ៊ំរបស់បាវិឌូឌភកុមារនោះ ដើរសំពះសក្យៈទាំងអស់ មិនបានឃើញសក្យៈសូម្បីតែមួយអង្គមកសំពះខ្លួន ទើបសួរថា ហេតុអ្វីមិនមានសក្យៈទាំងឡាយ មកសំពះខ្ញុំម្ចាស់ខ្លះ ?

ពួកសក្យៈត្រាស់ថា នែបា កុមារជាប្អូនៗ របស់បាយានទៅកាន់ជនបទអស់ហើយ ហើយទ្រង់ធ្វើសក្ការៈយ៉ាងធំថ្វាយព្រះកុមារនោះ វិឌូឌកៈប្រថាប់នៅទីនោះអស់ ២-៣ ថ្ងៃ ក៏យាងចេញពីព្រះនគរ ដោយបរិវារជាច្រើន ។

គ្រានោះ នាងទាសីម្នាក់បានជេរវិឌូឌកៈថា នេះជាបន្ទះក្តារដែលបុត្ររបស់នាងទាសីឈ្មោះវាសភខត្តិយាអង្គុយ ដូច្នេះហើយ លាងបន្ទះក្តារដែលព្រះកុមារនោះទ្រង់គង់ក្នុងរោង ដោយទឹកលាយដោយទឹកដោះ ។

ពេលនោះ មានមហាតលិកម្នាក់ភ្លេចអាវុធរបស់ខ្លួន ក៏ត្រឡប់ទៅយកអាវុធនោះ បានឮសំឡេងជេរវិឌូឌកកុមារ ក៏សួរទាសីនោះ ដឹងថា នាងវាសភខត្តិយា កើតនៅក្នុងផ្ទៃរបស់នាងទាសីនៃមហានាមសក្យៈ ក៏ប្រាប់ពួកពលសេនា បានឮតៗ គ្នាថា ព្រះនាងវាសភខត្តិយាជាធីតារបស់នាងទាសី ។

វិឌូឌកៈទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ ក៏ទ្រង់តាំងព្រះទ័យទុកថា ពួកសក្យៈទាំងនោះ ចូរលាងបន្ទះក្តារដែលយើងអង្គុយដោយទឹក

លាយជាមួយទឹកដោះមុនចុះ ប៉ុន្តែ កាលណាយើងបានសោយរាជសម្បត្តិហើយ យើងនឹងយកឈាមក្នុងបំពង់ករបស់ពួកសក្យៈទាំងនោះ លាងបន្ទះក្ដារដែលយើងអង្គុយវិញ កាលព្រះរាជាស្ដេចយាងមកដល់ក្រុងសាវត្ថី ពួកអមាត្យក៏ក្រាបទូលរឿងទាំងអស់នោះចំពោះព្រះអង្គ ។ ព្រះរាជាទ្រង់ពិរោធនឹងពួកសក្យៈថា បានឲ្យធីតានៃនាងទាសីដល់យើង ទើបបញ្ជាឲ្យដកហូតគ្រឿងប្រើប្រាស់ដែលព្រះរាជទាន ដល់ព្រះនាងវាសភខត្តិយា ព្រមទាំងឱរស បញ្ជាឲ្យព្រះរាជទានត្រឹមតែវត្ថុដែលទាសៈ និងទាសីគួរបានប៉ុណ្ណោះ ។

ក្រោយមក ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ព្រះសាស្ដាយាងទៅកាន់ព្រះរាជនិវេសន៍ ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ព្រះរាជាស្ដេចយាងមកថ្វាយបង្គំ ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន មានពាក្យចចាមអារ៉ាមថា ពួកព្រះញាតិរបស់ព្រះអង្គ បានប្រទានធីតានៃនាងទាសីដល់ខ្ញុំព្រះអង្គ ព្រោះដូច្នោះ ទើបខ្ញុំព្រះអង្គដកហូតគ្រឿងប្រើប្រាស់របស់នាងវាសភខត្តិយា ព្រមទាំងបុត្រ ឲ្យត្រឹមតែរបស់សម្រាប់បុគ្គលដែលជា

ទាសៈ និងទាសីគួរបានតែប៉ុណ្ណោះ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ពួកសក្យៈធ្វើអំពើនេះ មិនសមគួរទេ ធម្មតា កាលនឹងថ្វាយ ក៏គួរថ្វាយធីតាដែលមានជាតិស្មើគ្នា បពិត្រមហារាជ តថាគតទូលសួរព្រះអង្គថា ព្រះនាងវាសភខត្តិយា ជាធីតានៃខត្តិយរាជ បានអភិសេកក្នុងរាជដំណាក់នៃខត្តិយរាជ ចំណែកវិឌូឌភកុមារ ក៏ទ្រង់អាស្រ័យខត្តិយរាជនឹងឯងប្រសូតមក ធម្មតាថា គោត្រខាងមាតានឹងធ្វើអ្វីបាន គោត្រខាងបិតាប៉ុណ្ណោះ ជារបស់សំខាន់ ដូច្នេះហើយ ត្រាស់ថា បុរាណបណ្ឌិតទាំងឡាយ បានព្រះរាជតំណែងអគ្គមហេសី ដល់ស្រីកម្សត់អ្នករែកឧសម្នាក់ ឈ្មោះកដ្ឋហារិកា ហើយព្រះរាជកុមារដែលកើតក្នុងផ្ទៃរបស់នាងនោះ ក៏បានដល់ភាពជាព្រះរាជាក្នុងនគរពារាណសី ( ដ៏ធំធេង ) ដល់ ១២ យោជន៍ ទ្រង់ព្រះនាមថា កដ្ឋវាហនរាជា ហើយត្រាស់កដ្ឋហារិយជាតក ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ព្រះធម្មកថានោះហើយ ទ្រង់ត្រេកអរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រាបហើយថា គោត្រខាងបិតាប៉ុណ្ណោះ

ជារបស់សំខាន់ ទើបបញ្ជាឲ្យព្រះរាជទានគ្រឿងប្រើប្រាស់ ដូចសព្វដង នោះឯង ដល់នាងវាសភខត្តិយា និងវិឌូឌភៈវិញ ។

កិរិយារបស់ពន្ធុលសេនាបតីឈ្មោះមល្លិកា ដែលជាព្រះធីតារបស់មល្លក្សត្រ ក្នុងនគរកុសិនារា មិនមានបុត្រអស់កាលជាយូរ ។

ក្រោយមក ពន្ធុលសេនាបតីបញ្ជូននាងទៅថា នាងចូរទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនវិញចុះ ។

នាងគិតថា យើងចូលគាល់ព្រះសាស្តាសិនសឹមទៅ លុះគិតដូច្នេះហើយ ក៏ចូលទៅកាន់វត្តជេតវន ឈរថ្វាយបង្គំព្រះសម្ពុទ្ធ, ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលនាងដ៏ចម្រើន នាងទៅណា ? ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្វាមីរបស់ខ្ញុំព្រះអង្គបញ្ជូនខ្ញុំព្រះម្ចាស់ទៅកាន់ផ្ទះនៃត្រកូល ។

ព្រះសាស្តា. ព្រោះហេតុអ្វី ?

នាង. ព្រោះខ្ញុំម្ចាស់ជាស្រីអារមិនមានបុត្រ ។

ព្រះសាស្តា. បើដូច្នោះកិច្ចដែលត្រូវទៅមិនមាន នាងចូរត្រឡប់ទៅ

វិញចុះ ។ នាងត្រេកអរណាស់ ថ្វាយបង្គំព្រះមានជោគត្រឡប់ទៅកាន់និវេសន៍វិញ កាលដែលស្វាមីសួរថា ម្នាលនាងដ៏ចម្រើន នាងត្រឡប់មកធ្វើអ្វី ? ក៏ឆ្លើយថា ព្រះទសពលឲ្យខ្ញុំម្ចាស់ត្រឡប់មកវិញ ពន្ធុលៈគិតថា ព្រះទសពលឃើញកាលវែងឆ្ងាយ ប្រាកដជាឃើញហេតុ ( នេះ ) ទើបទទួលនាងទុក ។

តមកមិនយូរប៉ុន្មាននាងក៏តាំងគភ៌ កើតអាការចាញ់ផ្ទៃ ក៏ប្រាប់ពន្ធុលសេនាបតីថា បពិត្រព្រះស្វាមី អាការចាញ់ផ្ទៃមានដល់ខ្ញុំម្ចាស់ហើយ ។

ពន្ធុលៈ. ម្នាលនាងដ៏ចម្រើន នាងចាញ់គភ៌ដូចម្តេច ?

នាង. បពិត្រព្រះស្វាមី ខ្ញុំមានចំណង់ចង់ចុះងូតទឹក ហើយផឹកទឹកក្នុងស្រះបោក្ខរណី ដែលជាស្រះមង្គលក្នុងពិធីអភិសេកនៃគណរាជត្រកូលក្នុងនគរវេសាលី ។

ពន្ធុលៈពោលថា ប្រពៃហើយនាង ហើយកាន់ធ្នូដែលបុគ្គលគប្បីលើករួចដោយកម្លាំងបុរសមួយពាន់នាក់ បីនាងឡើងរទេះចូលទៅកាន់

ក្រុងវេសាលី តាមទ្វារដែលស្ដេចលិច្ឆវីឲ្យដល់មហាលិលិច្ឆវី ។

លំនៅរបស់ស្ដេចលិច្ឆវីនាមថា មហាលិ មាននៅក្នុងទីជិតនោះឯង ។ពេលមហាលិបានឮសំឡេងកង់ប៉ះខ្ទប់ធរណីទ្វារក៏ដឹងថាសំឡេងរទេះរបស់ពន្ធុលៈ ទើបពោលថា ថ្ងៃនេះភ័យនឹងកើតមានដល់ស្ដេចលិច្ឆវី ។

ការរក្សាការពារស្រះបោក្ខរណី គឺងរឹងទាំងខាងក្នុង និងខាងក្រៅខាងលើគេបាំងដោយសំណាញ់លោហៈ សូម្បីតែសត្វក៏មិនមានឱកាសចុះទៅកាន់ស្រះនោះដែរ ។

ចំណែកពន្ធុលសេនាបតីចុះពីលើរទេះ វាយពួកមនុស្សដែលរក្សាស្រះបោក្ខរណីដោយរំពាត់ផ្ដៅ ឲ្យចៀសចេញទៅ ហើយកាត់សំណាញ់លោហៈ ឲ្យកិរិយាចុះងូត ។ សូម្បីខ្លួនឯងក៏ចុះងូតទឹកខាងក្នុងស្រះបោក្ខរណី ហើយបីនាងឡើងរទេះចេញចាកព្រះនគរ បរទៅតាមផ្លូវដែលមកនោះឯង ។

ពួកអ្នករក្សាស្រះបោក្ខរណី ទូលរឿងនោះថ្វាយស្ដេចលិច្ឆវី ពួក

ស្តេចលិច្ឆវីខ្វាល់ ស្តេចយាងឡើងរទេះ ៥០០ បរចេញទៅដោយចេតនាថា នឹងចាប់ស្តេចមល្លៈឈ្មោះពន្ធុលៈ បានប្រាប់រឿងនោះដល់ស្តេចមហាលិ ។

ស្តេចមហាលិត្រាស់ថា ពួកលោកកុំទៅ ព្រោះស្តេចពន្ធុលៈនោះនឹងសម្លាប់ពួកលោកទាំងអស់ ស្តេចលិច្ឆវីទាំងនោះ បានត្រាស់ប្រាប់មហាលិថា ពួកខ្ញុំម្ចាស់នឹងទៅឲ្យទាល់តែបាន ស្តេចមហាលិត្រាស់ថា បើដូច្នោះ កាលបើទ្រង់ឃើញទីដែលកង់រទេះលិចចុះក្នុងផែនដីរហូតដល់ដុំហើយ គប្បីយាងត្រឡប់មកវិញ កាលមិនត្រឡប់ពីទីនោះ នឹងបានឮសំឡេងដូចខ្សែរន្ទះខាងមុខ គប្បីត្រឡប់អំពីទីនោះ កាលមិនត្រឡប់អំពីទីនោះ ពេលឃើញប្រហោងក្នុងនឹមរទេះរបស់ពួកលោក គប្បីត្រឡប់ពីទីនោះភ្លាម កុំយាងទៅមុខទៀត ( ជាដាច់ខាត ) ស្តេចលិច្ឆវីទាំងនោះ មិនយាងត្រឡប់មកវិញ តាមពាក្យរបស់មហាលិទេ គិតតែដេញតាមពន្ធុលៈជានិច្ច ។ នាងមល្លិកាឃើញស្តេចលិច្ឆវីទាំងនោះដេញតាម ក៏និយាយប្រាប់ពន្ធុលៈថា បពិត្រស្វាមីរទេះទាំងឡាយ

សំដៅមករកយើងហើយ ។

ពន្ធុលៈពោលថា បើដូច្នោះ ពេលណាដែលរទេះប្រាកដជាជួរតែមួយ នាងគប្បីប្រាប់ខ្ញុំ ។

ពេលដែលរទេះប្រាកដជាជួរហើយ នាងប្រាប់ថា បពិត្រព្រះស្វាមី ក្បាលរទេះប្រាកដជាជួរតែមួយហើយ ។

ពន្ធុលៈនិយាយថា បើអ៊ីចឹង នាងចូរចាប់ខ្សែទាំងនោះឲ្យជាប់ ហើយឲ្យខ្សែទៅនាងមល្លិកា ឈរលើរទេះយឹតធ្នូឡើង កង់រទេះលិចចុះទៅក្នុងផែនដីដល់ដុំ ។ ស្តេចលិច្ឆវីទ្រង់ឃើញដូច្នោះហើយ ក៏នៅតែមិនព្រមយាងត្រឡប់ទៅវិញ ។ ពន្ធុលៈទៅបានបន្តិច ក៏ទាញខ្សែធ្នូសំឡេងខ្សែធ្នូនោះ ប្រៀបដូចជាស្នូររន្ទះ ។ ពួកស្តេចលិច្ឆវីទាំងនោះក៏នៅតែមិនយាងត្រឡប់អំពីទីនោះ នៅតែដេញតាមទៅទៀត ។

ពន្ធុលៈឈរនៅលើរទេះនោះឯង បាញ់កូនសរទៅមួយគ្រាប់ ។ កូនសរនោះ បានធ្វើឲ្យចន្ទោលរទេះ ៥០០ មានប្រហោង ហើយចាក់ទម្លុះព្រះរាជា ៥០០ ចំត្រង់កន្លែងចងក្រោះ ហើយលិចចុះទៅ

ក្នុងផែនដី ។

ស្ដេចលិច្ឆវីទាំងនោះមិនបានដឹងថា ខ្លួនត្រូវព្រួញចាក់ហើយទេ ក៏ត្រាស់ថា ឈប់សិនវ៉ឺយ ឈប់សិនវ៉ឺយ នៅតែដេញតាមទៅទៀត ។

ពន្ធុលសេនាបតីបញ្ឈប់រទេះ ហើយពោលថា មហាបពិត្រ មនុស្សស្លាប់ហើយ ការច្បាំងរបស់ខ្ញុំជាមួយនឹងមនុស្សស្លាប់ទាំងឡាយរមែងមិនមាន ។

ស្ដេចលិច្ឆវី. ដែលឈ្មោះថា មនុស្សស្លាប់ មិនដូចយើងទេ ។

ពន្ធុលៈ. បើដូច្នោះ មហាបពិត្រ ចូរដោះអាវក្រោះរបស់មហាបពិត្រ ខាងក្រោយទាំងអស់មើល ។

ពួកស្ដេចលិច្ឆវីទាំងនោះឲ្យដោះហើយ ស្ដេចលិច្ឆវីទាំងនោះក៏ដួលចុះ អស់ជីវិតក្នុងខណៈដោះអាវចេញនោះឯង ។

ពេលនោះ ទើបពន្ធុលៈនិយាយនឹងស្ដេចលិច្ឆវីទាំងនោះថា ពួកលោកសូម្បីទាំងអស់ក៏ដូចគ្នា យាងទៅដល់លំនៅរបស់ខ្លួនៗ ហើយចាត់ចែងវត្ថុដែលគួរចាត់ចែងផ្ដែផ្ដាំកូនប្រពន្ធហើយ សឹមដោះអាវក្រោះចេញ ។

ស្តេចលិច្ឆវីទាំងនោះ ធ្វើយ៉ាងនោះគ្រប់ៗ អង្គ ទើបសោយទិវង្គត ។

ចំណែកពន្ធុលៈ និងនាងមល្លិកា មកកាន់នគរសាវត្ថី ។ នាងប្រសូតបុត្រជាគូៗ ដល់ ១៦ ដង ។

បុត្ររបស់នាងទាំងអស់នោះ សុទ្ធតែជាអ្នកក្លៀវក្លា ដល់ព្រមដោយកម្លាំង បានសម្រេចសិល្បៈទាំងអស់គ្នា ។ ម្នាក់ៗ មានបុរសជាបរិវារមួយពាន់ ។ ព្រះលានហ្លួងពេញទៅដោយបុត្រទាំងនោះឯងដែលទៅកាន់រាជនិវេសន៍ជាមួយនឹងបិតា ។

ថ្ងៃមួយ ពួកមនុស្សដែលចាញ់ក្តី ដោយក្តីកោង ក្នុងការវិនិច្ឆ័យបានឃើញពន្ធុលៈកំពុងដើរមក ក៏ស្រែកទ្រហោយំ ប្រាប់ការវិនិច្ឆ័យក្តីកោងរបស់ពួកអមាត្យដល់ពន្ធុលៈនោះ ។

ពន្ធុលៈទៅកាន់រោងវិនិច្ឆ័យ ពិចារណាក្តីនោះហើយ បានធ្វើអ្នកដែលជាម្ចាស់របស់ឲ្យជាម្ចាស់របស់ ។ មហាជនឲ្យពរសាធុការដោយសំឡេងដ៏ខ្លាំង ព្រះរាជាទ្រង់ព្រះសណ្តាប់នូវសំឡេងនោះភ្លាម ក៏ទ្រង់ត្រាស់សួរថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សំឡេងអ្វីនោះ ? កាល

ទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ទ្រង់សោមនស្សឲ្យដកពួកអមាត្យទាំងនោះ ចេញអំពីការវិនិច្ឆ័យ ហើយប្រគល់ការវិនិច្ឆ័យ ឲ្យពន្ធុលៈតែម្នាក់តែប៉ុណ្ណោះ ។ តាំងពីពេលនោះមក ពន្ធុលៈក៏វិនិច្ឆ័យក្ដីដោយត្រឹមត្រូវ ។ ចាប់ផ្ដើមអំពីថ្ងៃនោះមក ពួកអមាត្យដែលវិនិច្ឆ័យក្ដីកាលពីមុនមិនបានថ្ងៃឈ្នួល មានកម្រៃតិច ក៏ញុះញង់ក្នុងរាជត្រកូលថា ពន្ធុលៈចង់ធ្វើជាព្រះរាជា ។

ព្រះរាជា ទ្រង់ជឿពាក្យរបស់ពួកអមាត្យទាំងនោះហើយ មិនអាចគ្របសង្កត់ព្រះហឫទ័យបាន ក៏ទ្រង់ព្រះតម្រិះទៀតថា កាលបើពន្ធុលៈត្រូវសម្លាប់ក្នុងទីនេះ ការតិះដៀលនឹងមានដល់យើង លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់បញ្ជាឲ្យពួកបុរសរៀបចំ ធ្វើឲ្យបច្ចន្តជនបទចលាចល ហើយបញ្ជាឲ្យហៅពន្ធុលៈមក ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា បានឮថា នៅជនបទ មានចោរកើតឡើង ធ្វើឲ្យចលាចល អ្នកព្រមទាំងបុត្ររបស់អ្នកចូរទៅចាប់ចោរនោះមក ហើយទ្រង់បញ្ជូននាយទាហាន ដែលខ្លាំងពូកែក្រុមដទៃទៅជាមួយនឹងពន្ធុលសេនាបតីនោះ ដោយព្រះតម្រាស់ថា ពួកអ្នកចូរកាត់សិរសាពន្ធុលសេនាបតី

ព្រមទាំងបុត្រ ៣២ នាក់ ក្នុងទីនោះ ហើយនាំមក ។

កាលពន្ធុលៈ ទៅដល់ជនបទជាយដែនហើយ ពួកចោរដែលព្រះរាជាទ្រង់រៀបចំទុកនោះ និយាយគ្នាថា ម្នាលអ្នកទាំងឡាយ បានឮថា សេនាបតីមកហើយ ហើយក៏នាំគ្នារត់ចៀសចេញទៅ ។

ពន្ធុលសេនាបតី ញ៉ាំងប្រទេសនោះឲ្យស្ងប់រម្ងាប់ហើយ ក៏ត្រឡប់ទៅវិញ ។ គ្រានោះ ទាហានទាំងនោះក៏កាត់សិរសារបស់ពន្ធុលសេនាបតី ព្រមទាំងបុត្រទាំងអស់ ក្នុងទីជិតព្រះនគរ ។

ថ្ងៃនោះ នាងមល្លិកាទេវី បាននិមន្តព្រះអគ្គសាវកទាំងពីរ ព្រមទាំងភិក្ខុ ៥០០ អង្គ ។

លុះព្រឹកឡើង ពួកមនុស្សបាននាំសំបុត្រមកឲ្យនាង មានសេចក្តីថា ចោរកាត់ក្បាលស្វាមី ព្រមទាំងបុត្ររបស់នាងអស់ហើយ នាងដឹងរឿងនោះហើយ មិនប្រាប់នរណាទាំងអស់ បត់សំបុត្រដាក់ក្នុងថ្នក់សំពត់អង្គាសភិក្ខុសង្ឃតទៅ ។

គ្រានោះ ស្រីបម្រើរបស់នាងថ្វាយភត្តដល់ភិក្ខុហើយ នាំថាសទឹកដោះថ្លាមក ធ្វើថាសបែកត្រង់ទីចំពោះមុខព្រះថេរៈ ព្រះធម្មសេនាបតី

ពោលថា វត្ថុដែលមានការបែកធ្លាយជាធម្មតា ក៏បែកទៅហើយ នរណាៗ មិនគួរគិត ។

នាងមល្លិកា នាំយកសំបុត្រចេញពីថ្នក់សំពត់ ពិតព្រះសារីបុត្រ ថា បពិត្រលោកម្ចាស់ដ៏ចម្រើន គេនាំសំបុត្រនេះមកឲ្យខ្ញុំ ប្រាប់ថា ពួកចោរកាត់ក្បាលបិតា ព្រមទាំងបុត្រ ៣២ នាក់ ខ្ញុំម្ចាស់សូម្បីដឹង រឿងនេះហើយ ក៏មិនបានគិត ពោលទៅថ្វី ( ត្រឹមតែ ) ថាសទឹកដោះ បែក នាងខ្ញុំនឹងគិតដូចម្តេចទៅ ។

ព្រះធម្មសេនាបតី ពោលពាក្យជាដើមថា

ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមាននិមិត្ត នរណាម្នាក់ ក៏ដឹងមិនបាន ទាំងក្រ ទាំងមាន ហើយជីវិតនោះ ប្រកបដោយ សេចក្តីទុក្ខ សម្តែងធម៌ចប់ ក៏ក្រោកចាកអាសនៈទៅកាន់វិហារ ។

ចំណែកនាងមល្លិកា ឲ្យគេទៅហៅកូនប្រសាស្រីទាំង ៣២ នាក់ មក ហើយទូន្មានថា ស្វាមីរបស់ពួកនាងមិនមានកំហុស បានទទួល ផលកម្មក្នុងជាតិមុនរបស់ខ្លួន នាងទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួល កុំធ្វើការចងគំនុំនឹងព្រះរាជាឡើយ ។

ចារបុរសរបស់ព្រះរាជាស្តាប់ពាក្យនោះហើយ ទៅក្រាបទូលនូវការដែលជនទាំងនោះ មិនមានទោសចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ដល់នូវការស្ងុតព្រះហឫទ័យ ស្តេចយាងទៅកាន់និវេសន៍របស់នាងមល្លិកា ឲ្យនាងមល្លិកា និងកូនប្រសារបស់នាងអត់ទោសឲ្យហើយបានព្រះរាជទានពរដល់នាងមល្លិកា នាងក្រាបទូលថា ពរ សូមជាពរដែលនាងខ្ញុំម្ចាស់ទទួលទុកចុះ កាលព្រះរាជាស្តេចយាងទៅវិញនាងថ្វាយកត្តដើម្បីមនុស្សស្លាប់ ងូតទឹកហើយ ចូលទៅគាល់ព្រះរាជាទូលថា បពិត្រមហាតេជះ ព្រះអង្គព្រះរាជទានពរឲ្យខ្ញុំម្ចាស់ហើយម្យ៉ាងទៀត ខ្ញុំម្ចាស់មិនមានសេចក្តីត្រូវការដោយរបស់ដទៃទេ សូមព្រះអង្គទ្រង់អនុញ្ញាតឲ្យកូនប្រសាទាំង ៣២ នាក់ របស់ខ្ញុំម្ចាស់ និងខ្លួនខ្ញុំម្ចាស់ត្រឡប់ទៅផ្ទះវិញចុះ ។

ព្រះរាជាទ្រង់ទទួលហើយ នាងមល្លិកាបញ្ជូនកូនប្រសា ទាំង ៣២ នាក់ ទៅកាន់ត្រកូលរបស់ខ្លួនដោយខ្លួនឯង ។ ចំណែកនាងទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនក្នុងនគរកុសិនារា ។

ចំណែកព្រះរាជា ទ្រង់បានព្រះរាជទានតំណែងសេនាបតីដល់

ទីឃការាយនៈ ដែលជាក្មួយរបស់ពន្ធុលសេនាបតី ។

ទីឃការាយនៈនោះ ស្វែងរកកំហុសរបស់ព្រះរាជា ដោយគិតថា អ៊ំរបស់យើងត្រូវព្រះរាជាអង្គនេះ បញ្ជាឲ្យគេសម្លាប់ហើយ បានឮថា ចាប់ផ្តើមអំពីការដែលពន្ធុលៈ ដែលមិនមានកំហុសត្រូវសម្លាប់ហើយ ព្រះរាជាទ្រង់មានវិប្បដិសារៈ មិនបានទទួលការសប្បាយព្រះហឫទ័យ មិនបានសោយនូវសេចក្តីសុខ ក្នុងព្រះរាជសម្បត្តិឡើយ ។

គ្រានោះ ព្រះសាស្តា ទ្រង់អាស្រ័យនិគម ឈ្មោះមេទឡុបៈ នៃពួកសក្យរាជ ។ ព្រះរាជាស្តេចយាងទៅកាន់ទីនោះហើយ ទ្រង់ឲ្យបោះជំរំក្នុងទីមិនឆ្ងាយពីអារាម ហើយស្តេចយាងទៅកាន់វិហារ ដោយបរិវារជាច្រើន ដោយទ្រង់ព្រះតម្រិះថា នឹងថ្វាយបង្គំព្រះសាស្តា ព្រះរាជទានគ្រឿងរាជកកុធភណ្ឌទាំង ៥ ដល់ទីឃការាយនៈ ហើយស្តេចយាងចូលកាន់ព្រះគន្ធកុដិ តែមួយព្រះអង្គឯងប៉ុណ្ណោះ ។ គប្បីជ្រាបរឿងទាំងអស់នោះ តាមទំនងនៃធម្មចេតិយសូត្រចុះ ។ កាលព្រះរាជាស្តេចចូលទៅកាន់ព្រះគន្ធកុដិហើយ ទីឃការាយនៈក៏កាន់យកគ្រឿងកកុធភណ្ឌទាំងនោះ ធ្វើវិឌូឌភៈឲ្យជាព្រះរាជា បន្សល់ទុកសេះមួយ និង

ស្ត្រីបម្រើម្នាក់ ហើយត្រឡប់ទៅក្រុងសាវត្ថីវិញ ។

ព្រះរាជាត្រាស់បិយកថានឹងព្រះសាស្តារួចហើយ យាងចេញមកវិញ ទ្រង់មិនឃើញសេនា ក៏ត្រាស់សួរស្រីនោះ ទ្រង់បានដឹងរឿងនោះហើយ ទ្រង់ព្រះតម្រិះថា យើងនឹងនាំក្មួយរបស់យើងទៅចាប់វិឌូឌភៈដូច្នេះហើយ ស្តេចយាងទៅកាន់ក្រុងរាជគ្រឹះ លុះស្តេចយាងទៅដល់ព្រះនគរ គេក៏បិទទ្វារព្រះនគរល្មម ព្រះរាជាក៏ផ្ទុំក្នុងសាលាមួយក្បែរទ្វារនគរ ទ្រង់នឿយហត់ព្រោះខ្យល់ និងកម្តៅថ្ងៃខ្លាំងពេកក៏សោយទិវង្គតក្នុងទីនោះ នៅពេលពាក់កណ្តាលយប់ ។ លុះភ្លឺឡើង ប្រជាជនបានឮសំឡេងស្ត្រីនោះយំរៀបរាប់ថា បពិត្រព្រះសម្មតិទេព ព្រះអង្គជាស្តេចនៃអ្នកកោសល ព្រះអង្គមិនមានទីពឹងឡើយ ក៏ក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជាឲ្យធ្វើសរីរកិច្ចរបស់ម្ចាស់អ៊ំដោយសក្ការៈដ៏ធំ ។

ចំណែកព្រះបាទវិឌូឌភៈ បានរាជសម្បត្តិហើយ ទ្រង់រឭកដល់ពៀរនោះ ទ្រង់ត្រិះរិះថា យើងនឹងញុាំងពួកសក្យៈទាំងនោះឲ្យស្លាប់ដូច្នេះហើយ ក៏ស្តេចយាងចេញទៅដោយសេនាដ៏ធំ ។

ក្នុងថ្ងៃនោះ ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញសេចក្តីវិនាសនៃពួកញាតិ ហើយទ្រង់ព្រះតម្រិះថា តថាគត គួរធ្វើញាតិសង្គហៈ ក្នុងវេលាព្រឹក ទ្រង់យាងទៅបិណ្ឌបាត ត្រឡប់មកអំពីបិណ្ឌបាតវិញ ទ្រង់សម្រេចសីហសេយ្យាក្នុងព្រះគន្ធកុដិ ក្នុងវេលាល្ងាច ស្តេចយាងទៅតាមផ្លូវអាកាស ទ្រង់គង់ក្រោមដើមឈើដែលមានម្លប់រង្វើលៗ ជិតក្រុងកបិលពស្តុនោះ ។ នៅទីជិតនោះ មានដើមជ្រៃ ដែលមានម្លប់ត្រឈឹងត្រឈៃមួយដើម នៅក្នុងរាជសីមារបស់ព្រះបាទវិឌូឌភៈ ព្រះបាទវិឌូឌភៈទតឃើញព្រះសាស្តា ក៏យាងចូលទៅគាល់ ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុដូចម្តេច ទើបព្រះអង្គ ទ្រង់គង់ក្រោមដើមឈើដែលមានម្លប់តិចៗ ក្នុងវេលាក្តៅបែបនេះ សូមព្រះអង្គមេត្តាគង់ក្រោមដើមជ្រៃដែលមានម្លប់ដ៏ក្រាស់នោះចុះ ព្រះសាស្តាតបវិញថា ណ្ហើយចុះមហាបពិត្រ ដែលឈ្មោះថា ម្លប់នៃពួកញាតិជារបស់ត្រជាក់ជាង ទើបទ្រង់ត្រិះរិះថា ព្រះមានជោគស្តេចយាងមក ដើម្បីទ្រង់រក្សាពួកញាតិ ទើបថ្វាយបង្គំព្រះសាស្តា ហើយយាងត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញ ។ ចំណែកព្រះ

សាស្តា ទ្រង់ហោះទៅកាន់វត្តជេតពនវិញដែរ ។ ព្រះរាជាទ្រង់រឭក ដល់កំហុសនៃពួកសក្យៈ យាងចេញទៅលើកទី ២ ក៏ទតឃើញព្រះ សាស្តាទ្រង់គង់នៅទីនោះទៀត ក៏យាងត្រឡប់មកវិញទៀត ។ ស្តេច យាងចេញទៅលើកទី ៣ ក៏ទ្រង់ឃើញព្រះសាស្តាក្នុងទីនោះ ស្តេច ក៏យាងត្រឡប់មកវិញទៀត ។ ប៉ុន្តែ កាលព្រះបាទវិឌូឌភៈ យាងចេញ ទៅលើកទី៤ព្រះសាស្តាទ្រង់ពិចារណាឃើញបុព្វកម្មរបស់ពួកសក្យៈ ទាំងឡាយ ទ្រង់ជ្រាបថា កម្មដ៏លាមក គឺការបាចថ្នាំពិស ក្នុងស្ទឹង នៃពួកសក្យៈទាំងនោះ ជាកម្មដែលនរណាម្នាក់ មិនអាចហាមឃាត់ បាន ទើបមិនយាងទៅលីកទី ៤ ។ ព្រះបាទវិឌូឌភៈយាងចេញទៅដោយ ពលសេនាដ៏ច្រើន ដោយទ្រង់ព្រះតម្រិះថា យើងនឹងសម្លាប់ពួកសក្យៈ

ព្រះញាតិទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ ជាអ្នកវៀរចាកការ សម្លាប់សត្វ សូម្បីស្លាប់ក៏មិនផ្តាច់បង់ជីវិតរបស់សត្វដទៃដែរ ។

ពួកសក្យៈទាំងនោះគិតថា ពួកយើងហ្វឹកហាត់ហើយ មានគ្រឿង ក្រោះដែលធ្វើល្អហើយ មានការហ្វឹកហាត់មកច្រើនហើយ ។ ប៉ុន្តែ ពួក យើងមិនអាចសម្លាប់សត្វដទៃឡើយ ពួកយើងនឹងសម្តែងកម្មរបស់ខ្លួន

ហើយ ឲ្យចៀសចេញទៅ ។ ពួកសក្យៈទាំងនោះ ទ្រង់មានគ្រឿងចង សៀតដែលធ្វើហើយ ទើបស្តេចយាងចេញផ្តើមការប្រយុទ្ធ ។ កូនព្រួញដែលពួកសក្យៈទាំងនោះបាញ់ទៅ ទៅតាមចន្លោះៗ ពួកបុរសរបស់ព្រះបាទវិឌូឌភៈ ចេញទៅតាមចន្លោះរបាំង និងចន្លោះត្រចៀកជាដើម ។ ព្រះបាទវិឌូឌភៈទតឃើញ ត្រាស់ថា នែពួកសក្យៈ រមែងត្រាស់ថា ពួកយើងជាអ្នកមិនសម្លាប់សត្វ មិនមែនឬ ? កាលបើដូច្នោះ ហេតុដូចម្តេច ទើបពួកសក្យៈបាញ់បុរសរបស់យើងឲ្យវិនាសទៅ គ្រានោះ បុរសម្នាក់ក្រាបទូលព្រះបាទវិឌូឌភៈថា បពិត្រព្រះអង្គ ទ្រង់ពិនិត្យមើលហើយឬ ?

ព្រះបាទវិឌូឌភៈ. ពួកសក្យៈញុំាងបុរសរបស់យើងឲ្យវិនាស ។

បុរស. មនុស្សណាៗ របស់ព្រះអង្គ ឈ្មោះថា ស្លាប់ហើយ រមែងមិនមាន សូមព្រះអង្គបញ្ជាឲ្យរាប់មនុស្សទាំងនោះចុះ ។

ព្រះបាទវិឌូឌភៈកាលបញ្ជាឲ្យរាប់មើល ទ្រង់មិនឃើញអស់សូម្បីតែម្នាក់ ។ ព្រះអង្គយាងត្រឡប់ពីទីនោះ ហើយត្រាស់ថា នែនរណាៗ ប្រាប់ថា ពួកយើងជាសក្យៈ អ្នកទាំងឡាយចូរសម្លាប់អ្នក

ទាំងអស់នោះ ប៉ុន្តែ ឲ្យជីវិតដល់មនុស្សដែលឈរនៅក្នុងសម្នាក់របស់សក្យមហានាម ដែលជាស្តេចតារបស់យើង ។

ពួកសក្យៈទាំងឡាយ មិនឃើញវត្ថុណាដែលខ្វនគប្បីកាន់យក ពួកខ្លះរែកស្មៅ ពួកខ្លះឈរកាន់ដើមបបុស ត្រូវគេសួរថា លោកជាសក្យៈ ឬមិនមែនទេ ? ព្រោះហេតុតែពួកសក្យៈទាំងនោះ សូម្បីនឹងស្លាប់ក៏មិនពោលពាក្យកុហក ពួកដែលឈរបៀមស្មៅក៏ពោលថា មិនមែនពួកសក្យៈ ស្មៅ ពួកដែលកាន់ដើមបបុស ក៏ពោលថា មិនមែនពួកសក្យៈ ដើមបបុស ពួកសក្យៈទាំងនោះ និងពួកសក្យៈដែលឈរនៅក្នុងសម្នាក់នៃសក្យមហានាម បានរួចជីវិត ។

បណ្តាពួកសក្យៈទាំងនោះ ពួកសក្យៈដែលឈរបៀមស្មៅ ឈ្មោះថា សក្យៈស្មៅ ពួកដែលឈរកាន់ដើមបបុសឈ្មោះថា សក្យបបុស ។

ព្រះបាទវិឌូឌភៈ បញ្ជាឲ្យសម្លាប់ពួកសក្យៈដ៏សេសទាំងឡាយ មិនវៀរសូម្បីតែទារកដែលនៅមិនទាន់ផ្តាច់ដោះ ញុំាងស្ទឹង គឺលោហិតឲ្យហូរទៅ ហើយបញ្ជាឲ្យលាងបន្ទះក្តារដោយលោហិត ក្នុងបំពង់-ក

នៃពួកសក្យៈទាំងនោះ ។

សក្យវង្សត្រូវព្រះបាទវិឌូឌភៈ កាត់ផ្តាច់ហើយដោយអាការយ៉ាងនេះ ។ ព្រះបាទវិឌូឌភៈនោះ បញ្ជាឲ្យចាប់សក្យមហានាម ហើយស្តេចយាងត្រឡប់ទៅវិញ លុះដល់វេលាសោយព្រះក្រយាហារពេលព្រឹក ទ្រង់ក៏ត្រិះរិះថា យើងនឹងសោយអាហារព្រឹក ដូច្នេះហើយ ទ្រង់ចៀងទៅកាន់ទីកន្លែងមួយ កាលភោជនដែលបុគ្គលនាំចូលទៅ ក៏បញ្ជាឲ្យហៅសម្តេចតាមក ដោយព្រះតម្រាស់ថា យើងនឹងសោយរួមគ្នា ។

ប៉ុន្តែ ក្សត្រទាំងឡាយ សូម្បីអស់ជីវិតក៏មិនព្រមដោយរួមនឹងបុត្រនាងទាសីដែរ ព្រោះហេតុដូច្នោះ មហានាមទតឃើញស្រះមួយក៏ត្រាស់ថា តាមានរាងកាយកខ្វក់ បពិត្រចៅ តាងូតទឹកសិន ។

ព្រះបាទវិឌូឌភៈត្រាស់ថា ប្រពៃហើយ សូមសម្តេចតាយាងងូតចុះ មហានាមទ្រង់ត្រិះរិះថា ព្រះបាទវិឌូឌភៈនេះ នឹងសម្លាប់យើងដែលជាអ្នកមិនបរិភោគរួមជាមួយ ការស្លាប់ដោយឯងប៉ុណ្ណោះប្រសើរជាង លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់រំសាយសក់ ស៊កមេជើងទៅក្នុងសក់ ខ្វារឲ្យជាកំណួចត្រង់ចុង មុជចុះទៅក្នុងទឹក ។ ដោយតេជះ

នៃគុណមហានាមនោះ ពិភពនាគក៏សម្តែងអាការក្តៅ ។ ស្តេចនាគពិចារណាថា មានរឿងអ្វីទៅហ្ន៎ ឃើញមហានាមហើយ ក៏មកកាន់សម្នាក់មហានាម ឲ្យមហានាមប្រថាប់លើពពារ ហើយយាងស្តេចចូលទៅកាន់ពិភពនាគ ។ មហានាមនោះនៅក្នុងពិភពនាគអស់ ១២ ឆ្នាំ ។

ចំណែកព្រះបាទវិឌូឌភៈ គង់ចាំមហានាមសក្យៈ ដោយព្រះតម្រិះថា សម្តេចតារបស់យើង នឹងមកក្នុងកាលឥឡូវនេះ កាលមហានាមនោះបាត់យូរ ក៏បញ្ជាឲ្យរាវរកក្នុងស្រះ ទោះខំប្រឹងរាវរកយ៉ាងណាក៏ដោយ ក៏មិនឃើញ កាលរកមិនឃើញ ក៏ស្តេចយាងទៅដោយព្រះតម្រិះថា សម្តេចតារបស់យើងប្រាកដជាយាងទៅហើយ ។

ព្រះបាទវិឌូឌភៈនោះ យាងទៅដល់ស្ទឹងអចិរវតី ក្នុងវេលារាត្រីបញ្ជាឲ្យបោះជំរំនៅទីនោះ ។ មនុស្សពួកខ្លះ ដេកនៅលើឆ្នេរខ្សាច់ខាងក្នុងស្ទឹង ពួកខ្លះដេកនៅលើគោកខាងក្រៅ ។ បណ្តាពួកជនដែលដេកនៅខាងក្នុង ពួកដែលមិនបានធ្វើបាបកម្មកាលមុនក៏មាន បណ្តាពួកជនដែលដេកនៅខាងក្រៅ ដែលមានបាបកម្មបានធ្វើទុកហើយក្នុងកាលមុនក៏មាន ស្រមោចក្រហមទាំងឡាយ ក៏បានកើតឡើងក្នុងទីដែល

មនុស្សទាំងនោះដេក ។

ជនទាំងនោះនិយាយថា ស្រមោចក្រហមកើតឡើងហើយ ក្នុងទីដែលពួកយើងដេក ស្រមោចក្រហមកើតឡើងហើយ ក្នុងទីដែលពួកយើងដេក ក៏ក្រោកឡើង ពួកដែលមិនមានបាបកម្មក្រោកឡើងទៅដេកលើគោក ពួកដែលមានបាបកម្ម ចុះទៅដេកលើឆ្នេរខ្សាច់ ។

គ្រានោះ មហាមេឃក៏តាំងឡើង ញុំាំងគ្រាប់ភ្លៀងឲ្យធ្លាក់ចុះ អន្លង់ទឹកឡើងមក ញុំាំងព្រះបាទវិឌូឌភៈ ព្រមទាំងបរិស័ទឲ្យទៅដល់សមុទ្រ ។ ជនទាំងអស់នោះ បានជាចំណីត្រី និងអណ្ដើកក្នុងសមុទ្រនោះឯង ។ មហាជនញុំាំងកថាឲ្យតាំងឡើងថា ការស្លាប់របស់ពួកសក្យៈទាំងឡាយ មិនសមគួរសោះ ការស្លាប់នេះ គឺពួកសក្យៈ ដែលព្រះបាទវិឌូឌភៈប្រហារឲ្យស្លាប់យ៉ាងនេះ ទើបមិនសមគួរ ។

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់យ៉ាងនេះ មិនសមគួរដល់ពួកសក្យៈទាំងឡាយ ក្នុងអត្តភាពនេះក៏ពិតមែនហើយ ប៉ុន្តែ ការស្លាប់ដែលពួកសក្យៈទាំងនោះបានទទួលហើយសមគួរពិត ដោយអំណាចនៃកម្ម

ដ៏លាមក ដែលខ្លួនធ្វើទុកហើយក្នុងកាលមុន ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ពួកសក្យៈទាំងឡាយនោះ បាន ធ្វើកម្មអ្វីទុកក្នុងកាលមុន ព្រះអង្គ ?

ព្រះសាស្ដា. ក្នុងកាលមុន ពួកសក្យៈទាំងនោះ រួមគ្នាជាពួក មួយ បាចថ្នាំពិសទៅក្នុងស្ទឹង ។

ថ្ងៃស្អែកឡើង ពួកភិក្ខុទាំងឡាយ ញុំាងកថាឲ្យតាំងឡើងក្នុង រោងធម្មសភាថា ព្រះបាទវិឌូឌភៈ បានញុំាងសក្យៈទាំងឡាយ ប្រមាណ ប៉ុណ្ណោះឲ្យស្លាប់ ហើយស្ដេចយាងមក កាលមនោរថរបស់ខ្លួននៅ មិនទាន់ដល់បំផុតនោះឯង ក៏នាំជនប្រមាណប៉ុណ្ណោះ ( ទៅ ) ជា អាហាររបស់ត្រី និងអណ្ដើកក្នុងសមុទ្រហើយ ព្រះសាស្ដាយាងមក ហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយ សន្ទនាគ្នាដោយកថាអ្វីហ្ន៎ ? កាលភិក្ខុទាំងនោះទូលថា ដោយកថា ឈ្មោះនេះ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមនោរថរបស់សត្វ ទាំងនេះនៅមិនទាន់ដល់ទីបំផុតនោះឯង មច្ចុរាជផ្ដាច់ជីវិតិន្ទ្រិយ ហើយ ឲ្យលិចចុះក្នុងសមុទ្រ គឺអបាយភូមិ ៤ ដូចអន្លង់ទឹកដ៏ធំជន់ពន្លិចអ្នក

ស្រុកដែលដេកលក់ដូច្នោះ ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**

**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំ ដែលក្បួចយកអ្នកស្រុកកំពុងដេកលក់ទៅដូច្នោះឯង ។

បណ្តាបទទាំងនោះ បាទព្រះគាថាថា **ព្យាសត្តមនសំ នរំ** សេចក្តីថា អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ ដែលដល់ព្រមហើយ ឬដែលមិនទាន់ដល់ព្រមហើយ ។

ព្រះមានព្រះភាគ ត្រាស់អធិប្បាយពាក្យនេះទុកថា

នាយមាលាការចូលទៅកាន់សួនច្បារហើយ គិតថា យើងនឹងបេះផ្កាឈើទាំងឡាយ ហើយមិនបេះយកផ្កាឈើអំពីសួននោះ ប្រាថ្នាគុម្ពដទៃៗ ឈ្មោះថា បញ្ជូនចិត្តទៅក្នុងសួនផ្ការឈើទាំងអស់ ឬគិតថា យើងនឹងបេះផ្កាឈើអំពីគុម្ពនេះ ហើយមិនបេះយកផ្កាឈើអំពីគុម្ពនោះ

រមែងបញ្ជូនចិត្តទៅកាន់ទីដទៃ ជ្រើសរើសនូវគុម្ពផ្កាឈើនោះឯង ឈ្មោះថា រមែងដល់នូវសេចក្តីប្រមាទយ៉ាងណា នរជនខ្លះក៏ដូច្នោះដែរ ញ៉ាំងចិត្តចុះកាន់កណ្តាលកាមគុណ ៥ ដូចសួនច្បារ បានរូបដែលជាទីពេញចិត្តហើយ ប្រាថ្នាក្លិន រស ផោដ្ឋព្វៈ ដែលជាទីពេញចិត្តដទៃទៀត ឬបានអារម្មណ៍ណាមួយ មានសំឡេងជាដើមហើយ ប្រាថ្នាអារម្មណ៍ដទៃទៀត ឬបានរូបនោះហើយ ប្រាថ្នាអារម្មណ៍ផ្សេងទៀត ឈ្មោះថា រមែងត្រេកអរនឹងអារម្មណ៍នោះឯង ឬបានអារម្មណ៍ទាំងឡាយមានសំឡេងជាដើម ហើយប្រាថ្នាអារម្មណ៍ដទៃទៀត ( ឈ្មោះថា រមែងត្រេកអរនឹងអារម្មណ៍ ដែលខ្លួនបានហើយ ) ។ បណ្តាសវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ មានគោ ក្របី ទាសៈ ទាសី ស្រែ ចម្ការ ស្រុក និគម និងជនបទជាដើម ក៏ន័យនោះឯង ។

ចំណែកបរិវេណវិហារ មានបច្ច័យ គឺបាត្រ និងចីវរជាដើម របស់បព្វជិត ក៏មានន័យដូច្នោះដែរ ( មច្ចុរមែងនាំ ) នរជនដែលមានចិត្តជាប់ជំពាក់ក្នុងកាមគុណ ដែលដល់ព្រមហើយ ឬមិនទាន់ដល់ព្រម ដែលកំពុងជ្រើសរើសបេះផ្កាឈើ ពោល គឺកាមគុណ ៥ យ៉ាងនេះ

ដោយប្រការដូច្នេះ ( ទៅ ) ។

ពីរបទថា **សុត្តំ គាមំ** សេចក្តីថា ដែលឈ្មោះថា ការដេកលក់ដោយអំណាចនៃការលក់នៃទព្វសម្ភារៈទាំងឡាយ មានជញ្ជាំងផ្ទះជាដើមរបស់អ្នកស្រុក រមែងមិនមាន ប៉ុន្តែ ស្រុកឈ្មោះថា ជាការដេកលក់ហើយ ក៏ព្រោះប្រៀបធៀបនឹងសត្វទាំងឡាយ ដែលប្រមាទ ដូចដេកលក់ដូច្នោះ មច្ចុនាំ ( នរជន ) ទៅ ដូចអន្លង់ទឹកធំ វែង និងជ្រៅ ២-៣ យោជន៍ ( កួចនាំ ) អ្នកស្រុកដែលកំពុងដេកលក់ហើយយ៉ាងនោះទៅដូច្នោះ គឺថា អន្លង់ទឹកធំនោះ ញុំាងអ្នកស្រុកទាំងអស់មិនឲ្យសត្វណាៗ ក្នុងបណ្តាបុរស ស្ត្រី គោ ក្របី និងមាន់ជាដើមសល់ទៅឲ្យដល់មហាសមុទ្រ ហើយធ្វើឲ្យជាអាហាររបស់ត្រី និងអណ្តើកយ៉ាងណា មច្ចុរាជ គឺសេចក្តីស្លាប់ នាំនរជនដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ គឺកាត់ផ្តាច់ឥន្ទ្រិយ គឺជីវិតរបស់នរជននោះ ឲ្យលិចចុះក្នុងមហាសមុទ្រ គឺអបាយភូមិទាំង ៤ ក៏ដូច្នោះដែរ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ធម្មទេសនាបានប្រយោជន៍ដល់មហាជនដូច្នេះឯង ៕

# រឿងនាងចិញ្ចមាណវិកា

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងជេតពន ទ្រង់ប្រារព្ធ នាងចិញ្ច-មាណវិកា ត្រាស់ព្រះធម្មទេសនានេះថា ឯកំ ធម្មំ អតីតស្ស ជាដើម ។

សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល កាលសាវកព្រះសាស្តាមានប្រមាណច្រើន ពួកទេវតា និងពួកមនុស្សយាងចុះកាន់អរិយភូមិ ការកើតឡើងនៃព្រះគុណរបស់ព្រះសាស្តាបានផ្សព្វផ្សាយទៅ ទើបលាភសក្ការៈជាច្រើនបានកើតឡើង ។ពួកតិរ្ថិយប្រាកដដូចជាពន្លឺអំពិលអំពែក ក្នុងពេលព្រះអាទិត្យរះ ជាអ្នកសាបសូន្យលាភសក្ការៈ ។ ពួកតិរ្ថិយទាំងនោះ ឈរកណ្តាលផ្លូវ ប្រកាសឲ្យពួកមនុស្សដឹងច្បាស់យ៉ាងនេះថា ព្រះសមណគោតមប៉ុណ្ណោះឬ ជាព្រះពុទ្ធ សូម្បីយើងក៏ជាព្រះពុទ្ធដែរ ទានដែលឲ្យដល់ព្រះសមណគោតមប៉ុណ្ណោះឬ មានផលច្រើន សូម្បីទានដែលឲ្យហើយដល់ពួកយើង ក៏មានផលច្រើន ដូចគ្នាដែរ អ្នកទាំងឡាយចូរឲ្យ ចូរធ្វើដល់ពួកយើងខ្លះ មិនបានលាភសក្ការៈ

ក៏ប្រជុំគ្នាក្នុងទីស្ងាត់ថា ពួកយើងគប្បីញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ក្នុងរវាងមនុស្សទាំងឡាយ គប្បីញ៉ាំងលាភសក្ការៈឲ្យវិនាសដោយឧបាយដូចម្ដេចហ្ន៎ ? កាលនោះក្នុងក្រុងសាវត្ថី មាននាងបរិព្វាជិកាម្នាក់ ឈ្មោះចិញ្ចមាណវិកា ជាអ្នកមានរូបឆោមល្អ ដល់ការប្រសើរ ដោយភាពល្អ ដូចនាងទេពអប្សរដូច្នោះ រស្មីបានផ្សាយចេញចាកសរីរៈរបស់នាង ។

លំដាប់នោះ តិរ្ថិយអ្នកមានប្រាជ្ញាឈ្លាសវៃម្នាក់ ពោលយ៉ាងនេះថា ពួកយើងអាស្រ័យនាងចិញ្ចមាណវិកា គប្បីញ៉ាំងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ធ្វើលាភសក្ការៈរបស់លោកឲ្យវិនាសបាន ។ តិរ្ថិយទាំងនោះ ទទួលព្រមថា ឧបាយនេះល្អ ។ តមក នាងចិញ្ចមាណវិកានោះ ទៅកាន់អារាមរបស់តិរ្ថិយ ថ្វាយបង្គំហើយ ក៏បានឈរ ។ ពួកតិរ្ថិយមិនតបតជាមួយនាង ។ ទើបនាងគិតថា យើងមានទោសអ្វីហ្ន៎ សូម្បីនាងនិយាយដល់ ៣ ដងថា លោកម្ចាស់ទាំងឡាយ នាងខ្ញុំថ្វាយបង្គំ ហើយក៏និយាយថា លោកម្ចាស់ទាំងឡាយ នាងខ្ញុំមានទោសអ្វី ? ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិននិយាយ

ជាមួយនាងខ្ញុំ ?

តិរិយ. ម្នាលប្អូនស្រី នាងមិនដឹងថាព្រះសមណគោតមបៀតបៀនពួកយើង គ្រាប់ធ្វើពួកយើងឲ្យសាបសូន្យលាភសក្ការៈទេឬ ?

នាងចិ. នាងខ្ញុំមិនដឹងទេ លោកម្ចាស់ ចុះក្នុងរឿងនេះ នាងខ្ញុំគួរធ្វើដូចម្ដេច ?

តិរិយ. ម្នាលប្អូនស្រី បើនាងប្រាថ្នាសេចក្ដីសុខដល់ពួកយើង ចូរញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតម រួចញុំាងលាភសក្ការៈឲ្យសាបសូន្យ ព្រោះអាស្រ័យខ្លួននាង ។ នាងពោលថា ល្អ លោកម្ចាស់ទាំងឡាយ រឿងនេះចូរជាភារៈរបស់នាងខ្ញុំ លោកម្ចាស់ទាំងឡាយកុំគិតឡើយ ហើយក៏ចៀសចេញទៅ ដណ្ដប់សំពត់មានពណ៌ដូចសត្វមេភ្លៀង មានគ្រឿងក្រអូប និងកម្រងផ្កាជាដើមក្នុងដៃ តម្រង់មុខឆ្ពោះវត្តជេតពន ទៅក្នុងសម័យជាទីស្ដាប់ធម្មកថា នៃអ្នកក្រុងសាវត្ថី ហើយចេញទៅអំពីវត្តជេតពនតាំងអំពីកាលនោះ ព្រោះសេចក្ដីដែលនាងជាអ្នកឆ្លាតក្នុងមាយារបស់ស្ត្រី កាលអ្នកដទៃសួរនាងថា នាងទៅទីណាក្នុងវេលានេះ ? ក៏ពោលថា ប្រយោជន៍អ្វីរបស់ពួកលោក ដោយ

ទីដែលខ្ញុំទៅ សំរាកក្នុងវត្តរបស់តិរ្ថិយជិតវត្តជេតពន កាលមនុស្សជា ឧបាសកចេញអំពីព្រះនគរអំពីព្រលឹម ដោយសង្ឃឹមថា នឹងថ្វាយបង្គំ ព្រះមានជោគ នាងធ្វើដូចជានៅក្នុងវត្តជេតពនចូលទៅកាន់ព្រះនគរ កាលជនជាឧបាសកសួរថា នាងនៅទីណា ? ក៏ពោលថា ប្រយោជន៍អ្វី របស់ពួកលោក ដោយទីដែលខ្ញុំនៅ ដោយកាលកន្លងទៅ ២-៣ ខែ កាលត្រូវគេសួរ ក៏ពោលថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណ- គោតម ក្នុងវត្តជេតពនញុំាងសេចក្តីសង្ស័យដល់ពួកបុថុជ្ជនថា រឿងនុ៎ះ ពិត ឬមិនពិតហ្ន៎ ? ដោយកាលកន្លងទៅ ៣-៤ ខែ យកកំណាត់សំពត់ ចងពោះ សម្តែងភេទរបស់ស្រ្តីមានគភ៌ ឲ្យពួកជនអន្ធពាលប្រកាន់ ជឿថា គភ៌កើតឡើងព្រោះអាស្រ័យព្រះសមណគោតម ដោយកាល កន្លងទៅ ៨-៩ ខែ ចងដុំឈើ មូលត្រង់ពោះ ដណ្តប់សំពត់ពីលើយក ឆ្អឹងគោវាយដៃនិងជើង សម្តែងអាការផើម មានឥន្រ្ទិយមិនស្រស់បស់ កាលព្រះតថាគតប្រថាប់គង់សម្តែងធម៌លើធម្មាសនៈ ដែលគេតាក់ តែងហើយ ក្នុងវេលារសៀល ទៅកាន់ធម្មសភា ឈរខាងមុខព្រះភក្ត្រ ហើយរបស់ព្រះសាស្តាហើយ ពោលថា មហាសមណៈ ព្រះអង្គល្អ

តែសម្ដែងធម៌ដល់មហាជនប៉ុណ្ណោះ សំឡេងរបស់ព្រះអង្គពីរោះ ព្រះឱស្ឋរបស់ព្រះអង្គស្និទ្ធ ចំណែកខ្ញុំម្ចាស់អាស្រ័យព្រះអង្គ មានគភ៌គ្រប់កំណត់ហើយ ព្រះអង្គមិនទ្រង់ជ្រាបផ្ទះសម្រាប់ប្រសូត មិនជ្រាបគ្រឿងបរិហារគភ៌ មានទឹកដោះថ្លា និងទឹកឃ្មុំជាដើម បើទ្រង់មិនធ្វើខ្លួនឯងម្ដេចមិនត្រាស់ប្រាប់ព្រះបាទកោសល ឬអនាថបិណ្ឌិក ឬក៏នាងវិសាខា មហាឧបាសិកាណាមួយ បណ្ដាឧបដ្ឋាកទាំងឡាយថា អ្នកចូរធ្វើកិច្ចដែលគួរធ្វើដល់នាងចិញ្ចមាណវិកានេះ ព្រះអង្គទ្រង់ដឹងតែអភិរម្យប៉ុណ្ណោះ មិនទ្រង់ដឹងការរក្សាគភ៌ ( នាងចិញ្ចមាណវិកា ) ដូចព្យាយាមចាប់ដុំលាមក គប់មណ្ឌលព្រះចន្ទដូច្នោះ បានជេរព្រះតថាគតកណ្ដាលបរិស័ទ ។ ព្រះតថាគត ទ្រង់ផ្អាកធម្មកថាហើយ ទ្រង់បន្លឺសម្រែកសីហៈថា ប្អូនស្រី ពាក្យដែលនាងពោលហើយ នឹងពិត ឬមិនពិត មានតែតថាគត និងនាងប៉ុណ្ណោះដឹង ។

នាងចិញ្ចមាណវិកា. ត្រូវហើយ មហាសមណៈ រឿងនុ៎ះកើតឡើងដោយព្រះអង្គ និងខ្ញុំម្ចាស់ជាអ្នកជ្រាប ។

ខណៈនោះ អាសនៈរបស់សក្កទេវរាជ សម្ដែងអាការក្ដៅ ។

ព្រះអង្គពិចារណាមើលក៏ជ្រាបថា នាងចិញ្ចមាណវិកា ជេរព្រះតថាគត ដោយពាក្យមិនពិត ហើយទ្រង់តម្រិះទៀតថា យើងនឹងជម្រះរឿងនេះ ឲ្យហ្មត់ចត់ ទើបស្តេចមកជាមួយនឹងទេវបុត្រ ៤ អង្គ ។ ទេវបុត្រទាំងឡាយ ក្លែងជាកណ្តុរខាំខ្សែ ដែលចងដុំឈើមូល ដោយខាំតែម្តងប៉ុណ្ណោះ ។ ខ្យល់ផាត់ផ្ទាំងសំពត់ដណ្តប់ឡើង ។ ឈើមូលរបូតធ្លាក់ចុះលើខ្នងជើងរបស់នាងចិញ្ចមាណវិកានោះ ។ចុងជើងទាំងពីរខាងបានបែក ។ មនុស្សទាំងឡាយនិយាយថា នែនាងកាឡកណ្ណី នាងជេរព្រះសម្មាសម្ពុទ្ធ ហើយបានស្តោះទឹកមាត់លើក្បាល មានដៃកាន់ដុំដីនិងដំបង បណ្តេញនាងចេញចាកវត្តជេតពន ។

ពេលដែលនាងទៅផុតគន្លងព្រះនេត្រ របស់ព្រះតថាគតទៅមហាផែនដីបែករហែកចំហមាត់ចាំ ។ អណ្តាតភ្លើងតាំងឡើងអំពីអវិចីនរក ។ នាងចិញ្ចមាណវិកានោះ ទៅកើតក្នុងអវិចី ដូចជាដណ្តប់សំពត់កម្ពលដែលត្រកូលឲ្យ ។ លាភសក្ការៈរបស់ពួកតិរ្ថិយបានសាបសូន្យ ។ ត្រឡប់ជាចម្រើនដល់ព្រះសាស្តាប្រមាណក្រៃលែង ។

ក្នុងថ្ងៃព្រឹកឡើង ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមាន

អាយុទាំងឡាយ នាងចិញ្ចមាណវិកា ជេរព្រះសម្ពុទ្ធជាអគ្គទក្ខិណេយ្យ អ្នកមានគុណប្រមាណមិនបានយ៉ាងនេះ ដោយពាក្យមិនពិត ទើបដល់មហាវិនាស ។ ព្រះសាស្តា ស្តេចមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យពេចន៍អ្វី ? កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយពាក្យឈ្មោះនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ ក្នុងកាលមុន នាងចិញ្ចមាណវិកានោះ ក៏ជេរតថាគតដោយពាក្យមិនពិត ដល់សេចក្តីវិនាសដូចគ្នាដែរ ហើយត្រាស់មហាបទុមជាតក ក្នុងទ្វាទសកនិបាតនេះ ឲ្យពិស្តារថា

អ្នកជាធំ មិនឃើញទោសតូច-ធំរបស់អ្នកដទៃ ដោយប្រការទាំងពួងហើយ មិនទាន់ពិចារណាខ្លួនឯង មិនគប្បីដាក់អាជ្ញា ។

( ព្រះអង្គត្រាស់ថា ) បានឮថា ក្នុងកាលនោះ នាងចិញ្ចមាណវិកានោះ ជាអ្នករួមស្វាមីរបស់ព្រះមាតានៃព្រះពោធិសត្វ ព្រះនាមថាមហាបទុមកុមារ ជាអគ្គមហេសីរបស់ព្រះរាជា បបួលព្រះមហាសត្វដោយអសទ្ធម្ម មិនបានការយល់ព្រមរបស់ព្រះពោធិសត្វនុ៎ះហើយ ធ្វើប្រការប្លែកក្នុងខ្លួនដោយខ្លួនឯង សម្តែងអាការជាឈឺ ក្រាបទូល

ដល់ព្រះរាជាថា ព្រះឱរសរបស់ព្រះអង្គ ធ្វើឲ្យខ្ញុំម្ចាស់ដែលមិនប្រាថ្នាដល់ប្រការបែបនេះ ។ ព្រះរាជាទ្រង់ខ្ញាល់ទម្លាក់ព្រះពោធិសត្វទៅក្នុងជ្រោះ ដែលសម្រាប់ទម្លាក់ចោរ ។

គ្រានោះ ទេវតាដែលអាស្រ័យនៅត្រង់ផ្ទៃនៃភ្នំ ( ជ្រោះ ) ទទួលព្រះមហាសត្វនោះហើយ ឲ្យប្រតិស្ឋាននៅក្នុងផ្ទៃពាររបស់ស្ដេចនាគ ។ ស្ដេចនាគនាំព្រះមហាសត្វនោះទៅកាន់ភពនាគ ទ្រង់រាប់អានដោយរាជសម្បត្តិពាក់កណ្ដាល ។ ព្រះមហាសត្វនោះនៅក្នុងភពនាគអស់មួយឆ្នាំ ប្រាថ្នានឹងបួស ក៏មកកាន់ហិមវន្តប្រទេស បួសហើយ ក៏បានញុំាងឈាន និងអភិញ្ញាឲ្យកើតឡើង ។

តមក ព្រានព្រៃម្នាក់ឃើញព្រះមហាសត្វនោះក៏បានក្រាបទូលដល់ព្រះរាជា ។ ព្រះរាជា ស្ដេចទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះហើយ មានបដិសណ្ឋារៈដែលព្រះពោធិសត្វនោះធ្វើហើយ ទ្រង់បានជ្រាបព្រឹត្តិហេតុនោះទាំងអស់ ទ្រង់បានអញ្ជើញព្រះមហាសត្វដោយរាជសម្បត្តិ ព្រះមហាសត្វនោះ ថ្វាយព្រះឱវាទថាកិច្ចដោយរាជសម្បត្តិរបស់ខ្ញុំព្រះអង្គមិនមាន សូមព្រះអង្គកុំឲ្យរាជធម៌ ១០

ប្រការកម្រើក ទ្រង់លះអគតិចេញហើយ សោយរាជ្យដោយធម៌ចុះហើយ ស្តេចក្រោកពីអាសនៈ ទ្រង់ព្រះកន្សែង ស្តេចទៅកាន់ព្រះនគរ ត្រាស់សួរអមាត្យទាំងឡាយពាក់កណ្តាលផ្លូវថា យើងដល់ការព្រាត់ប្រាសចាកបុត្រ ដែលសម្បូណ៌ដោយអាចារយ៉ាងនេះ ព្រោះអាស្រ័យអ្នកណា ?

អមាត្យ. បពិត្រព្រះអង្គ ព្រោះអាស្រ័យអគ្គមហេសី ។

ព្រះរាជាត្រាស់ឲ្យចាប់ព្រះអគ្គមហេសីនោះ ឲ្យមានជើងឡើងលើ ទម្លាក់ទៅក្នុងជ្រោះសម្រាប់ទម្លាក់ចោរ ស្តេចចូលទៅកាន់ព្រះនគរ សោយរាជសម្បត្តិដោយធម៌ ។ ព្រះមហាបទុមកុមារក្នុងកាលនោះ បានមកជាព្រះមហាសត្វ ស្ត្រីរួមស្វាមីរបស់ព្រះមាតា បានមកជានាងចិញ្ចមាណវិកា ។

ព្រះសាស្តា ទ្រង់ប្រកាសសេចក្តីនេះហើយ មានព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលលះពាក្យសត្យ ដែលជាធម៌ឯកហើយ តាំងនៅក្នុងមុសាវាទ អ្នកមានបរលោកលះហើយ មិនធ្វើបាបកម្មមិនមានឡើយ ហើយត្រាស់ព្រះគាថានេះថា

ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ

**វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។**

បុគ្គលប្រព្រឹត្តកន្លង ( ពាក្យសច្ចៈ ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថាមិនធ្វើអំពើបាប មិនមែនឡើយ ។

បណ្តាបទទាំងនោះ បទថា **ឯកំ ធម្មំ** គឺនូវពាក្យសត្យ ។

បទថា **មុសាវាទិស្ស** សេចក្តីថា បណ្តាពាក្យនិយាយទាំង ១០ ពាក្យសត្យសូម្បីតែ ១ មិនមានដល់អ្នកណា អ្នកបែបនេះ ឈ្មោះថាអ្នកនិយាយតែពាក្យកុហក ។ បាទព្រះគាថាថា **វិតិណ្ណបរលោកស្ស** បានដល់ អ្នកមានបរលោកដែលលះចោលហើយ ក៏បុគ្គលបែបនេះរមែងមិនប្រទះសម្បត្តិទាំង ៣ នេះ គឺមនុស្សសម្បត្តិ ទេពសម្បត្តិ និព្វានសម្បត្តិក្នុងអវសានឡើយ ។ ពីរបទថា **នត្ថិ បាបំ** សេចក្តីថា សេចក្តីសង្ស័យថា បាបឈ្មោះនេះ ដែលបុគ្គលនោះ គឺអ្នកបែបនោះមិនគប្បីធ្វើ មិនមានសោះឡើយ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន សម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

# រឿងទេវទត្តភិក្ខុត្រូវធរណីស្រូប

មានរឿងតំណាលថា ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់នូវការដែលទេវទត្តភិក្ខុទៅកាន់គយាសីសប្រទេសនោះហើយ ទ្រង់ក៏បញ្ជូនព្រះអគ្គសាវកនោះទៅ ដើម្បីប្រយោជន៍ដល់ការនាំភិក្ខុទាំងនោះមកវិញ ។ ព្រះអគ្គសាវកទាំងពីរនោះ ទៅកាន់ទីនោះហើយ ប្រៀនប្រដៅដោយអនុសាសនីផង ដោយអាទេសនាបាដិហារ្យផង និងឥទ្ធិប្បាដិហារ្យផង ញុំាងភិក្ខុទាំងនោះឲ្យផឹកអមតធម៌ ហើយបាននាំមកតាមផ្លូវអាកាស ។

ចំណែកកោកាលិកភិក្ខុពោលថា នែទេវទត្ត លោកចូរក្រោកឡើងមក ព្រះសារីបុត្រ និងព្រះមោគ្គល្លាន នាំយកភិក្ខុទាំងនោះទៅអស់ហើយ ខ្ញុំបានពោលប្រាប់លោកហើយថា នែអាវុសោ លោកកុំទុកចិត្តព្រះសារីបុត្រ និងព្រះមោគ្គល្លានឲ្យសោះ ព្រោះព្រះសារីបុត្រ និងព្រះមោគ្គល្លាន មានសេចក្ដីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាលាមក ដូច្នេះហើយ យកជង្គង់អុកចំដើមទ្រូងទេវទត្តភិក្ខុ ។ លោហិត

ក៏បានហូរចេញមកពីមាត់របស់ទេវទត្តភិក្ខុ ។

ចំណែកពួកភិក្ខុឃើញព្រះសារីបុត្រ និងព្រះមោគ្គល្លាន មានភិក្ខុសង្ឃចោមរោមមកតាមអាកាសហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្រ និងព្រះមោគ្គល្លាន ក្នុងកាលទៅ មានតែពីរអង្គប៉ុណ្ណោះ ឥឡូវនេះ មានបរិវារច្រើនមកជាមួយ ល្អណាស់ ។

ព្រះមានជោគត្រាស់ប្រាប់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលដែលគេកើតនៅក្នុងកំណើតជាសត្តិរច្ឆាន បុត្ររបស់តថាគត បានមកកាន់សម្នាក់របស់តថាគត ក៏រមែងល្អយ៉ាងនេះដូចគ្នាដែរ ដូច្នេះហើយ បានត្រាស់ព្រះជាតកដូចនេះថា

*សេចក្តីចម្រើនតែងមានដល់អ្នកមានសីលទាំងឡាយ អ្នកប្រព្រឹត្តបដិសណ្ឋារៈ នាងចូរមើលម្រឹគ ឈ្មោះលក្ខណៈ កំពុងដើរមកដែលពួកញាតិហែហមហើយនាងឃើញម្រឹគឈ្មោះកាឡៈនេះដែលសាបសូន្យចាកពួកញាតិ កំពុងដើរមកឬទេ ?*

ដូច្នេះជាដើម កាលពួកភិក្ខុក្រាបទូលតទៅទៀតថា បពិត្រព្រះ

អង្គដ៏ចម្រើន បានឮថា ទេវទត្តភិក្ខុបានឲ្យព្រះអគ្គសាវកទាំងពីរគង់សង ខាងហើយ ពោលថា នៃសារីបុត្រ និងមោគ្គល្លាន អ្នកចុះសម្តែងធម៌ដល់ ភិក្ខុទាំងឡាយ យើងសម្រាកបន្តិចសិន ធ្វើអាកប្បកិរិយាតាមព្រះអង្គ គ្រានោះ ព្រះលោកនាថទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែន តែឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តភិក្ខុនេះ ក៏ព្យាយាមធ្វើតាម កិរិយារបស់តថាគតដែរ តែមិនអាច ដូច្នោះហើយ ព្រះអង្គទ្រង់ត្រាស់ នទីចរកាកជាតក ថា

នៃក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្លាប ដែលពោលពាក្យ ពីរោះ មានផ្នត់.កដូចជាផ្នត់.កនៃក្ងោក ជាក្អែកគោក ឈ្មោះសវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ ?

ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្លាប អ្នកត្រាច់ទៅក្នុងទឹក និង លើគោក បានបរិភោគត្រីស្រស់ ជានិច្ចនោះ ត្រូវសារាយព័ទ្ធព័ន្ធស្លាប់ ទៅហើយ ។

ដូច្នេះជាដើម សូម្បីថ្ងៃដទៃៗ ទៀត ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ប្រារព្ធ កថាដូច្នេះដែរ ត្រាស់ព្រះជាតកទាំងឡាយជាដើមយ៉ាងនេះថា

ម្នាលសេះឈ្មោះខទិរវនិយៈដ៏ចម្រើន អំបែងក្បាលបែកដោយការប្រហារតែម្តង ពួដ៏ដើមឈើណា ដើមនេះ មានស្លឹកល្អិត ប្រកបដោយបន្លា តើជាឈើឈ្មោះអ្វី ?

ខួរក្បាលរបស់អ្នកធ្លាយចេញផង លលាដ៏ក្បាលរបស់អ្នកបែកធ្លាយផង ឆ្អឹងជំនីរទាំងអស់របស់អ្នក ដំរីបំបាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត ។

ទ្រង់ប្រារព្ធកថាថា ភិក្ខុទេវទត្តជាមនុស្សអកតញ្ញូ ទើបទ្រង់ត្រាស់ព្រះជាតកមានជាអាទិទៀតថា

កម្លាំងរបស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើងត្រូវបានសាច់បន្តិចបន្តួចខ្លះ ។

អ្នកចូរទៅតាមចន្លោះនៃធ្មេញរបស់ខ្ញុំ ដែលជាអ្នកស៊ី ( សាច់ )

និងឈាម ធ្វើនូវអំពើអាក្រក់ទាំងឡាយជានិច្ច រស់នៅដោយសាច់ណា សាច់នោះ មានច្រើន ។

ទ្រង់ប្រារព្ធការព្យាយាមដើម្បីនឹងសម្លាប់ ( ព្រះអង្គ ) របស់ភិក្ខុទេវទត្តនោះទៀត ត្រាស់ព្រះជាតកទាំងឡាយ មានជាអាទិយ៉ាងនេះថា

ម្នាលដើមចំបក់ទាំងឡាយ អ្នកជម្រុះផ្លែមកដោយហេតុណា ហេតុនោះ អញជាអ្នកប្រើ បានដឹងហើយ អញនឹងទៅកាន់ដើមចំបក់ឯទៀត ផ្លែរបស់អ្នកអញមិនពេញចិត្តទេ ។

ភិក្ខុទេវទត្តសាបសូន្យហើយ ចាកវត្ថុ ២ ប្រការ គឺចាកលាភ និងសក្ការៈ ១ ប្រការ ចាកសាមញ្ញផល ១ ប្រការ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយមិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុទេវទត្តក៏សាបសូន្យហើយដែរ ។ ដូច្នេះហើយ ទ្រង់ត្រាស់ព្រះជាតកទាំងឡាយយ៉ាងនេះថា

ភ្នែកទាំងឡាយ បែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះក៏មានក្នុងផ្ទះនៃស្ត្រីជាសម្លាញ់ ការងារទាំងឡាយ ខូចទាំងសងខាង គឺ

ក្នុងទឹកផង លើគោកផង ។

ព្រះមានជោគ កាលគង់នៅក្នុងក្រុងរាជគ្រឹះ ត្រាស់ព្រះជាតកជាច្រើនដោយប្រការយ៉ាងនោះហើយ ស្តេចយាងចេញពីក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថី ទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ។

ចំណែកទេវទត្តភិក្ខុមានជំងឺអស់ ៩ ខែ មានបំណងនឹងទៅគាល់ព្រះលោកនាថ ទើបប្រាប់ពួកសាវ័ករបស់ខ្លួនថា យើងប្រាថ្នានឹងទៅគាល់ព្រះសាស្តា អ្នកទាំងឡាយចូរនាំយើងទៅ កាលសាវ័កទាំងនោះឆ្លើយថា ក្នុងកាលដែលលោកនៅជាអ្នកអាចបានប្រព្រឹត្តជាអ្នកមានពៀរនឹងព្រះសាស្តា ខ្ញុំម្ចាស់ទាំងឡាយ មិនអាចនាំលោកទៅកាន់សម្នាក់ព្រះសាស្តាទេ ទើបពោលថា លោកទាំងឡាយ កុំឲ្យយើងវិនាសឡើយ យើងបានចងអាឃាតជាមួយនឹងព្រះអង្គមែន ប៉ុន្តែថា ព្រះបរមសាស្តាមិនចងគំនុំចំពោះយើង សូម្បីប្រមាណប៉ុនចុងសក់ក៏មិនមាន ទ្រង់មានព្រះទ័យដ៏ស្មើ ក្នុងបុគ្គលទូទៅ គឺក្នុងនាយខ្មាន់ធ្នូ ក្នុងយើង ក្នុងចោរអង្គុលិមាល៍ ក្នុងដីរីធនបាល និងក្នុងរាហុល ។

ព្រោះដូច្នោះ ទើបភិក្ខុទេវទត្តអង្វរហើយ អង្វរទៀតថា លោកទាំងឡាយ ចូរនាំយើងទៅគាល់ព្រះសាស្ដាផង ។ពេលនោះ ទើបសាវ័កទាំងនោះ នាំទេវទត្តភិក្ខុនោះ ចេញទៅដោយគ្រែតូច ភិក្ខុទាំងឡាយបានឮដំណឹងថា ទេវទត្តភិក្ខុមកហើយ ទើបក្រាបទូលព្រះមានជោគថា បពិត្រព្រះអង្គដ៏ចម្រើន បានឮដំណឹងថា ភិក្ខុទេវទត្តមកដើម្បីប្រយោជន៍នឹងគាល់ព្រះអង្គ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តនោះនឹងមិនបានឃើញតថាគតទេ ។ បានឮថា ពួកភិក្ខុទេវទត្តរមែងមិនបានឃើញព្រះពុទ្ធទៀត ចាប់ផ្ដើមពីកាលដែលខ្លួនសូមវត្ថុ ៥ ប្រការ សភាវៈនេះ រមែងជាធម្មតា ពួកភិក្ខុក្រាបទូលថា ទេវទត្តភិក្ខុមកដល់ទីឯណោះនិងទីឯណោះហើយ ។

ព្រះសាស្ដាត្រាស់ថា ទេវទត្តចូរធ្វើអំពើឯណា ដែលខ្លួនប្រាថ្នាចុះ (តែទោះជាយ៉ាងណាក៏ដោយ) គេក៏នឹងមិនបានឃើញតថាគតដែរ ។

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តភិក្ខុមកដល់ទីប្រមាណមួយយោជន៍អំពីទីនេះហើយ ហើយទូលតទៅទៀត

ថា បពិត្រព្រះអង្គដ៏ចម្រើន នៅសល់កន្ទះយោជន៍ទៀត មកដល់ហើយ នៅសល់មួយគាវុតទៀត មកដល់ហើយ បពិត្រព្រះអង្គដ៏ចម្រើន មកដល់ទីជិតស្រះបោក្ខរណី ក្បែរវត្តជេតពនហើយ ។

ព្រះមានព្រះភាគត្រាស់ថា សុប្បីទេវទត្តនឹងចូលមកខាងក្នុងវត្តជេតពនសោត គេក៏នឹងមិនបានឃើញតថាគតដែរ ។

ពួកសាវកនាំទេវទត្តភិក្ខុមកហើយ ដាក់គ្រែចុះ នៅត្រង់មាត់ស្រះបោក្ខរណី ដែលនៅក្បែរវត្តជេតពន ក៏នាំគ្នាចុះទៅងូតទឹក ក្នុងស្រះបោក្ខរណី ។

សុប្បីភិក្ខុទេវទត្តក៏ក្រោកឡើងអំពីគ្រែ ហើយអង្គុយដាក់ជើងទាំងពីរលើផែនដី ជើងទាំងពីរនោះ ក៏លិចចុះទៅក្នុងផែនដី លោកក៏លិចចុះទៅក្នុងផែនដីដោយលំដាប់គឺត្រឹម.កជើង ត្រឹមជង្គង់ ត្រឹមចង្កេះ ត្រឹមដោះ រហូតដល់ត្រឹម.ក ក្នុងពេលដែលចង្កាតាំងនៅលើផែនដី បានពោលគាថានេះថា

ខ្ញុំព្រះអង្គសូមដល់ព្រះលោកនាថនោះ ជាបុគ្គលដ៏ប្រសើរ ជា

ទេវតាកន្ទងបង់នូវទេវតា ជាសារថី ជាអ្នកទូន្មាននូវនរជន មានចក្ខុ ដោយជុំវិញ មានព្រះលក្ខណៈមួយៗ កើតដោយបុណ្យទាំងរយជា ជាទីពឹង ដោយធ្មឹងទាំងនេះ ព្រមទាំងជីវិត ។

បានឮថា ព្រះតថាគតទ្រង់ឃើញនូវហេតុនេះ ទើបទ្រង់អនុញ្ញាត ឲ្យទេវទត្តបួស ។ ប្រសិនបើទេវទត្តនោះ មិនបានបួសទេ នៅជាគ្រហស្ថ វិញ នឹងបានធ្វើនូវកម្មធ្ងន់ មិនអាចជាបច្ច័យនៃកពតទៅបាន លុះបួស ហើយ នឹងធ្វើកម្មធ្ងន់ ក៏ពិតមែនហើយ ប៉ុន្តែក៏អាចដើម្បីនឹងធ្វើបច្ច័យ នៃកពតទៅបាន ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគ ទ្រង់ក៏អនុញ្ញាត ឲ្យលោកបួស ។

ពិតណាស់ ទេវទត្តភិក្ខុនោះ នឹងបានជាព្រះបច្ចេកពុទ្ធនាមថា **អដ្ឋិស្សរៈ** ក្នុងទីបំផុតមួយសែនកប្ប រាប់ពីកប្បនេះទៅ ទេវទត្តភិក្ខុ នោះ លិចចូលទៅក្នុងផែនដីហើយ កើតនៅក្នុងអវិចីមហានរក ហើយ លោកជាអ្នកកម្រើកមិនបាន ត្រូវភ្លើងឆេះ ព្រោះជាអ្នកប្រទូស្តចំពោះ ព្រះពុទ្ធអ្នកមិនញាប់ញ័រ សរីរៈរបស់លោក កម្ពស់ប្រមាណមួយរយ

យោជន៍ កើតក្នុងអវិចីមហានរក ដែលមានទំហំ ៣០០ យោជន៍ ក្បាលស៊កចូលទៅកាន់ផែនដែកខាងលើ រហូតដល់គុម្ពត្រចៀក ជើងទាំងពីរលិចចុះទៅក្នុងផែនដីដែក ខាងក្រោយរហូតដល់.កជើង លំពែងដែកមានប្រមាណប៉ុនដើមត្នោតខ្នាតធំ ចេញអំពីជញ្ជាំងខាងក្រោយចាក់ត្រង់កណ្តាលខ្នង ធ្លុះចេញមកតាមទ្រូង កប់ទៅនឹងជញ្ជាំងខាងមុខលំពែងមួយទៀត ចេញអំពីជញ្ជាំងខាងស្តាំ ចាក់ទម្លាយនូវចំហៀងខាងស្តាំ ធ្លុះចេញទៅខាងឆ្វេង ចូលទៅកាន់ជញ្ជាំងខាងឆ្វេង ។ មួយទៀតចេញអំពីក្បឿងខាងលើចាក់ទម្លាយនូវក្បាល ចេញទៅតាមចំណែកខាងក្រោម កប់ចូលទៅផែនដី ជាវិការនៃដែក ។ ទេវទត្តភិក្ខុនោះ ជាអ្នកកម្រើកមិនបាន ដែលភ្លើងឆេះក្នុងអវិចីនោះ ដោយប្រការយ៉ាងនេះ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា មកកាន់ទីប្រមាណប៉ុណ្ណេះ មិនទាន់បានគាល់ព្រះសាស្តាផង ក៏លិចចុះទៅហើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តប្រព្រឹត្តខុសចំពោះតថាគតហើយ លិចចុះទៅកាន់ផែនដី ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុន លោក

ក៏លិចចុះហើយផងដែរ ដើម្បីនឹងទ្រង់សម្តែងនូវការៈនៃទេវទត្តភិក្ខុនោះ ជាអ្នកវង្វេងផ្លូវ ដែលព្រះអង្គលួងលោមឲ្យធូរចិត្ត ហើយលើកឡើងដាក់លើខ្នងរបស់ព្រះអង្គ ហើយឲ្យដល់ទីក្សេម ហើយត្រឡប់មកកាន់ភ្នកទាំងឡាយ ដល់ទៅ ៣ ដង យ៉ាងនេះ គឺខាងចុង កណ្តាល និងគល់ ក្នុងវារៈទី ៣ កាលឈានកន្ទងចក្ខុរបស់មហាបុរសហើយ ក៏លិចចុះទៅក្នុងផែនដី ក្នុងកាលដែលព្រះអង្គជាស្តេចដំរី ទើបត្រាស់ព្រះជាតកយ៉ាងនេះថា

ប្រសិនបើគេឲ្យផែនដីទាំងមូល ដល់បុរសអកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញ៉ាំងបុរសអកតញ្ញូនោះ ឲ្យត្រេកអរបានឡើយ ។

កាលកថាតាំងឡើងហើយ ដូច្នោះទៀត ព្រពុទ្ធអង្គទ្រង់ត្រាស់ខន្តិវាទីជាតក ដើម្បីទ្រង់សម្តែងដល់ការដែលទេវទត្តភិក្ខុនោះ ជាព្រះបាទកលាពុ ប្រព្រឹត្តខុសចំពោះព្រះអង្គ ដែលជា ខន្តិវាទីតាបស ហើយលិចចូលទៅក្នុងផែនដី និង ចុល្លធម្មបាលជាតក ដើម្បីទ្រង់សម្តែងការ

ដែលទេវទត្តភិក្ខុនេះ បានជា **ព្រះបាទមហាបតាប** ប្រព្រឹត្តខុសចំពោះព្រះអង្គ កាលដែលនៅជា **ធម្មបាល** ហើយលិចចូលទៅក្នុងផែនដី ។ លុះទេវទត្តលិចចូលទៅក្នុងផែនដីហើយ មហាជនក៏រីករាយ ត្រេកអរញុំាងគ្នានឹងគ្នា ឲ្យលើកឡើងនូវទង់ជ័យ ទង់បដា ព្រមទាំងដើមចេកទាំងឡាយ តម្កល់ផ្តាំងទឹកដែលពេញហើយ លេងនូវមហោស្រពដ៏ធំដោយប្រារព្ធថា **ជាលាភរបស់ពួកយើងហើយហ្ន៎** ពួកភិក្ខុក្រាបទូលសេចក្តីនោះដល់ព្រះសាស្តា ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយកាលទេវទត្តស្លាប់ហើយ មហាជនរីករាយ ត្រេកអរ មិនមែនត្រឹមតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏រីករាយ ត្រេកអរហើយដែរ ។ ដើម្បីនឹងទ្រង់សម្តែងការដែលមហាជន ជាអ្នកត្រេកអរក្នុងកាលដែលព្រះរាជា **ព្រះនាមបិង្គលៈ** ក្នុងនគរពារាណសី ដ៏កាចអាក្រក់ មិនជាទីស្រឡាញ់នៃជនទូទៅ សោយទិវង្គតហើយ ទើបត្រាស់បិង្គលជាតកយ៉ាងនេះថា

ជនទាំងអស់ ត្រូវស្តេចបិង្គលៈបៀតបៀន កាលស្តេចនោះ

សោយទិវង្គតហើយ ជនទាំងឡាយ រមែងបាននូវសេចក្តីត្រេកអរ ម្នាល ទ្វារបាល ស្តេចអកណ្ហនេត្រ ជាទីស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វី បានជាអ្នកយំ ?

ទ្វារបាលបុរសពោលថា

ព្រះរាជាមានព្រះនេត្រមិនខ្មៅ មិនមែនជាទីស្រឡាញ់របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះ ត្រឡប់មកវិញ ព្រោះស្តេចនោះ ទៅអំពីមនុស្ស លោកនេះ គប្បីបៀតបៀននូវមច្ចុរាជ មច្ចុរាជនោះ ក្រែងត្រូវស្តេច បិង្គលៈបៀតបៀនហើយ គប្បីនាំមកទុកក្នុងមនុស្សលោកនេះវិញ ។

ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ទេវទត្តភិក្ខុទៅកើតក្នុងទីណា ? ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តទៅកើតក្នុងអវិចីមហានរក ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តភិក្ខុក្តៅក្រហាយក្នុង លោកនេះហើយ ទៅកើតក្នុងទីក្តៅក្រហាយដដែលទៀតឬ ?

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះហើយ

ក៏ជនទាំងឡាយ ទោះបីជាបព្វជិតក្តី គ្រហស្ថក្តី មានប្រក្រតីរស់នៅដោយសេចក្តីប្រមាទ រមែងក្តៅក្រហាយ ក្នុងលោកទាំងពីរពិតប្រាកដណាស់ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ឥធ តប្បតិ បេច្ច តប្បតិ     បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ     ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

បណ្តាបទទាំងនោះ ពីរបទថា ឥធ តប្បតិ សេចក្តីថា រមែងក្តៅក្រហាយក្នុងលោកនេះ ដោយត្រឹមតែទោមនស្ស ដោយការក្តៅក្រហាយព្រោះកម្ម ។ បទថា បេច្ច សេចក្តីថា ក្នុងលោកខាងមុខ រមែងក្តៅក្រហាយព្រោះទុក្ខដ៏យ៉ាងក្រៃលែង ដោយការក្តៅក្រហាយព្រោះវិបាក ។ បទថា បាបការី សេចក្តីថា អ្នកធ្វើបាប មានប្រការផ្សេងៗ ។ បទថា ឧភយត្ថ

សេចក្តីថា ឈ្មោះថា រមែងក្តៅក្រហាយក្នុងលោកទាំងពីរ ដោយការក្តៅក្រហាយ មានប្រការដូចពោលមកហើយនេះ ។ ពីរបទថា **បាបំ មេ** សេចក្តីថា អ្នកមានប្រក្រតីធ្វើបាបនោះ កាលក្តៅក្រហាយ ដោយការក្តៅក្រហាយ ព្រោះកម្ម ឈ្មោះថា រមែងក្តៅក្រហាយ ដោយគិតថា កម្មអាក្រក់ យើងធ្វើហើយ សេចក្តីក្តៅក្រហាយនោះ មានប្រមាណតិចតួចទេ តែកាលការក្តៅក្រហាយ ព្រោះវិបាក ទៅកាន់ទុគ្គតិហើយ រមែងក្តៅក្រហាយយ៉ាងក្រៃលែង គឺរមែងក្តៅក្រហាយដ៏លើសលុប ដោយការក្តៅក្រហាយដ៏អាក្រក់ក្រៃលែង ។

ក្នុងកាលចប់ព្រះគាថានេះ ជនជាច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ទេសនានេះបានជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។ល។

# ប្រវត្តិរាជិការាម

ក្រោយអំពីការត្រាស់ដឹងហើយ ព្រះសម្មាសម្ពុទ្ធនៃយើងទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ព្រះអង្គយាងប្រោសសត្វគ្រប់ៗ ទីកន្លែង ទ្រង់ញ៉ាំងព្រះរាជា សេដ្ឋី គហបតី និងមហាជនឲ្យជ្រះថ្លាហើយ លាភសក្ការៈ និងគ្រឿងបូជា ក៏បានកើតឡើងចំពោះព្រះមានព្រះភាគ ឬព្រះពុទ្ធសាសនាដ៏ច្រើនសន្ធឹកសន្ធាប់ ។ លាភសក្ការៈរបស់ពួកនិគ្រន្ថក៏អន់ថយទៅ ដូចជាពន្លឺអំពិលអំពេក កាលព្រះអាទិត្យរះឡើង ដូច្នោះ ។

សម័យនោះឯង ពួកនិគ្រន្ថទាំងឡាយ ក៏មកប្រជុំគ្នា ដើម្បីរកមធ្យោបាយធ្វើយ៉ាងណា ឲ្យព្រះពុទ្ធសាសនាអាប់ឱនសាបសូន្យទៅ ។ បណ្ដាពួកនិគ្រន្ថទាំងនោះ និគ្រន្ថខ្លះពោលថា ត្រូវបញ្ជូនអ្នកដែលមានបញ្ញាច្រើនទៅ ដើម្បីលើកវាទៈជាមួយព្រះសមណគោតម ឬសាវករបស់ព្រះសមណគោតម ទើបជាការល្អ ព្រោះថា កាលបើព្រះសាស្ដា ឬសាវករបស់ព្រះសាស្ដាចាញ់យើងដោយការលើកវាទៈហើយ ព្រះ

ពុទ្ធសាសនានឹងអាប់ឱនទៅឯង និគ្រន្ថខ្លះពោលថា ព្រះសមណគោតមក្តី សាវ័ករបស់ព្រះសមណគោតមក្តី ចេះនូវមន្តបង្វែរចិត្ត និងមន្តធ្វើឲ្យលាភសក្ការៈកើតឡើង មន្តទាំងនោះ ភិក្ខុទាំងឡាយតែងតែសូធ្យរៀនរាល់កន្លះខែម្តង ដោយបិទទ្វារយ៉ាងជិត សូម្បីតែសាមណេរក៏មិនឲ្យចូល ពួកយើងត្រូវតែបន្ទំខ្លួនបួស ហើយរៀនយកនូវមន្តនោះ ទើបលាភសក្ការៈកើតឡើងដល់ពួកយើងវិញ ។ ពួកនិគ្រន្ថទាំងនោះ តែងជួបប្រជុំគ្នាជារឿយៗ ហើយធ្វើតាមអ្វីដែលពួកគេបានគិត ប៉ុន្តែមិនអាចទទួលជោគជ័យឡើយ ។ ថ្ងៃមួយ ក៏បានជួបប្រជុំគ្នាដូចសព្វមួយដង ពេលនោះមាននិគ្រន្ថម្នាក់ បានឲ្យយោបល់ថា ទីកដីនៃវត្តជេតពន គឺជាទីកដីជ័យភូមិ ពួកយើងត្រូវធ្វើអារាមនៅជិតទីនោះ ទើបលាភសក្ការៈហូរចូលមកពួកយើងបាន ។ ខណៈនោះ និគ្រន្ថម្នាក់ទៀត ក៏ពោលឡើងថា យោបល់នេះពិតជាល្អណាស់ តែការទៅកសាងអារាមនៅក្បែរវត្តជេតពននោះ មិនជាការងាយស្រួលឡើយ ព្រោះរាជា.ជាអ្នកជ្រះថ្លាក្នុងព្រះសាសនា អាចថា មានទោសដល់ពួកយើងក៏ថាបាន ដូច្នេះ ពួកយើងត្រូវតែយកអ្វី

ទៅសូកព្រះរាជាជាមុនទើបបាន ។ ក្រោយពីស្រុះស្រួលមូលមតិគ្នា ហើយក៏រៃអង្គាសគ្នាបានប្រាក់ប្រមាណ ១សែនកហាបណៈ ដើម្បីយកទៅសូកព្រះរាជា គឺព្រះបាទបសេនទិកោសល ។ព្រះរាជាក្រោយពីបានសំណូកហើយ ក៏អនុញ្ញាតឲ្យធ្វើអារាមនៅជាប់វត្តជេតពននោះ ។

សម័យនោះ ព្រះមានជោគ ទ្រង់ហៅព្រះអានន្ទមកត្រាស់សួរថា ម្នាលអានន្ទ សំឡេងអ៊ឹកងរំពងម៉្លេះដូចជាសំឡេងរបស់ពួកអ្នកប្រមង់ជណ្តើមត្រីគ្នានៅក្បែរវត្តជេតពននេះ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកនិគ្រន្ថទាំងឡាយ នាំគ្នាកសាងអារាមនៅជាប់នឹងរបងវត្តជេតពននេះ ។ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ពួកនិគ្រន្ថទាំងនេះមិនមានសីលាចារវត្តជាមនុស្សដែលមិនសង្រួម បានធ្វើសំឡេងរំខានដល់សមណៈអ្នកត្រូវការនូវវិវេកធម៌ ហើយទើបទ្រង់បញ្ជូនព្រះព្រះមហាមោគ្គល្លានទៅជួបព្រះរាជា ដើម្បីឲ្យទ្រង់ជួយធ្វើអន្តរាគមន៍ក្នុងរឿងនេះ តែព្រះរាជាមិនយាងមកជួប ។ព្រះសាស្តាទ្រង់ជ្រាបរឿងនោះហើយ ក៏ទ្រង់បញ្ជូនព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានទៅម្តង ព្រះ

រាជាក៏មិនចេញមកជួបទៀត ។ព្រះមានជោគទ្រង់សង្វេគក្នុងហេតុនេះ ទើបទ្រង់ត្រាស់ព្យាករថា ព្រះរាជាអង្គនេះ ជាបុគ្គលមិនគោរពចំពោះគូនៃអគ្គសាវកទាំង ២ ដោយការមិនគោរពយ៉ាងនេះ បាបកម្មនេះនឹងធ្វើឲ្យព្រះរាជាមិនបានសោយទិវង្គតនៅលើរាជបល្ល័ង្កឡើយ នឹងត្រូវសោយទិវង្គតយ៉ាងអនាថាបំផុត ព្រះអង្គត្រាស់ដូច្នេះហើយ ព្រះអង្គក៏យាងទៅជួបព្រះរាជា ។ព្រះរាជាព្រមចេញមកជួយដោះស្រាយរឿងនេះ ដោយបញ្ឈប់ពួកនិគ្រន្ថ លែងឲ្យធ្វើអារាមនៅក្បែរវត្តជេតពន.តទៅទៀត ហើយព្រះរាជាទ្រង់សង្វេគក្នុងព្រះរាជហឫទ័យ ទើបចំណាយព្រះរាជទ្រព្យកសាងអារាមត្រង់ទីកន្លែងនោះ ដើម្បីជាប្រយោជន៍ដល់ភិក្ខុនី ដែលមានឈ្មោះថា **រាជិការាម** ។

សម័យក្រោយមក ព្រះរាជាទ្រង់ចូលទៅគាល់ព្រះមានព្រះភាគទ្រង់បោះព្រះពន្លានៅខាងក្រៅ ពេលនោះ **ទីឃការាយនៈ** ដោយមានគំនុំជាមួយព្រះរាជា ព្រោះកាលនោះ ព្រះរាជាជឿពាក្យញុះញង់អ្នកដទៃហើយរៀបចំល្បិចសម្លាប់ពន្ធុលសេនាបតី និងកូនរបស់គាត់ ៣២ នាក់

ដែលត្រូវជាអំនិងត្រូវជាបងប្អូនជាជីដូនមួយរបស់ខ្លួនស្លាប់គ្មានសល់ម្នាក់ ក៏ញុះញង់ព្រះរាជកុមារឈ្មោះ **វិឌូឌភៈ** ដែលត្រូវជាបុត្ររបស់ព្រះរាជា ឲ្យទ្រង់គ្រឿង **កកុធភណ្ឌ** ហើយលើកស្វេតច្ឆត្រឡើង ដើម្បីសោយរាជ្យជាព្រះរាជា ត្រង់ព្រះពន្លានោះ ជំបូងឡើយ វិឌូឌភៈមិនហ៊ានទេ ព្រោះគោរពក្នុងបិតា តែទីឃការាយនៈគំរាមថា បើព្រះអង្គមិនហ៊ានទេ ទូលបង្គំនឹងសោយរាជ្យក៏បាន ក៏យល់ព្រមលើកស្វេតច្ឆត្រឡើង ហើយសោយរាជ្យ លើករេហ៍ពលចូលទៅកាន់ព្រះនគរ ដោយបន្សល់ទុកស្រីស្នំតែម្នាក់ និងសេះមួយក្បាលឲ្យព្រះរាជាប៉ុណ្ណោះ ។ ព្រះរាជាចេញមកពីគាល់ព្រះអង្គវិញ ទ្រង់ជ្រាបហេតុការណ៍នេះ កើតទោមនស្សយ៉ាងខ្លាំង ទើបទ្រង់ឡើងផែលលើខ្នងសេះជាមួយនឹងស្រីស្នំ ឆ្ពោះទៅកាន់ក្រុងរាជគ្រឹះ ដើម្បីពឹងពាក់ព្រះបាទអជាតសត្តុដែលជាក្មួយឲ្យជួយដណ្តើមរាជ្យមកវិញ តែលុះទៅដល់នគររាជគ្រឹះ គាប់ជួនជាយប់យន្តល្ងាចព្រះនគរក៏បិទទ្វារ ទ្រង់ក៏យាងចូលទៅក្នុងសាលាជាមួយស្រីស្នំ ហើយថែមទាំងបានផ្ទុំលើភ្លៅស្រីស្នំនោះ ទាំងក្តីសោកសៅ ហើយ

ក៏សោយទវង្គតនៅក្នុងទីនោះឯង ដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ព្យាករទុក ដូច្នោះ ។

សម័យមួយ ភិក្ខុទាំងឡាយបានអង្គុយសន្ទនាគ្នាថា ឱហ្ន៎ ! ព្រះរាជាអង្គនេះ ព្រោះហេតុតែសំណូក ទើបដល់នូវការវិនាសយ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់យាងមកដល់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកសន្ទនាគ្នាពីរឿងអ្វី ភិក្ខុទាំងឡាយ ក៏ក្រាបទូលរឿងនោះឲ្យព្រះអង្គជ្រាប ព្រះមានជោគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែព្រះរាជាក្នុងកាលឥឡូវនេះទេ ដែលវិនាសព្រោះតែរឿងសំណូកនោះសូម្បីព្រះរាជាក្នុងកាលមុនក៏ដល់នូវសេចក្តីវិនាសព្រោះតែរឿងសំណូកនេះដែរ ។ ទ្រង់មានព្រះពុទ្ធដីកាប៉ុណ្ណោះ ក៏នៅស្ងៀម ទើបភិក្ខុទាំងឡាយអារាធនាឲ្យព្រះអង្គទ្រង់នាំអតីតនិទានមក ។

ក្នុងអតីតកាល មានព្រះបាទការុកច្ឆ គ្រប់គ្រងរាជ្យនៅក្នុងការុកច្ឆនគរ ។ សម័យនោះ មានឥសី ២ រូប ម្នាក់ៗ មានបរិវារ ៥០០ អាស្រ័យនៅក្នុងព្រៃហិមពាន្ត ។ ឥសីទាំង ២ រូបនោះ កាលបើត្រូវការ

បរិភោគអាហារដែលមានរសជូរ និងរសប្រៃ ក៏នាំគ្នាចូលមកកាន់ស្រុក ហើយស្នាក់អាស្រ័យនៅក្បែរស្រុក ក្រោមដើមឈើធំ ២ ដើមរៀងៗខ្លួន ។ចំណោរតមក ដើមឈើមួយដើមក៏ងាប់ទៅ ឥសីដែលធ្លាប់អាស្រ័យត្រង់ដើមឈើនោះ ក៏នាំបរិវារទាំង ៥០០ របស់ខ្លួនទៅគង់ក្រោមដើមឈើរបស់ឥសីមួយរូបទៀត ។ក្នុងសម័យនោះឯង ឃើញឥសីដែលមកមុនចូលទៅអាស្រ័យដើមឈើរបស់ខ្លួន ដែលធ្លាប់អាស្រ័យនៅក៏ចូលទៅបណ្តេញពួកឥសីដែលមកដល់មុនឲ្យចេញ ។ឥសីម្ខាងទៀតពោលថា ធម្មតាដើមឈើជារបស់សាធារណៈ មិនមែនជារបស់អ្នកណាដាច់មុខឡើយ ពួកយើងមិនចេញទេ ។ឥសីពួកទី ២ ខឹងសម្បាយ៉ាងខ្លាំង ទើបចូលទៅចាប់ត្រង់ដើមដៃខ្លះ ក្របួចត្រង់.កខ្លះ អូសឥសីទាំងនោះចេញទៅ ពួកឥសីទាំងនោះក៏ខឹងតប ហើយពោលថា អ្នកចាំមើលចុះ យើងនឹងដឹងគ្នា ។ហើយនិម្មិតកង់រថមាសមួយ ដែលមានកាំ និងដុំដ៏វិចិត្រដោយឫទ្ធិ ឲ្យកង់នោះវិលទៅខ្លួនឯង ត្តោះទៅកាន់ព្រះរាជវាំង ដើម្បីជាសំណូកដល់ព្រះរាជា ព្រះរាជាបញ្ជូនរាជបុរសមក ក៏ដឹងរឿង

រាវនេះ ទើបបញ្ជូនរាជបុរសជាច្រើន មកអូសឥសីទាំងនោះចេញទៅ ហើយប្រគល់ដើមនោះដល់ឥសីមួយពួកទៀត ។ ឥសីមួយពួកទៀត កាលបើដឹងថា ឥសីមុននិម្មិតកង់រថដើម្បីសូកព្រះរាជា ក៏និម្មិតស៊ុម បង្អួចមាសដ៏វិចិត្រឲ្យអណ្តែតទៅកាន់ព្រះរាជវាំង ។ ព្រះរាជាបានដឹង រឿងនេះ ទ្រង់ទទួលសំណូកនោះហើយ ក៏ឲ្យពួករាជបុរសអូសឥសី ពួកទី ១ នោះចេញ ប្រគល់ដើមឈើនោះដល់ឥសីពួកទី ២ វិញ ។ ឥសីទាំង ២ ពួកទាស់ទែងគ្នាយ៉ាងខ្លាំង ពួកមនុស្សដែលធ្លាប់ឧបដ្ឋាក ឥសីទាំង២ក៏កាន់ជើងឥសីរៀងៗខ្លួន ។ទេវតារក្សានគរគិតថា ព្រះរាជា អង្គនេះ ព្រោះតែរឿងសំណូក មិនប្រព្រឹត្តតាមធម៌ ញុំាងកោលាហល ឲ្យកើតឡើង ទើបខឹងសម្បា ហើយក៏ពន្លិចនគរនោះទាំងមូល ឲ្យក្លាយ ជាសមុទ្រ ដល់នូវការវិនាស ដោយប្រការដូច្នេះឯង ៕

# ✍ ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងឱ្យឱវាទដល់ពួកភិក្ខុនី "

*ព្រះនន្ទកត្ថេរ លោកជាមហាសាវ័កមួយរូប ដែលមានតំណែងជាឯតទគ្គៈផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ថែមទាំងមានការសម្តែងធម៌ធ្វើចិត្តបរិស័ទទាំង ៤ ជំពូកឲ្យកើតសេចក្តីជ្រះថ្លា និងមានភាពអង់អាចដ៏ខ្ពង់ខ្ពស់ក្នុងព្រះសាសនានេះ ព្រោះលោកជាព្រះអរហន្ត ដែលមានជំនាញក្នុងការរឭកជាតិបានផងដែរ ។*

*ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ មានសម្តែងនៅក្នុង* **អដ្ឋកថា គម្ពីរមនោរថបូរណី** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី ក្នុង* **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** *ដូចមានសេចក្តីថា ៖*

*ព្រះនន្ទកៈកើតនៅក្នុងត្រកូលព្រាហ្មណ៍ ដែលស្ថិតនៅក្នុងក្រុងសាវត្ថី ពេលចម្រើនវ័យធំឡើង លោកបានទៅស្តាប់ធម៌ទេសនា ក្នុងសម្នាក់ព្រះសម្ពុទ្ធជាម្ចាស់ ក៏កើតមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា*

ទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទា ។

កាលបានបំពេញបព្វជ្ជាឧបសម្បទាជាភិក្ខុ ក្នុងសាសនព្រហ្ម-ចរិយធម៌នេះហើយ តាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចនូវព្រះអរហត្តផល ( ផល គឺភាពជាអ្នកឆ្ងាយចាកសត្រូវគឺកិលេស ឬជាអ្នកមិនមានកិលេស ) ថែមទាំងបានជាព្រះអសេក្ខបុគ្គល ( គឺបុគ្គលមិនមានការសិក្សាជាបន្តទៅទៀត ) ។

ព្រះនន្ទកៈ លោកមានភាពជំនាញក្នុងបុព្វេនិវាសានុស្សតិញ្ញាណ គឺអាចរឭកដឹងដល់ការកើតក្នុងអតីតជាតិរបស់លោក និងសត្វដទៃទៀតបាន លោកជាអ្នកឈ្លាសវៃក្នុងការសម្ដែងធម៌ ធ្វើឲ្យចិត្តបរិស័ទទាំង ៤ ជំពូក ឲ្យកើតមានសេចក្ដីជ្រះថ្លាក្នុងព្រះសាសនានេះ គឺសម្ដែងព្រះធម៌ពន្យល់នូវហេតុផលឲ្យជាទីពេញចិត្ត និងយល់បានងាយ ទើបលោកបានទទួលនាមថា **ព្រះនន្ទកៈ** បានដល់ភាពជាអ្នកមានការសម្ដែងព្រះធម៌ ធ្វើឲ្យជាទីសប្បាយពេញចិត្តដល់អ្នកស្ដាប់ ។

ការសម្ដែងធម៌របស់ព្រះនន្ទកត្ថេរ ដែលរាប់ថាគួរឲ្យអស្ចារ្យនោះ

បានដល់ ការសម្ដែងធម៌ដល់ពួកភិក្ខុនីចំនួន ៥០០ រូប ឲ្យបានសម្រេចជាព្រះអរហន្តីទាំងអស់អង្គ ។

ដូចមានរឿងប្រាកដដូច្នេះថា ពួកសក្យកុមារ៥០០នាក់ បានចូលមកបួសក្នុងព្រះសាសនាហើយ កើតការមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ឡើយ ។

ព្រះភគវាជាម្ចាស់ ទើបទ្រង់នាំភិក្ខុទាំងនោះទៅកាន់ស្រះកុណាលដែលជាស្រះធំ តាំងនៅក្នុងព្រៃហិមពាន្ត ហើយទ្រង់សម្ដែងកុណាលជាតក គឺជាតកដែលសម្ដែងដល់សត្វតាវ៉ៅ និងទ្រង់ជ្រាបថា ភិក្ខុទាំង ៥០០ រូប កើតមានការរន្ធត់ចិត្ត ទើបទ្រង់សម្ដែងចតុរារិយសច្ច គឺការពិតដ៏ប្រសើរ ៤ ប្រការ អនុគ្រោះឲ្យភិក្ខុទាំង ៥០០ រូបនោះ បានតាំងនៅក្នុងសោតាបត្តិផល លុះកាលជាខាងក្រោយមក ព្រះសាស្ដាជាម្ចាស់ទ្រង់សម្ដែង **មហាសមយសូត្រ** អនុគ្រោះភិក្ខុទាំងនោះ ឲ្យបានសម្រេចជាព្រះអរហន្ត ដែលជាទីបំផុតនៃការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងព្រះសាសនានេះ ។

ចំណែកកកិរិយាចាស់របស់ភិក្ខុទាំងនោះ លុះបានជ្រាបថា ស្វាមីរបស់ខ្លួនបួសហើយ ទើបប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងរស់នៅក្នុងភាពជាឃរាវាសបានប្រយោជន៍អ្វី ហើយព្រមព្រៀងគ្នាទៅរកព្រះនាងមហាបជាបតិគោតមីថេរី ដើម្បីសូមបព្វជ្ជាឧបសម្បទាជាភិក្ខុនី ព្រះនាងមហាបជាបតិគោតមីក៏ព្រមឲ្យឧបសម្បទា ដោយមានសង្ឃទាំងពីរចំណែក គឺភិក្ខុសង្ឃមួយចំណែក ភិក្ខុនីមួយចំណែក ជាអ្នកឲ្យឧបសម្បទា ។

ដូចមានរឿងសម្ដែងទាក់ទងនឹងពួកភិក្ខុនីទាំង ៥០០ រូបនោះថា ក្នុងអតីតកាល ពួកនាងទាំងនោះធ្លាប់បានធ្វើជាអ្នកបម្រើរបស់ព្រះថេរៈ កាលដែលលោកកើតជាព្រះរាជា ដែលមានរឿងប្រាកដនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលអធិប្បាយសេចក្ដីព្រះបាលីក្នុង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ក្នុង **នន្ទកោវាទសូត្រ** ដូចមានសេចក្ដីថា ៖

ក្នុងអតីតជាតិ លោកកើតនៅក្រុងពារាណសី មានពួកទាសានិងទាសីមួយចំណែកៗ ៥០០ នាក់ដូចគ្នា បានរួមការងារស្នាក់អាស្រ័យនៅជាមួយគ្នា ។ចំណែកព្រះនន្ទកត្ថេរនោះបានជាអ្នកគ្រប់គ្រងផ្នែកខាង

ទាសា ក្នុងកាលនោះ ព្រះនាងមហាបជាបតិគោតមីថេរី បានជាអ្នកគ្រប់គ្រងផ្នែកខាងទាសី ព្រោះនាងជាភរិយារបស់ទាសាដែលជាធំ ប៉ុន្តែអ្នកទាំងពីរនាក់នោះ ជាអ្នកមានបញ្ញាឈ្លាសវៃក្នុងការគ្រប់គ្រងពួកទាសា ទាសីទាំង ១០០០ នាក់នោះ ដូចមានការធ្វើបុណ្យរួមគ្នា ប្រាថ្នាឲ្យកើតជាតិណាជួបគ្នា ដូច្នេះជាដើម ។

នៅក្នុងថ្ងៃមួយ ដែលជារដូវចូលព្រះវស្សា មានព្រះបច្ចេកពុទ្ធ ៥០០ អង្គ បាននិមន្តមកអំពីភ្នំនន្ទមូលកៈ មកគង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន នៅក្នុងក្រុងពារាណសី ហើយបានពោលនឹងគ្នាថា ពួកយើងទាំងឡាយនឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង ហើយនឹងសូមការជួយពីអ្នកស្រុក ដើម្បីឲ្យធ្វើទីអាស្រ័យ សម្រាប់ចាំវស្សាត្រង់ព្រៃឥសិបតនមិគទាយវ័ននេះ ។

ដល់ពេលល្ងាច ព្រះបច្ចេកពុទ្ធជាម្ចាស់បាននាំគ្នានិមន្តចូលទៅកាន់ក្រុងពារាណសី បានចូលទៅឈរនៅទៀបមាត់ទ្វារផ្ទះរបស់សេដ្ឋីម្នាក់ ។ ក្នុងពេលនោះ ជាពេលដែលទាសីជាធំ បានចុះទៅកាន់កំពង់ទឹក

ដើម្បីដងទឹក ចៃដន្យល្អណាស់ បានជួបព្រះបច្ចេកពុទ្ធកំពុងនិមន្តចូលទៅកាន់ក្រុងពារាណសី ។

ចំណែកសេដ្ឋីម្ចាស់ស្រុកនោះបានជ្រាបនូវបំណងព្រះបច្ចេកពុទ្ធទាំងនោះហើយ ទើបប្រាប់ដល់ព្រះបច្ចេកពុទ្ធទាំងនោះថា ខ្ញុំព្រះករុណាមិនមានពេល សូមលោកម្ចាស់ទាំងឡាយនិមន្តត្រឡប់ទៅវិញចុះ ។

ព្រះបច្ចេកពុទ្ធជាម្ចាស់ កាលបើបានស្តាប់ពាក្យបដិសេធរបស់សេដ្ឋីហើយបាននាំគ្នានិមន្តត្រឡប់ទៅវិញក្នុងពេលដែលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តត្រឡប់ចេញអំពីក្រុងពារាណសី ក៏ជាពេលដែលទាសីជាធំកំពុងត្រឡប់មកអំពីដងទឹកវិញដែរ គេបានឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ទើបដាក់ក្អមទឹកចុះ លើកដៃឡើងថ្វាយបង្គំ រួចហើយសួរថា បពិត្រលោកម្ចាស់ទាំងឡាយ លោកនិមន្តចូលទៅកាន់ក្រុងអម្បាញ់មិញនេះ ហេតុអ្វីទើបប្រញាប់និមន្តត្រឡប់ចេញមកវិញម្ល៉េះ ។

ព្រះបច្ចេកពុទ្ធជាម្ចាស់ប្រាប់នូវបំណង ឲ្យនាងទាសីជាធំដឹងថា នែ៎ នាងដ៏ចម្រើន ពួកអាត្មាបាននិមន្តចូលទៅកាន់ក្រុងនោះ ក៏ដើម្បីនឹង

សូមឲ្យមនុស្សទាំងឡាយធ្វើទីអាស្រ័យក្នុងការចាំវស្សាឲ្យ ។ ទាសីជាធំសួរថា លោកម្ចាស់ទាំងឡាយបានទទួលការជួយឬទេ ? ព្រះបច្ចេកពុទ្ធជាម្ចាស់ឆ្លើយថា ពួកអាត្មាមិនទាន់មានអ្នកជួយទេ ។

បពិត្រលោកម្ចាស់ តើទីអាស្រ័យនោះ អាចធ្វើបានតែចំពោះអ្នកមានស្តុកស្តម្ភទេឬ ឬអ្នកទីទ័លក្រក៏នឹងអាចធ្វើបានដែរលោកម្ចាស់ ? ព្រះបច្ចេកពុទ្ធឆ្លើយថា នាងដ៏ចម្រើន អ្នកណាៗ ក៏នឹងអាចធ្វើបានដែរ ទាសីជាធំក៏ឆ្លើយថា ប្រសិនបើដូច្នោះ ល្អហើយលោកម្ចាស់ ពួកនាងខ្ញុំទាំងអស់គ្នា នឹងនាំគ្នាទៅធ្វើក្នុងថ្ងៃស្អែកនេះ សូមលោកម្ចាស់និមន្តមកទទួលកិច្ចាក្នុងផ្ទះរបស់នាងខ្ញុំម្ចាស់ ក្នុងថ្ងៃស្អែកនេះផងណា កាលទាសីជាធំ ពោលដូច្នេះហើយ បានប្រញាប់រូតរះត្រឡប់ទៅផ្ទះ ហើយបានប្រញាប់ត្រឡប់ចេញមកវិញ ដើម្បីប្រាប់ដល់ពួកទាសី ដែលមកដងទឹកទាំងនោះថា នាងទាំងអស់គ្នា ចូរឈប់នៅទីនេះសិន ហើយពោលសួរថា ពួកនាងសុខចិត្តព្រមធ្វើជាទាសីរបស់អ្នកដទៃជានិច្ចយ៉ាងនេះរហូតទៅឬ ឬថាចង់រួចផុតពីភាពជាទាសីរបស់អ្នកដទៃដែរឬទេ ? ទាសី

ទាំងនោះឆ្លើយថា ពួកខ្ញុំម្ចាស់ចង់រួចផុតចាកភាពជាទាសីរបស់អ្នកដទៃ ក្នុងថ្ងៃនេះតែម្តង ។

ពេលនោះ ទាសីជាធំពោលថា ល្អហើយ យើងក៏បាននិមន្តព្រះបច្ចេកពុទ្ធឲ្យមកទទួលចង្ហាន់បិណ្ឌបាត នៅផ្ទះរបស់ពួកយើងក្នុងថ្ងៃស្អែកនេះដែរ ប៉ុន្តែអ្នកទាំងអស់គ្នា ចូរប្រាប់ឲ្យស្វាមីរបស់ពួកនាងទៅជួយធ្វើទីស្នាក់អាស្រ័យ សម្រាប់ចាំព្រះវស្សាប្រគេនចំពោះលោកម្ចាស់ ក្នុងថ្ងៃស្អែកផងណា ។

កាលបើទាសីជាធំ បានបបួលទាសីទាំងនោះយ៉ាងនេះហើយ ក៏ទទួលថា ល្អហើយ ទើបប្រាប់ដល់ស្វាមីរបស់ខ្លួនរៀងៗ ខ្លួន ក្នុងពេលដែលស្វាមីរបស់ខ្លួនត្រឡប់មកអំពីព្រៃវិញ ។ក្នុងពេលប្រជុំព្រមព្រៀងគ្នានោះ ទាសីជាធំទើបប្រាប់ថា ព្រឹកស្អែកនេះ អ្នកទាំងឡាយចូរជួយគ្នាទៅធ្វើទីស្នាក់អាស្រ័យថ្វាយព្រះបច្ចេកពុទ្ធ ហើយបបួលណែនាំបុគ្គលដែលមិនប្រាថ្នាជួយធ្វើ ឲ្យកើតសេចក្តីត្រេកអរដោយហេតុផល ដែលមានសារៈខ្លឹមសារគួរជឿបាន ។លុះព្រឹកស្អែកឡើងបានរៀបចំការថ្វាយ

កិក្ខាដល់ព្រះបច្ចេកពុទ្ធ ហើយថែមទាំងពោលជាមួយនឹងបុត្រទាសាទាំងពួង ឲ្យចេញទៅជួយធ្វើកិច្ចការនោះដែរ ។

ពួកបុត្ររបស់ទាសាប្រមាណ ៥០០ នាក់បានព្រមព្រៀងគ្នាចេញទៅព្រៃរកឈើមកធ្វើកុដិ និងទីចង្ក្រមជាដើម ឲ្យរួចស្រេចរៀបរយល្អហើយ ចាត់ចែងរកគ្រឿងប្រើប្រាស់ មានគ្រែ តាំង ក្អមដាក់ទឹក និងគ្រឿងប្រើសព្វគ្រប់ហើយ ។ បន្ទាប់មក ទើបនិមន្តព្រះបច្ចេកពុទ្ធឲ្យគង់ចាំព្រះវស្សាត្រង់ព្រៃឥសិបតនមិគទាយវ័ននោះ ហើយប្តូរវេនគ្នាដាក់បាត្រ កាលបើវេនមកដល់នរណា អ្នកនោះក៏ត្រូវចាត់ចែងកិក្ខាដាក់បាត្រ រីឯទាសីជាធំនោះបាននាំយកកិក្ខាពីផ្ទះរបស់ខ្លួនទៅថ្វាយផងដែរ ។

លុះមកដល់ពេលចេញវស្សាហើយ ទាសីជាធំនោះបានឲ្យទាសីម្នាក់ៗ ថ្វាយសំពត់ដល់ព្រះបច្ចេកពុទ្ធមួយអង្គៗ មួយផ្ទាំង រួមជាសំពត់ ៥០០ ផ្ទាំង ។ ព្រះបច្ចេកពុទ្ធជាម្ចាស់បានទទួលសំពត់អំពីទាសីទាំងនោះហើយ ពោលសុំលាចេញចាកព្រៃឥសិបតនមិគទាយវ័ន ។ លុះទាសានិងទាសីទាំងអស់ស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតក្នុងស្ថានសួគ៌

ពេលចុតិចាកស្ថានសួគ៌មកវិញ បានជាស្វាមីភរិយានឹងគ្នាទៀត ។

ចំណែកទាសាជាធំបានមកកើតនៅក្នុងរាជត្រកូល ចំពោះនាងទេពធីតាទាំង ៥០០ នោះ បានមកកើតនៅក្នុងត្រកូលអ្នកមានស្តុកស្តម្ភហើយ បានជាភរិយានៃបុត្ររបស់ទាសាជាធំៗ លោកបានជាក្សត្រក្នុងជាតិនោះ ។ កាលបើនាងទាំង ៥០០ នាក់នោះស្លាប់កើតៗ ក្នុងមនុស្សទេវតាដូច្នេះហើយ លុះមកដល់សាសនាព្រះពុទ្ធជាម្ចាស់នៃយើង ពួកនាងក៏បានមកកើតក្នុងត្រកូលក្សត្រសក្យរាជ នៅក្នុងកោលិយនគរ និងទេវទហនគរ ។

ចំណែកទាសាជាធំនោះ ដែលធ្លាប់បានកើតជាក្សត្រមកពីមុនក៏បានមកជាព្រះនន្ទកត្ថេរ ។ចំណែកទាសីជាធំ បានមកជាព្រះនាងមហាបជាបតិគោតមី ជាអគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ ហើយក្នុងកាលជាទីបំផុតក៏បួលមកបួសជាភិក្ខុនី ។ចំណែកទាសាដែលជាស្វាមីពីជាតិមុន បានមកកើតជាព្រះរាជកុមារទាំង ៥០០ អង្គ ហើយថែមទាំងបានចេញបួសក្នុងព្រះសាសនា រួចក៏បានសម្រេចជាព្រះអរហន្តគ្រប់ៗ

ព្រះអង្គ ។ ទាសីដែលជាករិយាទាំងនោះ បានមកកើតជាខត្តិយកញ្ញា ក៏បានចេញសាងបព្វជ្ជាជាភិក្ខុនីតាមស្វាមីផងដែរ នៅក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមីថេរី ។ នេះជារឿងអតីតជាតិរបស់ព្រះនន្ទកត្ថេរ និងភិក្ខុនីទាំង ៥០០ រូបនោះ ។

ចំណែកជីវប្រវត្តិបច្ចុប្បន្នជាតិរបស់លោក ដែលមានប្រាកដនៅក្នុងព្រះបាលី **នន្ទកោវាទសូត្រ គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ដូចមានសេចក្តីថា ៖

សម័យថ្ងៃមួយ ព្រះសក្យមុនីជាម្ចាស់ទ្រង់សម្រួលព្រះឥរិយាបថនៅក្នុងវត្តជេតពនមហាវិហារ ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ តាំងនៅក្បែរក្រុងសាវត្ថី គ្រានោះ ព្រះនាងមហាបជាបតិ-គោតមីថេរី ព្រមទាំងភិក្ខុនីប្រមាណ ៥០០ រូប ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរដល់ខ្លួន ទើបព្រះនាងមហាបជាបតិគោតមីថេរីទូលថា បពិត្រព្រះសាស្តាជាម្ចាស់ សូមព្រះអង្គ ទ្រង់មេត្តាសម្តែងធម៌ឲ្យដល់ភិក្ខុនីទាំងឡាយផង គ្រានោះ ព្រះ

សាស្តាបានត្រាស់ប្រាប់ភិក្ខុទាំងឡាយ ទៅឲ្យឱវាទដល់ភិក្ខុនីទាំងឡាយ ដោយប្តូរវេនគ្នាទៅ ។ កាលតមក ព្រះថេរៈទាំងឡាយបានសម្តែងធម៌ឲ្យភិក្ខុនីបានស្តាប់ដោយអនេកបរិយាយ គឺប្តូរគ្នាទៅតាមលំដាប់ថេរៈ ។ កាលបើមកដល់វារៈព្រះនន្ទកត្ថេរ លោករឭកមើលក្នុងអតីតជាតិក៏ជ្រាបថា ភិក្ខុនីទាំងនោះធ្លាប់ធ្វើជាអ្នកបម្រើរបស់ខ្លួនរៀងមក ទើបលោកគិតថា ប្រសិនបើព្រះថេរៈអង្គដទៃៗ ដែលលោកបានបុព្វេនិវាសានុស្សតិញាណ មើលឃើញយើងអង្គុយសម្តែងធម៌នៅក្នុងចំណោមពួកភិក្ខុនី ប្រាកដជាយល់ថា ព្រះនន្ទកត្ថេរនេះ នៅមិនទាន់លះបង់នាងស្រីស្នំរបស់ខ្លួនសោះ រហូតដល់ថ្ងៃនេះក៏នៅតែហែហមទៅដោយនាងស្រីស្នំចាស់ៗទាំងនោះនៅឡើយ ។

ព្រោះដូច្នោះ កាលដល់វារៈព្រះនន្ទកត្ថេរទៅឲ្យឱវាទដល់ភិក្ខុនី ទើបលោកឲ្យភិក្ខុអង្គដទៃទៅជំនួសវិញ ប៉ុន្តែភិក្ខុនីទាំង ៥០០ រូបនោះ មានសេចក្តីត្រូវការនឹងទទួលស្តាប់ឱវាទរបស់លោក ប៉ុន្តែក៏ត្រូវខុសក្តីសង្ឃឹម ។ ដោយហេតុនោះ ព្រះភគវា ទើបត្រាស់សួរព្រះអានន្ទកត្ថេរ

ថា ម្នាលអានន្ទ វារៈនេះជានាទីរបស់នរណាក្នុងការឲ្យឱវាទភិក្ខុនី ព្រះអានន្ទត្ថេរក្រាបបង្គំទូលតាមសេចក្តីពិតថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងពួងបានដាក់វេន ទៅឲ្យឱវាទដល់ពួកភិក្ខុនីមកជារៀងរហូតហើយ ប៉ុន្តែថ្ងៃនេះជាវេនរបស់ព្រះនន្ទកត្ថេរ តែព្រះនន្ទកៈមិនប្រាថ្នានឹងទៅឲ្យឱវាទភិក្ខុនីទាំងនោះទេ ព្រះអង្គ ព្រះសាស្តាត្រាស់ប្រាប់ព្រះនន្ទកត្ថេរថា ម្នាលនន្ទកៈ អ្នកកុំឲ្យភិក្ខុដទៃទៅជំនួសឡើយ ចូរអ្នកទៅឲ្យឱវាទភិក្ខុនីដោយខ្លួនឯងចុះ ។

ព្រះនន្ទកត្ថេរក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ លុះដល់ពេលដែលត្រូវថ្ងៃលោកឲ្យឱវាទភិក្ខុនី ពេលព្រឹកឡើងលោកនិមន្តទៅបិណ្ឌបាតក្រុងសាវត្ថី កាលត្រឡប់ពីបិណ្ឌបាត ពេលក្រោយភត្តកិច្ចស្រេចហើយ ទើបចៀងចូលទៅកាន់ទីវត្តរាជការាម ។ វត្តរាជការាម ជាវត្តដែលព្រះបាទបសេនទិកោសលទ្រង់កសាង ដែលតាំងនៅទិសខាងត្បូងក្រុងវេសាលី ។ ភិក្ខុនីទាំងឡាយ ក្រឡេកឃើញព្រះនន្ទកត្ថេរអំពីចម្ងាយ ក៏ត្រៀមរៀបចំតាំងអាសនៈ និងចាត់ចែងទឹកសម្រាប់លាងជើង លុះព្រះ

នន្ទកត្ថេរមកដល់ ទើបនិមន្តឲ្យគង់លើអាសនៈដែលគេក្រាលថ្វាយ ។

ចំណែកភិក្ខុនីទាំងនោះ នាំគ្នាថ្វាយបង្គំព្រះថេរៈ ហើយអង្គុយក្នុងទីដ៏សមគួរ ទើបព្រះនន្ទកត្ថេរ ពោលជាមួយនឹងភិក្ខុនីទាំងនោះថា ម្នាលប្អូនស្រីទាំងឡាយ ប្រសិនបើយើងសួរអ្នកហើយ បើដឹងចូរឆ្លើយថាដឹង មិនដឹងចូរឆ្លើយថាមិនដឹង ឬមានសេចក្ដីសង្ស័យ ស្នាក់ស្ទើរ ចូរសួរមកចុះ ភិក្ខុនីទាំងនោះត្រេកអរពេញចិត្តចំពោះព្រះនន្ទកត្ថេរថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អនុញ្ញាតទុកដូច្នេះហើយ ធ្វើឲ្យខ្ញុំព្រះករុណាទាំងឡាយ មានសេចក្ដីត្រេកអរពេញចិត្តណាស់ ។

ព្រះនន្ទកត្ថេរចាប់ផ្ដើមសួរថា នាងទាំងឡាយយល់ថា **ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត ទៀង ឬមិនទៀង** ? មិនទៀងទេ លោកម្ចាស់ វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខ លោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា នាងទាំងឡាយគួរយល់ឃើញថា វត្ថុនោះជារបស់យើង ជាយើង ជាខ្លួនរបស់យើងឬ ?មិនគួរទេ លោកម្ចាស់ ទុំះព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះ

កាលពីមុនខ្ញុំម្ចាស់ទាំងឡាយ មិនបានឃើញដោយបញ្ញាតាមសេចក្ដីពិតថា សូម្បីដោយហេតុដូចនេះ អាយតនៈខាងក្នុង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ជារបស់មិនទៀង ( ពាក្យថា អាយតនៈ បានដល់គ្រឿងដឹង និងវត្ថុដែលគួរដឹង ឬគ្រឿងជាប់បន្តគ្នាជាមួយនឹងអាយតនៈខាងក្រៅ ) ។

ព្រះថេរៈឆ្លើយថា ត្រូវហើយៗ ប្អូនស្រីទាំងឡាយ ការយល់យ៉ាងនេះ រមែងមានដល់ព្រះអរិយសាវក អ្នកឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិត គឺយល់យ៉ាងច្បាស់ដោយវិបស្សនាបញ្ញា ( បានដល់បញ្ញា ដែលឃើញច្បាស់លាស់ គឺឃើញថា វត្ថុទាំងពួងដែលមានបច្ច័យប្រជុំតាក់តែងមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ) ដោយប្រការដូចនេះ កាលបើព្រះថេរៈបានពោលរ៉ាប់រងដូច្នេះហើយ ក៏នឹងតាំងបញ្ហាសួរភិក្ខុនីទាំងនោះ តទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងយល់ថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយទៀងឬមិនទៀង ? មិនទៀងទេលោកម្ចាស់ ! វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ?

ជាទុក្ខ លោកម្ចាស់ ! វត្ថុណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា នាងគួរយល់ឃើញថា វត្ថុនោះជារបស់យើង ជាយើង ជាតួខ្លួនរបស់យើងឬ ? មិនគួរទេលោកម្ចាស់ ព្រោះហេតុអ្វី ? ព្រោះថា កាលមុននោះ នាងខ្ញុំម្ចាស់ទាំងឡាយមិនបានឃើញយ៉ាងនេះ ដោយបញ្ញាដ៏ប្រពៃតាមពិតថា សូម្បីដោយហេតុនេះៗ អាយតនៈខាងក្រៅ ៦ គឺរូប សំឡេងក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយនោះរបស់យើង ទើបឈ្មោះថាមិនទៀង លោកម្ចាស់ ល្អហើយៗ ម្នាលប្អូនស្រីទាំងឡាយ ព្រះអរិយសាវករមែងឃើញយ៉ាងនេះ ដោយបញ្ញាតាមសេចក្ដីពិតដូច្នេះឯង ។ កាលបើលោកពោលដូច្នេះហើយ បានសួរភិក្ខុនីទាំងនោះតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងយល់ឃើញថា ចក្ខុវិញ្ញាណសោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោ-វិញ្ញាណ ទៀង ឬមិនទៀង ? មិនទៀងទេលោកម្ចាស់ វត្ថុណាមិនទៀងវត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខ លោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខមានសេចក្ដីប្រែប្រួលជាធម្មតា នាងគួរយល់ឃើញថា វត្ថុនោះជារបស់

យើង ជាយើង ជាខ្លួនរបស់យើងឬ ? មិនគួរទេ លោកម្ចាស់ ព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំម្ចាស់មិនបានឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិតថា សូម្បីដោយហេតុនេះៗ វិញ្ញាណទាំង ៦ នោះ របស់យើង ទើបឈ្មោះថា មិនទៀងតាមពិតទេ លោកម្ចាស់ ។

ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ព្រះអរិយសាវករមែងឃើញដោយវិបស្សនាបញ្ញា គឺឃើញយ៉ាងជាក់ច្បាស់តាមសេចក្ដីពិតយ៉ាងនេះឯង ។ កាលបើព្រះនន្ទកត្ថេរពោលដូច្នេះហើយ ទើបពោលជាមួយនឹងភិក្ខុនីទាំងនោះដោយធ្វើសេចក្ដីឧបមា និងតាំងជាពាក្យសួរថា

ម្នាលប្អូនស្រីទាំងឡាយ កាលបុគ្គលដុតប្រទីបប្រេង ដែលមានប្រេងក៏ល្អ ប្រឆេះក៏ល្អ អណ្ដាតប្រទីបក៏ល្អ ពន្លឺប្រទីបក៏ល្អ សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា អ្នកណានឹងពោលថា ប្រទីបប្រេងបែបនេះ កាលបើត្រូវឆេះ ប្រេងក្ដី ប្រឆេះក្ដី អណ្ដាតប្រទីបក្ដី សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅ ជាធម្មតា វៀរតែពន្លឺ

នៃប្រទីបនោះជារបស់ទៀង មានការស្ថិតស្ថេរនៅដដែល មិនប្រែសភាព ទៅជាយ៉ាងដទៃ នឹងហៅបុគ្គលនោះថា ជាអ្នកពោលត្រឹមត្រូវឬ ? បពិត្រលោកម្ចាស់ អ្នកនោះពោលមិនត្រឹមត្រូវទេ ម្នាលប្អូនស្រីទាំងឡាយ សេចក្តីនេះព្រោះហេតុអ្វី ? ព្រោះហេតុថា ប្រទីបប្រេងដែលឆេះនោះ ប្រេងក្តី ប្រឆេះក្តី អណ្តាតប្រទីបក្តី សុទ្ធតែមិនទៀង មានការប្រែប្រួលជាធម្មតា មិនចាំបាច់ពោលថ្វីដល់ពន្លឺនៃប្រទីបនោះ ក៏ជារបស់មិនទៀង មានការប្រែប្រួលជាធម្មតាដូចគ្នា លោកម្ចាស់ ( ពន្លឺនៃប្រទីបមានការអាស្រ័យប្រឆេះ និងប្រេងនោះ ) ។

សេចក្តីឧបមាក៏ដូច្នោះដែរ ប្អូនស្រីទាំងឡាយ គឺអ្នកណាពោលថា អាយតនៈខាងក្នុង ៦ របស់យើង ជារបស់មិនទៀង តែទុក្ខ ឬសុខ ឬមិនទុក្ខមិនសុខ ដែលយើងបានទទួល ព្រោះអាស្រ័យអាយតនៈខាងក្នុងនោះជារបស់ទៀង គឺមានការស្ថិតស្ថេរនៅដដែលមិនប្រែប្រួល ដូច្នេះ នឹងហៅអ្នកនោះថា ជាអ្នកពោលត្រឹមត្រូវឬទេ ? មិនត្រឹមត្រូវទេ សេចក្តីនោះព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ ពីព្រោះវេទនាដែលកើតអំពី

អាយតនៈខាងក្នុងនោះៗ ដែលអាស្រ័យបច្ច័យទើបកើតឡើងពីអាយតនៈខាងក្នុងនោះៗ ហើយ ទើបកើតឡើងបាន កាលកើតឡើងហើយក៏រលត់ទៅវិញជាធម្មតា ។ ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ការឃើញដូច្នេះរមែងមានដល់ព្រះអរិយសាវក ដែលលោកឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត ។ លុះព្រះនន្ទកត្ថេរពោលយ៉ាងនេះហើយ ទើបពោលប្រៀបធៀបតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ឫស ដើម មែក ស្លឹក និងស្រមោលនៃដើមឈើធំជាដើម ឈើមានខ្លឹម សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា នឹងមាននរណាមកពោលថា ឫស ដើម មែក ស្លឹកនៃដើមឈើធំនោះក្តី ជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា តែថាស្រមោលនៃដើមនោះជារបស់ទៀង គឺជារបស់ស្ថិតស្ថេរនៅដដែលមិនប្រែប្រួលដូច្នេះ ឬនឹងហៅអ្នកនោះថាជាអ្នកពោលត្រូវឬទេ ? អ្នកនោះពោលមិនត្រឹមត្រូវទេ លោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ម្នាលប្អូនស្រី ព្រោះហេតុថា ឫស ដើម មែក ស្លឹក រហូតដល់ស្រមោលនៃដើមឈើធំនោះ សុទ្ធតែជារបស់មិនទៀង

ទាំងអស់ មានការផ្លាស់ប្តូរប្រែប្រួលជាធម្មតា ( កាលបើដើមឈើនោះ មិនទៀង ស្រមោលនៃដើមឈើនោះ នឹងទៀងមកពីណា ) ។

ព្រះនន្ទកត្ថេរពោលថា សេចក្តីនោះក៏ដូច្នោះដែរ ហើយទើបលើកយកអាយតនៈខាងក្រៅមកសាកសួរទៀតថា នែប្អូនស្រីទាំងឡាយ អ្នកណានិយាយថា អាយតនៈខាងក្រៅ ៦ របស់យើងជារបស់មិនទៀង ប៉ុន្តែទុក្ខ និងសុខ ឬមិនមែនទុក្ខមិនមែនសុខ ដែលយើងបានទទួលព្រោះអាស្រ័យអាយតនៈខាងក្រៅ ៦ នោះជារបស់ទៀង ជារបស់ស្ថិតស្ថេរ តាំងនៅជាដែលមាំមួនមិនប្រែប្រួលដូច្នេះ នឹងថាអ្នកនោះនិយាយត្រូវដែរ ឬទេ ? មិនត្រូវទេលោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ម្នាលប្អូនស្រី ? បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះវេទនាដែលកើតឡើងពីអាយតនៈខាងក្រៅ ៦ នោះ អាស្រ័យបច្ច័យដែលកើតពីអាយតនៈខាងក្រៅទាំង ៦ នោះហើយ ទើបកើតឡើងបាន កាលកើតឡើងហើយ ក៏រលត់ទៅវិញជាធម្មតា ។ ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ការឃើញដូច្នេះ រមែងមានដល់ព្រះអរិយសាវកដែលលោកឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃ

តាមសេចក្ដីពិត ដូចបានពោលរួចមកហើយ ។ កាលបើព្រះថេរៈពោលយ៉ាងនេះហើយ ទើបពោលឧបមាដោយន័យដទៃទៀតថា ម្នាលប្អូនស្រីទាំងឡាយ អ្នកសម្លាប់គោ ឬកូនឈ្នួលអ្នកដែលសម្លាប់គោដ៏ឈ្លាសវៃពន្លះស្បែកខាងក្រៅទុកមួយចំណែក ពន្លះសាច់ទុកមួយចំណែក សរសៃគ្រឿងចងរឹតខាងក្នុងទុកមួយចំណែកៗ បន្ទាប់មក លាតចំណែកស្បែកខាងក្រៅនោះគ្របដណ្ដប់សាច់គោនោះទុក ហើយគេពោលថា ខ្លួនគោនេះផ្សំដោយស្បែកផ្ទាំងនេះដូចដើមនោះឯង ម្នាលប្អូនស្រីទាំងឡាយ អ្នកសម្លាប់គោ ឬកូនឈ្នួលសម្លាប់គោដែលពោលនោះ ឈ្មោះថា ត្រឹមត្រូវឬទេ ? មិនត្រូវទេលោកម្ចាស់ សេចក្ដីនោះព្រោះហេតុអ្វី ប្អូនស្រីទាំងឡាយ ព្រោះហេតុថា អ្នកសម្លាប់គោ ឬកូនឈ្នួលសម្លាប់គោដ៏ឈ្លាសវៃនោះ កាលសម្លាប់គោស្លាប់ហើយ ក៏យកកាំបិតដ៏មុតមកពន្លះសាច់ខាងក្នុងទុកមួយចំណែក ស្បែកទុកមួយចំណែក សរសៃគ្រឿងចងរឹតខាងក្នុងចេញមកជាចំណែកៗ ហើយយកស្បែកគ្របដណ្ដប់គោទុក សូម្បីអ្នកនោះនឹងពោលថា គោនេះនឹងនៅមានស្បែកគ្របដណ្ដប់ដូចដើមក៏ដោយ គោ

នោះក៏បែកគ្នាចាកស្បែកជាផ្ទាំងគ្របដណ្តប់នោះហើយ លោកម្ចាស់ ។

ម្នាលប្អូនស្រីទាំងឡាយ យើងបានលើកការឧបមានេះមកសម្តែង ដើម្បីនឹងឲ្យជ្រាបសេចក្តីនៃពាក្យពន្យល់ ពាក្យថា ដុំសាច់ខាងក្នុងនោះ បានដល់ អាយតនៈខាងក្នុង ៦ ពាក្យថា ស្បែកខាងក្រៅនោះ បានដល់ អាយតនៈខាងក្រៅ ៦ សាច់ដែលជាប់នឹងស្បែកខាងក្នុង សរសៃខាងក្នុង គ្រឿងចងរឹតខាងក្នុងនោះ បានដល់ រាគៈ និងកាំបិតដ៏មុតនោះ បានដល់ បញ្ញារបស់ព្រះអរិយបុគ្គល ប្រើកាត់ផ្តាច់នូវកិលេសខាងក្នុង កាត់ផ្តាច់ សំយោជនៈ (កិលេសដែលចងរឹតចិត្តសត្វទុកក្នុងវដ្តសង្សារ) ខាងក្នុង និងកាត់ផ្តាច់គ្រឿងចងរឹតខាងក្នុង ។ លំដាប់តមក ព្រះនន្ទកត្ថេរ ពោល អំពីពោជ្ឈង្គ គឺអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដល់ភិក្ខុនីទាំងនោះថា

ម្នាលប្អូនស្រីទាំងឡាយ ពោជ្ឈង្គ ៧ ប្រការ ដែលភិក្ខុបានអប់រំ ឲ្យច្រើនហើយ ក៏បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមាន អាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយការដឹងដ៏ក្រៃលែងដោយ ខ្លួនឯង ។ ពោជ្ឈង្គ ៧ ប្រការនោះបានដល់អ្វីខ្លះ សតិ គឺការរឭកបាន

ធម្មវិចយៈ គឺការយកចិត្តទុកដាក់នូវធម៌ **វិរិយៈ** គឺការព្យាយាម **បីតិ** គឺការផ្អែតចិត្ត **បស្សទ្ធិ** គឺការស្ងប់ក្នុងអារម្មណ៍ **សមាធិ** គឺការតាំងចិត្តមាំ **ឧបេក្ខា** គឺភាពព្រងើយៗ ដែលត្រូវអាស្រ័យវិវេក គឺភាពស្ងប់ស្ងាត់ ការរលត់ បង្អោនទៅក្នុងការលះបង់ដូច្នេះ ។

កាលព្រះថេរៈបានសម្តែងពន្យល់ធម៌ដល់ពួកនាងភិក្ខុនីទាំងនោះដោយឱវាទដូចបានសម្តែងរួចមកហើយទាំងអស់ ទើបលោកប្រាប់ភិក្ខុនីទាំងនោះថា ពួកនាងចូរត្រឡប់ទៅវិញចុះ ព្រោះដល់កាលដ៏សមគួរហើយ ។ភិក្ខុនីទាំងនោះ បានសម្តែងអាការកោតសរសើរត្រេកអរចំពោះឱវាទ ដែលព្រះនន្ទកត្ថេរបានសម្តែងរួចហើយ ក៏ថ្វាយបង្គំលារួចក៏ចូលទៅគាល់ព្រះសម្ពុទ្ធជាម្ចាស់ថ្វាយបង្គំរួចហើយទើបឈរក្នុងទីដ៏សមគួរដោយសេចក្តីគោរពកោតក្រែង កាលបានស្តាប់នូវព្រះតម្រាស់ថា នាងទាំងឡាយចូរទៅចុះ ដល់កាលដ៏សមគួរហើយ ភិក្ខុនីទាំងអស់ក៏ថ្វាយបង្គំលាព្រះភគវាត្រឡប់ទៅវិញ ។ក្រោយភិក្ខុនីទាំងនោះត្រឡប់ទៅវិញមិនយូរប៉ុន្មាន ព្រះលោកនាថជាម្ចាស់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា

ការងឿងឆ្ងល់ ឬការសង្ស័យរបស់បុថុជ្ជន រមែងមិនមាននៅក្នុងថ្ងៃឧបោសថទី ១៤ ពាក្យថា ខែរនោច ឬខ្មៅត ប៉ុន្តែព្រះចន្ទក៏នៅតែរនោចយ៉ាងណា ម្នាលភិក្ខុ ភិក្ខុនីទាំងឡាយ សូម្បីនឹងមានសេចក្តីត្រេកអរចំពោះការសម្តែងធម៌របស់ព្រះនន្ទកៈក៏ពិតមែន ប៉ុន្តែនៅមិនទាន់ពេញចិត្តតាមសេចក្តីប្រាថ្នា គឺនៅមិនទាន់បានសម្រេចអរហត្តផលដូច្នោះៗកាលបើព្រះអង្គត្រាស់ដូច្នេះហើយ ទើបត្រាស់ប្រាប់ព្រះនន្ទកត្ថេរថា ម្នាលនន្ទកៈ ព្រឹកស្អែកនេះ អ្នកចូរសម្តែងធម៌ដល់ភិក្ខុនីទាំងនោះ ដោយធម្មោវាទនោះទៀត ។ ព្រះនន្ទកត្ថេរក្រាបទូលទទួលព្រះពុទ្ធដីកាថាព្រះករុណា ព្រះអង្គ លុះព្រឹកស្អែកឡើង ទើបលោកទៅសម្តែងធម៌ដល់ភិក្ខុនីទាំងនោះ ដូចសម្តែងរួចមកហើយកាលពីម្សិលមិញ លើកយកមកសម្តែងម្តងទៀត តាមព្រះពុទ្ធបំណង ។ ភិក្ខុនីទាំងនោះ បានស្តាប់ធម្មកថារបស់ព្រះនន្ទកៈ ដែលសម្តែងម្តងទៀត ក៏បានសម្រេចនូវអរហត្តផល ជាព្រះអរហន្តខីណាស្រពគ្រប់ៗ អង្គ ហើយបានចូលទៅគាល់ព្រះបរមសាស្តា ។

កាលបើភិក្ខុនីទាំងនោះ ចេញអំពីកន្លែងស្តាប់ធម៌ មិនយូរប៉ុន្មាន ក៏ព្រះសាស្តាជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ការជឿងឆ្ងល់ ឬការសង្ស័យរបស់មនុស្សភាគច្រើន រមែងមិនមានក្នុង ថ្ងៃ ១៥ រោចថា ព្រះចន្ទរះខាងរនោច ឬរះខាងខ្នើតក៏ដោយ ប៉ុន្តែព្រះចន្ទ រះពេញវង់ យ៉ាងណា ភិក្ខុនីទាំងនោះក៏មានការកោតសរសើរ ត្រេកអរ ចំពោះភាសិតរបស់ព្រះនន្ទកៈដូច្នោះដែរ ។ ប្រសិនបើសរុបពុទ្ធតម្រាស់ ដែលបានត្រាស់សរសើរព្រះនន្ទកត្ថេរ ក្នុងថ្ងៃដែលព្រះភិក្ខុនីទាំងនោះ បានសម្រេចព្រះអរហត្តផល ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបថា ភិក្ខុនីទាំងនោះ បានសម្រេចជាព្រះអរហន្តីហើយ ព្រោះបានស្តាប់ព្រះ ធម៌ទេសនារបស់ព្រះនន្ទកត្ថេរ ទើបត្រាស់ថា ព្រះធម៌ទេសនារបស់ ព្រះនន្ទកៈ កាលពីម្សិលមិញនោះ មានដូចគ្នានឹងព្រះចន្ទរះក្នុងថ្ងៃ ១៤ កើត ចំណែកព្រះធម៌ក្នុងថ្ងៃនេះ ដូចជាព្រះចន្ទរះក្នុងថ្ងៃ ១៥ កើត ហើយ ព្រះអង្គអាស្រ័យគុណសម្បត្តិនេះឲ្យជាដើមហេតុ ទើបទ្រង់តែងតាំង ព្រះនន្ទកត្ថេរ ទុកក្នុងតំណែងជាឯតទគ្គៈមួយអង្គដែរ ។

ដូចមានសេចក្ដីនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** មានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយ **ននុក:** ប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ។

គុណសម្បត្តិដ៏ខ្ពង់ខ្ពស់ដែលព្រះននុកត្ថេរបានទទួលនោះ កើតអំពីការកសាងនូវសេចក្ដីល្អគ្រប់យ៉ាងក្នុងជាតិបច្ចុប្បន្ននេះ ដូចពោលមកហើយ ក៏នៅមានសេចក្ដីល្អរបស់លោកទៀត ក្នុងអតីតជាតិមួយផ្នែកទៀតផងដែរ ដូចមានរឿងតំណាលទុកក្នុង **អដ្ឋកថាមនោរថបូរណី** ពោលដោយការកសាងបុណ្យកុសល និងបុព្វចរិយារបស់ព្រះននុកត្ថេរ ដូចមានសេចក្ដីថា

ក្នុងពុទ្ធសម័យនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរ: លោកបានកើតជាកុលបុត្រនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ ( ក្នុងគម្ពីរខ្លះថា កើតក្នុងត្រកូលសេដ្ឋី ) ក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ លោកបានទៅស្ដាប់ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធបទុមុត្តរ: កុលបុត្រនោះបានឃើញ

ព្រះបទុមុត្តរៈជាម្ចាស់ ទ្រង់ប្រកាសតែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ក៏កើតមានសេចក្តីពេញចិត្តក្នុងតំណែងនោះ ទើបធ្វើអធិការកុសល (មានគម្ពីរមួយថា បានថ្វាយសំពត់តម្លៃមួយសែន) ចំពោះព្រះបទុមុត្តរៈ ហើយប្រាថ្នាតំណែងនោះ និងបានបូជាដើមពោធិ៍ដែលព្រះអង្គត្រាស់ដឹងដោយប្រទីបទៀតផង ទាំងធ្វើកុសលវត្តរហូតអស់ជីវិត ។ ពេលដែលកុលបុត្រនោះអស់ជីវិតទៅហើយ ក៏បានទៅកើតក្នុងស្ថានសួគ៌ កាលបើចុតិចាកស្ថានសួគ៌មកវិញ ក៏បានមកកើតជាមនុស្ស វិលកើត វិលស្លាប់ដូច្នេះអស់កាលដ៏យូរ ប្រមាណមួយសែនកប្ប ទើបបានមកកើតជានន្ទកៈនៅក្នុងត្រកូលអ្នកមានធនធានក្នុងក្រុងសាវត្ថី ដែលជាជាតិចុងក្រោយបំផុតរបស់លោក ។

ចំណែកអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយសេចក្តីបាលី **គម្ពីរខុទ្ទកនិកាយ នន្ទកត្ថេរគាថា** បានពោលដល់ការកសាងបុញ្ញកុសល ដែលឲ្យកើតជាបារមីរបស់ព្រះនន្ទកត្ថេរថា ៖

ព្រះនន្ទកត្ថេររូបនេះ ធ្លាប់ធ្វើអធិការកុសលទុកក្នុងសម្នាក់នៃព្រះពុទ្ធជាម្ចាស់ទាំងឡាយក្នុងកាលមុនតរៀងមក ។ជាតិមួយ លោកបានកើតជានាយព្រានទៅបច្ចន្តប្រទេស ដែលស្រេបគ្នានឹងពុទ្ធកាលរបស់ព្រះសិទ្ធិសម្មាសម្ពុទ្ធជាម្ចាស់ ។ នៅថ្ងៃមួយ ខណៈដែលគេត្រាច់ទៅក្នុងពនាលី (ជាយព្រៃ ឬជួរព្រៃ) បានទៅជួបទីចង្ក្រមនៃព្រះសម្មាសម្ពុទ្ធសិទ្ធិ ក៏កើតមានសេចក្ដីជ្រះថ្លា ទើបទៅស្វែងរកដីខ្សាច់មករោយរាយពាសពេញក្នុងទីចង្ក្រមនោះ លុះគេស្លាប់ទៅ បានត្រាច់រង្គាត់ទៅក្នុងមនុស្ស និងទេវតាដោយបុញ្ញកម្មនោះ ។ លុះមកដល់កាលនៃព្រះសម្ពុទ្ធជាម្ចាស់នៃយើង លោកបានមកកើតក្នុងត្រកូលគហបតី នៅក្នុងក្រុងចម្ប៉ា មានឈ្មោះថា **នន្ទកៈ** មានបងប្រុសម្នាក់ឈ្មោះ **ភារតៈ** ។ ដើមហេតុដែលបងប្អូនទាំងពីរនោះចេញបួស ព្រោះជ្រាបដំណឹងថា ព្រះសោណកោឡិវិសត្ថេរបួសជាភិក្ខុរួចហើយ ទើបប្រឹក្សាគ្នាថា **សោណកោឡិវិសៈ** ជាអ្នកមានសុខុមាលជាតិ នៅតែអាចបួសបាន រឿងអ្វីយើងបួសមិនបាន ប្រឹក្សាគ្នាដូច្នេះហើយ ក៏នាំគ្នាចេញបួស ។ ព្រះភារតៈជាបងប្រុស បានសម្រេច

ជាព្រះអរហន្ត ព្រមដោយអភិញ្ញា ៦ មុន ទើបប្រៀនប្រដៅព្រះនន្ទកត្ថេរ ឲ្យបានសម្រេចជាព្រះអរហន្តក្នុងកាលជាខាងក្រោយ ។

កាលបើព្រះនន្ទកត្ថេរពោលអះអាងភាពជាព្រះអរហន្តរបស់ខ្លួន ទើបលោកពោលគាថា ២ គាថា តាមដែលមានសេចក្តីប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖

សេះអាជានេយ្យដ៏ចម្រើន ភ្លាត់ភ្លាំងហើយ រមែងឈរស៊ប់ឡើងវិញ ទោះបីបាននូវសេចក្តីតក់ស្លុត ក៏ជាសត្វមានចិត្តមិនរួញរា រមែងនាំនូវធុរៈទៅបាន យ៉ាងណាមិញ អ្នកទាំងឡាយសូមជ្រាបនូវខ្ញុំ ថាជាអាជានេយ្យ បរិបូណ៌ដោយទស្សនៈ ជាសាវករបស់ព្រះសម្ពុទ្ធ ជាបុត្រជាឱរសរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។

សេចក្តីក្នុងគម្ពីរដែលពោលរួចមកហើយនេះ មានរឿងផ្សេងគ្នាដែលទាក់ទងនឹងត្រកូល និងក្រុងដែលកើតព្រម ទាំងដើមហេតុនៃការចេញបួសផងដែរ ។ ដូចមានរឿងពោលនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូច្នេះថា ៖

កាលព្រះនន្ទកត្ថេរ ជាព្រះអរហន្តហើយ លោកបានប្រកាស បុព្វចរិយារបស់លោកទុកថា ខ្ញុំព្រះករុណាម្ចាស់ឈ្មោះនន្ទកៈ ធ្លាប់បាន កើតជានាយព្រានក្នុងកាលមុន កាលបើដើរត្រាច់ទៅស្វែងរកម្រឹគ នៅក្នុងព្រៃ បានទៅជួបព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ ព្រះអង្គស្តេចចូលទៅ ប្រថាប់នៅក្នុងព្រៃ ដើម្បីទ្រង់ត្រូវការវិវេក ខ្ញុំម្ចាស់បានរៀបចំការតាំង មូលដ្ឋាន ៤ មូលដ្ឋាន ធ្វើបារាំប្រក់ដោយផ្កាឈូកថ្វាយដល់ព្រះអនុរុទ្ធ សម្ពុទ្ធជាម្ចាស់ លុះធ្វើបារាំរួចហើយ ក៏បោះបោលធ្នូក្នុងទីនោះ ហើយ ក៏បួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។ ក្រោយពីបានបួសរួចហើយ មិនយូរប៉ុន្មាន ក៏មានរោគាពាធកើតឡើងដល់ខ្ញុំម្ចាស់ ប៉ុន្តែរឭកចាំនូវ បុណ្យកុសលដែលខ្លួនបានធ្វើហើយនោះដរាបដល់ថ្ងៃស្លាប់ ទើបបាន ទៅកើតនៅក្នុងស្ថានតុសិតទេវលោក និងពេលដែលខ្ញុំម្ចាស់កើតនៅក្នុង ស្ថានតុសិតទេវលោកនោះ មានរថទិព្វទឹមដោយសេះមួយពាន់ ជាពាហនៈ របស់ខ្ញុំ ពេលណាដែលខ្ញុំត្រូវការទៅទីណា ក៏ឡើងជិះរថនោះទៅតាម សេចក្តីប្រាថ្នារបស់ខ្ញុំ ក៏មានមណ្ឌបលាតសន្ទឹង បាំងដល់ខ្ញុំរហូតដល់

មួយរយយោជន៍ សូម្បីពេលដេកក៏ដេក នៅលើកន្ទេលដែលសម្រេច ដោយផ្កា មានទាំងផ្កាឈូកធំធ្លាក់ចុះមកបូជាខ្ញុំផងដែរអស់កាលជានិច្ច ។

ចំណែកក្នុងបច្ចុប្បន្នជាតិនេះ ខ្ញុំម្ចាស់មិនធ្លាប់ត្រូវកម្តៅថ្ងៃក្តៅ ដូចភ្លើងឡើយមូលហេតុនេះមានដោយអំណាចអានិសង្សដែលខ្ញុំម្ចាស់ បានធ្វើបារាំថ្វាយដល់ព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ និងមិនមែនមានផលល្អ ប្រាកដត្រឹមតែប៉ុណ្ណោះទេ ទាំងអាចបិទទ្វារទុគ្គតិអបាយភូមិបានផងដែរ ការក្តៅក្រហាយ រមែងមិនមានដល់ខ្ញុំម្ចាស់ ពេលដែលនៅក្នុងទីណា ក៏ដោយ ។ ខ្ញុំម្ចាស់អធិដ្ឋានសមុទ្រឲ្យជាផែនដីក៏បាន អធិដ្ឋានផ្ទៃមេឃ ឲ្យជាផ្លូវដើរទៅមកក៏បាន ខ្ញុំម្ចាស់មានទិព្វចក្ខុ ដឹងនូវបុព្វេនិវាសានុស្សតិ ( ទីនៅជាតិមុន ) បានដោយល្អ ទាំងបានជាពុទ្ធបុត្រអ្នកទទួលធម្មតិក ជាអ្នកទ្រទ្រង់ធម៌ ព្រមទាំងបានបដិបត្តិព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គ ទ្រង់ជាលោកនាយកទៀតផង ។ព្រះមានជោគជាម្ចាស់ទ្រង់សម្តែងធម៌ ដ៏គម្ភីរភាព គឺភាពដ៏ជ្រាលជ្រៅ ឲ្យខ្ញុំម្ចាស់ស្តាប់រហូតដល់ខ្ញុំបានសម្រេច ធម៌ ដែលធ្វើឲ្យអស់អាសវក្កិលេស ខ្ញុំម្ចាស់មិនមានការកើតតទៅទៀត

បានទម្លាយជាតិកំណើតចេញអស់ហើយ ដោយការផ្តាច់ផ្តិលគ្រឿងចង ឲ្យដាច់អស់ ដូចដីរដែលរឹខ្ជួនចាកកក់បានហើយ ។ កាលដែលខ្ញុំម្ចាស់ ចូលមកក្នុងព្រះសាសនានេះ ជាវត្ថុដ៏ប្រសើរក្រៃលែង ពីព្រោះខ្ញុំម្ចាស់ បានសម្រេចវិជ្ជា ៣ បានធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ហើយ ។

កាលព្រះនន្ទកត្ថេរ លោកទ្រទ្រង់អាយុសង្ខាររបស់លោកមក ដល់កាលសមគួរហើយ ក៏រំលត់ខន្ធបរិនិព្វានទៅហោង ។

( ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាងសោណាថេរី ✍

## “ ព្រះនាងសោណាថេរីជាឯតទគ្គៈផ្នែកខាងជាអ្នកមានព្យាយាមបរិបូណ៌ ”

ព្រះនាងសោណាភិក្ខុនី ជាអ្នកមានចំណុចពិសេសច្រើនយ៉ាង ដែលគួរឲ្យចាប់អារម្មណ៍ ថែមទាំងជាអ្នកមានគុណធម៌ដ៏ប្រសើរ ចំណុចពិសេសនោះ គឺមុនពេលដែលនាងមកបួស នាងក៏ធ្លាប់ជាអ្នកមានកូនច្រើនទៀតផង ទាំងជាអ្នកមានអាយុច្រើនហើយណាស់ដែរមុនពេលនាងមកបួស ថែមទាំងជាអ្នកបរិបូណ៌ទៅដោយសេចក្តីព្យាយាមច្រើន ព្រះនាងក៏បានទទួលតំណែងជាឯតទគ្គៈ ផ្នែកខាងជាអ្នកមានព្យាយាមបរិបូណ៌ ។ ជីវប្រវត្តិរបស់ព្រះនាងសោណាថេរី ក៏មានសម្តែងទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។

ជីវប្រវត្តិអតីតជាតិ របស់ព្រះនាងសោណាភិក្ខុនី ក៏មានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុងគម្ពីរខុទ្ទកនិកាយ ថេរីគាថា និងក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជា

អដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** និង ក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្ដីថា ៖

ព្រះមានជោគ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ព្រះពុទ្ធអង្គជានាយក ទ្រង់កើតឡើងហើយ ក្នុងកប្បទីមួយសែន ដែលរាប់ថយក្រោយអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដល់នូវសេចក្ដីសុខ ជាស្រីមានគេជាប់ចិត្ត ជាទីស្រឡាញ់ ( នៃជនដទៃ ) ។ ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ជាអ្នកប្រាជ្ញដ៏ប្រសើរ បានស្ដាប់នូវព្រះតម្រាស់ដ៏ពីរោះ ។ ព្រះជិនស្រីទ្រង់សរសើរភិក្ខុនី អ្នកមានព្យាយាមលើសលប់ ជាងភិក្ខុនីទាំងឡាយ អ្នកមានព្យាយាមប្រារព្ធ ខ្ញុំបានស្ដាប់ព្រះពុទ្ធតម្រាស់នោះ ក៏មានចិត្តរីករាយ ហើយធ្វើនូវសក្ការៈ ចំពោះព្រះសាស្ដា ។ កាលនោះ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធ ហើយប្រារព្ធនូវតំណែងនោះ ព្រះមហាវីរបុរស ទ្រង់អនុមោទនាថា សេចក្ដីប្រាថ្នានៃនាងនឹងបានសម្រេចក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងនៅក្នុងលោក ។ នាងនឹងបាន

ជាញាតិក្នុងធម៌ទាំងឡាយ នៃព្រះសាស្តានោះ ជាឱរស ជាធម្មនិមិត្ត ជាសាវិកានៃព្រះសាស្តា មានឈ្មោះថា **សោណា** ។ កាលនោះ ខ្ញុំបានស្តាប់ ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះសម្មាសម្ពុទ្ធ ជានាយកនៃសត្វលោក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំបានធ្វើល្អហើយនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្ស នេះហើយ ក៏បានទៅកើតក្នុងស្ថានតាវត្តិង្ស បានអន្ទោលកើត និងស្លាប់ នៅក្នុងទេវតា និងមនុស្សអស់កាលដ៏យូរអង្វែង ។

ជីវប្រវត្តិបច្ចុប្បន្នជាតិរបស់ព្រះនាងសោណាភិក្ខុនី មានសម្តែង នៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី ក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** និងក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

កាលកន្លងមកបានមួយសែនកប្ប ក្នុងភទ្ទកប្បនេះ ដែលត្រូវនឹង ពុទ្ធុប្បាទកាលនៃព្រះមានព្រះភាគនៃយើងទាំងឡាយនេះ ខ្ញុំបានមកកើត

ក្នុងត្រកូលនៃសេដ្ឋី ជាត្រកូលស្តុកស្តម្ភធំទូលាយ មានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរ និងមានឈ្មោះថា សោណា ប្រែថា មាស ។ កាលណាខ្ញុំដល់នូវវ័យទៅនៅត្រកូលប្តី បានបង្កើតកូន ១០ នាក់ មានរូបល្អប្លែកៗ គ្នា ។ កូនទាំងអស់នោះ ស្ថិតនៅក្នុងសេចក្តីសុខ ជាទីគាប់ភ្នែក និងចិត្តនៃជន សូម្បីសត្រូវទាំងឡាយក៏គង់គាប់ចិត្តដែរ នឹងចាំបាច់និយាយថ្វីដល់កូនទាំងនោះ ដែលជាទីស្រឡាញ់របស់ខ្ញុំ ។ ក្នុងកាលតមក ស្វាមីរបស់នាងខ្ញុំ មានបំណងនឹងបួសក្នុងព្រះពុទ្ធសាសនា ខ្ញុំ និងកូនៗ ម្នាក់ៗ នាំគ្នាហាមឃាត់ តែស្វាមីរបស់នាងខ្ញុំ មានចិត្តពិតប្រាកដក្នុងការបួស សូម្បីខ្ញុំជំទាស់យ៉ាងណាក៏មិនយល់ព្រម ក្នុងទីបំផុតស្វាមីរបស់ខ្ញុំ ក៏បានទៅបួសទាល់តែបាន ។ ចំណែកខ្ញុំនៅគ្រប់គ្រងផ្ទះតមក ដោយមានកូនប្រុសស្រី ១០ នាក់ចោមរោម នាងគិតពិចារណាឲ្យបុត្រធីតាទាំងឡាយ មានគូគ្រប់គ្រង មានផ្ទះសម្បែង ហើយខ្ញុំក៏បានរៀបចំឲ្យកូនប្រុសស្រី មានករិយាស្វាមីនៅគ្រប់គ្រងផ្ទះ ។ ក្រោយពីនាងសោណារៀបចំ ឲ្យកូនប្រុសស្រីនាងហើយ កូនប្រុសស្រី និងកូន

ប្រសាទាំងនោះរបស់នាង មិនព្រមនាំគ្នាបដិបត្តិបម្រើមាតា តាមដែលធ្លាប់ធ្វើរួចមកហើយទេ បែរទៅជានាំគ្នាពោលពាក្យមើលងាយមាតាថា មាតាមិនបានធ្វើប្រយោជន៍អ្វីឲ្យពួកយើងសោះ ដោយមិនបានព្រមនាំគ្នាទទួលដឹងព្ធចំពោះមាតា ដែលមកដល់ផ្ទះរបស់ខ្លួន ដោយមិនព្រមហៅថាម៉ែ ។ នាងសោណា ដឹងថា កូនប្រុសស្រីទាំងនោះ មិនបានគោរពខ្លួនហើយ ទើបគិតរំពឹងតែម្នាក់ឯងថា ការដែលស្ត្រីមេម៉ាយ ព្រាត់ប្រាសចាកស្វាមី និងកូន ដូច្នេះ មិនមានប្រយោជន៍អ្វីសោះ ដែលយើងត្រូវរស់នៅក្នុងផ្ទះនេះតទៅទៀត ដើម្បីឲ្យបុគ្គលទាំងនោះមើលងាយយើង នាងបានគិតដល់ស្វាមីរបស់នាង ដែលចាកចោលនាងទៅបួសថា ឥឡូវនេះស្វាមីរបស់យើងនៅក្នុងទីណា យើងគួរនឹងទៅក្នុងទីនោះ ។ កាលណានាងសោណាគិតសម្រេចចិត្តដូច្នេះហើយ នាងទើបទៅកាន់សម្នាក់របស់ភិក្ខុនី ហើយសូមបព្វជ្ជាជាភិក្ខុនី នាងក៏ត្រូវបានទទួលអនុញ្ញាត ឲ្យបួសនៅក្នុងធម្មវិន័យសមតាមបំណាង ។ កាលបើនាងសោណា បានបំពេញឧបសម្បទាជាភិក្ខុនីហើយ តែនាងបានបួស ក្នុងខណៈដែលនាងមាន

អាយុច្រើនហើយនោះ ការប្រព្រឹត្តបដិបត្តិវិញ គង់នឹងមានការខ្វះខាតពុំខានឡើយ ។

គ្រាមួយ ភិក្ខុនីទាំងឡាយបានដាក់ទណ្ឌកម្ម ( ការដាក់ទោស ) ដល់សោណាភិក្ខុនីថា សោណាភិក្ខុនីមិនដឹងវត្តបដិបត្តិ ( កិច្ចដែលគួរធ្វើ ) បានធ្វើអំពើដែលមិនសមគួរ ។ ចំណែកឯកូនប្រុសស្រីរបស់នាងបានឃើញសោណាភិក្ខុនីដែលជាម្តាយ ត្រូវជាប់ទណ្ឌកម្ម ម្នាក់ៗ នាំគ្នានិយាយចំអកចំអន់ថា ភិក្ខុនីរូបនេះ បួសមករហូតដល់ថ្ងៃនេះហើយនៅតែមិនទាន់ចេះសិក្ខាបទ នាងសោណាភិក្ខុនី បានស្តាប់ពាក្យនិយាយចំអកចំអន់របស់កូនៗ ហើយ កើតការតក់ស្លុតចិត្ត ទើបគិតពិចារណាមើលខ្លួនឯងថា យើងបួសនៅក្នុងវ័យចាស់ជរា គួរជាអ្នកមិនប្រមាទយើងគួរនឹងធ្វើគតិ ( ដំណើរផ្លូវ ) ឲ្យបរិសុទ្ធផូរផង់ ហើយនាងក៏ផ្តើមបរិកម្មការនាអាការៈ ៣២ ដែលមាននៅក្នុងខ្លួនយើង គឺ កេសា សក់ទាំងឡាយ លោមា រោមទាំងឡាយ នខា ក្រចកទាំងឡាយ ទន្តា ធ្មេញទាំងឡាយ តចោ ស្បែក មំសំ សាច់ នហារូ សរសៃទាំងឡាយ

**អដ្ឋិ** ឆ្អឹងទាំងឡាយ **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង **វក្កំ** ទាច **ហទយំ** បេះដូង **យកនំ** ថ្លើម **កិលោមកំ** វាវ **បិហកំ** ក្រពះ **បប្ផាសំ** សួត **អន្តំ** ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ **បិត្តំ** ប្រមាត់ **សេម្ហំ** ស្លេស្ម **បុព្វោ** ខ្ទុះ **លោហិតំ** ឈាម **សេទោ** ញើស **មេទោ** ខ្លាញ់ខាប់ **អស្សុ** ទឹកភ្នែក **វសា** ខ្លាញ់រាវ **ខេឡោ** ទឹកមាត់ **សិង្ឃាណិកា** ទឹកសម្បោរ **លសិកា** ទឹករំអិល **មុត្តំ** ទឹកមូត្រ ។ ខ្ញុំតម្កល់ចិត្តមាំ បរិកម្មភាវនា ទាំងក្នុងទីអង្គុយ ឈរ ឬដើរ ខ្ញុំបានតម្កល់ចិត្តមាំ ធ្វើនូវសមណធម៌ នៅរហូតដល់យប់ ដោយទប់ខ្លួននឹងសសរកុដិខាងក្រោម ដើរវិលទៅមក វេលាខ្ញុំដើរចង្ក្រមក្នុងទីងងឹតក៏គិតក្រែងថា សរីរៈរបស់ខ្ញុំប៉ះទង្គិចវត្ថុណាមួយ មានមែកឈើជាដើម ខ្ញុំទើបចាប់តោងដើមឈើដើរវិលជុំវិញ ចាប់ដើមអំពីនោះមក ទើបប្រាកដឈ្មោះថា **ព្រះនាងសោណាភិក្ខុនី** អ្នកមានព្យាយាមបរិបូណ៌ ដោយសេចក្តីព្យាយាម ។ ថ្ងៃមួយ ភិក្ខុនីទាំងឡាយបាននាំគ្នាទៅកាន់វិហារ ដើម្បីទៅទទួលឱវាទ តែមុននឹងចេញទៅ បាន

នាំគ្នាពោលប្រាប់ដល់ព្រះនាងសោណាថេរីថា នាងចូរដាំទឹកទុកឲ្យភិក្ខុនីទាំងឡាយ ស្រង់សិនហើយចាំទៅ ។ ព្រះនាងសោណាភិក្ខុនី ត្រូវគេបោះបង់ឲ្យនៅចាំលំនៅរបស់ភិក្ខុនី ថែមទាំងប្រាប់ឲ្យដាំទឹកទុកទៀតផង គ្រានោះ ខ្ញុំបាននាំទឹកមកហើយ ចាក់អំពីក្អម តម្កល់ទុកក្នុងភាជនៈតូច ហើយអង្គុយតម្កល់ចិត្តមាំ ក្នុងខណៈនោះ ខ្ញុំទើបផ្តើមសេចក្តីព្យាយាមផ្លូវចិត្ត ដោយបានពិចារណាឃើញនូវខន្ធ ៥ ទាំងឡាយថា មិនទៀងជាទុក្ខ និងជាអនត្តា ដោយខ្ញុំបានញ៉ាំងវិបស្សនាឲ្យចម្រើនឡើង ដោយលំដាប់ ។ គ្រានោះ ព្រះសម្ពុទ្ធគង់នៅក្នុងព្រះគន្ធកុដិ ទ្រង់បានបញ្ចេញព្រះរស្មីឲ្យទៅប្រាកដ ដូចជាព្រះអង្គប្រថាប់ឈរនៅក្នុងទីចំពោះមុខនៃសោណាភិក្ខុនី ហើយព្រះលោកនាថទ្រង់ត្រាស់ព្រះគាថា ថា

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនបានឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

លុះចប់ព្រះធម៌ទេសនាហើយ ខ្ញុំក៏បានសម្រេចអរហត្តផល ជា

ព្រះអរហន្ត ហើយខ្ញុំគិតថា ខ្ញុំបានសម្រេចជាព្រះអរហន្តហើយ ដូច្នេះ កាលភិក្ខុនីទាំងឡាយត្រឡប់មកវិញ មិនបានពិចារណាជាមុន ហើយ អាចនឹងពោលមើលងាយចំពោះយើងយ៉ាងណានីមួយនោះ ប្រាកដជា មានបាបធ្ងន់ដល់ភិក្ខុនីទាំងនោះ ព្រោះដូច្នោះ យើងគួរធ្វើហេតុយ៉ាងណា មួយ ឲ្យជាគ្រឿងសង្កេតដឹងសម្រាប់ភិក្ខុនីទាំងនោះ ។ កាលនាងគិត ដូច្នេះហើយ ទើបអធិដ្ឋានតេជោធាតុ ( ធាតុភ្លើង ) ហើយញុំាងទឹក ឲ្យក្តៅយ៉ាងរហ័ស ។ លុះដល់ភិក្ខុនីទាំងនោះ ត្រឡប់មកអំពីវិហារវិញ បានក្រឡេកមើលត្រង់ចង្ក្រាន មិនឃើញមានភ្លើង ទើបនាំគ្នាពោលថា ពួកយើងបានប្រាប់ដល់ភិក្ខុនីចាស់នេះថា នាងចូរដាំទឹក ទុកឲ្យភិក្ខុនី ទាំងឡាយស្រង់ជាមុនសិន ហើយទើបចាំទៅ តែរហូតដល់ពេលនេះ នាងក៏នៅមិនទាន់បានបង្កាត់ភ្លើងទៀត ។ សោណាភិក្ខុនី បានពោលជា មួយភិក្ខុនីទាំងនោះដោយពាក្យដ៏សុភាពទន់ភ្លន់ មិនបានសម្តែងអាការៈ ក្រោធចេញមកទេ ហើយបានពោលថា បពិត្រនាងជាម្ចាស់ទាំងឡាយ ពួកនាងត្រូវការអ្វីជាមួយនឹងភ្លើង កាលបើពួកនាងមានបំណងនឹងងូតទឹក

ក្តៅ សូមទៅដងមកអំពីកាជនៈនោះមកផ្ទួតចុះ ៗភិក្ខុនីទាំងនោះគិតជញ្ជឹងថា គង់នឹងមានហេតុយ៉ាងណាមួយជាពិតប្រាកដ ទើបយកម្រាមដៃជ្រលក់ទៅក្នុងទឹក ក៏ដឹងថាជាទឹកក្តៅ កាលភិក្ខុនីទាំងនោះដឹងថា ជាទឹកក្តៅហើយទើបយកកាជនៈដងទឹកយកមកផ្ទួត ។ ហេតុអស្ចារ្យ បានប្រាកដឡើងត្រង់កាជនៈដាំទឹករបស់ព្រះនាងសោណាភិក្ខុនី គឺបណ្តាភិក្ខុនីទាំងនោះម្នាក់ៗ ក៏យកកាជនៈទៅដងទឹកមកផ្ទួត ចំណែកទឹកក្នុងកាជនៈ ដែលសោណាភិក្ខុនីប្រើដាំទឹកដោយតេជោធាតុ ក៏នៅតែពេញដដែល មិនខ្វះខាតអ្វីឡើយ ។ គ្រានោះ ភិក្ខុនីទាំងនោះ ក៏បានដឹងថា សោណាភិក្ខុនីបានសម្រេចជាព្រះអរហន្តីហើយ ពួកភិក្ខុនីដែលមានអាយុនៅក្មេងជាងម្នាក់ៗ ក៏បាននាំគ្នា ក្រាបចុះទៀបជើងនាង ហើយពោលសូមខមាទោសថា បពិត្រព្រះនាងជាម្ចាស់ ពួកខ្ញុំមិនបានពិចារណាឲ្យដឹងជាមុន ហើយនិយាយបៀតបៀននាងមកអស់កាលដ៏យូរហើយ សូមព្រះនាងជាម្ចាស់អត់ទោស ឲ្យដល់ពួកខ្ញុំម្ចាស់ផង ។

ចំណែកឯភិក្ខុនីមានអាយុចាស់ជាង ក៏បានអង្គុយចុះពោលសូម

ខមាទោសថា បពិត្រព្រះនាងជាម្ចាស់ ពួកខ្ញុំម្ចាស់មិនបានពិចារណាឲ្យដឹងមុន បានពោលពាក្យបៀតបៀននាងមកអស់កាលដ៏យូរហើយណាស់ដែរ ហេតុដូច្នេះ សូមព្រះនាងជាម្ចាស់អត់ទោសឲ្យដល់ពួកខ្ញុំផងចុះ ។ សោណាភិក្ខុនី ដែលជាអ្នកមានចិត្តផុតស្រឡះចាកអាសវក្កិលេស ជាអ្នកមានចិត្តផូរផង់បរិសុទ្ធ នៅសល់តែសេចក្តីប្រាថ្នាល្អ ចំពោះអ្នកដទៃតែម្យ៉ាងប៉ុណ្ណោះ ទឹកចិត្តរបស់នាងប្រៀបដូចទឹកស្អាត ប្រាសចាកមន្ទិល អ្នកផឹកទឹក ឬអ្នកប្រើប្រាស់ទឹក នឹងបានទទួលនូវប្រយោជន៍ តែម្យ៉ាងប៉ុណ្ណោះ ដូច្នោះ នាងទើបមិនក្រោធតបនឹងភិក្ខុនីទាំងនោះ ថែមទាំងបានអត់ទោសឲ្យគ្រប់ៗ គ្នាទៀតផង ។ ចាប់តាំងពីកាលដែលសោណាភិក្ខុនីសូម្បីជាអ្នកបួសនៅក្នុងវ័យចាស់ជរា តែនាងអាចបដិបត្តិធម៌ជរាបបានសម្រេចអរិយផល ថ្នាក់ខ្ពង់ខ្ពស់បំផុតក្នុងព្រះសាសនានេះ ដោយនាងខំព្យាយាមធ្វើសមណធម៌ មិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្តីទាំងនេះព្រោះនាងខំចម្រើនសេចក្តីព្យាយាមជាទីតាំង ដោយអាស្រ័យហេតុ នៃការព្យាយាមរបស់នាង កិត្តិគុណដែលជាសេចក្តីល្អ របស់នាង

ក៏បានផ្សព្វផ្សាយទូទៅ ។

ព្រះនាងសោណាភិក្ខុនី បានទទួលការលើកតម្កើងពីព្រះសាស្តា ផ្នែកខាងជាអ្នកមានព្យាយាមបរិបូណ៌ តាមដែលមានសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះលោកនាថ គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ព្រះអង្គបានប្រកាសតែងតាំងភិក្ខុនីទាំងឡាយ ទុកក្នុងតំណែងផ្សេងៗទៅតាមអភិនីហារបារមី ឬចរិតអធ្យាស្រ័យដែលខ្លួនធ្លាប់សន្សំមកហើយអំពីអតីតជាតិ ប៉ុន្តែនៅក្នុងពេលនោះដែរ ព្រះលោកនាយកព្រះអង្គក៏បានទ្រង់ប្រកាសតែងតាំងព្រះនាងសោណាភិក្ខុនី ទុកនៅក្នុងតំណែងដ៏ប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងជាអ្នកមាននូវសេចក្តីព្យាយាមបរិបូណ៌ថា

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ អារទ្ធវីរិយានំ យទិទំ សោណា** ម្នាលភិក្ខុទាំងឡាយ សោណាភិក្ខុនី ជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ជាសាវិការបស់តថាគត ផ្នែកខាងជាអ្នក

មានព្យាយាមបរិបូណ៌ ។

ឯព្រះតម្រាស់ដែលត្រាស់សរសើរព្រះនាងសោណាភិក្ខុនី ដូចមានសម្តែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដែលជាការពោលអំពីជីវប្រវត្តិខ្លួនឯងផ្ទាល់ដោយព្រះថេរី គឺក្រោយពីនាងបានសម្រេចជាព្រះអរហន្តីហើយ ដូចដែលបានពោលរួចមកហើយពីខាងដើម ក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** នោះឯង ថា ៖

ភិក្ខុនីទាំងឡាយ ដែលធ្លាប់បានពោលមើលងាយ ចំពោះព្រះនាងសោណាថេរី ថាជាអ្នកបួសចាស់ មិនចេះចាំខ.បដិបត្តិអ្វីៗ តែកាលបានជ្រាបថា នាងបានសម្រេចជាព្រះអរហន្តីហើយ ភិក្ខុនីទាំងអស់នោះម្នាក់ៗ ក៏នាំគ្នាឆ្ងល់ ហើយបានចូលទៅគាល់ក្រាបបង្គំទូលព្រះមានជោគឲ្យទ្រង់ជ្រាបក្នុងរឿងនោះ ។ គ្រានោះ ព្រះជិនស្រី ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ព្រះអង្គក៏បានទ្រង់ត្រាស់សរសើរថា អ្នកមានសេចក្តីព្យាយាមប្រារព្ធហើយ មានជីវិតរស់នៅតែមួយថ្ងៃ នៅតែប្រសើរជាងបុគ្គលអ្នកខ្ជិលច្រអូស លះបង់នូវសេចក្តីព្យាយាម សូម្បីមានជីវិតរស់

នៅមួយរយឆ្នាំ មិនប្រសើរទេ ។ ព្រះអង្គបានត្រាស់ថា សោណាថេរី ជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងជាអ្នកមាននូវព្យាយាមបរិបូណ៌ ។ លំដាប់នោះ ព្រះនាងសោណាថេរី បានពោលថា ខ្ញុំបានដុតបំផ្លាញកិលេសហើយ ភពទាំងអស់ ខ្ញុំក៏បានគាស់រំលើងចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱហ្ន៎ ! ខ្ញុំកើតមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

នៅមានរឿងទាក់ទងការពោលគាថា របស់ព្រះនាងសោណាថេរី ក្រោយអំពីនាងបានសម្រេចអរហត្តផល ជាព្រះអរិយបុគ្គលថ្នាក់ខ្ពស់បំផុត ក្នុងព្រះពុទ្ធសាសនានេះហើយ តាមដែលមានសម្តែងទុកនៅក្នុងគម្ពីរខុទ្ទកនិកាយ ថេរីគាថា ដូចមានសេចក្តីថា ៖

ថ្ងៃមួយ ព្រះនាងសោណាភិក្ខុនី បានពិចារណាមើលការបដិបត្តិ

របស់ខ្លួន បានពោលគាថា ៤ គាថាឡើងថា អាត្មាអញ បានសម្រាលកូន ១០ ក្នុងសរីរៈ គឺរូបនេះ ព្រោះហេតុនោះ អាត្មាអញមានកម្លាំងថយ គ្រាំគ្រា បានចូលទៅរកភិក្ខុនីមួយរូប ។ លោកបានសម្តែងធម៌ គឺខន្ធ អាយតនៈ ធាតុ ដល់អាត្មាអញ លុះអាត្មាអញបានស្តាប់ធម៌របស់លោកហើយ ក៏បានកោរសក់បួស អាត្មាអញនោះ កំពុងសិក្សា ( សិក្ខា ៣ ) បានជម្រះទិព្វចក្ខុ ដឹងនូវបុព្វេនិវាស ដែលអាត្មាអញបានអាស្រ័យនៅហើយក្នុងកាលមុន ។ អាត្មាអញមានអារម្មណ៍តែមួយ មានចិត្តតម្កល់មាំ ចម្រើនអនិមិត្តវិមោក្ខ ជាអ្នកបានវិមោក្ខក្នុងលំដាប់ (នៃមគ្គដ៏ប្រសើរ) រំលត់កិលេសហើយ ព្រោះមិនប្រកាន់មាំ ។ បញ្ចក្ខន្ធ អាត្មាអញបានកំណត់ហើយ មានឫសផ្តាច់ផ្តិលហើយ អាត្មាអញ មិនមានតណ្ហា ដែលកើតអំពីវត្ថុ ដែលតាំងនៅ ឥឡូវនេះ ភពថ្មីមិនមាន ។

មួយទៀត មានគតិធម៌សម្រាប់រឿងនេះ ជីវិតរបស់ព្រះនាងសោណាថេរី ជាជីវិតដែលគួរឲ្យអាណិតណាស់ ព្រោះកាលនាងអាយុច្រើនហើយ ស្វាមីក៏ទៅបួសចោល នាងមានកូនប្រុសស្រី ១០ នាក់

នាងបានរៀបចំឲ្យកូនៗ មានគូគ្រប់គ្រងផ្ទះសម្បែង រហូតទាំងអស់ ទៅតាមតួនាទីជាឪពុកម្ដាយ តែក្រោយមកមានរឿងប្រាកដថា នាងមិនអាចទីពឹងកូនណាមួយបានឡើយ កូនរបស់នាងជាមនុស្សអកតញ្ញូទាំងអស់ បុរាណថា **កូន ១០ នាក់ ឪពុក ឬម្ដាយតែម្នាក់ អាចចិញ្ចឹមកូនបាន តែឪពុក ឬម្ដាយតែម្នាក់ កូន ១០ មិនអាចចិញ្ចឹមបាន** ។ នរណាៗ មិនគួរកាន់យកជាគំរូ កាលបើធ្វើដូចជាកូនៗ ទាំង ១០ នាក់ របស់ព្រះនាងសោណាថេរី រមែងទទួលបាននូវការតិះដៀលអំពីសម្នាក់សប្បុរសជាច្រើន ព្រោះជាកូន **អកតញ្ញូ** គឺជាអ្នកមិនដឹងនូវឧបការគុណរបស់អ្នកដទៃ ឬអ្នកមានគុណ ។

បុគ្គលជាមនុស្សអកតញ្ញូចំពោះមាតាបិតា ជាមនុស្សដែលមិនគួរសេពគប់ ព្រោះថាសូម្បីមាតាបិតារបស់គេ ដែលជាអ្នកមានគុណច្រើនចំពោះគេដល់ម្ល៉េះហើយ នៅតែគេមិនដឹងគុណ ឬគោរពរាប់អាន ឬតបស្នងសងគុណទៅហើយ ចុះអ្នកដទៃវិញ គេនឹងដឹងគុណដូចម្ដេចទៅ ។ មនុស្សអកតញ្ញូ សូម្បីដល់នូវសេចក្ដីចម្រើននោះ ក៏ចម្រើន

មិនបានយូរប៉ុន្មាន ត្រូវមានការប្រែប្រួលទៅ ប្រៀបដូចបុគ្គល ដែលព្រោះស្រូវនៅលើថ្មបាយក្រៀម រមែងមិនដុះលូតលាស់បានយ៉ាងណា បុគ្គលដែលជាអកតញ្ញូ ក៏មិនដុះលូតលាស់ឡើងដូច្នោះដែរ ។ មនុស្សអកតញ្ញូ ទទួលបានតែនូវការតិះដៀលពីអ្នកដទៃថា ជាមនុស្សមិនល្អ ប្រសិនបើមិនមានបុណ្យចាស់ ចូលមកជួយឧបត្ថម្ភទេនោះ គេក៏នឹងទទួលគុណវិបត្តិយ៉ាងណានីមួយ ។ ទោះបីថា មនុស្សអកតញ្ញូនោះ ជាមនុស្សមានបញ្ញាច្រើនយ៉ាងណាក៏ដោយ កាលបើគេអស់បុណ្យចាស់ក្នុងវេលាណាហើយ វេលានោះ គេនឹងត្រូវបានទទួលទោស ដែលកើតមកអំពីផលនៃអកតញ្ញូ យ៉ាងពិតប្រាកដ ដោយមិនសង្ស័យ ។

ព្រោះដូច្នោះ បុគ្គលមិនត្រូវជាមនុស្សអកតញ្ញូ ចំពោះមាតាបិតា គ្រូអាចារ្យ ឬអ្នកមានគុណជាដាច់ខាត ព្រោះប្រសិនបើមនុស្សអកតញ្ញូ មានចំពោះលោកអ្នកមានគុណហើយ បុគ្គលនោះ នឹងចូលដល់នូវសេចក្តីវិនាស យ៉ាងពិតប្រាកដ ។៚

( ជីវប្រវត្តិរបស់ព្រះនាងសោណាថេរី ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាងសកុលាថេរី ✍

## " ព្រះនាងសកុលាថេរីជាឯតទគ្គៈផ្នែកខាងមានទិព្វចក្ខុ "

ព្រះនាងសកុលាថេរី ជាអ្នកទ្រទ្រង់នូវអច្ឆរិយធម៌ ថែមទាំងបាន ទទួលការលើកតម្កើងពីព្រះលោកនាយកថា ជាស្រ្តីអ្នកមានគុណធម៌ ជា ឧបាសិកា ដែលជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនានេះ តាំងពី នៅវ័យក្មេងៗ ទើបរាប់ថាជាស្រ្តីមានគុណធម៌ ដែលជាតួយ៉ាង ទាំងជា អ្នកបានទទួលការលើកតម្កើងពីព្រះមហាមុនី ទុកក្នុងតំណែងជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកមានទិព្វចក្ខុ ។

ជីវប្រវត្តិរបស់ព្រះនាងសកុលាភិក្ខុនី ក៏មានសម្តែងទុកទាំងក្នុង អតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។ តាមដែលមានរឿងពោលទុកក្នុង អដ្ឋកថាមនោរថបូរណី ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៅក្នុង គម្ពីរអង្គុត្តរនិកាយ ឯកនិបាត និងក្នុង អដ្ឋកថាបរមត្ថទីបនី ដែលជា អដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង គម្ពីរខុទ្ទកនិកាយ ថេរីគាថា ថា ៖

ក្នុងអតីតកាល ព្រះនាងសកុលាភិក្ខុនីនេះ ធ្លាប់បានកើតនៅក្នុងរាជត្រកូលជាព្រះរាជធីតារបស់ព្រះបាទនន្ទរាជ ក្នុងនគរហង្សវតី ត្រូវនឹងពុទ្ធកាលនៃព្រះបទុមុត្តរសម្ពុទ្ធ ព្រះនាងទ្រង់បានជាព្រះភគិនីផ្សេងពីព្រះមាតារបស់ព្រះលោកនាថ និងទ្រង់មានព្រះនាមថា **នន្ទា** ។ ថ្ងៃមួយកាលព្រះនាងធំដឹងក្តីហើយ ព្រះនាងបានទៅស្តាប់ព្រះធម៌ទេសនា ក្នុងសម្នាក់របស់ព្រះបទុមុត្តរសម្ពុទ្ធ ។ គ្រានោះ ព្រះនាងបានទតឃើញព្រះបរមសាស្តា ទ្រង់បានប្រកាសតែងតាំងភិក្ខុនីមួយរូប ទុកក្នុងតំណែងជាឯតទគ្គៈ គឺឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងមានទិព្វចក្ខុ ព្រះនាងឃើញដូច្នោះហើយ ក៏នឹកពេញចិត្ត ទើបជាបច្ច័យធ្វើឲ្យព្រះនាងកើតការពេញចិត្ត ធ្វើបុណ្យកុសលឡើង ហើយក៏បានតាំងបណិធាន គឺសេចក្តីប្រាថ្នាក្នុងតំណែងនោះ ព្រះនាងក៏បានប្រឹងប្រែងធ្វើសេចក្តីល្អរហូតអស់ព្រះជន្មរបស់ព្រះនាង ។ កាលព្រះនាងសោយទិវង្គតទៅហើយ ព្រះនាងបានទៅកើតក្នុងទេវលោក បានត្រាច់រង្គាត់ទៅមក គឺស្លាប់កើតៗ ស្លាប់ នៅតែក្នុងសុគតិទេវលោកប៉ុណ្ណោះ ។ តមក ក្នុង

ពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ ព្រះនាងបានទៅកើតក្នុងត្រកូលព្រាហ្មណ៍ កាលដែលនាងធំដឹងក្តីហើយ បានទៅបួសជាបរិព្វាជិកា ប្រក្រតីរបស់នាងតែងតែត្រាច់ទៅតែម្នាក់ឯង ។ ថ្ងៃមួយ នាងបានដើរទៅសូមប្រេងលុះបានប្រេងហើយ នាងក៏បានយកប្រេងនោះ ទៅដុតធ្វើជាប្រទីបបូជាព្រះចេតិយរបស់ព្រះកស្សបសម្ពុទ្ធ រហូតនៅទល់ភ្លឺ ដោយអំណាចផលនៃការបូជាព្រះចេតិយនោះ កាលនាងអស់ជីវិតទៅហើយ បានទៅកើតក្នុងស្ថានតាវត្តិង្ស និងជាអ្នកមានទិព្វចក្ខុ ហើយបានកើតស្ទាប់ៗ កើតក្នុងទេវលោកអស់មួយពុទ្ធន្តរ ។

ក្នុងពុទ្ធកាល នៃព្រះសមណគោតមបរមគ្រូនៃយើងនេះ នាងបានមកកើតក្នុងត្រកូលព្រាហ្មណ៍មួយ ក្នុងក្រុងសាវត្ថី នាងមានឈ្មោះថា **សកុលា** ។ កាលនាងសកុលានោះ ធំដឹងក្តីហើយ គឺអាចដឹងការខុសត្រូវតាមប្រក្រតីសាមញ្ញហើយ និងជាហេតុ ដែលធ្វើឲ្យនាងកើតមានសេចក្តីជ្រះថ្លាក្នុងព្រះសាសនានេះ រហូតមានឈ្មោះថាជាឧបាសិកាក្នុងគ្រាដែលព្រះលោកនាយក ទ្រង់ទទួលការថ្វាយវត្តជេតពន របស់

អនាថបិណ្ឌិកសេដ្ឋីកសាងថ្វាយនៅក្នុងក្រុងសាវត្ថី ។ កាលតមក នាងសកុលាឧបាសិកា បានស្ដាប់ព្រះធម៌ក្នុងសម្នាក់របស់ព្រះខីណាស្រពមួយរូប នាងក៏កើតសេចក្ដីសង្វេគ ទើបសម្រេចចិត្តបួសជាភិក្ខុនីក្នុងព្រះពុទ្ធសាសនានេះ ។ ក្រោយពីព្រះនាងសកុលាភិក្ខុនីបួសហើយ ក៏មានសេចក្ដីព្យាយាមចម្រើននូវវិបស្សនា ( ប្រែថា ការឃើញច្បាស់សំដៅដល់ ការធ្វើឲ្យចិត្តស្ងប់អស់កាពពាយមាយ គឺឃើញថា សង្ខារទាំងឡាយដែលកើតអំពីបច្ច័យតាក់តែងទាំងពួងមិនទៀង ជាទុក្ខ មិនមែនខ្លួន ) ដោយការខំព្យាយាមចម្រើនយ៉ាងនេះ មិនយូរប៉ុន្មាន នាងក៏បានសម្រេចជាព្រះអរហន្តី ( គឺជាអ្នកឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ជាព្រះអរិយបុគ្គលថ្នាក់ខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនានេះ ) ។

ព្រោះដូច្នោះ ក្រោយពីនាងបានសម្រេចជាព្រះអរហន្តីហើយ នាងក៏បានពោលអំពីជីវប្រវត្តិនៅក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិដោយខ្លួនឯង តាមដែលមានសម្ដែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្ដីថា ៖

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ជាបុគ្គលអាជានេយ្យ ប្រតិបត្តិដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីសេចក្តីចម្រើនដល់សព្វសត្វក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ ព្រះវិជិតមារ ទ្រង់ដល់នូវយសដ៏ប្រសើរ មានសិរីពេញពោរទៅដោយកេរ្តិ៍ឈ្មោះ និងសេចក្តីសរសើរដែលលោកទាំងពួងបូជាហើយ ប្រាកដក្នុងទិសទាំងពួង ។ ព្រះអង្គមានសេចក្តីសង្ស័យឆ្លងហើយ មានសេចក្តីងឿងឆ្ងល់កន្លងបង់ហើយ មានសេចក្តីត្រិះរិះក្នុងព្រះទ័យបរិបូណ៌ហើយ ទ្រង់ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះសម្ពុទ្ធប្រសើរជាងនរជន ទ្រង់ញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើងផង សម្តែងនូវមគ្គដែលមិនទាន់សម្តែងផង បណ្តុះនូវមគ្គដែលមិនទាន់បណ្តុះផង ។ ព្រះលោកនាយក ជាអ្នកអង់អាចជាងនរជន ព្រះអង្គជ្រាបនូវមគ្គ ត្រាស់ដឹងនូវមគ្គ ប្រាប់នូវមគ្គ ជាគ្រូប្រៀនប្រដៅដ៏ឧត្តម ប្រសើរជាងសារថីទាំងឡាយ ។ ព្រះសក្យមុនី ព្រះអង្គប្រកប

ដោយព្រះទ័យករុណាដ៏ធំ ជាទីពឹងនៃសត្វលោក ជាអ្នកដឹកនាំសត្វលោក ទ្រង់សម្ដែងព្រះធម៌ស្រោចស្រង់នូវសត្វទាំងឡាយ ដែលមុជចុះក្នុងភព គឺកាម ។ កាលនោះ ខ្ញុំកើតក្នុងក្រុងហង្សវតី **ឈ្មោះខត្តិយនន្ទា** ជាស្រី មានរូបល្អ ប្រកបដោយទ្រព្យ មានចិត្តអាណិតអាសូរចំពោះអ្នកដទៃ ជាស្រីមានសិរី ។ ខ្ញុំជាធីតានៃមហារាជ **ព្រះនាមអានន្ទ** ជាស្រីមានលម្អ ដ៏ប្រសើរ ជាប្អូនស្រីមានមាតាផ្សេងគ្នា នៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ខ្ញុំស្អិតស្អាង ដោយគ្រឿងអាភរណៈទាំងពួង ជាមួយនឹងព្រះរាជកញ្ញា ទាំងឡាយហើយ ចូលទៅគាល់ព្រះពុទ្ធ ទ្រង់មានព្យាយាមធំ ហើយ ស្ដាប់ធម៌ទេសនា ។

គ្រានោះ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ទ្រង់តាំងភិក្ខុនីនោះ ដែលមានចក្ខុ ដូចជាទិព្វ ក្នុងឋានៈដ៏ប្រសើរ ក្នុងកណ្ដាលនៃបរិស័ទ ទាំង ៤ ។ បរិស័ទទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ ខ្ញុំបានស្ដាប់ ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ ថ្វាយទានដល់ព្រះសាស្ដា បានបូជាដល់ព្រះសម្ពុទ្ធ ដោយគ្រឿងសក្ការៈផ្សេងៗ ហើយប្រាថ្នានូវ

ទិព្វចក្ខុ ។ លំដាប់នោះ ព្រះលោកនាយក បានត្រាស់នឹងខ្ញុំថា នាងនឹងបានសម្រេចតាមសេចក្តីប្រាថ្នានូវតំណែងនោះ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនឹងបានជាព្រះញាតិ ជាសាវិកាព្រះមានជោគ មានឈ្មោះថា **សកុលា** ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងស្ថានតាវត្តិង្ស ។ ក្នុងភទ្ទកប្បនេះ ( កប្បដ៏ចម្រើន ) ព្រះពុទ្ធព្រះនាមកស្សបៈ ព្រះអង្គមានផៅពង្សដ៏ប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតក្នុងភទ្ទកប្បនេះ ។ កាលនោះ ខ្ញុំបួសជានាងបរិព្វាជិកា ប្រព្រឹត្តម្នាក់ឯង ត្រាច់ទៅដើម្បីភិក្ខា បាននូវវត្ថុត្រឹមតែប្រេងប៉ុណ្ណោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានអុជប្រទីបដោយប្រេងនោះ បូជាព្រះចេតិយដ៏ប្រសើរសមរម្យជាងចេតិយទាំងពួង នៃព្រះលោកនាថដ៏ប្រសើរជាងសត្វមានជើងពីរ ។ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់

បេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងស្ថានតាវត្តិង្ស ដោយផលនៃកម្ម ខ្ញុំកើតក្នុងទីណាៗ ប្រទីបដ៏ធំទាំងឡាយ បំភ្លឺដល់ខ្ញុំ នៅក្នុងទីនោះៗ ។ ខ្ញុំប្រាថ្នារបស់ណា ខ្ញុំឃើញ ( របស់នោះ ) ធ្លុះរហូតខាងក្រៅជញ្ជាំង ធ្លុះរហូតខាងក្រៅនៃភ្នំថ្ម នេះជាផលនៃការឲ្យប្រទីប ។ ខ្ញុំជាអ្នកមានភ្នែកស្អាត ជាអ្នករុងរឿងដោយយសមានសទ្ធា មានប្រាជ្ញា នេះជាផលនៃការឲ្យប្រទីប ។

ឥឡូវនេះ ដល់បច្ឆិមកព ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ មានទ្រព្យនិងស្រូវច្រើន ជាត្រកូលរីករាយ ដែលស្តេចរាប់អានបូជាហើយ ។ ខ្ញុំបរិបូណ៌ដោយអវយវៈគ្រប់យ៉ាង ស្អិតស្អាងដោយអាភរណៈទាំងពួង ខ្ញុំឈរនៅត្រង់បង្អួច ឃើញព្រះលោកនាថ ត្រង់ប្រទេសជាទីចូលទៅកាន់បុរី ។ ខ្ញុំឃើញព្រះពុទ្ធរុងរឿងដោយយស ដែលទេវតា និងមនុស្សធ្វើសក្ការៈហើយ ទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ស្អិតស្អាងដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ខ្ញុំមានចិត្តរីករាយជ្រះថ្លា ពេញចិត្តក្នុងការបូជា ។ កាលខ្ញុំបួសមិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត ។

ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមសាសនានៃព្រះសាស្ដា ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំបានញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកស្អាតបរិសុទ្ធ មិនមានមន្ទិលឡើយ ។ ព្រះសាស្ដាខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំក៏បានដាក់ចោលហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ ដែលជាធម៌ធ្វើឲ្យអស់សំយោជនៈ ( កិលេសដែលចងសត្វទុកនៅក្នុងវដ្តសង្សារ ) ទាំងពួង ទាំងខ្ញុំបានសម្រេចហើយ ។

លំដាប់នោះ ព្រះពុទ្ធអង្គប្រសើរជាងនរជន ព្រះលោកនាយកប្រកបដោយមហាករុណា ទ្រង់តាំងខ្ញុំជាឯតទគ្គៈ ដោយព្រះពុទ្ធដីកាថា **នាងសកុលាថេរី** ជាភិក្ខុនីប្រសើរបំផុត ជាងថេរីទាំងឡាយ ដែលមានទិព្វចក្ខុ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូច

មេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱហ្ន៎ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ( បានដល់ **១- បុព្វេនិវាសានុស្សតិញ្ញាណ** គឺរឭកដឹងជាតិបាន **២- ចុតូបបាតញ្ញាណ** គឺកំណត់ដឹងចុតិ និងកើត **៣- អាសវក្ខយញ្ញាណ** គឺដឹងធ្វើអាសវៈឲ្យអស់ទៅ ) ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ ( បានដល់ **១- អត្ថប្បដិសម្ភិទា** គឺបញ្ញាបែកធ្លាយក្នុងអត្ថ **២- ធម្មប្បដិសម្ភិទា** គឺបញ្ញាដែលបែកធ្លាយក្នុងធម៌ **៣- និរុត្តិប្បដិសម្ភិទា** គឺបញ្ញាដែលបែកធ្លាយក្នុងភាសា **៤- បដិភាណប្បដិសម្ភិទា** គឺបញ្ញាដែលបែកធ្លាយក្នុងបដិភាណ ដោយពោលឆ្លើយតបបានភ្លាមៗ ) វិមោក្ខ ៨ ( បានដល់ បុគ្គលអ្នកមានរូបជ្ឈាន ( បុគ្គលនោះបានរូបាវចរជ្ឈានទាំង ៤ ព្រោះអាស្រ័យកសិណជាវត្ថុខាងក្នុង មានសក់ជាដើមជារបស់ខ្លួន ) តែងឃើញរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជាវិមោក្ខទី ១ បុគ្គលមិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុង មានសក់ជាដើមរបស់ខ្លួន ( បុគ្គលដែលបានរូបាវចរជ្ឈាន មិនអាស្រ័យនឹងអាការ

មានសក់ជាដើមរបស់ខ្លួន ) តែងឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម នេះជាវិមោក្ខទី ២ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណ ដែលបរិសុទ្ធ ( បុគ្គលដែលបានឈាន ព្រោះអាស្រ័យវណ្ណកសិណ មាននីលកសិណជាដើម ដែលបរិសុទ្ធថ្លៃថ្លាជាងបុគ្គលទី ១-២ ) នេះជាវិមោក្ខទី ៣ បុគ្គលដែលកន្លងនូវរូបសញ្ញា ដល់នូវសេចក្ដីវិនាសនៃបដិឃសញ្ញា ទាំងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយចូលទៅកាន់អាកាសានញ្ចាយតនជ្ឈានដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ បុគ្គលដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកនៅក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយ

ប្រការទាំងពួង ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ បុគ្គលដែលកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់សញ្ញាវេទយិតនិរោធ ( សេចក្តីរលត់នៃសញ្ញា និងវេទនា ) នេះជាវិមោក្ខទី ៨ ។ និងអភិញ្ញា ៦ នេះ ( បានដល់ ១- **ឥទ្ធិវិធិ** គឺសម្តែងឫទ្ធិបាន ២- **ទិព្វសោត** គឺត្រចៀកទិព្វ ៣- **ចេតោបរិយញ្ញាណ** គឺកំណត់ដឹងចិត្តអ្នកដទៃ ៤- **បុព្វេនិវាសានុស្សតិញ្ញាណ** គឺរឭកដឹងជាតិបាន ៥- **ទិព្វចក្ខុ** គឺភ្នែកទិព្វ ៦- **អាសវក្ខយញ្ញាណ** គឺដឹងធ្វើឲ្យអាសវៈអស់ ) ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានបដិបត្តិហើយ ។

កាលព្រះនាងសកុលាភិក្ខុនី បានសម្រេចដល់អរហត្ត ជាព្រះអរហន្តីហើយ ជាអ្នកស្ទាត់ជំនាញក្នុងទិព្វចក្ខុ ព្រោះភាពជាអ្នកបានកសាងបុណ្យបារមីទុកមកហើយ ព្រោះដូច្នោះ ព្រះទសពល ព្រះអង្គក៏បានតែងតាំងព្រះថេរី ទុកក្នុងតំណែងដ៏ប្រសើរ ក្នុងកណ្តាលបរិស័ទទាំង ៤ ដូចមានសម្តែងនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ ទិព្វចក្ខុកានំ យទិទំ សកុលា ម្នាលភិក្ខុទាំងឡាយ សកុលាថេរីជាឯតទគ្គៈ គឺអ្នកប្រសើរជាង ភិក្ខុនីទាំងឡាយ ដែលជាសាវិការបស់តថាគត ផ្នែកខាងមានចក្ខុទិព្វ ឬភ្នែកទិព្វ ។

ព្រះនាងសកុលាថេរីនោះ បានពិចារណាដល់ការបដិបត្តិនៃខ្លួន ក៏កើតបីតិសោមនស្ស បានពោលគាថាទាំងនេះជាឧទាន ដែលមាន សម្តែងនៅក្នុង គម្ពីរខុទ្ទកនិកាយ ថេរីគាថា ថា ៖

អាត្មាអញ កាលនៅក្នុងផ្ទះ បានស្តាប់ធម៌របស់ភិក្ខុនីហើយ ឃើញធម៌ ប្រាសចាកធូលី គឺកិលេស ជាធម៌នាំសត្វឲ្យចេញចាក តណ្ហា ជាហេតុនាំឲ្យបានសេចក្តីសុខ មិនឃ្លាត ។ អាត្មាអញនោះ បានបោះបង់ចោលនូវកូនប្រុសផង កូនស្រីផង ទ្រព្យ និងស្រូវផង បានឲ្យគេកោរសក់ ហើយមកបួសក្នុងធម្មវិន័យ ។ អាត្មាអញ កាល នៅជាសិក្ខមានា បានញ៉ាំងមគ្គខាងលើឲ្យកើត បានលះបង់រាគៈ និង ទោសៈផង អាសវៈទាំងឡាយ ដែលតាំងនៅជាមួយគ្នានឹងរាគៈ ទោសៈ

នោះផង ។ លុះអាត្មាអញ បានឧបសម្បទាជាភិក្ខុនីហើយ ក៏រឭកឃើញនូវបុព្វជាតិ ទាំងទិព្វចក្ខុមិនមានមន្ទិល ដែលពួកសប្បុរសចម្រើនហើយ ក៏អាត្មាអញបានជម្រះហើយ ។ អាត្មាអញ បានឃើញសង្ខារទាំងឡាយ ដែលកើតអំពីហេតុ មានសភាពទ្រុឌទ្រោម ថាជារបស់ដទៃ ហើយបាន លះអាសវៈទាំងអស់ ជាអ្នកមានចិត្តត្រជាក់ បានរំលត់ទុក្ខហើយ ។៚

( ជីវប្រវត្តិរបស់ព្រះនាងសកុលាថេរី ចប់ )

8888888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះនាងកិសាគោតមីថេរី ✍

## “ ព្រះនាងកិសាគោតមីថេរីជាឯតទគ្គៈផ្នែកខាងទ្រទ្រង់ចីវរដ៏សៅហ្មង ”

ព្រះថេរីជាអ្នកទ្រទ្រង់នូវអរិយធម៌ថ្នាក់ខ្ពង់ខ្ពស់បំផុត នៅក្នុងព្រះពុទ្ធសាសនានេះ ថែមទាំងជាអ្នកបានទទួលតំណែងជាឯតទគ្គៈ គឺបានទទួលការលើកតម្កើងអំពីព្រះលោកនាយក ឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងទ្រទ្រង់ចីវរដ៏សៅហ្មង ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិ របស់ព្រះនាងកិសាគោតមីថេរី មានសម្ដែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយបាលីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ ថេរីគាថា** និងនៅក្នុង **អដ្ឋកថាធម្មបទ នៃ សហស្សវគ្គ** ក្នុង **រឿងកិសាគោតមី** ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនជិត

ក្រុងសាវត្ថី ព្រះអង្គបានត្រាស់ប្រាប់រឿងនាងកិសាគោតមី ទើបទ្រង់ត្រាស់ធម្មទេសនា ដើម្បីប្រោសដល់នាងកិសាគោតមី និងពុទ្ធបរិស័ទច្រើននាក់ទៀត ឲ្យបានសម្រេចមគ្គផល ទៅតាមបុណ្យបារមីដែលខ្លួនបានសន្សំមករៀងៗ ខ្លួន ។ គ្រានោះ នាងកិសាគោតមី ( ពាក្យថា **គោតមី** ជាឈ្មោះដើមរបស់នាង ពាក្យថា **កិសា** ជាពាក្យដែលពួកអ្នកស្រុកហៅ ដោយមានសេចក្ដីថា **ស្គម ឬ ស្តើង** ) ជាធីតារបស់ត្រកូលអ្នកកម្សត់ទ្រព្យសម្បត្តិ ឬទីទ័លក្រម្នាក់ នៅក្នុងក្រុងសាវត្ថី ។ កាលនាងកិសាគោតមី ចម្រើនវ័យធំដឹងក្ដីហើយ ល្មមអាចនឹងមានគូស្រករគ្រប់គ្រងផ្ទះបាន តែមុនដែលនាងមានគូស្រករជាមេគ្រួសារនោះ បានមានវត្ថុប្រាប់នូវហេតុជាសុភនិមិត្តថា នាងកិសាគោតមី ជាអ្នកមានបុណ្យបារមីច្រើន ដែលអាចជួយឲ្យដល់ត្រកូលស្វាមី ដោយមិនមាននរណាមួយគិតស្មានដល់ ។ព្រោះថា នៅក្នុងក្រុងសាវត្ថី មានសេដ្ឋីម្នាក់ជាអ្នកមានទ្រព្យសម្បត្តិ ៤០ កោដិ តែទ្រព្យសម្បត្តិទាំង ៤០ កោដិនោះបានដល់ភាពវិបរិត គឺការប្រែប្រួល ធ្វើឲ្យទ្រព្យសម្បត្តិទាំងអស់នោះ

ក្លាយទៅជាធ្យូង យកទៅប្រើប្រាស់ធ្វើអ្វីមិនកើត សេដ្ឋីនោះក៏ដល់នូវសភាពជាមនុស្សទ្រីទ័លក្រម្នាក់នៅក្នុងក្រុងនោះទៅ ។ កាលលោកសេដ្ឋីបានក្រឡេកឃើញទ្រព្យ ដែលមានការវិបរិតនោះហើយ ក៏បានកើតការតូចចិត្ត ទុក្ខទោមនស្ស ថែមទាំងមិនបរិភោគអាហារ បានដេកស្ងៀមនៅលើគ្រែ ដោយគិតជញ្ជឹងលំបាកក្នុងចិត្ត មិនដឹងគិតធ្វើយ៉ាងណា ទើបជាការល្អ ។ គ្រានោះ មានសម្លាញ់ម្នាក់ ដែលជាសេដ្ឋីបានមកសួរសុខទុក្ខ ដោយមកជួបលោកកំពុងតែដេកនៅលើគ្រែ សម្តែងនូវអាការអស់សង្ឃឹម មានលក្ខណៈឲ្យប្រាកដដឹងបានថា កំពុងតែមានទុក្ខលំបាក រហូតដល់បរិភោគអាហារមិនបាន សម្រាន្តមិនលក់ គេឃើញដូច្នោះហើយ ទើបសួរសម្លាញ់ថា តើអ្នកមានហេតុអ្វី បានជាអ្នកមានសេចក្តីសោកសៅទុក្ខលំបាកចិត្តដូច្នេះ ? គ្រានោះ សេដ្ឋីបុត្រ ក៏បាននិយាយរឿងរ៉ាវទាំងអស់នោះ ប្រាប់ដល់សេដ្ឋីដែលជាសម្លាញ់បានជ្រាប ។

លំដាប់នោះ សេដ្ឋីដែលជាសម្លាញ់បាននិយាយលួងលោមចិត្តសម្លាញ់ថា សម្លាញ់កុំតូចចិត្តអ្វីឡើយ ខ្ញុំដឹងឧបាយម្យ៉ាង ដែលនឹង

អាចជួយសម្លាញ់បាន ចំពោះទ្រព្យដែលក្លាយទៅជាធ្យូង ឲ្យក្លាយមកជាទ្រព្យដូចដើមវិញបាន ។ គ្រានោះ សេដ្ឋីបុត្របានសួរទៅសេដ្ឋីបុត្រដែលជាសម្លាញ់ ដោយមានការសប្បាយចិត្តថា តើយើងគប្បីធ្វើយ៉ាងណាសម្លាញ់ ចូរជួយប្រាប់ឧបាយនោះមកចុះ យើងនឹងព្រមធ្វើតាមគ្រប់យ៉ាង ។ លំដាប់នោះ សេដ្ឋីបុត្រដែលជាសម្លាញ់បានប្រាប់ឧបាយនោះថា លោកចូរយកកន្ទេលទៅក្រាលក្នុងទីផ្សារ ហើយជញ្ជូនមាសនិងប្រាក់យកទៅដាក់លើកន្ទេលនោះ ដោយធ្វើឲ្យជាគំនរជំ ដូចមនុស្សលក់ធ្យូង ហើយអង្គុយចាំសង្កេតមើលថា មនុស្សទាំងឡាយ ដែលដើរមកដល់ហើយ គេទាំងនោះនិយាយគ្នាយ៉ាងណា ។ ប្រសិនបើមានអ្នកណាមកដល់ទីផ្សារនោះហើយ អ្នកនោះនិយាយថា អ្នកដទៃៗ បានលក់វត្ថុផ្សេងៗ មានសំពត់ ប្រេង ទឹកឃ្មុំ ជាដើម ចំណែកលោកមកអង្គុយលក់ធ្យូងទៅវិញ កាលបើមានគេនិយាយយ៉ាងនេះហើយ លោកត្រូវតបថា កាលបើខ្ញុំមិនលក់របស់របរនេះ តើឲ្យខ្ញុំលក់អ្វីទៅ ? ប៉ុន្តែប្រសិនបើមានគេនិយាយថា អ្នកដទៃមកលក់សំពត់ ប្រេង ទឹកឃ្មុំ

ជាដើម រីឯលោកមកអង្គុយលក់មាស និងប្រាក់ទៅវិញ កាលមានគេនិយាយយ៉ាងនេះ លោកត្រូវនិយាយថា មាស និងប្រាក់នៅទីណា ? កាលអ្នកនោះនិយាយថា នុ៎ះមាស ប្រាក់ លោកត្រូវប្រាប់គេថា ចូរនាំយកមកមើល កាលបើគេចាប់ឡើងយកមកឲ្យមើល លោកត្រូវទទួលទុក ព្រោះរបស់ដែលគេឲ្យយ៉ាងនេះ នឹងក្លាយជាមាស និងប្រាក់បានពិតប្រាកដ ហើយលោកចូរពោលជាមួយនឹងអ្នកនោះថា មាស និងប្រាក់ទាំងអស់នេះជារបស់អ្នកៗ ចូរមករស់នៅជាមួយនឹងយើងចុះ ប្រសិនបើអ្នកនោះជាកុមារី គឺជាស្រី លោកត្រូវនាំយកមកធ្វើជាភរិយានៃបុត្ររបស់លោក ហើយប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់នាងកុមារីនោះ ចំណែកលោកចូរប្រើប្រាស់ទ្រព្យដែលកុមារីនោះឲ្យចុះ ។ បើអ្នកនោះជាបុរស លោកចូរលើកធីតាឲ្យទៅគេ ហើយប្រគល់ទ្រព្យ ៤០ កោដិឲ្យគេដែរ ហើយប្រើប្រាស់ចំពោះមាស និងប្រាក់ដែលគេឲ្យចុះ ។ លោកសេដ្ឋីទទួលព្រមថា ឧបាយនេះជាឧបាយដ៏ល្អ ហើយបានធ្វើតាមពាក្យណែនាំរបស់សម្លាញ់ ដោយជញ្ជូនមាស និងប្រាក់ទៅចាក់ជាគំនរ

លើកនេះលក្កុងទីផ្សារ ហើយនៅអង្គុយចាំមើលដូចជាអ្នកលក់ធ្យូង ។

អ្នកខ្លះមកឃើញហើយក៏ពោលថា អ្នកដទៃៗគេលក់សំពត់ លក់ប្រេង លក់ទឹកឃ្មុំជាដើម រីឯលោកមកអង្គុយលក់ធ្យូង ។ លោកសេដ្ឋីនិយាយតបទៅជាមួយនឹងអ្នកនោះវិញថា បើខ្ញុំមិនលក់របស់របរ ដែលខ្ញុំមាន តើឲ្យខ្ញុំធ្វើអ្វី ? គ្រានោះ នាងកិសាគោតមី ដែលជាធីតារបស់ត្រកូលកម្សត់ឥតទ្រព្យម្នាក់ បានទៅដល់ផ្សារ ដោយកិច្ចណានីមួយរបស់ខ្លួន ក៏បានឃើញលោកសេដ្ឋី ទើបសួរថា បពិត្របិតា អ្នកដទៃៗគេលក់សំពត់ ប្រេង ទឹកឃ្មុំជាដើម ហេតុអ្វីទើបលោកមកអង្គុយលក់មាស និងប្រាក់ដូច្នេះ ? ទើបលោកសេដ្ឋីសួរថា មាស និងប្រាក់នៅទីណា កូនស្រី ? នាងកិសាគោតមីឆ្លើយថា ចាសត្រង់គំនរនោះឯង ។ លោកសេដ្ឋីពោលថា បើដូច្នោះ កូនចូរចាប់យកមកឲ្យបិតាមើលបន្តិច ។ នាងកិសាគោតមី ទើបចាប់យកមាស និងប្រាក់ ពេញមួយក្តាប់ដៃឲ្យលោកសេដ្ឋីមើល ។ មាស និងប្រាក់ដែលក្លាយជាធ្យូងនោះ ក៏ត្រឡប់ក្លាយជាមាស និងប្រាក់ដូចដើមវិញ ។ លោកសេដ្ឋីមានការចាប់អារម្មណ៍

ចំពោះនាងកិសាគោតមីជាទីបំផុត ព្រោះនាងជាអ្នកដែលយើងត្រូវស្វែងរក និងត្រូវគ្នានឹងឧបាយ ដែលសម្លាញ់ណែនាំមក ទើបសួរថា កូនឈ្មោះអ្វី ? ផ្ទះរបស់កូននៅទីណា ? នាងកិសាគោតមីឆ្លើយថា ខ្ញុំឈ្មោះថា **គោតមី** តែអ្នកដទៃហៅខ្ញុំ តាមដែលខ្ញុំស្គម ដោយផ្ដើមពាក្យថា **កិសា** រួមឈ្មោះថា **កិសាគោតមី** ។ លោកសេដ្ឋីសួរតទៅទៀតថា នាងមានប្ដីហើយឬនៅ ? នាងឆ្លើយថា ចាំខ្ញុំនៅមិនទាន់មានប្ដីទេ លោកសេដ្ឋីមានការពេញចិត្តណាស់ កាលដឹងថា នាងកិសាគោតមីនៅមិនទាន់មានប្ដី ទើបប្រគល់មាស និងប្រាក់ ទាំងនោះឲ្យ និងទៅនិយាយសូមស្ដីដណ្ដឹងដល់ឪពុកម្ដាយ របស់នាងកិសាគោតមី ហើយយកមកធ្វើជាកូនប្រសាររបស់ខ្លួន ទាំងបានប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់នាង ។ ទ្រព្យ ៤០ កោដិដែលក្លាយជាធ្យូងនោះ បានក្លាយមកជាមាស និងប្រាក់ដូចដើម ។ នាងកិសាគោតមី កាលចូលមកជាកូនប្រសានៅក្នុងផ្ទះរបស់លោកសេដ្ឋី ហេតុតែនាង ជាអ្នកមកពីត្រកូលឥតទ្រព្យ ទើបត្រូវបុគ្គលទាំងឡាយក្នុងផ្ទះលោកសេដ្ឋី មិនដឹងគុណនាង

ម្នាក់ៗ និយាយស្តី និងធ្វើអាការមើលងាយប្រមាថនាងថា ជាកូនក្រមុំរបស់មនុស្សទ័លក្រ ធ្វើហាក់បីដូចជានាងមកអាស្រ័យនៅក្នុងបុណ្យនៃត្រកូលសេដ្ឋីនេះ ទើបនាងមានការតូចចិត្ត ។ ប៉ុន្តែនាងកិសាគោតមីនៅគ្រប់គ្រងផ្ទះរួមជាមួយស្វាមី រហូតមកនាងបានតាំងគភ៌ កាលនាងមានគភ៌គ្រប់ ១០ ខែ នាងក៏បានប្រសូតបុត្រ ។ ការមានបុត្ររបស់នាងកិសាគោតមី ធ្វើឲ្យនាងបានទទួលការលើកតម្កើង រាប់អានពីបណ្ដាពពួកញាតិខាងប្ដី ដែលធ្លាប់តែនិយាយមើលងាយនាង ។ សភាពប្រែប្រួលពីអាក្រក់មកល្អ ជួយឲ្យជីវិតរបស់នាងកិសាគោតមី មានសេចក្ដីសុខសប្បាយស្រស់បស់ឡើងវិញ ។ ហេតុការណ៍ ដែលគួរសោកសៅតូចចិត្ត ដែលមិនមាននរណា អាចស្មានដឹងមុនបាន ក៏បានកើតឡើងដល់នាងកិសាគោតមីយ៉ាងច្រើនបំផុត ដែលនាងមិនធ្លាប់បានប្រទះ ព្រោះកូនរបស់នាង កាលចាប់ផ្ដើមធំ ក្នុងវ័យដែលគួរស្រឡាញ់ស្រាប់តែកូននោះស្លាប់ចោលនាងទៅ ។ នាងកិសាគោតមីមានសេចក្ដីសោក ក៏គិតថា យើងជាអ្នកបំផ្លាញលាភ និងសក្ការៈក្នុងផ្ទះនេះ នាង

គិតថា ចាប់តាំងអំពីកូនប្រុសកើតមក យើងជាអ្នកមានលាភ និងសក្ការៈ បុគ្គលទាំងនេះនឹងយកកូនប្រុសយើងទៅចោល នាងគិតដូច្នេះ ព្រោះ មិនដឹងថា កូនប្រុសរបស់នាងស្លាប់ទៅហើយទេ ។

កាលបើកូនប្រុសរបស់នាងស្លាប់ទៅហើយ បុគ្គលទាំងឡាយ យកកូនប្រុសរបស់នាងទៅដុត នាងក៏ហាមឃាត់ មិនព្រមឲ្យយកទៅ ដុតឡើយ ទាំងនេះ ព្រោះនាងមិនធ្លាប់ឃើញមនុស្សស្លាប់មកពីមុន ហើយនាងគិតថា យើងនឹងសួររកថ្នាំ ដើម្បីនាំមកប្រស់កូនប្រុសរបស់ យើង នាងទើបបីសាកសពកូនប្រុស ដើរសួរទៅតាមលំដាប់ផ្ទះថា លោកទាំងឡាយដឹងថ្នាំប្រស់កូនប្រុសរបស់ខ្ញុំឬទេ ? បុគ្គលទាំងឡាយ ស្តាប់សំណួររកថ្នាំប្រស់កូនរបស់នាង ម្នាក់ៗប្រាប់ថា ថ្នាំសម្រាប់ប្រស់ មនុស្សស្លាប់នាងធ្លាប់ឃើញទីណា ? នាងឆ្កួតឬ ? ទើបដើរសួររកថ្នាំ ប្រស់កូនដែលស្លាប់ហើយ បុគ្គលទាំងនោះ ម្នាក់ៗ ទះដៃ ធ្វើការចំអក ចំអន់នាងដោយអាការផ្សេងៗ ។ នាងកិសាគោតមីដើរចេញទៅ ព្រោះ សម្តីចំអកចំអន់របស់បុគ្គលទាំងនោះ តែនាងក៏នៅតែយល់ថា គង់នឹង

បានជួបអ្នកដែលដឹងថ្នាំប្រស់កូនឲ្យរស់ឡើងវិញ ។ កាលនោះ មាន
បុរសជាបណ្ឌិតម្នាក់ ក្រឡេកឃើញនាងកិសាគោតមីកំពុងដើរបីសាក
សពកូន ទើបគិតថា ប្រហែលជាបុត្រដំបូងហើយ ទើបនាងមានចិត្ត
រាយមាយ ព្រោះសេចក្តីសោកចំពោះបុត្រ យើងនឹងជួយសង្គ្រោះស្ត្រី
នេះ ក៏ប្រាប់នាងកិសាគោតមីថា ខ្ញុំមិនដឹងថ្នាំទេ តែដឹងអ្នកដែលស្គាល់
ថ្នាំប្រស់កូនឲ្យរស់វិញ ។ នាងកិសាគោតមីទើបសួរថា លោកដែល
ស្គាល់ថ្នាំប្រស់នោះជានរណា ? ហើយនៅទីណា ? បុរសនោះតបថា
ព្រះសាស្តា ទ្រង់ជាអគ្គបុគ្គលប្រសើរក្នុងលោក ព្រមទាំងទេវលោក
ប្រថាប់នៅវត្តជេតពន ជិតក្រុងសាវត្ថីនេះ ព្រះអង្គទ្រង់ស្គាល់ថ្នាំប្រស់
កូននាងឲ្យរស់វិញ សូមនាងទៅកាន់សម្នាក់ព្រះអង្គ និងក្រាបទូលសួរ
ព្រះអង្គចុះ នាងកិសាគោតមីពោលថា ល្អហើយ ខ្ញុំនឹងទៅក្រាបទូល
សួរព្រះអង្គ ហើយក៏បីសាកសពកូនចូលទៅគាល់ព្រះសាស្តា ដោយ
ឈរនៅខាងចុងបរិស័ទ កាលព្រះសាស្តាប្រថាប់លើពុទ្ធាសនៈហើយ
ក៏ក្រាបទូលសួរថា បពិត្រព្រះសម្ពុទ្ធ បានឮថា ព្រះអង្គទ្រង់ស្គាល់ថ្នាំ

ប្រស់កូនឲ្យរស់វិញឬ ព្រះអង្គ ? ព្រះមានព្រះភាគត្រាស់ថា នែនាង កិសាគោតមី តថាគតស្គាល់ ។ នាងកិសាគោតមី ក្រាបទូលសួរថា ព្រះអង្គត្រូវការវត្ថុអ្វីខ្លះដែលធ្វើជាថ្នាំ ? ព្រះភគវា ត្រាស់ថា តថាគត ត្រូវការគ្រាប់ស្ពៃមួយក្ដាប់ ។

គ្រានោះ នាងកិសាគោតមីក្រាបទូលថា ខ្ញុំព្រះអង្គនឹងរកមក ថ្វាយឲ្យទាល់តែបាន តែថាមិនដឹងទៅរកគ្រាប់ស្ពៃក្នុងទីណា ព្រះអង្គ ? ព្រះលោកនាថ ទ្រង់ត្រាស់ថា នែនាងកិសាគោតមី នាងចូរទៅក្នុងក្រុង ដោយដើរពេញក្នុងក្រុងសាវត្ថី តាំងពីដើមរហូតដល់ទីបំផុត បើនៅក្នុង ផ្ទះណាមួយ មិនធ្លាប់មានមនុស្សស្លាប់ នាងចូរយកគ្រាប់ស្ពៃពីផ្ទះនោះ មកឲ្យតថាគត ។ នាងកិសាគោតមីក្រាបទូលទទួលថា ព្រះករុណា ព្រះអង្គ ហើយនាងក៏សប្បាយចិត្ត បានក្រាបថ្វាយបង្គំលាព្រះទសពល ដោយបីសាកសពកូនប្រុសចូលទៅក្នុងក្រុងសាវត្ថី ។ លំដាប់នោះ នាង កិសាគោតមីចូលទៅក្នុងផ្ទះមួយខ្នងជាលើកដំបូងបានសួរថា លោកម្ចាស់ ផ្ទះនេះមានគ្រាប់ស្ពៃឬទេ ប្រសិនបើមាន ខ្ញុំសូមយកទៅធ្វើថ្នាំប្រស់ឲ្យ

កូនរបស់ខ្ញុំរស់ឡើងវិញ ។ ម្ចាស់ផ្ទះតបថា មាន ហើយយកគ្រាប់ស្ពៃមកឲ្យនាង ។ ពេលនោះ នាងកិសាគោតមីមុននឹងទទួលគ្រាប់ស្ពៃ បានសួរម្ចាស់ផ្ទះថា ក្នុងផ្ទះរបស់អ្នក មានអ្នកណាៗ ស្លាប់ហើយឬទេ ? គ្រានោះ ម្ចាស់ផ្ទះតបថា កិសាគោតមី ហេតុអ្វីនាងសួរយ៉ាងនេះ មានអ្នកណាខ្លះ ដែលនឹងរាប់ចំនួនមនុស្ស ដែលស្លាប់ហើយក្នុងផ្ទះនេះបាន អ្នកដែលមានជីវិតរស់នៅសល់តិចណាស់ ឯអ្នកដែលស្លាប់មានច្រើនជាងណានាង ។ ពេលនោះ នាងកិសាគោតមីពោលថា ប្រសិនបើយ៉ាងនោះ អ្នកចូរយកគ្រាប់ស្ពៃរបស់អ្នកត្រឡប់ទៅវិញចុះ គ្រាប់ស្ពៃនេះមិនអាចធ្វើថ្នាំប្រស់ឲ្យកូនប្រុសរបស់យើងបានទេ ព្រោះថា ព្រះភគវាទ្រង់ត្រាស់ឲ្យខ្ញុំយកតែគ្រាប់ស្ពៃអំពីផ្ទះ ដែលមិនមានមនុស្សស្លាប់តែប៉ុណ្ណោះ ។ នាងកិសាគោតមី ក៏បានដើរទៅរកគ្រាប់ស្ពៃក្នុងផ្ទះបន្តបន្ទាប់ទៅទៀត ក៏បានទទួលពាក្យតបពីម្ចាស់ផ្ទះគ្រប់ៗ ផ្ទះ ដូចៗ គ្នាទាំងអស់ ។ សូម្បីនាងបានដើរទៅពាសពេញទីក្រុង ទៅតាមព្រះពុទ្ធតម្រាស់របស់ព្រះលោកនាយក រហូតដល់វេលាល្ងាច នាងក៏កើតការតក់ស្លុតចិត្តថា

ខ្ញុំយល់ថា សេចក្តីស្លាប់មានចំពោះកូនខ្ញុំតែប៉ុណ្ណោះ តែតាមការពិត មនុស្សស្លាប់មានច្រើនជាងមនុស្សដែលរស់នៅ ដោយហេតុនេះ ព្រះមានជោគ ទ្រង់អនុគ្រោះដោយប្រយោជន៍ ។ កាលនាងកិសាគោតមីបានគិតឃើញដូច្នេះហើយ ចិត្តដែលទន់ភ្លន់ព្រោះស្រឡាញ់កូន ក៏កើតការរឹងរូសចបេស នាងទើបចេញពីផ្ទះ ទៅខាងក្នុងក្រុង ដោយឆ្ពោះមុខទៅកាន់ព្រៃខ្មោច ។ លុះនាងចូលទៅដល់ព្រៃខ្មោចហើយ នាងក៏បាននិយាយជាមួយនឹងកូនដែលបីនៅក្នុងដៃរបស់នាងថា កូនសម្លាញ់ម៉ែៗបានគិតថា ការស្លាប់នេះមានចំពោះកូនតែម្នាក់ប៉ុណ្ណោះ ប៉ុន្តែមរណធម៌នេះជាធម៌ដែលកើតទូទៅដល់សត្វលោកទាំងអស់ រួចហើយនាងបានដាក់កូនប្រុសចោលក្នុងព្រៃខ្មោច នាងបានពោលគាថាថា

ធម៌ណា ដែលមានឈ្មោះថា អនិច្ចតា គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយៗទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយៗទេឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗក៏មិនមែនទេ អនិច្ចតាធម៌នោះជាធម៌សម្រាប់មនុស្ស

សត្វ ព្រមទាំងទេវតា មារ ព្រហ្មទាំងអស់គ្រប់រូប ។

លុះនាងកិសាគោតមីពោលដូច្នេះហើយ នាងបានត្រឡប់ចូលទៅគាល់ព្រះវិជិតមារ ថ្វាយបង្គំរួចហើយ ឈរនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះសក្យមុនីទ្រង់ត្រាស់សួរថា នែនាងកិសាគោតមី នាងបានគ្រាប់ស្ពៃឬទេ ? នាងកិសាគោតមីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរកគ្រាប់ស្ពៃតាមពុទ្ធបំណាងមិនបានទេ ព្រោះក្នុងផ្ទះមួយៗ មានមនុស្សស្លាប់ច្រើនជាងមនុស្សដែលរស់នៅ ខ្ញុំព្រះអង្គឈប់រកគ្រាប់ស្ពៃហើយ តែសូមព្រះលោកនាថទ្រង់ព្រះករុណា ប្រទានទីពឹង ឲ្យដល់ខ្ញុំព្រះអង្គផង ។ លំដាប់នោះ ព្រះសក្យមុនីត្រាស់ថា នែនាងកិសាគោតមី នាងយល់ថា កូនរបស់នាងប៉ុណ្ណោះទេដែលស្លាប់ តែការស្លាប់នោះ ជាទំនៀមការពិតសម្រាប់សត្វលោក ព្រោះថា មច្ចុរាជ តែងតែទាញយកសត្វលោកទាំងពួងទៅ អ្នកដែលមានអធ្យាស្រ័យ មិនទាន់គ្រប់គ្រាន់នូវបំណង រមែងរំកិលចុះទៅក្នុងសមុទ្រ គឺអបាយ ( ទឹកទន្លេដែលគ្មានសេចក្ដីចម្រើន ឬមានតែសេចក្ដីវិនាស ) ដូចអន្លង់ទឹកដ៏ធំក្ដួចនាំយក

សត្វលោកទាំងពួងទៅដូច្នោះដែរ ព្រះទសពលក៏ទ្រង់ត្រាស់សម្តែងធម៌ ទើបត្រាស់នូវព្រះគាថាថា

មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នោះឯង ដូចទឹកជំនន់ដ៏ធំ ដែលកួចយកអ្នកស្រុកកំពុងតែដេកលក់ទៅដូច្នោះឯង ។

កាលព្រះបរមសាស្តា ទ្រង់ត្រាស់សម្តែងព្រះគាថានេះចប់ នាងកិសាគោតមី ក៏បានសម្រេចសោតាបត្តិផល ជាព្រះអរិយបុគ្គលថ្នាក់ដំបូងក្នុងព្រះពុទ្ធសាសនានេះ ពុទ្ធបរិស័ទទាំងឡាយ ដែលមកប្រជុំគ្នាក្នុងទីនោះ ក៏បានសម្រេចសោតាបត្តិផលជាដើមផងដែរ ទៅតាមបុណ្យបារមីរៀងៗ ខ្លួន ។ គ្រានោះ នាងកិសាគោតមី ដែលបានសម្រេចសោតាបត្តិផលហើយ ទើបក្រាបទូលសូមបព្វជ្ជា ចំពោះព្រះទសពល ព្រះអង្គក៏ទ្រង់អនុញ្ញាតឲ្យនាងបួស ដោយបានបញ្ជូននាង ឲ្យទៅកាន់សម្នាក់ភិក្ខុនី ។ នាងក៏បានថ្វាយបង្គំព្រះមានបុណ្យ រួចប្រទក្សិណ ៣ ជុំ

ហើយក៏បានទៅកាន់សម្នាក់ភិក្ខុនី កាលនាងបានបំពេញឧបសម្បទាហើយ ក៏ប្រាកដឈ្មោះថា **កិសាគោតមីថេរី** ។ ថ្ងៃមួយ ព្រះនាងកិសាគោតមីថេរី ដល់វារៈទទួលនាទីចាត់ចែងដុតប្រទីបក្នុងរោងឧបោសថ ព្រះថេរីក៏បាន ឃើញអណ្តាតប្រទីបឆេះសន្ធោសន្ធៅឡើង និងរលត់ទៅវិញ នាងក៏បាន កាន់យកជាអារម្មណ៍ថា សត្វលោកដែលកើតមកហើយ ត្រូវតែស្លាប់ ទៅវិញ ដូចជាអណ្តាតនៃប្រទីបនេះដូច្នេះឯង ។ រីឯអ្នកដល់នូវព្រះនិព្វាន ហើយ មិនប្រាកដយ៉ាងនោះទេ នាងបានធ្វើទុកក្នុងចិត្តដោយឧបាយនៃ ប្រាជ្ញាយ៉ាងនេះ វិបស្សនាញាណក៏បានចម្រើនឡើងហើយ ។ គ្រានោះ ព្រះពុទ្ធអង្គគង់នៅក្នុងព្រះគន្ធកុដិ ព្រះអង្គក៏បានបញ្ចេញឆព្វណ្ណរង្សីទៅ ហាក់បីដូចថា ព្រះបរមសាស្តាគង់ប្រថាប់នៅខាងមុខព្រះថេរី ត្រាស់ថា យ៉ាងនោះឯងកិសាគោតមី សត្វលោកដែលកើតមកហើយ ត្រូវតែមាន សេចក្តីស្លាប់ជាទីបំផុត ដូចជាអណ្តាតប្រទីបនោះឯង អ្នកដល់នូវព្រះ និព្វានហើយ រមែងមិនប្រាកដយ៉ាងនេះឡើយ ព្រះអង្គទើបទ្រង់ត្រាស់ ព្រះគាថាថា

បុគ្គលណា កាលមិនបានឃើញនូវការកើត និងការសូន្យទៅ (នៃបញ្ចក្ខន្ធ) ទេ ហើយរស់នៅ ១០០ ឆ្នាំក៏ដោយ ជីវិតរបស់បុគ្គលអ្នកឃើញនូវការកើតឡើង និងការសូន្យទៅ (នៃបញ្ចក្ខន្ធ) សូម្បីរស់នៅតែមួយថ្ងៃ ក៏ប្រសើរជាង ។

កាលដែលព្រះអង្គទ្រង់ត្រាស់ព្រះគាថានេះចប់ហើយ ព្រះនាងកិសាគោតមីថេរី បានសម្រេចនូវអរហត្តផល ជាព្រះអរហន្តី ដែលជាព្រះអរិយបុគ្គលថ្នាក់ខ្ពស់បំផុត ក្នុងព្រះពុទ្ធសាសនានេះ ព្រមទាំងបែកធ្លាយក្នុងបដិសម្ភិទាទាំង ៤ នៅក្នុងពេលនោះឯង ។ ព្រះនាងកិសាគោតមីថេរី ជាអ្នកតឹងរ៉ឹងបំផុត ក្នុងការប្រើប្រាស់គ្រឿងបរិក្ខារ ដោយនាងជាអ្នកមានប្រក្រតីទ្រទ្រង់នូវចីវរសៅហ្មង ៣ ប្រការ គឺ ១- សំពត់ចីវរក៏សៅហ្មង ២- អំបោះសម្រាប់ដេរក៏សៅហ្មង ៣- ជ្រលក់ទឹកអម្ចត់ក៏សៅហ្មង ។ ក្រោយមក ព្រះវិជិតមារទ្រង់គង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ព្រះអង្គក៏បានប្រកាសតែងតាំងភិក្ខុនីទាំងឡាយទុកក្នុងតំណែងជាឯតទគ្គៈផ្សេងៗ ទៅតាមបុណ្យបារមីរៀងៗ ខ្លួន ប៉ុន្តែក្នុង

ពេលនោះដែរ ព្រះលោកនាយក ទ្រង់បានប្រកាសតែងតាំងព្រះនាងកិសាគោតមីថេរីទុកក្នុងតំណែងជាឯតទគ្គៈ ឲ្យជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ផ្នែកខាងទ្រទ្រង់ចីវរសៅហ្មងមួយរូបដែរ ។

ចំពោះរឿងការប្រកាសតែងតាំងព្រះនាងកិសាគោតមីថេរីទុកក្នុងតំណែងជាឯតទគ្គៈនោះ ដូចមានសម្ដែងនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ លូខចីវរធរានំ យទិទំ កិសាគោតមី** ម្នាលភិក្ខុទាំងឡាយ កិសាគោតមី ជាអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ជាសាវិការបស់តថាគត ផ្នែកខាងទ្រទ្រង់ចីវរសៅហ្មង ។

ព្រះនាងកិសាគោតមីថេរី ក្រោយពីបានសម្រេចជាព្រះអរហន្តីហើយ នាងបានពោលគាថា តាមដែលមានសម្ដែងប្រាកដនៅក្នុង គម្ពីរខុទ្ទកនិកាយ ថេរីគាថា ដូចមានសេចក្ដីថា ៖

ភាពនៃកល្យាណមិត្រចំពោះសត្វលោក ព្រះមុនីទ្រង់សរសើរហើយ បុគ្គលកាលគប់រក នូវពួកកល្យាណមិត្រ សូម្បីខ្លួនជាបុគ្គល

ពាល ក៏គង់បានទៅជាបណ្ឌិត ។ បុគ្គលគួរគប់រក នូវពួកសប្បុរស ប្រាជ្ញានៃបុគ្គលដែលគប់រក ( នូវសប្បុរស ) រមែងចម្រើនដោយពិត បុគ្គលឯណានីមួយ មានក្សត្រជាដើម កាលគប់រកនូវពួកសប្បុរស គប្បីរួចចាកទុក្ខទាំងពួង គប្បីដឹងនូវអរិយសច្ចទាំង ៤ ផង គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ ទុក្ខនិរោធសច្ច ១ មគ្គសច្ច ប្រកបដោយអង្គ ៨ ប្រការ ១ ។ ព្រះមានព្រះភាគ ជាសារថីទូន្មាននូវបុរស ទ្រង់ត្រាស់ថា ឥត្ថីភាពនាំមកនូវសេចក្ដីទុក្ខ ។ ពិតមែន ការនៅរួមជាមួយនឹងស្វាមី នាំមកនូវទុក្ខ ស្រីពួកខ្លះសម្រាលបុត្រតែម្ដង ដាច់បំពង់ស្បូន ( ស្លាប់ ) ក៏មាន ( ស្រីពួកខ្លះ ) ជាសុខុមាលជាតិ មានគភ៌វាងពាក់កណ្ដាល ប្រាថ្នាសម្លាប់កូនក្នុងគភ៌ ស៊ីថ្នាំពិស ដល់នូវសេចក្ដីវិនាសទាំងពីរនាក់ ( កូន និងម្ដាយ ) ក៏មាន ។

ខ្ញុំកាល ទៅរកទីសម្រាលកូន បានឃើញប្ដីស្លាប់ ខ្ញុំទៅមិនទាន់ដល់ផ្ទះរបស់ខ្លួន ក៏សម្រាលកូនកណ្ដាលផ្លូវ ។ កូនទាំងពីរក៏បានធ្វើមរណកាល ប្ដីរបស់ខ្ញុំក៏ស្លាប់ក្នុងវាងផ្លូវ ខ្ញុំជាស្រីកំព្រា ឯមាតាបិតា

និងបងប្អូនប្រុសក៏ត្រូវគេដុតលើជើងថ្ករជាមួយគ្នា ។ នាងវេទនាទុក្ខប្រមាណមិនបាន ក្នុងត្រកូលដែលអត់កោតទ្រព្យ ជាត្រកូលកំព្រា ទឹកភ្នែករបស់នាងប្រព្រឹត្តទៅអស់ពាន់ជាតិជាច្រើន ។ ខ្ញុំឃើញនាង ( កើតជា ) ចចកញីស៊ីសាច់មនុស្សក្នុងកណ្ដាលព្រៃស្មសាន ។ មួយទៀត សាច់កូនក៏នាងបានស៊ីហើយ ( ក្នុងអត្តភាពនេះ ) ខ្ញុំមានវង្សត្រកូលសាបសូន្យ ត្រូវអ្នកផងតិះដៀល មានប្ដីក៏ស្លាប់ តែបានត្រាស់ដឹងនូវអមតៈ ។ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វាន ឈ្មោះថាអមតៈនេះ ខ្ញុំបានចម្រើនហើយ ទាំងព្រះនិព្វាន ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយដែរ ខ្ញុំបានឃើញហើយនូវកញ្ចក់ គឺធម៌ ។ ខ្ញុំមានសរ គឺរាគាទិក្កិលេសកាត់ហើយ មានភារៈដាក់ចុះហើយ កិច្ចដែលគួរធ្វើ ខ្ញុំបានធ្វើរួចហើយ នាងជាកិសាគោតមីថេរី មានចិត្តផុតស្រឡះហើយ ( ចាកកិលេស ) បានពោលនូវសេចក្ដីនេះ ។

( មួយទៀត ពាក្យរបស់ព្រះនាងកិសាគោតមីថេរី មានពាក្យដែលគួរឲ្យសង្ស័យច្រើនខ. តែសូមឲ្យយល់ថា ពាក្យទាំងនេះ ជាពាក្យ

ដែលព្រះថេរីនាំរឿងរ៉ាវរបស់នាង និងអ្នកដទៃខ្លះ របស់ខ្លួនឯងខ្លះ មកសម្តែងលាយប្រឡំគ្នា ) ។

នៅមានរឿង ដែលមារចូលមករុកកួនព្រះនាងកិសាគោតមីថេរី តាមដែលមានសម្តែងប្រាកដនៅក្នុង **កិសាគោតមីសូត្រ** នៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **ភិក្ខុនីសំយុត្ត** ដូចមានសេចក្តីថា ៖

សាវត្ថីនិទាន ។ គ្រានោះ ព្រះនាងកិសាគោតមីភិក្ខុនី ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាតក្នុងបច្ឆាភត្ត ក៏ដើរសំដៅទៅកាន់អន្ធវ័ន ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់អន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃក្រោមម្លប់ឈើមួយ ។ គ្រានោះ មារមានចិត្តបាប មានប្រាថ្នាដើម្បីញុំាងភ័យ សេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់ព្រះនាងកិសាគោតមីថេរី មានប្រាថ្នាឲ្យនាងឃ្លាតចាកសមាធិ ក៏ចូលទៅរកព្រះនាងកិសាគោតមីថេរី លុះចូលទៅដល់ហើយ ក៏ពោលគាថានឹងព្រះ

នាងកិសាគោតមីភិក្ខុនីថា

នាងឯងមានកូនស្លាប់ហើយ មកអង្គុយតែម្នាក់ឯង មានមាត់ទួញយំ នៅកណ្តាលព្រៃតែម្នាក់ឯង នាងមកស្វែងរកប្រុសឬ ?

គ្រានោះ ព្រះនាងកិសាគោតមីភិក្ខុនី មានសេចក្តីត្រិះរិះយ៉ាងនេះថា អ្នកនេះជាអ្វីហ្ន៎ ជាមនុស្ស ឬជាអមនុស្ស បានជាពោលគាថា ដូច្នេះ ។ ទើបព្រះនាងកិសាគោតមីភិក្ខុនី មានសេចក្តីចូលចិត្តដូច្នេះថា នេះពិតជាមារមានចិត្តបាប មានប្រាថ្នាដើម្បីបំភ័យ ធ្វើសេចក្តីតក់ស្លុត និងសេចក្តីព្រឺរោម ឲ្យកើតឡើងដល់អាត្មាអញ ប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកសមាធិ បានជាពោលគាថា ។ លុះព្រះនាងកិសាគោតមីភិក្ខុនី ដឹងច្បាស់ថា នេះពិតជាមារមានចិត្តបាបហើយ ក៏បានពោលគាថាតបនឹងមារមានចិត្តបាប ដូច្នេះថា

យើងជាស្ត្រីមានកូនស្លាប់ ជាទីបំផុតត្រឹមនេះ បុរសទាំងឡាយក៏មានទីបំផុតត្រឹមនេះដែរ ម្នាលអាវុសោ យើងមិនសោកសៅ មិនទួញយំ មិនខ្លាចអ្នកទេ ព្រោះថា សេចក្តីត្រេកអរក្នុងវត្ថុទាំងអស់

យើងកម្ចាត់ចោលហើយ គំនរនៃងងឹត គឺអវិជ្ជា យើងទម្លាយបង់បាន ហើយ យើងឈ្នះនូវសេចក្តីវិនាសនៃមច្ចុមារ ជាស្រ្តីមិនមានអាសវៈ ។

លំដាប់នោះ មារមានចិត្តបាបដឹងថា ព្រះនាងកិសាគោតមីថេរី ស្គាល់ខ្លួនហើយ ក៏មានសេចក្តីទុក្ខតូចចិត្ត បាត់អំពីទីនោះទៅ ។

ភាពជាអ្នកដឹងមារយាទ និងរបៀបក្នុងការចូលទៅកាន់សង្គមថា គួរ មិនគួររបស់ព្រះនាងកិសាគោតមីភិក្ខុនី និងភាពជាអ្នកបានទទួល ការសរសើរ ផ្នែកខាងទ្រទ្រង់ចីវរសៅហ្មងពីព្រះទសពល ក្នុងកាល ដែលព្រះអង្គគង់ប្រថាប់នៅភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ តាមដែលមាន រឿងសម្តែងនៅក្នុង អដ្ឋកថាធម្មបទ នៃ ព្រាហ្មណវគ្គ ក្នុង រឿងព្រះ **នាងកិសាគោតមីភិក្ខុនី** ដូចមានសេចក្តីថា ៖

សក្កទេវរាជ ព្រមដោយទេវតាជាបរិវារ ស្តេចចូលទៅគាល់ ព្រះលោកនាថនៅភ្នំគិជ្ឈកូដនោះ ក្នុងវេលាឈានចូលកាន់មជ្ឈិមយាម ទ្រង់ថ្វាយបង្គំហើយ ប្រថាប់ឈរនៅក្នុងទីដ៏សមគួរ ហើយទ្រង់ព្រះ សណ្តាប់ធម្មកថា ឈ្មោះថា **សារាណីយធម៌** គឺធម៌ដែលប្រព្រឹត្តទៅ

ដើម្បីរឭកដល់គ្នានឹងគ្នា ឬដើម្បីសម្តែងមេត្រីភាពដល់គ្នានឹងគ្នា ។ ក្នុងខណៈនោះ ព្រះនាងកិសាគោតមីភិក្ខុនីគិតថា យើងនឹងចូលទៅគាល់ព្រះសម្ពុទ្ធ នាងបានហោះទៅតាមផ្លូវអាកាស លុះទៅដល់ទីជិតកន្លែងគង់ប្រថាប់របស់ព្រះមានបុណ្យ ព្រះថេរីបានក្រឡេកឃើញសក្កទេវរាជព្រមទាំងទេវតាជាច្រើន ដែលនៅជិតទីគង់ប្រថាប់របស់ព្រះសម្ពុទ្ធនោះ ព្រះថេរីគិតថា កាលនេះជាកាលមិនគួរ ដែលខ្លួនចូលទៅគាល់ព្រះមុនីទេ ត្រឹមតែបានថ្វាយបង្គំព្រះសាស្តា នៅលើអាកាសរួចហើយ ក៏ត្រឡប់ចៀសចេញទៅ ។ គ្រានោះ សក្កទេវរាជបានទតឃើញព្រះថេរីថ្វាយបង្គំព្រះពុទ្ធអង្គរួចហើយ ក៏បានត្រឡប់ចៀសចេញទៅវិញ តែសក្កទេវរាជព្រះអង្គមិនបានជ្រាបថា ជានរណា ទើបក្រាបទូលសួរព្រះមហាវីរៈថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីរូបនោះ មានឈ្មោះអ្វី លុះបានថ្វាយបង្គំព្រះអង្គហើយ ក៏ត្រឡប់ទៅវិញ ព្រះអង្គ ? គ្រានោះ ព្រះលោកនាថត្រាស់តបថា មហាបពិត្រ ភិក្ខុនីរូបនោះ ឈ្មោះ **កិសាគោតមី** ជាធីតារបស់តថាគត ជាថេរីអ្នកប្រសើរជាងភិក្ខុនីទាំងឡាយ ជាសាវិការបស់

តថាគត ផ្អែកខាងទ្រទ្រង់ចីវរសៅហ្មង ព្រះសាស្តាបានត្រាស់ព្រះគាថាថា

តថាគតហៅបុគ្គល អ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលឯកឯង ចម្រើនឈាននៅក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។

ក្នុងពេលដែលព្រះសាស្តា ទ្រង់ត្រាស់សម្តែងព្រះគាថានេះចប់ មានពុទ្ធបរិស័ទជាច្រើន ដែលបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទៅតាមបុណ្យបារមីរៀងៗ ខ្លួនទៅ ។

ជីវប្រវត្តិក្នុងអតីតជាតិ របស់ព្រះនាងកិសាគោតមីភិក្ខុនី ដែលពោលអំពីការសន្សំបុណ្យបារមីទុកមក ដើម្បីជាផ្លូវទៅកាន់ព្រះនិព្វាន ដែលជាដែនដីបរមសុខ មានសម្តែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដែលជាការពោលអំពីជីវប្រវត្តិខ្លួនឯងទុក **ដោយព្រះនាងកិសាគោតមីភិក្ខុនី** ដូចមានសេចក្តីថា ៖

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែន រាប់ថយក្រោយ

អំពីកប្បនេះទៅ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលមួយ នៅក្នុងក្រុង ហង្សវតី បានចូលទៅគាល់ព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់ប្រសើរជាងនរជននោះ ហើយយកព្រះអង្គជាទីពឹង ។ ខ្ញុំបានស្តាប់ធម៌ដ៏ពីរោះរបស់ព្រះអង្គ ជាធម៌ដែលប្រកបដោយសច្ចៈ៤ មានអានិសង្សដ៏ក្រៃលែង នាំមកនូវសេចក្តីស្ងប់ និងសេចក្តីសុខ ក្នុងចិត្ត ។ កាលនោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់សរសើរ តាំងភិក្ខុនី អ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ក្នុងទីជាឯតទគ្គៈ ។ ខ្ញុំញុំាងបីតិ មានប្រមាណច្រើនឲ្យកើតឡើង ស្តាប់នូវគុណនៃភិក្ខុនី ខ្ញុំធ្វើនូវគ្រឿងសក្ការៈដល់ព្រះពុទ្ធតាមគួរដល់សេចក្តីអង់អាច តាមគួរដល់កម្លាំង ។ ខ្ញុំបានក្រាបចុះ ជិតព្រះលោកនាថ ជាអ្នកប្រាជ្ញ មានប្រាជ្ញាខ្ជាប់ខ្ជួននោះ ហើយប្រាថ្នានូវតំណែងនោះ ។ កាលនោះ ព្រះសម្ពុទ្ធ ជានាយក ទ្រង់អនុមោទនាចំពោះការបាននូវតំណែងនោះថា ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះបរមសាស្តា ព្រះនាមគោតម ទ្រង់កើតឡើងក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនេះនឹងបានជាព្រះញាតិ ក្នុងធម៌

ទាំងឡាយ នៃព្រះគោតមនោះ ជាឱរស ជាធម្មនិមិត្ត បានជាសាវិកា នៃព្រះសាស្តា មានឈ្មោះថា **កិសាគោតមី** ។ កាលនោះ ខ្ញុំបានស្តាប់នូវពុទ្ធព្យាករណ៍នោះ ក៏រីករាយ មានចិត្តប្រកបដោយមេត្តា បានបម្រើព្រះជិនស្រី ជានាយក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើតនៅក្នុងស្ថានតាវត្តិង្ស ។ ព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយ ក្នុងភទ្ទកប្បនេះ ។ កាលនោះ ព្រះរាជាក្នុងដែនកាសី ទ្រង់ព្រះនាម កិកិ ព្រះអង្គជាធំ ជាងនរជន ក្នុងក្រុងពារាណសីដ៏ឧត្តម ទ្រង់ជាឧបដ្ឋាកនៃព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ។ ខ្ញុំជាធីតាទី ៥ នៃព្រះរាជានោះ មានឈ្មោះប្រាកដថា **ធម្មា** បានស្តាប់ព្រះធម៌ព្រះលោកនាថដ៏ប្រសើរ ហើយពេញចិត្តនឹងផ្នួស ។ព្រះបិតានៃយើង មិនទ្រង់អនុញ្ញាតឲ្យបួសទេ កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយធម៌

សម្រាប់កុមារី អស់ពីរម៉ឺនឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញានៃស្តេច ស្ថិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយ ក្នុងការបម្រើព្រះពុទ្ធ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគម្រប់ ៧ ។ ( ព្រះរាជធីតា ៧ អង្គនោះ លុះវិលវិញបានមកជា ) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលកេសា ១ ខ្ញុំ ១ ធម្មទិន្នា ១ វិសាខាជាគម្រប់ ៧ ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះឯង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងស្ថានតាវត្តិង្ស ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដែលជាអ្នកជ្លាក់ខ្ជួនកម្សត់ឥតទ្រព្យ ជាត្រកូលទន់ទាបវិញ តែខ្ញុំមានប្តីត្រកូលសម្បូណ៌ដោយទ្រព្យសម្បត្តិ ។ ជនទាំងឡាយដ៏សេស វៀរលែងតែប្តីរបស់ខ្ញុំចេញ សុទ្ធតែជាអ្នកឥតទ្រព្យ ខ្ញុំប្រសូតកូនក្នុងកាលណា ជនទាំងពួងក៏អាណិតខ្ញុំ ក្នុងកាលនោះ ។ កាលណា កូនខ្ញីរបស់ខ្ញុំនោះជាកុមារតូច ស្ថិតនៅក្នុងសេចក្តីសុខ ជាទីស្រឡាញ់របស់ខ្ញុំ ដូចជា

ជីវិតរបស់ខ្លួន កាលនោះ កូននោះ ក៏លុះអំណាចនៃសេចក្ដីស្លាប់ទៅ ។ ខ្ញុំមានសេចក្ដីសោកគ្របសង្កត់ មានមុខប្រកបដោយសេចក្ដីទុក្ខ មានភ្នែកពេញទៅដោយទឹកភ្នែក មានមាត់យំ ព.សាកសពដែលស្លាប់នោះដើរយំត្អូញត្អែរ ។ កាលនោះ ខ្ញុំបានជួបបុរសម្នាក់ ក៏ចូលទៅរកព្រះពុទ្ធជាគ្រូពេទ្យដ៏ប្រសើរ ហើយពោលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គឲ្យថ្នាំប្រស់កូនឲ្យរស់ ។ ព្រះជិនស្រី ព្រះអង្គជាអ្នកឈ្លាសវៃក្នុងឧបាយនៃការទូន្មាន ទ្រង់ត្រាស់ថា ជនទាំងឡាយដែលស្លាប់ហើយមិនមានក្នុងផ្ទះណា ចូរនាងយកគ្រាប់ស្ពៃ អំពីផ្ទះនោះមកឲ្យតថាគត ។ កាលនោះ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី រកមិនបានផ្ទះប្រាកដដូច្នោះ ព្រោះហេតុនោះ នឹងរកគ្រាប់ស្ពៃអំពីផ្ទះណាបាន ? លំដាប់នោះ ខ្ញុំក៏បាននូវស្មារតីឡើង ។ ខ្ញុំចោលនូវសាកសព ហើយចូលទៅគាល់ព្រះពុទ្ធអង្គជាលោកនាយក ចំណែកខាងព្រះអង្គមានសំឡេងពីរោះ ទ្រង់ទតឃើញខ្ញុំអំពីចម្ងាយ ហើយត្រាស់ថា បុគ្គលណា កាលមិនបានឃើញនូវការកើត និងការសូន្យទៅ ( នៃបញ្ចក្ខន្ធ ) ទេ ហើយរស់នៅ ១០០ ឆ្នាំ

ក៏ដោយ ជីវិតរបស់បុគ្គលអ្នកឃើញនូវការកើតឡើង និងការសូន្យទៅ ( នៃបញ្ចក្ខន្ធ ) សូម្បីរស់នៅតែមួយថ្ងៃ ក៏ប្រសើរជាង ។

**អនិច្ចតាធម៌នេះ នឹងថា ជាធម៌សម្រាប់អ្នកស្រុកមួយក៏ទេ ជាធម៌សម្រាប់អ្នកនិគមមួយក៏ទេ ជាធម៌សម្រាប់ត្រកូលមួយក៏ទេ ធម៌នោះឯងសម្រាប់លោក ព្រមទាំងទេវលោកទាំងអស់ ។**

ខ្ញុំនោះ បានស្តាប់នូវគាថាទាំងឡាយនេះ ហើយជម្រះនូវធម្មចក្ខុ គឺសោតាបត្តិមគ្គ លំដាប់នោះ ខ្ញុំក៏ដឹងច្បាស់នូវព្រះសទ្ធម្ម ហើយចូលទៅកាន់ផ្នួស ។

ប៉ុន្តែ នឹងសូមនាំយកជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិ របស់ព្រះនាងកិសាគោតមីថេរី ដែលមានសេចក្តីផ្សេងគ្នា ពីការពោលរួចមកហើយ ជារឿងដែលពោលដល់ការបានសម្រេចអរិយផល តាមន័យនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

លុះខ្ញុំបួសរួចហើយ ក៏មានចិត្តស្ងប់ ប្រកបក្នុងសាសនាព្រះមុនីអស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចជាព្រះអរហន្តី ។ ខ្ញុំជាអ្នកធ្វើ

នូវសាសនានៃព្រះមុនី ស្ទាត់ក្នុងឫទ្ធិទាំងឡាយ ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុ ខ្ញុំបានសម្រេចហើយ ខ្ញុំបានញុំាងអាសវៈទាំងពួងឲ្យអស់ទៅ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលសោះឡើយ ។ ព្រះលោកនាថ ខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាដែលជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំគាស់រំលើងចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺកិរិយាអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានសម្រេចហើយ ញាណរបស់ខ្ញុំដ៏ទូលាយស្អាត ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ព្រោះអំណាចនៃព្រះពុទ្ធដ៏ប្រសើរ ។ខ្ញុំនាំសំពត់អំពីគំនរសំរាមផង អំពីព្រៃស្មសានផង អំពីប្រកផង ហើយធ្វើជាសង្ឃាដី ទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ព្រះជិនស្រីជាលោកនាយក ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំ គឺការទ្រទ្រង់នូវចីវរដ៏សៅហ្មងនោះ បានតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ក្នុងពួកបរិស័ទ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រី

មិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្ទឹង ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនាព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយដែរ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៕

( ជីវប្រវត្តិរបស់ព្រះនាងកិសាគោតមីថេរី ចប់ )

8888888888888888888888888888888888888888888

# ១៣–សញ្ជី

✳-**ស្រុកកំណើត** របស់ព្រះមហាកច្ចាយនត្ថេរ ។ សេចក្តីពិស្តារ មានក្នុងជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ ក្នុង **ទំព័រ ៦៨១** ។

✳-ជាស្រុកកំណើតរបស់ **ព្រះនាងវេទសទេវី** ជាមាតារបស់ព្រះមហិន្ទត្ថេរ និងព្រះនាងសង្ឃមិត្តា ជាអគ្គមហេសីរបស់ព្រះបាទធម្មាសោកមហារាជ ។

✳-កន្លែងតម្កល់ព្រះអដ្ឋិធាតុរបស់ព្រះសារីបុត្រ ដែលជាឯតទគ្គៈផ្នែកខាងបញ្ញា និងព្រះមហាមោគ្គល្លាន ដែលជាឯតទគ្គផ្នែកខាងឫទ្ធិ។

✳-កន្លែងតម្កល់ព្រះអដ្ឋិធាតុព្រះអរហន្តចំនួន ១០ អង្គទៀត គឺ ១-ព្រះកស្សបគប្តៈ ២-ព្រះមជ្ឈិមៈ ៣-ព្រះហារិតិបុត្ត ៤-ព្រះអបគិរៈ ៥-ព្រះវធិយសុវិជយតៈ ៦-ព្រះមហាវនយ ៧-ព្រះកោទិនិបុត្ត ៨-ព្រះកោសិកិបុត្ត ៩-ព្រះគោតិបុត្រ ១០-ព្រះមោគលិបុត្ត ។

# ✍ ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ ✍

## “ ដែលជាឯតទគ្គៈផ្នែកខាងចែកសេចក្ដីក្នុងធម៌ដែលតថាគត សម្ដែងដោយសង្ខេបឱ្យពិស្ដារបាន ”

*ព្រះមហាកច្ចាយនត្ថេរ លោកមានភាពអង់អាចខាងចែកសេចក្ដីនៃព្រះធម៌ ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងដោយសេចក្ដីសង្ខេបឲ្យពិស្ដារបានត្រឹមត្រូវតាមពុទ្ធបំណង រហូតបានទទួលការលើកតម្កើងអំពីព្រះលោកនាថថា មានតែមួយមិនមានពីរ ក្នុងការអធិប្បាយធម៌ និងជាអ្នកមានរូបសម្បត្តិស្អាត ជាទីពិតពិលរមិលមើល ។ ព្រះមហាកច្ចាយនត្ថេរ លោកមានជីវប្រវត្តិគួរសិក្សាដូច្នេះ ។*

*ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ មានពោលនៅក្នុង* ***អដ្ឋកថាគម្ពីរមនោរថបូរណី*** *ក្នុង* ***អដ្ឋកថាបរមត្ថទីបនី*** *និង* ***គម្ពីរខុទ្ទកនិកាយអបទាន*** *ដូចមានសេចក្ដីថា ៖*

*ក្នុងសម័យព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ស្ដេចទ្រង់ឧប្បត្តិកឡើងក្នុង*

លោក ព្រះមហាកច្ចាយនត្ថេរបានកើតនៅក្នុងត្រកូលគហបតីមហាសាល ពេលចម្រើនវ័យធំឡើង ថ្ងៃមួយបានទៅស្តាប់ព្រះធម៌ទេសនានៅឯវត្ត ។ បានឃើញព្រះបទុមុត្តរៈទ្រង់ប្រកាសតែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងដ៏ប្រសើរផ្នែកខាងចែកសេចក្តីសង្ខេបក្នុងធម៌ឲ្យពិស្តារបាន ទើបគិតថា ភិក្ខុរូបនេះជាអ្នកមានគុណធម៌ដ៏ក្រៃលែងណាស់ យើងនឹងបានដូចជាភិក្ខុរូបនេះដែរ ក្នុងព្រះសាសនាព្រះពុទ្ធអង្គណាមួយ នាកាលអនាគត ។

កាលបើលោកគិតដូច្នេះហើយ ទើបរៀបចំការថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធបទុមុត្តរៈជាប្រធាន រហូតអស់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៧ បានតាំងសេចក្តីប្រាថ្នាចំពោះព្រះភក្ត្រព្រះបទុមុត្តរៈថា បពិត្រព្រះសាស្តា ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិយ៉ាងដទៃ ដោយផលនៃការធ្វើកុសលនេះ ប៉ុន្តែសូមឲ្យខ្ញុំព្រះអង្គបាននូវតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងចែកសេចក្តីសង្ខេបក្នុងធម៌ឲ្យពិស្តារនាកាលអនាគតកុំបីខានឡើយ ។ព្រះសម្ពុទ្ធបទុមុត្តរៈ ទ្រង់ព្រះសណ្តាប់សេចក្តីប្រាថ្នាហើយ ទើបទ្រង់ពិចារណាដល់អនាគតកាលហើយទ្រង់ឃើញថា

ការប្រាថ្នារបស់កុលបុត្រនេះនឹងបានសម្រេច ទើបត្រាស់ថា ក្នុងទីបំផុតមួយសែនកប្បខាងមុខនេះ មានព្រះពុទ្ធទ្រង់ព្រះនាមសមណគោតម ស្តេចឧប្បត្តិកឡើងក្នុងលោក អ្នកនឹងបានទទួលការតែងតាំងឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងចែកសេចក្តីសង្ខេបក្នុងធម៌ឲ្យពិស្តារបាន ។

កាលបើព្រះបទុមុត្តរៈ ទ្រង់ព្យាករយ៉ាងនេះហើយ ទ្រង់បានអនុមោទនាគាថារួចជាស្រេចហើយ ព្រះសាស្តាក៏និមន្តត្រឡប់ទៅវិញ ។ ចំណែកកុលបុត្រនោះ បានធ្វើកុសលជារឿយៗ រហូតអស់ជីវិត បានត្រាច់រង្គាត់ទៅក្នុងមនុស្ស និងទេវតា អស់កាលជាយូរអង្វែង ដោយអំណាចបុណ្យកុសល ដែលខ្លួនធ្វើរួចហើយនោះឯង ។ លុះមកដល់កាលនៃព្រះសម្ពុទ្ធសុមេធ កុលបុត្រនោះត្រឡប់បានមកកើតជាវិជ្ជាធរ ថ្ងៃមួយវិជ្ជាធរនោះ បានហោះទៅជួបព្រះមានព្រះភាគ ដែលគង់នៅក្នុងដងព្រៃមួយកន្លែង មានសទ្ធាជ្រះថ្លា ទើបបូជាដោយផ្កាកណិការ ដោយផលនៃកុសលនោះ ធ្វើឲ្យកើតនៅក្នុងទេវលោកអស់កាលដ៏យូរទៀត មិនធ្លាប់ទៅកើតក្នុងទុគ្គតិឡើយ ។ លុះដល់ពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធ

កស្សបៈ លោកបានមកកើតនៅក្នុងត្រកូលមួយនាក្រុងពារាណសី កាលបើព្រះពុទ្ធស្ដេចបរិនិព្វានទៅហើយ លោកបានកសាងព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ ដោយការលះបង់មាសមួយសែនតម្លឹង ដើម្បីចាក់ពុម្ពជាឥដ្ឋ សម្រាប់ការប្រើប្រាស់ ក្នុងការកសាងព្រះចេតិយ ដោយតាំងសេចក្ដីប្រាថ្នាថា

ខ្ញុំកើតក្នុងទីណាៗ សូមឲ្យរាងកាយមានពណ៌សម្បុរដូចមាស បានធ្វើកុសលកម្មដទៃៗ ទៀត ពេលអស់ជីវិតទៅ ក៏បានកើតជាមនុស្សនិងទេវតាអស់កាលមួយពុទ្ធន្តរ ។ ក្នុងពុទ្ធកាលនេះ លោកបានកើតជាបុត្ររបស់ព្រាហ្មណ៍ក្នុងត្រកូលកច្ចាយនគោត្រ ឪពុកជាបុរោហិតរបស់ព្រះបាទចណ្ឌប្បជ្ជោតក្នុងនគរឧជ្ជេនី ។ក្នុងថ្ងៃដែលដាក់ឈ្មោះឲ្យលោក មាតាបិតាប្រឹក្សាគ្នាថា បុត្ររបស់យើងមានពណ៌សម្បុរដូចមាស គួរនឹងកាន់យកនិមិត្តដ៏ល្អនោះ ហើយដាក់ឈ្មោះឲ្យថា កាញ្ចនៈ ឬកញ្ចនៈ ដែលប្រែថា មាស ។ កាញ្ចនមាណព កាលចម្រើនវ័យធំហើយ ក៏បានសិក្សាវិជ្ជាត្រៃវេទរហូតដល់ចប់ ទាំងមានភាពជំនាញទៀតផង កាលបើ

បិតាធ្វើកាលកិរិយាទៅ ទើបបានទទួលតំណែងជាបុរោហិតជំនួសបិតា ប៉ុន្តែឈ្មោះរបស់លោក ក្នុងកាលខាងក្រោយមក ប្តូរជាកច្ចាយនះតាមឈ្មោះត្រកូល ។

កាលជាខាងក្រោយមក ព្រះបាទចណ្ឌប្បជ្ជោតទ្រង់ជ្រាបដំណឹងថា ព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិកឡើងក្នុងលោកហើយ ស្តេចតែងតែចារិកទៅសម្តែងធម៌ ញុំាងប្រយោជន៍ឲ្យសម្រេចដល់មហាជនជាច្រើន ទ្រង់មានព្រះរាជបំណងនឹងក្រាបទូលអារាធនាព្រះមានព្រះភាគ ឲ្យស្តេចយាងមកប្រកាសសាសនានៅនាគរឧជ្ជេនីផង ទើបទ្រង់ត្រាស់បញ្ជាឲ្យប្រជុំពួកអាមាត្យរាជបុរោហិត ហើយមានរាជតម្រាស់សួរថា

នែអស់លោកទាំងឡាយ អ្នកណាមានសមត្ថភាពអាចដើម្បីទៅក្រាបទូលអារាធនាព្រះលោកនាថ ឲ្យស្តេចយាងមកបាន សូមឲ្យអ្នកនោះទៅក្រាបទូលអារាធនាព្រះសម្ពុទ្ធមក ។ ពួកអាមាត្យក្រាបបង្គំទូលថា អ្នកដទៃដែលនឹងមានសមត្ថភាពទៅក្រាបទូលអារាធនាព្រះមុនីនោះ មិនឃើញមានឡើយ ក្រៅអំពីកច្ចាយនព្រាហ្មណ៍ដែលជាអាចារ្យ

តែម្នាក់ប៉ុណ្ណោះ សូមព្រះអង្គទ្រង់ព្រះករុណាឲ្យកច្ចាយនព្រាហ្មណ៍ទៅចុះ ។ ព្រះបាទចណ្ឌបជ្ជោត ទើបត្រាស់បញ្ជាឲ្យកច្ចាយនរាជបុរោហិតទៅក្រាបទូលអារាធនាព្រះសម្ពុទ្ធមកកាន់នគរឧជ្ជេនីនេះ ។ កច្ចាយន-ព្រាហ្មណ៍ ក្រាបបង្គំទូលទទួលដោយការស្ម័គ្រចិត្ត និងក្រាបបង្គំទូលលាបួសផងថា សូមតេជះ កាលបើខ្ញុំព្រះអង្គទៅហើយ សូមឲ្យខ្ញុំព្រះអង្គបានបួសផង ខ្ញុំព្រះអង្គនឹងក្រាបទូលអារាធនាព្រះសាស្ដា ឲ្យព្រះអង្គយាងមក ។ ព្រះរាជាទ្រង់ត្រាស់អនុញ្ញាតថា លោកអាចារ្យធ្វើយ៉ាងណានីមួយក៏បាន ប៉ុន្តែចូរយាងព្រះភគវាមកឲ្យបានកុំខានឡើយ ។

កច្ចាយនព្រាហ្មណ៍ កាលបើបានទទួលព្រះបរមរាជានុញ្ញាតហើយ ទើបគិតពិចារណាមើលថា អ្នកដែលអាចចូលទៅគាល់ព្រះសម្មាសម្ពុទ្ធមិនចាំបាច់ច្រើនគ្នាឡើយ ហើយបាននាំយកព្រាហ្មណ៍ ៧ នាក់ទៅជាមួយផង រួមទាំងអស់មាន ៨ នាក់ ។ ក្នុងខណៈដែលកច្ចាយនៈ ព្រមទាំងសម្លាញ់ ៧ នាក់ទៀត បានធ្វើដំណើររហូតមកដល់ ក៏ចូលទៅគាល់ព្រះសក្យមុនី ព្រះអង្គក៏ទ្រង់សម្ដែងធម៌ឲ្យដល់ជនទាំងនោះបានស្ដាប់

កាលចប់ព្រះធម៌ទេសនា កច្ចាយនៈ ព្រមជាមួយនឹងព្រាហ្មណ៍ ៧ នាក់ទៀត បានសម្រេចជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទាទៀតផង ។

ពេលនោះក៏ទូលសូមបព្វជ្ជាឧបសម្បទា ទើបព្រះមានព្រះភាគត្រាស់ថា អ្នកចូរមកជាភិក្ខុចុះ នេះជាការបួសដោយវិធីជា **ឯហិភិក្ខុឧបសម្បទា** ជាវិធីបំបួសអ្នកដែលបានសម្រេចជាព្រះអរហន្តមុនបួស ។ រំពេចនោះឯង ព្រាហ្មណ៍ទាំង ៨ នាក់នោះ ក៏ត្រឡប់មានភេទជាភិក្ខុទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយបុញ្ញឫទ្ធិ ដូចព្រះថេរៈមានវស្សា ១០០ ដូច្នោះឯង ។កិច្ចនៃការបួសដល់ទីបំផុតហើយ ព្រះមហាកច្ចាយនត្ថេរ មិនបាននៅស្ងៀម តែងតែចាំនូវព្រះរាជតម្រាស់របស់ព្រះបាទចណ្ឌប្បជ្ជោត ទើបក្រាបទូលអារាធនាព្រះសម្ពុទ្ធ ឲ្យស្តេចយាង់ទៅកាន់នគរឧជ្ជេនី ។ព្រះអង្គទ្រង់សណ្តាប់ហើយក៏ជ្រាបថា ធម្មតាព្រះពុទ្ធទាំងឡាយ ព្រះអង្គមិននិមន្តទៅក្នុងស្ថានទីដែលមិនសមគួរឡើយ ។ ព្រោះដូច្នោះ ទើបព្រះភគវាត្រាស់ថា អ្នកចូរទៅ និងកាលអ្នកទៅដល់ព្រះរាជា នឹងទ្រង់ជ្រះថ្លាចំពោះ ជាមួយពួកអ្នកមិនខានឡើយ ។

ព្រះមហាកច្ចាយនត្ថេរគិតថា ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មានតែមួយដងប៉ុណ្ណោះ មិនមានលើកទីពីរឡើយ ទើបក្រាបបង្គំទូលលានាំភិក្ខុ ៧ រូបទៅជាមួយផង និមន្តទៅកាន់នគរឧជ្ជេនី ក្នុងរវាងផ្លូវបានចៀងចូលទៅបិណ្ឌបាត ក្នុងនាលិនិគម ។ កន្លែងនាលិនិគមនោះ មានសេដ្ឋីធីតាម្នាក់ កាលដែលមាតាបិតាធ្វើកាលកិរិយាទៅហើយ ត្រឡប់ជាមនុស្សទ័លក្រទៅវិញ នៅជាមួយនឹងអ្នកបម្រើម្នាក់ ប៉ុន្តែជាអ្នកមានរូបរាងកាយល្អស្អាត មានសក់វែងស្អាត គួរជាទីស្រឡាញ់ណាស់ ។

ចំណែកសេដ្ឋីធីតាត្រកូលមួយទៀត ជាស្រីដែលមានសក់តិចធ្លាប់ប្រើអ្នកបម្រើរបស់ខ្លួន ឲ្យទៅសូមទិញសក់សេដ្ឋីធីតាធ្លាក់ខ្លួនក្រនោះ ដោយឲ្យតម្លៃ ១០០ ឬ ១០០០ កហាបណៈ ប៉ុន្តែនាងមិនលក់ឡើយ ។ ក្នុងថ្ងៃមួយ សេដ្ឋីធីតាដែលធ្លាក់ខ្លួនក្រនោះ បានឃើញព្រះមហាកច្ចា-យនត្ថេរ និមន្តបិណ្ឌបាតរួមជាមួយនឹងភិក្ខុ ៧ រូប ប៉ុន្តែនៅមិនទាន់បានចង្ហាន់សោះ ក្នុងបាត្ររបស់លោកក៏គ្មានចង្ហាន់ដែរ ។ នាងគិតថា រូបសម្បត្តិដែលមានពណ៌សម្បុរដូចមាសនេះ ប្រាកដជាព្រាហ្មណ៍ លោក

មិនទាន់បានទទួលចង្ហាន់ពីនរណានីមួយនៅឡើយ យើងនឹងដាក់បាត្រ ចំពោះលោក ប៉ុន្តែទេយ្យធម៌របស់យើងមិនមាន នាងសញ្ជឹងគិតដោយការអាណិតភិក្ខុសង្ឃ ។កាលបើនាងគិតត្រឹមតែមួយភ្លែត ក៏បាននឹកឃើញថា សេដ្ឋីធីតាឯណោះធ្លាប់ប្រើអ្នកបម្រើឲ្យមកសូមទិញសក់របស់យើង ប៉ុន្តែយើងមិនព្រមលក់ ពេលនេះយើងនឹងលក់សក់របស់យើងឲ្យដល់គេ ដើម្បីយកប្រាក់មកទិញចង្ហាន់ប្រគេនភិក្ខុសង្ឃ ។

លុះនាងបាននឹកឃើញដូច្នេះហើយ ទើបនិមន្តព្រះថេរៈទាំង ៨ រូបឡើងមកគង់លើផ្ទះ ហើយខ្លួនឯងចូលទៅបន្ទប់ កាត់សក់ឲ្យអ្នកបម្រើយកទៅលក់ឲ្យសេដ្ឋីធីតាឯណោះ ដោយតម្លៃប៉ុន្មានក៏បាន ខ្ញុំនឹងថ្វាយចង្ហាន់ដល់លោកម្ចាស់ទាំងឡាយ អ្នកបម្រើអាណិតសេដ្ឋីធីតាដែលធ្លាក់ខ្លួនក្រ ដោយឃើញការធ្វើយ៉ាងនេះហើយ នាងក៏ហូរទឹកភ្នែកដោយមិនដឹងខ្លួនចេញមក យកដៃជូតទឹកភ្នែករួចហើយ កាន់យកសក់សេដ្ឋីធីតាទៅ ទាំងមិនឲ្យព្រះថេរៈទាំងឡាយបានឃើញ ។

ធម្មតារបស់មានតម្លៃ នឹងលក់បានតម្លៃថ្លៃពេលមនុស្សត្រូវការ

ប្រសិនបើមិនត្រូវការហើយ របស់មានតម្លៃក៏មិនថ្លៃដែរ ។ព្រោះដូច្នោះ ទើបសេដ្ឋីធីតាគិតថា ក្នុងកាលមុនយើងអាចទិញសក់នេះ បានដោយតម្លៃថ្លៃ ឥឡូវនេះ គេព្រមកាត់សក់លក់ឲ្យយើង សក់ក៏មានតម្លៃថោករហូតដល់តម្លៃ ៨ កហាបណៈ ព្រមទាំងនិយាយថា កាលមុន ខ្ញុំមិនអាចទិញសក់នេះអំពីចៅហ្វាយស្រីរបស់នាងបាន សូម្បីឲ្យតម្លៃថ្លៃខ្ពស់បំផុតយ៉ាងណាក៏ដោយ ក៏មិនព្រមលក់ឲ្យឡើយ ប៉ុន្តែឥឡូវនេះសក់នេះឲ្យតម្លៃ៨កហាបណៈសមរម្យណាស់ទៅហើយ ។អ្នកបម្រើមិននិយាយស្តីអ្វីឡើយ នាំយកប្រាក់ ៨ កហាបណៈឲ្យទៅចៅហ្វាយស្រីនោះ ទើបឲ្យអ្នកបម្រើយកប្រាក់ ៨ កហាបណៈទៅទិញចង្ហាន់ ៨ ចំណែក ក្នុងមួយចំណែកៗ ១ កហាបណៈ ហើយដាក់ចង្ហាន់ទាំងនោះទៅក្នុងបាត្រព្រះថេរៈទាំងអស់ ។

ព្រះថេរៈទាំងឡាយ មានព្រះមហាកច្ចាយនៈជាដើម បានឃើញសេដ្ឋីធីតាដែលមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែងនោះហើយ ទើបសួរថា សេដ្ឋីធីតាទៅណា ? អ្នកបម្រើតបថា នៅក្នុងបន្ទប់ ។ព្រះថេរៈពោលថា

ចូរទៅហៅនាងមក សេដ្ឋីធីតានោះក៏ព្រមចេញមកជួបព្រះថេរៈទាំងនោះ បានថ្វាយបង្គំព្រះថេរៈដោយសេចក្តីជ្រះថ្លាហើយ សក់របស់នាងដែលត្រូវកាត់យ៉ាងខ្លីនោះ ត្រឡប់ដុះវែងឡើងដូចដើមវិញ ។

ទានដែលបុគ្គលបូជាចំពោះអ្នកមានសីល មានគុណធម៌ដ៏ខ្ពង់ខ្ពស់ រមែងឲ្យផលឃើញទាន់ភ្នែកក្នុងបច្ចុប្បន្ននេះ ។ ព្រះថេរៈទាំងឡាយបានទទួលចង្ហាន់បិណ្ឌបាតហើយ បានហោះឡើងទៅឰដ៏អាកាស នៅចំពោះមុខសេដ្ឋីធីតានោះ ទៅចុះក្នុងកាញ្ចនឧទ្យានរបស់ព្រះបាទចណ្ឌប្បជ្ជោត ។

នាយឧទ្យានបានឃើញព្រះថេរៈទាំងនោះហើយ ទើបទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ ព្រះបុរោហិតកច្ចាយនៈបានបួសហើយ ឥឡូវមកស្នាក់អាស្រ័យក្នុងព្រះរាជឧទ្យាននៅឡើយ ។ ព្រះបាទចណ្ឌបជ្ជោត ស្តេចបានយាងទៅកាន់ព្រះរាជឧទ្យានភ្លាមៗ ប៉ុន្តែត្រូវពេលដែលព្រះថេរៈទាំងឡាយឆាន់រួចជាស្រេច ព្រះរាជាក៏ថ្វាយបង្គំហើយ ទើបត្រាស់សួរថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់នៅក្នុងទីណា ? ព្រះកច្ចាយនៈតបថា ព្រះលោកនាយក ទ្រង់មិនបាននិមន្តមកទេ ប៉ុន្តែទ្រង់អនុញ្ញាត

ឲ្យអាត្មាមកជំនួសវិញ ។

ព្រះរាជាទ្រង់ត្រាស់សួរទៀតថា ថ្ងៃនេះ លោកម្ចាស់ទាំងឡាយបានចង្ហាន់មកពីណាឆាន់ ? ព្រះថេរៈទាំងនោះបានតំណាលរឿងសេចក្តីល្អរបស់សេដ្ឋីធីតាឲ្យព្រះរាជាទ្រង់សណ្តាប់ថា

សេដ្ឋីធីតាកម្សត់ម្នាក់ដែលនៅក្នុងនាលិនិគម បានកាត់សក់របស់ខ្លួនយកទៅលក់ យកប្រាក់មកទិញចង្ហាន់ដាក់បាត្ររបស់អាត្មាភាព ។ ព្រះរាជាទ្រង់សណ្តាប់ហើយ ទ្រង់សព្វព្រះហឫទ័យ ក៏ថ្វាយបង្គំលាព្រះថេរៈទាំងឡាយ និងស្តេចត្រឡប់ទៅដល់ព្រះរាជវាំងវិញហើយ ឲ្យគេទៅនាំយកសេដ្ឋីធីតាកម្សត់នោះមកធ្វើជាអគ្គមហេសីរបស់ខ្លួន ។

ចាប់ផ្តើមពីនោះមក ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ធ្វើសក្ការគោរពបូជាចំពោះព្រះថេរៈទាំងនោះជារឿយៗ ។ ព្រះមហាកច្ចាយនត្ថេរ អាចធ្វើឲ្យមហាជនកើតសេចក្តីជ្រះថ្លា ក្នុងការសម្តែងធម៌របស់ខ្លួន ជនជាច្រើននាក់បានបួសក្នុងសម្នាក់ព្រះថេរៈ ដោយសេចក្តីជ្រះថ្លា ។ ចាប់ពីព្រះកច្ចាយនត្ថេរ ព្រមទាំងព្រះថេរៈ ៧ រូបទៀត មកគង់នៅក្នុងនគរ

ឧជ្ជេនី បានធ្វើឲ្យនគរឧជ្ជេនីទាំងអស់រុងរឿងស្រស់បស់ ដោយសំពត់កាសាវពស្ត្រ ច្រើនទៅដោយអ្នកស្វែងរកបុណ្យ ។

បន្ទាប់មក អគ្គមហេសីរបស់ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់មានព្រះរាជឱរសមួយព្រះអង្គ ទ្រង់កំណត់ព្រះនាមឲ្យព្រះរាជឱរសថា គោបាលកុមារ ព្រះនាមនេះប្រោសព្រះរាជទាន ឲ្យដូចគ្នានឹងឈ្មោះរបស់ជីតាតាំងពីពេលនោះមកសេដ្ឋីជីតា ដែលជាអគ្គមហេសីរបស់ព្រះបាទចណ្ឌ-ប្បជ្ជោតនោះ ទើបបាននាមមួយទៀតថា ព្រះនាងគោបាលមាតា ។ ព្រះនាងរីងរឹតតែមានសេចក្ដីជ្រះថ្លា ចំពោះបុណ្យកុសលណាស់ដែលខ្លួនបានធ្វើហើយ ទើបទូលសូមព្រះបាទចណ្ឌប្បជ្ជោត ដើម្បីកសាងវត្តថ្វាយដល់ព្រះថេរៈ ក្នុងកាញ្ចនឧទ្យាននោះឯង ។

ការនាំកងទ័ពធម៌ចារិកប្រកាសព្រះសាសនា របស់ព្រះកច្ចាយនៈនិងព្រះថេរៈទាំង ៧ រូបទៀត ជាផលឲ្យព្រះបាទចណ្ឌប្បជ្ជោត ព្រមទាំងអ្នកនគរឧជ្ជេនីកើតសេចក្ដីជ្រះថ្លា ហើយទើបត្រឡប់មកគាល់ព្រះសម្ពុទ្ធម្ដងទៀត ។ កាលដែលព្រះមហាកច្ចាយនត្ថេរ បានទទួលការលើកតម្កើង

ឲ្យជាអ្នកចែកសេចក្ដីសង្ខេបឲ្យពិស្ដារបាននោះ គ្រាមួយព្រះមានព្រះភាគ ទ្រង់សម្ដែងភទ្ទេករត្តសូត្រទុកដោយសង្ខេប ដែលប្រាកដនៅក្នុង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ដូចមានសេចក្ដីថា ៖

បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគត ព្រោះថា បញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះក៏មិនទាន់មកដល់មួយទៀត បុគ្គលណា ពិចារណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ គួរចម្រើនឲ្យរឿយៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតនូវកិលេស បុគ្គលគួរធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្ដីស្លាប់ នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកំដៅកិលេសជាអ្នកមិន

ខ្ជិលច្រអូសអស់ថ្ងៃ និងយប់នោះឯង ថាជាអ្នកមានរាត្រីមួយចម្រើន ។

ឧទ្ទេសនេះ បើព្រះមានបុណ្យទ្រង់សម្តែងដោយសេចក្តីសង្ខេប មិនបានចែកសេចក្តីដោយពិស្តារ អ្នកណាហ្ន៎ គប្បីចែកសេចក្តីដោយពិស្តារបាន ម្នាលអាវុសោកច្ចាយនៈ ពួកយើងខ្ញុំទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចាយនៈមានអាយុនេះឯង ព្រះមានជោគ តែងសរសើរផង ពួកសព្រហ្មចារីជាអ្នកចេះដឹងបានលើកតម្កើងផង ព្រះមហាកច្ចាយនៈ មានអាយុ អាចចែករំលែកសេចក្តីនៃឧទ្ទេស ។

ដែលព្រះមានជោគ ទ្រង់សម្តែងដោយសង្ខេបនេះ ឲ្យពិស្តារបានផង បើដូច្នោះ គួរតែយើងនាំគ្នាចូលទៅរកព្រះមហាកច្ចាយនៈមានអាយុ លុះចូលទៅដល់ហើយ ត្រូវសួរសេចក្តីនេះ នឹងព្រះមហាកច្ចាយនៈមានអាយុ សូមឲ្យព្រះមហាកច្ចាយនៈមានអាយុ ចែកសេចក្តីឲ្យទាន ។

ព្រះមហាកច្ចាយនៈពោលថា ម្នាលអាវុសោ បុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ស្វែងរកខ្លឹមឈើ កាលឈើមានខ្លឹមដុះនៅមុខ ក៏រំលងគល់ រំលងដើម ហើយសម្គាល់រកខ្លឹមឯមែក

និងស៊ីកវិញ មានឧបមាយ៉ាងណាមិញ សេចក្តីនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ ព្រះមានជោគនៅក្នុងទីចំពោះមុខ របស់លោកអ្នកមានអាយុទាំងឡាយ ពួកលោករំលងព្រះមានព្រះភាគនោះហើយ សម្គាល់សេចក្តីដែលត្រូវសួរនោះចំពោះខ្ញុំវិញ ។

ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបនូវធម៌ដែលគួរជ្រាបបាន ឃើញនូវធម៌ ដែលគួរឃើញបាន ទ្រង់មានបញ្ញាចក្ខុ មានញាណ ទ្រង់មានធម៌ មានគុណដ៏ប្រសើរ ទ្រង់កាន់ធម៌ប្រព្រឹត្តធម៌ ពន្យល់សេចក្តី ទ្រង់ប្រទាននូវអមតៈ ជាម្ចាស់ធម៌ ជាព្រះតថាគត ទើបសមគួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលអ្នកទាំងឡាយគួរតែសួរសេចក្តីនុ៎ះ នឹងព្រះមានព្រះភាគ បើព្រះអង្គទ្រង់ដោះស្រាយដល់អ្នកទាំងឡាយ យ៉ាងណា ចូរអ្នកទាំងឡាយ ចាំទុកសេចក្តីនោះយ៉ាងនោះចុះ ។

ម្នាលអាវុសោកច្ចាយនៈ ព្រះមានព្រះភាគ ព្រះអង្គជ្រាបនូវធម៌មានបញ្ញាចក្ខុ យើងទាំងឡាយ គប្បីចាំទុកសេចក្តីនោះ យ៉ាងនោះ ក៏ពិត

មែនហើយតែថា ព្រះមហាកច្ចាយនៈមានអាយុ ព្រះសាស្តាតែងសរសើរ ផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផង មួយទៀត ព្រះមហាកច្ចាយនៈ លោកអាចចែកសេចក្តីនៃឧទ្ទេស ដែលព្រះភគវា សម្តែងហើយដោយសេចក្តីសង្ខេប មិនទាន់ចែករំលែកសេចក្តីដោយ ពិស្តារនោះ ឲ្យពិស្តារបានផង សូមព្រះមហាកច្ចាយនៈមានអាយុ កុំធ្វើ ឲ្យយឺតយូរឡើយ សូមចែកឲ្យទាន ។ ព្រះមហាកច្ចាយនៈតបថា ម្នាល អាវុសោ បើដូច្នោះ លោកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលពាក្យរបស់ព្រះមហា កច្ចាយនៈមានអាយុថា ករុណា អាវុសោ ។ នៃអាវុសោ កាលព្រះ សម្ពុទ្ធ ទ្រង់សម្តែងនូវឧទ្ទេសនោះ ដោយសង្ខេប មិនទាន់បានចែក សេចក្តីឲ្យពិស្តារ ខ្ញុំយល់សេចក្តីពិស្តារដូច្នេះ ។ ម្នាលអាវុសោ បុគ្គល អាឡោះអាល័យបញ្ចក្ខន្ធជាអតីតតើដូចម្តេច ? វិញ្ញាណរមែងជាប់ជំពាក់ នឹងឆន្ទរាគៈក្នុងចក្ខុ និងរូបនោះថា អាត្មាអញមានចក្ខុ ក្នុងអតីតដូច្នេះ បុគ្គលតែងត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណជាប់ជំពាក់ដោយ

ឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា អាឡោះអាល័យចក្ខុ និងរូបជាអតីត ។

អាត្មាអញ មានសោតៈ ក្នុងកាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ ...អាត្មាអញ មានឃានៈ ក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ ...អាត្មាអញមានជិវ្ហា ក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ ...អាត្មាអញ មានកាយក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... អាត្មាអញ មានចិត្តក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចិត្ត និងធម្មារម្មណ៍នោះដូច្នេះ បុគ្គលរមែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថានៅអាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ នែអាវុសោ បុគ្គលនៅអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

នែ អាវុសោ បុគ្គល មិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្ដេច ? វិញ្ញាណរមែងមិនជាប់ជំពាក់នឹងឆន្ទរាគៈក្នុងចក្ខុ និងរូប

នោះថា អាត្មាអញ មានចក្ខុ ក្នុងកាលជាអតីតដូច្នេះ មានរូបដូច្នេះ បុគ្គលរមែងមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណមិនបានជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថាមិនបានអាឡោះអាល័យចក្ខុនិងរូបជាអតីត ។

អាត្មាអញ មានសោតៈ ក្នុងកាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ... អាត្មាអញ មានឃានៈក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ... អាត្មាអញ មានជិវ្ហាក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ... អាត្មាអញ មានកាយក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ ... វិញ្ញាណរមែងមិនជាប់ជំពាក់ដោយឆន្ទរាគៈ ក្នុងចិត្តនិងធម្មារម្មណ៍នោះថា អាត្មាអញ មានចិត្ត ក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ បុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់ដោយឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា មិនអាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ នែអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបច្ចុប្បន្នជាអនាគត តើដូចម្តេច ? បុគ្គលតម្កល់ចិត្តដើម្បីការបាននូវរបស់ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ កាលបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា ប្រាថ្នានូវចក្ខុ និងរូបជាអនាគត ។

ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានសោតៈដូច្នេះ មានសំឡេងដូច្នេះ...ក្នុងកាលជាអនាគតសូមឲ្យអាត្មាអញមានឃានៈដូច្នេះ មានក្លិនដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ...បុគ្គលតម្កល់ចិត្ត ដើម្បីការបាននូវចិត្ត និងធម្មារម្មណ៍ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលនោះត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា ប្រាថ្នានូវចិត្ត និងធម្មារម្មណ៍ ជា

អនាគត ។ នែ អាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។ នែ អាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ? បុគ្គលមិនតម្កល់ចិត្តដើម្បីការបាននូវរបស់ដែលខ្លួនមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរចំពោះចក្ខុ និងរូបនោះ កាលបុគ្គលលែងត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា មិនប្រាថ្នានូវចក្ខុ និងរូបជាអនាគត ។ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានសោតៈដូច្នេះ មានសំឡេងដូច្នេះ...ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានឃានៈដូច្នេះ មានក្លិនដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានជិវ្ហាដូច្នេះ មានរសដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... បុគ្គលមិនបានតម្កល់ចិត្តទុក ដើម្បីការបាននូវចិត្ត និងធម្មារម្មណ៍ ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តទុកជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរ

ចំពោះចិត្ត និងធម្មារម្មណ៍នោះ កាលបុគ្គលលែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថាមិនប្រាថ្នានូវចិត្ត និងធម្មារម្មណ៍ជាអនាគត ។ នែអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

នែអាវុសោ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ? នែអាវុសោ ចក្ខុនិងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចក្ខុ និងរូបជាបច្ចុប្បន្ននោះឯង បុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថារសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ នែអាវុសោ ត្រចៀក និងសំឡេង... ច្រមុះ និងក្លិន... អណ្តាតនិងរស.... កាយ និងផោដ្ឋព្វៈ... ចិត្តនិងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចិត្ត និងធម្មារម្មណ៍នោះឯង បុគ្គលរមែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ឈ្មោះថារសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។

នែ អាវុសោ បុគ្គលរសេមរសោមក្នុងធម៌ជាបច្ចុប្បន្នយ៉ាងនេះឯង ។

ម្នាលអាវុសោ បុគ្គលមិនរសេមរសោម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ? ម្នាលអាវុសោ ចក្ខុនិងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចក្ខុនិងរូបជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថាមិនរសេមរសោម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ នែអាវុសោ ត្រចៀកនិងសំឡេង... ច្រមុះនិងក្លិន ... អណ្តាត និងរស ... កាយ និងផោដ្ឋព្វៈ ... ចិត្ត និងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងមិនជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចិត្ត និងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថាមិនរសេមរសោម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ នែ អាវុសោ បុគ្គលមិនរសេមរសោម ក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

នែអាវុសោ ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកសេចក្តីដោយពិស្តារនេះឯង ខ្ញុំយល់សេចក្តីដោយពិស្តារយ៉ាងនេះ ប្រសិនបើលោកមានអាយុប្រាថ្នា ត្រូវចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរបញ្ហាក់សេចក្តីនោះ ហើយត្រូវចងចាំសេចក្តីនោះ តាមទំនងដែលព្រះអង្គដោះស្រាយយ៉ាងនោះចុះ ។

គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះមហាកច្ចាយនៈមានអាយុ ហើយក្រោកអំពីអាសនៈចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះលោកនាថហើយអង្គុយក្នុងទីដ៏សមគួរ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះសម្ពុទ្ធយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើនព្រះអង្គទ្រង់សម្តែងនូវឧទ្ទេសណា ដោយសេចក្តីសង្ខេប មិនទាន់បានចែករំលែកសេចក្តីដោយពិស្តារនៅឡើយ ហើយក៏ក្រោកចាកអាសនៈចូលទៅកាន់វិហារទៅ ព្រះអង្គយាងទៅមិនយូរប៉ុន្មាន យើងខ្ញុំទាំងនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា នែ អាវុសោ ព្រះពុទ្ធអង្គទ្រង់សម្តែងនូវ

ឧទ្ទេសនេះដោយសង្ខេប មិនទាន់ចែកសេចក្ដីដោយពិស្ដារនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈទៅ តើនរណាហ្ន៎ គប្បីចែកសេចក្ដីនៃឧទ្ទេស ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្ដែងដោយសង្ខេប ទ្រង់មិនទាន់ចែកសេចក្ដីដោយពិស្ដារនោះ ឲ្យពិស្ដារបាន បពិត្រព្រះភគវា ខ្ញុំព្រះអង្គទាំងឡាយនោះ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចាយនៈមានអាយុនេះឯង ព្រះសាស្ដាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផង ព្រះកច្ចាយនៈមានអាយុអាចចែកសេចក្ដីនៃឧទ្ទេស ដែលព្រះសាស្ដា ទ្រង់ត្រាស់សម្ដែងដោយសង្ខេបឲ្យពិស្ដារបាន បើដូច្នេះ គួរពួកយើងចូលទៅរកព្រះមហាកច្ចាយនៈមានអាយុ លុះចូលទៅដល់ហើយ ពួកយើងគប្បីសួរបញ្ជាក់សេចក្ដីនោះនឹងព្រះមហាកច្ចាយនៈមានអាយុចុះ បពិត្រព្រះសក្យមុនី កាលបើហេតុយ៉ាងនេះ ពួកខ្ញុំព្រះអង្គ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចាយនៈ លុះចូលទៅដល់ហើយ ក៏បានសួរសេចក្ដីនេះនឹងព្រះមហាកច្ចាយនៈ បពិត្រព្រះមានជោគ ព្រះកច្ចាយនៈដ៏មានអាយុ ក៏បានចែកសេចក្ដីដោយអាការ

ទាំងឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះ ដល់ពួកខ្ញុំព្រះអង្គទាំងនោះ ។

ម្នាលភិក្ខុទាំងឡាយ មហាកច្ចាយនៈជាបណ្ឌិត ជាអ្នកមានប្រាជ្ញាច្រើន ប្រសិនបើអ្នកទាំងឡាយ សួរបញ្ហាក់សេចក្តីនោះ នឹងតថាគត តថាគតនឹងដោះស្រាយសេចក្តីនោះ តាមទំនងដែលមហាកច្ចាយនៈដោះស្រាយយ៉ាងនោះដែរ សេចក្តីនៃភាសិតនោះ ដូច្នោះមែនហើយ ចូរអ្នកទាំងឡាយចងចាំយ៉ាងនេះចុះ ។ លុះព្រះមានជោគត្រាស់ភាសិតនោះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

បន្ទាប់មកខាងក្រោយ ព្រះសាស្តាទ្រង់សម្តែងព្រះសូត្រទាំងបី គឺ មធុបិណ្ឌិកសូត្រ កច្ចាយនបេយ្យាសូត្រ និង បារាយនសូត្រ ឲ្យជាមូលហេតុ គ្រាដែលព្រះអង្គទ្រង់ប្រថាប់នៅវត្តជេតពន ទើបទ្រង់តែងតាំងព្រះមហាកច្ចាយនត្ថេរក្នុងចំណោមបរិស័ទ ទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយជាសាវ័ករបស់ព្រះអង្គ អ្នកចែកសេចក្តីសង្ខេបឲ្យ

ពិស្ដារបាន ដូចដែលពោលទុកក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា៖

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោ ។** ម្នាលភិក្ខុទាំងឡាយ មហាកច្ចាយនៈជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងជាអ្នកចែកសេចក្ដីធម៌ ដែលតថាគតសម្ដែងដោយសង្ខេបឲ្យពិស្ដារបាន ។

គុណសម្បត្តិរបស់ព្រះមហាកច្ចាយនៈ ក្រៅអំពីព្រះសាស្ដាទ្រង់លើកតម្កើងតែងតាំងហើយ សូម្បីសក្កទេវរាជ ក៏មានការគោរពលើកតម្កើងលោកដែរ ដូចមានរឿងចារឹកទុកក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **អរហន្តវគ្គ** ក្នុងរឿងព្រះមហាកច្ចាយនត្ថេរ ដូចមានសេចក្ដីថា ៖

ថ្ងៃមួយ ព្រះបរមសាស្ដា ទ្រង់ប្រថាប់នៅក្នុងវត្តបុព្វារាម ត្រាស់ព្រះធម៌ទេសនា ដោយទ្រង់ប្រារព្ធដល់ព្រះមហាកច្ចាយនៈជាដើមហេតុ ។

សេចក្ដីពិស្ដារនៃរឿងនេះថា ក្នុងសម័យមួយ ព្រះពុទ្ធអង្គ មានសាវកជាច្រើន ទ្រង់ប្រថាប់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងថ្ងៃ

មហាបវារណា ។ ក្នុងគ្រានោះ ព្រះមហាកច្ចាយនត្ថេរនៅក្នុងអវន្តីជនបទ សូម្បីលោកនិមន្តមកអំពីចម្ងាយ ក៏នៅតែមានការលើកតម្កើងអំពីព្រះថេរៈ ព្រោះដូច្នោះ ព្រះថេរៈទាំងឡាយកាលបើនឹងគង់ ក៏គង់វៀរអាសនៈមួយទុកដើម្បីព្រះមហាកច្ចាយនត្ថេរ ។ សក្កទេវរាជ ស្តេចយាងមកអំពីទេវលោក ព្រមដោយទេវបរិស័ទ ទ្រង់បូជាព្រះបរមសាស្តា ដោយផ្កានិងគ្រឿងក្រអូបដែលជាទិព្វជាដើម ហើយនៅប្រថាប់ឈរ កាលបើទតមើលទៅមិនបានឃើញព្រះមហាកច្ចាយនត្ថេរ ទើបទ្រង់រំពឹងថា ព្រោះហេតុអ្វីហ្ន៎ លោកម្ចាស់កច្ចាយនៈរបស់យើង ទើបនៅមិនទាន់មក ប្រសិនបើលោកម្ចាស់និមន្តមក រាប់ថាជាការល្អប្រពៃណាស់ ។ ព្រះមហាកច្ចាយនត្ថេរ បាននិមន្តមកដល់ក្នុងពេលនោះឯង ដោយការមកប្រាកដខ្លួនឡើងគង់លើអាសនៈដែលព្រះថេរៈទាំងឡាយវៀរទុកដើម្បីខ្លួន ។ ចំណែកសក្កទេវរាជ បានទតឃើញព្រះមហាកច្ចាយនត្ថេរ ទ្រង់ចាប់កជើងទាំងពីរយ៉ាងមាំ ហើយត្រាស់ថា លោកម្ចាស់របស់យើងមកហើយ កាលបើសក្កទេវរាជពោលដូច្នេះហើយ ទើបទ្រង់យកព្រះហស្ត

ទាំងពីរប្រេបាច់ព្រះបាទទាំងសងខាងរបស់ព្រះថេរៈ ទាំងទ្រង់បូជាព្រះថេរៈ ដោយផ្កា និងគ្រឿងក្រអូបជាដើម ទ្រង់ថ្វាយបង្គំព្រះថេរៈរួចហើយ បានប្រថាប់ឈរនៅក្នុងទីដ៏សមគួរ ។

ភិក្ខុទាំងឡាយពោលទោសតិះដៀលដល់សក្កទេវរាជថា ធ្វើសក្ការៈ ចំពោះតែព្រះមហាកច្ចាយនៈប៉ុណ្ណោះ សូម្បីសាវ័កធំៗ ដ៏សេសក្រៅអំពីនោះ ទ្រង់ទតមើលមិនឃើញឡើយ ។ ព្រះសាស្ដា ទ្រង់សណ្ដាប់ពាក្យភិក្ខុទាំងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានទ្វារដែលខ្លួនគ្រប់គ្រងរក្សាល្អហើយ ក្នុងឥន្ទ្រិយទាំងឡាយ ដូចមហាកច្ចាយនៈ ដែលជាបុត្ររបស់តថាគតនេះរមែងជាទីស្រឡាញ់ពេញចិត្តរបស់សក្កទេវរាជនោះ កាលព្រះអង្គនឹងទ្រង់បន្តអនុសន្ធិសម្ដែងព្រះធម៌ ទើបត្រាស់គាថាធម្មបទ ថា

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថី ហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និងមនុស្សទាំងឡាយក៏ស្រឡាញ់អ្នកនោះឯង ដែលមានការលះបង់ហើយ មិនមានអាសវៈ

ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ ។

គាថានេះ មានសេចក្ដីអធិប្បាយថា ពាក្យថា ឥន្ទ្រិយទាំងឡាយ សំដៅដល់ឥន្ទ្រិយទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត របស់ភិក្ខុណាដែលដល់នូវភាពស្ងប់ គឺជាឥន្ទ្រិយដែលខ្លួនទូន្មានបាន ល្អហើយ បានដល់ ប្រៀបដូចគ្នានឹងសេះដែលនាយសារថី ហ្វឹកហ្វឺន រាបល្អហើយ ដូច្នោះ ។

ក្នុងពេលដែលព្រះសាស្ដាទ្រង់ទេសនាចប់ ជនជាច្រើនបានសម្រេច អរិយផល ផលដ៏ប្រសើរ មានសោតាបត្តិផលជាដើម ។ សេចក្ដីល្អ របស់លោក ដែលញ៉ាំងឲ្យបានជាប្រយោជន៍រហូតមកដល់សព្វថ្ងៃនេះ គឺលោកបានក្រាបទូល សូមឲ្យព្រះមានជោគ ទ្រង់ដោះស្រាយចំពោះ ពុទ្ធប្បញ្ញត្តិប្រការខ្លះដែលខ្វះខាតក្នុងភូមិប្រទេសនាៗ ដូចមានប្រាកដ ក្នុង សោណសូត្រ នៃ គម្ពីរខុទ្ទកនិកាយ ឧទាន និង គម្ពីរមហាវគ្គ វិនយបិដក ដោយមានសេចក្ដីថា ៖

ក្នុងសម័យមួយ ព្រះមហាកច្ចាយនៈ គង់នៅលើភ្នំឈ្មោះបវត្តៈ

ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តីជនបទ ពេលនោះឧបាសកឈ្មោះសោណកុដិកណ្ណៈ ជាឧបដ្ឋាក របស់ព្រះមហាកច្ចាយនៈ មានបំណងនឹងបួស ក៏បានត្រឹមតែបព្វជ្ជាជាសាមណេរប៉ុណ្ណោះ មិនអាចនឹងឧបសម្បទាជាភិក្ខុបាន ព្រោះក្នុងដែនអវន្តីជនបទ រកភិក្ខុឲ្យគ្រប់គណៈសង្ឃលំបាកណាស់ ត្រូវនៅរង់ចាំរហូតដល់ ៣ឆ្នាំ ទើបអាចឧបសម្បទាជាភិក្ខុបាន ។

កាលដែលព្រះសោណកុដិកណ្ណៈ បានឧបសម្បទាជាភិក្ខុហើយមានបំណងនឹងចូលទៅគាល់ព្រះពុទ្ធអង្គ ទើបថ្វាយបង្គំលាព្រះកច្ចាយនៈដែលជាឧបជ្ឈាយ៍ ពេលនោះព្រះថេរៈពោលថា នែសោណៈ ប្រពៃពេកណាស់ ចូរទៅចុះ ហើយផ្តាំសួរសុខទុក្ខព្រះអង្គឲ្យផង កាលបើអ្នកថ្វាយបង្គំព្រះសក្យមុនីរួចហើយ ទូលសូមឲ្យព្រះសាស្តាដោះស្រាយចំពោះពុទ្ធប្បញ្ញត្តិ ដែលខ្វះខាតក្នុងដែនអវន្តីជនបទនេះ ៥ ខ.ផងគឺ

១-ក្នុងដែនអវន្តីជនបទ មានភិក្ខុតិច សូមឲ្យព្រះសុគតសាស្តាទ្រង់អនុញ្ញាតឧបសម្បទាដោយគណៈសង្ឃតិចជាង ១០ រូប ។

ក្នុងប្រការនេះ ព្រះសាស្តាទ្រង់ពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបសម្បទាក្នុងបច្ចន្តជនបទ ដោយមានភិក្ខុជាគណៈសង្ឃ ៥ រូបបាន ។

២- ក្នុងដែនអវន្តីជនបទ មានផ្ទៃដីរដិបរដុបមិនស្មើ លំបាកក្នុងការនិមន្តទៅមកណាស់ សូមទ្រង់អនុញ្ញាតស្បែកជើងផង ។

ក្នុងប្រការនេះ ព្រះអង្គបានពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ។

៣- ក្នុងដែនអវន្តីជនបទ ប្រជាជនជាច្រើនមានទំនៀមទម្លាប់និយមងូតទឹកជានិច្ច ប្រកបដោយសេចក្តីស្អាតព្រោះទឹក ហេតុនេះសូមឲ្យព្រះអង្គទ្រង់អនុញ្ញាតផង ។

ក្នុងប្រការនេះ ព្រះអង្គក៏អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការងូតទឹកបានជានិច្ច ។

៤- ក្នុងដែនអវន្តីជនបទ មានកម្រាលស្បែកទាំងឡាយ មានស្បែកពពែ ស្បែកចៀម ស្បែកម្រឹគ សូមឲ្យព្រះអង្គអនុញ្ញាតផង ។

ក្នុងប្រការនេះ ព្រះអង្គក៏ទ្រង់បានពុទ្ធានុញ្ញាតឲ្យភិក្ខុប្រើប្រាស់កម្រាលដែលធ្វើដោយស្បែកនោះបាន ។

៥- ក្នុងដែនអវន្តីជនបទ ឥឡូវនេះមនុស្សទាំងឡាយគេប្រគេនចីវរ ដើម្បីពួកភិក្ខុដែលនៅក្រៅសីមា យើងនឹងប្រគេនចីវរនេះដើម្បីភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកហើយប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះ បានប្រគេនចីវរចំពោះលោក ភិក្ខុទាំងនោះក៏រង្កៀសមិនត្រេកអរដោយគិតថា កុំឲ្យមាននិស្សគ្គិយដល់យើងឡើយ ហេតុនេះសូមឲ្យព្រះមានព្រះភាគទ្រង់គួរប្រាប់របៀបប្រតិបត្តិក្នុងចីវរផង ។

ប្រការនេះ ព្រះពុទ្ធអង្គទ្រង់ពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរបាន ចីវរមិនទាន់មកដល់ដៃដរាបណាចីវរនោះ ភិក្ខុមិនទាន់ត្រូវរាប់តាមកំណត់ថ្ងៃដរាបនោះ ។

ក្នុងការមានបដិភាណឆ្លើយតបឲ្យគូសន្ទនាកើតការចាប់ចិត្ត និងយល់ក្នុងពាក្យសម្ដីដែលបានពន្យល់ហើយនោះ ព្រះមហាកច្ចាយនត្ថេររាប់ជាព្រះថេរៈមួយរូបដែលមានបដិភាណក្នុងការឆ្លើយ ដូចមានសូត្រ

ដែលពោលថា មនុស្សចាស់ និងក្មេង ក្នុងសមចិត្តវគ្គ នៃ **បឋមបណ្ណាសកៈ** គឺពួក ៥០ សូត្រទី ១ **គម្ពីរអង្គុត្តរនិកាយ ទុកនិបាត** បានសម្តែងការឆ្លើយតបរវាងព្រះមហាកច្ចាយនៈជាមួយនឹងកណ្ឌរាយនព្រាហ្មណ៍មានសេចក្តីថា ៖

គ្រាមួយ ព្រះមហាកច្ចាយនៈសម្រាកនៅគុន្ទាវ័ន ក្បែរក្រុងមធុរា ក្នុងពេលនោះ កណ្ឌរាយនព្រាហ្មណ៍ចូលទៅរកព្រះថេរៈ ហើយពោលថា លោកម្ចាស់កច្ចាយនៈ ខ្ញុំព្រះករុណាបានឮមកថា លោកម្ចាស់កច្ចាយនៈ មិនសំពះ មិនក្រោកទទួលនូវព្រាហ្មណ៍ចាស់ជរា មិនឲ្យអាសនៈដល់ព្រាហ្មណ៍ចាស់ជរា ការដែលលោកម្ចាស់កច្ចាយនៈធ្វើយ៉ាងនេះ មិនសមគួរឡើយ ។ព្រះមហាកច្ចាយនត្ថេរតបថា នែព្រាហ្មណ៍ មនុស្សចាស់ ឬក្មេងក្នុងធម្មវិន័យនេះ ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងទុកថា សូម្បីមនុស្សចាស់ជរាដល់អាយុ ៨០ ឆ្នាំ ឬ ១០០ ឆ្នាំក៏ដោយ ប្រសិនបើនៅបរិភោគកាម ដេកនៅក្នុងកាម ជាអ្នកក្តៅក្រហាយដោយកាម ជាអ្នកមាននូវកាមវិតក្ក ឬកំពុងខ្វល់ខ្វាយស្វែង

រកកាម ក៏នៅតែរាប់ថាជាមនុស្សក្មេងដោយពិត មិនរាប់ថាជាមនុស្ស ចាស់ជរាឡើយ ប៉ុន្តែសូម្បីមនុស្សនោះនៅក្មេងក៏ដោយ មានសក់ខ្មៅស្រិលក៏ដោយ នៅក្នុងបឋមវ័យក៏ដោយ ប្រសិនបើមិនបរិភោគកាម មិនដេកក្នុងកាម មិនក្តៅក្រហាយដោយកាម មិនមានកាមវិតក្ក មិនខ្វល់ខ្វាយស្វែងរកកាម ក៏រាប់ថាជាមនុស្សចាស់ជរា នៅក្នុងធម្មវិន័យនេះ ដោយពិតប្រាកដ ។

កាលបើព្រះថេរៈតបយ៉ាងនេះហើយ កណ្ឌរាយនព្រាហ្មណ៍បានក្រោកឡើង ជណ្តប់សំពត់ឆៀងស្មាម្ខាង ក៏បានក្រាបថ្វាយបង្គំព្រះថេរៈហើយពោលឡើងថា លោកម្ចាស់ជាមនុស្សចាស់ ចំណែកខ្ញុំព្រះករុណាជាមនុស្សក្មេង ក្នុងធម្មវិន័យនេះ ចាប់ពីថ្ងៃនេះតទៅសូមលោកម្ចាស់ចាំទុកខ្ញុំព្រះករុណាថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យស្មើដោយជីវិតជារៀងរហូតតទៅ ។

មួយទៀត ផលល្អនៃការសម្តែងធម៌របស់ព្រះកច្ចាយនៈ កាលខ្លះមានអ្នកចូលមកសួរ លោកបានអធិប្បាយឲ្យអ្នកសួរកើតការយល់

បានយ៉ាងជាក់ច្បាស់ តាមដែលមានរឿងពោលប្រាកដនៅក្នុង គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ នៃ លោហិច្ចសូត្រ ដូចមានន័យថា ៖

សម័យមួយ ព្រះមហាកច្ចាយនៈគង់នៅអរញ្ញកុដិ ដែលតាំងនៅក្បែរកម្មក្ករកដនគរ ក្នុងអវន្តីជនបទ ។ គ្រានោះ មានពួកមាណពជាច្រើននាក់ ដែលជាអន្តេវាសិករបស់លោហិច្ចព្រាហ្មណ៍ បានដើរទៅរកអុសនិងបាននាំគ្នាចូលទៅកាន់អរញ្ញកុដិរបស់ព្រះមហាកច្ចាយនៈ ហើយនាំគ្នាដើរទៅក្នុងបរិវេណកុដិរបស់ព្រះថេរៈ និងមានការរត់លេងស្រែកសំឡេងអ៊ូអរស្មូរទ្រហឹង ទាំងពោលថា សមណៈត្រងោលទាំងនេះ មានពូជអម្បូរថ្នាក់ថោកទាប ជាពួកដែលកើតអំពីជើងរបស់ព្រហ្ម ។

ក្នុងខណៈនោះ ព្រះមហាកច្ចាយនត្ថេរ បានស្តាប់សំឡេងពោលមើលងាយរបស់មាណពទាំងនោះ ទើបលោកចេញពីកុដិ និងបានពោលជាមួយមាណពទាំងនោះថា នែមាណពទាំងឡាយ ពួកអ្នកកុំពោលសំឡេងឡូឡាអ្វីឡើយ ចាំអាត្មានឹងពោលធម៌ឲ្យពួកអ្នកស្តាប់ ។

កាលបើព្រះមហាកច្ចាយនៈមានថេរដីកាយ៉ាងនេះ ពួកមាណព

ទាំងនោះ ក៏នាំគ្នានៅស្ងៀម ហើយបានពោលជាមួយមាណពទាំងនោះ ដោយគាថាដែលជាធម៌ទាំងឡាយថា

ព្រាហ្មណ៍ពួកណា រមែងរឭកនូវធម៌របស់ព្រាហ្មណ៍ពីបុរាណបាន ព្រាហ្មណ៍ទាំងនោះជាអ្នកខ្ពង់ខ្ពស់បំផុតដោយសីល ព្រាហ្មណ៍ទាំងឡាយពីបុរាណដែលសង្រួមនៅក្នុងទ្វារបាន គ្រប់គ្រងដោយល្អហើយ នឹងអាចគ្របសង្កត់នូវសេចក្តីក្រោធដែលកើតឡើងបាន ។

ព្រាហ្មណ៍ពួកណា រឭកនូវធម៌របស់ពួកព្រាហ្មណ៍ពីបុរាណបាន ព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រព្រឹត្តក្នុងធម៌ និងប្រព្រឹត្តក្នុងឈាន ។

ព្រាហ្មណ៍ពួកណា លះធម៌ ២ នេះចោលហើយ ជាអ្នកស្រវឹងដោយគោត្រថា មានអាជ្ញាក្នុងខ្លួនច្រើន ជាអ្នកប្រព្រឹត្តខុសចំពោះសត្វទាំងឡាយ ព្រាហ្មណ៍នោះជាអ្នកមានភ័យជាប់តាមខ្លួន ។

ការសមាទានវត្តទាំងពួង បានដល់ការមិនបរិភោគ ការដេកលើបន្ទា ការចុះត្រាំទឹក និងការមិនគ្រប់គ្រងនូវទ្វារទាំងនេះ ជាការគ្មានផលប្រៀបដូចជាបុរសដែលដេកសុបិន ដូច្នោះដែរ ។ ការពោលសរសើរ

បរិក្ខារភណ្ឌទាំងនេះ គឺស្បែកខ្លា ព្រមទាំងក្រចក ជដា និងការសន្សំនូវរបស់មិនស្អាតជាមូល ធ្មេញ មន្ត្ត សីលព្វតៈ ដែលថាជាតបៈ ។ ការបោកបញ្ឆោតឈើច្រត់ដែលកោង.ង និងការប្រោះព្រំទឹក ដែលពោលថា ជាចំណេះដឹងរបស់ព្រាហ្មណ៍ ទាំងនេះជាការបំពេញដើម្បីអាមិសដែលពួកព្រាហ្មណ៍ធ្វើហើយ ។

ចំណែកពួកបុរាណណាជាអ្នកមានចិត្តតាំងមាំល្អ មានចិត្តផូរផង់ជាអ្នកមានចិត្តមិនឃោរឃៅចំពោះសត្វទាំងឡាយ ការធ្វើយ៉ាងនេះជាដំណើរទៅកាន់ព្រហ្មលោក ។ ពួកមាណពទាំងនោះ បានស្តាប់ថេរវាចារបស់ព្រះមហាកច្ចាយនត្ថេរហើយ កើតការចង្អៀតចង្អល់ និងមិនពេញចិត្តចំពោះព្រះថេរៈឡើយ ទើបនាំគ្នាចូលទៅដល់ទីលំនៅរបស់លោហិច្ច-ព្រាហ្មណ៍ដែលជាអាចារ្យ និងបានពោលជាមួយលោហិច្ចព្រាហ្មណ៍ថា បពិត្រលោកអាចារ្យដ៏ចម្រើន សូមលោកអាចារ្យជ្រាបចុះ ព្រះកច្ចាយនៈពោលបញ្ជិតបញ្ជៀងបញ្ឈឺចិត្ត និងជំទាស់ចំពោះមន្តរបស់ព្រាហ្មណ៍ទាំងឡាយ ។

កាលបើពួកមាណពពោលយ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍កើតការបង្អៀតបង្អល់ចិត្ត ថែមទាំងមិនពេញចិត្តចំពោះព្រះថេរៈទៀតផង ប៉ុន្តែគេគិតឡើងថា ការដែលយើងជេរតិះដៀលព្រះថេរៈរូបនេះ ព្រោះជឿស្តាប់ពាក្យសម្តីរបស់ពួកមាណពទាំងនេះដូចមិនសមគួរដល់យើងឡើយ ទោះបីយ៉ាងណា យើងនឹងចូលទៅរកព្រះថេរៈសួរមើលសិនមើល៍ទើបជាការល្អ ។ កាលបើលោហិច្ចព្រាហ្មណ៍បានគិតដូច្នេះហើយ ទើបនាំមាណពទាំងនោះ ចូលទៅរកព្រះមហាកច្ចាយនត្ថេរ រហូតដល់ទីលំនៅនិងបានប្រាស្រ័យចរចាជាមួយនឹងលោករួចហើយទើបអង្គុយនៅក្នុងទីដ៏សមគួរ ហើយសួរព្រះថេរៈថា លោកម្ចាស់កច្ចាយនៈដ៏ចម្រើន ពួកមាណពជាច្រើន ដែលដើរមករកអុស ជាសិស្សរបស់ខ្ញុំធ្លាប់បានចូលមកទីនេះដែរឬទេ ? ព្រះថេរៈតបថា ធ្លាប់មក លោហិច្ចព្រាហ្មណ៍ផ្តើមសួរថា លោកម្ចាស់កច្ចាយនៈ លោកធ្លាប់បានប្រាស្រ័យចរចាជាមួយនឹងមាណពទាំងនោះដែរឬទេ ? ព្រះថេរៈតបថា ធ្លាប់បានប្រាស្រ័យចរចាដែរ ។លោហិច្ចព្រាហ្មណ៍ផ្តើមសួរទៀតថា លោកម្ចាស់ធ្លាប់ប្រាស្រ័យ

ចរចាជាមួយនឹងមាណពទាំងនោះ យ៉ាងណាដែរ ? ព្រះមហាកច្ចាយនៈពោលពន្យល់ថា អាត្មាបានប្រាស្រ័យចរចាជាមួយមាណពទាំងនោះយ៉ាងនេះថា

ពួកព្រាហ្មណ៍ណា រមែងរឭកនូវធម៌របស់ព្រាហ្មណ៍ពីបុរាណបាន ព្រាហ្មណ៍ពួកនោះ ជាអ្នកខ្ពង់ខ្ពស់បំផុតដោយសីល ។ល។ ការធ្វើយ៉ាងនេះ ជាដំណើរទៅកាន់ព្រហ្មលោក នៃព្រាហ្មណ៍ អាត្មាបានប្រាស្រ័យចរចាជាមួយមាណពយ៉ាងនេះឯង ។ លោហិច្ចព្រាហ្មណ៍ បានស្តាប់ពាក្យពន្យល់របស់ព្រះថេរៈហើយ ក៏សួរតទៅទៀតថា លោកម្ចាស់កច្ចាយនៈដ៏ចម្រើន ដែលលោកពោលថា អ្នកដែលមិនបានគ្រប់គ្រងទ្វារ ដោយមានហេតុប្រមាណប៉ុន្មាន ទើបបុគ្គលឈ្មោះថា ជាអ្នកមានទ្វារមិនបានគ្រប់គ្រង ? ព្រះមហាកច្ចាយនៈពោលអធិប្បាយថា នៃព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ឃើញរូបដោយភ្នែក ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ដឹងរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ និងដឹងធម្មារម្មណ៍ដោយចិត្តហើយ រមែងពេញចិត្តក្នុងរូប សំឡេង ក្លិន រស

ផោដ្ឋព្វៈ និងធម្មារម្មណ៍ដែលជាទីពេញចិត្ត ជាអ្នកមិនមានសតិតាំងមាំ មិនរវាំងនិងមិនដឹងច្បាស់នូវចេតោវិមុត្តិបញ្ញាវិមុត្តិតាមពិតដោយអំណាចអកុសលធម៌ដ៏លាមកទាំងនេះ កើតឡើងហើយក្នុងចិត្តនៃបុគ្គលនោះទាំងនេះឈ្មោះថា ជាអ្នកមិនគ្រប់គ្រងទ្វារ ។លោហិច្ចព្រាហ្មណ៍ បានស្តាប់ដូច្នេះហើយក៏ពោលឡើងថា លោកម្ចាស់កច្ចាយនៈសេចក្តីដែលលោកបានពោលថា បុគ្គលដែលមិនបានគ្រប់គ្រងទ្វារ គួរអស្ចារ្យណាស់ មិនធ្លាប់មាន ទើបសួរព្រះថេរៈបន្តទៀតថា ចុះបុគ្គលដែលគ្រប់គ្រងទ្វារដោយល្អនោះ មានន័យយ៉ាងណា ?

ព្រះថេរៈតបថា ភិក្ខុក្នុងធម្មវិន័យនេះ បានឃើញរូបដោយភ្នែក ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ដឹងរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ និងដឹងធម្មារម្មណ៍ដោយចិត្តហើយ រមែងជាអ្នកមិនត្រេកអររីករាយចំពោះរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ដែលគួរប្រាថ្នាពេញចិត្តឡើយ ជាអ្នកមានសតិតាំងមាំ ដឹងច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ តាមសេចក្តីពិត ដូច្នេះហើយ អកុសលធម៌

ដ៏លាមកទាំងឡាយ ក៏មិនកើតមានដល់ភិក្ខុនោះ ទាំងនេះឈ្មោះថាជាអ្នកគ្រប់គ្រងទ្វារដោយល្អ ដោយប្រការយ៉ាងនេះឯង ។

លោហិច្ចព្រាហ្មណ៍ បានពោលសរសើរព្រះថេរៈថា លោកម្ចាស់ពោលដល់បុគ្គលដែលជាអ្នកគ្រប់គ្រងទ្វារនេះ គួរឲ្យអស្ចារ្យណាស់ មិនធ្លាប់មាន ភាសិតរបស់លោកម្ចាស់ជាក់ច្បាស់ពេកណាស់ ដោយអនេកបរិយាយ ប្រៀបដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ បើករបស់ដែលបិទ ឬដូចបុគ្គលទ្រោលប្រទីបក្នុងទីងងឹត ដូច្នោះឯង ។ បពិត្រលោកម្ចាស់កច្ចាយនៈដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះមានព្រះភាគអង្គនោះព្រមទាំងព្រះធម៌ និងព្រះសង្ឃជាសរណៈ ជាទីពឹង ទីរឭកស្មើដោយជីវិតចាប់តាំងពីថ្ងៃនេះតទៅ ។

ម្យ៉ាងទៀត សូមលោកម្ចាស់កច្ចាយនៈដ៏ចម្រើន ចូលទៅកាន់លោហិច្ចត្រកូល ដូចដែលលោកម្ចាស់ចូលទៅកាន់ត្រកូលឧបាសកទាំងឡាយក្នុងកម្មក្ករកដនគរចុះ ពួកមាណពដែលនៅក្នុងលោហិច្ចត្រកូលទាំងនោះនឹងថ្វាយបង្គំ នឹងក្រោកឡើងទទួលលោកម្ចាស់ដើម្បីប្រយោជន៍

និងសេចក្តីសុខអស់កាលជាយូរអង្វែងដល់ពួកគេ ។

ដូចមានរឿងសម្តែងហេតុផលថា ព្រះមហាកច្ចាយនត្ថេរ លោកមានរូបរាងកាយស្អាតណាស់ មានសម្បុរលឿងដូចមាស គួរឲ្យស្រឡាញ់ មាននៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **ចិត្តវគ្គ** ក្នុងរឿងព្រះសោរេយ្យត្ថេរ ដូចមានសេចក្តីថា ៖

នៅក្នុងសោរេយ្យនគរ មានសេដ្ឋីបុត្រម្នាក់ ឈ្មោះថា សោរេយ្យ បានអង្គុយលើយានជាមួយនឹងសម្លាញ់ ចេញអំពីក្រុងដើម្បីងូតទឹករួមជាមួយនឹងបរិវារជាច្រើននាក់ ។ ខណៈនោះ ព្រះមហាកច្ចាយនត្ថេរ ចូលទៅបិណ្ឌបាតក្នុងសោរេយ្យនគរ មុននឹងចូលទៅក្នុងក្រុង លោកឃ្លុំចីវរនៅក្រៅក្រុង ធ្វើឲ្យសោរេយ្យក្រឡេកមើលឃើញសម្បុរកាយពណ៌ដូចមាស ទើបគិតឡើងថា សូមឲ្យព្រះថេរៈរូបនេះ បានជាភរិយារបស់យើង ឬសូមឲ្យភរិយារបស់យើង មានពណ៌សម្បុរកាយដូចព្រះថេរៈរូបនេះ ។ គ្រាន់តែគិតដូច្នេះ ភេទរបស់បុរសក៏បាត់ទៅ ប្រាកដជាភេទស្រីឡើង គេអៀនខ្មាសណាស់ ទើបចុះពីយាននោះរត់ទៅដោយ

មិនឲ្យនរណាដឹងបាន គេបានធ្វើដំណើរទៅកាន់នគរតក្កសិលា មិនឲ្យនរណាដឹងរឿងរបស់ខ្លួន ។

ចំណែកសម្លាញ់របស់សោរេយ្យបានស្វែងរកសព្វទិសទី ក៏នៅតែមិនបានជួបប្រទះ គ្រប់គ្នាងូតទឹករួចហើយ ក៏ត្រឡប់ទៅផ្ទះវិញ ដោយនឹកថា សោរេយ្យគេងូតទឹកហើយ គង់នឹងត្រឡប់មកផ្ទះមិនខាន ។ គ្រានោះ មាតាបិតារបស់សោរេយ្យ មិនឃើញកូនត្រឡប់មក ទើបចេញទៅតាមសួររកកូនសព្វទីកន្លែង ក៏នៅតែមិនបានជួបប្រទះ និងមិនមានការដឹងដំណឹងអ្វីសោះ ក៏បានស្រែកយំដោយយល់ថា សោរេយ្យកូនរបស់យើងស្លាប់ទៅហើយ ទើបនាំគ្នាធ្វើបុណ្យឧទ្ទិសដល់សោរេយ្យ ។

ចំណែកសោរេយ្យ ដើរតាមពីក្រោយរទេះដែលនឹងទៅកាន់នគរតក្កសិលា ប៉ុន្តែគេដើរទៅមិនបានប៉ុន្មានក៏ដើរមិនរួច ទើបគេដោះចិញ្ចៀនមួយវង់ជាថ្លៃឈ្នួលក្នុងការជិះរទេះ ។ ជនជាច្រើនលុះឃើញសោរេយ្យមានរូបស្អាតរកកន្លែងរិះគន់មិនបាន ទើបប្រឹក្សាគ្នាថា បុត្រសេដ្ឋីក្នុងនគរតក្កសិលាមិនទាន់មានភរិយា ពួកយើងប្រាប់គេហើយ គង់នឹងបានរង្វាន់

មិនខាន ។ជនទាំងនោះកាលទៅដល់នគរតក្កសិលាហើយ បានប្រញាប់ទៅប្រាប់សេដ្ឋីបុត្រថា នែនាយ ពួកខ្ញុំបាននាំស្រីកែវមកឲ្យលោក សេដ្ឋីបុត្រស្តាប់ហើយចាប់ចិត្ត ទើបឲ្យនាំស្រីនោះមកមើល កាលគេឃើញរូបស្អាត ក៏បានកើតសេចក្តីស្នេហា យកនាងធ្វើជាភរិយារបស់ខ្លួន ។

បុរសដែលមិនធ្លាប់កើតជាស្រី ឬស្រីដែលមិនធ្លាប់កើតជាបុរសមិនមានឡើយ ព្រោះបុរសទាំងឡាយ ប្រព្រឹត្តខុសចំពោះបុត្រភរិយារបស់អ្នកដទៃ ស្លាប់ទៅត្រូវកើតក្នុងនរកច្រើនសែនឆ្នាំ ហើយត្រឡប់មកកើតជាមនុស្ស តែត្រូវកើតជាស្រីចំនួន ១០០ ជាតិ ។

សូម្បីព្រះអានន្ទត្ថេរ បានកសាងបុណ្យបារមីមកហើយ មួយសែនកប្ប ជាតិមួយ លោកបានកើតក្នុងត្រកូលជាងមាស បានប្រព្រឹត្តខុសចំពោះបុត្រភរិយារបស់អ្នកដទៃ ក្រោយពីស្លាប់ ត្រូវទៅឆេះក្នុងនរករួចហើយ ក៏ត្រឡប់បានកំណើតជាស្រី និងជាភរិយារបស់គេ១៤ជាតិ ទាំងបានជាស្រីអារ ៧ ជាតិ ប៉ុន្តែប្រសិនបើស្ត្រីប្រាថ្នាចង់កើតជាបុរសវិញ ត្រូវធ្វើបុណ្យ ឲ្យទាន រក្សាសីលជាដើម បើអស់ការពេញចិត្ត

ជាស្រីហើយ គប្បីតាំងចិត្តទុកដូច្នេះថា

បុណ្យរបស់យើងនេះ សូមឲ្យយើងបានកើតជាបុរស ពេលស្លាប់ទៅហើយ ក៏បានកើតជាបុរសមែន ។ ឬម្យ៉ាងទៀត អ្នកដែលគោរពស្វាមីដូចជាទេវតា រមែងកើតជាបុរសបាន ដោយអំណាចការបដិបត្តិចំពោះស្វាមី ។

កាលសោរេយ្យនៅរួមជាមួយនឹងសេដ្ឋីបុត្រ មានកូន ២ នាក់ទៀត កាលពីមុនដែលគេនៅក្នុងសោរេយ្យនគរ គេមានកិរិយា និងមានបុត្រ ២ នាក់ទៅហើយ រួមបុត្រទាំងមុនក្រោយត្រូវជា ៤ នាក់ ។ ជាតិនេះធ្លាប់ជាស្វាមីគេផង និងធ្លាប់ជាប្រពន្ធគេផង ពេលជាខាងក្រោយមកគេបានជ្រាបដំណឹងពីសម្លាញ់ដែលនាំទំនិញមកលក់ នៅនគរតក្កសិលាថា ព្រះមហាកច្ចាយនៈ មកអាស្រ័យនៅក្នុងនគរនេះ ទើបត្រៀមរៀបចំចង្ហាន់ និងគ្រឿងសក្ការៈទុកប្រគេន ហើយនិមន្តព្រះថេរៈមកផ្ទះរបស់ខ្លួន ។ សោរេយ្យបានតំណាលរឿងក្នុងកាលមុន ឲ្យស្វាមីស្តាប់ ហើយស្វាមីក៏បាននាំចូលទៅសូមខមាទោសចំពោះព្រះថេរៈ ព្រះថេរៈក៏បាន

អត់ទោសឲ្យ ភេទស្រីបាត់ទៅមួយរំពេច ភេទបុរសក៏បានប្រាកដឡើងដូចដើមវិញ ព្រះមហាកច្ចាយនៈ បានស្ដាប់រឿងនេះហើយ កើតការស្ដុតចិត្ត និងការពារមិនឲ្យហេតុយ៉ាងនេះកើតឡើងទៀត ព្រោះការគិតមិនល្អ ទើបលោកអធិដ្ឋានឲ្យរូបរបស់លោកមិនស្អាត មិនគួរឲ្យចង់មើលទៀតផង ។

នៅមានរឿងដែលសម្ដែងដល់ព្រះមហាកច្ចាយនៈ ថាជាអ្នកមានរូបស្អាតឥតខ្ចោះ មានពណ៌សម្បុរលឿងដូចជាមាស និងមានអ្នកដទៃពោលសរសើរលោកថា មានបុគ្គលិកលក្ខណៈប្រៀបដូចព្រះសម្ពុទ្ធ តាមដែលមានរឿងតំណាលទុកក្នុង**គម្ពីរអសីតិមហាសាវកនិព្វាន** ថា៖

ព្រះមហាកច្ចាយនៈ ជាអ្នកមានសីល សមាធិ បញ្ញា សម្រាកសម្រួលឥរិយាបថ ប្រាសចាកភ័យនៅក្នុងកុដិ ក្នុងព្រៃស្រស់មានម្លប់ត្រឈឹងត្រឈៃ ដែលតាំងនៅជើងភ្នំបជ្ជលិតបព៌ត ដោយអាស្រ័យនៅហេមនគរ ជាទីគោចរបិណ្ឌបាត លោកបានសម្ដែងធម៌ធ្វើឲ្យមនុស្ស និងទេវតាកើតសេចក្ដីត្រេកអរក្នុងការបរិច្ចាគទាន ក្នុងការរក្សាសីល និង

មានសទ្ធាជ្រះថ្លាក្នុងព្រះសាសនា រហូតដល់មានការគោរពចំពោះព្រះរតនត្រ័យជានិច្ចនិរន្តរ៍ ។ រូបកាយរបស់ព្រះមហាកច្ចាយនៈនោះ ស្អាតពេកក្រៃ រកព្រះថេរានុថេរៈទាំងឡាយប្រៀបផ្ទឹមមិនបាន វៀរលែងតែព្រះមុនីចេញប៉ុណ្ណោះ ដូចមានពាក្យពណ៌នាសរសើរលោកថា

កាលបើព្រះមហាកច្ចាយនត្ថេរ ចារិកបិណ្ឌបាតទៅក្នុងប្រទេសណា មនុស្ស និងទេវតាទាំងឡាយក្នុងប្រទេសនោះ ពោលសរសើរស្រែកឡើងថា **សត្ថា អាគតោ** ពួកយើង ព្រះបរមគ្រូមកប្រោសពួកយើងហើយ ទើបនាំគ្នាធ្វើសក្ការបូជាសម្តែងនូវការគោរពថ្វាយបង្គំព្រះមហាកច្ចាយនត្ថេរនោះ ដោយការពេញចិត្ត ។ កាលបើព្រះថេរៈបានស្តាប់ពាក្យរបស់មនុស្ស និងទេវតាទាំងឡាយ ដែលនាំគ្នាពោលសរសើរលើកតម្កើងខ្លួនប្រៀបផ្ទឹមជាមួយគ្នានឹងព្រះមុនី ទើបលោកគិតពិចារណានៅក្នុងចិត្តថា មនុស្ស និងទេវតាទាំងនេះ ពោលសរសើរយើងដោយពាក្យមិនសមគួរទាល់តែសោះដោយបាននាំគ្នាហៅខ្លួនយើងថាជាព្រះសក្យមុនីទៅវិញ ពាក្យនេះរមែងជាការមិនសមគួរទេ ។

កាលបើព្រះថេរៈ លោកគិតពិចារណាមើលហេតុផលនៃពាក្យសម្ដីរបស់មនុស្ស និងទេវតាទាំងនោះ ដែលនាំគ្នាពោលសរសើរខ្លួន មិនអាចនឹងអត់ទ្រាំស្ដាប់វាចា ដែលពោលសរសើរលើកតម្កើងខ្លួនឡើងស្មើគ្នានឹងព្រះសាស្ដាទៅតទៀតបាន ទើបលោកគិតថា យើងចាំបាច់ត្រូវនិម្មិតរូបកាយរបស់យើងនេះ ឲ្យផ្លាស់ប្ដូរប្រែប្រួលខុសពីសភាពដើម កាលបើលោកគិតដូច្នេះហើយ ទើបព្រះថេរៈអធិដ្ឋានចិត្ត និម្មិតរូបកាយរបស់លោកឲ្យរួញខ្ញីជាត់ អស់នូវភាពស្អាត ព្រោះដូច្នោះ រូបកាយរបស់ព្រះមហាកច្ចាយនត្ថេរ ទើបប្រាកដមានលក្ខណៈមិនស្អាតរហូតមកដល់សព្វថ្ងៃនេះ ។

រឿងឈ្មោះរបស់ព្រះមហាកច្ចាយនត្ថេរ ជារឿងដែលគួរឲ្យចាប់ចិត្ត ម្យ៉ាងទៀត ក្នុង **គម្ពីរអសីតិមហាសាវកនិព្វាន** ពោលថា អតីតលោកឈ្មោះថា ព្រហ្មបុត្រ បន្ទាប់មកបានហៅឈ្មោះលោកថា ព្រះគវម្បតិត្ថេរ ព្រោះហេតុថា លោកមានរូបកាយស្អាតក្រៃពេក ទេសនាក៏ពីរោះ ដូចព្រះពុទ្ធជាម្ចាស់ ទើបមហាជនហៅថា **គវម្បតិ** ប្រែថា

ម្ចាស់នៃពាក្យនិយាយ ។

ការដែលមានចំណេះចេះដឹង អាចអធិប្បាយសេចក្តីឲ្យយល់បានងាយ នាំយកហេតុផលមកពន្យល់ឲ្យអ្នកស្តាប់យល់ចូលចិត្ត ព្រមទទួលការពិត ព្រះមហាកច្ចាយនត្ថេរ រាប់ថាជាព្រះថេរៈមួយរូប ដែលបានធ្វើសេចក្តីល្អជាច្រើន ដូចមានរឿងចារឹកទុកនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** នៃមធុរសូត្រ ហើយរឿងនេះនៅជាលក្ខណ៍ដ្ឋានបង្ហាញឲ្យបានដឹងថា លោកមានអាយុយឺនយូរ មកដល់ក្រោយព្រះពុទ្ធជាម្ចាស់ទ្រង់រំលត់ខន្ធបរិនិព្វានហើយ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមហាកច្ចាយនត្ថេរ សម្រាន្តឥរិយាបថនៅក្នុងគុន្ទាវ័ន ទៀបក្រុងមធុរា ។ ព្រះបាទមធុររាជអវន្តីបុត្រ បានឮដំណឹងថា ម្នាលគ្នាយើងដ៏ចម្រើន សមណៈឈ្មោះកច្ចាយនៈ ឥឡូវនេះគង់នៅក្នុងគុន្ទាវ័ន ទៀបក្រុងមធុរា កិត្តិស័ព្ទដ៏ប្រពៃយ៉ាងនេះ របស់ព្រះកច្ចាយនៈដ៏ចម្រើននោះឯង តែងផ្សាយទៅសព្វទិសថា លោកជាបណ្ឌិតឈ្លាសវៃ មានបញ្ញា ជាពហូសូត មានសម្តីដ៏វិចិត្រ មានបញ្ញាដ៏ល្អ ជាអ្នកចាស់

ព្រឹទ្ធាចារ្យផង ជាព្រះអរហន្តផង ការបានឃើញព្រះអរហន្ត មានសភាព យ៉ាងនេះ ជាការញុំាងប្រយោជន៍ឲ្យសម្រេចដោយពិត ។ គ្រានោះ ព្រះបាទមធុរាជអវន្តីបុត្ត ទ្រង់ឲ្យរៀបចំយានទាំងឡាយដែលល្អៗ ទ្រង់ឡើងគង់លើយានដែលល្អៗ ហើយទ្រង់ស្ដេចចេញចាកក្រុងមធុរា ដោយយានទាំងឡាយដែលល្អៗ ដើម្បីជួបនឹងព្រះមហាកច្ចាយនៈ ដោយរាជានុភាពដ៏ធំ ទ្រង់ស្ដេចទៅដោយយាន កំណត់ត្រឹមផែនដី ដែលបរយានទៅបាន ហើយទ្រង់យាងចុះពីយាន ទ្រង់ព្រះដំណើរទៅដោយព្រះបាទា ចូលទៅរកព្រះមហាកច្ចាយនៈ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះថេរៈ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ព្រះបាទមធុរាជបុត្រ លុះគង់នៅក្នុងទីដ៏សមគួរហើយ មានព្រះបន្ទូលពាក្យនេះនឹងព្រះមហាកច្ចាយនៈមានអាយុថា បពិត្រព្រះកច្ចាយនៈដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាពោលយ៉ាងនេះថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែន

ព្រាហ្មណ៍ មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្ររបស់ព្រហ្មជាឱរស កើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងឲ្យកើត ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ សេចក្ដីនេះ ព្រះកច្ចាយនៈដ៏ចម្រើន នឹងពោលដូចម្ដេចទៅវិញ ។

ព្រះមហាកច្ចាយនៈថ្វាយព្រះពរថា បពិត្រមហារាជ សំឡេង សុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃ ជាវណ្ណៈទាបជាដើម ។បេ។ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនោះ អ្នកប្រាជ្ញគប្បីដឹងដោយបរិយាយ ដូចត ទៅនេះ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច បើក្សត្រ គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើក្សត្រ ( ដទៃ ) គប្បីជាអ្នកតើនឡើងមុន ផ្ទំក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រនោះឬទេ ? ព្រាហ្មណ៍ក្ដី... វេស្សៈក្ដី... សុទ្ទៈក្ដី គប្បីជាអ្នក ក្រោកឡើងមុន ដេកក្រោយក្ដី ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទី

គាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃក្សត្រនោះឬទេ ? ព្រះបាទមធុររាជត្រាស់ថា បពិត្រព្រះកច្ចានៈដ៏ចម្រើន បើក្សត្រគប្បីសម្រេច (ឥទ្ធានុភាព) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស ក្សត្រដទៃ ក៏ជាអ្នកត្រូវតើនឡើងមុន ផ្ទំក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃក្សត្រនោះឯង ។ ព្រាហ្មណ៍ក្ដី...វេស្សៈក្ដី... សុទ្ទៈក្ដី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃក្សត្រនោះឯង ។

ព្រះថេរៈសួរបន្តទៀតថា បពិត្រមហារាជ ប្រសិនបើសេចក្ដីត្រូវការរបស់វេស្សៈ សុទ្ទៈ... ក្សត្រ... ព្រាហ្មណ៍... នឹងត្រូវសម្រេចដោយទ្រព្យ ស្រូវ ឬមាសប្រាក់ហើយ សុទ្ទៈ... ក្សត្រ... ព្រាហ្មណ៍... ត្រូវភ្ញាក់មុន ផ្ទំក្រោយ ត្រូវរង់ចាំស្ដាប់ទទួលបម្រើ ប្រព្រឹត្តឲ្យត្រូវចិត្ត និងត្រូវនិយាយពាក្យពីរោះចំពោះវេស្សៈយ៉ាងនោះឬ មហារាជ ? ព្រះរាជាតបថា យ៉ាងនោះហើយ លោកម្ចាស់កច្ចាយនៈ ។ ព្រះថេរៈសួរបន្តទៀតថា បពិត្រមហារាជ ប្រសិនបើសេចក្ដីត្រូវការរបស់សុទ្ទៈ វេស្សៈ...

ក្សត្រ... ព្រាហ្មណ៍... នឹងត្រូវសម្រេចដោយទ្រព្យ ស្រូវ ឬមាស ប្រាក់ហើយ វេស្ស:... ក្សត្រ... ព្រាហ្មណ៍... ត្រូវក្រោក់មុន ផ្ទុំក្រោយ ត្រូវរង់ចាំស្តាប់ ទទួលបម្រើ ប្រព្រឹត្តឲ្យត្រូវចិត្ត និងត្រូវនិយាយពាក្យពីរោះចំពោះសុទ្ទ:យ៉ាងនេះឬ មហារាជ ? ព្រះរាជាតបថា បពិត្រលោកម្ចាស់កច្ចាយន: យ៉ាងនោះហើយ ។

ព្រះថេរ:សួរបន្តទៀតថា បពិត្រមហារាជ ប្រសិនបើសេចក្តីត្រូវការរបស់ព្រាហ្មណ៍ វេស្ស:... សុទ្ទ:... ក្សត្រ... នឹងត្រូវសម្រេចដោយទ្រព្យ ស្រូវ ឬមាសប្រាក់ហើយ វេស្ស:... សុទ្ទ:... ក្សត្រ... ត្រូវក្រោក់មុន ផ្ទុំក្រោយ ត្រូវរង់ចាំស្តាប់ ទទួលបម្រើ ប្រព្រឹត្តឲ្យត្រូវចិត្ត និងត្រូវនិយាយពាក្យពីរោះ ចំពោះវេស្ស:យ៉ាងនោះឬ មហារាជ ? ព្រះរាជាតបថា យ៉ាងនោះហើយ លោកម្ចាស់កច្ចាយន: ។

ទើបព្រះថេរ:សួរទៀតថា បពិត្រមហារាជ កាលបើយ៉ាងនោះបុគ្គលទាំង ៤ ពួកនេះ រមែងជាអ្នកស្មើគ្នាមិនមែនឬ តើមហារាជទ្រង់មានព្រះទ័យយល់យ៉ាងណា ក្នុងបុគ្គលទាំង ៤ ពួកនោះ ? ព្រះរាជា

តបថា បពិត្រលោកម្ចាស់កច្ចាយនៈ កាលបើយ៉ាងនោះ បុគ្គលទាំង ៤ ពួកនេះ ជាអ្នកស្មើគ្នាទាំងអស់ ខ្ញុំព្រះករុណាមិនឃើញការប្លែកផ្សេងគ្នាយ៉ាងណានីមួយឡើយ ។ព្រះថេរៈសួរបន្តបន្ថែមទៀតថា បពិត្រមហារាជ សូមទ្រង់ជ្រាបនូវសេចក្តីនេះ ដោយហេតុផលដូចតទៅនេះទៀត ប្រសិនបើក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ សម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ និយាយកុហក និយាយញុះញង់ និយាយពាក្យពេយរាយឥតប្រយោជន៍ ចិត្តរំពៃចង់បានទ្រព្យរបស់គេ មានចិត្តគិតព្យាបាទ មានការយល់ខុស ពេលបុគ្គលទាំងនោះស្លាប់ទៅហើយ នឹងទៅកើតក្នុងអបាយភូមិ ទុគ្គតិ វិនិបាត នរក ដូច្នេះឬ មហាបពិត្រ ? ព្រះរាជាត្រាស់តបថា ខ្ញុំព្រះករុណាបានស្តាប់ថេរវាចារបស់ព្រះអរហន្តទាំងឡាយថា បុគ្គលធ្វើអំពើអាក្រក់ទាំងនោះ ក្រោយអំពីស្លាប់ហើយរមែងទៅកើតក្នុងអបាយភូមិដូចគ្នាទាំងអស់ ។

ព្រះថេរៈសួរទៀតថា បពិត្រមហារាជ ប្រសិនបើយ៉ាងនោះ បុគ្គលទាំង ៤ ពួកនេះ ជាអ្នកស្មើគ្នាឬទេ ឬមានសេចក្តីប្លែកផ្សេងពីគ្នាយ៉ាង

ណា ? ព្រះរាជាត្រាស់តបថា បុគ្គលទាំង ៤ ពួកនេះ ជាអ្នកស្មើគ្នាព្រមទាំងមិនឃើញការប្លែកគ្នាត្រង់កន្លែងណាទីមួយឡើយ ។ ព្រះថេរៈបានដោះស្រាយបញ្ហាជាច្រើនទៀត ពន្យល់ធ្វើឲ្យព្រះរាជាយល់ទៅតាមសេចក្ដីពិតហើយ ក៏កើតសេចក្ដីត្រេកអររីករាយចំពោះភាសិតទាំងនោះដែលព្រះមហាកច្ចាយនៈបានសម្ដែងហើយ ព្រះបាទមធុរាជអវន្តិបុត្រទ្រង់ត្រាស់សរសើរព្រះថេរៈថា បពិត្រលោកម្ចាស់ ថេរវាចារបស់លោកម្ចាស់ជាក់ច្បាស់ពេកណាស់ លោកម្ចាស់បានសម្ដែងធម៌ដល់ខ្ញុំករុណាដោយអនេកបរិយាយ ដើម្បីឲ្យបានជាប្រយោជន៍ដល់ខ្ញុំព្រះករុណា ប្រៀបដូចបុគ្គលផ្ងារបស់ដែលផ្កាប់ ប្រាប់ផ្លូវឲ្យដល់អ្នកវង្វេងផ្លូវដូច្នេះជាដើម ខ្ញុំព្រះករុណាសូមដល់លោកម្ចាស់កច្ចាយនៈផង ព្រះធម៌ និងព្រះសង្ឃជាសរណៈ ព្រះថេរៈត្រាស់តបថា សូមមហាបពិត្រកុំយកអាត្មាជាសរណៈឡើយ ចូរយកព្រះពុទ្ធជាសរណៈវិញចុះ ។

ព្រះបាទមធុរាជអវន្តិបុត្រ បានសួរព្រះថេរៈថា ឥឡូវនេះព្រះភគវាទ្រង់គង់ប្រថាប់នៅក្នុងទីណា ? ព្រះសាស្ដាទ្រង់បរិនិព្វានទៅហើយ ។

ព្រះរាជាទ្រង់សម្តែងសេចក្តីជ្រះថ្លាក្នុងចិត្តថា ប្រសិនបើខ្ញុំករុណាបាន ជ្រាបដំណឹងថា ព្រះមានព្រះភាគទ្រង់គង់ប្រថាប់នៅក្នុងទីណា ចម្ងាយ ១០ យោជន៍ ២០-៣០ ឬ ១០០ យោជន៍ក៏ដោយ ខ្ញុំព្រះករុណានឹងចូលទៅ គាល់ឲ្យបាន ប៉ុន្តែព្រះសម្ពុទ្ធស្តេចរំលត់ខន្ធបរិនិព្វានទៅហើយ ហេតុដូច្នេះ ខ្ញុំព្រះករុណាសូមដល់ព្រះពុទ្ធអង្គនោះផង ព្រះធម៌ និងព្រះសង្ឃថាជា សរណៈ ជាទីពឹងទីរឭក សូមលោកម្ចាស់កច្ចាយនៈ ចាំទុកខ្ញុំព្រះករុណា ថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យស្មើដោយជីវិតផងចុះ ។

ដោយសរុបហេតុផលបានថា មនុស្សយើងទាំងអស់គ្នាមានភាព ស្មើគ្នាគ្រប់វណ្ណៈ ដែលថាមានការប្លែកផ្សេងគ្នានោះ ក៏ដោយសារអំពើ ល្អ និងអាក្រក់ប៉ុណ្ណោះ ។ មានជម្មកថាដែលព្រះមហាកច្ចាយនត្ថេរ បានឲ្យ ឱវាទដល់ភិក្ខុទាំងឡាយ ដែលមាននៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖

គ្រាមួយ ព្រះមហាកច្ចាយនត្ថេរ បានឲ្យឱវាទដល់ភិក្ខុច្រើនរូប ដោយសារភិក្ខុទាំងនោះ នាំគ្នាលះបង់ក្នុងការធ្វើសមណៈធម៌ បែរមក

ត្រេកអរក្នុងការងារ ជាប់ក្នុងរសអាហារ ជាអ្នកពេញចិត្តនឹងពួកគណៈ រស់នៅច្រើនទៅដោយសេចក្ដីប្រាថ្នា ទើបព្រះថេរៈឲ្យឱវាទថា បព្វជិតមិនគប្បីធ្វើនូវកម្មច្រើនទេ គប្បីលះបង់ជន (បាបមិត្ត) មិនគប្បីខ្វល់ខ្វាយ (ដើម្បីលាភទេ) ព្រោះបព្វជិតអ្នកខ្វល់ខ្វាយ ជាប់ចិត្តក្នុងរស រមែងលះបង់ប្រយោជន៍ ដែលនាំមកនូវសេចក្ដីសុខ ។ ការថ្វាយបង្គំ និងការបូជាក្នុងត្រកូលទាំងឡាយ ពួកព្រះអរិយៈដឹងច្បាស់ នូវការថ្វាយបង្គំ និងការបូជានោះ ថាដូចជាភក់ ទាំងដឹងថាជាសរដ៏ឆ្មារ គេកម្រដកបាន ជាគ្រឿងសក្ការៈ ដែលបុរសអាក្រក់ លះបង់បានដោយកម្រ ។ បុគ្គលមិនគប្បីសេពនូវអំពើអាក្រក់ដោយខ្លួនឯង ព្រោះបំពេញ (ទុក្ខ) ដល់សត្វដទៃ (ទាំងមិនគប្បីញុំាងបុគ្គលដទៃឲ្យសេពនូវអំពើអាក្រក់នោះ) ព្រោះថាសត្វទាំងឡាយ មានកម្មជាផៅពង្ស ។ បុគ្គលជាចោរ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលជាអ្នកប្រាជ្ញ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលដឹងខ្លួនឯង យ៉ាងណា សូម្បីពួកទេវតាក៏ដឹងបុគ្គលនោះ ដូច្នោះដែរ ។ ពួកជនផ្តេសផ្តាស រមែងមិនដឹងច្បាស់ថា យើងទាំងឡាយនឹងលំបាក

ក្នុងលោកនេះ តែពួកជនណា ដឹងច្បាស់ក្នុងដំណើរនោះ ជម្លោះតែងស្ងប់រម្ងាប់ទៅ អំពីសម្នាក់ពួកជននោះ ។ បុគ្គលប្រកបដោយបញ្ញា បើទុកជាអស់សម្បត្តិរលីងធេង ក៏ឈ្មោះថារស់នៅ ឯបុគ្គលមានសម្បត្តិឈ្មោះថា មិនរស់នៅ ព្រោះការមិនបាននូវបញ្ញា ។ បុគ្គលរមែងស្តាប់នូវសំឡេងទាំងអស់បាន ដោយសារត្រចៀក បុគ្គលមានចក្ខុរមែងឃើញរូបគ្រប់យ៉ាង ចំណែកអ្នកប្រាជ្ញមិនគួរលះបោល ឬប្រកាន់នូវអារម្មណ៍ទាំងពួងដែលខ្លួនឃើញហើយ ឮហើយឡើយ ។ បុគ្គលអ្នកមានភ្នែកគប្បីធ្វើដូចជាខ្វាក់ បុគ្គលអ្នកមានត្រចៀក គប្បីធ្វើដូចជាថ្លង់ បុគ្គលអ្នកមានបញ្ញា គប្បីធ្វើដូចជាគ បុគ្គលអ្នកមានកម្លាំង គប្បីធ្វើដូចជាអ្នកខ្សោយកម្លាំង តែកាលបើហេតុ ( មិនគួរធ្វើ ) កើតឡើងហើយ ត្រូវដេកដូចជាស្លាប់ ។

ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ លោកមានភាពច្លាតក្នុងការចែកសេចក្តីសង្ខេបឲ្យពិស្តារបាន លោករំលត់ខន្ធបរិនិព្វាន ក្រោយពីព្រះមានព្រះភាគស្តេចរលត់ខន្ធបរិនិព្វានហើយ ដូចមានការសម្តែងទុក

ក្នុងមធុរសូត្រហើយ ប៉ុន្តែថាស្ថានទីដែលព្រះមហាកច្ចាយនត្ថេរបរិនិព្វាន នោះ មិនបានឃើញមានការពោលទុកក្នុងទីណាទីមួយឡើយ ។៚

( ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ ចប់ )

# ១៤-ភ្នំហិមពាន្ត

ទឹកដីនៃព្រៃហិមពាន្ត គឺជាទឹកដីដ៏ស្រស់ត្រកាលមួយ ប្រកបទៅដោយជ្រោះជ្រងជ្រលងភ្នំ ថែមទាំងមានដើមឈើ និងសត្វចម្លែកៗជាច្រើន ជាពិភពបាថិកំបាំងមួយ ដែលលំបាកនឹងស្រាវជ្រាវដឹងបាន ឬស្ទើរតែមិនជឿថា ទីនេះពោរពេញទៅដោយរឿងរ៉ាវចម្លែកៗ ដែលយើងនឹកស្មានមិនដល់ ។ ទឹកដីនេះហើយដែលព្រះពោធិសត្វ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងពួកឥសីទាំងឡាយធ្លាប់គង់ស្នាក់អាស្រ័យនៅឬជាកន្លែងដែលធ្លាប់បំពេញបុណ្យបារមីដើម្បីឲ្យបានត្រាស់ដឹងសច្ចធម៌ដែលមានសម្តែងនៅក្នុងព្រះជាតកជាច្រើន ដូចពុទ្ធបរិស័ទបានជ្រាបហើយ ។

ពិតណាស់ **ជម្ពូទ្វីបនេះ** ដែលមានទំហំ ១ **ម៉ឺនយោជន៍** តែផ្ទៃដីដែលគ្របដណ្តប់ទៅដោយទឹក មានរហូតដល់ទៅ ៤ **ពាន់យោជន៍**, ៣ **ពាន់យោជន៍** ជាទឹកដីនៃព្រៃហិមពាន្ត ៣ **ពាន់យោជន៍ទៀត** សម្រាប់មនុស្សរស់នៅ ។ ជួរភ្នំហិមពាន្ត គឺជាជួរភ្នំដ៏វែងអន្លាយ បត់បែនដាច់កន្ទុយភ្នែក ដែលមានកម្ពស់ **១៥០ យោជន៍** ប្រដាប់ដោយកំពូល **៨ ម៉ឺន**

៤ ពាន់កំពូល ដ៏ស្រស់ស្អាត លម្អដោយ ស៊ីង ៥០០ ខ្សែ ហួរជុំវិញ មានស្រះធំ ៧ គឺ អនោតត្តស្រះ ១ កណ្ណមុណ្ឌស្រះ ១ រថការស្រះ ១ ឆទ្ទន្តស្រះ ១ កុណាលស្រះ ១ មន្ទាកិនីស្រះ ១ សីហប្បាទស្រះ ១ ។ ស្រះទាំងនោះ បណ្តោយ ទទឹង និងជម្រៅ ៥០ យោជន៍ បរិមាត្រ ២៥០ យោជន៍ ។ បណ្តាស្រះទាំង ៧ នោះ អនោតត្តស្រះ មានភ្នំ ៥ ព័ទ្ធជុំវិញ គឺ សុទស្សកូដ ចិត្រកូដ កាឡកូដ គន្ធមាទនកូដ កៃលាសកូដ ។ ក្នុងភ្នំ ៥ នោះ សុទស្សនកូដ ជាភ្នំមាស កម្ពស់ ២០០ យោជន៍ ខាងក្នុងកោងមានសណ្ឋានដូចចំពុះក្អែក បិទបាំងស្រះនោះឯង ។ ចិត្រកូដ ជាភ្នំរតនៈ កាឡកូដ ជាភ្នំពេជ្រ គន្ធមាទនកូដ ជាភ្នំមានកំពូលរាបស្មើល្អ ដេរដាសទៅដោយគន្ធជាតិ មានក្លិនប្រអូបទាំង ១០ គឺឈើឫសក្រអូប ឈើក្រមរក្រអូប ឈើសម្បកក្រអូប ឈើស្រាយក្រអូប ឈើរសក្រអូប ឈើស្លឹកប្រអូប ឈើផ្កាក្រអូប ឈើផ្លែក្រអូប ឈើដើមក្រអូប ដេរដាសទៅដោយឱសថច្រើនប្រការ ថ្ងៃឧបោសថខាងរនោច នឹងមានពន្លឺ ដូចរងើកភ្លើង ។ កៃលាសកូដជាភ្នំប្រាក់ ជាទីអាស្រ័យនៅនៃពួកកិន្នរទាំងឡាយជាដើម ។

ភ្នំទាំងអស់ មានរាងកោងដូចចំពុះក្អែកព័ទ្ធជុំវិញស្រះ ហើយមានកម្ពស់ស្មើនឹងភ្នំសុទស្សនកូដដែរ ភ្នំទាំងនេះស្ថិតនៅបានដោយអានុភាពរបស់ទេវតា និងនាគ ។ ទឹកភ្លៀង និងទឹកជ្រោះដែលហូរពីលើភ្នំនេះ ធ្លាក់ចូលទៅក្នុងអនោតត្តស្រះតែមួយ ។ ព្រះចន្ទ និងព្រះអាទិត្យ គោចរទៅទិសខាងត្បូងខ្លះ ខាងជើងខ្លះ ចាំងពន្លឺទៅត្រង់ស្រះនោះ ដោយវាងភ្នំ មិនគោចរទៅត្រង់ៗ ដោយហេតុនោះឯង ទើបស្រះនោះឈ្មោះថា អនោតត្តៈ គឺមិនត្រូវពន្លឺថ្ងៃ ក្នុងអនោតត្តស្រះនោះ ធម្មជាតិបានរៀបចំទុកយ៉ាងល្អ មានជុំមនោសិលា និងហរតាល ប្រាសចាកអណ្តើក និងត្រី មានទឹកថ្លាច្រែង ដូចកែវផលិក មានកំពង់រាបស្មើ ដែលជាទីស្រពស្រង់របស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្តខីណាស្រព និងពួកឥសីដែលមានឫទ្ធិ ទាំងពួងទេវតា និងយក្ខក៏មកលេងទឹកនោះដូចគ្នា ជុំវិញអនោតត្តស្រះនោះ មានប្រកផ្លូវ ៤ គឺផ្លូវរាជសីហ៍ ផ្លូវសេះ ផ្លូវគោឧសភៈ ដែលជាផ្លូវហូរនៃស្ទឹង ៤ ខ្សែ ។ ហ្វូងរាជសីហ៍មានច្រើន នៅតាមមាត់ច្រាំងស្ទឹងដែលហូរចេញអំពីផ្លូវរាជសីហ៍ មានហ្វូងដំរី ហ្វូងសេះ ហ្វូងគោច្រើន តាមមាត់

ប្រាំងស្ទឹងដែលហូរចេញតាមផ្លូវដំរីជាដើម ។ ស្ទឹងដែលហូរចេញទៅកាន់ទិសខាងកើត ព័ទ្ធស្តាំជុំវិញអនោតត្តស្រះ ៣ ផ្នត់ មិនជួបជាមួយស្ទឹងដទៃ ៣ ខ្សែ ហូរកាត់ទឹកដីអមនុស្ស តាមភ្នំហិមពាន្ត នាទិសខាងកើត ចុះកាន់មហាសមុទ្រ ។ ឯស្ទឹងដែលហូរចេញអំពីទិសខាងត្បូង បត់ខាងស្តាំអនោតត្តស្រះនោះ ៣ផ្នត់ ហូរត្រង់ទៅទិសខាងត្បូង ៦០ យោជន៍ ខាងក្រោយផែនថ្មនោះឯង ទម្លុះភ្នំចេញមក មានក្រសែទឹកប្រមាណ ៣០ គាវុត ព័ទ្ធទុក ធ្លងអាកាសគង្គា ៦០ យោជន៍ ទៅធ្លាក់ចុះលើផែនថ្មឈ្មោះ តិយគ្គឡ ផែនថ្មក៏បែកដោយកម្លាំងនៃក្រសែទឹក ទីដែលផែនថ្មឈ្មោះតិយគ្គឡបែកនោះ ក៏កើតជាស្រះបោក្ខរណី ឈ្មោះតិយគ្គឡា ប្រមាណ ៥០ យោជន៍ ក្រសែទឹកទម្លុះប្រាំងស្រះបោក្ខរណី ទម្លុះថ្មទៅ ៦០ យោជន៍ បន្ទាប់អំពីនោះ ក៏ទម្លុះផែនដីទៅ ៦០ យោជន៍ ក្លាយជាឧម្មង្គទន្លិចនឹងតិរច្ឆានបពិត ឈ្មោះវិជ្ឈ ទៅជាក្រសែទឹក ៥ ខ្សែ ដូចគ្នានឹងម្រាមដៃទាំង ៥ ខ្សែទឹកនោះ ដែលហូរបត់ទៅស្តាំអនោតត្តស្រះ ៣ ផ្នត់ ហៅថា អាវដ្តគង្គា ក្នុងទីដែលហូរត្រង់ទៅ ៦០ យោជន៍ លើខ្នងថ្ម

ហៅថា **កណ្ណគង្គា** ក្នុងទីដែលហូរទៅ ៦០ យោជន៍ តាមអាកាស ហៅថា **អាកាសគង្គា** ដែលតាំងនៅក្នុងអាកាស ៦០ យោជន៍ ត្រង់ខ្នងថ្មឈ្មោះ តិយគ្គឡ ហៅថា **តិយគ្គឡបោក្ខរណី** ក្នុងទីដែលទម្លុះខ្នងស្រះ ធ្លុះថ្មទៅ ៦០ យោជន៍ ហៅថា **ពហលគង្គា** ។ ក្នុងទីដែលហូរទៅ ៦០ យោជន៍ តាមផ្លូវឧម្មង្គ ហៅថា **ឧម្មង្គាគង្គា** ឯក្នុងទីដែលទង្គិចនឹងតិរច្ឆានបព៌ត ឈ្មោះវិជ្ឈ បែកចេញជាក្រសែទឹក ៥ ខ្សែ ក្លាយជាស្ទឹង ៥ គឺ **គង្គា យមុនា អចិរវតី សរភូ មហី** មហានទី ៥ ខ្សែនេះ មានប្រភពកើតមកអំពីហិមវន្តបព៌ត ដោយប្រការដូច្នេះ ។ ទឹកដីនៃព្រៃហិមពាន្ត គឺជាទឹកដីបង្កប់ទៅដោយអាថ៌កំបាំងផ្សេងៗ មានដើមព្រីងប្រចាំទ្វីប និងសត្វចម្លែកៗ ដូចជានាគ រាជសីហ៍ហង្ស ឥន្ទ្រីយ៍ ចាមរី និងកិន្នរជាដើម ថែមទាំងមានសម្បត្តិធម្មជាតិប្លែកៗ ដូចជាអនោតត្តស្រះ ភ្នំកៃលាស និងអាកាសគង្គាជាដើម ដែលពាក្យទាំងនេះ ស្ទើរក្លាយទៅជាពាក្យសម្រាប់ពោលក្នុងរឿងព្រេងនិទានទៅហើយ ទឹកដីដ៏ស្រស់ត្រកាលនេះ ជាទីពួនសម្ងំ ជាទីស្វែងរកតបធម៌ និងជាកន្លែងព្រះបច្ចេកពុទ្ធ ឥសី ឬកុលបុត្តអ្នកត្រូវការមោក្ខធម៌ដោយប្រការដូច្នេះជាដើម ៕៚

# ១៥–ភ្នំអាជិន្តា

ភ្នំអាជិន្តា កសាងឡើង នៅក្នុងពុទ្ធសករាជ ៣០០ មានគុហាទាំងអស់ ២៩ ដែលទាក់ទងនឹងព្រះពុទ្ធសាសនា ពណ៌នាអំពីពុទ្ធប្បវត្តិ ឬរឿងរ៉ាវដែលទាក់ទងនឹងព្រះជាតកផ្សេងៗ ដើម្បីជាការបូជាចំពោះព្រះរតនត្រ័យ ក៏ដូចជាការប្រកាសខ្លួនប្រាប់ពុទ្ធបរិស័ទឲ្យបានដឹងថា ព្រះពុទ្ធសាសនា គឺជាសាសនាដ៏ប្រសើរ សមគួរដល់ពុទ្ធបរិស័ទ ធ្វើសក្ការគោរពបូជា ទោះបីព្រះអង្គរំលត់ខន្ធបរិនិព្វានទៅហើយក៏ដោយ ប៉ុន្តែព្រះគុណរបស់ព្រះពុទ្ធអង្គ សមគួរដល់ពុទ្ធបរិស័ទគោរពបូជា ព្រោះការគោរពបូជានេះហើយ ជាឧបនិស្ស័យនៃព្រះអរិយបុគ្គល ព្រោះថា ព្រះអរិយបុគ្គលដែលបានត្រាស់ដឹងនូវសច្ចធម៌ មិនមែនបានមកអំពីណាទេ គឺបានមកអំពីការគោរពបូជាចំពោះព្រះគុណរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ អគ្គសាវកពុទ្ធ និងអសីតិមហាសាវក ឬចំពោះបុគ្គលដែលជាអ្នកទ្រទ្រង់នូវគុណធម៌ផ្សេងៗ មានមេត្តា ករុណាជាដើម អាស្រ័យដូចហេតុដែលបានពណ៌នាមកនេះ សូមឲ្យពុទ្ធមាមិកជនទាំងអស់ តាំងចិត្តបដិបត្តិចំពោះ

ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលព្រះមានជោគ បានត្រាស់រួចមក ហើយ រយៈពេល ៤៥ ព្រះវស្សា ដោយអាស្រ័យព្រះបារមី ដែលបាន សន្សំមក ២០ អសង្ខេយ្យមួយសែនកប្ប (គិតក្នុងព្រះទ័យ ៧ អសង្ខេយ្យ, បញ្ចេញវាចា ៩ អសង្ខេយ្យ, ទទួលការព្យាករណ៍ ៤ អសង្ខេយ្យ ១ សែនកប្ប) ទើបបានព្រះធម៌ដែលជាសការៈសម្តែងអំពីការពិតនៃជីវិត របស់ពុទ្ធបរិស័ទ ឲ្យបានយល់ទៅតាមសច្ចធម៌ ក៏ដូចជាការចង្អុលបង្ហាញ អំពីផ្លូវដើរចេញអំពីសេចក្តីទុក្ខ ឬក៏ជាការប្រាប់ឲ្យបានដឹងថា សេចក្តីល្អ ដែលយើងបានធ្វើហើយនឹងជួយឲ្យយើងបានដល់ទីបំផុតទុក្ខ បើមិនទាន់ ដល់ទីបំផុតទុក្ខទេ សេចក្តីល្អដែលកើតឡើងអំពីការបដិបត្តិ ឬការគោរព បូជានោះ នឹងជួយរៀបចំដំណើរជីវិតរបស់ពុទ្ធបរិស័ទឲ្យជួបប្រទះនូវ សេចក្តីសុខ និងសេចក្តីចម្រើនទៀតផង ៕

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៥

**ដោយប្រធានសមាគមធម្មទានអរិយទ្រព្យចំស្វាគ**

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានតំរុយន៍ជាដើម ក្នុងកិច្ចការខាងធម្មទាន

❋ ឧបាសិកា ហម យិម

ឧបាសក អ៊ុឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ុឹង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូជម្ទាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ុឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទថូ(LAURA)+បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដាទេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុធា (ហៅអាហួយ)

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន យឹម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

✵ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមប៉ៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងងិម និងស្វាមី ព្រមទាំងកូនចៅ

✵ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

✵ឧបាសក ឡាំ ជៀន ឧបាសិកា សឺន បន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដារណ្ណ ឧបាសិកា ឡាំ ចាន់វ៉ារី

✵ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ួន ព្រមទាំងបុត្រ

ញោម ឥទ្ធន្ទីនិងធូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា នា ញោម ឆាង ញោម ជឹង ឡេង ញោម អៀម ញោម ភួង ញោម អុំកា ញោម សុភា ញោម វល័ក្ខ ញោម ឆាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម ភាព សាវឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុនសេរី

លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ឹង ហេ្គចឡេង ឧបាសិកា តាំង ប៉េជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ុ ទី អ្នកស្រី តាំង ប៉េគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាងនិងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុកនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អឿន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ី ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ថៃ អេង+គឹម ជី+ខៀវ វ៉ន+ គឹម

ញោម នឿង+យាយ ធីង+គួង កាង+សើន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ រ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាក់ឡែន+ ហ៊ុង+ ថៃ ង៉ា+ រី រុន្ធ

ញោមអ្នកគ្រូ រ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោរ អ៊ុំ វីរៈ

ញោមថៃ ង៉ាច្នុគោល+អ្នកស្រី លេង យ៉ុង+គី លី+នាង ឈៀត

ញោម ហ៊ុង+នាង មឿន+អូនប៉ុច+ ឡាត រ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+តាំង វេន+ យុន+ យាយ ធុច + យាយ យន
ញោម ហ៊ិន ស៊ិម ញោម អឿន ភី+រ៉ាន់ ស៊ុនឡាយ+ផល្លី+សរ៉ាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី
ញោម ណេ ហ្គេចណៃ+រ៉ាន់ សុផានី+សា រឿន+សំ គី+ចាន់ ណារ៉ា
ញោម ធារ៉ា+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ រ៉ាន់នី+ គឹម អ៊ី
ញោម អៀប សាននួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

# នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

ឧបាសិកា ធីក ស្រ៊ន ព្រមទាំងកូនប្រុស អ៊ីង រិទ្ធី និងភរិយា

ឧបាសក ប៊ូហោ នាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យេម សំណាង ឧបាសិកា យេម ឡរ៉ា ព្រមទាំងបុត្រ

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ

ឧបាសក ឈៀងសារឿន ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ធាន់ កាន់ជួង ព្រមទាំងបុត្រ

ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ

ឧបាសិកា ម៉ី ចាន់រ៉ាវី ព្រមទាំងបុត្រធីតា

ឧបាសិកា យ៉ក់ ស៊ីមូរ៉ា ព្រមទាំងបុត្រ

ឧបាសិកា វ៉ាន់ចាន់ ព្រមទាំងបុត្រធីតា

ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រធីតា

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គឹមសែ កូន+ចៅ
ឧបាសិកា យូ ស៊ាងនទួលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

| | |
|---|---|
| ឧបាសក ប៊ុន ហេង | ឧបាសិកា ជុំ សុខុម |
| ឧបាសិកា ហេង ស្រីជា | ឧបាសិកា ហេង ស្រីចន្ទ |
| ឧបាសិកា ហេង គង្គា | ឧបាសក ហេង សុកត្រ័ |

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គឹមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ
ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន

ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ
ឧបាសក រៀម ឈឺន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ
ឧបាសក ញ៉ែម មឿន ឧបាសិកា រៀម ថុល ព្រមទាំងកូនចៅ
ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ
ឧបាសក នាង រ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ
ឧបាសក សៅ ស៊ុន្ទរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ
ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ
ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ
ឧបាសិកា សោម គឹមលឿម និងស្វាមី ព្រមទាំងកូនចៅ
ឧបាសិកា គីម ធវី និងស្វាមី ព្រមទាំងកូនចៅ
ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ុម គឹមជីវ
ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី
ឧបាសិកា ហួត អេង ឧបាសិកា ឡោ សាយហ៊ួច
ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ
ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ
ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ
ឧបាសិកា សឿង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងកូនចៅ

លោក លី ហុង លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន លោកស្រី ជា ណាវី ព្រមទាំងបុត្រ ធីតា

លោក លឹម ចាន់ឌី លោកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា និងភរិយា លឹម ចាន់មុនីរ័ត្ន

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

យុវជន ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអូន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គឹមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ាន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា លោកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័គ លោកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

លោក ឈើន សាគីម លោកស្រី ខឹម អូន ព្រមទាំងបុត្រ ធីតា

លោក រស់ ប៊ុនឡេង លោកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀវ នីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

លោកស្រី ផុន បូណ៌ាមី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ធា ព្រមទាំងកូនក្មួយ

ឧបាសិកា គីម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និង កុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជឹ សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជឹ ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ុំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី បួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ារិទ្ធ លោកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា លីម ម៉ាលី (គីម ហ៊ួយ) និងស្វាមី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ស៊ិន ឡាច ព្រមទាំងក្រុមគ្រួសារ

ឧបាសក ប៊ុន បួន ឧបាសិកា យុត សួគ៌ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុគី និង ប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឺន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី និង អ្នកស្រី អ៊ួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត លោកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន លោកស្រី ម៉ម សុធា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ លោកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេង វណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គីមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា ឈឹន សង់ ព្រមទាំងកូនចៅ

លោក ឈឹន ចំរើន លោកស្រី ហោ វាសនា ព្រមទាំងបុត្រធីតា

ឧបាសិកា ប៉េ សារ៉ា(ម្ដាយ) ឧបាសក ម៉ុី ធារី

ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ង៉ួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូច សាមុត ព្រមទាំងកូនចៅ

ឧបាសិកា មាស អួន ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

អ្នកគ្រូ ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសក ធឹង ផាត់ ឧបាសិកា ណុប សៀងហេង ព្រមទាំងកូនចៅ

លោក អ៊ិត សារឿន លោកស្រី ញ៉ឹក សោភ័ណ ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុធី +បុត្រ ហែម តុលា

# នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទរួមមានឧបការៈក្នុងការចារធម្មទាន

១- ឧបាសិកា ប៉េង តាំង ឧបាសិកា ហ៊ូ គឹមងៀក

២- ឧបាសក ស្រេង ស្រ៊ាង ឧបាសិកា គិម ចន្ទា

៣- ឧបាសក ឡាយ សុខុម ឧបាសិកា គី គឹមហាប់

៤- ឧបាសិកា បួ ម៉ាឡា កញ្ញា បួ ដាវី

៥- ឧបាសិកា ង៉ែង យូអេង កញ្ញា អ៊ុង មុយហៀក

៦- ឧបាសក លឹម ខូង ឧបាសិកា កែវ អុន

៧- ឧបាសិកា កែវ កល្យាណ ឧបាសិកា សុខ សុទ្ធី

៨- ឧបាសិកា សឹន ចន្ទា លោក ឡាំ ដាវណ្ណ

៩- ឧបាសិកា គួ ប៊ុនគាង ឧបាសិកា ឈុំ សុធា

១០- ឧបាសិកា នេត្រ នរិន្ទ ឧបាសិកា ទន់

១១-ឧបាសិកា ឱម លក្ខណា ឧបាសិកា ហេង ច័ន្ទបុញ្ញវត្តី

១២-ឧបាសិកា គី យក់បួយ ឧបាសិកា ឈុន ណាត

១៣-ឧបាសិកា អ៊ុង រិទ្ធារី ឧបាសក អ៊ុន សេរី

១៤-ឧបាសិកា វៀម ថុល ឧបាសិកា ម៉ៅ នី

១៥-ឧបាសិកា សន ឈៀត ឧបាសក ឡាន សុខុម

១៦-ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ប៉ាន ណាម

១៧-ឧបាសិកា សួន កល្យាណ ឧបាសិកា ភយង់ ភក្តី

១៨-ឧបាសក អ៊ឹង វ៉ៃយ៉ា ឧបាសក កុយ សាមន

១៩-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ៉េត

## តម្លៃបោះពុម្ពក្នុង ១ ក្បាល ៥ $

ខ្ញុំព្រះករុណា អាត្មាភាពមានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០១២ ៣០៥ ៧៦៦, ០៨៨៨ ៧៧ ៩៩ ៦៦ ០៧៧ ៦៦ ៦៦ ៣៨ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសក** មាន ៥ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៥ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយ

*សព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។*

***-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ*** *សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។*

***-វិសុទ្ធិមគ្គ*** *និង* ***បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស*** *សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេចដែរ ដែលមាន ៣ ភាគ ។*

***-គម្ពីរសារត្ថសង្គហៈ*** *ហើយសព្វថ្ងៃនេះ បានធ្វើរួចជាស្ថាពរ គឺវាយកុំព្យូទ័ររួចជាស្រេចអស់ហើយទាំង ២ ភាគ ដែលមានកម្រាស់ រហូតទៅដល់ ៦០០ ទំព័រជាង ។*

***-គម្ពីរអភិធម្មត្ថសង្គហៈ*** *និង* ***វិភាវិនីដីកា*** *សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។*

***-អភិធម្មត្ថសង្គហៈ*** *និង* ***បរមត្ថទីបនីដីកា*** *សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់*

រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-**គម្ពីរអភិធម្មាវតា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-**មិលិន្ទបញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-**រឿងរ៉ាវដែលទាកទង់ នឹងពុទ្ធស្ថាន** បានធ្វើសម្រេចជាស្ថាពរហើយ ដែលមានចំនួន ៥ ភាគ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦០០-៧០០ ទំព័រជាងក៏មាន ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើ **គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា** បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៨ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះសព្វថ្ងៃនេះ បានចំនួន ៦១ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
# ខ្ញុំព្រះករុណា អាត្មាភាព
# ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មួយភាគ ១

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ១

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

# នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិច្ចាគប្រាក់ជួយបោះពុម្ពសៀវភៅនេះ

| | |
|---|---|
| លោកគ្រូធម្មបណ្ឌិត អៀ សៅ ................................... | ៥០០ $ |
| ឧបាសក អៀប ហៃសាន និងភរិយា ព្រមទាំងបុត្រ<br>ឧបសិកា ឡឹក ពេញចិត្ត និងស្វាមី ព្រមទាំងបុត្រ | ៥០០ $ |
| ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ុង រិទ្ធារី+បុត្រ ............ | ១០០ $ |
| ឧបាសក សៅ ហ៊ាន ឧបាសិកា មាស ម៉ូនីកា+បុត្រ ......... | ១០០ $ |
| ឧបាសក ឆេង សារឿន ឧបាសិកា ជុំ លាភ+បុត្រ .......... | ១០០ $ |
| ឧបាសក វង់ ម៉ៅ ឧបាសិកា ឆាន់ កាន់ជួង+បុត្រ ............ | ១០០ $ |
| ឧបាសក អៀម វ៉ៃ ឧបាសិកា សុខ សៅរិទ+បុត្រ .......... | ៥០ $ |
| ឧបាសក សំណាង យឹម ឧបាសិកា យ៉េម ឡូរ៉ា+បុត្រ ..... | ៥០ $ |
| ឧបាសិកា តាំង ហុង ព្រមទាំងបុត្រ .......................... | ៥០ $ |
| ឧបាសក ម៉ាក់ អ៊ុយ .................................................. | ៥០ $ |
| ឧបាសិកា ទូច គឹមអេង ព្រមទាំងបុត្រ ........................ | ៥០ $ |
| ឧបាសិកា ជិម អុល ព្រមទាំងកូនចៅ .......................... | ៣៥ $ |

*ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ ....................... ២៥ $*

*ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ+បុត្រ .. ២៥ $*

*ឧបាសិកា សុខ ឡាង ................................................ ១០ $*

**បោះពុម្ពជាធម្មទាន**

**ក្នុងតម្លៃ ១ ក្បាល ៥ ដុល្លារ**

**អេចពុម្ព រមណីយ**

TEL : 012597431

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត